# រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍
# ស្ដីពីវឌ្ឍនភាពនៃការអនុវត្ត
# គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា
# ឆ្នាំ ២០១៥-២០២៥

ក្នុងឆ្នាំ២០១៧-២០១៨

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី**
**ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃសុក្រ ១០រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤**
**ត្រូវនឹងថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០**

# មាតិកា


បញ្ជីពាក្យកាត់ ........................................ i

ខ្លឹមសារសង្ខេបប្រតិបត្តិ ........................................ vii

១. សេចក្ដីផ្ដើម ........................................ ១

២. វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ ........................................ ២

  ២.១. បច្ចុប្បន្នភាពនៃសូចនាករសម្រាប់គោលដៅទាំង៣ ........................................ ២

  ២.២. វឌ្ឍនភាពនៃការអនុវត្តវិធានការគន្លឹះបួនជាក់ស្ដែង គិតត្រឹមដំណាច់ឆ្នាំ២០១៨ ........................................ ៥

    ២.២.១- វិធានការទី១ ........................................ ៥

    ២.២.២- វិធានការទី២ ........................................ ៧

    ២.២.៣- វិធានការទី៣ ........................................ ៩

    ២.២.៤- វិធានការទី៤ ........................................ ១១

  ២.៣. វឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ និងផែនការសកម្មភាព ក្នុងឆ្នាំ២០១៧-២០១៨ . ១២

    ២.៣.១. ការជំរុញការទាក់ទាញវិនិយោគ ........................................ ១២

    ២.៣.២. ការពង្រីក និងទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម ........................................ ២៤

    ២.៣.៣. ការកែលម្អបរិស្ថាននិយ័តកម្ម ........................................ ៣២

    ២.៣.៤. ការសម្របសម្រួលគោលនយោបាយគាំទ្រ ........................................ ៣៧

    ២.៣.៥. ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា ........................................ ៥០

៣. បញ្ហាប្រឈម និងហានិភ័យនៃការអនុវត្តគោលនយោបាយ ........................................ ៥៣

៤. សេចក្ដីសន្និដ្ឋាន ........................................ ៥៤

ឧបសម្ព័ន្ធទី១ : ឧបសម្ព័ន្ធ “គ”: ម៉ាទ្រីសអំពីវិធានការគន្លឹះបួនជាក់ស្ដែង ដើម្បីជំរុញ “គោលនយោបាយអភិវឌ្ឍន៍វិស័យ ឧស្សាហកម្ម”

ឧបសម្ព័ន្ធទី២ : ឧបសម្ព័ន្ធ “ឃ”: ម៉ាទ្រីសនៃវិធានការគោលនយោបាយ និងផែនការសកម្មភាព

# បញ្ជីពាក្យកាត់

## បញ្ជីពាក្យកាត់ជាភាសាខ្មែរ

| | |
|---|---|
| ក.អ.ក | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| គ.ជ.នា | គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា |
| គ.ផ.ក | គណៈកម្មាធិការផលិតភាពកម្ពុជា |
| គ.ម | គីឡូម៉ែត្រ |
| ផ.យ.អ.ជ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ផ.ស.ស | ផលិតផលក្នុងស្រុកសរុប |
| ម | ម៉ែត្រ |
| ម២ | ម៉ែត្រការ៉េ |
| ម៣ | ម៉ែត្រគូប |
| ស.ម | សង់ទីម៉ែត្រ |
| ហ.ត | ហិកតា |

## បញ្ជីពាក្យកាត់សំខាន់ៗជាភាសាបរទេស

| | | |
|---|---|---|
| ACCU | Air Cargo Control Unit | ការិយាល័យអង្គភាពត្រួតពិនិត្យទំនិញតាមផ្លូវអាកាស |
| ACTS | ASEAN Customs Transit System | ប្រព័ន្ធឆ្លងកាត់គយអាស៊ាន |
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFD | Agence Française de Développement | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| AGT | Automated Guideway Transit | ផ្លូវរថភ្លើងស្វ័យប្រវត្តិលើអាកាស |
| AHKFTA | ASEAN-Hong Kong, China Free Trade Agreement | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង |
| AHKIA | ASEAN-Hong Kong, China Investment Agreement | កិច្ចព្រមព្រៀងវិនិយោគអាស៊ាន-ហុងកុង |

| | | |
|---|---|---|
| AI | Artificial Intelligence | បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត |
| AIIB | Asian Infrastructure Investment Bank | ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី |
| AIMS | Accelerating Inclusive Markets for Smallholders | គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច |
| AJCEP | ASEAN-Japan Comprehensive Economic Partnership | កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយ អាស៊ាន-ជប៉ុន |
| APO | Asia Productivity Organization | អង្គការផលិតភាពអាស៊ី |
| AQRF | Asean Qualifications Reference Framework | ក្របខ័ណ្ឌគុណវុឌ្ឍិយោងអាស៊ាន |
| AQSIQ | General Administration of Quality Supervision, Inspection and Quarantine | អគ្គរដ្ឋបាលត្រួតពិនិត្យគុណភាពអធិការកិច្ច និង ចត្តាឡីស័ក្ត |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| ASYCUDA | Automated System for Customs Data | ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ |
| ATM | Automated Teller Machine | ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ |
| BFC | Better Factories Cambodia | គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា |
| C/O | Certificate of Origin | វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ |
| CBT | Capacity-based Training | ការបណ្តុះបណ្តាលផ្អែកលើសមត្ថភាព |
| CBTA | Cross Border Transport Agreement | កិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន |
| CCU | Container Control Unit | ការិយាល័យអង្គភាពត្រួតពិនិត្យកុងទែន័រ |
| CDC | Council for the Development of Cambodia | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CLMV | Cambodia-Laos-Myanmar-Vietnam | កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម |
| CMT | Cut Make and Trim | កាត់ ដេរ និងតម្រឹម |
| CPPM | Customs-Private Sector Partnership Mechanism | យន្តការភាពជាដៃគូគយ-ផ្នែកឯកជន |
| CQF | Cambodia Qualification Framework | ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា |

| | | |
|---|---|---|
| CRMDS | Customs Risk Management Database System | ប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យគយ |
| CVSS | Customs Valuation Support System | ប្រព័ន្ធទ្រទ្រង់តម្លៃគិតពន្ធគយ |
| DMC | Data Management Centre | មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ |
| EDC | Electricite Du Cambodge | អគ្គិសនីកម្ពុជា |
| EDCF | Korea Economic Development Cooperation Fund | មូលនិធិសហប្រតិបត្តិការអភិវឌ្ឍសេដ្ឋកិច្ចកូរ៉េ |
| EMF | Export Management Fee | កម្រៃគ្រប់គ្រងការនាំចេញ |
| ERIA | Economic Research Institute for ASEAN and East Asia | វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាននិងអាស៊ីបូព៌ា |
| ESIA | Environmental and Social Impact Assessment | របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម |
| FAQs | Frequently Asked Questions | សំណួរចម្លើយដែលសួរញឹកញាប់ |
| GAP | Good Agricultural Practice | ការអនុវត្តកសិកម្មល្អ |
| GHP | Good Hygienic Practice | ការអនុវត្តអនាម័យល្អ |
| GIZ | Deutschen Gesellschaft für Internationale Zusammenarbeit | ទីភ្នាក់ងារអភិវឌ្ឍន៍អាល្លឺម៉ង់ |
| GMP | Good Manufacturing Practice | ការអនុវត្តផលិតកម្មល្អ |
| GMS | Greater Mekong Subregion | មហាអនុតំបន់មេគង្គ |
| ICAO | International Civil Aviation Organization | អង្គការអាកាសចរស៊ីវិលអន្តរជាតិ |
| ICD | Inland Container Depot | ទីលានស្តុកទំនិញ និងកុងតឺន័រ |
| ICT | Information and Communications Technology | បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន |
| IDP | Cambodia Industrial Development Policy | គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា |
| IESIA | Initial Environmental and Social Impact Assessment | របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមបឋម |

| | | |
|---|---|---|
| IFAD | International Fund for Agricultural Development | មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម |
| IFC | International Finance Corporation | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| ILO | International Labor Organization | អង្គការអន្តរជាតិខាងការងារ |
| IMF | International Monetary Fund | អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ |
| IMO | International Maritime Organization | អង្គការសមុទ្រអន្តរជាតិ |
| IT | Information Technology | បច្ចេកវិទ្យាព័ត៌មាន |
| ITC | Institute of Technology of Cambodia | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា |
| JAIF | Japan-ASEAN Integration Fund | មូលនិធិជប៉ុនអាស៊ាន |
| JBAC | Japanese Business Association of Cambodia | សមាគមធុរកិច្ចជប៉ុននៅកម្ពុជា |
| JICA | Japan International Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| KOSHA | Korea Occupational Safety and Health Agency | ទីភ្នាក់ងារសុខភាព និងសុវត្ថិភាពការងារកូរ៉េ |
| kV | kilovolt | គីឡូវ៉ុល |
| MCT | Malaysia-Cambodia-Thailand | ម៉ាឡេស៊ី កម្ពុជា និងថៃ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MIH | Ministry of Industry and Handicraft | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| MoSVY | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MOU | Memorandum of Understanding | អនុស្សារណៈនៃការយោគយល់គ្នា |
| MRA | Mutual Recognition Agreement | កិច្ចព្រមព្រៀងទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក |
| MRS | Mutual Recognition of Skills | ការទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក |
| NAWI | Non-automatic Weighing Instrument | ជញ្ជីងមិនស្វ័យប្រវត្តិ |

| | | |
|---|---|---|
| NPCC | National Productivity Center of Cambodia | មជ្ឈមណ្ឌលផលិតភាពជាតិកម្ពុជា |
| NTTI | National Technical Training Institute | វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស |
| PCP | Programme for Country Partnership | កម្មវិធីកិច្ចសហប្រតិបត្តិការភាពជាដៃគូរបស់ប្រទេស |
| PCT | Patent Cooperation Treaty | សន្ធិសញ្ញាប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម |
| PES | Payment Ecosystem Services | ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី |
| PISA-D | Programme for International Student Assessment for Development | កម្មវិធីតេស្តវាយតម្លៃលទ្ធផលសិក្សាកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ |
| Port EDI | Port Electronic Data Interchange System | ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យកំពង់ផែ |
| PPAP | Phnom Penh Autonomous Port | កំពង់ផែស្វយ័តភ្នំពេញ |
| PPP | Public-Private Partnership | ភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន |
| RCC | Recognition of Current Competency | ការទទួលស្គាល់សមត្ថភាពបច្ចុប្បន្ន |
| RCEP | Regional Comprehensive Economic Partnership | ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ |
| ReCAAP ISC | Regional Cooperation Agreement on Combating Piracy and Armed Robbery against Ships in Asia Information Sharing Center | កិច្ចព្រមព្រៀងតំបន់ស្តីពីការប្រយុទ្ធប្រឆាំងនឹងចោរសមុទ្រ និងការប្លន់ប្រដាប់អាវុធប្រឆាំងនឹងនាវានៅអាស៊ី |
| RPL | Recognition of Prior Learning | កម្មវិធីទទួលស្គាល់ការសិក្សាពីមុន |
| RTGS | Real-Time Gross Settlement | ប្រព័ន្ធទូទាត់ដុលភ្លាមៗ |
| SAD | Single Administrative Document | ប្រតិវេទន៍គយ |
| SEZ | Special Economic Zone | តំបន់សេដ្ឋកិច្ចពិសេស |
| SMAS | School Management System | ប្រព័ន្ធគ្រប់គ្រងសាលារៀន |
| SME | Small and Medium Enterprises | សហគ្រាសធុនតូច និងមធ្យម |

| | | |
|---|---|---|
| SSI | Single Stop Inspection | ការត្រួតពិនិត្យទំនិញតែម្តងនៅទីលានបញ្ចេញទំនិញនៅមាត់ច្រក |
| STEAM | Science, Technology, Engineering, Arts and Math | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា |
| STEM | Science, Technology, Engineering and Math | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា |
| TC | Telecom Cambodia | ទូរគមនាគមន៍កម្ពុជា |
| TCMS | Trade Credibility Management System | ប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន |
| TEU | Twenty-foot Equivalent Unit | ខ្នាតកុងតឺន័រម្ភៃហ្វីត |
| TF-ATISA | Special Task Force on ASEAN Trade in Services Agreement | កិច្ចប្រជុំក្រុមការងារពិសេសស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាន |
| TFP | Total Factor Productivity | ផលិតភាពជាតិសរុប |
| TRS | Time Release Study | ការសិក្សារយៈពេលបញ្ចេញទំនិញពីគយ |
| TVET | Technical and Vocational Education and Training | អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNIDO | United Nations Industrial Development Organization | អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម |
| USAID | United States Agency for International Development | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| WB | World Bank | ធនាគារពិភពលោក |
| WIPO | World Intellectual Property Organization | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក |

# ខ្លឹមសារសង្ខេបប្រតិបត្តិ

១. រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភាសម្រេចបានវឌ្ឍនភាពយ៉ាងធំធេងក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ ទន្ទឹមនឹងការធានាបាននូវសន្តិភាពនិងសន្តិសុខទូទាំងប្រទេស, ស្ថិរភាពនយោបាយ, ការរក្សាបានកំណើនប្រកបដោយចីរភាពនិងធន់នឹងវិបត្តិ, ការកាត់បន្ថយភាពក្រីក្រ, ការបង្កើតការងារជូនប្រជាជន និងការពង្រឹងសមត្ថភាពស្ថាប័នសាធារណៈ តាមរយៈការដាក់ឱ្យអនុវត្តនិងកែលម្អជាបន្តបន្ទាប់នូវក្របខ័ណ្ឌគោលនយោបាយ ព្រមទាំងយន្តការសំខាន់ៗ ដើម្បីឈានទៅសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ក៏ដូចជាការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់៧% និងការសម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រឱ្យស្ថិតនៅក្រោម១០%។

២. ក្នុងន័យនេះ ដើម្បីរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាពនិងបរិយាបន្ន រាជរដ្ឋាភិបាលបានដាក់ចេញ និងកំពុងអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មីរបស់កម្ពុជា ផ្តោតសំខាន់លើការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព ស្របតាមបរិបទនៃការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និងសភាពការណ៍ប្រែប្រួលនៃភូមិសាស្ត្រនយោបាយ និងនិម្មាបនកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក។ គោលនយោបាយនេះ បានដាក់ចេញនូវយុទ្ធសាស្ត្រគន្លឹះ វិធានការ និងផែនការសកម្មភាព ដែលផ្សារភ្ជាប់ជាមួយគោលបំណងនិងគោលដៅដែលត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ២០២៥។ ក្នុងគោលបំណងធានាឱ្យបាននូវវឌ្ឍនភាពជាប្រចាំ ប្រកបដោយប្រសិទ្ធភាពនិងសង្គតិភាព រាជរដ្ឋាភិបាលបានសម្រេចឱ្យមានយន្តការតាមដាននិងត្រួតពិនិត្យការអនុវត្ត តាមរយៈការរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយនេះ។

៣. ការសម្រេចបាននូវរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ សម្រាប់ឆ្នាំ២០១៧-២០១៨ គឺជាសមិទ្ធផលទី២ ដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងនាមជាស្ថាប័នសម្របសម្រួលនិងជំរុញការអនុវត្តគោលនយោបាយនេះបានរៀបចំប្រមូលចងក្រង បន្ទាប់ពីរបាយការណ៍វឌ្ឍនភាពគិតត្រឹមខែធ្នូ ឆ្នាំ២០១៦ បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ក្នុងឆ្នាំ២០១៧-២០១៨ រាជរដ្ឋាភិបាល ដែលមានក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធជាសេនាធិការ បានបន្តអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ កាន់តែសកម្មខ្លាំងឡើង បន្ថែមពីលើសមិទ្ធផលដែលសម្រេចបានក្នុងឆ្នាំ២០១៦។ ជាលទ្ធផល សម្រាប់ឆ្នាំ២០១៧ និងឆ្នាំ២០១៨ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បាននិង

កំពុងបន្តអនុវត្តសកម្មភាពការងារដែលស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនតាមវិធានការគន្លឹះជាក់ស្តែង និងវិធានការគោលនយោបាយ/ផែនការសកម្មភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលសមិទ្ធផលជាក់ស្តែងទាំងនោះ ត្រូវបានរៀបចំនិងបង្ហាញជូននៅក្នុងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា សម្រាប់ឆ្នាំ២០១៧-២០១៨។ របាយការណ៍វឌ្ឍនភាពនេះ បានឆ្លុះបញ្ចាំងពីសមិទ្ធផលសំខាន់ៗក្នុងដំណើរឈានទៅសម្រេចបាននូវគោលដៅនៃគោលនយោបាយ ដែលគោលដៅទាំងនេះនឹងចូលរួមចំណែកជំរុញឱ្យកម្ពុជាឈានទៅសម្រេចបាននូវចក្ខុវិស័យប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

៤ ជាលទ្ធផលជាក់ស្តែងពាក់ព័ន្ធនឹងគោលដៅចម្បងទាំងបីនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បានដឹកនាំសម្របសម្រួល និង/ឬអនុវត្តវិធានការគោលនយោបាយ និងផែនការសកម្មភាពដែលខ្លួនទទួលខុសត្រូវដោយសម្រេចបានពេញលេញនិងមានវឌ្ឍនភាពសំខាន់ៗ ដូចខាងក្រោម÷

*គោលដៅទី១នៃគោលនយោបាយ គឺការកែប្រែនិងពង្រឹងរចនាសម្ព័ន្ធឧស្សាហកម្មក្នុងសេដ្ឋកិច្ចជាតិដោយបង្កើនអនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស ឱ្យបាន៣០% នៅឆ្នាំ២០២៥ ក្នុងនោះវិស័យកម្មន្តសាលត្រូវកើនដល់ ២០%។* ជាក់ស្តែង អនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស បានកើនឡើងពី ២៧,៧% នៅឆ្នាំ២០១៥ ដល់ ៣២,៦% នៅឆ្នាំ២០១៨ ពោលគឺសម្រេចបានមុនគោលដៅដែលបានកំណត់នៅឆ្នាំ២០២៥ (សូមមើលតារាងទី១)។ ដោយឡែក អនុបាតវិស័យកម្មន្តសាលក្នុង ផ.ស.ស បានកើនឡើងបន្តិចពី ១៦,០% នៅឆ្នាំ២០១៥ ដល់ ១៦,៣% នៅឆ្នាំ២០១៨ ដោយកំណើននេះមានលក្ខណៈយឺត បើធៀបនឹងគោលដៅឆ្នាំ២០២៥។ យ៉ាងណាក្តី តួលេខទាំងនេះអាចបង្ហាញថា កម្ពុជាកំពុងកែប្រែនិងបន្តពង្រឹងរចនាសម្ព័ន្ធឧស្សាហកម្មដោយងាកចេញជាបណ្តើរៗពីការពឹងផ្អែកសំខាន់លើវិស័យកសិកម្ម ឆ្ពោះទៅការធ្វើឧស្សាហូបនីយកម្មនៃមូលដ្ឋានសេដ្ឋកិច្ច ដែលនឹងពន្លឿនការអភិវឌ្ឍឱ្យឈានឆ្ពោះទៅដល់កម្រិតថ្មីមួយទៀត។

**តារាងទី១÷ ការបែងចែក ផ.ស.ស តាមវិស័យ**

| វិស័យ | ១៩៩៨ | ២០១៣ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | គោលដៅ ២០២០ | គោលដៅ ២០២៥ |
|---|---|---|---|---|---|---|---|---|
| កសិកម្ម | ៤៤,៥% | ៣១,៦% | ២៦,៦% | ២៤,៧% | ២៣,៤% | ២២,២% | ២៥% | ២៣% |
| ឧស្សាហកម្ម | ១៦,៧% | ២៤,១% | ២៧,៧% | ២៩,៥% | ៣០,៩% | ៣២,៦% | ២៨% | ៣០% |
| *- កម្មន្តសាល* | *១២,៧%* | *១៥,៥%* | *១៦,០%* | *១៦,០%* | *១៦,២%* | *១៦,៣%* | *១៨%* | *២០%* |
| សេវាកម្ម | ៣៤,៨% | ៣៨,៥% | ៣៩,៨% | ៣៩,៩% | ៣៩,៧% | ៣៩,៣% | ៤០% | ៤០% |
| ឧបត្ថម្ភធនទុននិងពន្ធ | ៤% | ៥,៨% | ៥,៩% | ៥,៩% | ៦,១% | ៦,០% | ៧% | ៧% |

*កំណត់សម្គាល់÷ ទិន្នន័យចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ទទួលបានពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

*គោលដៅទី២ នៃគោលនយោបាយ គឺការបង្កើននិងពិពិធកម្មមុខទំនិញនាំចេញ ដោយបង្កើនការនាំចេញទំនិញកម្មន្តសាល (មិនមែនវាយនភណ្ឌ) ឱ្យបាន១៥% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥ ទន្ទឹមនឹងការជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឱ្យបាន១២% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥។* ជាក់ស្តែង ចំណែកនៃការនាំចេញសម្លៀកបំពាក់និងស្បែកជើងមានការថយចុះជាលំដាប់ពី៧១,៦% នៃបរិមាណនាំចេញសរុប នៅឆ្នាំ២០១៥ មកត្រឹម៦៩,២% នៅឆ្នាំ២០១៨។ ដោយឡែក ការនាំចេញទំនិញកម្មន្តសាលមិនមែនសម្លៀកបំពាក់និងស្បែកជើង មានកំណើនគួរឱ្យកត់សម្គាល់ពី៥,៦% នៃបរិមាណនាំចេញសរុប នៅឆ្នាំ២០១៥ ដល់ ១៣,៣% នៅឆ្នាំ២០១៨ ពោលគឺសម្រេចបានប្រមាណ៨៨,៦% បើធៀបនឹងគោលដៅឆ្នាំ២០២៥ (សូមមើលតារាងទី២)។ ទន្ទឹមនឹងនេះ ការនាំចេញកសិផលកែច្នៃ ក៏មានការកើនឡើងពី៥,៩% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០១៥ ដល់៧,០% នៅឆ្នាំ២០១៨ ពោលគឺសម្រេចបានប្រមាណ៥៨,៣% បើធៀបនឹងគោលដៅឆ្នាំ២០២៥។ ទិន្នន័យទាំងនេះ ឆ្លុះបញ្ចាំងឱ្យឃើញថា កម្ពុជាបាន និងកំពុងធ្វើពិពិធកម្មមុខទំនិញនាំចេញរបស់ខ្លួនជាបន្តបន្ទាប់ និងបន្តជំរុញកំណើននៃការនាំចេញកសិផលកែច្នៃឱ្យបានកាន់តែសម្បូរបែប ដោយមិនពឹងផ្អែកតែទៅលើការនាំចេញទំនិញកម្មន្តសាលផ្នែកសម្លៀកបំពាក់និងស្បែកជើងនោះទេ។

**តារាងទី២÷ ចំណែកនៃមុខទំនិញនាំចេញ**

| វិស័យ | ១៩៩៨ | ២០១៣ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | គោលដៅ ២០២០ | គោលដៅ ២០២៥ |
|---|---|---|---|---|---|---|---|---|
| ការនាំចេញកសិផលកែច្នៃ | ១០% | ៧,៩% | ៥,៩% | ៥,២% | ៦,៩% | ៧,០% | ១០% | ១២% |
| កម្មន្តសាល | | | | | | | | |
| - *សម្លៀកបំពាក់និងស្បែកជើង* | ៨០% | ៧៥,៩% | ៧១,៦% | ៧១,៧% | ៧០,៤% | ៦៩,២% | ៥៥% | ៥០% |
| - *មិនមែនសម្លៀកបំពាក់និងស្បែកជើង* | ០,១% | ៥,០% | ៥,៦% | ៤,៤% | ១១,៦% | ១៣,៣% | ១០% | ១៥% |

*កំណត់សម្គាល់÷ ទិន្នន័យចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៨ ទទួលបានពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

*គោលដៅទី៣ នៃគោលនយោបាយ គឺនៅឆ្នាំ២០២៥ សហគ្រាសធុនតូចនិងមធ្យម៨០% និង៩៥% រៀងគ្នា នឹងត្រូវបានចុះបញ្ជីជាផ្លូវការ ហើយសហគ្រាសធុនតូចនិងមធ្យម៥០% និង៧០% រៀងគ្នា នឹងមានបញ្ជិកាគណនេយ្យនិងតារាងតុល្យការត្រឹមត្រូវ។* ជាក់ស្តែង ការចុះបញ្ជីផ្លូវការនៃសហគ្រាសធុនតូច មធ្យម និងធំ មានការកើនឡើងពី ៣៧%, ៧២% និង៩៣% រៀងគ្នា នៅឆ្នាំ២០១០ ដល់ ៧៦%, ៨៧% និង៩៨% រៀងគ្នា នៅឆ្នាំ២០១៨ ពោលគឺខិតជិតសម្រេចបានតាមគោលដៅឆ្នាំ២០២៥ (សូមមើលតារាងទី៣)។ សហគ្រាសធុនមធ្យមដែលមានតារាងតុល្យការ បានកើនឡើងពី ២៤% ក្នុងឆ្នាំ២០១០ ដល់ ៧២% ក្នុងឆ្នាំ២០១៨ លើសពីគោលដៅឆ្នាំ២០២៥ ទៅទៀត ខណៈដែលសហគ្រាសធុនតូច និងធុនធំដែលមានតារាងតុល្យការក៏បានកើនឡើងផងដែរពី ៤% និង៦៦% រៀងគ្នាក្នុងឆ្នាំ២០១០ ដល់ ២៨% និង៨៧% រៀងគ្នា ក្នុងឆ្នាំ២០១៨។

ទោះជាយ៉ាងណាក្តី កំណើននៃការចុះបញ្ជីផ្លូវការនៃសហគ្រាសធុនតូចនិងមធ្យម បានបង្ហាញពីការយល់ដឹងកាន់តែច្រើនរបស់សហគ្រាសធុនតូចនិងមធ្យម អំពីសារៈសំខាន់នៃការចុះបញ្ជីផ្លូវការ ដើម្បីពង្រឹងអភិបាលកិច្ចអាជីវកម្ម, បង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទាន និងជាមូលដ្ឋានវាយតម្លៃសម្រាប់ទទួលបានការគាំទ្រផ្នែកបច្ចេកទេស ឬការលើកទឹកចិត្តផ្សេងៗពីរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា។

**តារាងទី៣÷ អត្រាក្រុមហ៊ុនផ្លូវការបានចុះបញ្ជី និងមានតារាងតុល្យការ**

| ទំហំ/ប្រភេទសហគ្រាស | បានចុះបញ្ជីផ្លូវការ | | | | | | មានតារាងតុល្យការ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១០ | ២០១៦ | ២០១៧ | ២០១៨ | គោលដៅ ២០២០ | គោលដៅ ២០២៥ | ២០១០ | ២០១៦ | ២០១៧ | ២០១៨ | គោលដៅ ២០២០ | គោលដៅ ២០២៥ |
| ធុនតូច | ៣៧% | N/A | N/A | ៧៦% | ៧០% | ៨០% | ៤% | ២៤% | ២៩% | ២៨% | ៣០% | ៥០% |
| ធុនមធ្យម | ៧២% | N/A | N/A | ៨៧% | ៨០% | ៩៥% | ២៤% | ៧៥% | ៧១% | ៧២% | ៥០% | ៧០% |
| ធុនធំ | ៩៣% | ៩៦% | ៩៨% | ៩៨% | ១០០% | ១០០% | ៦៦% | ៨៥% | ៨៦% | ៨៧% | ១០០% | ១០០% |

*កំណត់សម្គាល់÷ - ទិន្នន័យសហគ្រាសដែលបានចុះបញ្ជីផ្លូវការចាប់ពីឆ្នាំ២០១៦-២០១៨ ទទួលបានពីក្រសួងឧស្សាហកម្មនិងសិប្បកម្ម*

*- ទិន្នន័យសហគ្រាសដែលមានតារាងតុល្យការចាប់ពីឆ្នាំ២០១៦-២០១៨ ទទួលបានពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

*- N/A: គ្មានទិន្នន័យ*

៥ បន្ថែមលើវឌ្ឍនភាពនៃគោលដៅចម្បងទាំងបីខាងលើក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ បានសម្រេចនូវវឌ្ឍនភាពមួយចំនួនទាក់ទងនឹងវិធានការគន្លឹះបួនជាក់ស្តែង ដែលក្រសួង ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្តបានធ្វើការវាយតម្លៃ និងកំណត់ជានិទ្ទេសចំនួន៤កម្រិត ស្របតាមស្មារតីនៃកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កម្រិតទី១ សម្រេចបានពេញលេញ, កម្រិតទី២ សម្រេចបានភាគច្រើន, កម្រិតទី៣ សម្រេចបានដោយផ្នែក និងកម្រិតទី៤ មានការយឺតយ៉ាវ)។ វឌ្ឍនភាពនៃការអនុវត្តវិធានការទាំងនេះ មានដូចខាងក្រោម÷

***វិធានការទី១- "រៀបចំនិងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនីសម្រាប់វិស័យឧស្សាហកម្មនិងពាណិជ្ជកម្ម រួមទាំងការពង្រឹងភាពទុកចិត្ត និងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី"***

រាជរដ្ឋាភិបាលបានអនុម័តផែនការបន្ថយថ្លៃលក់អគ្គិសនីបន្ថែមទៀតតាមបណ្តាខេត្តនិងរាជធានី (២០១៧-២០២០) បន្ថែមពីលើផែនការយុទ្ធសាស្ត្រកាត់បន្ថយអត្រានិងតម្លាតថ្លៃលក់អគ្គិសនី សម្រាប់ឆ្នាំ ២០១៥-២០២០ ដែលបានដាក់ចេញកាលពីឆ្នាំ២០១៥។ បន្ថែមលើផែនការដែលបានកែសម្រួលនេះ នៅខែតុលា ឆ្នាំ២០១៨ រាជរដ្ឋាភិបាល តំណាងដោយក្រសួងរ៉ែនិងថាមពល បានចេញប្រកាសស្តីពីការកែសម្រួលអត្រាថ្លៃលក់អគ្គិសនីឡើងវិញ នៅក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រានិងតម្លាតថ្លៃលក់អគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ការអនុវត្តបន្តពីឆ្នាំ២០១៩-២០២០។ កម្មវិធីបន្ថយថ្លៃតាមឆ្នាំ ក្នុងឆ្នាំ២០១៧ បានកាត់បន្ថយនិងអនុគ្រោះចំពោះអ្នកប្រើប្រាស់ប្រភេទឧស្សាហកម្មនិងពាណិជ្ជកម្មធំៗ ក្នុងតម្លៃត្រឹមតែ

១២,៦០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោងសម្រាប់ការទិញពីអនុស្ថានីយផ្ទាល់, ១៦,៧០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោងសម្រាប់ការទិញពីបណ្ដាញភ្នំពេញ និង១៦,៥០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោងសម្រាប់ការទិញពីបណ្ដាញតាមខេត្ត។ សម្រាប់ឆ្នាំ២០១៨ ការទិញពីបណ្ដាញភ្នំពេញថយចុះមកត្រឹម ១៦,៥០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោងនិង១៦,៤០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការទិញពីបណ្ដាញតាមខេត្ត។ លើសពីនេះ រាជរដ្ឋាភិបាលបានកំណត់បញ្ជីថ្លៃលក់អគ្គិសនីតាមពេលវេលាដែលជាជម្រើសថ្លៃមួយទៀតសម្រាប់អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម ពាណិជ្ជកម្ម និងកសិកម្មក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ដោយបែងចែកអត្រាថ្លៃលក់ជា២ប្រភេទទៅតាមពេលវេលាថ្ងៃយប់ ព្រមទាំងបានកំណត់អត្រាថ្លៃលក់អគ្គិសនីពិសេសនៅរដូវវស្សាផងដែរ។

តារាងខាងក្រោម បង្ហាញពីតារាងជាក់ស្ដែងនៃការបន្ថយថ្លៃលក់អគ្គិសនីសម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ នៅក្នុងតំបន់ដែលមានប្រភពអគ្គិសនីរបស់បណ្ដាញជាតិគ្រប់ដណ្ដប់÷

| ប្រភេទនៃការទិញ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ |
|---|---|---|
| **១- សម្រាប់អ្នកប្រើប្រាស់ធំៗ គ្រប់ប្រភេទ ទិញអគ្គិសនីពីអនុស្ថានីយ** | | |
| ទិញតាមទ្វារចរន្តតង់ស្យុងខ្ពស់ | 0,១២៤០$ | |
| ទិញតាមទ្វារចរន្តតង់ស្យុងមធ្យមនៅអនុស្ថានីយ តាមខេត្ត | 0,១២៦០$ | |
| ទិញតាមទ្វារចរន្តតង់ស្យុងមធ្យមនៅអនុស្ថានីយក្នុងរាជធានីភ្នំពេញ | 0,១៤៩៥$ | 0,១៤៧៥$ |
| **២- សម្រាប់អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម** | | |
| ទិញតាមខ្សែបញ្ជូនរងនិងតាមខ្សែតង់ស្យុងមធ្យមនៃតំបន់ចែកចាយ | ភ្នំពេញ 0,១៦៧០$<br>ខេត្ត 0,១៦៥០$ | ភ្នំពេញ 0,១៦៥០$<br>ខេត្ត 0,១៦៤០$ |
| ទិញក្រោមត្រង់ស្វូដែលបានវិនិយោគដោយខ្លួនឯង | ភ្នំពេញ 0,១៧១០$<br>ខេត្ត 0,១៧១៩$ | 0,១៧០៦$ |
| ទិញក្រោមត្រង់ស្វូដែលឲ្យអ្នកផ្គត់ផ្គង់វិនិយោគ | ភ្នំពេញ 0,១៧៩០$<br>ខេត្ត 0,១៨១៩$ | 0,១៧៨៦$ |
| **៣- សម្រាប់អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្មធំៗនិងរដ្ឋបាល** | | |
| ទិញតាមខ្សែបញ្ជូនរងនិងតាមខ្សែតង់ស្យុងមធ្យមនៃតំបន់ចែកចាយ | ភ្នំពេញ 0,១៦៧០$<br>ខេត្ត 0,១៦៥០$ | ភ្នំពេញ 0,១៦៥០$<br>ខេត្ត 0,១៦៤០$ |
| ទិញក្រោមត្រង់ស្វូដែលបានវិនិយោគដោយខ្លួនឯង | ភ្នំពេញ 0,១៧១០$<br>ខេត្ត 0,១៧១៩$ | 0,១៧០៦$ |
| ទិញក្រោមត្រង់ស្វូដែលឱ្យអ្នកផ្គត់ផ្គង់វិនិយោគ | ភ្នំពេញ 0,១៧៩០$<br>ខេត្ត 0,១៨១៩$ | 0,១៧៨៦$ |

ចំពោះការពង្រីកវិសាលភាពគ្រប់ដណ្ដប់និងការពង្រឹងភាពទុកចិត្តនៃការផ្គត់ផ្គង់អគ្គិសនី រាជរដ្ឋាភិបាលបានសាងសង់ខ្សែបណ្ដាញមេចេញពីអនុស្ថានីយដើម្បីរំលែកបន្ទុកពីខ្សែចាស់ដែលមានបន្ទុកធ្ងន់ ក្នុង

គោលដៅបង្កើនស្ថិរភាពក្នុងការផ្គត់ផ្គង់ជូនរោងចក្រឧស្សាហកម្មក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ ព្រមទាំងបាន និងកំពុងបង្កើនប្រភពផ្គត់ផ្គង់អគ្គិសនីដែលរួមមាន (១) ការដាក់ឱ្យដំណើរការស្ថានីយអគ្គិសនីដុតធ្យូងថ្មអានុភាព ១៣៥មេហ្គាវ៉ាត់, (២) ការដាក់ឱ្យដំណើរការស្ថានីយអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព ១០មេហ្គាវ៉ាត់, (៣) ការដាក់ឱ្យដំណើរការស្ថានីយវារីអគ្គិសនីសេសានក្រោម២ អានុភាពសរុប ៤០០មេហ្គាវ៉ាត់, (៤) ការដាក់ឱ្យដំណើរការអនុស្ថានីយទួលពង្រ (GS8) អានុភាព ៧៥មេហ្គាវ៉ាត់ ដើម្បីជួយបង្កើនការផ្គត់ផ្គង់ដល់តំបន់ឧស្សាហកម្មនៅវេងស្រេង និងទួលពង្រ, (៥) ការពង្រីកការផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ធុនធំដែលភ្ជាប់ចេញពីខ្សែបណ្តាញតង់ស្យុងខ្ពស់ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងរោងចក្រស៊ីម៉ងត៍ ខនស៍ (Conch) នៅស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង, (៦) បាននិងកំពុងសាងសង់អនុស្ថានីយនៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ អានុភាពសរុប ៥០មេហ្គាវ៉ាត់, (៧) បន្ថែមកម្លាំងត្រង់ស្វូតាមបណ្តាអនុស្ថានីយក្នុងរាជធានីភ្នំពេញនិងខេត្តក្រុងសំខាន់ៗ ដែលជាទិសដៅអាទិភាព ដើម្បីបង្កើនសមត្ថភាពនិងស្ថិរភាពក្នុងការផ្គត់ផ្គង់ជូនអតិថិជន ដែលនឹងគ្រោងដាក់ឱ្យដំណើរការក្នុងឆ្នាំ២០១៩, (៨) បន្តតាមដាននិងដោះស្រាយបញ្ហាដាច់ចរន្តអគ្គិសនីញឹកញាប់ និងបញ្ហាធ្លាក់គុណភាពខ្សែបណ្តាញ, និង (៩) សិក្សាអំពីលទ្ធភាពក្នុងការបន្ថយថ្លៃលក់អគ្គិសនីបន្ថែមសម្រាប់ឆ្នាំ២០១៩ និង២០២០។

ជារួម លទ្ធផលការងារនៃការអនុវត្តវិធានការគន្លឹះទី១ នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលសម្រេចជាក់ស្តែងត្រឹមដំណាច់ឆ្នាំ២០១៨ គឺស្ថិតក្នុងកម្រិតទី១ ពោលគឺ "**សម្រេចបានពេញលេញ**" ស្របតាមគោលដៅដែលបានកំណត់នៅក្នុងសូចនាករនៃវិធានការនេះរួមមាន ១. ការរៀបចំនិងការអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនីសម្រាប់វិស័យឧស្សាហកម្មនិងពាណិជ្ជកម្ម និង ២. ការពង្រឹងភាពជឿទុកចិត្ត និងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនីឱ្យដល់គ្រប់តំបន់ឧស្សាហកម្មគោលដៅ (គិតត្រឹមឆ្នាំ២០១៨ ដោយផ្តោតលើតំបន់សេដ្ឋកិច្ចពិសេសស្របតាមការកំណត់នៃផែនការគ្រោងទុក)។

***វិធានការទី២- "រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម"***

ក្នុងទិសដៅជំរុញការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានភាពប្រកួតប្រជែងនិងប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលបានរៀបចំធ្វើកំណែទម្រង់ស៊ីជម្រៅស្របពេលជាមួយគ្នា ទាំងក្នុងក្របខ័ណ្ឌស្ថាប័ន ទាំងក្នុងក្របខ័ណ្ឌគោលនយោបាយ។ ក្នុងក្របខ័ណ្ឌស្ថាប័ន រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាជាតិភស្តុភារកម្ម ដែលជាក្រុមប្រឹក្សាសម្រាប់បង្កើតឡើងនូវគោលនយោបាយ គណៈ-កម្មាធិការជាតិភស្តុភារកម្ម ដែលជាគណៈកម្មាធិការសម្រាប់អនុវត្តគោលនយោបាយ និងអគ្គនាយកដ្ឋានភស្តុភារកម្មនៃក្រសួងសាធារណការនិងដឹកជញ្ជូន ដែលជាសេនាធិការក្នុងការសម្របសម្រួលលើកិច្ចការ

ឡូជិស្ទីកនិងដឹកជញ្ជូននេះ។ នៅក្នុងក្របខ័ណ្ឌគោលនយោបាយ រាជរដ្ឋាភិបាលបានបញ្ចប់ការសិក្សាផែនការមេស្តីពីការកែលម្អប្រព័ន្ធភស្តុភារកម្មនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨-២០២៥ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តក្នុង៣ដំណាក់កាល រយៈពេលខ្លី (២០១៨-២០១៩), រយៈពេលមធ្យម (២០២០-២០២២) និងរយៈពេលវែង (២០២៣-២០២៥) និងបានបញ្ចប់សេចក្តីព្រាងផែនការមេថ្នាក់ជាតិស្តីពីការដឹកជញ្ជូននិងភស្តុភារកម្ម។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បាននិងកំពុងអនុវត្តគម្រោងសហប្រតិបត្តិការបច្ចេកទេសជាមួយដៃគូអភិវឌ្ឍជាច្រើន ក្នុងការអនុវត្តគម្រោងនានាដូចជា÷ គម្រោងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធភស្តុភារកម្ម, គម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេស ដើម្បីរៀបចំផែនការមេបណ្តុះបណ្តាលក្នុងវិស័យភស្តុភារកម្ម និងគម្រោងពិនិត្យឡើងវិញលើក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តនៅក្នុងវិស័យភស្តុភារកម្ម ព្រមទាំងការសិក្សាបុរេសមិទ្ធិលទ្ធភាពនៃគម្រោងអភិវឌ្ឍន៍មជ្ឈមណ្ឌលភស្តុភារកម្មចំនួន ២កន្លែង ក្នុងនោះរួមមាន (១) គម្រោងសិក្សាអភិវឌ្ឍន៍មជ្ឈមណ្ឌលភស្តុភារកម្មក្រុងព្រះសីហនុ និង (២) គម្រោងសិក្សាអភិវឌ្ឍន៍មជ្ឈមណ្ឌលភស្តុភារកម្មភ្នំពេញ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បាននិងកំពុងរៀបចំការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រចាំបាច់នានា ដើម្បីតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និងអភិវឌ្ឍរបៀងសេដ្ឋកិច្ច ភ្នំពេញ-ខេត្តព្រះសីហនុ, និងភ្នំពេញ-បាវិត, ដែលក្នុងនោះរួមមាន (១) ការដំណើរការសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន, និង (២) ការបញ្ចប់ការសិក្សាសមិទ្ធិលទ្ធភាពលើគម្រោងសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-បាវិត និងកំពុងស្ថិតក្នុងដំណាក់កាលពិភាក្សាលើតម្លៃនៃគម្រោងនិងប្រភពថវិកា។

ជារួម រាជរដ្ឋាភិបាលបានសម្រេចជោគជ័យនូវសមិទ្ធផលការងារជាច្រើនក្នុងការអនុវត្តវិធានការទី២នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ ដែលការអនុវត្តវិធានការនេះ ស្ថិតនៅកម្រិតទី២ ពោលគឺ “**សម្រេចបានភាគច្រើន**”។

ជាមួយនឹងសមិទ្ធផលខាងលើ ការងារនៅក្នុងវិស័យភស្តុភារកម្ម ដែលជាការងារមានលក្ខណៈអន្តរវិស័យ ទាមទារនូវកិច្ចសហការ និងការសម្របសម្រួលមួយកម្រិតថែមទៀត ទាំងក្នុងក្របខណ្ឌនៃការរៀបចំគោលនយោបាយ ផែនការ និងការអនុវត្ត។ ការកៀរគរប្រភពហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងពីផ្នែកឯកជន ដើម្បីគាំទ្រដល់ការអនុវត្តផែនការមេ និងការបន្តស្តារនិងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ក៏ជាកិច្ចការចាំបាច់មួយទៀត ដែលត្រូវមានការចូលរួមយ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធ។

សម្រាប់ទិសដៅការងារបន្ត រាជរដ្ឋាភិបាលនឹងជំរុញអនុវត្តការងារសំខាន់ៗមួយចំនួនដូចជា (១) បញ្ចប់ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយនិងភស្តុភារកម្ម នៅក្នុងឆ្នាំ ២០២០ និងបន្តអនុវត្តដល់ឆ្នាំ២០៣០, (២) កំណត់អាទិភាពនៃផែនការសកម្មភាពនិងដាក់បញ្ចូលក្នុង

ផែនការវិនិយោគសាធារណៈ, (៣) កៀរគរធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍនិងពីវិស័យឯកជន ដើម្បីគាំទ្រដល់ការអនុវត្តផែនការមេអន្តរកាល ស្តីពីការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយនិងភស្តុភារកម្មឱ្យមានប្រសិទ្ធភាពខ្ពស់, (៤) បញ្ចប់ការសាងសង់ផ្លូវជាតិលេខ១០ ប្រវែង ១៩៨,៧១គ.ម ចាប់ពីសំឡូត វាលវែង អូរសោម ដល់កោះកុង នៅឆ្នាំ២០២៣, (៥) បន្តស្តារនិងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឱ្យបានយ៉ាងហោចប្រវែង ៧០០គ.ម.ក្នុងមួយឆ្នាំ, (៦) បន្តពង្រីកផ្លូវជាតិកម្រិត១ភ្ជាប់ទៅតំបន់អភិវឌ្ឍសំខាន់ៗ និងនៅជុំវិញទីក្រុងសំខាន់ៗពី ២គន្លងទៅ៤គន្លង, (៧) បន្តស្តារ សាងសង់ផ្លូវជាតិ ផ្លូវខេត្ត ភ្ជាប់ទៅតំបន់អភិវឌ្ឍឧស្សាហកម្ម កសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍ ដែលបានបង្កើតឡើង និងតាមតំបន់ព្រំដែន និង (៨) ជំរុញការសាងសង់ផ្លូវល្បឿនលឿន ដែលជាគម្រោងអាទិភាពផ្អែកលើផែនការមេនៃការអភិវឌ្ឍផ្លូវល្បឿនលឿននៅកម្ពុជា ដូចជាខ្សែផ្លូវរាជធានីភ្នំពេញ-ក្រុងព្រះសីហនុ, ភ្នំពេញ-បាវិត និងភ្នំពេញ-សៀមរាប។ គម្រោងផ្លូវល្បឿនលឿនរាជធានីភ្នំពេញ-ក្រុងព្រះសីហនុ ត្រូវបានគ្រោងថានឹងបញ្ចប់នៅឆ្នាំ២០២៣។ ដោយឡែក ចំពោះគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-បាវិត ក្រសួងសាធារណការនិងដឹកជញ្ជូន បានចុះកិច្ចព្រមព្រៀងក្របខ័ណ្ឌឱ្យក្រុមហ៊ុនឯកជនសិក្សាគម្រោងនេះ ខណៈភាគីវៀតណាមកំពុងរៀបចំការសាងសង់ផ្លូវល្បឿនលឿនហូជីមិញ-ម៉ុកបៃ ដើម្បីតភ្ជាប់ជាមួយកម្ពុជា ហើយនឹងខិតខំសាងសង់ឱ្យរួចរាល់ និងដាក់ឱ្យដំណើរការនៅក្នុងឆ្នាំ២០២៥។

***វិធានការទី៣- "ពង្រឹង និងបន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្ម និងការបណ្តុះបណ្តាលជំនាញ"***

វិធានការទី៣ គឺជាវិធានការស្នូលដែលរាជរដ្ឋាភិបាលបាននិងកំពុងបន្តអនុវត្តរៀងមក សំដៅធ្វើយ៉ាងណាឱ្យកម្មករ និយោជិត មានជីវភាពសមរម្យ និងទទួលបាននូវលក្ខខណ្ឌការងារល្អប្រសើរជាងមុន ឱ្យស្របទៅនឹងកំណើនសេដ្ឋកិច្ច-ឧស្សាហកម្មរបស់កម្ពុជា។ រាជរដ្ឋាភិបាលបានបង្កើតយន្តការត្រីភាគីក្នុងការពិភាក្សានិងកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិត ក្នុងរយៈពេល ១ឆ្នាំម្តង។ ជាលទ្ធផលប្រាក់ឈ្នួលអប្បបរមាក្នុងឆ្នាំ២០១៧ មានចំនួន ១៥៣ដុល្លារ/ខែ និងឆ្នាំ២០១៨ មានចំនួន ១៧០ដុល្លារ/ខែ មានកំណើន ១៧ដុល្លារ។ ការដំឡើងនេះ មានអត្រាកំណើនខ្ពស់ជាងអត្រាអតិផរណាប្រចាំឆ្នាំ ព្រមទាំងបានរក្សានូវអត្ថប្រយោជន៍ផ្សេងៗចន្លោះពី១១ ទៅ១៧ដុល្លារ/ខែផងដែរ។ ខណៈចំនួនរោងចក្រផ្នែកវាយនភណ្ឌកាត់ដេរនិងផលិតស្បែកជើងមានការកើនឡើងពីចំនួន១ ១០៧រោងចក្រនៅឆ្នាំ២០១៦ ដល់ចំនួន១ ១៥៩រោងចក្រនៅឆ្នាំ២០១៨ ចំនួនវិវាទការងារបានបន្តថយចុះពីចំនួន៨៥៣ករណីនៅឆ្នាំ២០១៦ មកនៅត្រឹម៦៩៣ករណីនៅឆ្នាំ២០១៧ និង៥៨៨ករណីនៅឆ្នាំ២០១៨ ហើយទន្ទឹមគ្នានេះ ការធ្វើកូដកម្មបានថយចុះពីចំនួន២៧០ករណីនៅឆ្នាំ២០១៦ មកនៅត្រឹម៩៧ករណីនៅឆ្នាំ២០១៧ និងមកនៅត្រឹម៤៧ករណីនៅឆ្នាំ២០១៨ផងដែរ។ លើសពីនេះ ដើម្បីជួយសម្រាលបន្ទុកចំណាយរបស់កម្មករ និយោជិត រាជរដ្ឋាភិបាលបានដំឡើងកម្រិត

អប្បបរមានៃប្រាក់បៀវត្សដែលត្រូវជាប់ពន្ធ, ដំឡើងកម្រិតទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក ដើម្បីកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស, ដាក់ចេញនូវយន្តការអនុគ្រោះពន្ធលើប្រាក់បៀវត្ស ចំពោះអត្ថប្រយោជន៍បន្ថែមសម្រាប់ចំណាយលើការដឹកជញ្ជូន ស្នាក់នៅ និងហូបចុករបស់កម្មករនិយោជិត, និងយន្តការលើកលែងអាករលើតម្លៃបន្ថែម តាមរយៈការផ្គត់ផ្គង់មិនជាប់អាករលើទឹកស្អាត អគ្គិសនី និងសេវាសាធារណៈមួយចំនួនទៀត។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញនូវគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងយន្តការមួយចំនួនទៀតផងដែរ សំដៅពង្រឹងនិងពង្រីកការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈឱ្យកាន់តែមានប្រសិទ្ធភាព ក្នុងនោះរួមមាន (១) ការដាក់ឱ្យអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥, (២) ការដាក់ឱ្យអនុវត្តគម្រោងសាកល្បងមូលនិធិជាតិអភិវឌ្ឍជំនាញ ដើម្បីបង្កើនជំនាញ ទប់ស្កាត់ចំណាកស្រុកនិងចំណាកប្រទេស បង្កើនផលិតភាព និងលើកកម្ពស់ជីវភាពរបស់ប្រជាជននៅទីជនបទ និង (៣) ការបង្កើនការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈរយៈពេលវែងតាមវិស័យអាទិភាព ទាំង៥រួមមានសំណង់ អគ្គិសនី មេកានិករថយន្ត កម្មន្តសាលធុរកិច្ចនិងព័ត៌មានវិទ្យា ដើម្បីគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្ម។ ជាមួយគ្នានេះ ក្នុងគោលបំណងកែលម្អស្ថិរភាពទីផ្សារពលកម្មនិងកាត់បន្ថយចំនួនវិវាទការងារ រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តកិច្ចការនិងសកម្មភាពគួរឱ្យកត់សម្គាល់មួយចំនួន រួមមាន (១) ការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារពាក់ព័ន្ធនឹងការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ក្នុងការដោះស្រាយទាន់ពេលវេលាចំពោះករណីរោងចក្រក្ស័យធនឬបិទទ្វារដោយថៅកែរត់ចោល, (២) ការពង្រឹងគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញានៅថ្នាក់ជាតិនិងថ្នាក់រាជធានីខេត្ត, និង (៣) ការធ្វើទំនើបកម្មនិងពង្រឹងយន្តការអធិការកិច្ចការងារតែមួយ ដើម្បីឱ្យកាន់តែមានប្រសិទ្ធភាពជាងមុន។

សរុបមក គិតត្រឹមឆ្នាំ២០១៨នេះ សូចនាករដែលបានកំណត់នៅក្នុងវិធានការទី៣ ត្រូវបានសម្រេចក្នុងកម្រិតទី២ ពោលគឺ "**សម្រេចបានភាគច្រើន**"។ វឌ្ឍនភាពដែលសម្រេចបានខាងលើនេះ បញ្ជាក់ឱ្យឃើញថា រាជរដ្ឋាភិបាលបានខិតខំធានានូវកម្រិតជីវភាពរស់នៅសមរម្យនិងលក្ខខណ្ឌការងារល្អប្រសើរសម្រាប់កម្មករ និយោជិត តាមរយៈការដំឡើងប្រាក់ឈ្នួលអប្បបរមាជាបន្តបន្ទាប់ ការកាត់បន្ថយចំនួនវិវាទការងារ និងការធ្វើទំនើបកម្មប្រព័ន្ធអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងជំនាញឱ្យកាន់តែល្អប្រសើរឡើង។

ទោះបីជាលទ្ធផលនៃវិធានការនេះ សម្រេចបានភាគច្រើនតាមសូចនាករដែលបានកំណត់ក្តី ចំណុចប្រឈមនៃការអនុវត្តវិធានការបន្តនេះ គឺកង្វះភាពចាស់ទុំ និងក្រមសីលធម៌នៃអង្គការវិជ្ជាជីវៈក្នុងការដោះស្រាយវិវាទការងារ និងការចរចាផ្សេងៗ។ រីឯចំនួនកម្មករជំនាញដែលទទួលបានបណ្តុះបណ្តាលនៅមានចំនួនតិច មិនទាន់ឆ្លើយតបបានទៅនឹងកម្រិតនៃការចង់បានដើម្បីទាក់ទាញឱ្យគម្រោងវិនិយោគថ្មីៗ

ជាពិសេសគម្រោងវិនិយោគផ្នែកគ្រឿងបង្គុំ និងសម្ភារបរិក្ខារអគ្គិសនី ហើយផលិតភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់ពេលវេលារបស់កម្មករនិយោជិត គឺនៅមានកម្រិតនៅឡើយ ដែលតម្រូវឱ្យមានការបណ្តុះបណ្តាលនិងបំប៉នបន្ថែម។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងនៅតែបន្តអនុវត្តវិធានការនេះ ដើម្បីពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ជំរុញការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈដែលឆ្លើយតបនឹងតម្រូវការនៃគម្រោងវិនិយោគថ្មី សំដៅបង្កើតឱកាសការងារកាន់តែច្រើន និងបង្កើនផលិតភាពនិងជំនាញពលកម្ម ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

***វិធានការទី៤ "អភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស"***

វិធានការទី៤ គឺជាវិធានការគន្លឹះសំខាន់ ដែលពាក់ព័ន្ធច្រើនទៅនឹងការកែប្រែយន្តការរដ្ឋបាល និងស្ថាប័នឱ្យស្របទៅនឹងគោលការណ៍តំបន់រដ្ឋបាលពិសេស ដែលទាមទារឱ្យមានការសម្របសម្រួលនិងសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅ មុននឹងដាក់ចេញនូវគោលនយោបាយនិងយន្តការចាំបាច់នានាឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផល។ ក្នុងដំណើរការនៃការអភិវឌ្ឍនិងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងអនុវត្តកិច្ចការងារចំពោះមុខ ជាច្រើន ដូចជា (១) បានអនុម័តឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តព្រះសីហនុ និងផែនទីបណ្តាញផ្លូវថ្នល់ ឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រក្នុងគោលបំណងកំណត់ចក្ខុវិស័យ និងយុទ្ធសាស្ត្រតម្រង់ទិសនៃការប្រើប្រាស់ដី និងការអភិវឌ្ឍផ្នែករូបវន្តដោយផ្អែកលើសក្តានុពលនៃភូមិសាស្ត្រ និងតំបន់នីមួយៗក្នុងខេត្តព្រះសីហនុ និង (២) បានសហការជាមួយវិទ្យាស្ថាននគរូបនីយកម្ម និងឌីសាញស៊ិនជិន ក្នុងការសិក្សាលើការរៀបចំផែនការមេ ដើម្បីអភិវឌ្ឍនិងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដោយមានការគាំទ្រ និងសហការសម្របសម្រួលពីអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍឧស្សាហកម្ម។ ក្រៅពីកិច្ចការទាំងនេះ រាជរដ្ឋាភិបាលក៏បានអនុវត្តសកម្មភាពគាំទ្រមួយចំនួនទៀត ដូចជា (១) បានកំពុងធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ខេត្តព្រះសីហនុ ២០១៦-២០២៥ ទៅជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ខេត្តព្រះសីហនុ ២០២០-២០២៥, (២) បានកំពុងរៀបចំផែនការសកម្មភាពឆ្នាំ២០២៣-២០២៥ លើវិស័យអាកាសចរស៊ីវិលដើម្បីចូលរួមអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពហុបំណង និង (៣) បាននិងកំពុងរៀបចំហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍និងបច្ចេកវិទ្យាព័ត៌មាន ដោយកសាងបណ្តាញខ្សែកាប្លិ៍អុបទិកទូទាំងប្រទេស និងបានដាក់ឱ្យដំណើរការគម្រោងខ្សែកាប្លិ៍ក្រោមបាតសមុទ្រ ដែលតភ្ជាប់កម្ពុជា តាមរយៈខេត្តព្រះសីហនុទៅអន្តរជាតិ។

ផ្អែកតាមសកម្មភាពដែលសម្រេចបានខាងលើ ការអនុវត្តវិធានការនេះ អាចត្រូវបានចាត់ទុកថាសម្រេចបានក្នុងកម្រិតទី៤ ពោលគឺ "**មានការយឺតយ៉ាវ**" ដោយសារតែការរៀបចំផែនការមេជាក់ស្តែងនៅមិនទាន់សម្រេចបានតាមសូចនាករដែលបានកំណត់និងទាមទារឱ្យមានការគិតគូរឱ្យបានល្អិតល្អន់ជាមុន លើ

គ្រប់ទិដ្ឋភាព ក្នុងនោះរួមមាន ទិដ្ឋភាពគោលនយោបាយ ទិដ្ឋភាពច្បាប់ រួមទាំងផែនការប្រតិបត្តិក្នុងកម្រិតបច្ចេកទេសនិងការអនុវត្តសកម្មភាពគាំទ្រនានា។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាល តាមរយៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងពិនិត្យ និងជំរុញអនុវត្តបន្ថែមទៀត នូវការងារពាក់ព័ន្ធនឹងការរៀបចំផែនការមេ ដើម្បីអភិវឌ្ឍនិងប្រែក្លាយខេត្តព្រះសីហនុឱ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណងនិងជាប៉ូលសេដ្ឋកិច្ច មជ្ឈមណ្ឌលឧស្សាហកម្ម ពាណិជ្ជកម្មនិងទេសចរណ៍ ស្របតាមទស្សនទាននៃការអភិវឌ្ឍប្រកបដោយចីរភាពនិងមេត្រីភាពបរិស្ថាន។

សម្រាប់ទិសដៅបន្ត គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងសហការជាមួយវិទ្យាស្ថាន ផែនការនគរូបនីយកម្មនិង រចនាបថទីក្រុងស៊ិនជិន នៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីសិក្សាលើការរៀបចំផែនការមេនេះ ព្រមទាំងរៀបចំឯកសារគតិយុត្តក្នុងការបង្កើតក្រុមប្រឹក្សាកម្រិតគោលនយោបាយ គណៈកម្មាធិការកម្រិតបច្ចេកទេស និងក្រុមការងារបច្ចេកទេស។

៦ ក្រៅពីវឌ្ឍនភាពនៃការអនុវត្តវិធានការទាំង៤ ខាងលើ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បាននិងកំពុងបន្តអនុវត្តសកម្មភាពយ៉ាងច្រើន ទៅតាមវិធានការគោលនយោបាយនិងផែនការសកម្មភាពរបស់ខ្លួន ពាក់ព័ន្ធនឹង (១) ការជំរុញការទាក់ទាញវិនិយោគ, (២) ការពង្រីកនិងទំនើបកម្មសហគ្រាសធុនតូច និងមធ្យម, (៣) ការកែលម្អបរិស្ថាននិយ័តកម្ម និង (៤) ការសម្របសម្រួលគោលនយោបាយគាំទ្រ ដែលបានកំណត់នៅក្នុងតារាងម៉ាទ្រីស "ឃ" នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ដូចបានបង្ហាញជូនលម្អិតនៅក្នុងរបាយការណ៍វឌ្ឍនភាព និងឧបសម្ព័ន្ធដែលបានជូនភ្ជាប់មកជាមួយនេះ។

៧ ទន្ទឹមនឹងវឌ្ឍនភាពដែលសម្រេចបានដូចមានរៀបរាប់ខាងលើ ការអនុវត្តគោលនយោបាយនេះក៏បានជួបប្រទះបញ្ហាប្រឈមនិងហានិភ័យមួយចំនួន ដែលទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការដាក់ចេញនិងអនុវត្តផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយឱ្យបានគ្រប់ជ្រុងជ្រោយនិងប្រកបដោយប្រសិទ្ធភាពខ្ពស់។ បញ្ហាប្រឈមនិងហានិភ័យទាំងនោះ រួមមាន (១) ភាពប្រកួតប្រជែងរបស់កម្ពុជានៅមានកម្រិត÷ បញ្ហាថ្លៃដើមផលិតកម្មដូចជា ថ្លៃដឹកជញ្ជូន ថ្លៃអគ្គិសនីនៅស្ថិតក្នុងកម្រិតមួយខ្ពស់ បើធៀបនឹងប្រទេសជិតខាង និងការកើនឡើងនូវប្រាក់ឈ្នួលអប្បបរមា ខណៈដែលផលិតភាពការងារនៅមានកម្រិត, (២) បរិស្ថានធុរកិច្ចនិងវិនិយោគដែលកាន់តែមានភាពអំណោយផលរបស់ប្រទេសក្នុងតំបន់÷ ការដាក់ចេញនូវគោលនយោបាយអនុគ្រោះពាក់ព័ន្ធនឹងការជំរុញ និងលើកទឹកចិត្តការវិនិយោគរបស់បណ្តាប្រទេសក្នុងតំបន់ ជាពិសេសប្រទេសថៃ វៀតណាម និងមីយ៉ាន់ម៉ា ដែលអាចប៉ះពាល់ដល់ភាពប្រកួតប្រជែងរបស់កម្ពុជា, (៣) ការប្រែប្រួលភូមិសាស្ត្រនយោបាយ÷ ភាពមិនច្បាស់លាស់នៃទស្សនវិស័យសេដ្ឋកិច្ចនិងពាណិជ្ជកម្មសកល ដោយរាប់បញ្ចូលទាំងភាពតានតឹងផ្នែកពាណិជ្ជកម្មរវាងប្រទេសមហាអំណាចក្រោមគោលការណ៍គាំពារនិយម អាចជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជា និង (៤) ការផ្លាស់ប្តូរលក្ខខណ្ឌនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ÷ ការបោះជំហានរបស់កម្ពុជាចេញពីឋានៈប្រទេសមានចំណូលទាប

ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប អាចធ្វើឱ្យដៃគូអភិវឌ្ឍន៍ផ្លាស់ប្តូរលក្ខខណ្ឌនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ។ ក្រៅពីបញ្ហាប្រឈមចម្បងខាងលើ ការអនុវត្តគោលនយោបាយនេះ ក៏ជួបប្រទះការលំបាកមួយចំនួនទៀត ដូចជាការសម្របសម្រួលនិងការកសាងសមត្ថភាពស្ថាប័ននៅមានកម្រិត ព្រមទាំងបញ្ហាកង្វះថវិកានិងធនធានមនុស្សសម្រាប់គាំទ្រលើវិធានការមួយចំនួន។

៨ សរុបសេចក្តីមក តាមការពិនិត្យនិងតាមដានលើវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ យើងអាចសន្និដ្ឋានបានថា ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បាននិងកំពុងអនុវត្តនូវវិធានការគោលនយោបាយនិងផែនការសកម្មភាពរបស់ខ្លួន តាមការចង្អុលបង្ហាញនៅក្នុងឯកសារគោលនយោបាយនេះ ប្រកបដោយស្មារតីទទួលខុសត្រូវ និងស្ថិតនៅក្នុងទិសដៅត្រឹមត្រូវ ដែលអាចឈានទៅសម្រេចគោលដៅដែលបានកំណត់នៅឆ្នាំ២០២៥។ ជាលទ្ធផលការអនុវត្តគោលនយោបាយនេះ ទទួលបាននូវវឌ្ឍនភាពជាវិជ្ជមានគួរឱ្យកត់សម្គាល់ ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈការសម្រេចបានជាបន្តបន្ទាប់នូវគោលដៅចម្បងទាំងបី និងវិធានការគន្លឹះបួនជាក់ស្តែងនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។ ទន្ទឹមនឹងនេះ ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា នារយៈកាលកន្លងមក បានជួបប្រទះនូវបញ្ហាប្រឈមនិងហានិភ័យមួយចំនួន ដែលតម្រូវឱ្យតួអង្គពាក់ព័ន្ធទាំងអស់រួមមាន ស្ថាប័នជាតិ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ បន្តកិច្ចសហការក្នុងការគ្រប់គ្រង និងដោះស្រាយប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់បំផុត និងទាន់ពេលវេលា ពិសេសធ្វើការបន្សុំទៅនឹងសភាពការណ៍ដែលមានការប្រែប្រួលឥតឈប់ឈរ ដើម្បីធានាភាពជោគជ័យនៃគោលនយោបាយនេះ។

៩. សម្រាប់ទិសដៅការងារបន្ត រាជរដ្ឋាភិបាលនឹងរៀបចំការត្រួតពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិលើគោលនយោបាយនេះ នៅពាក់កណ្តាលឆ្នាំ២០២១ ដើម្បីឆ្លុះបញ្ចាំងពីជំហាននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងជាមូលដ្ឋានកែតម្រូវនិងតម្រង់ទិសដល់ការអនុវត្តបន្ត ដោយមានកំណត់នូវសូចនាករនិងគោលដៅថ្មីៗបន្ថែម ដែលអាចវាស់វែងបាន ហើយឆ្លើយតបនឹងអាទិភាពនៃតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ក្នុងន័យនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាស្ថាប័នសម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា បាននិងកំពុងសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍ ក្នុងការរៀបចំនូវប្រព័ន្ធតាមដាននិងវាយតម្លៃគោលនយោបាយនេះ។

# របាយការណ៍

# ស្តីពី

# វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ក្នុងឆ្នាំ២០១៧-២០១៨

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភាសម្រេចបានវឌ្ឍនភាពយ៉ាងធំធេងក្នុងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចជាតិ ទន្ទឹមនឹងការធានាបាននូវសន្តិភាពនិងសន្តិសុខទូទាំងប្រទេស, ស្ថិរភាពនយោបាយ, ការរក្សាបានកំណើនប្រកបដោយចីរភាពនិងធន់នឹងវិបត្តិ, ការកាត់បន្ថយភាពក្រីក្រ, ការបង្កើតការងារជូនប្រជាជននិងការពង្រឹងសមត្ថភាពស្ថាប័នសាធារណៈ តាមរយៈការដាក់ឱ្យអនុវត្តនិងកែលម្អជាបន្តបន្ទាប់នូវក្របខ័ណ្ឌគោលនយោបាយ ព្រមទាំងយន្តការសំខាន់ៗ ដើម្បីឈានទៅសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ក៏ដូចជាការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់៧% និងការសម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រឱ្យស្ថិតនៅក្រោម១០%។

ក្នុងន័យនេះ ដើម្បីរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាពនិងបរិយាបន្ន រាជរដ្ឋាភិបាលបានដាក់ចេញ និងកំពុងអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មីរបស់កម្ពុជា ផ្តោតសំខាន់លើការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព ស្របតាមបរិបទនៃការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និងសភាពការណ៍ប្រែប្រួលនៃភូមិសាស្ត្រនយោបាយ និងនិម្នាបនកម្មសេដ្ឋកិច្ចតំបន់និងពិភពលោក។ គោលនយោបាយនេះ បានដាក់ចេញនូវយុទ្ធសាស្ត្រគន្លឹះ វិធានការ និងផែនការសកម្មភាពដែលផ្សារភ្ជាប់ជាមួយគោលបំណងនិងគោលដៅដែលត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ២០២៥។ ក្នុងគោលបំណងធានាឱ្យបាននូវវឌ្ឍនភាពជាប្រចាំ ប្រកបដោយប្រសិទ្ធភាពនិងសង្គតិភាព រាជរដ្ឋាភិបាលបានសម្រេចឱ្យមានយន្តការតាមដាននិងត្រួតពិនិត្យការអនុវត្ត តាមរយៈការរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយនេះ។

របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ គិតត្រឹមខែធ្នូ ឆ្នាំ២០១៦ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ បានបង្ហាញថា ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធបានដាក់

ចេញនូវវិធានការគោលនយោបាយ និងផែនការសកម្មភាពរបស់ខ្លួន ព្រមទាំងបានធ្វើសកម្មភាពជាក់ស្តែងក្នុងការអនុវត្តគោលនយោបាយនេះ ដោយសម្រេចបាននូវសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់ និងកំពុងស្ថិតនៅលើផ្លូវត្រូវឈានទៅសម្រេចបាននូវគោលដៅចម្បងៗរបស់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ នឹងបន្តជាគោលនយោបាយតាមវិស័យដ៏សំខាន់មួយ ដែលសំដៅជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា ដោយរួមចំណែកក្នុងការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាពនិងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។ ក្នុងស្មារតីនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងនាមជាស្ថាប័នសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ បានបន្តធ្វើការងារយ៉ាងសកម្ម ជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ ក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងអំពីខ្លឹមសារសំខាន់ៗនៃគោលនយោបាយនេះ ព្រមទាំងជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មនេះឱ្យទទួលបានលទ្ធផលជោគជ័យតាមការកំណត់។

ដើម្បីបន្តធានាវឌ្ឍនភាពជាប្រចាំ ប្រសិទ្ធភាព និងសង្គតិភាពនៃការអនុវត្តគោលនយោបាយនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានធ្វើការសម្របសម្រួល និងសហការយ៉ាងជិតស្និតជាមួយក្រសួង ស្ថាប័ន រដ្ឋ-បាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ក្នុងការរៀបចំនូវរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ក្នុងឆ្នាំ២០១៧-២០១៨។ រចនាសម្ព័ន្ធនៃសេចក្តីព្រាងរបាយការណ៍នេះ រួមមាន បញ្ជីពាក្យកាត់, ខ្លឹមសារសង្ខេបប្រតិបត្តិ និងផ្នែកខ្លឹមសារចំនួន៤គឺ÷ ១-សេចក្តីផ្តើម, ២-វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ ដែលចែកចេញជា ៣អនុផ្នែកទៀត រួមមាន (២.១) បច្ចុប្បន្នភាពនៃសូចនាករសម្រាប់គោលដៅទាំង៣, (២.២.) វឌ្ឍនភាពនៃការអនុវត្តវិធានការគន្លឹះបួនជាក់ស្តែង គិតត្រឹមដំណាច់ឆ្នាំ២០១៨ និង (២.៣) វឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ និងផែនការសកម្មភាព ក្នុងឆ្នាំ២០១៧-២០១៨, ៣-បញ្ហាប្រឈម និងហានិភ័យនៃការអនុវត្តគោលនយោបាយ និង ៤-សេចក្តីសន្និដ្ឋាន ព្រមទាំងមានឧបសម្ព័ន្ធចំនួន២ ផងដែរ។

## ២. វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ

### ២.១. បច្ចុប្បន្នភាពនៃសូចនាករសម្រាប់គោលដៅទាំង៣

*គោលដៅទី១ នៃគោលនយោបាយ គឺការកែប្រែនិងពង្រីករចនាសម្ព័ន្ធឧស្សាហកម្មក្នុងសេដ្ឋកិច្ចជាតិ ដោយបង្កើនអនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស ឱ្យបាន៣០% នៅឆ្នាំ២០២៥ ក្នុងនោះវិស័យកម្មន្តសាល ត្រូវកើនដល់ ២០%។* ជាក់ស្តែង អនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស បានកើនឡើងពី ២៧,៧% នៅឆ្នាំ

២០១៥ ដល់ ៣២,៦% នៅឆ្នាំ២០១៨ ពោលគឺសម្រេចបានមុនគោលដៅដែលបានកំណត់នៅឆ្នាំ២០២៥ (សូមមើលតារាងទី១)។ ដោយឡែក អនុបាតវិស័យកម្មន្តសាលក្នុងផ.ស.ស បានកើនឡើងបន្តិចពី ១៦,០% នៅឆ្នាំ២០១៥ ដល់ ១៦,៣% នៅឆ្នាំ២០១៨ ដោយកំណើននេះមានលក្ខណៈយឺត បើធៀបនឹងគោលដៅឆ្នាំ ២០២៥។ យ៉ាងណាក្តី តួលេខទាំងនេះអាចបង្ហាញថា កម្ពុជាកំពុងកែប្រែនិងបន្តពង្រឹងរចនាសម្ព័ន្ធឧស្សាហកម្ម ដោយងាកចេញជាបណ្តើរៗពីការពឹងផ្អែកសំខាន់លើវិស័យកសិកម្ម ឆ្ពោះទៅការធ្វើឧស្សាហូបនីយកម្មនៃមូលដ្ឋានសេដ្ឋកិច្ច ដែលនឹងពន្លឿនការអភិវឌ្ឍឱ្យឈានឆ្ពោះទៅដល់កម្រិតថ្មីមួយទៀត។

**តារាងទី១÷ ការបែងចែក ផ.ស.ស តាមវិស័យ**

| វិស័យ | ១៩៩៨ | ២០១៣ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | គោលដៅ ២០២០ | គោលដៅ ២០២៥ |
|---|---|---|---|---|---|---|---|---|
| កសិកម្ម | ៤៤,៥% | ៣១,៦% | ២៦,៦% | ២៤,៧% | ២៣,៤% | ២២,២% | ២៥% | ២៣% |
| ឧស្សាហកម្ម | ១៦,៧% | ២៤,១% | ២៧,៧% | ២៩,៥% | ៣០,៩% | ៣២,៦% | ២៨% | ៣០% |
| *- កម្មន្តសាល* | *១២,៧%* | *១៥,៥%* | *១៦,០%* | *១៦,០%* | *១៦,២%* | *១៦,៣%* | *១៨%* | *២០%* |
| សេវាកម្ម | ៣៤,៨% | ៣៨,៥% | ៣៩,៨% | ៣៩,៩% | ៣៩,៧% | ៣៩,៣% | ៤០% | ៤០% |
| ឧបត្ថម្ភធនទុននិងពន្ធ | ៤% | ៥,៨% | ៥,៩% | ៥,៩% | ៦,១% | ៦,០% | ៧% | ៧% |

*កំណត់សម្គាល់÷ ទិន្នន័យចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ទទួលបានពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

*គោលដៅទី២ នៃគោលនយោបាយ គឺការបង្កើននិងពិពិធកម្មមុខទំនិញនាំចេញ ដោយបង្កើនការនាំចេញទំនិញកម្មន្តសាល (មិនមែនវាយនភណ្ឌ) ឱ្យបាន១៥%នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥ ទន្ទឹមនឹងការជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឱ្យបាន១២%នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥។* ជាក់ស្តែង ចំណែកនៃការនាំចេញសម្លៀកបំពាក់និងស្បែកជើងមានការថយចុះជាលំដាប់ពី៧១,៦% នៃបរិមាណនាំចេញសរុប នៅឆ្នាំ២០១៥ មកត្រឹម៦៩,២% នៅឆ្នាំ២០១៨។ ដោយឡែក ការនាំចេញទំនិញកម្មន្តសាលមិនមែនសម្លៀកបំពាក់និងស្បែកជើង មានកំណើនគួរឱ្យកត់សម្គាល់ពី៥,៦% នៃបរិមាណនាំចេញសរុប នៅឆ្នាំ២០១៥ ដល់ ១៣,៣% នៅឆ្នាំ២០១៨ ពោលគឺសម្រេចបានប្រមាណ៨៨,៦% បើធៀបនឹងគោលដៅឆ្នាំ២០២៥ (សូមមើលតារាងទី២)។ ទន្ទឹមនឹងនេះ ការនាំចេញកសិផលកែច្នៃ ក៏មានការកើនឡើងពី៥,៩% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០១៥ ដល់៧,០% នៅឆ្នាំ២០១៨ ពោលគឺសម្រេចបានប្រមាណ៥៨,៣% បើធៀបនឹងគោលដៅឆ្នាំ២០២៥។ ទិន្នន័យទាំងនេះ ឆ្លុះបញ្ចាំងឱ្យឃើញថា កម្ពុជាបាន និងកំពុងធ្វើពិពិធកម្មមុខទំនិញនាំចេញរបស់ខ្លួនជាបន្តបន្ទាប់ និងបន្តជំរុញកំណើននៃការនាំចេញកសិផលកែច្នៃឱ្យបានកាន់តែសម្បូរបែប ដោយមិនពឹងផ្អែកតែទៅលើការនាំចេញទំនិញកម្មន្តសាលផ្នែកសម្លៀកបំពាក់ និងស្បែកជើងនោះទេ។

**តារាងទី២÷ ចំណែកនៃមុខទំនិញនាំចេញ**

| វិស័យ | ១៩៩៨ | ២០១៣ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | គោលដៅ ២០២០ | គោលដៅ ២០២៥ |
|---|---|---|---|---|---|---|---|---|
| ការនាំចេញកសិផលកែច្នៃ | ១០% | ៧,៩% | ៥,៩% | ៥,២% | ៦,៩% | ៧,០% | ១០% | ១២% |
| កម្មន្តសាល | | | | | | | | |
| *- សម្លៀកបំពាក់និងស្បែកជើង* | ៨០% | ៧៥,៩% | ៧១,៦% | ៧១,៧% | ៧០,៤% | ៦៩,២% | ៥៥% | ៥០% |
| *- មិនមែនសម្លៀកបំពាក់និងស្បែកជើង* | ០,១% | ៥,០% | ៥,៦% | ៤,៤% | ១១,៦% | ១៣,៣% | ១០% | ១៥% |

*កំណត់សម្គាល់÷ ទិន្នន័យចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ទទួលបានពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

*គោលដៅទី៣ នៃគោលនយោបាយ គឺនៅឆ្នាំ២០២៥ សហគ្រាសធុនតូចនិងមធ្យម៨០% និង ៩៥% រៀងគ្នា នឹងត្រូវបានចុះបញ្ជីជាផ្លូវការ ហើយសហគ្រាសធុនតូចនិងមធ្យម៥០% និង៧០% រៀងគ្នា នឹងមានបញ្ជិកាគណនេយ្យនិងតារាងតុល្យការត្រឹមត្រូវ។* ជាក់ស្តែង ការចុះបញ្ជីផ្លូវការនៃសហគ្រាសធុនតូច មធ្យម និងធំ មានការកើនឡើងពី ៣៧%, ៧២% និង៩៣% រៀងគ្នា នៅឆ្នាំ២០១០ ដល់ ៧៦%, ៨៧% និង ៩៨% រៀងគ្នា នៅឆ្នាំ២០១៨ ពោលគឺខិតជិតសម្រេចបានតាមគោលដៅឆ្នាំ២០២៥ (សូមមើលតារាងទី៣)។ សហគ្រាសធុនមធ្យមដែលមានតារាងតុល្យការ បានកើនឡើងពី ២៤% ក្នុងឆ្នាំ២០១០ ដល់ ៧២% ក្នុងឆ្នាំ ២០១៨ លើសពីគោលដៅឆ្នាំ២០២៥ ទៅទៀត ខណៈដែលសហគ្រាសធុនតូច និងធុនធំដែលមានតារាង តុល្យការ ក៏បានកើនឡើងផងដែរពី ៤% និង៦៦% រៀងគ្នាក្នុងឆ្នាំ២០១០ ដល់ ២៨% និង៨៧% រៀងគ្នា ក្នុងឆ្នាំ២០១៨។ ទោះជាយ៉ាងណាក្តី កំណើននៃការចុះបញ្ជីផ្លូវការនៃសហគ្រាសធុនតូចនិងមធ្យម បាន បង្ហាញពីការយល់ដឹងកាន់តែច្រើនរបស់សហគ្រាសធុនតូចនិងមធ្យម អំពីសារៈសំខាន់នៃការចុះបញ្ជីផ្លូវការ ដើម្បីពង្រឹងអភិបាលកិច្ចអាជីវកម្ម, បង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទាន និងជាមូលដ្ឋានវាយតម្លៃសម្រាប់ ទទួលបានការគាំទ្រផ្នែកបច្ចេកទេស ឬការលើកទឹកចិត្តផ្សេងៗពីរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា។

**តារាងទី៣÷ អត្រាក្រុមហ៊ុនផ្លូវការបានចុះបញ្ជី និងមានតារាងតុល្យការ**

| ទំហំ/ប្រភេទសហគ្រាស | បានចុះបញ្ជីផ្លូវការ | | | | | | មានតារាងតុល្យការ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១០ | ២០១៦ | ២០១៧ | ២០១៨ | គោលដៅ ២០២០ | គោលដៅ ២០២៥ | ២០១០ | ២០១៦ | ២០១៧ | ២០១៨ | គោលដៅ ២០២០ | គោលដៅ ២០២៥ |
| ធុនតូច | ៣៧% | N/A | N/A | ៧៦% | ៧០% | ៨០% | ៤% | ២៤% | ២៩% | ២៨% | ៣០% | ៥០% |
| ធុនមធ្យម | ៧២% | N/A | N/A | ៨៧% | ៨០% | ៩៥% | ២៤% | ៧៥% | ៧១% | ៧២% | ៥០% | ៧០% |
| ធុនធំ | ៩៣% | ៩៦% | ៩៨% | ៩៨% | ១០០% | ១០០% | ៦៦% | ៨៥% | ៨៦% | ៨៧% | ១០០% | ១០០% |

*កំណត់សម្គាល់÷ - ទិន្នន័យសហគ្រាសដែលបានចុះបញ្ជីផ្លូវការចាប់ពីឆ្នាំ២០១៦-២០១៨ ទទួលបានពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម*

*- ទិន្នន័យសហគ្រាសដែលមានតារាងតុល្យការចាប់ពីឆ្នាំ២០១៦-២០១៨ ទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*- N/A: គ្មានទិន្នន័យ*

## ២.២. វឌ្ឍនភាពនៃការអនុវត្តវិធានការគន្លឹះបួនជាក់ស្តែង គិតត្រឹមដំណាច់ឆ្នាំ២០១៨

បន្ថែមលើវឌ្ឍនភាពនៃគោលដៅចម្បងទាំងបីខាងលើ ក្រសួង ស្ថាប័នពាក់ព័ន្ធ បានសម្រេចនូវវឌ្ឍនភាពមួយចំនួនទាក់ទងនឹងវិធានការជាក់ស្តែងគន្លឹះបួនយ៉ាង ដែលក្រសួង ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្តបានធ្វើការវាយតម្លៃ និងកំណត់ជានិទ្ទេសចំនួន៤កម្រិត (កម្រិតទី១ សម្រេចបានពេញលេញ, កម្រិតទី២ សម្រេចបានភាគច្រើន, កម្រិតទី៣ សម្រេចបានដោយផ្នែក, កម្រិតទី៤ មានការយឺតយ៉ាវ)។

វឌ្ឍនភាពនៃការអនុវត្តវិធានការទាំងនេះ មានដូចខាងក្រោម៖

### ២.២.១- វិធានការទី១ - *"រៀបចំនិងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនីសម្រាប់វិស័យឧស្សាហកម្មនិងពាណិជ្ជកម្ម រួមទាំងការពង្រឹងភាពទុកចិត្តនិងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី"*

រាជរដ្ឋាភិបាលបានអនុម័តផែនការបន្ថយថ្លៃលក់អគ្គិសនីបន្ថែមទៀតតាមបណ្តាខេត្តនិងរាជធានី (២០១៧-២០២០) បន្ថែមពីលើផែនការយុទ្ធសាស្ត្រកាត់បន្ថយអត្រានិងតម្លាតថ្លៃលក់អគ្គិសនី សម្រាប់ឆ្នាំ ២០១៥-២០២០ ដែលបានដាក់ចេញកាលពីឆ្នាំ២០១៥។ បន្ថែមលើផែនការដែលបានកែសម្រួលនេះ នៅខែតុលា ឆ្នាំ២០១៨ រាជរដ្ឋាភិបាល តំណាងដោយក្រសួងរ៉ែនិងថាមពល បានចេញប្រកាសស្តីពីការកែសម្រួលអត្រាថ្លៃលក់អគ្គិសនីឡើងវិញ នៅក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រានិងតម្លាតថ្លៃលក់អគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ការអនុវត្តបន្តពីឆ្នាំ២០១៩-២០២០។ កម្មវិធីបន្ថយថ្លៃតាមឆ្នាំ ក្នុងឆ្នាំ២០១៧ បានកាត់បន្ថយនិងអនុគ្រោះចំពោះអ្នកប្រើប្រាស់ប្រភេទឧស្សាហកម្មនិងពាណិជ្ជកម្មធំៗ ក្នុងតម្លៃត្រឹមតែ ១២,៦០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោងសម្រាប់ការទិញពីអនុស្ថានីយផ្ទាល់, ១៦,៧០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោងសម្រាប់ការទិញពីបណ្តាញភ្នំពេញ និង១៦,៥០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោងសម្រាប់ការទិញពីបណ្តាញតាមខេត្ត។ សម្រាប់ឆ្នាំ២០១៨ ការទិញពីបណ្តាញភ្នំពេញថយចុះមកត្រឹម ១៦,៥០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោងនិង១៦,៤០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការទិញពីបណ្តាញតាមខេត្ត។ លើសពីនេះ រាជរដ្ឋាភិបាលបានកំណត់បញ្ជីថ្លៃលក់អគ្គិសនីតាមពេលវេលាដែលជាជម្រើសថ្លៃមួយទៀតសម្រាប់អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម ពាណិជ្ជកម្ម និងកសិកម្មក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ដោយបែងចែកអត្រាថ្លៃលក់ជា២ប្រភេទទៅតាមពេលវេលាថ្ងៃយប់ ព្រមទាំងបានកំណត់អត្រាថ្លៃលក់អគ្គិសនីពិសេសនៅរដូវវស្សាផងដែរ។

តារាងខាងក្រោម បង្ហាញពីតារាងជាក់ស្តែងនៃការបន្ថយថ្លៃលក់អគ្គិសនីសម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ នៅក្នុងតំបន់ដែលមានប្រភពអគ្គិសនីរបស់បណ្តាញជាតិគ្របដណ្តប់៖

| ប្រភេទនៃការទិញ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ |
|---|---|---|
| **១- សម្រាប់អ្នកប្រើប្រាស់ធំៗ គ្រប់ប្រភេទ ទិញអគ្គិសនីពីអនុស្ថានីយ** | | |
| ទិញតាមទ្វារចរន្តតង់ស្យុងខ្ពស់ | 0,១២៥0$ | |

| ប្រភេទនៃការទិញ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ |
|---|---|---|
| ទិញតាមទ្វារចរន្តតង់ស្យុងមធ្យមនៅអនុស្ថានីយ តាមខេត្ត | 0,១២៦0$ | |
| ទិញតាមទ្វារចរន្តតង់ស្យុងមធ្យមនៅអនុស្ថានីយក្នុងរាជធានីភ្នំពេញ | 0,១៤៩៥$ | 0,១៤៧៥$ |
| **២- សម្រាប់អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម** | | |
| ទិញតាមខ្សែបញ្ជូនរងនិងតាមខ្សែតង់ស្យុងមធ្យមនៃតំបន់ចែកចាយ | ភ្នំពេញ 0,១៦៧0$<br>ខេត្ត 0,១៦៥0$ | ភ្នំពេញ 0,១៦៥0$<br>ខេត្ត 0,១៦៤0$ |
| ទិញក្រោមត្រង់ស្វូដែលបានវិនិយោគដោយខ្លួនឯង | ភ្នំពេញ 0,១៧១0$<br>ខេត្ត 0,១៧១៩$ | 0,១៧0៦$ |
| ទិញក្រោមត្រង់ស្វូដែលឱ្យអ្នកផ្គត់ផ្គង់វិនិយោគ | ភ្នំពេញ 0,១៧៩0$<br>ខេត្ត 0,១៨១៩$ | 0,១៧៨៦$ |
| **៣- សម្រាប់អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្មធំៗនិងរដ្ឋបាល** | | |
| ទិញតាមខ្សែបញ្ជូនរងនិងតាមខ្សែតង់ស្យុងមធ្យមនៃតំបន់ចែកចាយ | ភ្នំពេញ 0,១៦៧0$<br>ខេត្ត 0,១៦៥0$ | ភ្នំពេញ 0,១៦៥0$<br>ខេត្ត 0,១៦៤0$ |
| ទិញក្រោមត្រង់ស្វូដែលបានវិនិយោគដោយខ្លួនឯង | ភ្នំពេញ 0,១៧១0$<br>ខេត្ត 0,១៧១៩$ | 0,១៧0៦$ |
| ទិញក្រោមត្រង់ស្វូដែលឱ្យអ្នកផ្គត់ផ្គង់វិនិយោគ | ភ្នំពេញ 0,១៧៩0$<br>ខេត្ត 0,១៨១៩$ | 0,១៧៨៦$ |

ចំពោះការពង្រីកវិសាលភាពគ្រប់ដណ្តប់និងការពង្រឹងភាពទុកចិត្តនៃការផ្គត់ផ្គង់អគ្គិសនី រាជរដ្ឋាភិបាលបានសាងសង់ខ្សែបណ្តាញមេចេញពីអនុស្ថានីយដើម្បីរំលែកបន្ទុកពីខ្សែចាស់ដែលមានបន្ទុកធ្ងន់ ក្នុងគោលដៅបង្កើនស្ថិរភាពក្នុងការផ្គត់ផ្គង់ជូនរោងចក្រឧស្សាហកម្មក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ ព្រមទាំងបាននិងកំពុងបង្កើនប្រភពផ្គត់ផ្គង់អគ្គិសនីដែលរួមមាន (១) ការដាក់ឱ្យដំណើរការស្ថានីយអគ្គិសនីដុតធ្យូងថ្មអានុភាព ១៣៥មេហ្គាវ៉ាត់, (២) ការដាក់ឱ្យដំណើរការស្ថានីយអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព ១0មេហ្គាវ៉ាត់, (៣) ការដាក់ឱ្យដំណើរការស្ថានីយវារីអគ្គិសនីសេសានក្រោម២ អានុភាពសរុប ៤00មេហ្គាវ៉ាត់, (៤) ការដាក់ឱ្យដំណើរការអនុស្ថានីយទួលពង្រ (GS8) អានុភាព ៧៥មេហ្គាវ៉ាត់ ដើម្បីជួយបង្កើនការផ្គត់ផ្គង់ដល់តំបន់ឧស្សាហកម្មនៅវែងស្រេង និងទួលពង្រ, (៥) ការពង្រីកការផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ធុនធំដែលភ្ជាប់ចេញពីទ្វារចរន្តតង់ស្យុងខ្ពស់ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងរោងចក្រស៊ីម៉ងត៍ ខនស៍ (Conch) នៅស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង, (៦) បាននិងកំពុងសាងសង់អនុស្ថានីយនៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ អានុភាពសរុប ៥0មេហ្គាវ៉ាត់, (៧) បន្ថែមកម្លាំងត្រង់ស្វូរតាមបណ្តាអនុស្ថានីយក្នុង

រាជធានីភ្នំពេញនិងខេត្តក្រុងសំខាន់ៗ ដែលជាទិសដៅអាទិភាព ដើម្បីបង្កើនសមត្ថភាពនិងស្ថិរភាពក្នុងការផ្គត់ផ្គង់ជូនអតិថិជន ដែលនឹងគ្រោងដាក់ឱ្យដំណើរការក្នុងឆ្នាំ២០១៩, (៨) បន្តតាមដាននិងដោះស្រាយបញ្ហាដាច់ចរន្តអគ្គិសនីញឹកញាប់ និងបញ្ហាធ្លាក់គុណភាពខ្សែបណ្តាញ, និង (៩) សិក្សាអំពីលទ្ធភាពក្នុងការបន្ថយថ្លៃលក់អគ្គិសនីបន្ថែមសម្រាប់ឆ្នាំ២០១៩ និង២០២០។

ជារួម លទ្ធផលការងារនៃការអនុវត្តវិធានការគន្លឹះទី១ នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលសម្រេចជាក់ស្តែងត្រឹមដំណាច់ឆ្នាំ២០១៨ គឺស្ថិតក្នុងកម្រិតទី១ ពោលគឺ "**សម្រេចបានពេញលេញ**" ស្របតាមគោលដៅដែលបានកំណត់នៅក្នុងសូចនាករនៃវិធានការនេះ រួមមាន ១. ការរៀបចំនិងការអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនីសម្រាប់វិស័យឧស្សាហកម្មនិងពាណិជ្ជកម្ម និង ២. ការពង្រឹងភាពជឿទុកចិត្ត និងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនីឱ្យដល់គ្រប់តំបន់ឧស្សាហកម្មគោលដៅ (គិតត្រឹមឆ្នាំ២០១៨ ដោយផ្តោតលើតំបន់សេដ្ឋកិច្ចពិសេសស្របតាមការកំណត់នៃផែនការគ្រោងទុក)។

**២.២.២- វិធានការទី២** - *"រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម"*

ក្នុងទិសដៅជំរុញការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានភាពប្រកួតប្រជែងនិងប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលបានរៀបចំធ្វើកំណែទម្រង់ស៊ីជម្រៅស្របពេលជាមួយគ្នា ទាំងក្នុងក្របខ័ណ្ឌស្ថាប័ន ទាំងក្នុងក្របខ័ណ្ឌគោលនយោបាយ។ ក្នុងក្របខ័ណ្ឌស្ថាប័ន រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាជាតិភស្តុភារកម្ម ដែលជាក្រុមប្រឹក្សាសម្រាប់បង្កើតឡើងនូវគោលនយោបាយ គណៈកម្មាធិការជាតិភស្តុភារកម្ម ដែលជាគណៈកម្មាធិការសម្រាប់អនុវត្តគោលនយោបាយ និងអគ្គនាយកដ្ឋានភស្តុភារកម្មនៃក្រសួងសាធារណការនិងដឹកជញ្ជូន ដែលជាសេនាធិការក្នុងការសម្របសម្រួលលើកិច្ចការឡូជីស្ទីកនិងដឹកជញ្ជូននេះ។ នៅក្នុងក្របខ័ណ្ឌគោលនយោបាយ រាជរដ្ឋាភិបាលបានបញ្ចប់ការសិក្សាផែនការមេស្តីពីការកែលម្អប្រព័ន្ធភស្តុភារកម្មនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨-២០២៥ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តក្នុង៣ដំណាក់កាល រយៈពេលខ្លី (២០១៨-២០១៩), រយៈពេលមធ្យម (២០២០-២០២២) និងរយៈពេលវែង (២០២៣-២០២៥) និងបានបញ្ចប់សេចក្តីព្រាងផែនការមេថ្នាក់ជាតិស្តីពីការដឹកជញ្ជូននិងភស្តុភារកម្ម។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បាននិងកំពុងអនុវត្តគម្រោងសហប្រតិបត្តិការបច្ចេកទេសជាមួយដៃគូអភិវឌ្ឍជាច្រើន ក្នុងការអនុវត្តគម្រោងនានាដូចជា÷ គម្រោងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធភស្តុភារកម្ម, គម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេស ដើម្បីរៀបចំផែនការមេបណ្តុះបណ្តាលក្នុងវិស័យភស្តុភារកម្ម និងគម្រោងពិនិត្យឡើងវិញលើក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តនៅក្នុងវិស័យភស្តុភារកម្ម ព្រមទាំងការសិក្សាបុរេសមិទ្ធិលទ្ធភាពនៃគម្រោងអភិវឌ្ឍន៍មជ្ឈមណ្ឌលភស្តុភារកម្មចំនួន ២កន្លែង ក្នុងនោះរួមមាន (១) គម្រោង

សិក្សាអភិវឌ្ឍន៍មជ្ឈមណ្ឌលភស្តុភារកម្មក្រុងព្រះសីហនុ និង (២) គម្រោងសិក្សាអភិវឌ្ឍន៍មជ្ឈមណ្ឌលភស្តុភារកម្មភ្នំពេញ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បាននិងកំពុងរៀបចំការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រចាំបាច់នានា ដើម្បីតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និងអភិវឌ្ឍរបៀងសេដ្ឋកិច្ច ភ្នំពេញ-ខេត្តព្រះសីហនុ, និងភ្នំពេញ-បាវិត, ដែលក្នុងនោះរួមមាន (១) ការដំណើរការសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន និង (២) ការបញ្ចប់ការសិក្សាសមិទ្ធិលទ្ធភាពលើគម្រោងសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-បាវិត និងកំពុងស្ថិតក្នុងដំណាក់កាលពិភាក្សាលើតម្លៃនៃគម្រោងនិងប្រភពថវិកា។

ជារួម រាជរដ្ឋាភិបាលបានសម្រេចជោគជ័យនូវសមិទ្ធផលការងារជាច្រើនក្នុងការអនុវត្តវិធានការទី២ នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ ដែលការអនុវត្តវិធានការនេះស្ថិតនៅកម្រិតទី២ ពោលគឺ “**សម្រេចបានភាគច្រើន**”។

ជាមួយនឹងសមិទ្ធផលខាងលើ ការងារនៅក្នុងវិស័យភស្តុភារកម្ម ដែលជាការងារមានលក្ខណៈអន្តរវិស័យ ទាមទារនូវកិច្ចសហការ និងការសម្របសម្រួលមួយកម្រិតថែមទៀត ទាំងក្នុងក្របខណ្ឌនៃការរៀបចំគោលនយោបាយ ផែនការ និងការអនុវត្ត។ ការកៀរគរប្រភពហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងពីផ្នែកឯកជន ដើម្បីគាំទ្រដល់ការអនុវត្តផែនការមេ និងការបន្តស្តារនិងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ក៏ជាកិច្ចការចាំបាច់មួយទៀត ដែលត្រូវមានការចូលរួមយ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធ។

សម្រាប់ទិសដៅការងារបន្ត រាជរដ្ឋាភិបាលនឹងជំរុញអនុវត្តការងារសំខាន់ៗមួយចំនួនដូចជា (១) បញ្ចប់ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយនិងភស្តុភារកម្ម នៅក្នុងឆ្នាំ២០២០ និងបន្តអនុវត្តដល់ឆ្នាំ២០៣០, (២) កំណត់អាទិភាពនៃផែនការសកម្មភាពនិងដាក់បញ្ចូលក្នុងផែនការវិនិយោគសាធារណៈ, (៣) កៀរគរធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍនិងពីវិស័យឯកជន ដើម្បីគាំទ្រដល់ការអនុវត្តផែនការមេអន្តរកាល ស្តីពីការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយនិងភស្តុភារកម្មឱ្យមានប្រសិទ្ធភាពខ្ពស់, (៤) បញ្ចប់ការសាងសង់ផ្លូវជាតិលេខ១០ ប្រវែង ១៩៨,៧១គ.ម ចាប់ពីសំឡូត វាលវែងអូរសោម ដល់កោះកុង នៅឆ្នាំ២០២៣, (៥) បន្តស្តារនិងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឱ្យបានយ៉ាងហោចប្រវែង ៧០០គ.ម.ក្នុងមួយឆ្នាំ, (៦) បន្តពង្រីកផ្លូវជាតិកម្រិត១ភ្ជាប់ទៅតំបន់អភិវឌ្ឍសំខាន់ៗ និងនៅជុំវិញទីក្រុងសំខាន់ៗពី ២គន្លងទៅ៤គន្លង, (៧) បន្តស្តារ សាងសង់ផ្លូវជាតិ ផ្លូវខេត្ត ភ្ជាប់ទៅតំបន់អភិវឌ្ឍឧស្សាហកម្ម កសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍ ដែលបានបង្កើតឡើង និងតាមតំបន់ព្រំដែន និង (៨) ជំរុញការសាងសង់ផ្លូវល្បឿនលឿន ដែលជាគម្រោងអាទិភាពផ្អែកលើផែនការមេនៃការអភិវឌ្ឍផ្លូវល្បឿនលឿននៅកម្ពុជា ដូចជាខ្សែផ្លូវរាជធានីភ្នំពេញ-ក្រុងព្រះសីហនុ, ភ្នំពេញ-បាវិត និងភ្នំពេញ-សៀមរាប។ គម្រោងផ្លូវល្បឿនលឿនរាជធានីភ្នំពេញ-ក្រុងព្រះសីហនុ ត្រូវបានគ្រោងថានឹងបញ្ចប់នៅឆ្នាំ២០២៣។

ដោយឡែក ចំពោះគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-បាវិត ក្រសួងសាធារណការនិងដឹកជញ្ជូន បានចុះកិច្ចព្រមព្រៀងក្របខ័ណ្ឌឱ្យក្រុមហ៊ុនឯកជនសិក្សាគម្រោងនេះ ខណៈភាគីវៀតណាមកំពុងរៀបចំការសាងសង់ផ្លូវល្បឿនលឿនហូជីមិញ-ម៉ុកបៃ ដើម្បីតភ្ជាប់ជាមួយកម្ពុជា ហើយនឹងខិតខំសាងសង់ឱ្យរួចរាល់ និងដាក់ឱ្យដំណើរការនៅក្នុងឆ្នាំ២០២៥។

**២.២.៣- វិធានការទី៣** - *"ពង្រឹង និងបន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្ម និងការបណ្តុះបណ្តាលជំនាញ"*

វិធានការទី៣ គឺជាវិធានការស្នូលដែលរាជរដ្ឋាភិបាលបាននិងកំពុងបន្តអនុវត្តរៀងមក សំដៅធ្វើយ៉ាងណាឱ្យកម្មករ និយោជិត មានជីវភាពសមរម្យ និងទទួលបាននូវលក្ខខណ្ឌការងារល្អប្រសើរជាងមុន ឱ្យស្របទៅនឹងកំណើនសេដ្ឋកិច្ច-ឧស្សាហកម្មរបស់កម្ពុជា។ រាជរដ្ឋាភិបាលបានបង្កើតយន្តការត្រីភាគីក្នុងការពិភាក្សានិងកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិត ក្នុងរយៈពេល ១ឆ្នាំម្តង។ ជាលទ្ធផលប្រាក់ឈ្នួលអប្បបរមាក្នុងឆ្នាំ២០១៧ មានចំនួន ១៥៣ដុល្លារ/ខែ និងឆ្នាំ២០១៨ មានចំនួន ១៧០ដុល្លារ/ខែ មានកំណើន ១៧ដុល្លារ។ ការដំឡើងនេះ មានអត្រាកំណើនខ្ពស់ជាងអត្រាអតិផរណាប្រចាំឆ្នាំ ព្រមទាំងបានរក្សានូវអត្ថប្រយោជន៍ផ្សេងៗចន្លោះពី១១ ទៅ១៧ដុល្លារ/ខែផងដែរ។ ខណៈចំនួនរោងចក្រផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង មានការកើនឡើងពីចំនួន១ ១០៧រោងចក្រនៅឆ្នាំ២០១៦ ដល់ចំនួន១ ១៥៩រោងចក្រនៅឆ្នាំ២០១៨ ចំនួនវិវាទការងារបានបន្តថយចុះពីចំនួន៨៥៣ករណីនៅឆ្នាំ២០១៦ មកនៅត្រឹម៦៩៣ករណីនៅឆ្នាំ២០១៧ និង៥៨៨ករណីនៅឆ្នាំ២០១៨ ហើយទន្ទឹមគ្នានេះ ការធ្វើកូដកម្មបានថយចុះពីចំនួន២៧០ករណីនៅឆ្នាំ២០១៦ មកនៅត្រឹម៩៧ករណីនៅឆ្នាំ២០១៧ និងមកនៅត្រឹម៤៧ករណីនៅឆ្នាំ២០១៨ផងដែរ។ លើសពីនេះ ដើម្បីជួយសម្រាលបន្ទុកចំណាយរបស់កម្មករ និយោជិត រាជរដ្ឋាភិបាលបានដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សដែលត្រូវជាប់ពន្ធ, ដំឡើងកម្រិតទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក ដើម្បីកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស, ដាក់ចេញនូវយន្តការអនុគ្រោះពន្ធលើប្រាក់បៀវត្ស ចំពោះអត្ថប្រយោជន៍បន្ថែមសម្រាប់ចំណាយលើការដឹកជញ្ជូន ស្នាក់នៅ និងហូបចុករបស់កម្មករនិយោជិត, និងយន្តការលើកលែងអាករលើតម្លៃបន្ថែម តាមរយៈការផ្គត់ផ្គង់មិនជាប់អាករលើទឹកស្អាត អគ្គិសនី និងសេវាសាធារណៈមួយចំនួនទៀត។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញនូវគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងយន្តការមួយចំនួនទៀតផងដែរ សំដៅពង្រឹងនិងពង្រីកការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈឱ្យកាន់តែមានប្រសិទ្ធភាព ក្នុងនោះរួមមាន (១) ការដាក់ឱ្យអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥, (២) ការដាក់ឱ្យអនុវត្តគម្រោងសាកល្បងមូលនិធិជាតិអភិវឌ្ឍជំនាញ ដើម្បីបង្កើនជំនាញ ទប់ស្កាត់ចំណាកស្រុកនិងចំណាកប្រទេស បង្កើនផលិតភាព និង

លើកកម្ពស់ជីវភាពរបស់ប្រជាជននៅទីជនបទ និង (៣) ការបង្កើនការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈរយៈពេលវែងតាមវិស័យអាទិភាព ទាំង៥រួមមានសំណង់ អគ្គិសនី មេកានិករថយន្ត កម្មន្តសាលធុរកិច្ចនិងព័ត៌មានវិទ្យា ដើម្បីគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្ម។ ជាមួយគ្នានេះ ក្នុងគោលបំណងកែលម្អស្ថិរភាពទីផ្សារពលកម្មនិងកាត់បន្ថយចំនួនវិវាទការងារ រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តកិច្ចការនិងសកម្មភាពគួរឱ្យកត់សម្គាល់មួយចំនួន រួមមាន (១) ការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារពាក់ព័ន្ធនឹងការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ក្នុងការដោះស្រាយទាន់ពេលវេលាចំពោះករណីរោងចក្រក្ស័យធនឬបិទទ្វារដោយថៅកែរត់ចោល, (២) ការពង្រឹងគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញានៅថ្នាក់ជាតិនិងថ្នាក់រាជធានីខេត្ត, និង (៣) ការធ្វើទំនើបកម្មនិងពង្រឹងយន្តការអធិការកិច្ចការងារតែមួយ ដើម្បីឱ្យកាន់តែមានប្រសិទ្ធភាពជាងមុន។

សរុបមក គិតត្រឹមឆ្នាំ២០១៨នេះ សូចនាករដែលបានកំណត់នៅក្នុងវិធានការទី៣ ត្រូវបានសម្រេចក្នុងកម្រិតទី២ ពោលគឺ “**សម្រេចបានភាគច្រើន**”។ វឌ្ឍនភាពដែលសម្រេចបានខាងលើនេះ បញ្ជាក់ឱ្យឃើញថា រាជរដ្ឋាភិបាលបានខិតខំធានានូវកម្រិតជីវភាពរស់នៅសមរម្យនិងលក្ខខណ្ឌការងារល្អប្រសើរសម្រាប់កម្មករ និយោជិត តាមរយៈការដំឡើងប្រាក់ឈ្នួលអប្បបរមាជាបន្តបន្ទាប់ ការកាត់បន្ថយចំនួនវិវាទការងារ និងការធ្វើទំនើបកម្មប្រព័ន្ធអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងជំនាញឱ្យកាន់តែល្អប្រសើរឡើង។

ទោះបីជាលទ្ធផលនៃវិធានការនេះ សម្រេចបានភាគច្រើនតាមសូចនាករដែលបានកំណត់ក្តី ចំណុចប្រឈមនៃការអនុវត្តវិធានការបន្តនេះ គឺកង្វះភាពចាស់ទុំ និងក្រមសីលធម៌នៃអង្គការវិជ្ជាជីវៈក្នុងការដោះស្រាយវិវាទការងារ និងការចរចាផ្សេងៗ។ រីឯចំនួនកម្មករជំនាញដែលទទួលបានបណ្តុះបណ្តាល នៅមានចំនួនតិច មិនទាន់ឆ្លើយតបបានទៅនឹងកម្រិតនៃការចង់បានដើម្បីទាក់ទាញគម្រោងវិនិយោគថ្មីៗ ជាពិសេសគម្រោងវិនិយោគផ្នែកគ្រឿងបង្គុំ និងសម្ភារបរិក្ខារអគ្គិសនី ហើយផលិតភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់ពេលវេលារបស់កម្មករនិយោជិត គឺនៅមានកម្រិតនៅឡើយ ដែលតម្រូវឱ្យមានការបណ្តុះបណ្តាលនិងបំប៉នបន្ថែម។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងនៅតែបន្តអនុវត្តវិធានការនេះ ដើម្បីពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ជំរុញការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈដែលឆ្លើយតបនឹងតម្រូវការនៃគម្រោងវិនិយោគថ្មី សំដៅបង្កើតឱកាសការងារកាន់តែច្រើន និងបង្កើនផលិតភាពនិងជំនាញពលកម្មដើម្បីរួមចំណែកក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

**២.២.៤- វិធានការទី៤** -*"អភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស"*

វិធានការទី៤ គឺជាវិធានការគន្លឹះសំខាន់ ដែលពាក់ព័ន្ធច្រើនទៅនឹងការកែប្រែយន្តការរដ្ឋបាល និងស្ថាប័នឱ្យស្របទៅនឹងគោលការណ៍តំបន់រដ្ឋបាលពិសេស ដែលទាមទារឱ្យមានការសម្របសម្រួលនិងសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅ មុននឹងដាក់ចេញនូវគោលនយោបាយនិងយន្តការចាំបាច់នានាឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល។ ក្នុងដំណើរការនៃការអភិវឌ្ឍនិងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងអនុវត្តកិច្ចការងារចំពោះមុខ ជាច្រើន ដូចជា (១) បានអនុម័តឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តព្រះសីហនុ និងផែនទីបណ្តាញផ្លូវថ្នល់ ឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ ក្នុងគោលបំណងកំណត់ចក្ខុវិស័យ និងយុទ្ធសាស្ត្រតម្រង់ទិសនៃការប្រើប្រាស់ដី និងការអភិវឌ្ឍផ្ទៃក្រុងបវន្ត ដោយផ្អែកលើសក្តានុពលនៃភូមិសាស្ត្រ និងតំបន់នីមួយៗក្នុងខេត្តព្រះសីហនុ និង (២) បានសហការជាមួយវិទ្យាស្ថាននគរូបនីយកម្ម និងឌីសាញស៊ិនជិន ក្នុងការសិក្សាលើការរៀបចំផែនការមេ ដើម្បីអភិវឌ្ឍនិងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដោយមានការគាំទ្រ និងសហការសម្របសម្រួលពីអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍឧស្សាហកម្ម។ ក្រៅពីកិច្ចការទាំងនេះ រាជរដ្ឋាភិបាលក៏បានអនុវត្តសកម្មភាពគាំទ្រមួយចំនួនទៀត ដូចជា (១) បានកំពុងធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ខេត្តព្រះសីហនុ ២០១៦-២០២៥ ទៅជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ខេត្តព្រះសីហនុ ២០២០-២០២៥, (២) បានកំពុងរៀបចំផែនការសកម្មភាពឆ្នាំ២០២៣-២០២៥ លើវិស័យអាកាសចរស៊ីវិល ដើម្បីចូលរួមអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពហុបំណង និង (៣) បាននិងកំពុងរៀបចំហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍និងបច្ចេកវិទ្យាព័ត៌មាន ដោយកសាងបណ្តាញខ្សែកាប្លិ៍អុបទិកទូទាំងប្រទេស និងបានដាក់ឱ្យដំណើរការគម្រោងខ្សែកាប្លិ៍ក្រោមបាតសមុទ្រ ដែលតភ្ជាប់កម្ពុជា តាមរយៈខេត្តព្រះសីហនុទៅអន្តរជាតិ។

ផ្អែកតាមសកម្មភាពដែលសម្រេចបានខាងលើ ការអនុវត្តវិធានការនេះ អាចត្រូវបានចាត់ទុកថាសម្រេចបានក្នុងកម្រិតទី៤ ពោលគឺ "**មានការយឺតយ៉ាវ**" ដោយសារតែការរៀបចំផែនការមេជាក់ស្តែងនៅមិនទាន់សម្រេចបានតាមសូចនាករដែលបានកំណត់និងទាមទារឱ្យមានការគិតគូរឱ្យបានល្អិតល្អន់ជាមុន លើគ្រប់ទិដ្ឋភាព ក្នុងនោះរួមមាន ទិដ្ឋភាពគោលនយោបាយ ទិដ្ឋភាពច្បាប់ រួមទាំងផែនការប្រតិបត្តិក្នុងកម្រិតបច្ចេកទេសនិងការអនុវត្តសកម្មភាពគាំទ្រនានា។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាល តាមរយៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងពិនិត្យ និងជំរុញអនុវត្តបន្ថែមទៀត នូវការងារពាក់ព័ន្ធនឹងការរៀបចំផែនការមេ ដើម្បីអភិវឌ្ឍនិងប្រែក្លាយខេត្តព្រះសីហនុឱ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូ

ពហុបំណងនិងជាប៉ូលសេដ្ឋកិច្ច មជ្ឈមណ្ឌលឧស្សាហកម្ម ពាណិជ្ជកម្មនិងទេសចរណ៍ ស្របតាមទស្សនទាននៃការអភិវឌ្ឍប្រកបដោយចីរភាពនិងមេត្រីភាពបរិស្ថាន។

សម្រាប់ទិសដៅបន្ត គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងសហការជាមួយវិទ្យាស្ថានផែនការនគរូបនីយកម្មនិងរចនាបថទីក្រុងស៊ិនជិន នៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីសិក្សាលើការរៀបចំផែនការមេនេះ ព្រមទាំងរៀបចំឯកសារគតិយុត្តក្នុងការបង្កើតក្រុមប្រឹក្សាកម្រិតគោលនយោបាយ គណៈកម្មាធិការកម្រិតបច្ចេកទេស និងក្រុមការងារបច្ចេកទេស។

## ២.៣- វឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ និងផែនការសកម្មភាព ក្នុងឆ្នាំ ២០១៧-២០១៨

### ២.៣.១- ការជំរុញការទាក់ទាញវិនិយោគ

#### ក- បរិយាកាសវិនិយោគ

ក្នុងរយៈពេលកន្លងមកនេះ ក្នុងចំណោមវិធានការគោលនយោបាយចំនួន១០ ដែលពាក់ព័ន្ធទៅនឹង "បរិយាកាសវិនិយោគ" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើនដូចខាងក្រោម÷

#### ក.១- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្នុងក្របខណ្ឌនៃការរៀបចំក្របខណ្ឌច្បាប់គតិយុត្ត សំដៅធ្វើឱ្យកម្ពុជាក្លាយជាគោលដៅវិនិយោគដែលកាន់តែភាពអំណោយផល និងអនុគ្រោះ ក.អ.ក បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ថ្មីស្តីពីវិនិយោគក្នុងកម្រិតបច្ចេកទេស ដោយបានគិតគូរអំពី (១) ការផ្តល់ការលើកទឹកចិត្តដល់វិស័យអាទិភាព ការផ្ទេរបច្ចេកវិទ្យា ការបង្កើតការងារ ការបណ្តុះបណ្តាញជំនាញបច្ចេកទេស ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍនវានុវត្តន៍ និងសហគ្រាសធុនតូចនិងមធ្យមដែលមានសក្តានុពល និង (២) លក្ខខណ្ឌវិនិច្ឆ័យនានាសម្រាប់ទាក់ទាញគម្រោងវិនិយោគដែលមានសក្តានុពល និងគុណភាព។ ទន្ទឹមនឹងនេះ ក.អ.ក ដោយសហការជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បាននិងកំពុងធ្វើការសិក្សាស៊ីជម្រៅលើវិស័យអេឡិចត្រូនិក និងផលិតកម្មគ្រឿងបន្លាស់យានយន្ត ក្នុងគោលបំណងដាក់ចេញនូវយុទ្ធសាស្ត្រវិនិយោគចំគោលដៅ ដើម្បីទាក់ទាញគម្រោងវិនិយោគដែលមានតម្លៃបន្ថែមខ្ពស់ ជាពិសេសគម្រោងវិនិយោគក្នុងវិស័យអេឡិចត្រូនិក និងផលិតកម្មគ្រឿងបន្លាស់យានយន្ត។

ក្នុងក្របខណ្ឌពង្រឹងយន្តការស្ថាប័ន ក.អ.ក បានបន្តធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃយន្តការច្រកចេញ-ចូលតែមួយ និងការផ្តល់សេវាសាធារណៈរបស់ ក.អ.ក តាមរយៈ÷ (១) ការតាមដាន និងវិភាគនូវប្រសិទ្ធភាពនៃការផ្តល់សេវាបច្ចុប្បន្ន និងដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដូចជា ការកំណត់សេវាអាទិភាព, (២) ការបង្កើតយន្តការទទួលបណ្តឹងតវ៉ាពីសំណាក់អ្នកវិនិយោគ ពាក់ព័ន្ធនឹងការទទួលសេវានៅ ក.អ.ក, (៣) ការចុះត្រួតពិនិត្យការអនុវត្តគម្រោងវិនិយោគនានា និងធ្វើបច្ចុប្បន្នភាពគម្រោងវិនិយោគដែលបានបិទ

ព្រមទាំងទិន្នន័យវិនិយោគជាប្រចាំ, (៤) ការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ ដែលបម្រើឱ្យការអនុវត្តសេវាថែទាំការវិនិយោគ (Aftercare Service) ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់កិច្ចសម្រួលការវិនិយោគ និងដោះស្រាយបញ្ហាប្រឈមរបស់អ្នកវិនិយោគនៅគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោងវិនិយោគ ដោយបានបង្កើតយន្តការគណៈកម្មាធិការចម្រុះទ្វេភាគីរវាងអ្នកវិនិយោគជប៉ុន, ចិន, កូរ៉េ ជាដើម, (៥) ការបន្តកិច្ចការងារទាក់ទងនឹងការរៀបចំគេហទំព័រថ្មីរបស់ ក.អ.ក, និង (៦) បាននិងកំពុងគិតគូររៀបចំអនុវត្តតាមប្រព័ន្ធអេឡិកត្រូនិចនូវការចុះបញ្ជីគម្រោងវិនិយោគ, ការដាក់ពាក្យស្នើសុំនាំចូលដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋចំពោះវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង, និងការដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ ជាដើម។ ជាក់ស្តែង ក.អ.ក បានទទួលចុះបញ្ជីគម្រោងវិនិយោគចំនួន ១៨៣គម្រោង ក្នុងឆ្នាំ២០១៧, ២៥៦គម្រោង ក្នុងឆ្នាំ២០១៨, បានរៀបចំរបៀបវារៈកិច្ចប្រជុំយន្តការអន្តរស្ថាប័ន ដើម្បីពិនិត្យសំណើសុំការនាំចូលដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋលើការនាំចូលរបស់បណ្តាក្រុមហ៊ុនវិនិយោគ សរុបចំនួន ១៣៣លើក ក្នុងឆ្នាំ២០១៧, និង ៤៨៣លើក ក្នុងឆ្នាំ២០១៨។

ទន្ទឹមនឹងនេះ ក.អ.ក បាននិងកំពុងបន្តពង្រឹងសមត្ថភាពមន្ត្រីក្នុងការរៀបចំ អនុវត្ត និងពិនិត្យតាមដានការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ បន្ថែមលើតួនាទីជាប្រតិបត្តិករ, បានពង្រឹងសមត្ថភាព និងរៀបចំរចនាសម្ព័ន្ធអភិបាលកិច្ចស្ថាប័នតាមរយៈការបង្កើតលេខាធិការដ្ឋានដឹកនាំនិងសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ដែលជាសេនាធិការរបស់គណៈកម្មាធិការប្រតិបត្តិ ក.អ.ក ព្រមទាំងបានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំរបស់លេខាធិការដ្ឋាននេះផងដែរ។ ជាក់ស្តែង លេខាធិការដ្ឋានដឹកនាំនិងសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែលជាសេនាធិការរបស់គណៈកម្មាធិការប្រតិបត្តិ ក.អ.ក បានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ត្រឹមខែធ្នូ ឆ្នាំ២០១៦ និងបានដាក់ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ហើយទទួលបានការឯកភាពទាំងស្រុង កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧, បានបន្តរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ ក្នុងឆ្នាំ២០១៧ ព្រមទាំងបានរៀបចំឯកសារជំនួយស្មារតី ទស្សនាទាន និងចូលរួមផ្តល់ធាតុចូលលើឯកសារគោលនយោបាយ និងឯកសារស្រាវជ្រាវដទៃទៀត សរុបចំនួន ២១ករណី ក្នុងឆ្នាំ២០១៧ និង ៧៥ករណី ក្នុងឆ្នាំ២០១៨។

ដើម្បីជំរុញការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេសបន្ថែមទៀត ក.អ.ក បានបន្តអនុវត្តការងារជាច្រើនដូចជា (១) បានបន្តកិច្ចសហការជាមួយអ្នកអភិវឌ្ឍន៍តំបន់លើកិច្ចការផ្សព្វផ្សាយ និងទាក់ទាញអ្នកវិនិយោគថ្មីៗឱ្យមកបណ្តាក់ទុនវិនិយោគនៅតាមតំបន់នានាដែលបានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងមានដំណើរការរដ្ឋបាលក្នុងតំបន់រួច, និង (២) បានទទួលជួបគណៈប្រតិភូពីបណ្តាប្រទេសផ្សេងៗ ដើម្បីពិភាក្សាការងារលើ

គម្រោងវិនិយោគអភិវឌ្ឍន៍តំបន់ និងគម្រោងវិនិយោគក្នុងតំបន់ ជាដើម។ ក្រៅពីនេះ ក.អ.ក បាន (១) រៀបចំ និងចូលរួមសកម្មភាព សិក្ខាសាលា ឬវេទិកាទាំងក្នុងនិងក្រៅប្រទេស ទាក់ទងនឹងការទាក់ទាញវិនិយោគចំនួន ២៧លើក ក្នុងឆ្នាំ២០១៧ និង ៣១លើក ក្នុងឆ្នាំ២០១៨, (២) បានផ្តល់សេវាពិគ្រោះយោបល់ជូនអ្នកវិនិយោគខ្មែរ និងបរទេស សរុបចំនួន ៥៤៧នាក់ ក្នុងឆ្នាំ២០១៧ និង ៤៨៣លើក ក្នុងឆ្នាំ២០១៨ និង (៣) បានសម្របសម្រួលកម្មវិធីជួបសម្តែងការគួរសមរបស់គណៈប្រតិភូវិនិយោគ ចំនួន ២៣លើក ដែលមានអ្នកវិនិយោគសរុប ៦៥៩នាក់មកពីប្រទេសចិន ថៃ ជប៉ុន និងសិង្ហបុរី។

លើសពីនេះ ដើម្បីបន្តលើកកម្ពស់ការទាក់ទាញវិនិយោគ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌគតិយុត្ត និងបរិយាកាសអនុគ្រោះសម្រាប់ការវិនិយោគ ក.អ.ក តាមរយៈក្រុមការងារចរចា និងគណៈកម្មាធិការសម្របសម្រួលវិនិយោគ បានបំពេញការងារយ៉ាងសកម្មក្នុងការចូលរួមការចរចាកិច្ចព្រមព្រៀងអន្តរជាតិជាច្រើនដូចជា (១) ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគទ្វេភាគីរវាងកម្ពុជា និងអេមីរ៉ាតអារ៉ាប់រួម បន្ថែមលើកិច្ចព្រមព្រៀងវិនិយោគទ្វេភាគី សរុបចំនួន ២៧ ដែលមានស្រាប់, (២) ការចូលរួមបញ្ចប់ការចរចាកិច្ចព្រមព្រៀងវិនិយោគអាស៊ាន-ហុងកុង (AHKIA) ស្របជាមួយនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង (AHKFTA), (៣) ចូលរួមកិច្ចប្រជុំក្រុមការងារវិនិយោគក្រោមក្របខណ្ឌភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) ដែលគ្រោងនឹងបញ្ចប់ក្នុងឆ្នាំ២០១៩, (៤) ការចូលរួមកិច្ចប្រជុំគណៈកម្មាធិការចម្រុះភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់អាស៊ាន-ជប៉ុន, និង (៥) ការចូលរួមកិច្ចប្រជុំក្រុមការងារពិសេសស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាន (TF-ATISA)។

### ក.២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំនូវលិខិតបទដ្ឋានគតិយុត្តមួយចំនួនដូចជា សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការដាក់ឱ្យអនុវត្តច្បាប់ស្តីពីវិនិយោគ (មាត្រា១៥ ស្តីពីគម្រោងពង្រីក), អនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារនិងផ្នែកគយសម្រាប់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យអាទិភាព, អនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងអនុក្រឹត្យ និងប្រកាសមួយចំនួនទៀត។

ក្រៅពីការងារទាំងនេះ ក្រសួងបានចេញវិញ្ញាបនបត្រអនុលោមភាពជូនអ្នកជាប់ពន្ធ (អនុលោមភាពមាសបានចំនួន ៦៥សហគ្រាស), បានចូលរួមពង្រឹង និងតាមដាននូវសកម្មភាពរបស់គម្រោងវិនិយោគ តាមរយៈការវាយតម្លៃ និងការផ្តល់ជូននូវវិញ្ញាបនបត្របញ្ជាក់ពីការបំពេញកាតព្វកិច្ចសារពើពន្ធរបស់សហគ្រាសវិនិយោគ, បានផ្តល់វិញ្ញាបនបត្រសមាជិកក្រុមធុរជនល្អបំផុត ចំនួន ៣០ ក្រុមហ៊ុន, បន្តវាយតម្លៃទំហំទំនិញនាំចូល-នាំចេញ និងទឹកប្រាក់ពន្ធ និងអាករជាបន្ទុករដ្ឋរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមខែនីមួយៗជាប្រចាំ។ លើសពីនេះ ក្រសួងបានពង្រឹងយន្តការភាពជាដៃគូរវាងពន្ធដារនិងវិស័យឯកជន

តាមរយៈការបង្កើតក្រុមការងារអគ្គនាយកដ្ឋានពន្ធដារនិងផ្នែកឯកជន ក៏ដូចជាបានចូលរួមយ៉ាងសកម្មក្នុងវេទិកាស្តីពីពន្ធដារជាមួយវិស័យឯកជន ដូចជា EuroCham សភាពាណិជ្ជកម្មចិននៅកម្ពុជា សមាគមរោងចក្រកាត់ដេរជាដើម ដោយបានដោះស្រាយនូវសំណូមពរ និងបំភ្លឺចម្ងល់នានារបស់វិស័យឯកជន ព្រមទាំងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងកាតព្វកិច្ចសារពើពន្ធដល់វិស័យឯកជនជាច្រើនលើក, បានពង្រឹងយន្តការពិគ្រោះយោបល់ និងបំភ្លឺដល់អ្នកជាប់ពន្ធ តាមរយៈ CALL CENTER, LIVE CHAT, Email, តាមបណ្តាញទំនាក់ទំនងសង្គម, បញ្ជរពិគ្រោះយោបល់និងប្រអប់ពិគ្រោះយោបល់ ព្រមទាំងបានបង្កើតផែនការលើកទឹកចិត្តផ្នែកពន្ធសម្រាប់ច្បាប់វិនិយោគថ្មី និងបន្តចូលរួមរៀបចំសេចក្តីព្រាងកែសម្រួលបទប្បញ្ញត្តិពាក់ព័ន្ធនឹងការលើកទឹកចិត្ត។ ក្រសួងក៏បាននិងកំពុងរៀបចំប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដើម្បីកាត់បន្ថយពេលវេលាបង់ និងទូទាត់ប្រាក់សម្រាប់អ្នកវិនិយោគ និងអតិថិជន។ លើសពីនេះ ក្រសួងបានចូលរួមក្នុងការងារមួយចំនួនទៀតដូចជា (១) ពិនិត្យ ផ្តល់មតិ និងកែសម្រួលកិច្ចព្រមព្រៀងសិក្សា ស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ មួយចំនួនពាក់ព័ន្ធនឹងគម្រោងវិនិយោគសម្បទានរ៉ែ, (២) ពិនិត្យ ផ្តល់មតិ និងកែសម្រួលសេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីការគ្រប់គ្រងការប្រមូលចំណូលសួយសារធនធានរ៉ែពីការប្រើប្រាស់ធនធានរ៉ែសំណង់ក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ, (៣) សិក្សាពិនិត្យផ្តល់ការលើកទឹកចិត្ត និងគាំទ្រដល់គម្រោងវិនិយោគមួយចំនួន ដូចជា ករណីការនាំចូលសម្ភារៈផ្ទះបាយ និងការទទួលស្គាល់ម្ចាស់កម្មសិទ្ធិលើការនាំចូលសម្ភារៈ និងវត្ថុធាតុដើម ក្នុងរូបភាពជា ផលិត/ដេរកាត់ តម្រឹម (CMT: Cut Make and Trim) និង (៤) ចូលរួមរៀបចំប្រកាសរួមស្តីពីសេវាសាធារណៈរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

ចំពោះយន្តការភាពជាដៃគូគយ-ផ្នែកឯកជន (CPPM) ក្រសួងបានរៀបចំកែសម្រួលសមាសភាពក្រុមការងារនៃយន្តការនេះ និងបានបង្កើតក្រុមការងារចំនួន ០៤ នៃយន្តការ CPPM រួមមាន÷ (១) ក្រុមការងារគយ-ឧស្សាហកម្មបម្រើឱ្យការនាំចេញវិស័យកាត់ដេរ, (២) ក្រុមការងារគយ-ឧស្សាហកម្មបម្រើឱ្យការនាំចេញវិស័យមិនមែនកាត់ដេរ, (៣) ក្រុមការងារគយ-ធុរកិច្ចបម្រើទីផ្សារក្នុងស្រុក និង (៤) ក្រុមការងារគយ-ឧស្សាហកម្មធុនតូច និងមធ្យម។ ក្រសួងបានរៀបចំកិច្ចប្រជុំ CPPM លើកទី៧ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ និងបានប្រជុំក្រុមការងារទាំង៤ នៃ CPPM ដើម្បីដោះស្រាយនូវបញ្ហា និងកង្វល់នានាពាក់ព័ន្ធនឹងការងារគយ មានដូចជា (១) ការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ, (២) ការធ្វើសាមញ្ញកម្មនីតិវិធីទំនិញសេវាបញ្ញើរហ័ស, (៣) ការរៀបចំនិងដាក់អនុវត្តកម្រៃសេវាគយ, (៤) ការផ្ទៀតផ្ទាត់តម្លៃគិតពន្ធគយ, (៥) ការចូលរួមចំណែករបស់គយ និងវិស័យឯកជនក្នុងការអនុវត្តគោលនយោបាយពិពិធកម្មសេដ្ឋកិច្ច, (៦) ការរៀបចំខ្លួនឆ្លើយតបចំពោះការវិវត្តន៍នៃសេដ្ឋកិច្ចឌីជីថល និង (៧) ការកែសម្រួលអនុក្រឹត្យស្តីពីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ ជាដើម។

ក្នុងកិច្ចការពាក់ព័ន្ធនឹងគយនេះផងដែរ ក្រសួងបានសហការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីកម្រៃសេវាកម្មគយផ្សេងទៀត ជាមួយសភាពាណិជ្ជកម្មកម្ពុជា និងអឺរ៉ុបនៅភ្នំពេញ, បានប្រជុំពិគ្រោះពិភាក្សារវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងបណ្តាក្រុមហ៊ុនដឹកជញ្ជូនបញ្ញើរហ័ស, ព្រមទាំងបានរៀបចំកិច្ចប្រជុំអន្តរស្ថាប័ន ដើម្បីពិនិត្យឡើងវិញនូវខ្លឹមសារអនុក្រឹត្យលេខ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីមុខទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់។ ក្រសួងក៏បានដាក់ឱ្យអនុវត្តមុខងារប្រកាសកញ្ចប់បញ្ញើរហ័ស ឬទំនិញតម្លៃទាប (De Minimis) តាមប្រព័ន្ធអេឡិចត្រូនិកគយ, កែសម្រួលបន្ថយអត្រាអាករនាំចេញកៅស៊ូកែច្នៃ និងធ្វើវិមជ្ឈការការងារកំណត់តម្លៃគិតពន្ធគយទៅអាកាសយានដ្ឋានអន្តរជាតិបន្ថែមទៀត។ លើសពីនេះ ក្រសួងបាននិងកំពុងកសាងគម្រោងស្តីពីការសិក្សារយៈពេលបញ្ចេញទំនិញពីគយ, ការត្រួតពិនិត្យទំនិញរួមគ្នាតែមួយលើកនៅទីលានបញ្ចេញទំនិញនៅមាត់ច្រក ដោយអនុវត្តតាមកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន, និងប្រព័ន្ធសៀលអេឡិចត្រូនិកសម្រាប់តាមដានការចរាចរទំនិញ និងតម្រាយផ្លូវ។ ក្រសួងក៏បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពីយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ជូនដល់វិស័យឯកជនចំនួន ៣ជង,៧ បន្តពង្រីកយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ តាមអាជីវកម្មដ្ឋានពីវិស័យកាត់ដេរទៅវិស័យផ្សេងទៀត ដោយផ្អែកលើកម្រិតហានិភ័យ។

### ក.៣ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានចូលរួមយ៉ាងសកម្មក្នុងការផ្តល់ធាតុចូល និងកិច្ចប្រជុំ "ច្រកចេញ-ចូលតែមួយ" របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលើការអនុម័តលើកទឹកចិត្តដល់គម្រោងវិនិយោគនានា។ លើសពីនេះទៀត ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានរៀបចំធ្វើគោលនយោបាយជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ក្នុងនោះបានគិតគូរពីការកំណត់និយមន័យ សហគ្រាសធុនតូច និងមធ្យមឡើងវិញតាមវិស័យ ក្នុងគោលបំណងឱ្យមានការកំណត់ការលើកទឹកចិត្តចំគោលដៅ។ ជាមួយគ្នានេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានផ្តល់ការបណ្តុះបណ្តាល ដល់កម្មករបច្ចេកទេសសុវត្ថិភាពឧស្សាហកម្មដោយមិនគិតថ្លៃបានចំនួនសរុប ១៣ លើក ។

### ក.៤. ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ

ក្រៅពីក្រសួង ស្ថាប័ន៣ខាងលើ វិធានការពាក់ព័ន្ធនឹងបរិយាកាសវិនិយោគនេះ មានការចូលរួមអនុវត្តយ៉ាងសកម្មពីទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងពាណិជ្ជកម្ម, ក្រសួងបរិស្ថាន, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងមហាផ្ទៃ, ក្រសួងទេសចរណ៍, រដ្ឋបាលរាជធានីភ្នំពេញ, រដ្ឋបាលខេត្តកណ្តាល, រដ្ឋបាលខេត្តបន្ទាយមានជ័យ និងរដ្ឋបាលខេត្តកោះកុង។ សកម្មភាពអនុវត្តលម្អិត មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២ នៃរបាយការណ៍នេះ។

## ៦. ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងការរៀបចំតំបន់ឧស្សាហកម្ម

ក្នុងរយៈពេលកន្លងមកនេះ ក្នុងចំណោមវិធានការគោលនយោបាយចំនួន ១៣ ដែលពាក់ព័ន្ធទៅនឹង "ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងការរៀបចំតំបន់ឧស្សាហកម្ម" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធ សម្រេចបានវឌ្ឍនភាពជាច្រើនដូចខាងក្រោម÷

### ៦.១. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានប្រជុំពិនិត្យលើគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួន ៩ ក្នុងឆ្នាំ ២០១៧ (២ នៅខេត្តកំពត, ១ នៅខេត្តកំពង់ឆ្នាំង, ១ នៅខេត្តស្វាយរៀង, ១ នៅខេត្តកណ្ដាល, ១ នៅខេត្តកោះកុង និង ៣ នៅខេត្តព្រះសីហនុ) និងបានសម្រេចចេញអនុក្រឹត្យបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួន ៤ ក្នុងនោះ ២ នៅខេត្តស្វាយរៀង និង ២ នៅខេត្តព្រះសីហនុ។ តំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជាមានចំនួនសរុប ៥៤តំបន់ ក្នុងឆ្នាំ២០១៨ ដោយមានការកើនឡើងជាងឆ្នាំ២០១៧ ចំនួន ២តំបន់ ដែលក្នុងនោះ ៣៤ តំបន់ត្រូវបានបង្កើតដោយអនុក្រឹត្យ ហើយ ២០តំបន់កំពុងមានដំណើរការ ដោយមានគម្រោងវិនិយោគសរុបចំនួន ៤០៤ ជាមួយនឹងទុនវិនិយោគចំនួនប្រមាណ ៣ប៊ីលានដុល្លារអាមេរិក និងបានបង្កើតការងារបានចំនួនប្រមាណជា ១១ម៉ឺនកន្លែង បើធៀបទៅនឹងឆ្នាំ២០១៧ ដែលមានគម្រោងវិនិយោគសរុបចំនួន ៣៥១ ទុនវិនិយោគចំនួនប្រមាណ ២ប៊ីលានដុល្លារអាមេរិក និងបានបង្កើតការងារបានចំនួនប្រមាណជា ១០ម៉ឺនកន្លែង។

ក្នុងក្របខណ្ឌសេចក្ដីព្រាងច្បាប់ស្ដីពីតំបន់សេដ្ឋកិច្ចពិសេស ក.អ.ក បានបន្តធ្វើការសិក្សាស្រាវជ្រាវប្រមូលធាតុចូលដែលពាក់ព័ន្ធពីបណ្ដាប្រទេសនានានៅក្នុងតំបន់ ដោយបានគិតគូរគ្រប់ជ្រុងជ្រោយពីប្រព័ន្ធគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត វត្ថុធាតុដើម និងធាតុចូលផ្សេងៗ កិច្ចសម្រួលការដឹកជញ្ជូន និងពាណិជ្ជកម្ម ការតភ្ជាប់ខ្សែច្រវាក់តម្លៃរវាងសហគ្រាសក្នុងស្រុក និងសហគ្រាសធំបរទេស ព្រមទាំងការលើកទឹកចិត្ត ជាពិសេសការលើកទឹកចិត្តពិសេសជូនក្រុមហ៊ុនទាំងឡាយរាប់ទាំងសហគ្រាសធុនតូច និងមធ្យម ដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ ជាក់ស្ដែង ដើម្បីជាធាតុចូលសម្រាប់ការស្វែងយល់លទ្ធភាពតភ្ជាប់ខ្សែច្រវាក់តម្លៃរវាងសហគ្រាសក្នុងស្រុក ជាពិសេសសហគ្រាសធុនតូចនិងមធ្យម និងសហគ្រាសធំបរទេស ក.អ.ក បានចូលរួមសហការ និងផ្ដល់ការសម្របសម្រួលលើការសិក្សាអង្កេតរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ស្ដីពីការតភ្ជាប់រវាងក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស និងសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក នៅកម្ពុជា។

បន្ថែមលើនេះ ក.អ.ក បាននិងកំពុងបន្តកិច្ចសហការជាមួយអ្នកអភិវឌ្ឍន៍តំបន់លើកិច្ចការផ្សព្វ-ផ្សាយ និងទាក់ទាញអ្នកវិនិយោគថ្មីៗឱ្យមកបណ្ដាក់ទុនវិនិយោគនៅតំបន់នានា, ជំរុញអ្នកអភិវឌ្ឍន៍តំបន់ឱ្យបន្តកាន់តែសកម្មថែមទៀត ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសរៀងៗខ្លួន, បាន

សម្របសម្រួល និងលើកទឹកចិត្តដល់ការអភិវឌ្ឍតំបន់ប្រកបដោយភាតរបរិស្ថាន, និងកំពុងពង្រឹងសមត្ថភាពមន្ត្រីនៅតាមរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ដើម្បីផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ជូនអ្នកវិនិយោគ។

ដើម្បីរៀបចំផែនការអភិវឌ្ឍទីប្រជុំជន/ទីក្រុងឱ្យក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្ម ក.អ.ក បន្តចូលរួមកិច្ចប្រជុំអន្តរក្រសួងពាក់ព័ន្ធនឹង (១) សេចក្តីព្រាងផែនការប្រើប្រាស់ដីខេត្តព្រះសីហនុ និងខេត្តបាត់ដំបង, (២) ការងាររៀបចំផែនការអភិវឌ្ឍទីប្រជុំជន/ទីក្រុងឱ្យក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្ម ដូចជា យុទ្ធសាស្ត្រសមាហរណកម្មតំបន់ឆ្នេរ និងផែនការរៀបចំដែនដីខេត្តព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣០, ឯកសារក្របខណ្ឌអភិវឌ្ឍតំបន់ទីក្រុងជុំវិញបឹងទន្លេសាប, និង (៣) អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ព្រមទាំងសេចក្តីសម្រេចស្តីពីការរៀបចំផែនការរៀបចំដែនដីថ្នាក់ជាតិ និងសេចក្តីសម្រេចស្តីពីនីតិវិធីនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី។ ក្នុងក្របខណ្ឌតំបន់ ទាក់ទងនឹងការអភិវឌ្ឍរបៀងឧស្សាហកម្ម ពិសេស ផ្តោតលើរបៀងសេដ្ឋកិច្ចតំបន់ឆ្នេរខាងត្បូង ក.អ.ក ក៏បានចូលរួមវេទិការបៀងសេដ្ឋកិច្ចមហាអនុតំបន់មេគង្គលើកទី៩ និងចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់មេគង្គលើកទី២២ នៅប្រទេសវៀតណាមផងដែរ។

### ៦.២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបន្តផ្សព្វផ្សាយ និងអនុវត្តពេញលេញនូវនីតិវិធីគយពិសេសក្នុងតំបន់សេដ្ឋកិច្ចពិសេស អមភ្ជាប់ជាមួយអនុក្រឹត្យពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសជាធរមានសម្រាប់ជាមូលដ្ឋានក្នុងការកសាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស, ជំរុញឱ្យមានការបែងចែកដែនគយក្នុងតំបន់សេដ្ឋកិច្ចពិសេសជាពីរផ្នែកតាមបទប្បញ្ញត្តិជាធរមានគឺដែនគយជាតិ និងដែនគយពិសេសដែលទទួលបានការលើកទឹកចិត្តផ្សេងគ្នា ព្រមទាំងបានជំរុញដាក់ឱ្យដំណើរការនូវរបបពន្ធ និងអាករក្នុងតំបន់សេដ្ឋកិច្ចពិសេសដូចជាភណ្ឌាគារគយមានដែនកំណត់ និងមណ្ឌលផលិតកម្ម ឬសេវាកម្មក្នុងទម្រង់នានា។ បន្ថែមលើនេះ ក្រសួងក៏បានបន្តចូលរួមពិនិត្យពិចារណាលើប្រព័ន្ធលើកទឹកចិត្តពន្ធដារ និងផ្នែកគយ តាមរយៈកិច្ចប្រជុំដើម្បីកសាងសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់មួយចំនួនពាក់ព័ន្ធ និងការគ្រប់គ្រងវិនិយោគ, ព្រមទាំងបានអនុវត្តការលើកលែងពន្ធលើអចលនទ្រព្យ សម្រាប់ក្រុមហ៊ុនដែលមានទីតាំងស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស និងបម្រើផ្ទាល់ដល់សកម្មភាពផលិតកម្ម។ ទន្ទឹមនេះដែរ ក្រសួងបានរៀបចំនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួនដូចជា សេចក្តីព្រាងបទប្បញ្ញត្តិស្តីពីភណ្ឌាគារគយមានដែនកំណត់សម្រាប់គ្រប់គ្រងទំនិញដែលផលិតក្នុងតំបន់សេដ្ឋកិច្ចពិសេស, ប្រកាសស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យា ដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ វាយនភណ្ឌ ស្បែកជើង កាបូប និងមួក, និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត។

ចំពោះការជំរុញការអភិវឌ្ឍរបៀងឧស្សាហកម្ម ក្រសួងបានពិនិត្យ និងអនុម័តលើផែនការដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងអភិវឌ្ឍន៍បណ្តាក្រុងរបៀងទី១ និងសេចក្តីព្រាងផែនការដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងអភិវឌ្ឍន៍បណ្តាក្រុងរបៀងទី២ និងគម្រោងអភិវឌ្ឍន៍បណ្តាក្រុងរបៀងទី៤។ ពាក់ព័ន្ធនឹងការរៀបចំផែនការអភិវឌ្ឍន៍ទីប្រជុំជន ឬទីក្រុងឱ្យក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្ម ក្រសួងបានចូលរួមជាមួយក្រុមការងារបេសកកម្មរបស់ធនាគារពិភពលោក ក្រោមគម្រោងជំនួយបច្ចេកទេសស្តីពី "ការពិនិត្យមើលឡើងវិញអំពីនគរូបនីយកម្មកម្ពុជា" (Cambodia Urbanization Review) និងបានបញ្ចប់ការងារដោះស្រាយទីតាំងដីសម្រាប់សាងសង់ស្ថានីយបូមជំរុញទឹកកខ្វក់ និងចម្រោះទឹកកខ្វក់នៅក្រុងប៉ោយប៉ែត ក្រុងបាត់ដំបង និងក្រុងបាវិត។

ក្នុងការបន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ក្រសួងបានរៀបចំបញ្ជីគម្រោង/កម្មវិធី ក្នុងក្របខណ្ឌថវិកាជាតិ សម្រាប់វិភាជន៍ថវិកាទៅលើកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចមាននៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ រួមមានផ្លូវថ្នល់ ទឹកស្អាត អគ្គិសនី គមនាគមន៍ និងទូរគមនាគមន៍, ព្រមទាំងបានរៀបចំ និងកំពុងបន្តអនុវត្តឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០។ ក្នុងនោះផងដែរ ក្រសួងបាននិងកំពុងសហការអនុវត្តគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី២, គម្រោងផ្គត់ផ្គង់ទឹកស្អាតសៀមរាប, គម្រោងពង្រីកបន្ថែមបន្ទាន់សមត្ថភាពផ្គត់ផ្គង់ទឹកស្អាតនៅខេត្តសៀមរាប, និងគម្រោងពង្រីកសមត្ថភាពរោងចក្រផលិតទឹកស្អាតចំការមន និងប្រព័ន្ធចែកចាយទឹក។ ជាការកត់សម្គាល់ ក្រសួងបានបញ្ចប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងផ្លូវជាតិលេខ១, លេខ៦, លេខ១៣, លេខ២១, លេខ៣១, លេខ៣៣, លេខ៥១, លេខ៥៥, លេខ៥៦, និងផ្លូវខេត្តលេខ១៥០B, លេខ១៥១B, លេខ៣១៤D និងគម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធមួយចំនួនទៀត ខណៈដែលគម្រោងខ្លះកំពុងអនុវត្តការងារដោះស្រាយផលប៉ះពាល់។

### ២.៣. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ក្នុងឆ្នាំ២០១៧-២០១៨ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការជំរុញលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យានៅកម្ពុជា ដោយសម្រេចបាន ២៥%។ ក្រសួងឧស្សាហកម្ម និងសិប្បកម្មក៏បានចេញប្រកាសលេខ០៨០ MIH/2018 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម សាធារណរដ្ឋប្រជាមានិតចិន នៅកម្ពុជា និងបានចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណរដ្ឋប្រជាមានិតចិន នៅកម្ពុជា រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតចិន ព្រម

ទាំងបានកែសម្រួលនីតិវិធីចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្មឱ្យមានភាពល្អប្រសើរឡើង តាមរយៈការចុះបញ្ជីស្វ័យប្រវត្តិកម្មប្រព័ន្ធចុះបញ្ជី។

ទន្ទឹមគ្នានេះ ក្នុងឆ្នាំ២០១៧-២០១៨ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បាន និងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជន សម្រាប់ផ្គត់ផ្គង់ទឹកស្អាតដល់រោងចក្រ សហគ្រាសកម្មន្តសាល និងតំបន់អភិវឌ្ឍន៍ពាក់ព័ន្ធវិស័យឧស្សាហកម្មនានា ដើម្បីសម្រេចគោលដៅនៃការផ្គត់ផ្គង់ទឹកស្អាត ប្រើប្រាស់នៅទីប្រជុំជនឱ្យបាន ១០០% នៅឆ្នាំ២០២៥ ព្រមទាំងបានដាក់ចេញនូវគោលការណ៍លើកទឹកចិត្តឱ្យវិស័យឯកជនចូលរួមធ្វើការវិនិយោគ បង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅតាមទីប្រជុំជន ស្រុក ឃុំ សង្កាត់ ដែលរដ្ឋមិនទាន់មានលទ្ធភាពធ្វើបាន ដោយផ្តល់សិទ្ធិធ្វើអាជីវកម្មរហូតដល់២០ឆ្នាំ ដែលពីមុនអនុញ្ញាតឱ្យត្រឹម៣ឆ្នាំ ដើម្បីធានាបាននិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាត និងពង្រីកផ្ទៃសេវាផ្គត់ផ្គង់ឱ្យបានលឿន។ ក្រសួងឧស្សាហកម្ម និងសិប្បកម្មក៏បានអនុវត្តគោលនយោបាយផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារក្រីក្រ ឬមានចំណូលទាប និងសម្រាប់និស្សិត កម្មករ កម្មការិនី ស្នាក់នៅ បន្ទប់ជួល ទោះបីការកំណត់ថ្លៃទឹកថ្មីនេះទាបជាងថ្លៃដើមផលិតក្តី។ ជាងនេះទៅទៀត ដើម្បីសម្របសម្រួលក្នុងការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានទឹកស្អាត អគ្គិសនី គមនាគមន៍ និងទូរគមនាគមន៍ជាដើម ក្រសួងបានចេញប្រកាសអនុញ្ញាតឱ្យដំណើរការអាជីវកម្មទឹកស្អាតក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងតំបន់សេដ្ឋកិច្ចពិសេសផ្សេងទៀតតាមការស្នើសុំរបស់អ្នកវិនិយោគ។ ក្រសួង ក៏បានអនុវត្តគោលនយោបាយផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារក្រីក្រ ឬមានចំណូលទាប និងសម្រាប់និស្សិត កម្មករ កម្មការិនី ស្នាក់នៅបន្ទប់ជួល ទោះបីការកំណត់ថ្លៃទឹកថ្មីនេះទាបជាងថ្លៃដើមផលិតក្តី។ ជាក់ស្តែង ក្នុងឆ្នាំ២០១៧-២០១៨ ការផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជន បានសរុបចំនួន ៣០៨.៩២២.៧៣៤ម$^{៣}$ ដល់ប្រជាជនរស់នៅទីប្រជុំជនទូទាំងប្រទេសទទួលបានទឹកស្អាតប្រើប្រាស់។

**១.៤ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ក្នុងឆ្នាំ២០១៧-២០១៨ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានបន្តអនុវត្ត និងសម្រេចនូវការងារមួយចំនួនបន្ថែមទៀត ដើម្បីរៀបចំតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្ម។ ក្នុងឆ្នាំ២០១៧ ក្រសួងបាននិងកំពុងរៀបចំផែនការរៀបចំដែនដីថ្នាក់ជាតិ និងតាមតំបន់, ផែនការរៀបចំដែនដីតំបន់ឆ្នេរ, ផែនការរៀបចំដែនដីខេត្តបាត់ដំបង ខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តតាកែវ និងខេត្តប៉ៃលិន, បានបែងចែកបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋក្នុងខេត្តព្រះសីហនុ, និងបានសហការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីរៀបចំច្បាប់ និងក្របខណ្ឌគតិយុត្ត ក្នុងការគាំទ្រដល់ការគ្រប់គ្រងការអភិវឌ្ឍ និងការសាងសង់។

ជាមួយគ្នានោះ ក្នុងឆ្នាំ២០១៨ ក្រសួងក៏បានខិតខំបន្តកិច្ចការរបស់ខ្លួនបន្ថែមទៀត មានដូចជា (១) ការរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តព្រះសីហនុ និងខេត្តបាត់ដំបង, (២) បាន

និងកំពុងបន្តរៀបចំផែនការរៀបចំដែនដីខេត្តសៀមរាប ខេត្តតាកែវ និងខេត្តប៉ៃលិន, (៣) បានចេញបណ្ណកម្មសិទ្ធិដីសរុបចំនួន ១៧៨ ៨១២បណ្ណ, បានចុះបញ្ជីជួលរយៈពេលវែងសរុបចំនួន ១១បណ្ណចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ចសរុបចំនួន ៧៤បណ្ណ ចុះបញ្ជីពីការផ្ទេរសិទ្ធិសរុបចំនួន ៣៥ ០០១បណ្ណ និងចុះបញ្ជីសិទ្ធិប្រាតិភោគសរុបចំនួន ២១ ២១៨បណ្ណ, (៤) បានដោះស្រាយវិវាទដីធ្លី ៣៦៤ករណី និងបានពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់ជូនប្រជាពលរដ្ឋចំនួន២ ៨៦៧គម្រោង, និង (៥) បានរៀបចំបញ្ចប់ និងត្រៀមស្នើសុំការអនុម័តសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដីខណ្ឌទាំង១២ នៅក្នុងរាជធានីភ្នំពេញ។

ទន្ទឹមនឹងនេះ ក្រសួងក៏បានរៀបចំច្បាប់ និងក្របខណ្ឌគតិយុត្ត ដើម្បីគាំទ្រដល់ការគ្រប់គ្រងការអភិវឌ្ឍនិងការសាងសង់ ដែលក្នុងនោះរួមមាន ច្បាប់ស្តីពីសំណង់ ច្បាប់រៀបចំដែនដី និងនគរូបនីយកម្ម ច្បាប់គ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា និងបទដ្ឋានគតិយុត្តមួយចំនួនទៀតដើម្បីគាំទ្រនិងចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា ដែលបាននិងកំពុងត្រូវរៀបចំជាបន្តបន្ទាប់ផងដែរ។

### ១.៥ ក្រសួងសាធារណការ និងដឹកជញ្ជូន

ក្រសួងសាធារណការនិងដឹកជញ្ជូន បានដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្ត ឆ្នាំ២០១៥-២០១៨ ដោយត្រៀមអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងខាងត្បូង (កែលម្អហេដ្ឋារចនាសម្ព័ន្ធក្រុង : ក្រុងប៉ោយប៉ែត ក្រុងបាត់ដំបង ក្រុងបាវិត និងទីប្រជុំជនអ្នកលឿង) រួមមានការសាងសង់ប្រព័ន្ធលូចម្រោះទឹកសំណល់ និងទីលានកែច្នៃសំរាម សាងសង់ផ្លូវក្រុង ប្រព័ន្ធការពារទឹកជំនន់ និងទប់ច្រាំងបាក់។ ជាងនេះទៅទៀត ក្រសួងបានដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្ត ឆ្នាំ២០១៦-២០១៩ ដោយត្រៀមអនុវត្តគម្រោងអភិវឌ្ឍន៍ក្រុងរបៀង២ ផ្តោតការអភិវឌ្ឍក្រុងចំនួនពីរ តាមតំបន់ឆ្នេរគឺ ក្រុងកំពតនិងក្រុងព្រះសីហនុ (សាងសង់ប្រព័ន្ធលូចម្រោះទឹកសំណល់ និងទីលានកប់សំរាម)។ ការអភិវឌ្ឍន៍កំពង់ផែក្រុងព្រះសីហនុ÷ ក្រសួងបានបញ្ចប់ (១) គម្រោងចំណតផែកុងតឺន័រក្រុងព្រះសីហនុ ប្រវែង២៤០ម. ជម្រៅ ១១,៥ម. ដោយថវិកាកម្ចីពីប្រទេសជប៉ុន និងពង្រីកចំណតផែកុងតឺន័របន្ថែមប្រវែង ១៦០ម. (២) បានបង្កើតតំបន់សេដ្ឋកិច្ចពិសេស កំពង់ផែស្វយ័តក្រុងព្រះសីហនុ (៧០ហិកតា) ដោយប្រើប្រាស់ថវិកាជប៉ុន (៣) បានបញ្ចប់គម្រោងអភិវឌ្ឍចំណតពហុបំណងកំពង់ផែស្វយ័តក្រុងព្រះសីហនុប្រវែង ៣៣០ម ជម្រៅទឹក ១៣,៥ម និងចំណតមូលដ្ឋានផ្គត់ផ្គង់ភស្តុភារសម្រាប់ការរុករកប្រេង បណ្តោយប្រវែង២០០ម. ជម្រៅទឹក ៧,៥ម.។

លើសពីនេះ ក្រសួងក៏កំពុងអនុវត្ត ដើម្បីជួយជំរុញល្បឿនដល់ការអភិវឌ្ឍផ្នែកឧស្សាហកម្ម និងការរីកលូតលាស់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា (១) កំពុងរៀបចំគម្រោងសាងសង់ចំណតផែកុងតឺន័រក្រុងព្រះសីហនុប្រវែង៣៥០ម. ជម្រៅទឹក១៤,៥ម. គ្រោងអនុវត្តសាងសង់ចុងឆ្នាំ២០១៩ និងបញ្ចប់ក្នុងឆ្នាំ២០២២ ( តាមរយៈចំណតផែកុងតឺន័រថ្មីនេះ នឹងអាចឱ្យនាវាដឹកជញ្ជូនកុងតឺន័រធុនធំអន្តរជាតិ ប្រមាណ៩៣% ចូលចតបាន ដែលធ្វើឱ្យតម្លៃដឹកជញ្ជូនតាមសមុទ្រ (Ocean Freight Fee) នឹងអាចមានតម្លៃប្រហាក់ប្រហែលជាមួយប្រទេស

ជិតខាង) (២) សិក្សាគម្រោងអភិវឌ្ឍន៍ទីលានស្តុកទំនិញ និងកុងតឺន័រ(ICD) លើផ្ទៃដីជាង៥៤ហិកតានៅក្រៅបរិវេណកំពង់ផែ (៣) សិក្សាគម្រោងធ្វើឱ្យប្រសើរឡើងចំណតស្ថានីយនាវាទេសចរណ៍អន្តរជាតិនៅផែចាស់ (៤) សិក្សា និងរៀបចំកែសម្រួលអភិវឌ្ឍន៍ចំណតផែចាស់ ឱ្យក្លាយទៅជាស្ថានីយអ្នកដំណើរ ដោយសហការជាមួយដៃគូវិស័យឯកជន (PPP) (៥) សិក្សាបន្ថែមតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ ដោយបង្កើតគម្រោងសាកល្បង “Customs Manufacturing Bonded Warehouse ” និង “ Free Port ” ព្រមទាំងបម្រុងជា Logistic Hub (៦) កំពុងពង្រីកទីលានស្តុកកុងតឺន័របន្ថែមចំនួន០២ទីតាំងគឺ ១-ទីលានស្តុកកុងតឺន័រក្រឡាផ្ទៃ ២៨.០០០ម² ដែលស្ថិតនៅក្នុងទីតាំងកំពង់ផែ និង ២-ទីលានស្តុកកុងតឺន័រក្រឡាផ្ទៃ ៤០.០០០ម² ដែលស្ថិតនៅក្នុងទីតាំងតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ។

ក្នុងការអភិវឌ្ឍកំពង់ផែស្វយ័តភ្នំពេញ ក្រសួងបានពង្រីកហេដ្ឋារចនាសម្ព័ន្ធចំណតផែកុងតឺន័រ LM១៧ ជំហានទី២ លើផ្ទៃដីទំហំ៤,៥ហិកតាបន្ថែមទៀត ដោយមានការបំពាក់បន្ថែមនូវគ្រឿងចក្រលើកដាក់នៅលើទីលានកុងតឺន័រ ចំនួន០៤គ្រឿង រថយន្តដឹកជញ្ជូនចំនួន ២៤គ្រឿង ដែលមានសមត្ថភាពទទួលកុងតឺន័របានចំនួន ៣០ម៉ឺន TEUs ក្នុងមួយឆ្នាំ និងបានសាងសង់ស្ពានទំហំ ៣ម.x៣៥ម. និងបង្កើតផែបណ្តែតថ្មីទំហំ ៣០ម.X១២ម. បន្ថែម នៅចំណតផែអ្នកដំណើរ និងទេសចរ (TS១)។ ហើយក្រសួងក៏កំពុង (១)ជំរុញគម្រោងអភិវឌ្ឍន៍ជំហានទី៣ លើផ្ទៃដីទំហំ ៥,៥ហិកតា ដែលមានសមត្ថភាពផ្ទុកកុងតឺន័របន្ថែមបានចំនួន ២០០ ០០០ TEUs ក្នុងមួយឆ្នាំ (២) ជំរុញការអភិវឌ្ឍចំណតផែទន្លេបិទ UM២ ដើម្បីឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ច និងការនាំចេញផលិតផលកសិកម្មនៅតាបណ្តាខេត្តទន្លេមេគង្គលើ (៣) ជំរុញការសាងសង់ចំណតផែទំនិញចាក់ធារ នៅជិតចំណតផែកុងតឺន័រLM១៧(៤) ការថែទាំផ្លូវនាវាចរណ៍ និងធ្វើការបូមស្តារប្រឡាយនាវាចរណ៍ ដែលស្ថិតនៅក្នុងដែនអាជីវកម្មរបស់កំពង់ផែស្វយ័តភ្នំពេញ ដើម្បីបង្កើនសមត្ថភាព និងសុវត្ថិភាពនៃការដឹកជញ្ជូន (៥)ជំរុញការបង្កើតតំបន់គាំទ្រកំពង់ផែ ឃ្លាំងស្ងួត និងឃ្លាំងត្រជាក់ និង (៦) ជំរុញការអភិវឌ្ឍមជ្ឈមណ្ឌលផ្តល់សេវាកម្មប្រមូល និងចែកចាយទំនិញ។

### ខ.៦ ក្រសួងបរិស្ថាន

សម្រាប់ឆ្នាំ២០១៧-២០១៨ ក្រសួងបរិស្ថាន បាននិងកំពុងខិតខំប្រឹងប្រែងអនុវត្តផែនការសកម្មភាពរបស់ខ្លួន និងសម្រេចបានលទ្ធផលសំខាន់ៗមួយចំនួន រួមមាន÷ (១) ការពន្លឿនដំណើរការរៀបចំក្រមបរិស្ថាន, ការរៀបចំយុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថាន ២០១៦-២០២៣, ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងការអនុវត្តថវិកាកម្មវិធីដើម្បីចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ដោយកំពុងគិតគូរ និងពិនិត្យលើការអនុវត្តសេវាកម្មចុះបញ្ជី ការផ្តល់អាជ្ញាបណ្ណ និងការកសាងឯកសារបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំមួយចំនួនពាក់ព័ន្ធការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស សុវត្ថិភាពផលិតកម្ម និងតំបន់ឧស្សាហកម្មផ្សេងៗទៀត, (២) បានធ្វើបច្ចុប្បន្នភាពប្រភពបំពុលរោងចក្រសហគ្រាស

នៅទូទាំងប្រទេសមានចំនួន ១.១៤៤ទីតាំង ដែលក្នុងនោះបានចុះត្រួតពិនិត្យការបំពុលបរិស្ថានបានចំនួន ២៣៩ករណី ដោះស្រាយបណ្ដឹងការបំពុលបរិស្ថានចំនួន ១០ករណី ចេញលិខិតបញ្ជាកែលម្អការបំពុលបរិស្ថាន ២៣ករណី និងបានពិន័យអន្តរកាលលើបទល្មើសបំពុលបរិស្ថានចំនួន ១៣ករណី ដែលបានធ្វើឱ្យបទល្មើសបំពុលបរិស្ថានមានការថយចុះ, ម្ចាស់ប្រភពបំពុលបានយកចិត្តទុកដាក់លើកិច្ចគាំពារបរិស្ថាននៅទីតាំងរបស់ខ្លួន និងការពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធកិច្ចគាំពារបរិស្ថានកាន់តែមានប្រសិទ្ធភាព។

ទន្ទឹមនេះ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលជាសេនាធិការរបស់ក្រសួង បាននិងកំពុងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំគោលនយោបាយស្ដីពីការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី (Payment Ecosystem Services-PES) ដែលនឹងត្រូវអនុវត្តសាកល្បងក្នុងតំបន់គោលដៅចំនួន២ គឺឧទ្យានជាតិជ័យវរ្ម័ន-នរោត្តម (ភ្នំតូលែន) ក្នុងខេត្តសៀមរាប និងតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយក្នុងខេត្តព្រះសីហនុ។ គោលបំណងនៃគោលនយោបាយសាកល្បង PES នេះ គឺសំដៅធានាដល់ស្ថិរភាពនៃប្រភពទឹកទាំងពីរទីតាំងប៉ូល ឱ្យមានការទទួលខុសត្រូវរួមគ្នារវាងអ្នកប្រើប្រាស់ប្រភពទឹក និងអ្នករក្សាប្រភពទឹក។ PES នឹងអនុវត្តចំពោះអ្នកប្រើប្រាស់ទឹកជាលក្ខណៈអាជីវកម្មដោយប្រើប្រាស់យន្តការនៃការស្ម័គ្រចិត្ត ដូចជា ក្រុមហ៊ុនផលិតស្រាបៀរ ក្រុមហ៊ុនភេសជ្ជៈផលិតទឹកសុទ្ធ សិប្បកម្មទឹកកក សណ្ឋាគារលំដាប់ផ្កាយ និងក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាត។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក៏បានសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីពង្រឹងសមត្ថភាពមន្ត្រីរាជការរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពាក់ព័ន្ធនឹងការធ្វើផែនការ និងប្រើប្រាស់បច្ចេកវិទ្យាដែលបញ្ចេញកាបូនតិចពីរោងចក្រឧស្សាហកម្ម។ សមិទ្ធផលសំខាន់ៗដែលទទួលបានពីកិច្ចសហការនេះគឺ ក) បញ្ជីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យឧស្សាហកម្ម (ការផលិត និងការប្រើប្រាស់) ខ) បានសាកល្បងអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថាន (EMS) និងប្រព័ន្ធផលិតកម្មស្អាត និងប្រសិទ្ធភាពថាមពល (RECP) ដែលបានអនុវត្តដោយរោងចក្រឧស្សាហកម្មក្នុងគោលដៅកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និង គ) ការពង្រឹងសមត្ថភាព និងការផ្សព្វផ្សាយអំពីវិធីសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មដែលបញ្ចេញកាបូនតិចដល់មន្ត្រីនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងសហគ្រាសធុនតូច និងមធ្យម។

### ខ.៧- រដ្ឋបាលរាជធានីភ្នំពេញ

រដ្ឋបាលរាជធានីភ្នំពេញបានជំរុញ ជាបន្តបន្ទាប់ឱ្យរោងចក្រ (មានទុនវិនិយោគក្រោម ២លានដុល្លារអាមេរិក) សហគ្រាសធុនតូច និងមធ្យម ចូលរួមថែរក្សាគុណភាពបរិស្ថានតាមរយៈការគ្រប់គ្រងបានច្បាស់លាស់នូវសំណល់រឹង សំណល់ឧស្សាហកម្ម សំណល់រាវ និងឧស្ម័ន ដែលបញ្ចេញដោយរោងចក្រ-សហគ្រាស និងជំរុញឱ្យមូលដ្ឋានខាងលើរៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន ឬកិច្ចសន្យាការពារបរិស្ថាន។ ទន្ទឹមនឹងនេះ រដ្ឋបាលរាជធានីភ្នំពេញបានប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីឆ្នាំ២០៣៥ របស់រាជធានីភ្នំពេញ ជាឧបករណ៍គោលក្នុងការតម្រង់ទិស និងគ្រប់គ្រងការអភិវឌ្ឍក្នុងន័យធានាដល់សក្ដា-

នុពលដែលមានស្រាប់របស់ទីក្រុង គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ធានាសន្តិសុខស្បៀង ជាពិសេស តម្រង់ទិសនៃការអភិវឌ្ឍប្រកបដោយតុល្យភាព និងភាពស៊ីសង្វាក់គ្នារវាងរាជធានី និងទីក្រុងតូចបន្ទាប់ ខេត្ត និងទីក្រុងរបស់ប្រទេសជាដៃគូកិច្ចសហប្រតិបត្តិការ តាមរយៈការបែងចែកជាតំបន់សំខាន់ៗដូចជា÷ ប៉ូល អភិវឌ្ឍន៍ស្នូល តំបន់ទីក្រុងប្រកបដោយគុណភាពអន្តរជាតិ តំបន់បម្រុងទុកនូវហេដ្ឋារចនាសម្ព័ន្ធរបវន្ត មេចាំបាច់ តំបន់អភិវឌ្ឍនគរូបនីយកម្មក្នុងកម្រិតទីក្រុងធំ និងតំបន់ពិសេសៗ ដែលមានបេតិកភណ្ឌ និងផ្តល់ សោភណភាពទីក្រុង។ បច្ចុប្បន្ននេះ នៅរាជធានីភ្នំពេញមានតំបន់ឧស្សាហកម្មសំខាន់ៗដូចជា ÷ តំបន់សេដ្ឋកិច្ច ពិសេសភ្នំពេញ សួនឧស្សាហកម្មកាណាឌីយ៉ា សួនឧស្សាហកម្មវឌ្ឍនៈI និងសួនឧស្សាហកម្មវឌ្ឍនៈ II។ល។

**១.៨ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ**

ក្រៅពីក្រសួង ស្ថាប័ន៧ខាងលើ វិធានការពាក់ព័ន្ធនឹងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងការ រៀបចំតំបន់ឧស្សាហកម្ម មានការចូលរួមអនុវត្តយ៉ាងសកម្មពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, រដ្ឋបាល ខេត្តស្វាយរៀង, រដ្ឋបាលខេត្តកណ្តាល, រដ្ឋបាលខេត្តព្រះសីហនុ, រដ្ឋបាលខេត្តបន្ទាយមានជ័យ និងរដ្ឋបាល ខេត្តកោះកុង។ សកម្មភាពអនុវត្តលម្អិត មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២ នៃរបាយការណ៍នេះ។

## ២.៣.២ ការពង្រីក និងទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម

### ក. ការរៀបចំស្ថាប័ន និងការលើកទឹកចិត្ត

ក្នុងរយៈពេលកន្លងមកនេះ ក្នុងចំណោមវិធានការគោលនយោបាយចំនួន ១០ ដែលពាក់ព័ន្ធទៅនឹង "ការរៀបចំស្ថាប័ន និងការលើកទឹកចិត្ត" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធ សម្រេចបានវឌ្ឍនភាពដូច ខាងក្រោម÷

**ក.១ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានរៀបចំសេចក្តីព្រាងគោលនយោបាយលើកទឹកចិត្តដល់សហ-គ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការសម្របសម្រួលការចុះបញ្ជីពាក់ព័ន្ធ នឹងសហគ្រាសធុនតូច និងមធ្យម និងសេវាកម្មនៅក្រោមក្របខណ្ឌដំបូលតែមួយ។ ក្រសួង ក៏បានធ្វើប្រតិភូកម្ម មុខងារដល់ថ្នាក់ក្រោមជាតិ សំដៅធ្វើឱ្យការផ្តល់សេវាដែលពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម និងសិប្បកម្ម ត្រូវ បានពង្រាយ និងបង្កិតជិតទៅដល់អ្នកដែលត្រូវការសេវា និងបានផ្ទេរសមត្ថកិច្ចឱ្យទៅមន្ទីរឧស្សាហកម្មនិង សិប្បកម្មរាជធានី ក្នុងការចុះបញ្ជីរោងចក្រ សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដែលកំពុងអនុវត្តនៅ ថ្នាក់កណ្តាល។ លើសពីនេះ ក្រសួងបានសម្របសម្រួលឱ្យសហគ្រាសខ្នាតតូច និងមធ្យមបានចូលរួមពិព័រណ៍ ក្នុងនិងក្រៅប្រទេស និងរៀបចំបេសកកម្មពាណិជ្ជកម្មទៅកាន់គោលដៅទីផ្សារដើម្បីឱ្យសហគ្រាសខ្នាតតូច និងមធ្យមបានសិក្សារៀនសូត្រពីភាពជឿនលឿននៃឧស្សាហកម្មខ្នាតតូច និងមធ្យមនៃបណ្តាប្រទេសទាំង នោះ។ ក្នុងការជួយគាំទ្រដល់ការផ្ទេរបច្ចេកវិទ្យា ក្រសួងបានរៀបចំកម្មវិធីផ្តល់ពានរង្វាន់ "ស៥" ចំនួន ៤ពាន់ រង្វាន់ជូនដល់ក្រុមហ៊ុន សហគ្រាស រោងចក្រ និងសិប្បកម្ម ព្រមទាំងបានចាត់បញ្ជូនមន្ត្រីបច្ចេកទេសទៅចូល

រួមកម្មវិធីទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យា នៃក្រសួងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃសាធារណរដ្ឋប្រជាមានិតចិន ជប៉ុន កូរ៉េ និងបណ្តាប្រទេសអាស៊ានមួយចំនួនទៀត តាមរយៈកិច្ចសហប្រតិបត្តិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

**ក.២ ក្រសួងពាណិជ្ជកម្ម**

ក្រសួងពាណិជ្ជកម្ម បានចាត់បញ្ជូនមន្ត្រីជំនាញចូលរួមក្នុងក្រុមការងារទទួលចុះបញ្ជីសហគ្រាសខ្នាតតូច និងមធ្យម នៅច្រកចេញ-ចូលតែមួយ ដែលមានការិយាល័យនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបានដាក់ឱ្យដំណើរការចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីកាត់បន្ថយពេលវេលា និងលុបបំបាត់ចំណាយក្រៅផ្លូវការ ដោយធ្វើការទូទាត់ជាមួយធនាគារកាណាឌីយ៉ា ធនាគារអេស៊ីលីដា និងក្រុមហ៊ុន VISA និងបានលុបចោលកម្រៃគ្រប់គ្រងការនាំចេញ (EMF) ដើម្បីរក្សា និងពង្រីកការនាំចេញ ព្រមទាំងរក្សាកំណើនផលិតភាព និងបៀវត្សរ៍។ ក្រសួង បានអនុវត្តកម្មវិធីភ្ជាស់សហគ្រាសធុនតូចនិងមធ្យម និងបានរៀបចំសិក្ខាសាលាជាសេរី សម្រាប់ពង្រឹង និងបង្កើតគំនិតច្នៃប្រឌិតលើការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិក ព្រមទាំងបានរៀបចំយុទ្ធនាការទិញផលិតផលខ្មែរ ចំនួន ១០លើក។

ទន្ទឹមនឹងនេះ ក្រសួងបានបើកមជ្ឈមណ្ឌលដាក់តាំងបង្ហាញផលិតផលកម្ពុជា នៅក្នុងប្រទេសចិនបានចំនួន ៥ទីតាំង និងបានសម្របសម្រួលឱ្យសហគ្រាសខ្នាតតូច និងមធ្យមបានចូលរួមពិព័រណ៍ក្នុងនិងក្រៅប្រទេស ដើម្បីឱ្យសហគ្រាសខ្នាតតូច និងមធ្យមបានសិក្សារៀនសូត្រពីភាពជឿនលឿននៃឧស្សាហកម្មខ្នាតតូច និងមធ្យមនៃបណ្តាប្រទេសទាំងនោះ។ ក្រសួងក៏បានរៀបចំជំនួបពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស និងសិក្ខាសាលាស្តីពីការជំរុញផលិតផលសក្តានុពលទៅកាន់ទីផ្សារអន្តរជាតិ សំដៅទាក់ទាញការវិនិយោគ និងស្វែងរកដៃគូពាណិជ្ជកម្មថ្មីបន្ថែម ព្រមទាំងបានបង្កើតផ្សារព្រំដែនកម្ពុជា-វៀតណាម នៅឃុំដា ខេត្តត្បូងឃ្មុំ បានចុះពង្រឹងសមត្ថភាព និងសកម្មភាព របស់សមាគមកសិ-ពាណិជ្ជកម្ម តាមបណ្តារាជធានី-ខេត្ត និងបានចុះអនុស្សារណៈយោគយល់គ្នាជាមួយអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាពអធិការកិច្ច និងចត្តាឡីស័ក្ត (AQSIQ) ស្តីពីកិច្ចសហប្រតិបត្តិការនៃការលើកកម្ពស់គុណភាព និងជំរុញការនាំចេញទៅកាន់ទីផ្សារចិន។

**ក.៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចូលរួមកិច្ចប្រជុំក្រុមការងារទី៣ ផ្នែកកម្មន្តសាល សហគ្រាសធុនតូចនិងមធ្យម និងសេវា ដើម្បីពិនិត្យដោះស្រាយនូវសំណូមពរពីវិស័យឯកជន, ព្រមទាំងបានសិក្សា និងរៀបចំឯកសារផ្សេងៗ ដើម្បីបង្កើត និងផ្តល់ហិរញ្ញប្បទានដល់គម្រោងសាកល្បងគ្រប់គ្រងមូលនិធិជាតិអភិវឌ្ឍន៍ជំនាញ ដើម្បីជំរុញការអភិវឌ្ឍសមត្ថភាព និងផលិតភាពរបស់វិស័យឯកជន និងវិស័យផ្សេងទៀត។ ក្នុងវិធានការនេះផងដែរ ក្រសួងបានដាក់ចេញនូវយន្តការលើកទឹកចិត្តពន្ធដារដល់សហគ្រាសធុនតូចនិងមធ្យម ដែលចុះបញ្ជីដោយស្ម័គ្រចិត្ត តាមរយៈអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧,

ប្រកាស ៥០២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ និងអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ០២ ខែតុលា ឆ្នាំ២០១៨, បានរៀបចំកែសម្រួលអត្រាពន្ធ និងអាករលើមុខទំនិញមួយចំនួន ជាពិសេសចំពោះមុខទំនិញបម្រើវិស័យកសិកម្ម និងគាំទ្រសហគ្រាសធុនតូចនិងមធ្យម នៃយន្តការ CPPM ដើម្បីដោះស្រាយបញ្ហា ឬសំណូមពរនានារបស់សហគ្រាសធុនតូចនិងមធ្យម។ លើសពីនេះ ក្រសួងក៏បានបន្តចូលរួមអនុវត្តកិច្ចសម្រួលពាណិជ្ជកម្ម តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងគោលដៅរក្សាបាននូវបរិស្ថានធុរកិច្ចសមធម៌មួយ ទន្ទឹមនឹងការកាត់បន្ថយតាមលទ្ធភាពនូវរបាំងពន្ធ និងរបាំងមិនមែនពន្ធផ្សេងៗដែលជាបន្ទុករបស់ធុរជនជាពិសេសបន្ទុកពេលវេលា និងការចំណាយក្រៅផ្លូវការ។

**ក.៤ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបណ្តុះបណ្តាលសិស្សបច្ចេកទេសវិជ្ជាជីវៈ កម្រិតជាន់ខ្ពស់បច្ចេកទេស/ឯកទេស និងវិស្វករ ក្នុងវិស័យអាទិភាព (សំណង់ មេកានិក អគ្គិសនី/អេឡិចត្រូនិក សេវាកម្មធុរកិច្ច/ព័ត៌មានវិទ្យា និងកម្មន្តសាល) ចំនួន ៩.១០៥នាក់ ដែលមានការកើនឡើង ធៀបនឹងឆ្នាំមុនៗ ដោយសាររាជរដ្ឋាភិបាលបានបង្កើនអាហារូបករណ៍, ការផ្សព្វផ្សាយ, និងការធ្វើទំនើបកម្មសម្ភារៈបរិក្ខារ។

**ក.៥ ក្រសួងអប់រំ យុវជន និងកីឡា**

ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ និងក្របខណ្ឌគោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន, បានរៀបចំផែនការសកម្មភាពអភិវឌ្ឍធនធានមនុស្សនៅមធ្យមសិក្សា, ព្រមទាំងបានរៀបចំសេចក្តីព្រាងឯកសារ និងផែនការសកម្មភាពមួយចំនួនទៀតពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានមនុស្ស។ ជាមួយគ្នានេះ ក្រសួងក៏បានអភិវឌ្ឍប្រព័ន្ធអភិវឌ្ឍសមត្ថភាពសិស្សផ្នែកគណិតវិទ្យា និងប្រវត្តិវិទ្យា (www.bacii.moeys.gov.kh) និងកម្មវិធីទូរសព្ទដៃ "កម្មវិធីល្បែងសិក្សាមេរៀនជីវវិទ្យាថ្នាក់ទី១២" លើប្រព័ន្ធប្រតិបត្តិ Android ជំនួយដល់ការសិក្សាសម្រាប់សិស្សថ្នាក់ទី១២, ហើយក៏បានធ្វើតេស្តវាយតម្លៃលទ្ធផលសិក្សាកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ ហៅកាត់ថា PISA-D ដែលជាការវាយតម្លៃប្រព័ន្ធអប់រំរបស់ប្រទេសមួយ ដោយផ្តោតលើគុណផលសិក្សារបស់សិស្សអាយុ ១៥ឆ្នាំ លើមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ និងអំណាន។

ទាក់ទិននឹងការលើកស្ទួយសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សា ក្រសួងបានបង្កើតគណៈកម្មាធិការវិទ្យាសាស្ត្រកម្ពុជា សម្រាប់ការស្រាវជ្រាវ និងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងបង្កើតសាលាបណ្ឌិត, បានរៀបចំវិបស្សនាក្រុមប្រឹក្សាសាកលវិទ្យាធិការដោយផ្តោតលើការរៀបចំឡើងវិញឋានៈសាស្ត្រាចារ្យ ការកសាងនិងការលើកកម្ពស់គុណភាពអប់រំនិងស្វ័យភាពឧត្តមសិក្សា, ព្រមទាំងបានបន្តកែលម្អនីតិវិធី និងដំណើរការទទួលស្គាល់គុណភាពអប់រំនៅគ្រឹះស្ថានឧត្តមសិក្សា និងកំពុងធ្វើការវាយតម្លៃលើគ្រឹះស្ថានឧត្តមសិក្សាមួយចំនួន។

### ក.៦ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍ បាននិងកំពុងធ្វើការស្រាវជ្រាវ និងប្រមូលធាតុចូលទាក់ទងនឹងប្រធានបទការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមនៅតាមបណ្ដាប្រទេសក្នុងតំបន់ ដើម្បីបន្តចូលរួម និងផ្ដល់ធាតុចូលលើសេចក្ដីព្រាងឯកសារក្របខណ្ឌគោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។ ជាមួយគ្នានេះ ក.អ.ក ក៏បានចូលរួមសហការ និងផ្ដល់ការសម្របសម្រួលលើការសិក្សាអង្កេតរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ស្ដីពីការតភ្ជាប់រវាងក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស និងសហគ្រាសធុនតូច និងមធ្យមក្នុងស្រុក ដើម្បីជាធាតុចូលក្នុងការពិនិត្យមើលការជំរុញការតភ្ជាប់រវាងសហគ្រាសធុនតូច និងមធ្យម និងសាជីវកម្មធំៗ ធានាឱ្យបាននូវកាលានុវត្តភាពក្នុងការឈានឡើងទៅក្នុងខ្សែច្រវាក់ផលិតកម្មក្នុងតំបន់ និងសកល។ ក្នុងឆ្នាំ២០១៨ ក.អ.ក បានបន្តជួបប្រជុំពិភាក្សា និងផ្ដល់ធាតុចូលលើសេចក្ដីព្រាងរបាយការណ៍បឋមនៃការសិក្សាអង្កេតលើការតភ្ជាប់រវាងពហុសាជីវកម្ម និងសហគ្រាសក្នុងស្រុកនៅកម្ពុជា ហើយគ្រោងនឹងរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីលទ្ធផលនៃការសិក្សានេះ នាដើមឆ្នាំ២០១៩។

### ក.៧ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ

ក្រៅពីក្រសួង ស្ថាប័ននាំមុខ ៦ខាងលើ វិធានការពាក់ព័ន្ធនឹងការរៀបចំស្ថាប័ននិងការលើកទឹកចិត្តមានការចូលរួមអនុវត្តយ៉ាងសកម្មពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ទីស្ដីការគណៈរដ្ឋមន្ត្រី, រដ្ឋបាលរាជធានីភ្នំពេញ, រដ្ឋបាលខេត្តស្វាយរៀង, រដ្ឋបាលខេត្តកណ្ដាល និងរដ្ឋបាលខេត្តព្រះសីហនុ។ សកម្មភាពអនុវត្តលម្អិត មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២ នៃរបាយការណ៍នេះ។

## ខ. ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យ

ក្នុងរយៈពេលកន្លងមកនេះ ក្នុងចំណោមវិធានការគោលនយោបាយចំនួន៦ ដែលពាក់ព័ន្ធទៅនឹង "ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យ" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធ សម្រេចបានវឌ្ឍនភាពដូចតទៅ÷

### ខ.១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគណនេយ្យ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគណនេយ្យ បានដាក់ឱ្យអនុវត្តនូវអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ ព្រមទាំងបាននិងកំពុងរៀបចំនិងដំណើរការសេចក្ដីព្រាងអនុក្រឹត្យ និងប្រកាសមួយចំនួនទៀត ស្របតាមខ្លឹមសារនៃច្បាប់ស្ដីពីគណនេយ្យ និងសវនកម្ម។ ស្ថាប័នទាំងពីរក៏បានសិក្សាស្រាវជ្រាវ ដោយសហការជាមួយគណៈកម្មការមូលបត្រកម្ពុជា ក្នុងការពិនិត្យលើលទ្ធភាពនៃការរៀបចំស្តង់ដារបាយការណ៍ហិរញ្ញវត្ថុសាមញ្ញសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដើម្បីសម្រួលដល់សហគ្រាសទាំងនោះមានលទ្ធភាពទទួលបានឥណទាន តាមរយៈធនាគារនិងទីផ្សារមូលបត្រ។ កន្លងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគណនេយ្យ បានរៀបចំសិក្ខាសាលាផ្សេងៗ សម្រាប់បណ្ដុះ-

បណ្តាលមន្ត្រីពន្ធដារអំពីគំរូបញ្ជីគណនេយ្យសាមញ្ញ និងបណ្តុះបណ្តាលអ្នកជាប់ពន្ធតូចអំពីគំរូបញ្ជីគណនេយ្យសាមញ្ញ និងកាតព្វកិច្ចសារពើពន្ធនានា។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានបន្តលើកទឹកចិត្តដល់អ្នកជាប់ពន្ធគ្រប់ប្រភេទ ដែលបានកាន់កាប់បញ្ជីគណនេយ្យបានត្រឹមត្រូវឱ្យរួចផុតពីការបង់ពន្ធអប្បបរមា និងបានត្រៀមសហការអនុវត្តនូវយន្តការក្រោមដំបូលតែមួយសម្រាប់ចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម។

### ខ.២ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ចាប់ពីឆ្នាំ២០១៧-២០១៨ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការសម្រួលការចុះបញ្ជីពាក់ព័ន្ធនឹងសហគ្រាសធុនតូច និងមធ្យម និងសេវាកម្មនៅក្រោមក្របខណ្ឌដំបូលតែមួយ។ ដើម្បីពង្រឹងយន្តការក្រោមដំបូលតែមួយសម្រាប់ការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម ក្រសួងក៏បានធ្វើប្រតិភូកម្មមុខងារដល់ថ្នាក់ក្រោមជាតិ សំដៅធ្វើឱ្យការផ្តល់សេវាដែលពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានពង្រាយ និងបង្កិតជិតទៅដល់អ្នកដែលត្រូវការសេវា។

គិតត្រឹមឆ្នាំ២០១៨ មានសហគ្រាសធុនតូច និងមធ្យម និងខ្នាតមីក្រូ ចំនួន ២៦.៣៤១មូលដ្ឋាន លើ ៥២.០៨៨មូលដ្ឋាន ប្រមាណ ៥០,៥៧% ដែលក្នុងនោះមានសហគ្រាសធុនមធ្យមចំនួន ១.០៣៨, សហគ្រាសធុនតូច ចំនួន ១៤.១៦៩ និងសហគ្រាសខ្នាតមីក្រូ ចំនួន ១១.១៣៤ បានចុះបញ្ជីជាផ្លូវការនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

### ខ.៣ ក្រសួងពាណិជ្ជកម្ម

ក្នុងការពង្រឹងអភិបាលកិច្ចសាជីវកម្ម ក្រសួងបានដាក់ឱ្យដំណើរការចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីកាត់បន្ថយពេលវេលា និងលុបបំបាត់ចំណាយក្រៅផ្លូវការ ដោយមានការទូទាត់ជាមួយធនាគារកាណាឌីយ៉ា ធនាគារអេស៊ីលីដា និងក្រុមហ៊ុន VISA ព្រមទាំងបានបន្តផ្សព្វផ្សាយតាមស្ថាប័នរាជធានី-ខេត្ត ពីនីតិវិធីស្នើសុំការបញ្ជាក់ប្រភពដើមទំនិញ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មផងដែរ។ លើសពីនេះទៀត ក្រសួងបានបើកវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវពាណិជ្ជកម្ម ដើម្បីពង្រឹងសមត្ថភាពវិស័យឯកជនឱ្យបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញក្នុងការធ្វើអាជីវកម្មប្រកបដោយប្រសិទ្ធភាព និងបានសិក្សាអំពីខ្សែសង្វាក់តម្លៃ លើផលិតផលសក្តានុពល និងផលិតផលប្រើប្រាស់ជាប្រចាំថ្ងៃ។ ក្រសួងក៏បានបន្តរៀបចំសិក្ខាសាលាអប់រំផ្សព្វផ្សាយពីនីតិវិធីនាំចេញ និងការពង្រឹងសមត្ថភាព និងការវេចខ្ចប់ និងបានបន្តចុះធ្វើការអប់រំ និងណែនាំពីរបៀបស្វែងរកទីផ្សារដល់ផលិតករដាំដុះ និងចិញ្ចឹមសត្វខ្នាតតូច តាមបណ្តាខេត្តគោលដៅ ហើយក្រសួងក៏បានសហការជាមួយម្ចាស់ជំនួយ និងអនុវត្តគម្រោងកសិកម្មខ្នាតតូច ដើម្បីផ្តល់លទ្ធភាពទទួលបានព័ត៌មានទីផ្សារ និងផ្តល់ហិរញ្ញប្បទានខ្នាតតូចជូនដល់កសិករតាមតំបន់គោលដៅ។

### ខ.៤ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ

ក្រៅពីក្រសួង ស្ថាប័ននាំមុខ ៣ខាងលើ វិធានការពាក់ព័ន្ធនឹងការចុះបញ្ជីនិងការកាន់បញ្ជីគណនេយ្យ មានការចូលរួមអនុវត្តយ៉ាងសកម្មពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, រដ្ឋបាលខេត្តស្វាយរៀង, រដ្ឋបាលខេត្តកណ្ដាល និងរដ្ឋបាលខេត្តព្រះសីហនុ។ សកម្មភាពអនុវត្តលម្អិត មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២ នៃរបាយការណ៍នេះ។

### គ. ការជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម

ក្នុងរយៈពេលកន្លងមកនេះ ក្នុងចំណោមវិធានការគោលនយោបាយចំនួន៥ ដែលពាក់ព័ន្ធទៅនឹង "ការជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើន ដូចខាងក្រោម÷

### គ.១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួង បានធ្វើការសិក្សា វិភាគ និងវាយតម្លៃតំបន់សក្តានុពលនៃផលិតកម្មកៅស៊ូធម្មជាតិនៅកម្ពុជា (តំបន់១÷ កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ព្រៃវែង និងស្វាយរៀង, តំបន់២÷ កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ សៀមរាប និង បន្ទាយមានជ័យ និងតំបន់៣÷ បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ កោះកុង ព្រះសីហនុ កំពត និង កំពង់ស្ពឺ)។ ក្រសួងក៏បាននិងកំពុងកំណត់ និងសិក្សាវាយតម្លៃតំបន់ដាំដុះ និងកែច្នៃផលិតផលកសិកម្មសំខាន់ៗ ដោយបានរៀបចំផែនទីតំបន់សមស្របសម្រាប់ដំណាំស្រូវ ដំឡូងមី ពោត អំពៅ ស្វាយចន្ទី ស្វាយ និងម្រេច ព្រមទាំងបានរៀបចំផែនទីចំណាត់ថ្នាក់ដីដំណាំស្រូវ នៅខេត្តព្រៃវែង កំពង់ធំ និងខេត្តបាត់ដំបង និងបានរៀបចំផែនទីការប្រើប្រាស់ដីកសិកម្ម និងផែនការទីចំណាត់ថ្នាក់ដីខេត្តត្បូងឃ្មុំ។ ក្រសួងក៏បាននិងកំពុងពង្រឹងសមត្ថភាពវិភាគលើគុណភាពសុវត្ថិភាពផលិតផលកសិកម្មក្នុងមន្ទីរពិសោធន៍ សិក្សាស្រាវជ្រាវវិធីសាស្ត្រទំនើបសម្រាប់វិភាគគុណភាពសុវត្ថិភាពផលិតផលកសិកម្ម និងស្បៀងអាហារ។

លើសពីនេះ ក្រសួងបានសម្របសម្រួលនិងគាំទ្រក្នុងការបង្កើត និងដំណើរការតំបន់ប្រមូលផ្តុំកន្លែងចិញ្ចឹមសត្វ កសិដ្ឋានចិញ្ចឹមសត្វ កន្លែងផលិតចំណីសត្វ បសុឱសថ កន្លែងកែច្នៃវេចខ្ចប់សាច់និងផលិតផលសត្វ ដើម្បីទាក់ទាញអ្នកវិនិយោគក្នុងវិស័យនេះ និងលើកកម្ពស់លក្ខខណ្ឌអនាម័យគុណភាពនិងសុវត្ថិភាពធានាដល់សុខភាពសាធារណៈផងដែរ។ ក្រសួង បានចងក្រងនិងពង្រឹងសមត្ថភាពសហគមន៍អភិវឌ្ឍន៍ការចិញ្ចឹមសត្វ ចំណីសត្វ និងកែច្នៃផលិតផលសាច់ ដោយបានចងក្រងសហគមន៍ចិញ្ចឹមសត្វបានចំនួន១៥ (សហគមន៍ចិញ្ចឹមជ្រូក សហគមន៍ចិញ្ចឹមគោ និងសហគមន៍ចិញ្ចឹមទា និងសហគមន៍ភ្នាក់ងារសុខភាពសត្វភូមិ), ចងក្រងក្រុមផលិតមាន់ និងទីផ្សារចំនួន ៧០៧ក្រុម, ចងក្រងក្រុមកម្មវិធីបង្វិលពូជ និងក្រុមសន្សំចំនួន ៤០ក្រុម និងបានបើកវគ្គបណ្តុះបណ្តាលចំនួន ៣៦វគ្គ ដើម្បីពង្រឹងសមត្ថភាពសហគមន៍លើការដឹកនាំ និងគ្រប់គ្រង ក្រុមបច្ចេកទេសចិញ្ចឹមសត្វ ជ្រើសរើសពូជ ការពារជំងឺសត្វ និងដំណាំចំណីសត្វ។

### គ.២. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានបង្កើតក្រុមការងារចុះពិនិត្យសិក្សា និងកំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់នូវតំបន់ការពារដីស្រែអំបិល និងរៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រងនិងអភិវឌ្ឍន៍ស្រែអំបិល។ ពាក់ព័ន្ធនឹងការងារនេះ ក្រសួងក៏បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងស្រែអំបិល និងផលិតកម្មអំបិល។ នៅក្នុងឆ្នាំ២០១៧ ការផលិតអំបិលសរុបបានចំនួន ១៤៣.៦៧៩តោន លើផ្ទៃដីទំហំ ៥.០៧១,៨២ហិកតា ក្នុងខេត្តកែប និងខេត្តកំពត និងមានក្រុមសាមគ្គីចំនួន ១៩៧ក្រុមសាមគ្គី ដែលបានបង្កើតការងារសរុបចំនួន ៥.០០០នាក់។ ក្នុងឆ្នាំ២០១៨ ផ្ទៃដីស្រែអំបិលក្នុងខេត្តកំពតនិងខេត្តកែប បានកើនឡើង ២៣៣,២៩ ហិកតា សរុបមានចំនួន ៥.៣០៥,១១ហិកតា និងមានក្រុមសាមគ្គីចំនួន ២០០ក្រុមសាមគ្គី ដែលបានបង្កើតការងារសរុប៥.០០០នាក់។ ក្នុងឆ្នាំ២០១៨ ការផលិតអំបិលពុំបានទទួលផលល្អ ដោយកត្តាអាកាសធាតុ ដែលមិនអាចធានាការផ្គត់ផ្គង់ក្នុងស្រុកបានគ្រប់គ្រាន់។ ដូចនេះ ដើម្បីរក្សាតុល្យភាពនៃការផ្គត់ផ្គង់តាមតម្រូវការ ក្រសួងបានគាំទ្រឱ្យមានការនាំចូលអំបិលចំនួន៣០,០០០តោន ពីប្រទេសចិន និងប្រទេសថៃ ។ លើសពីនេះ ដើម្បីជំរុញការនាំចេញកសិផល ក្រសួងក៏បាននិងកំពុងរៀបចំកម្រងបណ្តុំសហគ្រាសធុនតូចនិងមធ្យមនៅខេត្តកណ្តាលដើម្បីកែច្នៃផលិតផលផ្លែឈើ និងនៅកំពង់ឆ្នាំងដើម្បីកែច្នៃផលផលកម្ពុជាសម្រាប់នាំចេញ។

### គ.៣. ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្ម បានសម្របសម្រួលក្រុមហ៊ុនមកពីប្រទេសចិន មកបង្កើតតំបន់កែច្នៃផលិតផលកសិ-ឧស្សាហកម្មកម្ពុជា នៅខេត្តព្រះសីហនុ និងខេត្តកោះកុង និងសម្ព័ន្ធសមាគមជលផលសមុទ្រកម្ពុជា ដែលប្រមូលសមាគមជលផលសមុទ្រចំនួន ៥ នៅខេត្តកំពត ព្រះសីហនុ និងខេត្តកោះកុង និងគ្រោងបង្កើតជាបន្តបន្ទាប់បន្ថែមទៀត។ ក្រសួងក៏បាននិងកំពុងបន្តធ្វើសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលអាស៊ាន-ចិន, អាស៊ាន-ជប៉ុន, អាស៊ាន-កូរ៉េ និងដៃគូជំរុញពាណិជ្ជកម្មដទៃទៀតទាំងក្នុងតំបន់ និងលើពិភពលោក ដើម្បីបើកច្រកទីផ្សារលើផលិតផលដែលបានកែច្នៃរួចហើយ។ ជាមួយគ្នានេះ ក្រសួងបានចូលរួមតាំងពិព័រណ៍ដើម្បីស្វែងរកដៃគូពាណិជ្ជកម្ម និងធ្វើចរាចរបានទូលំទូលាយនៅលើទីផ្សារ និងបានសហការជាមួយអង្គការ UNIDO ក្នុងការរៀបចំបង្កើតទីផ្សារដាក់លក់ផលិតផលសមុទ្រនៅខេត្តកំពត (ផ្សារទំនើប ចាន់ ស៊ីថា) ដើម្បីគាំទ្រដល់កសិករ ផលិតករ និងសមាជិកសម្ព័ន្ធសមាគមជលផលសមុទ្រកម្ពុជាផងដែរ។

ទន្ទឹមនឹងនេះ ក្រសួងក៏បានរៀបចំ និងបង្កើតក្រុមប្រឹក្សាភិបាលដឹកនាំវិស័យម្រេច និងដំឡូងមីកម្ពុជា ដោយបាននិងកំពុងរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីដំឡូងមីកម្ពុជា និងសេចក្តីព្រាងគោល-នយោបាយជាតិស្តីពីម្រេច កម្ពុជា ដើម្បីជំរុញ និងសម្រួលដល់ទីផ្សារក្នុងស្រុក និងការនាំចេញទៅកាន់ទីផ្សារក្នុងតំបន់ និងអន្តរជាតិ។ ទន្ទឹមនឹងនេះ ក្រសួងបានសិក្សាលើផលិតផលថ្មីៗ ដែលមានសក្តានុពលបម្រើឱ្យទីផ្សារក្នុងស្រុក និងសម្រាប់នាំចេញ ដែលទើបតែលេចចេញនៅខេត្តមួយចំនួនដូចជា ស្វាយអំពៅខេត្ត

កោះកុង ព្រះវិហារ ផ្លែចេកខេត្តកំពង់ចាម និងខេត្តព្រះវិហារ ផ្លែល្មៅខេត្តព្រះវិហារ ផលិតផលសូត្រខេត្តសៀមរាប កំពង់ធំ តាកែវ បន្ទាយមានជ័យ កំពត និងខេត្តកណ្ដាល ហើយក្រសួងក៏បានបង្កើតក្រុមការងារ និងសិក្សាលទ្ធភាពដាក់បញ្ចូលគុយទាវភ្នំពេញ និងផលិតផលផ្កាអំបិលទៅជាផលិតផលម៉ាកសមូហភាព។ ក្រសួងបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ "ក្រូចថ្លុងកោះទ្រង់" ព្រមទាំងកំពុងពិនិត្យលទ្ធភាព និងសិក្សាផលិតផលសក្ដានុពលកម្ពុជា រួមមាន ម្នាស់ទឹកឃ្មុំខេត្តស្ទឹងត្រែង ស្រាផលិតពីផ្លែផាសិនខេត្តមណ្ឌលគិរី ផ្លែមៀនខេត្តប៉ៃលិន បន្ទាយមានជ័យ បាត់ដំបង និងពោធិ៍សាត់។ល។ ក្រសួងក៏បានបន្តពង្រឹងឧស្សាហកម្មស្រូវអង្ករតាមរយៈការពង្រឹងគុណភាព សុវត្ថិភាព រចនាសម្ព័ន្ធដឹកនាំ សហព័ន្ធនាំចេញអង្ករកម្ពុជា និងការប្រកួតប្រជែងអង្ករកម្ពុជាលើទីផ្សារអន្តរជាតិ និងបានលុបបំបាត់កម្រៃគ្រប់គ្រងការនាំចេញ (EMF) សម្រាប់ផលិតផលកាត់ដេរ សម្លៀកបំពាក់ និងស្បែកជើង។

### គ.៤ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្នុងក្របខណ្ឌវិនិយោគ នៅក្នុងឆ្នាំ២០១៧ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានពិនិត្យ និងអនុម័តគម្រោងវិនិយោគលើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម បានចំនួន ១០ ដែលមានទុនវិនិយោគប្រមាណជា ៣៩៦លានដុល្លារអាមេរិក ស្មើនឹង ៦% នៃទុនវិនិយោគសរុបដែលចុះបញ្ជីនៅ ក.អ.ក។ ក្នុងក្របខណ្ឌវិនិយោគនៅក្នុងឆ្នាំ២០១៨ បានពិនិត្យ និងអនុម័ត គម្រោងវិនិយោគលើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម បានចំនួន ១៨ ដែលមានទុនវិនិយោគប្រមាណជា ៤៥៨លានដុល្លារអាមេរិក ស្មើនឹង ៧% នៃទុនវិនិយោគសរុបដែលចុះបញ្ជីនៅ ក.អ.ក។ ទន្ទឹមនឹងនេះ ក.អ.ក ក៏បាននិងកំពុងបន្តធ្វើការផ្សព្វផ្សាយជូនអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេសអំពីបរិយាកាស និងកាលានុវត្តភាពវិនិយោគនៅកម្ពុជា ជាពិសេសសក្ដានុពលនៃការវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម ព្រមទាំងបានពិភាក្សាការងារជាមួយតំណាងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានាក្នុងការផ្ដល់ការគាំទ្រ និងលើកកម្ពស់ការវិនិយោគក្នុងវិស័យនេះ។

ក្នុងក្របខណ្ឌច្បាប់វិនិយោគ ក.អ.ក បានបន្តកិច្ចការងាររៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីវិនិយោគ ដោយបានគិតគូរផ្ដល់ការលើកទឹកចិត្តបន្ថែមដល់ក្រុមហ៊ុនទាំងឡាយណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងដែលបានបោះទីតាំងនៅក្នុងតំបន់កែច្នៃកសិផល។ ជាមួយគ្នានេះ ក.អ.ក ក៏បាននិងកំពុងគិតគូរ និងរៀបចំការសិក្សាស្រាវជ្រាវអំពីការរៀបចំតំបន់កែច្នៃកសិផល ដោយផ្អែកតាមបទពិសោធន៍ក្នុងតំបន់ ដើម្បីជាធាតុចូលបន្ថែមដល់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីវិនិយោគ។

### គ.៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិមួយចំនួន ដើម្បីលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យកសិកម្ម ដូចជា ការអនុវត្តអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃជាដើម, ព្រមទាំងកំពុងបន្តចូលរួមកសាងសេចក្ដីព្រាងបទប្បញ្ញត្តិពាក់ព័ន្ធនានាក្នុងលក្ខខណ្ឌ

រក្សាឱ្យបាននូវតុល្យភាពរវាងកិច្ចសម្រួលពាណិជ្ជកម្ម និងអនុលោមភាពច្បាប់។ ៣ ជាមួយគ្នានេះ ក្រសួងបានបន្តអនុវត្តការកែសម្រួលនីតិវិធីគយដើម្បីផ្តល់កិច្ចសម្រួលពាណិជ្ជកម្មបន្ថែមទៀត ដល់វិស័យឯកជនក្នុងការបំពេញបែបបទគយ តាមស្មារតីនៃកិច្ចប្រជុំយន្តការភាពជាដៃគូគយ-ផ្នែកឯកជន (CPPM) លើកទី៧ ដោយក្នុងនោះក្រសួងបានបង្កើតនិងកែលម្អ Hotline នៅតាមអង្គភាពគយនិងរដ្ឋាករមួយចំនួនសម្រាប់ផ្តល់ព័ត៌មាន និងសម្រាប់ការតវ៉ាប្រកបដោយប្រសិទ្ធភាពតាមមាត់ច្រកនានា, រៀបចំបញ្ចប់សេចក្តីព្រាងប្រកាសស្តីពីការបំពេញបែបបទគយមុនទំនិញមកដល់ (Pre-Arrival Clearance) និងបានកែសម្រួលបច្ចេកទេសប្រព័ន្ធសម្រាប់គាំទ្រដល់ការអនុវត្តនីតិវិធីនេះ និងអនុវត្តវិធានការមួយចំនួនទៀត។

ក្រៅពីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននិងកំពុងសហការអនុវត្តគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប (ហិរញ្ញប្បទានបន្ថែម) ដែលមានទឹកប្រាក់ប្រមាណ ៦៦ លានដុល្លារអាមេរិក, ហើយក៏បាននិងកំពុងសហការអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច (AIMS) ជាមួយមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម (IFAD) ដែលមានទឹកប្រាក់សរុបប្រមាណ ៦១លានដុល្លារអាមេរិក។ ក្រសួងក៏បានជំរុញលើកទឹកចិត្តដល់ក្រុមហ៊ុនកសិ-ឧស្សាហកម្ម ចំនួន ៤ ក្រុមហ៊ុនឱ្យចូលជាសមាជិកក្រុមធុរជនល្អបំផុត ដើម្បីទទួលបានកញ្ចប់លើកទឹកចិត្តក្នុងការសម្រួលនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយទាំងនាំចូល និងនាំចេញ។

**ឥ.៦ ទីស្តីការគណៈរដ្ឋមន្ត្រី**

ទីស្តីការគណៈរដ្ឋមន្ត្រី បានចូលរួមប្រជុំពាក់ព័ន្ធនឹង IDP លើការជំរុញនិងអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម។

### ២.៣.៣ ការកែលម្អបរិស្ថាននិយ័តកម្ម

#### ក. វិធានការសម្រួលពាណិជ្ជកម្ម និងជំរុញការនាំចេញ

ក្នុងរយៈពេលកន្លងមកនេះ ក្នុងចំណោមវិធានការគោលនយោបាយចំនួន១១ ដែលពាក់ព័ន្ធនឹង "ការសម្រួលពាណិជ្ជកម្ម និងជំរុញការនាំចេញ" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធ សម្រេចបានវឌ្ឍនភាពជាច្រើន ដូចខាងក្រោម÷

**ក.១. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងបន្តរៀបចំប្រព័ន្ធតាមដានការវិនិយោគ (Investment Tracking System) និងបន្តពង្រឹងការតាមដាន និងការអនុម័តលើសំណើសុំនាំចូលដោយអនុគ្រោះពន្ធជាប្រចាំរបស់រដ្ឋរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។

### ក.២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានពង្រីកភាពគ្របដណ្តប់លើភូមិសាស្ត្រ និងមុខងារប្រព័ន្ធស្វ័យប្រវត្តិកម្មគយ (អាស៊ីគូដា) ទៅគ្រប់ការិយាល័យគយ និងរដ្ឋាករនៅទូទាំងប្រទេស។ ជាងនេះទៅទៀត ក្រសួងក៏បាននិងកំពុងរៀបចំ អភិវឌ្ឍ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធបញ្ជរតែមួយជាតិ ដែលប្រព័ន្ធនេះត្រូវដាក់ឱ្យអនុវត្តសាកល្បងនៅតាមបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន ដែលរួមមាន ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសុខាភិបាល, ក្រសួងពាណិជ្ជកម្ម និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ព្រមទាំងកំពង់ផែអន្តរជាតិ និងអាកាសយានដ្ឋានអន្តរជាតិ។ ជាមួយគ្នានេះ ក្រសួងក៏បាននិងកំពុងធ្វើទំនើបកម្មនូវប្រព័ន្ធមួយចំនួនពាក់ពន្ធនឹងមុខងារគយ ដូចជា ប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យគយ (CRMDS), ប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (TCMS), ប្រព័ន្ធទ្រទ្រង់តម្លៃគិតពន្ធគយ (CVSS) ប្រព័ន្ធស្ថិតិគយ, និងប្រព័ន្ធប្រកាសប្រតិវេទន៍គយឆ្លងកាត់តាមទម្រង់អេឡិចត្រូនិក។ ទន្ទឹមគ្នានេះ ក្រសួងក៏បាននិងបន្តចូលរួមដោះស្រាយបញ្ហាប្រឈមក្នុងវិស័យគយ ក្រោមក្របខណ្ឌយន្តការភាពជាដៃគូគយ និងផ្នែកឯកជន (CPPM) ជាទៀងទាត់ផងដែរ។

### ក.៣ ក្រសួងសាធារណការ និងដឹកជញ្ជូន

ក្រសួងសាធារណការ និងដឹកជញ្ជូន បានបន្តខិតខំជំរុញ និងអភិវឌ្ឍកិច្ចសម្រួល ហេដ្ឋារចនាសម្ព័ន្ធ និងការងារតភ្ជាប់។ ក្របខណ្ឌក្នុងប្រទេស ក្រសួងបានបន្តរៀបចំផែនការមេថ្នាក់ជាតិស្តីពីការដឹកជញ្ជូន និងភស្តុភារកម្ម និងអនុវត្តគួរកត់សម្គាល់នូវគម្រោងអភិវឌ្ឍនិងស្តារហេដ្ឋារចនាសម្ព័ន្ធនានា ដូចជា ផ្លូវថ្នល់ ផ្លូវដែក ជាដើម។ ក្នុងក្របខណ្ឌនៃការអភិវឌ្ឍការតភ្ជាប់ក្នុងអនុតំបន់និងតំបន់ ក្រសួងក៏បានបន្តអនុវត្តគម្រោងកិច្ចប្រតិបត្តិការទ្វេភាគី ត្រីភាគី និងពហុភាគី លើការសាងសង់ស្ពាន ផ្លូវភ្ជាប់ ផ្លូវល្បឿនលឿន ផ្លូវដែក ហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ ជាដើម ព្រមទាំងបាននិងកំពុងពិចារណា និងចរចាក្នុងការបង្កើនចំនួនច្រក និងកូតាយានយន្តឆ្លងកាត់ព្រំដែន ជាមួយបណ្តាប្រទេសជិតខាង ក៏ដូចជាជាមួយបណ្តាប្រទេសក្នុងអនុតំបន់ និងតំបន់។ បន្ថែមពីនេះ ក្រសួងក៏បន្តជំរុញកិច្ចប្រតិបត្តិការលើការងារដឹកជញ្ជូនឆ្លងកាត់ព្រំដែន ទាំងទំនិញ ទាំងអ្នកដំណើរ និងទទួលលទ្ធផលជាផ្លែផ្កាជាបន្តបន្ទាប់។ មកទល់បច្ចុប្បន្ននេះ ក្រសួងបាននិងកំពុងពិចារណា និងចរចាក្នុងការបង្កើនចំនួនច្រក និងកូតាយានយន្តឆ្លងកាត់ព្រំដែន ជាមួយបណ្តាប្រទេសជិតខាង ក៏ដូចជាជាមួយបណ្តាប្រទេសក្នុងអនុតំបន់ និងតំបន់។

### ក.៤ ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្ម បានបន្តកែលម្អនីតិវិធីពាណិជ្ជកម្មយ៉ាងសស្រាក់សស្រាំ, រៀបចំមជ្ឈមណ្ឌលពាណិជ្ជកម្មនិងបង្កើតតំណាងពាណិជ្ជកម្មនៅក្រៅប្រទេស និងដំឡើងស្ថានអគ្គរាជទូតទទួលបន្ទុកពាណិជ្ជកម្មនៅអង្គការពាណិជ្ជកម្មពិភពលោក។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញការចូលរួមផ្សព្វផ្សាយផលិតផលខ្មែរ

ក៏ដូចជាលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យម តាមរយៈការចូលរួមរៀបចំពិព័រណ៍ និងព្រឹត្តិការណ៍នានា ដែលទាក់ទងពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ ទាំងក្នុង និងក្រៅប្រទេស។ ជាមួយគ្នានេះ ក្រសួងបានបន្តអនុវត្តគម្រោងកសិកម្មទីផ្សារខ្នាតតូច (AIMs) នៅតាមមូលដ្ឋាន និងបានបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសាងសង់ផ្សារព្រំដែនកម្ពុជា-វៀតណាម។ លើសពីនេះ ក្រសួងបានបន្តអនុវត្តការចុះបញ្ជីសហគ្រាស/ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ/ការចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិកត្រូនិក និងការបង់កម្រៃសេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិច (E-payment) ផងដែរ។

**ក.៥ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បាននិងកំពុងជំរុញ និងអនុវត្តកម្មវិធីពានរង្វាន់ "ស៥" ហើយមកដល់បច្ចុប្បន្ននេះ ពានរង្វាន់ "ស៥" នេះ ត្រូវបានផ្តល់ជូនក្រុមហ៊ុនសហគ្រាស រោងចក្រ និងសិប្បកម្ម សរុបបានចំនួន ១៥៣ពានរង្វាន់។

**ក.៦ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ**

ក្រៅពីក្រសួង ស្ថាប័ន៥ខាងលើ វិធានការពាក់ព័ន្ធនឹងការសម្រួលពាណិជ្ជកម្ម និងជំរុញការនាំចេញនេះ មានការចូលរួមអនុវត្តយ៉ាងសកម្មផងដែរពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, និងរដ្ឋបាលខេត្តស្វាយរៀង។ សកម្មភាពអនុវត្តលម្អិត មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២ នៃរបាយការណ៍នេះ។

**ខ- ការពង្រឹងបទដ្ឋានឧស្សាហកម្ម និងកម្មសិទ្ធិឧស្សាហកម្ម**

ក្នុងការអនុវត្តវិធានការគោលនយោបាយទាំង៩ ដែលពាក់ព័ន្ធនឹង "ការពង្រឹងបទដ្ឋានឧស្សាហកម្ម និងកម្មសិទ្ធិឧស្សាហកម្ម" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើនដូចខាងក្រោម÷

**ខ.១. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានបន្តលើកកម្ពស់ផលិតផលកម្ពុជាឱ្យកាន់តែមានភាពប្រកួតប្រជែងក្នុងផលិតកម្ម, ការលើកកម្ពស់គុណភាពផលិតផល, និងការធ្វើពាណិជ្ជកម្មលើទីផ្សារ ដោយបានកំណត់ស្តង់ដារជាតិចំនួន ១៤៨ស្តង់ដារ ជាបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ប្រើប្រាស់ក្នុងប្រទេស (លើផលិតផលម្ហូបអាហារ ផលិតផលអគ្គិសនី ផលិតផលយានយន្ត និងអេឡិចត្រូនិក)។ ជាមួយគ្នានេះ ក្រសួងបានទទួលធ្វើតេស្តវិភាគគំរូផលិតផល ដោយរួមបញ្ចូលផ្នែកមីក្រូជីវសាស្ត្រម្ហូបអាហារ និងទឹក គីមីសាស្ត្រទឹក គីមីសាស្ត្រម្ហូបអាហារ និងគីមីសាស្ត្រមិនមែនម្ហូបអាហារ។ ក្រសួងបានបន្តផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្ម និងការចុះបញ្ជីគំនូរឧស្សាហកម្ម,ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍។ បច្ចុប្បន្ននេះ ក្រសួងកំពុងបន្តពង្រឹងក្របខណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រងការងារមាត្រាសាស្ត្ររបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន សម្រាប់សកម្មភាពឧស្សាហកម្ម សេវាសាធារណៈ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រម

ទាំងបានខិតខំប្រឹងប្រែងបន្តរៀបចំក្របខណ្ឌគតិយុត្តិ និងសិក្សាស្រាវជ្រាវរៀបចំនីតិវិធីត្រួតពិនិត្យផ្ទៀងផ្ទាត់ព្យាសកម្ម តេស្តវិភាគ និងអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រ ដែលបម្រើឱ្យវិស័យឧស្សាហកម្មផងដែរ។

**ខ.២ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ**

ក្រៅពីក្រសួងឧស្សាហកម្មនិងសិប្បកម្ម វិធានការពាក់ព័ន្ធនឹងការពង្រឹងបទដ្ឋានឧស្សាហកម្ម និងកម្មសិទ្ធិឧស្សាហកម្មនេះ មានការចូលរួមអនុវត្តយ៉ាងសកម្មពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងរដ្ឋបាលខេត្តកណ្តាល។ សកម្មភាពអនុវត្តលម្អិត មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២ នៃរបាយការណ៍នេះ។

**គ. ការសម្រួលការបំពេញកាតព្វកិច្ចពន្ធ និងអាករ**

ក្នុងការអនុវត្តវិធានការគោលនយោបាយទាំង៥ ដែលពាក់ព័ន្ធទៅនឹងការសម្រួលការបំពេញកាតព្វកិច្ចពន្ធនិងអាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានពិនិត្យឡើងវិញនូវប្រព័ន្ធពន្ធ និងអាករលើផលិតផលសំខាន់មួយចំនួន និងបានធ្វើទំនើបកម្មយន្តការពន្ធដារ និងគយ រួមទាំងយន្តការប្រមូលចំណូល តាមរយៈការធ្វើវិចារណកម្ម និងការគាំទ្រដោយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ដើម្បីសម្រួលបន្ថែមដល់ការបង់ពន្ធ ក្រសួងបានរៀបចំការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធតាមធនាគារ និងកំពុងរៀបចំប្រព័ន្ធអេឡិចត្រូនិកសម្រាប់ការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធផងដែរ។

ចំពោះការរៀបចំក្របខណ្ឌគតិយុត្តពាក់ព័ន្ធ ក្រសួងបានបន្តចូលរួមរៀបចំបទប្បញ្ញត្តិទាក់ទិននឹងការសម្រួល ឬដកចេញនូវយន្តការទាំងឡាយណាដែលបណ្តាលឱ្យខ្វាស់គ្នារវាងនីតិវិធីនៃការយកពន្ធ និងការលើកលែងពន្ធ, បានពង្រឹងយន្តការបង្វិលសង តាមរយៈយន្តការវាយតម្លៃអនុលោមភាពរបស់អ្នកជាប់ពន្ធ, បានបង្កើតការិយាល័យបង្វិលសងអាករលើតម្លៃបន្ថែម, និងបានកាត់បន្ថយរយៈពេលបង្វិលសងបានឆាប់រហ័សជាងមុន។

ក្រៅពីវឌ្ឍនភាពការងារខាងលើ ក្រសួងក៏បានសិក្សាស្រាវជ្រាវ និងរៀបចំយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ព្រមទាំងរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិឆ្នាំ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ ដោយមានបញ្ចូលសកម្មភាព ដែលត្រូវអនុវត្តដើម្បីបន្តកែលម្អសេវាអ្នកជាប់ពន្ធ និងបានរៀបចំយុទ្ធសាស្ត្រកំណែទម្រង់និងទំនើបកម្មគយឆ្នាំ ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។ បន្ថែមពីនេះ ក្រសួងបានបន្តកិច្ចសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ លើការងារពាក់ព័ន្ធនឹងការផ្លាស់ប្តូរទិន្នន័យ ការលើកទឹកចិត្តពន្ធអាករ និងការកសាងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ, ព្រមទាំងបានកែសម្រួលសមាសភាពក្រុមការងារកិច្ចសហប្រតិបត្តិការរវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ។

### ឃ- ការរៀបចំទីផ្សារពលកម្ម និងទំនាក់ទំនងវិជ្ជាជីវៈ

ក្នុងចំណោមវិធានការគោលនយោបាយទាំង៩ ដែលពាក់ព័ន្ធនឹង "ការរៀបចំទីផ្សារពលកម្ម និងទំនាក់-ទំនងវិជ្ជាជីវៈ" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធ សម្រេចបានវឌ្ឍនភាពជាច្រើន ដូចខាងក្រោម÷

### ឃ.១- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជាតិមុខរបរ និងការងារ

ក្នុងក្របខណ្ឌនៃការរៀបចំច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការលើកកម្ពស់ផលិតភាពការងារ និងសុខុមាលភាពនិយោជិត ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្តរៀបចំ សម្របសម្រួល និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា, បានបន្តពង្រឹងយន្តការគណៈកម្មការប្រឹក្សាការងារដែលជាយន្តការត្រីភាគីក្នុងការចរចាប្រាក់ឈ្នួលអប្បបរមា អត្ថប្រយោជន៍ផ្សេងៗ, និងលក្ខខណ្ឌការងារ, ព្រមទាំងបានបន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសហជីពឱ្យមានប្រសិទ្ធភាព។ ជាមួយគ្នានេះ ក្រសួងក៏បានសហការ និងផ្តល់ធាតុចូលដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការរៀបចំគោលនយោបាយ និងកំណត់លក្ខណៈវិនិច្ឆ័យដល់កម្មករនិយោជិតដែលអាចមានលទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅដ្ឋានសម្រាប់បង្កើតគ្រួសារ និងមិនធ្វើការផ្លាស់ប្តូរទីលំនៅញឹកញាប់ពេក ដែលបង្កើតបញ្ហាខ្វះកម្លាំងពលកម្មក្នុងរយៈពេលខ្លី។

ទន្ទឹមនឹងនេះ ក្រសួងក៏បានបន្តពង្រឹងយន្តការចុះធ្វើអធិការកិច្ចលក្ខខណ្ឌការងារ តាមរយៈការច្របាច់បញ្ចូលគ្នាការធ្វើអធិការកិច្ចផ្សេងៗគ្នាឱ្យទៅជាក្រុមអធិការកិច្ចការងារតែមួយ, ការប្រើប្រាស់បទដ្ឋានវាយតម្លៃតែមួយ និងចុះធ្វើអធិការកិច្ចក្នុងពេលតែមួយ, ការធ្វើទំនើបកម្មប្រព័ន្ធអធិការកិច្ចការងារ, ការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងរបាយការណ៍ស្តីពីអធិការកិច្ចការងារ តាមប្រព័ន្ធព័ត៌មានវិទ្យា, និងការរៀបចំនិងដាក់ឱ្យអនុវត្តនូវសៀវភៅណែនាំ (Guidelines) ស្តីពីអធិការកិច្ចការងារ និងសៀវភៅក្រមសីលធម៌សម្រាប់មន្ត្រីអធិការកិច្ចការងារ។

ក្រៅពីនេះ ដើម្បីពង្រឹងយន្តការគ្រប់គ្រងការជ្រើសរើសកម្លាំងពលកម្ម ការផ្តល់ព័ត៌មានទីផ្សារការងារ និងការបណ្តុះបណ្តាលកម្មករនិយោជិតកាន់តែទូលំទូលាយ ក្រសួងបានពង្រីកការផ្តល់សេវាការងារទូទាំងប្រទេស តាមរយៈការពង្រីកមជ្ឈមណ្ឌលការងារ, ការរៀបចំ "វេទិកាការងារ", និងការពង្រីកការផ្តល់ព័ត៌មានទីផ្សារការងារជាដើម។ ជាមួយគ្នានេះ ក្នុងទិសដៅពង្រឹងយន្តការគ្រប់គ្រងកម្មករជំនាញ ជាពិសេសត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់សមាហរណកម្មអាស៊ាន ក្រសួងបានបង្កើតគណៈកម្មការសម្រប-សម្រួលថ្នាក់ជាតិ និងពង្រឹងសមត្ថភាពមន្ត្រី និងគ្រូបច្ចេកទេសអំពីវិធីសាស្ត្រផ្ទៀងផ្ទាត់ស្តង់ដារជាតិ និងស្តង់ដារតំបន់ផងដែរ។

ឃ.២ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏បានសហការជាមួយក្រុមហ៊ុន B & BM Development Co., Ltd. សាងសង់លំនៅឋានតម្លៃសមរម្យចំនួន ៥.៣៤០បន្ទប់ នៅខេត្តកណ្តាល និងសហការជាមួយក្រុមហ៊ុន Arakawa សាងសង់លំនៅឋានតម្លៃសមរម្យ ចំនួន ២.០០០បន្ទប់ នៅរាជធានីភ្នំពេញ។ ទន្ទឹមនឹងនេះ ក្រសួងបានសហការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិរៀបចំនិងទទួលបានការអនុម័តពីរាជរដ្ឋាភិបាល លើគោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ។ ជាមួយគ្នានេះ ក្រសួងក៏បានអនុវត្តសកម្មភាពជាច្រើន សំដៅចូលរួមលើកកម្ពស់សុខុមាលភាពរបស់កម្មករ តាមរយៈការផ្តល់ការគាំទ្របច្ចេកទេសលើការសិក្សាទីតាំងលំនៅឋាន, ការចុះប្រមូលទិន្នន័យកំណត់ស្ថានភាពលំនៅឋានដើម្បីកែលំអ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធលំនៅឋាន, ការបានចុះពិនិត្យការដ្ឋានគម្រោងអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ, និងការពិនិត្យនិងផ្តល់យោបល់លើសំណើគម្រោងអភិវឌ្ឍលំនៅឋាន និងការសាងសង់លំនៅឋានបន្សាំនឹងការប្រែប្រួលអាកាសធាតុ ជាដើម។

ឃ.៣ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ

បន្ថែមពីលើក្រសួងទាំងពីរខាងលើ ក៏នៅមានក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋបាលខេត្តស្វាយរៀង និងរដ្ឋបាលខេត្តព្រះសីហនុ ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការផ្សព្វផ្សាយច្បាប់បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងព័ត៌មានការងារ និងជំរុញសហគ្រាសគ្រឹះស្ថាន ឱ្យអនុវត្តកាតព្វកិច្ចហិរញ្ញវត្ថុ... តាមគោលការណ៍កំណត់។ សកម្មភាពអនុវត្តលម្អិត មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២ នៃរបាយការណ៍នេះ។

## ២.៣.៤ ការសម្របសម្រួលគោលនយោបាយគាំទ្រ

### ក. ការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស

ក្នុងចំណោមវិធានការគោលនយោបាយទាំង១៣ ពាក់ព័ន្ធទៅនឹង "ការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើនដូចខាងក្រោម÷

ក.១ ក្រសួងអប់រំ យុវជន និងកីឡា

ពាក់ព័ន្ធនឹងការបង្កើតប្រព័ន្ធសមមូលសញ្ញាបត្រ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំ និងអនុវត្តនូវកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ កម្មវិធីសិក្សាសមមូលកម្រិតបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ ទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ កម្មវិធីសិក្សាសមមូលកម្រិតមូលដ្ឋានតាមប្រព័ន្ធអ៊ិនធឺណែត និងកម្មវិធីផ្សេងៗទៀតក្នុងវិស័យអប់រំនៅតាមបណ្តារាជធានី ខេត្ត ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ និងតួអង្គពាក់ព័ន្ធ។ លិខិតបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធនឹងបណ្តាកម្មវិធីខាងលើក៏ត្រូវបាននិងកំពុងរៀបចំជាបន្តបន្ទាប់។ ក្រៅពីនេះ ក្រសួងបានពង្រឹងគុណភាពអប់រំ ជាពិសេសលើផ្នែកគណិតវិទ្យា វិទ្យាសាស្ត្រ អក្សរសាស្ត្រ និងបច្ចេកវិទ្យា

ដោយបានរាប់បញ្ចូលទាំងការអនុវត្តគោលនយោបាយអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា, មុខវិជ្ជាស្ទែម (STEM), និងអភិវឌ្ឍកម្មវិធីសិក្សាបែបអេឡិចត្រូនិចជាដើម។ ពាក់ព័ន្ធនឹងការកែលម្អកម្មវិធីសិក្សាដោយដាក់បញ្ចូលជំនាញទន់ ក្រសួងបានបញ្ជ្រាបជំនាញទន់ទៅក្នុងវិធីសាស្ត្របង្រៀនតាមមុខវិជ្ជានៅតាមគ្រឹះស្ថានសិក្សា និងបញ្ចូលកម្មវិធីបណ្តុះបណ្តាលសហគ្រិនភាព ភាពជាអ្នកដឹកនាំ និងជំនាញទន់ ទៅក្នុងមុខវិជ្ជាបំណិនជីវិត។

ចំពោះការបណ្តុះបណ្តាលបច្ចេកទេស ក្រសួងបានណែនាំការបែងចែកកម្មវិធីសិក្សាអប់រំបច្ចេកទេសមុខជំនាញបច្ចេកទេសអគ្គិសនី មេកានិក កេ្សត្រសាស្ត្រ និងបសុវប្បកម្ម, និង អភិវឌ្ឍសៀវភៅសិក្សាគោលផ្នែកអប់រំបច្ចេកទេសលើ ៥ជំនាញ រួមមានអគ្គិសនី មេកានិច អេឡិចត្រូនិច កេ្សត្រសាស្ត្រ និងបសុវប្បកម្មសម្រាប់ឆ្នាំទី១។ នៅឆ្នាំ២០១៨ ក្រសួងមានវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសចំនួន ១៤ ស្ថិតក្នុងរាជធានីភ្នំពេញ និងខេត្តចំនួន ១៣ ដែលមានសិស្សសរុបចំនួន ១.៤៧១ ដែលផ្តោតលើជំនាញអគ្គិសនី អេឡិចត្រូនិច បសុវប្បកម្ម កេ្សត្រសាស្ត្រ និងមេកានិច។ ក្រសួងក៏បានបង្កើតវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ ដោយសហការជាមួយនឹងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ និងបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍការអប់រំបច្ចេកទេសតំបន់អាស៊ីអាគ្នេយ៍, ព្រមទាំងបានសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍មួយចំនួន ដើម្បីជួយគាំទ្រដល់ការបណ្តុះបណ្តាល លើមុខជំនាញពាក់ព័ន្ធនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងការងារពាក់ព័ន្ធផ្សេងៗទៀត។ បន្ថែមពីនេះ ក្រសួងបានផ្តួចផ្តើមអនុវត្តកម្មវិធីអក្ខរកម្មសម្រាប់កម្មករ កម្មការិនីតាមរោងចក្រ ដោយសហការជាមួយដៃគូអភិវឌ្ឍ និងម្ចាស់រោងចក្រនៅរាជធានីភ្នំពេញ ខេត្តសៀមរាប កណ្តាល និងកំពង់ស្ពឺ។ កម្មវិធីនេះត្រូវបានពង្រីកដល់ ១១ខេត្ត និងរាជធានីភ្នំពេញនៅឆ្នាំ២០១៨។

### ក.២. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជាតិមុខរបរ និងការងារ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ចេញនូវវិធានការ និងកម្មវិធីសិក្សាមួយចំនួន ដោយសហការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីបង្កើតឱកាសទីពីរសម្រាប់ការទទួលបានការបញ្ចប់ថ្នាក់មធ្យមសិក្សាក្នុងនោះរួមមាន ការពង្រីកការបណ្តុះបណ្តាលកម្មវិធីស្ពានចម្លងបន្តជំនាញ សម្រាប់ផ្តល់ឱកាសទី២ដល់សិស្សដែលបានបោះបង់ការសិក្សានៅថ្នាក់ទី៧, ៨, និង៩ ដើម្បីអាចបន្តការសិក្សាទៅប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈផ្លូវការ បានចំនួន ២ ៧២៣នាក់ ត្រឹមឆ្នាំ២០១៨ និងបានអនុវត្តសាកល្បង លើកម្មវិធីទទួលស្គាល់ការសិក្សាពីមុន (Recognition of Prior Learning- RPL) ដល់សិក្ខាកាម ១៦២នាក់ ក្នុងឆ្នាំ២០១៨ លើមុខរបរការថែទាំ និងជួសជុលម៉ូតូ ការថែទាំនិងជួសជុលម៉ាស៊ីនធុនតូច និងការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ។ ក្រសួង បានផ្តល់ការបណ្តុះបណ្តាលសិស្សបច្ចេកទេសវិជ្ជាជីវៈ (C១, C២, និងC៣) ក្នុងវិស័យអាទិភាព (សំណង់ មេកានិក អគ្គិសនី/ អេឡិចត្រូនិក សេវាកម្មធុរកិច្ច/ ព័ត៌មានវិទ្យា និងកម្មន្តសាល) ចំនួន ៥ ៥២៩ នាក់ ក្នុងឆ្នាំ២០១៧ និង២០១៨ និងកម្រិតជាន់ខ្ពស់បច្ចេកទេស/ឯកទេស និងវិស្វករ ចំនួន ៩ ១០៥នាក់។

ជាមួយគ្នានេះ ក្រសួង ក៏បានបង្កើនការផ្តល់ការហ្វឹកហ្វឺនគ្រូជាងបានចំនួន ៥១ ០០១នាក់ នៅក្នុងឆ្នាំ ២០១៧ និងឆ្នាំ២០១៨។ ក្រសួង ក៏បានដាក់ឱ្យដំណើរការមជ្ឈមណ្ឌលឡានឆាងមេគង្គ នៅវិទ្យាស្ថានជាតិពហុ-បច្ចេកទេសកម្ពុជា ក្រោមគម្រោងឡានឆាងមេគង្គ នៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងឆ្នាំ២០១៨, និងបានបង្កើត វិទ្យាស្ថានពហុបច្ចេកទេសមិត្តភាពកម្ពុជា-ចិនខេត្តព្រះសីហនុ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ក្រោមគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន តាមរយៈ Wuxi Vocational Institute of Commerce នៅឆ្នាំ២០១៧ និងចាប់ផ្តើមផ្តល់ការបណ្តុះបណ្តាល ក្នុងឆ្នាំ២០១៨ លើមុខជំនាញ មេកានិករថយន្ត, អគ្គិសនី, សំណង់, ព័ត៌មានវិទ្យា, ទេសចរណ៍, និងបដិសណ្ឋារកិច្ច ដល់សិស្ស-និស្សិតចំនួន ២១០នាក់ និងសាលាមធ្យមសិក្សាបច្ចេកទេស និងវិជ្ជាជីវៈផ្លូវសូត្រ ចំនួន ៤ កន្លែង (NTTI, PPI, ITI, RTC BATTAMBANG)។ ក្រសួងក៏បានបង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យចំនួន ៤ គឺ វិស័យសំណង់នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ, វិស័យអគ្គិសនីនៅវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ, វិស័យមេកានិករថយន្តនៅវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង និងវិស័យកម្មន្តសាលនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា។ ក្រោមភាពជាដៃគូរវាងសាធារណៈ និងវិស័យឯកជន (PPP) ក្រសួងបានបណ្តុះបណ្តាលជំនាញដល់ជាងកំបោរ ជាងផ្សា ជាងក្រឡឹង អគ្គិសនី រថយន្ត បរិក្ខារត្រជាក់ អ៊ុបទិក និងសិល្បៈចម្អិនម្ហូប ចំនួន ៥០០នាក់ ក្នុងឆ្នាំ២០១៧ និង២០១៨។

### ក.៣. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ក្នុងឆ្នាំ២០១៧-២០១៨ ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីសុវត្ថិភាព ការផ្ទេរបច្ចេកវិទ្យា និងបរិស្ថានឧស្សាហកម្ម ដល់ម្ចាស់រោងចក្រ សហគ្រាសក្នុងស្រុក បានចំនួន ១២ដង ដោយមានសិក្ខាកាមចូលរួមចំនួន ២,២៧០នាក់ ដើម្បីបញ្ជ្រាបចំណេះដឹងដល់កម្មករ និយោជិត ពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា។

### ក.៤ ក្រសួង ស្ថាប័នពាក់ព័ន្ធ

ក្រៅពីក្រសួងទាំង៣ខាងលើ ក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, និងរដ្ឋបាលខេត្តកណ្តាល ក៏បានចាត់មន្ត្រីចូលរួម និងរៀបចំកម្មវិធីផ្សេងៗពាក់ព័ន្ធនឹងការបណ្តុះបណ្តាលជំនាញ និងអភិវឌ្ឍធនធានមនុស្ស។ សកម្មភាពអនុវត្តលម្អិត មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២ នៃរបាយ-ការណ៍នេះ។

## ខ. ការជំរុញវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ក្នុងចំណោមវិធានការគោលនយោបាយទាំង១០ ដែលពាក់ព័ន្ធទៅនឹង "ការជំរុញវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើន ដូចខាងក្រោម÷

### ៦.១. ក្រសួងផែនការ

ក្រសួងផែនការ ក្នុងការរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣ ដែលជាឯកសារតែមួយគត់របស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដើម្បីឈានទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ បានធ្វើការណែនាំច្បាស់លាស់ដល់គ្រប់ក្រសួង ស្ថាប័នទាំងអស់រៀបចំធាតុចូលរបស់ខ្លួនសម្រាប់អនុវត្តក្នុងចតុកោណទី២ "ការធ្វើពិពិធកម្មសេដ្ឋកិច្ច" ដែលមានជ្រុង "ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល" និងការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងការឆ្លើយតបបដិវត្តន៍ឧស្សាហកម្មទី៤" ដែលជារួមក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធជាមួយចតុកោណទី២នេះ បានបំពេញទៅតាមការណែនាំរបស់ក្រសួង ។ មកទល់ពេលនេះ ឯកសារ ផ.យ.អ.ជ. ២០១៩-២០២៣ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី សភាជាតិ ព្រឹទ្ធសភា និងឡាយព្រះហស្ថដោយព្រះមហាក្សត្រលើព្រះរាជក្រមសម្រាប់អនុវត្តរួចរាល់ហើយ។

### ៦.២ ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំ និងអនុវត្តនូវសកម្មភាពជាច្រើនដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយក្នុងនោះ ក្រសួងបានដាក់ឱ្យដំណើរការគេហទំព័រគ្រូ/មជ្ឈមណ្ឌលធនធានអប់រំ (Krou/Teacher Website) និងទំព័របណ្តាញសង្គមហ្វេសប៊ុកផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា (MoEYS Cambodia), បាននិងកំពុងផ្សព្វផ្សាយខ្លឹមសារព័ត៌មាន និងឯកសារក្នុងទម្រង់ឌីជីថល/អេឡិចត្រូនិក ជូនដល់សិស្ស និស្សិត គ្រូ សាស្ត្រាចារ្យ និងសាធារណជន, ព្រមទាំងបានបង្កើតប្រព័ន្ធគ្រប់គ្រងសាលារៀន (SMAS: School Management System)។

ពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពទៅតាមតម្រូវការសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍, ក្រសួងបានដាក់ឱ្យអនុវត្តលក្ខខណ្ឌប្រតិបត្តិនាយកទទួលបន្ទុកស្រាវជ្រាវ និងនាយកមជ្ឈមណ្ឌលស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា ព្រមទាំងបានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រ និងការស្រាវជ្រាវគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងប្រទេសផ្លូវមួយខ្សែក្រវាត់មួយ និងបញ្ជូនគ្រូបង្រៀនឧត្តមសិក្សាទៅសិក្សានៅប្រទេសបារាំង ថ្នាក់បណ្ឌិតផ្នែក STEM តាមរយៈកម្មវិធីអាហារូបករណ៍សហហិរញ្ញប្បទានរវាងក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋាភិបាលបារាំង។

ពាក់ព័ន្ធនឹងវិធានការបង្កើតយន្តការប្រឡងប្រណាំងផ្សេងៗ ដើម្បីចម្រាញ់ឧស្សាហករដែលមានទេពកោសល្យ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំការប្រកួតវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅតាមអនុវិទ្យាល័យ និងវិទ្យាល័យ ក្នុងខេត្តបាត់ដំបង កំពង់ចាម និងសៀមរាប ព្រមទាំងបានបង្កើនថវិកាឧបត្ថម្ភសម្រាប់ជ័យលាភីថ្នាក់ជាតិ និងអន្តរជាតិ។ ក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ កម្រិតថ្នាក់ជាតិ ក្រសួងបានជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា

ថ្នាក់ទី៩ និងថ្នាក់ទី១២ ចំនួន៦០នាក់ក្នុងមួយឆ្នាំ ដែលក្នុងមួយមុខវិជ្ជា និងមួយកម្រិតថ្នាក់ជ្រើសយក ១០ នាក់។ រីឯកម្រិតអន្តរជាតិ ក្រសួងបាន (១) បញ្ជូនសិស្សថ្នាក់ទី៥ និងទី៦ ចំនួន ៤០នាក់ ចូលរួមប្រឡងប្រជែងសិស្សពូកែគណិតវិទ្យាអូឡាំព្យាដអន្តរជាតិ, (២) បញ្ជូនសិស្សពូកែ ១២រូប ទៅចូលរួមប្រកួតប្រជែងអ្នកវិទ្យាសាស្ត្រវ័យក្មេងអាស៊ានបូកបីលើកទី៦ និងលើកទី៧, (៤) បញ្ជូនសិស្សពូកែគណិតវិទ្យា ១៦រូប ទៅចូលរួមប្រឡងប្រជែងគណិតវិទ្យាអូឡាំព្យាដអន្តរជាតិលើកទី៥៨ និងលើកទី៥៩, (៥) បញ្ជូនសិស្សពូកែរូបវិទ្យា ១០រូប ទៅចូលរួមប្រឡងប្រជែងរូបវិទ្យាអូឡាំព្យាដអន្តរជាតិ លើកទី៤៨ និងលើកទី ៤៩, (៦) បញ្ជូនសិស្សពូកែ ៣០រូប ទៅចូលរួមប្រឡងប្រជែងអ្នកវិទ្យាសាស្ត្រវ័យក្មេងអូឡាំព្យាដអន្តរជាតិ លើកទី១៤ និងទី១៥, (៧) បញ្ជូនសិស្សពូកែគណិតវិទ្យា និងរូបវិទ្យា ៤រូប ចូលរួមប្រកួតប្រជែងជ្រើសរើសជើងឯកអ្នកវិទ្យាសាស្ត្រវ័យក្មេងរបស់ស៊ីមេអូ ក្នុងសន្និបាតថ្នាក់តំបន់លើកទី១១ ឆ្នាំ២០១៨នៅប្រទេសម៉ាឡេស៊ី, និង (៨) ជ្រើសរើសបណ្តុះបណ្តាល និងដឹកនាំសិស្សានុសិស្ស ៣៣រូប ចូលរួមប្រកួតប្រជែងក្នុងកម្មវិធី "ទិវាប្រវត្តិសាស្ត្រធម្មជាតិសកល" នៅចុងជឹង សាធារណរដ្ឋប្រជាមានិតចិន។

សម្រាប់ការជំរុញការអប់រំលើជំនាញផ្នែក STEM ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំពិព័រណ៍ មហោស្រព និងសិក្ខាសាលាពាក់ព័ន្ធនឹងការលើកកម្ពស់ និងការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការបង្រៀននិងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ដោយសហការជាមួយដៃគូពាក់ព័ន្ធ, ព្រមទាំងបានបង្កើត និងគាំទ្រក្លឹបសិក្សាគណិតវិទ្យានៅតាមអនុវិទ្យាល័យ និងវិទ្យាល័យក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបានជ្រើសរើសនិស្សិតស្ម័គ្រចិត្តឱ្យចូលរួមចុះជួយបង្កើត និងគាំទ្រក្លឹបសិក្សាគណិតវិទ្យានៅតាមអនុវិទ្យាល័យ និងវិទ្យាល័យក្នុងរាជធានីភ្នំពេញ បានចំនួន ១៧១នាក់។

**ខ.៣. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

ក្នុងឆ្នាំ២០១៧-២០១៨ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីសុវត្ថិភាពការផ្ទេរបច្ចេកវិទ្យា និងបរិស្ថានឧស្សាហកម្ម ដល់ម្ចាស់រោងចក្រ សហគ្រាសក្នុងស្រុក បានចំនួន ០៥ដង ដោយមានសិក្ខាកាមចូលរួមចំនួន ៥២៨នាក់ ដើម្បីបញ្ជ្រាបចំណេះដឹងដល់កម្មករ និយោជិត ពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យឧស្សាហកម្ម។ ក្រសួង ក៏បានរៀបចំ PIP Information ផ្ញើទៅក្រសួងផែនការ ស្តីពីការបង្កើតមជ្ឈមណ្ឌលភ្ញាស់បច្ចេកវិទ្យា (Technology Incubation Center) ដើម្បីត្រៀមលើកសំណើទៅដៃគូអភិវឌ្ឍន៍ស្នើសុំថវិកាអនុវត្តគម្រោង។ ពាក់ព័ន្ធនឹងការសហការនិងជំរុញការសិក្សាស្រាវជ្រាវ ក្រសួងបានបញ្ជូនមន្ត្រីជំនាញចំនួន ០៥រូប ឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងវេទិកាពិគ្រោះយោបល់ផ្សេងៗនៅបរទេស ដូចជាប្រទេសថៃ ចិន កូរ៉េ ជាដើម។

### ខ.៤ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្នុងគោលបំណងពង្រឹងនិងកសាងសមត្ថភាពធនធានមនុស្សទៅតាមតម្រូវការសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាឧស្សាហកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតកម្មវិធី និងផ្តល់មូលនិធិស្រាវជ្រាវ និងនវានុវត្តន៍ដល់គ្រឹះស្ថានចំនួន៣ ដើម្បីសាស្ត្រាចារ្យ និងនិស្សិត ធ្វើការសិក្សាស្រាវជ្រាវបង្កើតស្នាដៃ រួមគ្នាដើម្បីចាប់យកបច្ចេកវិទ្យាថ្មី ដូចជា Robot, Drone, AI និងបានបង្កើតមជ្ឈមណ្ឌលឧត្តមភាព (Centers of Excellence) ចំនួន ៤ (២នៅភ្នំពេញ និង១ នៅខេត្តបាត់ដំបង និង១ នៅខេត្តសៀមរាប)។ លើសពីនេះ ក្រសួងក៏បានរៀបចំការប្រកួតប្រជែងជំនាញថ្នាក់ជាតិលើកទី៦ នៅឆ្នាំ ២០១៧ លើ ៥ មុខជំនាញ (តបណ្តាញអគ្គិសនី, ផ្សារអគ្គិសនី, រៀបឥដ្ឋ, IT Software Solution for Business និង Web Design) មានបេក្ខជនចំនួន ៤៤នាក់, បានសហការជាមួយក្រុមហ៊ុន SCG រៀបចំការប្រកួតប្រជែងជំនាញបូក និងជំនាញប្រកដំបូល ដែលមានបេក្ខជន ១៤ក្រុម ចំនួន ៣៤នាក់ចូលរួម, បានបញ្ជូនបេក្ខជនចំនួន ១៣នាក់ ទៅចូលរួមការប្រកួតប្រជែងជំនាញថ្នាក់អាស៊ាននៅប្រទេសថៃ លើ ៨មុខជំនាញ នៅឆ្នាំ២០១៨ ព្រមទាំងបានបញ្ជូននិស្សិតទៅចូលរួមការប្រកួតប្រជែង Robot ថ្នាក់ជាតិចំនួន ២ លើក និងអន្តរជាតិចំនួន ១លើក ផងដែរ។

### ខ.៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានពិនិត្យ និងស្រាវជ្រាវច្បាប់ និងលិខិតបទដ្ឋានដែលមានស្រាប់ ដើម្បីពិនិត្យលទ្ធភាពរៀបចំគ្រឹះស្ថានសាធារណៈរដ្ឋបាល និងជំរុញនិងពង្រឹងតួនាទីរបស់គ្រឹះស្ថានឱ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ។ បន្ថែមលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានពិនិត្យលើការផ្តល់អាទិភាពវិភាជថវិកាសម្រាប់ចំណាយលើកម្មវិធី ដែលមានគោលដៅជំរុញការងារស្រាវជ្រាវលើផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ព្រមទាំងបានពិភាក្សាកម្រិតបច្ចេកទេសអំពីការផ្តល់ហិរញ្ញប្បទានចំពោះវិទ្យាស្ថានស្រាវជ្រាវរដ្ឋ។

### ខ.៦ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

នៅក្នុងក្របខណ្ឌច្បាប់ស្តីពីវិនិយោគ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសដោយពិចារណាពីលទ្ធភាពបង្កើតសួនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាភ្ជាប់នឹងសួនឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេសនានា ដើម្បីផ្តល់សេវាពិសោធន៍ និងសិក្សាស្រាវជ្រាវដល់ឧស្សាហកម្ម។

### ខ.៧ ក្រសួង ស្ថាប័នពាក់ព័ន្ធ

ក្រៅពីក្រសួង ស្ថាប័ន ៦ខាងលើ ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក៏បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត

វិធានការនេះពាក់ព័ន្ធនឹងការជំរុញវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ សកម្មភាពអនុវត្តលម្អិត មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២ នៃរបាយការណ៍នេះ។

## គ. ការកសាងហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍ឧស្សាហកម្ម

ក្នុងចំណោមវិធានការទាំង១២ ពាក់ព័ន្ធនឹង "ការកសាងហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍ឧស្សាហកម្ម" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើនដូចខាងក្រោម÷

### គ.១. ក្រសួងសាធារណការ និងដឹកជញ្ជូន

ក្នុងវិស័យដឹកជញ្ជូនខាងផ្លូវគោក ផ្លូវទឹក ផ្លូវដែក និងឆ្លងកាត់ព្រំដែន ក្រសួងសាធារណការ និងដឹក-ជញ្ជូន បានសម្រេចនូវលទ្ធផលជាច្រើនរួមមាន÷

ចំពោះការងារដឹកជញ្ជូនផ្លូវគោក ក្រសួង បានចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសសរុប ១០២ក្រុមហ៊ុន គិតពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៧។ ចំពោះការងារដឹកជញ្ជូនឆ្លងកាត់ព្រំដែន ក្រសួង បានចុះអនុស្សារណៈនៃការយោគយល់ស្តីពីការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនទ្វេភាគី កម្ពុជា-វៀតណាម, អនុស្សារណៈនៃការយោគយល់ស្តីពីការផ្លាស់ប្តូរសិទ្ធិចរាចរណ៍សម្រាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែននៅច្រកទ្វារប៉ោយប៉ែត-អារញ្ញប្រាថេត និងអនុស្សារណៈនៃការយោគយល់ស្តីពីការដឹកជញ្ជូនឆ្លងកាត់ព្រំដែនកម្ពុជា-ឡាវ-វៀតណាម។ លើសពីនេះទៅទៀត ប្រទេសជាសមាជិកមហាអនុតំបន់មេគង្គទាំង ០៦ ចាប់ផ្តើមអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនអ្នកដំណើរ និងទំនិញ។ ទន្ទឹមគ្នានេះ អាស៊ានបានកំពុងអនុវត្តគម្រោងសាកល្បងប្រព័ន្ធឆ្លងកាត់គយអាស៊ាន (ASEAN Customs Transit System - ACTS) កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) នៅឆ្នាំ២០១៨នេះ ដែលជាច្រករបៀងខាងកើត-លិចនៃអាស៊ាន បន្ទាប់ពីអនុវត្តគម្រោងសាកល្បងនៅប្រទេសសិង្ហបុរី ថៃ និងម៉ាឡេស៊ី ដែលជាច្រករបៀងខាងជើង-ត្បូងនៃអាស៊ានក្រោមជំនួយពីសហគមន៍អឺរ៉ុប ដោយចាប់ផ្តើមពីការរៀបចំប្រព័ន្ធឆ្លងកាត់គយ (ACTS)។

ចំពោះការងារដឹកជញ្ជូនផ្លូវទឹក ក្រសួងបានសិក្សា និងអនុវត្តគម្រោងដឹកជញ្ជូនទំនិញ និងអ្នកដំណើរតាមកាណូតចាប់ពីស្ពានព្រែកព្នៅ-ភ្នំពេញ-តាខ្មៅ សំដៅដល់ការកាត់បន្ថយការកកស្ទះចរាចរណ៍ និងការចំណាយរបស់ពលរដ្ឋលើការធ្វើដំណើរ។ គម្រោងនេះក៏បានដាក់ឱ្យដំណើរការកាណូតដឹកអ្នកដំណើរតាមផ្លូវទឹកក្នុងក្រុង ពីឫស្សីកែវ ទៅតាខ្មៅ ចំនួន០៥ស្ថានីយ។ ជាមួយគ្នានេះ ក្រសួងបានពង្រឹងគុណភាពនៃការផ្តល់សេវាសាធារណៈលើការចុះបញ្ជីជលយាន ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ការផ្តល់បណ្ណបើកបរបណ្ណយន្តការី និងលិខិតអនុញ្ញាតធ្វើអាជីវកម្មជលយានយន្ត, គ្រប់គ្រងនាវាដែលធ្វើនាវាចរណ៍តាមប្រព័ន្ធទន្លេមេគង្គ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជំរុញការអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវទឹកឱ្យមានការរីកចម្រើន ឆ្លើយតបនឹងសេចក្តីត្រូវការអភិវឌ្ឍប្រទេស និងសេដ្ឋកិច្ចជាតិ, អភិវឌ្ឍធនធានមនុស្សក្នុងវិស័យដឹកជញ្ជូនផ្លូវទឹក ព្រមទាំងគ្រប់គ្រង និងជំរុញការអភិវឌ្ឍយានដ្ឋានជួសជុលនាវា។ ក្រសួងក៏បានជំរុញអនុម័តសេចក្តីព្រាង

ច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក និងរៀបចំបទដ្ឋានគតិយុត្តពាក់ព័ន្ធ, លើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមវិនិយោគលើការដឹកជញ្ជូនផ្លូវទឹក, ជំរុញអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការដឹកជញ្ជូនផ្លូវទឹកឆ្នាំ២០០៩។ ក្រសួង ក៏បានបញ្ចប់ការងារសាងសង់កំពង់ផែតាស្លាង ក្រុងស្វាយរៀង ខេត្តស្វាយរៀង បានសិក្សា និងសាងសង់កំពង់ផែតូចៗនៅតាមប្រព័ន្ធទន្លេមេគង្គ និងតំបន់សមុទ្រ រួមទាំងការសិក្សា និងស្តារផ្លូវទឹក ព្រមទាំងសហការជាមួយផ្នែកឯកជន និងដៃគូអភិវឌ្ឍនានា ក្នុងការធានាអភិវឌ្ឍន៍កំពង់ផែប្រកបដោយនិរន្តរភាព រួមនឹងទំនើបកម្មប្រតិបត្តិការកំពង់ផែ ដូចជារៀបចំនឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យកំពង់ផែ (Port EDI)។

ចំពោះការងារដឹកជញ្ជូនផ្លូវសមុទ្រ ក្រសួងបានអនុវត្តការងារជាច្រើនរួមមាន ការលើកគម្រោងសាងសង់កំពង់ផែ, ការលើកទឹកចិត្តឱ្យមានការវិនិយោគលើការដឹកជញ្ជូនតាមផ្លូវសមុទ្រ, ការអនុវត្តគោលនយោបាយជាតិស្តីពីកំពង់ផែ និងប្រព័ន្ធគ្រប់គ្រងកំពង់ផែ ឆ្នាំ២០១៣ និងការជំរុញរៀបចំកសាងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងនាវា នាវិក កណ្តាធារកិច្ច ព្រមទាំងការធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងមជ្ឈមណ្ឌលចែករំលែកព័ត៌មាន នៃកិច្ចព្រមព្រៀងតំបន់ស្តីពីការប្រយុទ្ធប្រឆាំងនឹងចោរសមុទ្រ និងការប្លន់ប្រដាប់អាវុធប្រឆាំងនឹងនាវានៅអាស៊ី (ReCAAP ISC: Regional Cooperation Agreement on Combating Piracy and Armed Robbery against Ships in Asia Information Sharing Center) និងបណ្តាប្រទេសជាសមាជិក និងកិច្ចសហប្រតិបត្តិការជាមួយអង្គការនាវាចរណ៍អន្តរជាតិ ដើម្បីកែតម្រូវការអនុវត្តសកម្មភាពនាវាចរណ៍សមុទ្រឱ្យស្របតាមអនុសញ្ញានៃអង្គការសមុទ្រអន្តរជាតិ (IMO) និងអន្តរជាតិ។

ចំពោះការងារផ្លូវដែកកម្ពុជា ដែលមានចំនួន ០២ខ្សែ និងប្រវែងសរុប ៦៥២គ.ម (ខ្សែទិសខាងជើងមានប្រវែង ៣៨៦គ.ម និងខ្សែទិសខាងត្បូងមានប្រវែង ២៦៦គ.ម) ក្រសួងបានបញ្ចប់ (១) ខ្សែផ្លូវដែកភាគខាងត្បូង(រាជធានីភ្នំពេញ-ក្រុងព្រះសីហនុ) បានស្តារ និងសាងសង់រួច (កំពុងដំណើរការដឹកជញ្ជូនទំនិញ និងអ្នកដំណើរ), (២) ដាក់ឱ្យប្រើរថភ្លើងដឹកអ្នកដំណើរពីស្ថានីយភ្នំពេញ ទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ, (៣) ដាក់ឱ្យដំណើរការជាបណ្តោះអាសន្នផ្លូវរថភ្លើង ភាគខាងជើង ប៉ោយប៉ែត-ភ្នំពេញ និង(៤) បានតភ្ជាប់ផ្លូវដែកកម្ពុជា ជាមួយផ្លូវដែកថៃ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនឆ្លងកាត់ព្រំដែនតាមផ្លូវដែកកម្ពុជា-ថៃ។ ក្រសួងក៏កំពុងអនុវត្តការងារមួយចំនួន ដែលរួមមាន (១) បាននិងកំពុងសហការជាមួយភាគីជប៉ុន ក្នុងការសិក្សាលទ្ធភាពសាងសង់ផ្លូវរថភ្លើងស្វ័យប្រវត្តិលើអាកាស (AGT) នៅរាជធានីភ្នំពេញ, (២) សិក្សាធ្វើឱ្យប្រសើរឡើងផ្លូវដែកភាគខាងជើង : គម្រោងសាងសង់ផ្លូវដែកថ្មី សិរីសោភណ្ឌ-សៀមរាប និងគម្រោងផ្លូវដែក AGT Monorail Tramway Subway ក្នុងរាជធានីភ្នំពេញ, (៣) ស្វែងរកការវិនិយោគតភ្ជាប់បណ្តាញផ្លូវដែកកម្ពុជាជាមួយបណ្តាញផ្លូវដែកប្រទេសជិតខាង ជាពិសេសបណ្តាញផ្លូវដែកសាំងហ្គាពួរ-គុនមីញ ផ្លូវដែកភ្នំពេញ-សៀមរាប និងភ្នំពេញ-បាវិត, (៤) ជំរុញឱ្យមានការតភ្ជាប់ផ្លូវដែកចូលរោងចក្រ សម្រាំគោល

តំបន់សេដ្ឋកិច្ចពិសេស ដូចជាពីស្ថានីយទូកមាសទៅរោងចក្រ Kស៊ីម៉ង់ ពីស្ថានីយកំពតទៅរោងចក្រស៊ីម៉ង់ចក្រីទីង និង (៥) កំពុងសិក្សាផ្លូវរថភ្លើងនៅបាត់ដឹង កំពង់ធំ សៀមរាប និងសីរីសោភ័ណ។

**គ.២ ក្រសួងរ៉ែនិងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងក្រុមហ៊ុនអគ្គិសនីកម្ពុជា**

ក្រសួងរ៉ែ និងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងក្រុមហ៊ុនអគ្គិសនីកម្ពុជា បានរៀបចំផែនការផលិតកម្មថាមពលសម្រាប់ឆ្នាំ២០១៧ ២០១៨ និង២០១៩ ក្នុងនោះគម្រោងស្ថានីយវារីអគ្គិសនីសេសានក្រោម២ អានុភាព ៤០០ មេហ្គាវ៉ាត់, ស្ថានីយអគ្គិសនីដុតធ្យូងថ្មអានុភាព ១៣៥មេហ្គាវ៉ាត់, និងស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យអានុភាព ១០មេហ្គាវ៉ាត់។

ទន្ទឹមគ្នានេះ ស្ថាប័នទាំង៣ បានរៀបចំផែនការផ្នែកខ្សែបញ្ជូនជាតិចាប់ពីចុងឆ្នាំ២០១៦ រហូតដល់ឆ្នាំ ២០២០ សរុបខ្សែបញ្ជូន ២៥៣០គីឡូវ៉ុលត្រូវបានតភ្ជាប់ទៅតាមតំបន់គោលដៅទូទាំងប្រទេសកម្ពុជា។ ជាមួយគ្នានេះ គម្រោងខ្សែបញ្ជូនមួយចំនួនត្រូវបានដាក់ឱ្យដំណើរការ ដែលមានដូចជាខ្សែបញ្ជូន ១១៥ គីឡូវ៉ុល តភ្ជាប់ពីភ្នំពេញ-បាវិត (អនុស្ថានីយច្រកម្ទេស និងអនុស្ថានីយកំពង់សិង្ហ) ដើម្បីជួយបង្កើនស្ថិរភាព និងគុណភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីដល់ខេត្តស្វាយរៀង និងព្រៃវែង ជាពិសេសតំបន់សេដ្ឋកិច្ចពិសេសក្រុងបាវិត, និងខ្សែបញ្ជូន ២៣០ គីឡូវ៉ុល កំពង់ចាម-ក្រចេះ-ស្ទឹងត្រែង-វារីអគ្គិសនីសេសានក្រោម ២ ដែលធ្វើឱ្យអគ្គិសនីនៅក្នុងខេត្តក្រចេះ ស្ទឹងត្រែង មានថ្លៃលក់ដូចថ្លៃលក់ក្នុងបណ្ដាញជាតិចាប់ពីឆ្នាំ ២០១៨។ ជាមួយគ្នានេះដែរ អនុស្ថានីយព្រះវិហារទី១ ក្នុងស្រុកឆែប ខេត្តព្រះវិហារ ក៏ត្រូវបានដាក់ឱ្យដំណើរការ ដើម្បីកាត់បន្ថយការយកប្រភពពីប្រទេសឡាវ ដែលមានចម្ងាយឆ្ងាយ។

**គ.៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ពាក់ព័ន្ធនឹងការស្វែងរកប្រភពហិរញ្ញប្បទានសម្រាប់គាំទ្រការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចូលរួមក្នុងដំណើរការរៀបចំ និងបង្កើតមូលនិធិវិនិយោគអាស៊ាន (AIF) និងធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB), បានជំរុញដៃគូអភិវឌ្ឍន៍ឱ្យផ្តល់ហិរញ្ញប្បទានសម្បទានកម្រិតខ្ពស់សម្រាប់វិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត កែលម្អសេវា និងមធ្យោបាយដឹកជញ្ជូន, ព្រមទាំងបានធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានសម្រាប់រយៈពេលវែង។ បន្ថែមពីនេះ ក្រសួងបានជំរុញការអនុវត្តឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០, ចូលរួមរៀបចំបទដ្ឋានគតិយុត្ត និងនីតិវិធីប្រតិបត្តិការសម្រាប់គ្រប់គ្រងគម្រោងជាដៃគូរវាងរដ្ឋ និងឯកជន, ព្រមទាំងរៀបចំបញ្ជីគម្រោងបឋមដែលគ្រោងនឹងអនុវត្តតាមយន្តការ PPP ដោយផ្អែកលើសំណើជាផ្លូវការ សិក្ខាសាលាពិគ្រោះយោបល់ និងកិច្ចប្រជុំពិភាក្សាជាមួយតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល។

### គ.៤ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្នុងក្របខណ្ឌវិនិយោគ នៅក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានពិនិត្យ និងអនុម័តគម្រោងវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ បានចំនួន ២១ ដែលមានទុនវិនិយោគប្រមាណជា ៤,២ ប៊ីលានដុល្លារ អាមេរិក។ ទន្ទឹមនឹងនេះ ក.អ.ក ក៏បានជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ច ដែលរួមមានអាងប្រព្រឹត្តកម្មទឹកកខ្វក់, ផ្លូវថ្នល់, លូទឹក, សួនច្បារ, បណ្តាញទឹក-ភ្លើង, ការឈូសឆាយដី និងការសាងសង់រោងចក្រ និងការពង្រឹងសន្តិសុខក្នុងតំបន់ ទាំងថ្ងៃ ទាំងយប់ ផងដែរ។ ក្នុងក្របខណ្ឌច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ក.អ.ក កំពុងសិក្សាបញ្ចូលបទប្បញ្ញត្តិមួយចំនួនពាក់ព័ន្ធទៅនឹងការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស។

### គ.៥ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ក្រសួងឧស្សាហកម្ម និងសិប្បកម្មបាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាត ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជន សម្រាប់ផ្គត់ផ្គង់ទឹកស្អាតដល់រោចក្រ សហគ្រាស កម្មន្តសាល និងតំបន់អភិវឌ្ឍន៍ពាក់ព័ន្ធនឹងវិស័យឧស្សាហកម្មនានា ដើម្បីសម្រេចគោលដៅនៃការផ្គត់ផ្គង់ទឹកស្អាត ប្រើប្រាស់នៅទីប្រជុំជនឱ្យបាន១០០% នៅឆ្នាំ២០២៥។ ជាមួយគ្នានេះ ក្រសួងបានធ្វើកំណែទម្រង់ក្នុងការផ្គត់ផ្គង់ទឹកស្អាត ដោយបានដាក់ចេញនូវគោលការណ៍លើកទឹកចិត្តឱ្យវិស័យឯកជនចូលរួមធ្វើការវិនិយោគបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅតាមទីប្រជុំជន ស្រុក ឃុំ សង្កាត់ ដែលរដ្ឋមិនទាន់មានលទ្ធភាពធ្វើបាន ដោយផ្តល់សិទ្ធិធ្វើអាជីវកម្មរហូតដល់២០ឆ្នាំ ដែលពីមុនអនុញ្ញាតឱ្យត្រឹម៣ឆ្នាំ ដើម្បីធានាបាននិរន្តរ-ភាពនៃការផ្គត់ផ្គង់ទឹកស្អាត និងពង្រីកផ្ទៃសេវាផ្គត់ផ្គង់ឱ្យបានលឿន និងបានអនុវត្តគោលនយោបាយផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារក្រីក្រ ឬមានចំណូលទាប និងសម្រាប់និស្សិត កម្មករ កម្មការិនីស្នាក់នៅបន្ទប់ជួល ទោះបីការកំណត់ថ្លៃទឹកថ្មីនេះទាបជាងថ្លៃដើមផលិតក្តី។

### គ.៦ រដ្ឋបាលរាជធានីភ្នំពេញ

រដ្ឋបាលរាជធានីភ្នំពេញ បានសាងសង់ហេដ្ឋារចនាសម្ព័ន្ធ សម្រាប់តភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និងការអភិវឌ្ឍច្រករបៀងសេដ្ឋកិច្ច ភ្នំពេញ-ព្រះសីហនុ, ភ្នំពេញ-បាវិត និងភ្នំពេញ-ប៉ោយប៉ែត និងបានស្ថាបនាពង្រីកកំណាត់ផ្លូវជាច្រើន ដើម្បីបញ្ចៀសចរាចរណ៍កកស្ទះ។

### គ.៧ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ

ក្រៅពីក្រសួង ស្ថាប័ន ៦ខាងលើ វិធានការនេះពាក់ព័ន្ធនឹងការកសាងហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍ឧស្សាហកម្ម ក៏មានការចូលរួមអនុវត្តយ៉ាងសកម្មពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងធនធានទឹក និងឧតុនិយម, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, រដ្ឋបាលខេត្តស្វាយរៀង, រដ្ឋបាលខេត្តកណ្តាល

និងរដ្ឋបាលខេត្តបន្ទាយមានជ័យ។ សកម្មភាពអនុវត្តលម្អិត មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២ នៃរបាយ-ការណ៍នេះ។

### ឃ. វិធានការផ្នែកហិរញ្ញប្បទាន

ក្នុងចំណោមវិធានការគោលនយោបាយទាំង៦ ពាក់ព័ន្ធនឹង "វិធានការផ្នែកហិរញ្ញប្បទាន" ក្រសួងស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើន ដូចខាងក្រោម÷

#### ឃ.១. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ពាក់ព័ន្ធនឹងការវិនិយោគសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងចូលរួមរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ ២០១៩-២០២៥ និងសេចក្តីព្រាងអនុក្រឹត្យគោលស្តីពីការគ្រប់គ្រងគម្រោងការវិនិយោគសាធារណៈ ហិរញ្ញប្បទានពីគ្រប់ប្រភេទ ព្រមទាំងចូលរួមពិនិត្យឡើងវិញនូវក្របខណ្ឌចំណាយសាធារណៈ និងចូលរួមធ្វើអាទិភាវូបនីយកម្មកម្មវិធីវិនិយោគ។

ក្រៅពីសកម្មភាពការងារខាងលើ ក្រសួងក៏បានរៀបចំនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្នុងនោះមានដូចជា (១) ប្រកាសស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងការផ្តល់ឥណទានដល់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ នីតិបុគ្គលសាធារណៈដទៃទៀត និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, និង (២) សេចក្តីព្រាងប្រកាសស្តីពីការធានារបស់រដ្ឋ ដែលនឹងផ្តល់ការធានាដល់សហគ្រាសរបស់រដ្ឋក្នុងការទទួលឥណទាន និងផ្តល់ការធានាដល់គម្រោងដែលមានយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។ ក្នុងវិស័យភតិសន្យាហិរញ្ញវត្ថុ ក្រសួង បានចូលរួមពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា, រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ភាពប្រទាក់ក្រឡាលើការអនុវត្តអាជីវកម្មទទួលបញ្ចាំ និងទទួលប្រតិភោគដោយអនុប្បទាន, ប្រតិបត្តិការដែលមានកិច្ចធានា និងភតិសន្យាហិរញ្ញវត្ថុ"។

ចំពោះការសម្រួលការទទួលបានឥណទានក្នុងវិស័យកសិកម្ម ក្រសួងបានរៀបចំប្រជុំគណៈកម្មការឥណទាននៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍វិស័យកសិកម្ម ដើម្បីពិនិត្យនិងវាយតម្លៃលើការស្នើសុំឥណទានថ្មី និងពន្យារពេលសងប្រាក់ជាដើមរបស់អតិថិជននៃវិស័យស្រូវអង្ករ, និងបង្កើតក្រុមការងារកម្រិតនាយកដ្ឋាន និងអគ្គនាយកដ្ឋាន ដើម្បីសិក្សាស្រាវជ្រាវរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការអនុវត្តគម្រោងធានាឥណទានសម្រាប់គាំទ្រវិស័យស្រូវ-អង្ករនៅកម្ពុជា។ លើសពីនេះ ក្រសួងបានរៀបចំឯកសារសំខាន់ៗពាក់ព័ន្ធនឹងគម្រោងធានាឥណទាន ព្រមទាំងរៀបចំរបាយការណ៍លើការពិនិត្យ និងសិក្សាលើកិច្ចព្រមព្រៀងធានាឥណទានដោយផ្នែក ក្នុងការបង្កើតគម្រោងធានាឥណទានសម្រាប់វិស័យស្រូវ-អង្ករ។

ដោយឡែក ចំពោះការជំរុញលទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូចនិងមធ្យម វឌ្ឍនភាពសំខាន់ពីរក្នុងកិច្ចការនេះ រួមមាន (១) ឯកសារទស្សនទាន និងរបាយការណ៍ស្តីពីការបង្កើតធនាគារសហគ្រាសធុនតូចនិងមធ្យមកម្ពុជា បានទទួលការឯកភាពពី **សម្តេចតេជោនាយករដ្ឋមន្ត្រី**, និង (២) ប្រកាសស្តីពីការបង្កើតក្រុមការងារដើម្បីរៀបចំគម្រោងបង្កើត "ធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា"

ត្រូវបានអនុម័ត។ បន្ថែមលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតធនាគារសហគ្រាសធុនតូចនិងមធ្យមកម្ពុជា។

ចំណែកឯក្នុងវិស័យមូលបត្រ ក្រសួងបាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្ត និងឯកសារមួយចំនួន ដូចជា (១) សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងនិងការបោះផ្សាយមូលបត្ររដ្ឋ, (២) សេចក្តីព្រាងប្រកាសស្តីពីប្រតិបត្តិការមូលបត្ររដ្ឋ, (៣) សេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងនិងការបោះផ្សាយមូលបត្ររដ្ឋ, និង (៤) សេចក្តីព្រាងឯកសារយុទ្ធសាស្ត្រនៃការអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា។

ពាក់ព័ន្ធនឹងវិស័យសោធន ក្រសួងបានរៀបចំច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម និងបានរៀបចំបង្កើតរចនាសម្ព័ន្ធដឹកនាំ និងដាក់ឱ្យដំណើរការក្រុមប្រឹក្សាជាតិគាំពារសង្គម, ព្រមទាំងបានបញ្ចប់ការរៀបចំសេចក្តីព្រាងបឋមនៃច្បាប់ស្តីពីរបបសោធនឯកជនស្ម័គ្រចិត្ត ត្រឹមកម្រិតការិយាល័យ។

### ឃ.២ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ ៤៣ អនក្រ.បកចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ ស្តីពីការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ដោយដំឡើងជា ៤កម្រិត។ ក្នុងឆ្នាំ២០១៧ និង២០១៨ ក្រសួង ក៏បានចេញប្រកាសមួយចំនួនដូចជា(១)ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ និងឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គម, និង(២) ការលុបសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈនិងឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុក។ ទន្ទឹមនឹងនេះ ក្រសួងក៏បានចុះពិនិត្យស្ថានភាពនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលមានជំងឺសុំផ្ទេរសិទ្ធិ, បានទទួលអតីតយុទ្ធជនដែលផ្ទេរពីក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ, និងបានផ្ទេរសិទ្ធិបើកប្រាក់ជូនគ្រួសារអតីតយុទ្ធជន។

### ឃ.៣ ធនាគារជាតិនៃកម្ពុជា

វិស័យធនាគារបានដើរតួនាទីយ៉ាងសំខាន់ ជាអន្តរការីហិរញ្ញវត្ថុក្នុងការគេណ្ឌប្រមូលធនធានហិរញ្ញវត្ថុសម្រាប់បំពេញតម្រូវការវិនិយោគ និងគាំទ្រដល់ការរីកចម្រើននៃសេដ្ឋកិច្ច។ កម្ពុជា មានធនាគារពាណិជ្ជចំនួន ៣៩ និងបានកើនដល់ ៤៣ ក្នុងឆ្នាំ២០១៨ ខណៈធនាគារឯកទេស មានចំនួន ១៤ ហើយសាខារបស់គ្រឹះស្ថានធនាគារបានកើនពី ៨៥៦ សាខា ក្នុងឆ្នាំ២០១៧ ដល់ ៨៧៧ សាខា និងម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិបានកើនពី ១.៤៩០ ម៉ាស៊ីន ក្នុងឆ្នាំ២០១៧ ដល់ ១.៨៣២ ម៉ាស៊ីន ក្នុងឆ្នាំ២០១៨។ ការរីកលូតលាស់នៃបណ្តាញសាខារបស់គ្រឹះស្ថានធនាគារ បានផ្តល់ដល់ប្រជាពលរដ្ឋកម្ពុជា ក្នុងការទទួលនិងប្រើប្រាស់សេវាហិរញ្ញវត្ថុកាន់តែមានភាពងាយស្រួល ដែលជំរុញដល់សកម្មភាពសេដ្ឋកិច្ច និងបរិយាប័ន្ន។ កំណើនឥណទានកើនដល់ ៧០ ទ្រីលានរៀល (កើន ១៨,៥%) ក្នុងឆ្នាំ២០១៧ និងបានកើនដល់ ៧៩,៥ ទ្រីលានរៀល (កើន ១៤%) ក្នុងឆ្នាំ២០១៨ ដោយបានដើរតួនាទីយ៉ាងសកម្មក្នុងការជំរុញការពង្រីកអាជីវកម្ម និងការប្រើប្រាស់ក្នុងស្រុក។ កំណើនឥណទានត្រូវបានបែងចែកទៅកាន់វិស័យសំខាន់ៗនៃសេដ្ឋកិច្ច ក្នុងនោះវិស័យពាណិជ្ជកម្ម

២៨% សំណង់និងអចលនទ្រព្យ ២៦% កសិកម្ម ៩% វិស័យកម្មន្តសាល ៦% នៃសំពៀតឥណទានសរុប។ ក្នុងស្ថានភាពដែលវិស័យធនាគារមានការរីកចម្រើន ការប្រកួតប្រជែង និងសុខភាពល្អ អត្រាការប្រាក់បានថយចុះជាលំដាប់។

រីឯវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា មានការរីកចម្រើនគួរឱ្យកត់សម្គាល់ប្រកបដោយនិរន្តរភាពទាំងវិសាលភាព ទំហំប្រតិបត្តិការ និងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការជួយជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា តាមរយៈការផ្តល់ឥណទានខ្នាតតូច និងមធ្យម។ នៅកម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៧៦ គ្រឹះស្ថានក្នុងឆ្នាំ២០១៧ និងបានកើនដល់ ៧៩ គ្រឹះស្ថានក្នុងឆ្នាំ២០១៨ ដែលក្នុងនោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានចំនួន ៧។ ទំហំឥណទានក្នុងវិស័យនេះកើនដល់ ១៧,៥ ទ្រីលានរៀលក្នុងឆ្នាំ២០១៧ និងកើនដល់ ២១,៨ ទ្រីលានរៀលក្នុងឆ្នាំ២០១៨ ដោយបានបែងចែកទៅតាមវិស័យផ្សេងៗរួមមាន គ្រួសារ ៣៦% វិស័យកសិកម្ម ២២% ពាណិជ្ជកម្ម ១៨% សេវាកម្ម ១១% ដឹកជញ្ជូន ៥% សំណង់ ៤% និងវិស័យផ្សេងៗ ៤%។

### ឃ.៤ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម កំពុងជ្រើសរើសធនាគារដែលមានភាពអនុគ្រោះបំផុត និងផ្តល់ការលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យម ដើម្បីធ្វើជាដៃគូក្នុងការជំរុញកិច្ចអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ព្រមទាំងរៀបចំសិក្ខាសាលា ដើម្បីផ្តល់ឱកាសឱ្យធនាគារដែលបានជ្រើសរើសទាំងអស់ធ្វើការបង្ហាញផលិតផលរបស់ខ្លួន និងរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់សហគ្រាសធុនតូច និងមធ្យមទាំងឡាយណាដែលមានបំណងទទួលយកកម្ចីពីធនាគារសាមី។

### ឃ.៥ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គមដែលមានវិសាលភាពកាន់តែទូលំទូលាយ ធានាសង្គតិភាព និងសមធម៌រវាងមន្ត្រីរាជការសាធារណៈ និងកម្មករនិយោជិត, និងបានបន្តពង្រីក និងអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គម សំដៅផ្តល់ការធានាសុខុមាលភាព និងកាត់បន្ថយបន្ទុកចំណាយរបស់កម្មករនិយោជិត ក៏ដូចជាកៀរគរប្រភពធនធានក្នុងស្រុកកាន់តែកើនឡើងដើម្បីចូលរួមជាប្រភពមូលធនហិរញ្ញវត្ថុបន្ថែមសម្រាប់គាំទ្រការវិនិយោគផ្សេងៗ ដែលនឹងបម្រើដល់ផលប្រយោជន៍របស់កម្មករនិយោជិត។

### ឃ.៦ ក្រសួងផែនការ

ក្រសួងផែនការ បាននិងកំពុងបន្តណែនាំដល់គ្រប់បណ្តាក្រសួង ស្ថាប័នឱ្យចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ តាមរយៈការស្នើគម្រោងសម្រាប់ដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០២០-២០២២។

### ២.៣.៥- ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា

ក្នុងបរិការណ៍នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍បច្ចុប្បន្ន ហិរញ្ញប្បទានសហប្រតិបត្តិការនៅរក្សាតួនាទីសំខាន់សម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា និងបំពេញតួនាទីជាកាតាលីករសម្រាប់កៀរគរធនធានអភិវឌ្ឍន៍ដទៃ ទាំងវិស័យសាធារណៈ និងឯកជន ដើម្បីរួមចំណែកគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។

**ក-តួនាទី និងសក្តានុពលនៃហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥**

ជារួម ហិរញ្ញប្បទានសហប្រតិបត្តិការមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ពិសេសការគាំទ្រការអភិវឌ្ឍវិស័យឯកជន តាមរយៈគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។ វិស័យសំខាន់ៗដែលមានសក្តានុពលសម្រាប់ដៃគូអភិវឌ្ឍន៍ផ្តល់ការគាំទ្រ រួមមាន÷ ១) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងប្រព័ន្ធឡូជីស្ទីក, ២) ភាពជាដៃគូដោយផ្ទាល់ជាមួយវិស័យឯកជន, ៣) ការវិនិយោគគន្លឹះជាយុទ្ធសាស្ត្រសម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម និងការលើកកម្ពស់ភាពប្រកួតប្រជែងសេដ្ឋកិច្ច និង ៤) ការគាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលសម្រាប់ធ្វើឱ្យមានភាពប្រសើរឡើងនូវបរិស្ថានអំណោយផល និងការទាក់ទាញវិនិយោគ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាស្ថាប័នដឹកនាំ និងសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម បានសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីសម្របសម្រួល និងតាមដានវឌ្ឍនភាពជាប្រចាំពីការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។ ផ្អែកតាមប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ន/ក.អ.ក) បានវិភាគអំពីការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។

**ខ-ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥**

បន្ទាប់ពីត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនាឆ្នាំ២០១៥ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា បានកំណត់នូវវិធានការគន្លឹះ, វិធានការគោលនយោបាយ និងផែនការសកម្មភាពសម្រាប់ក្រសួង និងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលអនុវត្ត និងដៃគូអភិវឌ្ឍន៍ផ្តល់ការគាំទ្រ។ ជារួម ហិរញ្ញប្បទានសរុបប្រមាណ ៦៥១,៥ លានដុល្លារ ក្នុងឆ្នាំ២០១៥-២០១៨ ត្រូវបានប្រើប្រាស់សម្រាប់គាំទ្រការអនុវត្តគោលនយោបាយនេះ។ ក្នុងឆ្នាំ២០១៧ ដៃគូអភិវឌ្ឍន៍បានបើកផ្តល់ហិរញ្ញប្បទានសរុបប្រមាណ ២២១,៨ លានដុល្លារ គាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។ ដោយឡែក ក្នុងឆ្នាំ

២០១៨ ដៃគូអភិវឌ្ឍន៍បានបើកផ្តល់ហិរញ្ញប្បទានសរុបប្រមាណ ១៥៦,៧ លានដុល្លារ ពោលគឺកើនឡើង ៥៧% បើធៀបនឹងឆ្នាំ២០១៥ ដែលមានត្រឹម ៨៨,៨ លានដុល្លារ ហើយក្នុងឆ្នាំ២០១៩ អាចកើនឡើងដល់ ២៦៥,៧ លានដុល្លារ ពោលគឺកើនជិត ៣ ដង ធៀបនឹងឆ្នាំ២០១៥។ ក្នុងឆ្នាំ២០១៧-២០១៨ វិធានការគន្លឹះបួនជាក់ស្តែងទទួលបានការគាំទ្រច្រើនជាងវិធានការដទៃក្នុងទំហំប្រមាណ ២៧១,៥លានដុល្លារ សមមូលនឹង ៧២% នៃហិរញ្ញប្បទានសរុប និងបន្ទាប់ គឺវិធានការស្តីពីការសម្របសម្រួលគោលនយោបាយគាំទ្រ ១៦%, វិធានការស្តីពីការកែលម្អបរិស្ថាននិយ័តកម្ម ៩%, វិធានការស្តីពីការពង្រីកសហគ្រាសធុនតូច និងមធ្យម ២% និងវិធានការស្តីពីការជំរុញការទាក់ទាញវិនិយោគ ១%។

**ការបើកផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា (លានដុល្លារ)**

| វិធានការគោលនយោបាយ និងវិធានការគន្លឹះបួនជាក់ស្តែង | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | សរុប (២០១៥-២០១៨) | ឆ្នាំ២០១៩ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|---|
| ការជំរុញការទាក់ទាញវិនិយោគ | ០,២ | ៣,៣ | ១,៨ | ២,៥ | ៧,៨ | ៤៥,៤ |
| ការពង្រីកសហគ្រាសធុនតូច និងមធ្យម | ១,១ | ១,៧ | ៣,៦ | ៣,៩ | ១០,៣ | ៦,៧ |
| ការកែលម្អបរិស្ថាននិយ័តកម្ម | ៤,៣ | ៩,០ | ២៥,៩ | ៨,៧ | ៤៧,៩ | ៦,១ |
| ការសម្របសម្រួលគោលនយោបាយគាំទ្រ | ២៧,៤ | ២២,២ | ២៨,២ | ៣១,៩ | ១០៩,៧ | ៣១,៤ |
| វិធានការគន្លឹះបួនជាក់ស្តែង | ៥៥,៩ | ១៤៧ | ១៦២,០ | ១០៩,៥ | ៤៧៥,៤ | ១៧៥,៩ |
| **សរុប** | **៨៨,៨** | **១៨៤,២** | **២២១,៨** | **១៥៦,៧** | **៦៥១,៥** | **២៦៥,៧** |

ក្នុងចន្លោះឆ្នាំ២០១៧-២០១៨ ដៃគូអភិវឌ្ឍន៍សំខាន់ៗដែលបានផ្តល់ការគាំទ្រ រួមមាន÷ សាធារណរដ្ឋប្រជាមានិតចិន, ធនាគារអភិវឌ្ឍន៍អាស៊ី, ជប៉ុន, បារាំង និងអូស្ត្រាលី។

ក្រៅពីការគាំទ្រផ្ទាល់លើវិធានការគោលនយោបាយ និងវិធានការគន្លឹះបួនជាក់ស្តែង ដៃគូអភិវឌ្ឍន៍ជាច្រើនក៏បានបញ្ជ្រាបគោលនយោបាយនេះទៅក្នុងគម្រោងអភិវឌ្ឍន៍របស់ខ្លួន។ ជាក់ស្តែង ដៃគូអភិវឌ្ឍន៍បានបញ្ជ្រាបការអភិវឌ្ឍវិស័យឧស្សាហកម្មទៅក្នុងបណ្តាគម្រោងរបស់ខ្លួន ដែលមានទំហំហិរញ្ញប្បទានប្រមាណ ១៦៨ លានដុល្លារ សមមូលនឹង ៨,៩% ក្នុងឆ្នាំ២០១៧ និងប្រមាណ ១៦០ លានដុល្លារ សមមូលនឹង ៨,៤% ក្នុងឆ្នាំ២០១៨ នៃទំហំហិរញ្ញប្បទានសរុបផ្តល់ដោយដៃគូអភិវឌ្ឍន៍ទាំងអស់។ ដៃគូអភិវឌ្ឍន៍សំខាន់ៗដែលគាំទ្រចំនួន ៣ រួមមាន ÷ សាធារណរដ្ឋប្រជាមានិតចិន ៨៧,៦ លានដុល្លារ, ជប៉ុន ៣៩,៦ លានដុល្លារ និងធនាគារអភិវឌ្ឍន៍អាស៊ី ១៤,៥ លានដុល្លារ។

ផ្អែកលើសារៈសំខាន់នៃការលើកកម្ពស់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ, ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា បានបង្ហាញថា ចន្លោះឆ្នាំ២០១៥-២០១៧ វិស័យអប់រំបណ្តុះបណ្តាល បច្ចេកទេសនិងវិជ្ជាជីវៈ និងថ្នាក់ឧត្តមសិក្សា ទទួលបានហិរញ្ញប្បទានសរុប ៨៧ លានដុល្លារ

ពេលគឺប្រមាណ ៣០ លានដុល្លារ ក្នុងមួយឆ្នាំ ហើយក្នុងឆ្នាំ២០១៨ ការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍គាំទ្រដល់វិស័យ នេះមានប្រមាណ ៣១,៨ លានដុល្លារ។ ក្នុងចំណោមដៃគូអភិវឌ្ឍន៍ចំនួន ១៣ ដែលបានគាំទ្រដល់វិស័យនេះ ធនាគារអភិវឌ្ឍន៍អាស៊ី, អូស្ត្រាលី, ជប៉ុន, ណូវែលហ្សេឡង់ និងស្វីស បានផ្តល់ហិរញ្ញប្បទានច្រើនជាងគេសរុបប្រមាណ ២៦,៦ លានដុល្លារ សមមូលនឹង ៨៤% នៃទំហំហិរញ្ញប្បទានសរុបគាំទ្រដល់វិស័យនេះ ក្នុងឆ្នាំ២០១៨។

**គ-អាទិភាពការងារកៀរគរ និងគ្រប់គ្រងធនធានហិរញ្ញប្បទានសម្រាប់គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥**

ផ្អែកលើសមិទ្ធផលដែលសម្រេចបានកន្លងមក គ.ជ.ឧ/ក.អ.ក បានរៀបចំ និងកំពុងអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូឆ្នាំ២០១៩-២០២៣ សម្រាប់បន្តលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍។ គោលដៅចម្បងនៃយុទ្ធសាស្ត្រនេះ គឺការបន្តកៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ សំដៅរួមចំណែកសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក៏ដូចជាយុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល។ យុទ្ធសាស្ត្រនេះ ក៏បានកំណត់នូវគោលការណ៍, យន្តការពិគ្រោះយោបល់ និងឧបករណ៍ ដើម្បីលើកកម្ពស់ស័ក្តិសិទ្ធិភាព, តម្លាភាព និងគណនេយ្យភាព ព្រមទាំងជាក្របខណ្ឌកៀរគរ និងតម្រង់ទិសការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ជំរុញកិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន។ ទន្ទឹមនេះ ក៏បានដាក់ចេញ និងអនុវត្តនូវគោលការណ៍បន្ថែមមួយចំនួនដើម្បីពង្រីកវិសាលភាពនៃភាពជាដៃគូ រួមមាន÷ កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន និងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង។ ក្នុងស្មារតីនេះ គ.ជ.ឧ/ក.អ.ក បានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល ដើម្បីបន្តដឹកនាំការសម្របសម្រួល និងកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ សម្រាប់រួមចំណែកគាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។

ដើម្បីបន្តរួមចំណែកគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា គ.ជ.ឧ/ក.អ.ក នឹងបន្តអនុវត្តការងារអាទិភាព ដូចខាងក្រោម÷

- ដឹកនាំកិច្ចពិគ្រោះយោបល់ទ្វេភាគី និងពហុភាគីជាមួយដៃគូអភិវឌ្ឍន៍ និងយន្តការភាពជាដៃគូដទៃទៀតដើម្បីតម្រឹមការគាំទ្រជាមួយអាទិភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។
- សម្របសម្រួលការអនុវត្តសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលស្តីពីយន្តការពិគ្រោះយោបល់ និងឧបករណ៍នៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ដើម្បីលើកកម្ពស់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។

- តាមដានលំហូរហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ដែលបានគាំទ្រវិស័យអាទិភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា តាមរយៈការធ្វើបច្ចុប្បន្នភាពទិន្នន័យគម្រោងរបស់ដៃគូអភិវឌ្ឍន៍ក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីកិច្ច-សហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា។

## ៣- បញ្ហាប្រឈម និងហានិភ័យនៃការអនុវត្តគោលនយោបាយ

ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មនេះ ទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការដាក់ចេញ និងអនុវត្តផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយឱ្យបានគ្រប់ជ្រុងជ្រោយ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ សំដៅជំរុញឱ្យសម្រេចបានតាមគោលដៅដែលបានគ្រោងទុក ឈានទៅរកការធ្វើពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ច ព្រមទាំងរក្សាឱ្យបាននូវបរិយាបន្ន និងចីរភាពនៃការអភិវឌ្ឍ។ ឆ្លងកាត់ការអនុវត្តនាពេលកន្លងមក ទោះបីជាមានវឌ្ឍនភាពការងារល្អប្រសើររបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធក្នុងការជំរុញការអនុវត្តគោលនយោបាយនេះក្តី ក៏នៅតែមានការលេចចេញនូវបញ្ហាប្រឈម និងហានិភ័យមួយចំនួន ដែលបង្កឱ្យរាំងស្ទះដល់ការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា។ បញ្ហាទាំងនោះមានដូចខាងក្រោម÷

- ភាពប្រកួតប្រជែងរបស់កម្ពុជានៅមានកម្រិត÷ បញ្ហាថ្លៃដើមផលិតកម្មដូចជា ថ្លៃដឹកជញ្ជូន ថ្លៃអគ្គិសនីនៅស្ថិតក្នុងកម្រិតមួយខ្ពស់ បើធៀបនឹងប្រទេសជិតខាង និងការកើនឡើងនូវប្រាក់ឈ្នួលអប្បបរមា ខណៈដែលផលិតភាពការងារនៅមានកម្រិត
- បរិស្ថានធុរកិច្ចនិងវិនិយោគដែលកាន់តែមានភាពអំណោយផលរបស់ប្រទេសក្នុងតំបន់÷ ការដាក់ចេញនូវគោលនយោបាយអនុគ្រោះពាក់ព័ន្ធនឹងការជំរុញនិងលើកទឹកចិត្តការវិនិយោគរបស់បណ្តាប្រទេសក្នុងតំបន់ ជាពិសេសប្រទេសថៃ វៀតណាម និងមីយ៉ាន់ម៉ា ដែលអាចប៉ះពាល់ដល់ភាពប្រកួតប្រជែងរបស់កម្ពុជា
- ការប្រែប្រួលភូមិសាស្ត្រនយោបាយ÷ ភាពមិនច្បាស់លាស់នៃទស្សនវិស័យសេដ្ឋកិច្ចនិងពាណិជ្ជ-កម្មសកល ដោយរាប់បញ្ចូលទាំងភាពតានតឹងផ្នែកពាណិជ្ជកម្មរវាងប្រទេសមហាអំណាចក្រោមគោលការណ៍គាំពារនិយម អាចជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជា
- ការផ្លាស់ប្តូរលក្ខខណ្ឌនៃការផ្តល់ហិរញ្ញប្បទានសហ-ប្រតិបត្តិការ÷ ការបោះជំហានរបស់កម្ពុជាចេញពីឋានៈប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប អាចធ្វើឱ្យដៃគូអភិវឌ្ឍន៍ផ្លាស់ប្តូរលក្ខខណ្ឌនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ។

ក្រៅពីបញ្ហាប្រឈមចម្បងខាងលើ ការអនុវត្តគោលនយោបាយនេះ ក៏ជួបប្រទះការលំបាកមួយចំនួនទៀត ដូចជាការសម្របសម្រួលនិងការកសាងសមត្ថភាពស្ថាប័ននៅមានកម្រិត ព្រមទាំងបញ្ហាកង្វះថវិកានិងធនធានមនុស្សសម្រាប់គាំទ្រលើវិធានការមួយចំនួន។

## ៤. សេចក្តីសន្និដ្ឋាន

ការត្រួតពិនិត្យ និងតាមដានលើវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ក្នុងឆ្នាំ២០១៧-២០១៨ បានបង្ហាញឱ្យឃើញថា ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បាននិងកំពុងអនុវត្ត និងបំពេញនូវសកម្មភាព និងសមត្ថកិច្ចរបស់ខ្លួន តាមការចង្អុលបង្ហាញនៃឯកសារគោលនយោបាយឧស្សាហកម្ម។ កិច្ចខិតខំប្រឹងប្រែងប្រកបដោយស្មារតីទទួលខុសត្រូវ និងសហការខ្ពស់ គឺជាកត្តាចាំបាច់សម្រាប់រួមចំណែកធ្វើឱ្យកម្ពុជាឈានទៅសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០ តាមរយៈការធ្វើពិពិធកម្មមុខទំនិញនាំចេញរបស់កម្ពុជាកាន់តែទូលំទូលាយ ជាមួយនឹងកំណើនតម្លៃបន្ថែមកាន់តែខ្ពស់ ការពង្រឹងភាពប្រកួតប្រជែងកាន់តែប្រសើរឡើង និងការបន្តលើកកម្ពស់ផលិតភាពកាន់តែខ្ពស់ជាងមុន។ នៅឆ្នាំ២០១៧ និងឆ្នាំ២០១៨ ការអនុវត្តគោលនយោបាយនេះ ទទួលបាននូវវឌ្ឍនភាពជាវិជ្ជមានគួរឱ្យកត់សម្គាល់ ដែលត្រូវបានឆ្លុះបញ្ចាំង តាមរយៈគោលដៅចម្បងទាំងបី និងវិធានការគន្លឹះបួនជាក់ស្តែងនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។

ចំពោះគោលដៅទី១ ពាក់ព័ន្ធនឹងការកែប្រែ និងពង្រឹងរចនាសម្ព័ន្ធឧស្សាហកម្មក្នុងសេដ្ឋកិច្ចជាតិ, អនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស បានកើនឡើងពី ២៧,៧% នៅឆ្នាំ២០១៥ ដល់ ៣២,៦% នៅឆ្នាំ២០១៨ ពោលគឺសម្រេចបានមុនគោលដៅដែលបានកំណត់នៅឆ្នាំ២០២៥។ ទន្ទឹមគ្នានេះ អនុបាតវិស័យកម្មន្តសាលក្នុង ផ.ស.ស. បានកើនឡើងបន្តិចពី ១៦,០% នៅឆ្នាំ២០១៥ ដល់ ១៦,៣% នៅឆ្នាំ២០១៨ ដោយកំណើននេះមានលក្ខណៈយឺត បើធៀបនឹងគោលដៅឆ្នាំ២០២៥។ យ៉ាងណាក្តី តួលេខទាំងនេះអាចបង្ហាញថាកម្ពុជាកំពុងកែប្រែនិងបន្តពង្រឹងរចនាសម្ព័ន្ធឧស្សាហកម្ម ដោយងាកចេញជាបណ្តើរៗពីការពឹងផ្អែកសំខាន់លើវិស័យកសិកម្ម ឆ្ពោះទៅការធ្វើឧស្សាហូបនីយកម្មនៃមូលដ្ឋានសេដ្ឋកិច្ច ដែលនឹងពន្លឿនការអភិវឌ្ឍឱ្យឈានឆ្ពោះទៅដល់កម្រិតថ្មីមួយទៀត។

ចំពោះគោលដៅទី២ ពាក់ព័ន្ធនឹងការបង្កើន និងពិពិធកម្មមុខទំនិញនាំចេញ, ចំណែកនៃការនាំចេញសម្លៀកបំពាក់និងស្បែកជើងមានការថយចុះជាលំដាប់ពី ៧១,៦% នៃបរិមាណនាំចេញសរុប នៅឆ្នាំ២០១៥ មកត្រឹម ៦៩,៤% នៅឆ្នាំ២០១៨។ ដោយឡែក ការនាំចេញទំនិញកម្មន្តសាលមិនមែនសម្លៀកបំពាក់និងស្បែកជើង មានកំណើនគួរឱ្យកត់សម្គាល់ពី ៥,៦% នៃបរិមាណនាំចេញសរុប នៅឆ្នាំ២០១៥ ដល់ ១៣,៣% នៅឆ្នាំ២០១៨ ពោលគឺសម្រេចបានប្រមាណ ៨៨,៦% បើធៀបនឹងគោលដៅឆ្នាំ២០២៥។ ទន្ទឹមនឹងនេះ ការនាំចេញកសិផលកែច្នៃ ក៏មានការកើនឡើងពី ៥,៩% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០១៥ ដល់ ៧,០% នៅឆ្នាំ២០១៨ ពោលគឺសម្រេចបានប្រមាណ ៥៨,៣% បើធៀបនឹងគោលដៅឆ្នាំ២០២៥។ ទិន្នន័យទាំងនេះ ឆ្លុះបញ្ចាំងឱ្យឃើញថា កម្ពុជាបាននិងកំពុងធ្វើពិពិធកម្មមុខទំនិញនាំចេញរបស់ខ្លួនជាបន្តបន្ទាប់ និងបន្តជំរុញកំណើននៃការនាំចេញកសិផលកែច្នៃឱ្យបានកាន់តែសម្បូរបែប ដោយមិនពឹងផ្អែកតែទៅលើការនាំចេញទំនិញកម្មន្តសាលផ្អែកសម្លៀកបំពាក់និងស្បែកជើងនោះទេ។

សម្រាប់គោលដៅទី៣ ពាក់ព័ន្ធនឹងការជំរុញសហគ្រាសធុនតូចនិងមធ្យមឱ្យចុះបញ្ជីផ្លូវការ និងមានតារាងតុល្យការត្រឹមត្រូវ, ការចុះបញ្ជីផ្លូវការនៃសហគ្រាសធុនតូច មធ្យម និងធំ មានការកើនឡើងពី ៣៧%, ៧២% និង៩៣% រៀងគ្នា នៅឆ្នាំ២០១០ ដល់ ៧៦%, ៨៧% និង៩៨% រៀងគ្នា នៅឆ្នាំ២០១៨ ពោលគឺខិតជិតសម្រេចបានតាមគោលដៅឆ្នាំ២០២៥។ សហគ្រាសធុនមធ្យមដែលមានតារាងតុល្យការ បានកើនឡើងពី ២៤% ក្នុងឆ្នាំ២០១០ ដល់ ៧២% ក្នុងឆ្នាំ២០១៨ លើសពីគោលដៅឆ្នាំ២០២៥ ទៅទៀត, ខណៈដែលសហគ្រាសធុនតូច និងធុនធំដែលមានតារាងតុល្យការ ក៏បានកើនឡើងផងដែរពី ៤% និង ៦៦% រៀងគ្នាក្នុងឆ្នាំ២០១០ ដល់ ២៨% និង ៨៧% រៀងគ្នាក្នុងឆ្នាំ២០១៨ ប៉ុន្តែនៅមិនទាន់កៀកនឹងគោលដៅឆ្នាំ២០២៥នោះទេ។ ទោះជាយ៉ាងណាក្តី កំណើននៃការចុះបញ្ជីផ្លូវការនៃសហគ្រាសធុនតូច និងមធ្យម បានបង្ហាញពីការយល់ដឹងកាន់តែច្រើនរបស់សហគ្រាសធុនតូចនិងមធ្យមអំពីសារសំខាន់នៃការចុះបញ្ជីផ្លូវការ ដើម្បីពង្រឹងអភិបាលកិច្ចអាជីវកម្ម, បង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទាន, និងជាមូលដ្ឋានវាយតម្លៃសម្រាប់ទទួលបានការគាំទ្រផ្នែកបច្ចេកទេស ឬការលើកទឹកចិត្តផ្សេងៗពីរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា។

ជាមួយគ្នានេះ កិច្ចប្រឹងប្រែងក្នុងការសម្រេចឱ្យបាននូវវិធានការគន្លឹះជាក់ស្តែងបួននៅមុនឆ្នាំ២០១៨ ក៏បានទទួលនូវផ្លែផ្កាគួរឱ្យកត់សម្គាល់ផងដែរ។ ជាក់ស្តែង ក្នុងវិស័យថាមពល ការផ្គត់ផ្គង់អគ្គិសនីនៅតាមតំបន់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ ត្រូវបានបន្តធ្វើឱ្យប្រសើរឡើង ទាំងគុណភាព (ស្ថិរភាពនៃការផ្គត់ផ្គង់) និងបរិមាណ (ការផ្គត់ផ្គង់ទាំងយប់ ទាំងថ្ងៃ) ហើយបន្តពង្រីកវិសាលភាពគ្របដណ្តប់ និងបញ្ចុះថ្លៃអគ្គិសនីជាបន្តបន្ទាប់។ រីឯក្នុងវិស័យដឹកជញ្ជូន និងភស្តុភារកម្ម ផែនការមេថ្នាក់ជាតិស្តីពីការដឹកជញ្ជូន និងភស្តុភារកម្មក៏ត្រូវបានបន្តរៀបចំ ដែលគ្រោងបញ្ចប់នៅចុងឆ្នាំ២០១៩ ហើយគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ រួមមានផ្លូវថ្នល់ ផ្លូវដែក ស្ពាន កំពង់ផែជាដើម ត្រូវបានស្តារ សាងសង់ ជួសជុល និងរៀបចំកសាងជាបន្តបន្ទាប់ ជាពិសេស គម្រោងសាងសង់ផ្លូវល្បឿនលឿនចំនួន៣ គឺភ្នំពេញ-បាវិត និងពីហូជីមិញ-ម៉ុកបៃ, ភ្នំពេញ-ព្រះសីហនុ, និងភ្នំពេញ-ប៉ោយប៉ែត-សៀមរាប ដើម្បីកាត់បន្ថយថ្លៃចំណាយ និងពេលវេលាក្នុងការដឹកជញ្ជូន។

ចំពោះវិធានការពាក់ព័ន្ធនឹងយន្តការគ្រប់គ្រងទីផ្សារពលកម្ម និងការបណ្តុះបណ្តាលជំនាញវិញ វឌ្ឍនភាពជាច្រើនក្នុងការងារនេះត្រូវបានសម្រេចជាបន្តបន្ទាប់ ដូចជា ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង ត្រូវបានដំឡើងជារៀងរាល់ឆ្នាំ រីឯគុណភាពនៃការអប់រំ និងការបណ្តុះបណ្តាលជំនាញ ឆ្លើយតបនឹងតម្រូវការឧស្សាហកម្ម ព្រមទាំងផលិតភាពការងារ មានភាពប្រសើរឡើងច្រើនគួរឱ្យកត់សម្គាល់ តាមរយៈការដាក់ចេញ និងពង្រឹងការអនុវត្តគោលនយោបាយជាតិផ្សេងៗក្នុងវិស័យអប់រំ និងវិស័យការងារ។ រីឯវិធានការគន្លឹះចុងក្រោយ ទាក់ទិននឹងការអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ជាវិធានការដ៏សំខាន់មួយដែលទាមទារឱ្យមានការសិក្សាច្បាស់លាស់លើទិដ្ឋភាពច្បាប់ និងបច្ចេកទេសឱ្យបានគ្រប់ជ្រុងជ្រោយ ក្នុងនោះផែនការមេសម្រាប់អភិវឌ្ឍខេត្តនេះ កំពុងត្រូវបានសិក្សានិងរៀបចំដោយក្រសួង ស្ថាប័នពាក់ព័ន្ធ។ ក្នុងវិធានការទី៤នេះផងដែរ វឌ្ឍនភាពការងារមួយចំនួនដែលសម្រេចបាន មានដូចជា ការអនុម័តឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តព្រះសីហនុ និងផែនទី

បណ្តាញផ្លូវថ្នល់ ឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ, ព្រមទាំងការងារជាច្រើនទៀតដែលរាជរដ្ឋាភិបាល តាមរយៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននិងកំពុងពិនិត្យ និងជំរុញអនុវត្ត ពាក់ព័ន្ធនឹងការរៀបចំផែនការមេ ដើម្បីអភិវឌ្ឍនិងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ជាប៉ូលសេដ្ឋកិច្ចសំខាន់មួយ និងជាមជ្ឈមណ្ឌលឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ ស្របតាមទស្សនទាននៃការអភិវឌ្ឍប្រកបដោយចីរភាព និងតុល្យភាពបរិស្ថាន ព្រមទាំងឱ្យក្លាយជាទីក្រុងឧស្សាហកម្មបៃតងអាស៊ាន នាពេលអនាគត។

ទន្ទឹមនឹងសមិទ្ធផលដែលទទួលបានពីការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា នារយៈកាលកន្លងមក បញ្ហាប្រឈម និងហានិភ័យមួយចំនួនក៏បានលេចចេញមក ដែលបង្កឱ្យរាំងស្ទះដល់ការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា។ បញ្ហាប្រឈម និងហានិភ័យដែលជួបប្រទះ មានដូចជា ភាពប្រកួតប្រជែងរបស់កម្ពុជានៅមានកម្រិត, បរិស្ថានធុរកិច្ចនិងវិនិយោគដែលកាន់តែមានភាពអំណោយផលរបស់ប្រទេសក្នុងតំបន់, ការប្រែប្រួលភូមិសាស្ត្រនយោបាយ ព្រមទាំងការផ្លាស់ប្តូរលក្ខខណ្ឌនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ។ ក្រៅពីបញ្ហាប្រឈមទាំងនេះ ការអនុវត្តគោលនយោបាយនេះ ក៏ជួបប្រទះការលំបាកមួយចំនួនទៀត ដូចជាការសម្របសម្រួលនិងការកសាងសមត្ថភាពស្ថាប័ននៅមានកម្រិត ព្រមទាំងបញ្ហាកង្វះថវិកានិងធនធានមនុស្សសម្រាប់គាំទ្រលើវិធានការមួយចំនួន។ ក្នុងបរិការណ៍នេះ តួអង្គពាក់ព័ន្ធទាំងអស់ រួមមាន ស្ថាប័នជាតិ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ត្រូវបន្តកិច្ចសហការក្នុងការគ្រប់គ្រង និងដោះស្រាយរាល់បញ្ហាប្រឈម និងហានិភ័យដែលកើតមាន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់បំផុត ឱ្យបានទាន់ពេលវេលា ពិសេសធ្វើការបន្សុីទៅនឹងសភាពការណ៍ដែលមានការប្រែប្រួលឥតឈប់ឈរ ដើម្បីធានាភាពជោគជ័យនៃការអនុវត្តគោលនយោបាយនេះ។

សម្រាប់ទិសដៅការងារបន្ត រាជរដ្ឋាភិបាលនឹងរៀបចំការត្រួតពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិលើគោលនយោបាយនេះ នៅពាក់កណ្តាលឆ្នាំ២០២១ ដើម្បីឆ្លុះបញ្ចាំងពីជំហាននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងជាមូលដ្ឋានកែតម្រូវនិងតម្រង់ទិសដល់ការអនុវត្តបន្ត ដោយមានកំណត់នូវសូចនាករនិងគោលដៅថ្មីៗបន្ថែម ដែលអាចវាស់វែងបាន ហើយឆ្លើយតបនឹងអាទិភាពនៃតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ ក្នុងន័យនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលជាស្ថាប័នសម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា បាននិងកំពុងសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍ ក្នុងការរៀបចំនូវប្រព័ន្ធតាមដាននិងវាយតម្លៃគោលនយោបាយនេះ៕

## ឧបសម្ព័ន្ធទី១ : ឧបសម្ព័ន្ធ "គ": ម៉ាទ្រីសអំពីវិធានការគន្លឹះបួនជាក់ស្តែង ដើម្បីជំរុញ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម"

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| **ទី១** | រៀបចំ និងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនី សម្រាប់វិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម រួមទាំងការពង្រឹងភាពទុកចិត្តនិងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី។ | - *បញ្ចុះថ្លៃទិញពីអនុស្ថានីយផ្ទាល់មកត្រឹម **១២,៦០សេនអាមេរិក** ក្នុង១គីឡូវ៉ាត់ម៉ោង*<br>- *បញ្ចុះថ្លៃទិញពីប្រព័ន្ធភ្នំពេញ កណ្តាល និងកំពង់ស្ពឺរបស់អគ្គិសនីកម្ពុជាមកត្រឹម **១៦,៥០សេនអាមេរិក** ក្នុង១គីឡូវ៉ាត់ម៉ោង*<br>- *បញ្ចុះថ្លៃទិញពីខ្សែបញ្ជូនវងនានា ដែលចេញពីអនុស្ថានីយ (ទាំងរបស់អគ្គិសនីកម្ពុជា និងទាំងរបស់សេវាករឯកជន) មកត្រឹមឯកតាថ្លៃរួមមួយ **១៦,៤០ សេនអាមេរិក** ក្នុង១គីឡូវ៉ាត់ម៉ោង*<br>- *អនុម័តបញ្ជីថ្លៃលក់អគ្គិសនីតាមពេលវេលា ថ្ងៃ-យប់ សម្រាប់ឧស្សាហកម្ម*<br>- *ពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនីឱ្យដល់គ្រប់តំបន់ឧស្សាហកម្មគោលដៅ*<br>- *ធានាស្ថិរភាពនិងភាពទុកចិត្តនៃការផ្គត់-ផ្គង់អគ្គិសនីដោយកាត់បន្ថយអត្រាដាច់* | **២០១៨** | - ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា÷<br>▪ បានអនុម័តផែនការសម្រាប់អនុវត្តការបន្ថយអត្រា និងតម្លាតថ្លៃលក់អគ្គិសនីតាមបណ្តាខេត្ត និងរាជធានី ចាប់ពីខែមីនា ឆ្នាំ២០១៧ ដល់ ឆ្នាំ២០២០<br>▪ កម្មវិធីបន្ថយថ្លៃតាមឆ្នាំ (២០១៧-២០២០) ត្រូវបានរៀបចំ និងកំពុងដាក់ឱ្យអនុវត្ត ដែលក្នុងនោះថ្លៃអគ្គិសនីនៅឆ្នាំ២០១៧ ត្រូវបានកាត់បន្ថយនិងអនុគ្រោះចំពោះអ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម និងពាណិជ្ជកម្មធំៗក្នុងតម្លៃត្រឹមតែ ១២,៦០សេនដុល្លារអាមេរិកក្នុង ១គីឡូវ៉ាត់ម៉ោង សម្រាប់ការទិញពីអនុស្ថានីយផ្ទាល់, ១៦,៧០ សេនដុល្លារអាមេរិកក្នុង ១គីឡូវ៉ាត់ម៉ោង សម្រាប់ការទិញពីបណ្តាញភ្នំពេញ និង ១៦,៥០សេនដុល្លារអាមេរិកក្នុង ១គីឡូវ៉ាត់ម៉ោង សម្រាប់ការទិញពីបណ្តាញតាមខេត្ត<br>▪ បានកំណត់បញ្ជីថ្លៃលក់អគ្គិសនីតាមពេលវេលាសម្រាប់ជាជម្រើសថ្លៃមួយទៀតសម្រាប់អ្នកប្រើ- | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷<br>▪ កង្វះទិន្នន័យនិងព័ត៌មានលម្អិតក្នុងវិស័យនេះ<br>▪ សមត្ថភាពធនធានមនុស្ស និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត។<br>- រដ្ឋបាលខេត្តកណ្តាល÷<br>▪ ដោះស្រាយផលប៉ះពាល់ទីតាំងគម្រោង<br>▪ ដោះស្រាយផលប៉ះពាល់តាមបណ្តោយនៃខ្សែបណ្តាញ។ |

| | វិធានការដាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | *បន្តមិនឱ្យលើសពី១២ដងឬ២៤ម៉ោង/ឆ្នាំ។* | | ប្រាស់ប្រភេទឧស្សាហកម្ម ពាណិជ្ជកម្ម និងកសិកម្មក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជាសម្រាប់ឆ្នាំ២០១៧ ដោយបែងចែកអត្រាថ្លៃលក់ជា២ប្រភេទទៅតាមពេលវេលា (១) ពីម៉ោង០៧:០០-២១:០០÷ ទិញពីអនុស្ថានីយថ្លៃ ១៣,៦០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង និងទិញពីខ្សែបណ្តាញតង់ស្យុងមធ្យមថ្លៃ ១៧,៥០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង និង (២) ពីម៉ោង២១:០០-៧:០០÷ ទិញពីអនុស្ថានីយថ្លៃ ៩,៣០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង និងទិញពីខ្សែបណ្តាញតង់ស្យុងមធ្យម ១២,០០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង<br>▪ បានកំណត់អត្រាថ្លៃលក់អគ្គិសនីពិសេសនៅរដូវវស្សា មកត្រឹម ១៤,០០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោងសម្រាប់លក់ឱ្យអ្នកប្រើប្រាស់ធុនធំដែលប្រើលើសពី១មេហ្គាវ៉ាត់<br>▪ បានសាងសង់ខ្សែបណ្តាញមេចេញពីអនុស្ថានីយដើម្បីរំលែកបន្ទុកលើខ្សែចាស់ និងបង្កើនស្ថិរភាពក្នុងការផ្គត់ផ្គង់នៅរោងចក្រឧស្សាហកម្មក្នុងឆ្នាំ២០១៦, ២០១៧ និងឆ្នាំ២០១៨<br>▪ បាននិងកំពុងជំរុញ និងបង្កើនប្រភពផ្គត់ផ្គង់អគ្គិ-សនីដែលរួមមាន÷ (១) ការដាក់ឱ្យដំណើរការ | |

| | វិធានការដាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ស្ថានីយអគ្គិសនីដុតធ្យូងថ្មអានុភាព ១៣៥មេហ្គាវ៉ាត់, (២) ការដាក់ឱ្យដំណើរការស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យអានុភាព ១០មេហ្គាវ៉ាត់, (៣) ការដាក់ឱ្យដំណើរការស្ថានីយវារីអគ្គិសនីសេសានក្រោម២ អានុភាពសរុប ៤០០មេហ្គាវ៉ាត់, (៤) ការដាក់ឱ្យដំណើរការអនុស្ថានីយទួលពង្រ (GS8) អានុភាព ៧៥មេហ្គាវ៉ាត់ ដើម្បីជួយបង្កើនការផ្គត់ផ្គង់ដល់តំបន់ឧស្សាហកម្មនៅវេងស្រេង និងទួលពង្រ, (៥) ការពង្រីកការផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ធុនធំ ដែលភ្ជាប់ចេញពីខ្សែបណ្តាញតង់ស្យុងខ្ពស់ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (PP-SEZ) និងរោងចក្រស៊ីម៉ង់ត៍ Conch នៅស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង, និង (៦) ការដាក់ឱ្យដំណើរការខ្សែបញ្ជូន១១៥គីឡូវ៉ុល ភ្នំពេញ-បាវិត (អនុស្ថានីយច្រកម្ទេស និងអនុស្ថានីយកំពង់សីង្ហ) ដើម្បីជួយបង្កើនស្ថិរភាព និងគុណភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនី ដល់ខេត្តស្វាយរៀង និងខេត្តព្រៃវែង ជាពិសេស តំបន់សេដ្ឋកិច្ចពិសេសនៅក្រុងបាវិត<br>▪ បាននិងកំពុងសាងសង់អនុស្ថានីយនៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ អានុភាពសរុប ៥០មេហ្គាវ៉ាត់, ព្រមទាំងបន្ថែមកម្លាំងត្រង់ស្វូ | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងចឡនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | តាមបណ្តាអនុស្ថានីយក្នុងរាជធានីភ្នំពេញ និងខេត្តក្រុងសំខាន់ៗ ដែលជាទិសដៅអាទិភាព ដើម្បីបង្កើនសមត្ថភាព និងស្ថិរភាពក្នុងការផ្គត់ផ្គង់ជូនអតិថិជន ដែលនឹងគ្រោងដាក់ឱ្យដំណើរការក្នុងឆ្នាំ២០១៩<br>▪ បានអនុញ្ញាតគម្រោងវិនិយោគបន្ថែមម៉ាស៊ីនផលិតអគ្គិសនីដុតត្បូងថ្មអានុភាព១៣៥មេហ្គាវ៉ាត់ ដែលនឹងដាក់ឱ្យដំណើរការនៅឆ្នាំ២០១៩<br>▪ បានសិក្សាគម្រោងសាងសង់អនុស្ថានីយថ្មីក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ<br>▪ បានបង្កើតក្រុមការងារពិនិត្យ តាមដាន និងដោះស្រាយបញ្ហាដាច់ចរន្តញឹកញាប់ និងបញ្ហាធ្លាក់គុណភាពខ្សែបណ្តាញ<br>▪ បាននិងកំពុងសិក្សាអំពីលទ្ធភាពក្នុងការបន្ថយថ្លៃលក់អគ្គិសនីបន្ថែមសម្រាប់ឆ្នាំ ២០១៩ និង ២០២០<br>▪ បានអនុវត្តគម្រោងវិនិយោគលើកកម្ពស់ស្ថិរភាពនៃការផ្គត់ផ្គង់ក្នុងឆ្នាំ២០១៧<br>▪ ស្របតាមផែនការយុទ្ធសាស្ត្ររបស់ក្រសួង រហូតដល់ឆ្នាំ២០១៨ បានកសាងខ្សែបញ្ជូនតង់ស្យុងខ្ពស់តភ្ជាប់រាជធានី ខេត្ត និងសម្រេចបានការផ្គត់ផ្គង់តំបន់ប៉ូលសេដ្ឋកិច្ចសំខាន់ៗប្រមាណជា | |

| | វិធានការដាក់ស្នែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ៥០% ក្នុងឆ្នាំ២០១៦ និងគ្រប់ដណ្ដប់ ១០០% ក្នុងឆ្នាំ២០១៨ (ចំពោះតំបន់ឧស្សាហកម្មស្ថិតនៅរង្វង់ ២៥ គីឡូម៉ែត្រពីអនុស្ថានីយ)<br>▪ បានត្រួតពិនិត្យជាប្រចាំប្រព័ន្ធផ្គត់ផ្គង់ឱ្យបានស្ថិរភាពខ្ពស់ខិតទៅរកស្តង់ដាអន្តរជាតិ ក្នុងឆ្នាំ២០១៨<br>▪ បានសាងសង់ខ្សែបណ្តាញមេចេញពីអនុស្ថានីយបន្ថែម និងខ្សែបណ្តាញជាកងសម្រាប់តំបន់សំខាន់ៗក្នុងឆ្នាំ២០១៨<br>▪ បានចេញសេចក្តីប្រកាស ស្តីពីការកែសម្រួលអត្រាថ្លៃលក់អគ្គិសនីឡើងវិញ នៅក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រា និងតម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០១៨ សម្រាប់ការអនុវត្តបន្តពីឆ្នាំ២០១៩ ដល់ឆ្នាំ ២០២០<br>▪ បានធ្វើការកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនី ជាបន្តបន្ទាប់ សម្រាប់អនុវត្តនៅឆ្នាំ២០១៦, ឆ្នាំ២០១៧, ឆ្នាំ២០១៨ និងឆ្នាំ២០១៩<br>▪ បានអនុវត្តតាមប្រកាសក្រសួងរ៉ៃ និងថាមពល បន្ថយអត្រាថ្លៃលក់អគ្គិសនី នៅតាមតំបន់ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិសម្រាប់ឆ្នាំ ២០១៧-២០២០ និងអនុវត្តតាមប្រកាសក្រសួងរ៉ៃ និងថាមពល បន្ថយអត្រាថ្លៃលក់អគ្គិសនីនៅ | |

| | វិធានការជាក់ស្តែងចម្បង | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | តាមតំបន់ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិសម្រាប់ឆ្នាំ២០១៩-២០២០<br>▪ បានអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីតាមពេលវេលាថ្ងៃ និងយប់ សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្ម សរុបអតិថិជនមានចំនួន ២៨ទីតាំង សម្រាប់ឆ្នាំ ២០១៧ និង ៣៦ទីតាំង សម្រាប់ឆ្នាំ២០១៨ ដែលថ្លៃលក់លើតង់ស្យុងខ្ពស់ និងតង់ស្យុងមធ្យម (ទាំងក្នុងតំបន់អគ្គិសនីកម្ពុជា និងតំបន់អ្នកកាន់អាជ្ញាបណ្ណឯកជន)<br>▪ បានអនុវត្តបញ្ជីថ្លៃលក់អគ្គិសនី ដែលមានដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ភ្ជាប់សាំងក្រូនជាមួយបណ្តាញជាតិ<br>▪ កំពុងសិក្សារៀបចំកែសម្រួលបញ្ជីថ្លៃលក់ តាមពេលវេលាថ្ងៃ-យប់ សម្រាប់អ្នកប្រើប្រាស់ធុនធំ និងធុនធំ "ប្រភេទឧស្សាហកម្ម ពាណិជ្ជកម្ម និងកសិកម្ម" ទាំងក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា និងទាំងក្នុងតំបន់ចែកចាយរបស់អ្នកផ្គត់ផ្គង់ឯកជន និងបញ្ជីថ្លៃលក់អគ្គិសនីសម្រាប់អ្នកផ្គត់ផ្គង់អគ្គិសនីលក់ឱ្យអ្នកប្រើប្រាស់ធុនធំ និងធុនធំដែលមានដំឡើងប្រព័ន្ធពន្លឺព្រះអាទិត្យភ្ជាប់សាំងក្រូនជាមួយប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីបណ្តាញជាតិ បញ្ចូលគ្នាទៅជា "បញ្ជីថ្លៃលក់អគ្គិសនីតាម | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ពេលវេលា និងអានុភាព" ចំពោះ "អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម និងកសិកម្ម" និងចំពោះ "អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្ម និងរដ្ឋបាល"<br>▪ បានដាក់ឱ្យដំណើរការ អនុស្ថានីយព្រះវិហារទី១ ក្នុងស្រុកឆែប ខេត្តព្រះវិហារ ដើម្បីកាត់បន្ថយការយកប្រភពពីប្រទេសឡាវដែលមានចម្ងាយឆ្ងាយ<br>▪ បានដាក់ឱ្យដំណើរការខ្សែបញ្ជូន ២៣០គីឡូវ៉ុល ពីកំពង់ចាម-ក្រចេះ-ស្ទឹងត្រែង-វ៉ារីអគ្គិសនីសេសាន ដែលធ្វើឱ្យតម្លៃអគ្គិសនីនៅក្នុងខេត្តក្រចេះ-ស្ទឹងត្រែង មានតម្លៃអគ្គិសនីដូចថ្លៃបណ្តាញជាតិចាប់ពីឆ្នាំ២០១៨<br>▪ បានសាងសង់ខ្សែបណ្តាញមេចេញពីអនុស្ថានីយ ដើម្បីរំលែកបន្ទុកលើខ្សែចាស់ និងបង្កើនស្ថិរភាពក្នុងការផ្គត់ផ្គង់នៅរោងចក្រឧស្សាហកម្មក្នុងឆ្នាំ២០១៧ និងកំពុងបន្តទៀតនៅឆ្នាំ២០១៨។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷<br>▪ បានសិក្សាវិភាគ និងផ្តល់ធាតុចូលក្នុងផែនការបញ្ចុះថ្លៃអគ្គិសនីបន្ថែមសម្រាប់ឆ្នាំ២០១៩-២០២០<br>▪ បានចូលរួមរៀបចំផែនការវិនិយោគ ២០១៩-២០២៣ របស់អគ្គិសនីកម្ពុជា ដើម្បីជាមូលដ្ឋានគ្រប់ជ្រុងជ្រោយ សម្រាប់ស្វែងរកហិរញ្ញប្បទាន | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានវិភាជថវិកា សម្រាប់គម្រោងសាងសង់ខ្សែបញ្ជូន ១១៥គីឡូវ៉ុល តភ្ជាប់ស្រែអំបិល-ខេត្តកោះកុង និងខេត្តកំពង់ចាម ខេត្តក្រចេះ និងខ្សែបញ្ជូនរងអគ្គិសនីជនបទ<br>▪ បានវិភាជថវិកា សម្រាប់គម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូន និងចែកចាយនៅរាជធានីភ្នំពេញ ជំហានទី១ ជំហានទី២<br>▪ បានវិភាជថវិកា សម្រាប់គម្រោងពង្រីកបណ្តាញអគ្គិសនីភាវូបនីយកម្មជនបទ ជំហានទី៣,៤,៥ និងទី៦<br>▪ បានវិភាជថវិកា សម្រាប់គម្រោងសាងសង់ខ្សែបញ្ជូនជាកងតង់ស្យុង ២៣០គីឡូវ៉ុល នៅភាគពាយ័ព្យនៃប្រទេសកម្ពុជា<br>▪ បានវិភាជថវិកា សម្រាប់គម្រោងសាងសង់ខ្សែបញ្ជូនជាកងតង់ស្យុង ២៣០គីឡូវ៉ុល<br>▪ បានវិភាជថវិកា សម្រាប់គម្រោងខ្សែបញ្ជូនអគ្គិសនី ២៣០គីឡូវ៉ុល តភ្ជាប់ខេត្តក្រចេះ-ស្ទឹងត្រែង<br>▪ បានសហការអនុវត្តគម្រោងសាងសង់ខ្សែអគ្គិសនីបណ្តាញមេ ជំហានទី១ (ពីខេត្តបាត់ដំបង ទៅខេត្តសៀមរាប និងពីខេត្តសៀមរាប ទៅខេត្តកំពង់ចាម) ហិរញ្ញប្បទានដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានសហការអនុវត្តគម្រោងពង្រីកបណ្តាញអគ្គិសនីភាវូបនីយកម្មជនបទ នៅខេត្តស្វាយរៀង ដោយធ្វើការតភ្ជាប់បណ្តាញចែកចាយអគ្គិសនីជូនប្រជាជនចំនួន ៨.០០០គ្រួសារ អនុវត្តដោយ EDC ដែលមានទឹកប្រាក់សរុប ៨,៦ លានដុល្លារអាមេរិក ហិរញ្ញប្បទានដោយ Australian Aid<br>▪ បានចូលរួមរៀបចំគម្រោង National Solar Park Program ដែលនឹងវិនិយោគលើស្ថានីយថាមពលអគ្គិសនីដើរដោយប្រព័ន្ធ Solar ហិរញ្ញប្បទានដោយ ADB ព្រមទាំងមានការចូលរួមពីវិស័យឯកជន មានទំហំ ១០០ មេហ្គាវ៉ាត់<br>▪ បានសហការអនុវត្ត÷<br>- គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីដល់ជនបទ ដំណាក់កាលទី៣ និង៤ ដែលហិរញ្ញប្បទានដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន<br>- គម្រោងសាងសង់ខ្សែអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុល ដំណាក់កាលទី១ ហិរញ្ញប្បទានដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន<br>- គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុល ដំណាក់កាលទី២ Part I | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ហិរញ្ញប្បទានដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។<br>▪ បានសហការអនុវត្តគម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូន និងចែកចាយនៅរាជធានីភ្នំពេញ (ដំណាក់កាលទី២) ជាមួយ JICA ដែលមានទឹកប្រាក់ប្រមាណ ៣៥,៣០ លានដុល្លារអាមេរិក ដើម្បីសាងសង់អនុស្ថានីយចំនួន២, និងជួសជុលពង្រីកអនុស្ថានីយដែលមានស្រាប់ចំនួន២, និងសាងសង់ខ្សែបញ្ជូនអគ្គិសនីបង្កប់ក្នុងដីទៅកាន់អនុស្ថានីយថ្មី និងរៀបចំប្រព័ន្ធទូរគមនាគមន៍សម្រាប់ប្រតិបត្តិការបណ្តាញបញ្ជូនអគ្គិសនី<br>▪ បន្តអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញសេរីអាស៊ានជាធរមាន ដែលជារួមអត្រាពន្ធគយបានធ្លាក់ដល់កម្រិត 0% លើមុខទំនិញទាំងនេះ (លើកលែងទំនិញក្នុង Exclusive List)<br>▪ បានលើកលែងការបង់ពន្ធនាំចូល និងអាករលើតម្លៃបន្ថែម (កត់ត្រាជាបន្ទុករបស់រដ្ឋ) ចំពោះការនាំចូលថាមពលអគ្គិសនី ធ្យូងថ្ម និងប្រេងខ្មៅរបស់អគ្គិសនីកម្ពុជា និងក្រុមហ៊ុនផលិតអគ្គិសនីឯករាជ្យ ដែលផលិតថាមពលអគ្គិសនីឱ្យអគ្គិសនី | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | កម្ពុជា (លិខិតលេខ១៨៤៦/១៨ អគរ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៨)<br>▪ បានបញ្ចុះអត្រាពន្ធគយលើមុខទំនិញប្រេងកាត ពី៧% មក០% និងអាករពិសេសលើមុខទំនិញ ប្រេងម៉ាស៊ូតពី១៥% មក៥,៥% (អនុក្រឹត្យលេខ ៨៦អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអាករ)<br>▪ គម្រោងរោងចក្រអគ្គិសនីដុតធ្យូងថ្ម អានុភាព ៧០០ មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ ត្រូវបាន អនុម័តដោយគណៈរដ្ឋមន្ត្រី<br>▪ គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនីអានុភាព ៦០មេហ្គាវ៉ាត់ នៅខេត្តកំពង់ស្ពឺ។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖<br>ក្នុងឆ្នាំ២០១៦៖<br>▪ បានផ្សព្វផ្សាយផែនការសម្រាប់អនុវត្តការបន្ថយ អត្រា និងតម្លាតថ្លៃលក់អគ្គិសនី នៅតាមតំបន់ សំខាន់ៗជូនអ្នកវិនិយោគ និងទាក់ទាញការវិនិ- យោគបន្ថែមក្នុងវិស័យផលិតថាមពលអគ្គិសនី។<br>ក្នុងឆ្នាំ២០១៧៖<br>▪ បានបន្តផ្សព្វផ្សាយផែនការសម្រាប់អនុវត្តការ បន្ថយអត្រា និងតម្លាតថ្លៃលក់អគ្គិសនី នៅតាម | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | តំបន់សំខាន់ៗជូនអ្នកវិនិយោគ និងទាក់ទាញការវិនិយោគបន្ថែមក្នុងវិស័យផលិតថាមពលអគ្គិសនី<br>▪ បានរៀបចំនិងអនុវត្តសកម្មភាពរបស់ខ្លួនជាច្រើនក្នុងការទាក់ទាញ ជំរុញ និងលើកទឹកចិត្តដល់គម្រោងវិនិយោគក្នុងវិស័យផលិត និងចែកចាយថាមពលអគ្គិសនី ដែលជាកត្តាគន្លឹះចម្បងក្នុងការបង្កើនប្រភពថាមពល និងកាត់បន្ថយថ្លៃអគ្គិសនី ដូចជា៖<br>- បានសិក្សាស្រាវជ្រាវអំពីតម្លៃអគ្គិសនីតាមបណ្តាប្រទេសសមាជិកអាស៊ាន ដើម្បីធ្វើការប្រៀបធៀបតម្លៃអគ្គិសនីក្នុងប្រទេសកម្ពុជាជាមួយបណ្តាប្រទេសក្នុងតំបន់ ក្នុងគោលបំណងផ្តល់ជាធាតុចូលសម្រាប់ការរៀបចំយុទ្ធសាស្ត្រដើម្បីកាត់បន្ថយថ្លៃអគ្គិសនីក្នុងប្រទេសកម្ពុជា<br>- បានធ្វើការផ្សព្វផ្សាយពីកាលានុវត្តភាព និងព័ត៌មានវិនិយោគសំខាន់ៗទាក់ទងនឹងវិស័យអគ្គិសនីក្នុងប្រទេសកម្ពុជា ជូនអ្នកវិនិយោគតាមបណ្តាប្រទេសសមាជិកអាស៊ាន និងប្រទេសមិនមែនសមាជិកអាស៊ានមួយចំនួនដូចជាប្រទេសចិន និងជប៉ុន ដើម្បីទាក់ទាញក្រុមហ៊ុន ឬគម្រោងវិនិយោគក្នុងវិស័យផលិត | |

| | វិធានការដាក់ស្តែងឬន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | និង/ឬចែកចាយថាមពលអគ្គិសនីឱ្យមកវិនិយោគកាន់តែច្រើនទៀតនៅប្រទេសកម្ពុជា<br>- បានចូលរួមគ្រប់សកម្មភាពប្រជុំពិភាក្សា ក៏ដូចជាការរៀបចំតាមដាន និងសហការអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនីសម្រាប់វិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ<br>- បានរួមសហការជាមួយក្រសួងរ៉ែនិងថាមពល ចុះស្រង់ស្ថិតិអំពីអស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនីនៅតាមតំបន់សេដ្ឋកិច្ចពិសេស និងកសាងមូលដ្ឋានទិន្នន័យ។<br>ក្នុងឆ្នាំ២០១៨ ÷<br>▪ បានបន្តធ្វើការស្រាវជ្រាវទាក់ទងនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធ ដូចជា ស្ថានភាពនិងតម្លៃថាមពលអគ្គិសនីក្នុងប្រទេសកម្ពុជា និងបណ្តាប្រទេសសមាជិកអាស៊ាន<br>▪ បានបន្តផ្សព្វផ្សាយពីកាលានុវត្តភាពនិងស្ថានភាពវិនិយោគក្នុងវិស័យផលិតនិង/ឬ ចែកចាយថាមពលអគ្គិសនីក្នុងប្រទេសកម្ពុជា ជូនអ្នកវិនិយោគតាមបណ្តាប្រទេសសមាជិកអាស៊ាន និងប្រទេសមិនមែនជាសមាជិកអាស៊ាន | |

| | វិធានការជាក់ស្ដែងបូន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងថវិកាភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានសម្រេចអនុញ្ញាតឱ្យក្រុមហ៊ុនមួយចំនួនវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ក្នុងនោះក្រុមហ៊ុនធំៗចំនួនបីបានវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតអគ្គិសនីដើរដោយធ្យូងថ្មដែលមានអានុភាព ១០០មេហ្គាវ៉ាត់, រោងចក្រផលិតថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យដែលមានអានុភាព ៦០មេហ្គាវ៉ាត់, និងគម្រោងវិនិយោគសាងសង់ខ្សែបណ្ដាញអគ្គិសនី ចំនួន ២គម្រោង ក្នុងទុនវិនិយោគសរុបប្រមាណ ៣១៦ លានដុល្លារអាមេរិក<br>▪ បានចូលរួមពង្រឹងភាពទុកចិត្ត និងការពង្រីកវិសាលភាពគ្របដណ្ដប់នៃការផ្គត់ផ្គង់អគ្គិសនីដល់គម្រោងវិនិយោគថ្មីចំនួន ៧៩ នៅតាមតំបន់សេដ្ឋកិច្ចពិសេស។<br>- រដ្ឋបាលរាជធានីភ្នំពេញ÷<br>▪ ដោយមានមន្ទីររ៉ែ និងថាមពលជាសេនាធិការនៅក្នុងក្របខណ្ឌរយៈពេលខ្លី មធ្យម និងវែង បានអនុវត្តផែនការបញ្ចុះតម្លៃអគ្គិសនី ដោយ÷<br>- បញ្ចុះថ្លៃទិញពីអនុស្ថានីយផ្ទាល់ មកត្រឹម ១១,៧០ សេនអាមេរិក ក្នុង១គីឡូវ៉ាត់ម៉ោង<br>- បញ្ចុះថ្លៃទិញពីប្រព័ន្ធភ្នំពេញ កណ្ដាល និងកំពង់ស្ពឺរបស់អគ្គិសនីកម្ពុជា មកត្រឹម១៦,៥០ សេនអាមេរិក ក្នុង១គីឡូវ៉ាត់ម៉ោង | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | - អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម ពាណិជ្ជកម្មធុនតូចទិញពីខ្សែបណ្តាញចែកចាយសាធារណៈតាមតង់ស្យុងទាប តម្លៃ៧៥០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង បញ្ចុះមកត្រឹម ៧៤០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង<br>- អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្មធុនធំ និងមធ្យម ដែលទិញពីខ្សែបណ្តាញតង់ស្យុងមធ្យមតាមនាឡិកាស្ទង់ MV នៅរាជធានី-ភ្នំពេញ តម្លៃ ០,១៦ដុល្លារអាមេរិក ក្នុង១គីឡូវ៉ាត់ម៉ោង បញ្ចុះមកត្រឹម ០,១៤ដុល្លារអាមេរិក ក្នុង១គីឡូវ៉ាត់ម៉ោង<br>- អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្មធុនធំ និងមធ្យម ដែលទិញក្រោមត្រង់ស្វូរផ្ទាល់ដែលត្រង់ស្វូរវិនិយោគដោយអ្នកទិញតាមនាឡិកាស្ទង់ LV នៅរាជធានីភ្នំពេញ តម្លៃ ០,១៧ដុល្លារអាមេរិក ក្នុង១គីឡូវ៉ាត់ម៉ោង បញ្ចុះមកត្រឹម០,១៥ដុល្លារអាមេរិក ក្នុង១គីឡូវ៉ាត់ម៉ោង<br>- អ្នកប្រើប្រាស់ធុនធំ និងមធ្យម ប្រភេទពាណិជ្ជកម្ម រដ្ឋបាលដែលទិញពីខ្សែបណ្តាញតង់ស្យុងមធ្យមតាមនាឡិកាស្ទង់ MV នៅរាជ-ធានីភ្នំពេញ តម្លៃ ០,១៦ដុល្លារអាមេរិក ក្នុង១ | |

| | វិធានការដាក់ស្នើបន្ថែម | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | គីឡូវ៉ាត់ម៉ោង បញ្ចុះមកត្រឹម ០,១៥ដុល្លារអាមេរិក ក្នុង១គីឡូវ៉ាត់ម៉ោង<br>- អ្នកប្រើប្រាស់ប្រភេទអនុគ្រោះពិសេស ក្នុងការបូមទឹកធ្វើកសិកម្មពេលយប់ចាប់ពីម៉ោង៩ ដល់ ម៉ោង៧ព្រឹក មានតម្លៃ ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង ចំពោះសាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព មានតម្លៃ៦១០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង។<br>- រដ្ឋបាលខេត្តកណ្ដាល បានចូលរួមសហការជាមួយអគ្គិសនីកម្ពុជា និងមន្ទីររ៉ែនិងថាមពល ក្នុងការរៀបចំបណ្ដាញបញ្ជូន ២៣០គីឡូវ៉ុល នៅស្រុកកណ្ដាលស្ទឹង និងស្រុកកៀនស្វាយសម្រាប់ឆ្នាំ២០១៧-២០១៨ និងជំរុញការអនុវត្តគម្រោងពាក់ព័ន្ធផ្សេងៗទៀតនៅឆ្នាំខាងមុខ ដើម្បីជួយប្រជាជនទាំង១.០១០ភូមិ មានអគ្គិសនីប្រើប្រាស់។<br>- រដ្ឋបាលខេត្តព្រះសីហនុ÷<br>▪ បានបញ្ចុះតម្លៃអគ្គិសនីសម្រាប់វិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម និងដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៨ ក្នុងតម្លៃ ១៦,៤០សេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង | |

| | វិធានការដាក់ស្នើខ្លួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានសម្រេចការរៀបចំប្រព័ន្ធបញ្ជូនអគ្គិសនីទៅទូទាំងក្រុងព្រះសីហនុ និងទៅកាន់តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុបានរួចរាល់<br>▪ បានសាងសង់អនុស្ថានីយរាម សម្រាប់ផ្គត់ផ្គង់អគ្គិសនីដល់តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ និងសម្រាប់ផ្គត់ផ្គង់អគ្គិសនីដល់ឧស្សាហកម្មធុនមធ្យម និងធុនតូច នៅក្នុងមួយផ្នែកនៃស្រុកព្រៃនប់<br>▪ ការប្រើប្រាស់ថាមពលអគ្គិសនីនៅក្នុងខេត្តបានកើនឡើងពី ៥០មេហ្គាវ៉ាត់ ទៅដល់ ១៥០ មេហ្គាវ៉ាត់ ដោយសារការកើនឡើងនូវរោងចក្រសហគ្រាសនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស និងកំណើននៃសំណង់អគារពាណិជ្ជកម្មខ្ពស់ៗនៅក្នុងខេត្ត<br>▪ រោងចក្រអគ្គិសនីដែលដើរដោយថាមពលធ្យូងថ្ម ដែលមាននៅក្នុងខេត្តព្រះសីហនុ មានចំនួន៣គឺ CEL1 ផលិតថាមពលបាន ១១០មេហ្គាវ៉ាត់ CEL2 ផលិតថាមពលបាន ១៥០មេហ្គាវ៉ាត់ CIIDG ផលិតថាមពលបាន ៤០៥មេហ្គាវ៉ាត់។ ដូចនេះ សរុបថាមពលដែលរោងចក្រទាំងបីផលិតបានគឺមានប្រមាណ ៦៦៥មេហ្គាវ៉ាត់ ដែលអាចផ្គត់ផ្គង់តម្រូវការនៅក្នុងខេត្ត និង | |

| | វិធានការដាក់ស្តែងចូន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | បញ្ជូនទៅតាមអនុស្ថានីយដទៃទៀត សម្រាប់ផ្គត់ផ្គង់ដល់បណ្តាខេត្ត និងរាជធានី ដែលខ្វះខាតចរន្តអគ្គិសនី។ | |
| ទី២ | រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម ក្នុងគោលដៅបង្កើតប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយនិងប្រព័ន្ធភស្តុភារកម្មដែលមានសមាហរណកម្ម និងប្រសិទ្ធភាពខ្ពស់ ពិសេស ផ្តោតលើការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និងការអភិវឌ្ឍរបៀងសេដ្ឋកិច្ច *ភ្នំពេញ-ខេត្តព្រះសីហនុ ភ្នំពេញ-បាវិត* និង *ភ្នំពេញ-ប៉ោយប៉ែត* ឱ្យក្លាយទៅជារបៀងសេដ្ឋកិច្ចគន្លឹះរបស់ជាតិ តាមរយៈការកសាងផ្លូវហាយវេស្តង់ដារអន្តរជាតិ និងការបង្កើតប្រព័ន្ធភស្តុ- | - *ផែនការមេសម្រាប់អភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន ស្តង់ដារអន្តរជាតិ*<br>- *ផែនការមេសម្រាប់អភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម ប្រកបដោយសមាហរណកម្ម និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់*<br>- *ផែនការអភិវឌ្ឍន៍របៀងសេដ្ឋកិច្ច*<br>- *ផែនការ កម្មវិធី និងគម្រោងវិនិយោគ*<br>- *យន្តការគ្រប់គ្រង និងអនុវត្ត។* | ២០១៨ | ▪ សម្របសម្រួលដោយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក្រសួងស្ថាប័នចូលរួម ÷<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន÷<br>▪ បានរៀបចំកែទម្រង់រចនាសម្ព័ន្ធក្រសួងដោយបានបង្កើតអគ្គនាយកដ្ឋានភស្តុភារកម្ម (មាននាយកដ្ឋានចំនួន០៤) ដែលជាស្ថាប័នទទួលបន្ទុកផ្ទាល់ក្នុងការរៀបចំ និងអនុវត្តផែនការមេភស្តុភារកម្ម។<br>▪ បានរៀបចំបង្កើតក្រុមប្រឹក្សាជាតិភស្តុភារកម្ម គណៈកម្មាធិការជាតិភស្តុភារកម្ម និងលេខាធិការដ្ឋាន ដោយព្រះរាជក្រឹត្យលេខ នស/រកត/១១១៧/១០៩២ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧។<br>▪ ក្រសួង រួមជាមួយ JICA និងធនាគារពិភពលោក បានបញ្ចប់ការសិក្សាផែនការមេស្តីពីការកែលម្អប្រព័ន្ធភស្តុភារកម្មនៅព្រះរាជាណាចក្រកម្ពុជា ២០១៨-២០២៥ គាំទ្រផ្នែកបច្ចេកទេសពី JICA និងធនាគារពិភពលោក ហើយគ្រោងនឹងដាក់ឱ្យអនុវត្តក្នុង ៣ដំណាក់កាលរយៈពេលខ្លី (២០១៨- | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷<br>▪ នៅមានកិច្ចការមួយចំនួនពាក់ព័ន្ធនឹងការបន្ស៊ីគ្នារវាងការរៀបចំផែនការមេឡូជីស្ទីករបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងការសិក្សានេះ<br>▪ ទាមទារឱ្យមានការពិភាក្សាថ្នាក់ម្រិតថ្នាក់ដឹកនាំឱ្យបានច្បាស់ពីគោលជំហររួម ដើម្បីឱ្យមានភាពស៊ីគ្នារវាងការសិក្សាទាំងពីរ<br>▪ ការបន្តកិច្ចសហការពីក្រសួង និងស្ថាប័នពាក់ព័ន្ធក្នុងការចូលរួមការសិក្សានេះ។<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន÷ |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | ភារកម្ម ប្រកបដោយប្រសិទ្ធភាព។ | | | ២០១៩) មធ្យម (២០២០-២០២២) និងវែង (២០២៣-២០២៥)<br>▪ ក្រសួង និង JICA កំពុងអនុវត្តគម្រោងសហប្រតិបត្តិការបច្ចេកទេស "គម្រោងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធភស្តុភារកម្ម" ដែលគាំទ្រដោយ JICA ពីឆ្នាំ២០១៨-២០២៥<br>▪ គម្រោងអភិវឌ្ឍមជ្ឈមណ្ឌលភស្តុភារកម្មក្រុងព្រះសីហនុ បានបញ្ចប់ការចុះកិច្ចព្រមព្រៀងផ្តល់សេវាពិគ្រោះយោបល់ផ្នែកហិរញ្ញវត្ថុ (Financial Advisory Service Agreement) ដើម្បីចាប់ផ្តើមធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព នឹងដំណើរការសិក្សានៅខែសីហា ឆ្នាំ២០១៩ អនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្រោមក្របខណ្ឌយន្តការភាពជាដៃគូវិនិយោគ ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ<br>▪ បាននិងកំពុងអនុវត្តនូវផែនការមេតភ្ជាប់អាស៊ាន ឆ្នាំ២០២៥<br>▪ គម្រោងអភិវឌ្ឍមជ្ឈមណ្ឌលឡូជីស្ទីកភ្នំពេញ (Phnom Penh Logistics Complex) កំពុងសិក្សាបុរេសមិទ្ធិលទ្ធភាព គ្រោងនឹងបញ្ចប់នៅខែវិច្ឆិកា ឆ្នាំ២០១៩ ខាងមុខនេះ គាំទ្រដោយ | ▪ ការងារនៅក្នុងវិស័យភស្តុភារកម្ម គឺមានជាប់ពាក់ព័ន្ធទៅនឹងអន្តរវិស័យដូច្នេះការសម្របសម្រួលទាំងក្នុងក្របខ័ណ្ឌនៃការរៀបចំផែនការ, គោលនយោបាយ និងការអនុវត្ត គឺជាបញ្ហាប្រឈមចំពោះមុខ<br>▪ ការកៀរគរប្រភពហិរញ្ញប្បទានពីដៃគូរអភិវឌ្ឍន៍ និងពីផ្នែកឯកជន ដើម្បីគាំទ្រដល់ការអនុវត្តផែនការមេ និងការបន្តស្តារ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ គឺជាបញ្ហាប្រឈមដ៏ធំមួយទៀត ដែលចាំបាច់ត្រូវមានយន្តការសម្របសម្រួល និងមានការចូលរួមយ៉ាងសកម្មពីតួអង្គពាក់ព័ន្ធ<br>- ក្រសួងអភិវឌ្ឍន៍ជនបទ÷ |

| | វិធានការដាក់ស្នើងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងចូលរួម | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ធនាគារអភិវឌ្ឍន៍អាស៊ី គ្រោងនឹងវិនិយោគក្រោមរូបភាពភាពជាដៃគូរវាងរដ្ឋ និងឯកជន<br>▪ បានសហការជាមួយ JICA និងធនាគារពិភព-លោក ក្នុងការកំណត់បញ្ហាដែលនាំឱ្យរាំងស្ទះដល់ការអភិវឌ្ឍភស្តុភារកម្ម និងប្រមូលបានព័ត៌មានត្រឡប់ពីអ្នកពាក់ព័ន្ធ សំដៅជំរុញផែនការមេភស្តុ-ភារកម្មជាតិឱ្យមានលក្ខណៈពេញលេញគ្រប់ជ្រុង-ជ្រោយ<br>▪ គម្រោងអភិវឌ្ឍន៍ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ កំពុងដំណើរការ<br>▪ គម្រោងសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-បាវិត បានបញ្ចប់ការសិក្សាសមិទ្ធិលទ្ធភាព និងកំពុងស្ថិតក្នុងដំណាក់កាលពិភាក្សាលើតម្លៃនៃគម្រោង និងប្រភពថវិកា<br>▪ គម្រោងសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-ប៉ោយប៉ែត-សៀមរាប ជាគម្រោងអាទិភាពក្នុងផែនការរយៈពេលខ្លីនៃការអភិវឌ្ឍផ្លូវល្បឿនលឿននៅកម្ពុជា បាននិងកំពុងពិភាក្សា<br>▪ ក្រសួងសាធារណការ និងដឹកជញ្ជូនកម្ពុជា និងក្រសួងដឹកជញ្ជូនវៀតណាម បានចុះអនុស្សារណៈយោគយល់គ្នា ស្តីពីជំរុញការសិក្សា និងសាងសង់ | ▪ កត្តាប្រែប្រួលអាកាសធាតុដែលធ្វើឱ្យរាំងស្ទះដល់ដំណើរការអនុវត្តគម្រោងមួយចំនួន<br>▪ ការទម្លាក់ថវិកាមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅមានភាពរអាក់រអួល<br>▪ ការកើនឡើងនូវតម្រូវការប្រើប្រាស់ផ្លូវជនបទយ៉ាងច្រើន ដោយសារការរីកលូតលាស់មុខជំនួញ អាជីវកម្ម និងកសិកម្មរបស់ប្រជាជនជនបទធ្វើឱ្យមានការកើនឡើងឡជីស្ទីកនៅតំបន់ជនបទ<br>▪ អាជីវកររកស៊ីដឹកទំនិញ ឬឈ្មួញកណ្តាលបានដឹកទំនិញលើសទម្ងន់កំណត់ដែលបណ្តាលឱ្យផ្លូវជនបទមួយចំណែកត្រូវខូចខាតវិញ មុនការកំណត់សុពលភាព |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ផ្លូវល្បឿនលឿន ភ្នំពេញ-បាវិត និងពីហូជីមិញ-ម៉ុកបៃ<br>▪ ត្រៀមអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងខាងត្បូង ផ្តោតលើការអភិវឌ្ឍក្រុង ចំនួនបួន (កែលម្អហេដ្ឋារចនាសម្ព័ន្ធក្រុង÷ ក្រុងប៉ោយប៉ែត ក្រុងបាត់ដំបង ក្រុងបាវិត និងទីប្រជុំជនអ្នកលឿង) រួមមានការសាងសង់ប្រព័ន្ធលូចម្រោះទឹកសំណល់ និងទីលានកែច្នៃសំរាម សាងសង់ផ្លូវក្រុង ប្រព័ន្ធការពារទឹកជំនន់ និងទប់ច្រាំងបាក់។ ដោយឡែក ក្រសួងបានចុះហត្ថលេខាអនុវត្តគម្រោងសាងសង់សម្រាប់អនុគម្រោងក្រុងបាត់ដំបង រួចរាល់ហើយ។<br>▪ ត្រៀមអនុវត្តគម្រោងអភិវឌ្ឍន៍ក្រុងរបៀង២ផ្តោតការអភិវឌ្ឍក្រុងចំនួនពីរតាមតំបន់ឆ្នេរតី ក្រុងកំពត និងក្រុងព្រះសីហនុ (សាងសង់ប្រព័ន្ធលូចម្រោះទឹកសំណល់ និងទីលានកប់សំរាម) គ្រោងអនុវត្តការងារសាងសង់នៅដើមឆ្នាំ២០១៩<br>▪ ភ្នាក់ងារនាវាចរណ៍ "កាំសាប" បាននិងកំពុងសហការជាមួយក្រុមការងារ JICA ក្នុងការបង្កើតប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិកនៅកំពង់ផែ (PortEDI) ដែលជាប្រព័ន្ធ Ship Clearance Online ដើម្បីរួមចំណែកកាត់បន្ថយចំណាយមិន | ▪ ទឹកជំនន់ ឬភ្លៀងខ្លាំងជាប់គ្នាយូរថ្ងៃហូរច្រោះផ្លូវដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។<br>- រដ្ឋបាលខេត្តកណ្តាល÷ ដោះស្រាយផលប៉ះពាល់តាមបណ្តាគម្រោង។ |

| | វិធានការដាក់ស្នើងបូន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ប្រក្រតី ៤៨% ជាអតិបរមា កាត់បន្ថយពេលវេលា និងការបំពេញឯកសារបែបបទរបស់នាវាដោយដៃ<br>▪ បានបញ្ចុះតម្លៃចំនួន ២០% លើសេវាកត់ត្រាកុងតឺន័រលើសម៉ោង (Tally Free-Overtime) និងតម្លៃសេវាត្រួតពិនិត្យកុងតឺន័រនៅពេលលើកដាក់នៅនាវា (Superintendence Fee) ជូនអតិថិជន រួចហើយបានបញ្ចុះតម្លៃបន្ថែមលើសេវាទាំងពីរនេះចំនួន៣០%ទៀតចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៨ ដើម្បីរួមចំណែកកាត់បន្ថយតម្លៃភស្តុភារកម្ម។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានចូលរួមបញ្ចប់ការរៀបចំផែនការមេអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងឡូជិស្ទីកជាមួយក្រុមហ៊ុន Henan Provincial Communication Planning របស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន<br>▪ កិច្ចសន្យាគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុជាមួយក្រុមហ៊ុន រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន Road and Bridge Corporation (CRBC) ត្រូវបានចុះហត្ថលេខា<br>▪ បានសហការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើងកំណាត់ផ្លូវជាតិលេខ៥ (North Section) ហិរញ្ញប្បទានដោយ JICA កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១៧ ដោយសាងសង់ផ្លូវប្រវែង ៨៤,៧៤គ.ម | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ជាផ្លូវ ៤គន្លង ក្រាលកៅស៊ូ A/C កម្រាស់ ១៥ ស.ម ក្នុងនោះ ផ្លូវពីក្រុងបាត់ដំបង ដល់ក្រុងសិរីសោភ័ណប្រវែង ៥១,៤៨គ.ម និងសាងសង់ផ្លូវវាងថ្មី ២ខ្សែ គឺផ្លូវវាងក្រុងបាត់ដំបងប្រវែង ២៣,៩២គ.ម និងផ្លូវវាងក្រុងសេរីសោភ័ណ ប្រវែង ៩,៣៤គ.ម<br>▪ បានសហការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើង កំណាត់ផ្លូវជាតិលេខ៥ (Middle Section) ហិរញ្ញប្បទានដោយ JICA ដោយសាងសង់កំណាត់ផ្លូវជាតិលេខ៥÷ ពីចំណុចថ្លាម្អម ស្រុកក្រគរ ខេត្តពោធិ៍សាត់-ក្រុងបាត់ដំបង ប្រវែង ១០៤ គ.ម និងផ្លូវវាងក្រុងពោធិ៍សាត់ ប្រវែង ៩គ.ម និងពីក្រុងសិរីសោភ័ណ-ក្រុងប៉ោយប៉ែត ប្រវែង ៣៦គ.ម ទាំងផ្លូវមេ និងផ្លូវវាងសរុបប្រវែង ១៤៩ គ.ម ដោយសាងសង់ជាផ្លូវ ៤គន្លង និងក្រាលកៅស៊ូ A/C កម្រាស់ ១៥ ស.ម<br>▪ បានវិភាជថវិកា ៣០.០៩៣លានរៀល សម្រាប់គម្រោងស្ពានផ្លូវលេខ១៥៧៧ បំបែកពីផ្លូវជាតិលេខ៥៧ ត្រង់សេកសក-សំឡូត-ច្រក៤០០ ព្រំដែនកម្ពុជា-ថៃ<br>▪ បានវិភាជថវិកា ៣៤.៨៣០លានរៀល សម្រាប់គម្រោងរៀបចំច្រកទ្វារអន្តរជាតិស្ទឹងបត់ និងផ្លូវតភ្ជាប់ផ្លូវជាតិលេខ៥ | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានវិភាជថវិកា ៧៣.១៥៣លានរៀល សម្រាប់គម្រោងសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គ (ស្ទឹងត្រង់-ក្រូចឆ្មារ)<br>▪ បានវិភាជថវិកា ៦៩.៦៦០លានរៀល សម្រាប់គម្រោងធ្វើឱ្យប្រសើរឡើងនូវកំណាត់ផ្លូវជាតិលេខ៥ ពីថ្លាម្អមទៅបាត់ដំបង និងពីសិរីសោភ័ណទៅប៉ោយប៉ែត<br>▪ បានវិភាជថវិកា ១៣៥.៧៨៥លានរៀល សម្រាប់គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀង (ក្រុងបាវិត ក្រុងស្វាយរៀង ក្រុងបាត់ដំបង និងក្រុងប៉ោយ-ប៉ែត)<br>▪ បានវិភាជថវិកា ២៦.២១៣លានរៀល សម្រាប់គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀង (ខេត្តកំពត និងខេត្តព្រះសីហនុ)<br>▪ បានវិភាជថវិកា ៣៧.២០៩លានរៀល សម្រាប់គម្រោងអភិវឌ្ឍន៍ចំណតផែពហុបំណង, កំពង់ផែក្រុងព្រះសីហនុ<br>▪ បានវិភាជថវិកា ៨៧.០៧៥លានរៀល សម្រាប់គម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មីកំពង់ផែស្វយ័តក្រុងព្រះសីហនុ<br>▪ ៧បានវិភាជថវិកា ៥៥.៧២៧លានរៀល សម្រាប់ជួសជុលផ្លូវជាតិលេខ ៤ និងផ្លូវជាតិលេខ ៤៨ | |

| | វិធានការជាក់ស្តែងប្អូន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានវិភាជថវិកា ៥២.២៤៥លានរៀល សម្រាប់គម្រោងអភិវឌ្ឍន៍ផ្លូវពីសំឡូត-វាលវែង និងទៅដល់កោះកុង<br>▪ ៣បានវិភាជថវិកា ២០លានដុល្លារអាមេរិក សម្រាប់ការស្តារឡើងវិញប្រព័ន្ធផ្លូវដែកភាគខាងជើង (ភ្នំពេញ-ប៉ោយប៉ែត)<br>▪ បានរៀបចំសិក្ខាសាលាស្តីពីវិស័យដឹកជញ្ជូន និងឡូជីស្ទីក ដោយផ្សារភ្ជាប់នឹងថវិកាជាតិសម្រាប់ឆ្នាំ ២០១៨ និងបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងផែនការមេឡូជីស្ទីក<br>▪ បានដាក់ឱ្យដំណើរការបន្ថែម (១) តំបន់សេដ្ឋកិច្ចពិសេស និងភណ្ឌាគារគយមានដែនកំណត់ Kerry Worldbridge Logistics នៅភ្នំពេញ និង (២) សន្និធិគយបណ្តោះអាសន្ន-ផែស្ងួត ៦ ថ្មីទៀត នៅត្រពាំងផ្លុង (Lim Bunna Dry Port), នៅបាវិត (Teeco Dry Port), នៅប៉ោយប៉ែត (Cambodian Diamond Transport), នៅម៉ាឡៃ និងភ្នំដី (Ly Kea Dry Port) និងនៅកែវផុស (Oknha Mong Port)<br>▪ បានលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងប្រតិបត្តិការម៉ាស៊ីនស្លែននៅទូទាំងប្រទេស តាមរយៈ (១) បានដាក់ឱ្យអនុវត្តមុខងារគ្រប់គ្រងលទ្ធផលស្កែនដោយមធ្យោបាយអេឡិកត្រូនិក, (២) បានបណ្តុះ- | |

| | វិធានការជាក់ស្តែងបន្ទាន់ | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | បណ្តាលមន្ត្រីទទួលបន្ទុកការងារម៉ាស៊ីនស្កេន៤៤ រូប, និង (៣) បានចាត់វិធានការពង្រឹងប្រសិទ្ធភាពការអនុវត្តការងាររបស់មន្ត្រីទទួលបន្ទុកការងារស្កេន<br>▪ បានឯកភាពជាមួយសភាពាណិជ្ជកម្មកម្ពុជា អនុញ្ញាតឱ្យប្រើប្រាស់មធ្យោបាយដឹកជញ្ជូនជារថយន្តដែលមានលក្ខណៈសម្បត្តិជាកុងតែន័រ សម្រាប់ដឹកជញ្ជូនទំនិញនាំចេញក្រោមរបបគយឆ្លងកាត់<br>▪ បានបង្កើតមុខងារប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីតាមដាន ការប្រើប្រាស់បណ្ណសម្គាល់យានយន្តដឹកជញ្ជូនឆ្លងកាត់ដើម្បីនាំចេញរបស់វិនិយោគិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់<br>▪ បានទទួលសំណើ និងកំពុងពិនិត្យសំណើសុំបង្កើតភណ្ឌាគារគយមានដែនកំណត់ និងសន្និធិគយបណ្តោះអាសន្នចំនួន ០៧ បន្ថែមទៀត<br>▪ បានដំឡើង និងកំពុងសាកល្បងប្រព័ន្ធបញ្ជូនរូបភាពស្កេន (Centralized Image Supervision) ចំនួន ០៤គ្រឿង ពីអង្គភាពគយពាក់ព័ន្ធចំនួន០៣កន្លែង មកកាន់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីពង្រឹងអនុលោមភាពនៃការត្រួតពិនិត្យទំនិញ<br>▪ បានដាក់ឱ្យអនុវត្តនូវអង្គភាព÷(១) ការិយាល័យអង្គភាពត្រួតពិនិត្យទំនិញតាមផ្លូវអាកាស (Air | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | Cargo Control Unit- ACCU) នៅសាខាគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ និង (២) ការិយាល័យអង្គភាពត្រួតពិនិត្យកុងទែន័រ (Container Control Unit-CCU) នៅសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីគយក្នុងការត្រួតពិនិត្យទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន គ្រឿងញៀន សារធាតុផ្សំ គ្រឿងញៀន និងសារធាតុវិទ្យុសកម្មជាដើម។<br>- ក្រសួងពាណិជ្ជកម្ម បានទទួលជំនួយពីមិត្តជប៉ុន ក្នុងការកសាងស្ថានីយចំណតរថយន្តនៅខេត្តកំពង់ឆ្នាំង និងបានដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការ កាលពីថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៨ ក្រោមអធិបតីភាពឯកឧត្តម ឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ក្នុងឆ្នាំ២០១៦÷<br>▪ បានត្រៀមផ្តល់ធាតុចូល និងចូលរួមកិច្ចប្រជុំអន្តរក្រសួងពាក់ព័ន្ធនឹងការកសាងផ្លូវល្បឿនលឿន ភ្នំពេញ- បាវិត និងភ្នំពេញ- ព្រះសីហនុ<br>▪ បានដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាការងារពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ដោយផ្តោតសំខាន់លើប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម<br>▪ បានចូលរួមពិនិត្យ ពិភាក្សា និងផ្តល់យោបល់ក្នុងកិច្ចប្រជុំមួយចំនួនពាក់ព័ន្ធការអភិវឌ្ឍវិស័យដឹកជញ្ជូន និងភស្តុភារកម្ម ដូចជា÷ (១) កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងរបាយការណ៍បញ្ចប់ស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធភស្តុភារកម្ម, (២) កិច្ចប្រជុំជាមួយ JICA ដើម្បីពិភាក្សាអំពីការសិក្សាលើប្រព័ន្ធភស្តុភារកម្មនៅកម្ពុជា, (៣) កិច្ចប្រជុំអនុក្រុមការងារបច្ចេកទេសដឹកជញ្ជូនផ្លូវគោក, (៤) កិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងរបាយការណ៍សិក្សាស្តីពីការសម្របសម្រួលសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ដែលត្រូវបានសហការរៀបចំដោយអង្គការ USAID និងក្រសួងពាណិជ្ជកម្ម ក្នុងគោលបំណងជំរុញការអនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម របស់អង្គការពាណិជ្ជកម្មពិភពលោក, (៥) កិច្ចប្រជុំអន្តរក្រសួងពាក់ព័ន្ធនឹងការពិភាក្សាលើកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនក្នុងក្របខ័ណ្ឌមហាអនុតំបន់មេគង្គ និងក្នុងក្របខ័ណ្ឌទ្វេភាគី, (៦) កិច្ចប្រជុំគណៈកម្មការចម្រុះអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសនៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ លើគម្រោងបើក | |

| | វិធានការជាក់ស្ដែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ច្រកអន្តរជាតិថ្មីនៅខេត្តបន្ទាយមានជ័យ និងខេត្តស្រះកែវ (ច្រកស្ទឹងបត់-ណាងអៀន) ដើម្បីដោះស្រាយបញ្ហាកកស្ទះនូវរថយន្តដឹកទំនិញ, (៧) កិច្ចប្រជុំអន្តរក្រសួងលើគម្រោងសាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-បាវិត និងគម្រោងសាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ, និង (៨) កិច្ចសន្ទនាគោលនយោបាយស្ដីពីភស្តុ-ភារកម្ម និងសិក្ខាសាលាស្ដីពីភស្តុភារកម្ម ដែលសហការរៀបចំដោយក្រសួងសាធារណការ និងដឹកជញ្ជូន ជាមួយក្រសួងដែនដី ហេដ្ឋារចនា-សម្ព័ន្ធដឹកជញ្ជូន និងទេសចរណ៍នៃប្រទេសជប៉ុន ក្រោមក្របខ័ណ្ឌនៃ“ភាពជាដៃគូដឹកជញ្ជូនអាស៊ាន-ជប៉ុន” ក្នុងគោលបំណងពិនិត្យលើស្ថានភាពភស្តុភារកម្មនៅកម្ពុជា និងក្របខ័ណ្ឌនៃការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន ព្រមទាំងលើកឡើងពីសំណូមពររបស់ភាគីជប៉ុនក្នុងការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារកម្មនៅកម្ពុជា។<br>ក្នុងឆ្នាំ២០១៧÷<br>▪ បានបន្តចូលរួមកិច្ចប្រជុំអន្តរក្រសួង ពាក់ព័ន្ធនឹងការកសាងផ្លូវល្បឿនលឿនភ្នំពេញ-បាវិត និងភ្នំពេញ-ព្រះសីហនុ | |

| | វិធានការជាក់ស្ដែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានចូលរួមប្រជុំពិភាក្សា និងផ្ដល់ធាតុចូលជាច្រើនករណី ពាក់ព័ន្ធនឹងការបង្កើតក្រុមប្រឹក្សាជាតិភស្តុភារកម្ម និងការរៀបចំផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងឡូជិស្ទីក<br>▪ បានចូលរួមជាសមាជិកនៃក្រុមប្រឹក្សាជាតិភស្តុ-ភារកម្ម និងជាអនុប្រធានគណៈកម្មការជាតិភស្តុ-ភារកម្ម<br>▪ បានបន្តធ្វើបច្ចុប្បន្នភាពជំនួយស្មារតីស្តីពីការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងឡូជិស្ទីក។<br>ក្នុងឆ្នាំ២០១៨÷<br>▪ បាននិងកំពុងធ្វើការស្រាវជ្រាវលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ, ទូរគមនាគមន៍, ប្រព័ន្ធដឹកជញ្ជូន និងឡូជិស្ទីក ដើម្បីជាមូលដ្ឋានក្នុងការពិភាក្សា និងការផ្ដល់កិច្ចសម្របសម្រួលដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ, ប្រព័ន្ធដឹកជញ្ជូន និងឡូជិស្ទីកក្នុងប្រទេសកម្ពុជា<br>▪ បានចូលរួមប្រជុំពិភាក្សា និងផ្ដល់ធាតុចូលជាច្រើនករណី ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងគោលបំណងកាត់បន្ថយរយៈពេល និងថ្លៃដឹកជញ្ជូន ដើម្បីបង្កើនភាពប្រកួតប្រជែងក្នុងវិស័យវិនិយោគក្នុងប្រទេសកម្ពុជា | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានអនុញ្ញាតឱ្យក្រុមហ៊ុនមួយចំនួនវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ក្នុងនោះ Cambodian PPSHV Expressway Co., Ltd. វិនិយោគលើគម្រោងសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុក្នុងទុនវិនិយោគ ១.៨៧០ លានដុល្លារអាមេរិក។<br>- ទីស្តីការគណៈរដ្ឋមន្ត្រី បានចូលរួមប្រជុំការងារពាក់ព័ន្ធនឹងវិធានការនេះផងដែរ ដើម្បីជំរុញការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក។<br>- ក្រសួងអភិវឌ្ឍន៍ជនបទ÷<br>▪ បានសាងសង់ផ្លូវជនបទថ្មីសរុបចំនួនសរុប ៦៧ គម្រោង ប្រវែងសរុប ៤៦១,៩៣គ.ម ហើយសម្រេចលទ្ធផលបាន ១០០% ក្នុងនោះ រួមមាន ÷ ផ្លូវកៅស៊ូប្រវែង ៧៨,២០គ.ម, ផ្លូវបេតុងប្រវែង ១១,៥៣គ.ម, ផ្លូវក្រាលក្រួសក្រហមប្រវែង ៣៧២,២០គ.ម, ស្ពានបេតុង ២០កន្លែង, ប្រវែង ៤៣៨ម, លូប្រអប់ ៤០កន្លែង និងលូមូល ២៣៦ កន្លែង<br>▪ បានសហការជាមួយដៃគូអភិវឌ្ឍន៍ បានស្ថាបនាផ្លូវជនបទក្រាលក្រួសក្រហមថ្មីសរុបបានប្រវែង ៣៩០,៤៦គ.ម, ផ្លូវក្រាលកៅស៊ូពីរជាន់សរុប ១៦៥,៦គ.ម និងផ្លូវចាក់បេតុងសរុបប្រវែង | |

| | វិធានការជាក់ស្ដែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ៦,៧៤គ.ម, ស្ពានបេតុង ៣១កន្លែង ប្រវែង ១ ៥១៦ម, សំណង់សិល្បការ្យ (លូប្រអប់ និងលូមូល) សរុបចំនួន ៧០៧កន្លែង និងបានជួសជុលថែទាំផ្លូវជនបទមានលក្ខណៈខួប និងប្រចាំទាំងបីប្រភេទបានចំនួន ២២២ខ្សែ បានប្រវែងសរុប ២ ០៥៨,០៨គ.ម ក្នុងនោះ ផ្លូវក្រួសក្រហម ១ ០១៣,៦១គ.ម, ផ្លូវក្រាលកៅស៊ូ ៥៥៣,៩៨គ.ម និងផ្លូវចាក់បេតុង ១៥,៨០គ.ម, បានសាងសង់ទំនប់បង្ហៀរ ០៣កន្លែង, ស្ពារប្រឡាយទឹកខ្នាតតូចបាន ០៦ខ្សែប្រវែង ១២,៥គ.ម, បានជួសជុលផ្លូវស្ដារឡើងវិញជាបន្ទាន់បានប្រវែង ២៦៧,៩៥គ.ម, លូមូល ២៦កន្លែង, លូប្រអប់ ០១កន្លែង និងស្ពាន ០១កន្លែង និងបានចុះស្រង់ទិន្នន័យខ្សែផ្លូវជនបទប្រចាំឆ្នាំបានចំនួន ៣០២ខ្សែ ស្មើនឹង ៧០៣គ.ម និងធ្វើបច្ចុប្បន្នភាពខ្សែផ្លូវឡើងវិញបាន ៣១៦ខ្សែ ប្រវែង ២ ៤០០,៣៥គ.ម។<br>- រដ្ឋបាលរាជធានីភ្នំពេញ ដោយមានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ ជាសេនាធិការបានដាក់ចេញនូវសកម្មភាព និងទិសដៅអនុវត្តការងារ ដោយអនុវត្តតាមផែនការមេដឹកជញ្ជូនរាជធានីភ្នំពេញឆ្នាំ ២០៣៥ បានដាក់ចេញនូវផែនការលើវិស័យនៃការដឹកជញ្ជូនទំនិញដូចខាងក្រោម÷ | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងទឡ្ហនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ សំណង់បរិក្ខារដឹកជញ្ជូនទំនិញអន្តរតំបន់នៅក្នុងតំបន់គម្រោងមានដូចជា កំពង់ផែរាជធានីភ្នំពេញថ្មី ព្រលានយន្តហោះអន្តរជាតិ ស្ថានីយដឹកជញ្ជូនទំនិញតាមផ្លូវដែកដែលបានគ្រោងទុក តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងតំបន់ឧស្សាហកម្មដែលមានស្រាប់ និងគ្រោងទុកផ្សេងទៀត។ ជាមួយនឹងមជ្ឈមណ្ឌល និងអនុមជ្ឈមណ្ឌលឧស្សាហកម្មដែលបានស្នើឡើង និងតាមរយៈទស្សនៈរចនាសម្ព័ន្ធទីក្រុងមុខងាររបស់បរិក្ខារដឹកជញ្ជូន ត្រូវបានរំពឹងថានឹងត្រូវបានរួមបញ្ចូលឧទាហរណ៍÷ ដើម្បីដោះស្រាយការផ្ទេរទំនិញក្នុងបរិមាណដ៏ច្រើន និងចេញ/ចូលខាងក្រៅរាជធានីភ្នំពេញ និងទំនិញបរិមាណតិចចេញ/ចូល ក្នុងទីក្រុងភ្នំពេញ។<br>▪ យោងតាមកំពង់ផែស្វយ័តភ្នំពេញ (PPAP) កំពង់ផែរាជធានីភ្នំពេញដែលមានស្រាប់នឹងនៅតែមានមុខងារជាកំពង់ផែដឹកទំនិញ។ ទោះជាយ៉ាងណាក៏ដោយ តាមទស្សនៈនៃការដឹកជញ្ជូននៅតាមទីក្រុង និងបរិស្ថាន នៅកណ្តាលទីក្រុង មិនគួរមានផែដឹកទំនិញមួយដែលបង្កើតចរាចរណ៍រថយន្តដឹកទំនិញធុនធ្ងន់ដ៏ច្រើនសន្ធឹកសន្ធាប់ទេ។ | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ ផ្លូវជាតិលេខ១ លេខ៦ និងផ្លូវក្រវាត់ក្រុងទី៣ RRIII នឹងត្រូវប្រើជាខ្សែផ្លូវដឹកជញ្ជូនទំនិញអន្តរតំបន់ដែលតភ្ជាប់កន្លែងដឹកជញ្ជូនទំនិញសំខាន់ៗ ហើយផ្លូវទាំងនេះត្រូវបានយើងរំពឹងថានឹងត្រូវបានកែលម្អទៅជាផ្លូវដឹកជញ្ជូន សម្រាប់រថយន្តដឹកទំនិញដ៏សមស្រប ឧទាហរណ៍÷ ដូចជាផ្លូវដែលមានពីរគន្លង តាមទិសនីមួយៗ ឬផ្លូវដែលមានចិញ្ចើមផ្លូវគ្រប់គ្រាន់<br>▪ ពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងការប្រើប្រាស់ដីធ្លីនៅតាមបណ្តោយខ្សែផ្លូវរថយន្តដឹកជញ្ជូនទំនិញ ដើម្បីជៀសវាងការលាយឡំនៃការធ្វើចរាចរណ៍រថយន្តដឹកទំនិញជាមួយនឹងចរាចរណ៍ប្រចាំថ្ងៃផ្សេងៗទៀត<br>▪ តំបន់ដាក់កំហិតចំពោះរថយន្តដឹកទំនិញ ត្រូវបានរំពឹងថានឹងត្រូវបានពង្រីកនៅក្នុងពេលអនាគត ដោយអនុលោមតាមការពង្រីកតំបន់នគរូបនីយ-កម្មនាពេលអនាគត។ ឧទាហរណ៍÷ សម្រាប់តំបន់ដាក់កំហិតនឹងត្រូវបានពង្រីកទៅដល់ផ្លូវក្រវាត់ក្រុងទី៣ (RRIII) អំឡុងពេលពីម៉ោង ៥:០០ ដល់ម៉ោង ២១:០០ រាល់ថ្ងៃធ្វើការ ដូចលក្ខខណ្ឌដែលមានស្រាប់។ | |

| | វិធានការដាក់ស្តែងចេញ | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ ការពង្រឹងស្ថាប័នដែលមានស្រាប់សម្រាប់ការថែទាំផ្លូវនេះ ដើម្បីថែរក្សាស្ថានភាពផ្លូវដែលល្អសម្រាប់ផ្លូវរថយន្តដឹកជញ្ជូនទំនិញ។<br>- រដ្ឋបាលខេត្តកណ្ដាល បានចូលរួមសហការជាមួយមន្ទីរសាធារណការនិងដឹកជញ្ជូន ក្នុងការជំរុញការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅឆ្នាំខាងមុខ ដូចជាផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ និងភ្នំពេញ-បាវិត, ផ្លូវជាតិលេខ៥ កណ្ដាល-ប៉ោយប៉ែត, ខ្សែក្រវ៉ាត់ក្រុងទី៣ ភ្នំពេញ-កណ្ដាល និងខ្សែក្រវ៉ាត់ក្រុងទី៤ ភ្នំពេញ-កណ្ដាល។<br>- រដ្ឋបាលខេត្តព្រះសីហនុ÷<br>▪ បានចូលរួមសហការជាមួយស្ថាប័នពាក់ព័ន្ធ ជាច្រើនលើកទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងជួយសម្របសម្រួលដោះស្រាយផលប៉ះពាល់ក្នុងកិច្ចការកសាងផ្លូវល្បឿនលឿនភ្ជាប់ពីខេត្តព្រះសីហនុ ទៅរាជធានីភ្នំពេញ<br>▪ បានដាក់ផែនការធ្វើការជួសជុលផ្លូវនៅក្នុងខេត្តសរុបចំនួន២២ខ្សែ ក្នុងនោះ១២ខ្សែ ត្រូវបានចាប់ផ្តើមធ្វើការជួសជុលនៅក្នុងឆ្នាំ២០១៨<br>▪ បានរៀបចំស្ថានីយបូមទឹកកខ្វក់បានចំនួន៤ទីតាំង ដើម្បីទប់ស្កាត់មិនឱ្យទឹកកខ្វក់ហូរចូលសមុទ្រ។ | |

| | **ទិសដៅការងារអាទិភាព** | **សូចនាករ** | **ឆ្នាំគោលដៅ** | **ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងចូលរួមអនុវត្ត** | **ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)** |
|---|---|---|---|---|---|
| ទី៣ | ពង្រឹង និងបន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្ម និងការបណ្ដុះបណ្ដាលជំនាញ ដើម្បីរក្សាស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្ម លើកកម្ពស់ផលិតភាព និងកែលម្អកម្រិតជីវភាពរបស់ពលករ តាមរយៈការជំរុញការអភិវឌ្ឍកម្មវិធីបណ្ដុះបណ្ដាល ជំនាញ ការពង្រឹងយន្តការកំណត់ប្រាក់បៀវត្សអប្បបរមា និងការពង្រឹងសុខដុមភាពនៃទំនាក់ទំនងវិជ្ជាជីវៈ ឈរលើគោលការណ៍ត្រីភាគីរវាងរដ្ឋាភិបាល និងរបស់សហជីព និងព្រហ្មវិហារធម៌របស់និយោជក ចំពោះនិយោជិត ដោយប្រើប្រាស់យន្តការមានស្រាប់ ជាអាទិ៍យន្តការ *"គណៈកម្មការប្រឹក្សា* | - *ថ្លៃឈ្នួលអប្បបរមា ដែលធានាបាននូវកម្រិតជីវភាពរស់នៅសមស្រប ភាពប្រកួតប្រជែង និងពិពិធកម្មនៃសេដ្ឋកិច្ច-ឧស្សាហកម្មកម្ពុជា*<br>- *កែលម្អស្ថិរភាពទីផ្សារពលកម្ម និងកាត់បន្ថយចំនួនវិវាទការងារ*<br>- *លក្ខខណ្ឌការងារ និងជីវភាពកម្មករប្រសើរឡើង*<br>- *ផែនការមេសម្រាប់ការពង្រីក និងទំនើបកម្មប្រព័ន្ធបណ្ដុះបណ្ដាលបច្ចេកទេស និងជំនាញ*<br>- *កម្មវិធី និងគម្រោងវិនិយោគសម្រាប់ការបណ្ដុះបណ្ដាលបច្ចេកទេស និងជំនាញ ដែលមានការសម្របសម្រួលលក្ខណៈជាប្រព័ន្ធឆ្លើយតបនឹងតម្រូវការឧស្សាហកម្ម។* | ២០១៨ | - ដើម្បីពង្រឹងសមត្ថភាព ផលិតភាព ឥរិយាបទការងារ មនះសិការការងារ និងសីលធម៌ វិជ្ជាជីវៈខ្ពស់របស់កម្មករនិយោជិត ក៏ដូចជាពង្រឹងភាពសុខដុមរមនានៃទំនាក់-ទំនងវិជ្ជាជីវៈ សំដៅរួមចំណែកក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម, ទ្រទ្រង់កំណើនសេដ្ឋកិច្ច, រក្សានិងបង្កើតការងារ, បង្កើនជីវភាពរស់នៅ និងលក្ខខណ្ឌការងាររបស់ប្រជាពលរដ្ឋនោះ ក្រសួងការងារ និងបណ្ដុះ-បណ្ដាលវិជ្ជាជីវៈ÷<br>▪ បានរៀបចំកម្មវិធីសំណេះសំណាលរបស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ជាមួយបងប្អូនកម្មករនិយោជិតរោងចក្រ នៅទូទាំងប្រទេស ដោយក្នុងឆ្នាំ២០១៧ បានចំនួន ២៦លើក ស្មើនឹង ២៨០ ៣៥៥នាក់ និងឆ្នាំ២០១៨ បានចំនួន ៣៥លើក ស្មើនឹង ៥៩៦ ១១៩នាក់។ តាមរយៈកម្មវិធីសំណេះសំណាល **សម្ដេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញវិធានការគន្លឹះមួយចំនួនដូចជា÷<br>**១.** រួមគ្នារក្សាសន្តិភាព, ស្ថិរភាពនយោបាយ និងសន្តិសុខសណ្ដាប់ធ្នាប់សង្គម<br>**២.** បន្តទាក់ទាញវិនិយោគ និងពង្រីកទីផ្សារនាំចេញសំដៅបង្កើតការងារថ្មី និងបង្កើនគុណភាពការងារដែលមានស្រាប់ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷<br>*បញ្ហាប្រឈម÷*<br>▪ កង្វះធនធានថវិកា និងធនធានមនុស្សជាគ្រូបង្ហាត់<br>▪ កង្វះរចនាសម្ព័ន្ធគ្រប់គ្រងដែលអាចផ្ដល់ទំនុកចិត្ត និងការចូលរួមរបស់វិស័យឯកជន<br>▪ ខ្វះមូលធនមនុស្ស<br>▪ ខ្វះវប្បធម៌វិទ្យាសាស្ត្រ និងគំរូអភិបាលកិច្ចសាជីវកម្មនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជន ដែលធ្វើឱ្យមានការរាំងស្ទះដល់ការអនុវត្ត IDP<br>▪ សមត្ថភាពស្រូបយកចំណេះដឹងរបស់សហគ្រាសធុនតូច និងមធ្យម នៅមានកម្រិត ដែលធ្វើឱ្យការអនុវត្តគោលនយោបាយ IDP មិនប្រទាក់ក្រឡាគ្នា |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | *ការងារ" និង "គណៈកម្មា-ធិការផលិតភាពកម្ពុជា"* ។ | | | ៣. បន្តខិតខំបណ្តុះបណ្តាល បង្កើនសមត្ថភាព និងចំណេះដឹងរបស់កម្មករនិយោជិត ដើម្បីលើកកម្ពស់ផលិតភាពការងារ<br>៤. រួមគ្នាបង្កើនប្រាក់ចំណូលរបស់កម្មករនិយោជិត តាមរយៈការប្រើប្រាស់យន្តការត្រីភាគីក្នុងការចរចាដំឡើងប្រាក់ឈ្នួលអប្បបរមាទៅតាមកាលវិភាគ និងលក្ខណៈវិនិច្ឆ័យ ដែលបានកំណត់ជារៀងរាល់ឆ្នាំ<br>៥. កាត់បន្ថយចំណាយរបស់កម្មករនិយោជិត ដោយពង្រីកការតបណ្តាញអគ្គិសនី និងទឹកស្អាតដែលមានតម្លៃទាបនៅតាមផ្ទះជួល, ផ្តល់ការធ្វើដំណើរតាមរថយន្តក្រុងរបស់រដ្ឋដោយមិនបង់ថ្លៃ, ដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សជាប់ពន្ធដល់ ១ ២០០០ ០០០ រៀល ចាប់ពីឆ្នាំ២០១៨, បន្តលើកលែងពន្ធលើប្រាក់អត្ថប្រយោជន៍បន្ថែមនានា, ផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មការិនីដែលសម្រាលកូនបាន ១ នាក់ បានថវិកា ៤០០ ០០០រៀល កូនភ្លោះពីរនាក់ បានថវិកា ៨០០ ០០០រៀល កូនភ្លោះបីនាក់ បានថវិកា ១ ២០០ ០០០រៀល<br>៦. ពង្រឹងការអនុវត្តរបបសន្តិសុខសង្គម ដោយបន្តពង្រីកគុណភាព និងសេវាឆ្លើយតបនៃការ | ▪ ការចែករំលែកព័ត៌មាន និងទិន្នន័យរវាងអន្តរក្រសួង-ស្ថាប័ននៅពុំទាន់រលូន<br>▪ ភ្នាក់ងារអន្តរក្រសួង-ស្ថាប័ន មិនមានជំនាញឯកទេសគ្រប់គ្រាន់ លើសេដ្ឋកិច្ចឧស្សាហកម្មសេដ្ឋកិច្ចពលកម្ម និងសេដ្ឋកិច្ចសង្គម<br>▪ ភ្នាក់ងារអន្តរក្រសួង-ស្ថាប័នត្រូវការចំណេះដឹងវិទ្យាសាស្ត្រ (scientific knowledge) និងវិទ្យាសាស្ត្រនយោបាយ (policy sciences) បន្ថែមដើម្បីឆ្លើយតបនិងវាស់វែងទៅលើគោលនយោបាយម៉ាក្រូ និងមីក្រូសេដ្ឋកិច្ច ព្រមទាំងគោលនយោបាយសេដ្ឋកិច្ចឧស្សាហកម្ម<br>▪ មិនមានយន្តការរួម ដែលច្បាស់លាស់ សម្រាប់តាម |

| | វិធានការដាក់ស្នើងបូន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | អនុវត្តផ្នែកហានិភ័យការងារ និងដាក់ឱ្យដំណើរការផ្នែកថែទាំសុខភាព នៅឆ្នាំ២០១៧ និងបានតម្រូវឱ្យនិយោជកបង់ប្រាក់ភាគទានផ្នែកថែទាំសុខភាព ១០០% ជំនួសកម្មករនិយោជិត ចាប់ពីខែមករា ឆ្នាំ២០១៨ និងបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលមានវិសាលភាពកាន់តែទូលំទូលាយ ធានាសង្គតិភាព និងសមធម៌រវាងមន្ត្រីរាជការសាធារណៈ និងកម្មករនិយោជិត<br>**៧.** បន្តលើកកម្ពស់លក្ខខណ្ឌការងារ សុវត្ថិភាព និងសុខភាពការងារ ដោយច្របាច់បញ្ចូលគ្នាក្រុមអធិការកិច្ចការងារច្រើនក្រុម ឱ្យទៅជាក្រុមអធិការកិច្ចការងារតែមួយ របស់ក្រសួង និងធ្វើទំនើបកម្មប្រព័ន្ធអធិការកិច្ចការងារ ប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា និងចុះអធិការកិច្ចដោយផ្តោតចំណាត់ថ្នាក់នៃកម្រិតហានិភ័យរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាននីមួយៗ ជាពិសេសផ្តោតលើកម្រិតហានិភ័យពាក់ព័ន្ធនឹងបទដ្ឋានស្នូលនៃលក្ខខណ្ឌការងារ សុវត្ថិភាព និងសុខភាពការងារ ដូចជាសេវាសង្គ្រោះអប្បបរមា បន្ទប់បំបៅកូន កន្លែងហូបបាយ នៅតាមតំបន់ឧស្សាហកម្ម | ដាន និងវាយតម្លៃទៅលើការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល<br>▪ ក្រុមហ៊ុនឯកជន មិនទាន់ជ្រាបច្បាស់ពីសារ និងយុទ្ធសាស្ត្រនៃ IDP<br>▪ ជាន់ដែនសមត្ថកិច្ច និងមុខងារនៅក្នុងអន្តរក្រសួង-ស្ថាប័ន<br>▪ ការអនុវត្តច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា និងវិធានប្រកួតប្រជែងនៅមានកម្រិត។<br>*សំណើដំណោះស្រាយ÷*<br>▪ ស្នើសុំការឧបត្ថម្ភថវិកាឱ្យបានគ្រប់គ្រាន់<br>▪ អភិបាលកិច្ចល្អ<br>▪ កិច្ចសហប្រតិបត្តិការសិក្សាស្រាវជ្រាវអន្តរក្រសួងក្នុងក្របខណ្ឌគោលនយោបាយ<br>▪ ចែករំលែកព័ត៌មាន និងទិន្នន័យ |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ៨. សម្រួលបន្ទុកចំណាយរបស់និយោជកផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង ដោយពន្យារការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញរយៈពេល៥ឆ្នាំ និងលុបចោលកម្រៃគ្រប់គ្រងការនាំចេញចាប់ពីឆ្នាំ ២០១៨<br>៩. រួមគ្នារក្សាសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ដោយកម្មករនិយោជិត និងនិយោជកត្រូវចាត់ទុកគ្នាដូចជាដៃគូមិនអាចខ្វះបាន, ចាត់ទុករោងចក្រសហគ្រាសជាផ្ទាំងបាយរួម, ដោះស្រាយជម្លោះដោយភាពទន់ភ្លន់, និងលុបបំបាត់ឱ្យបាន កូដកម្មខុសច្បាប់ គ្មានបងតូចបងធំនៅតាមរោងចក្រ សហគ្រាស និងបង្កើតយុទ្ធនាការ "សហគ្រាសមួយគឺជាសហគមន៍សុខសាន្តមួយ"។<br>▪ ៧បានបន្តសហការជាមួយអង្គការអន្តរជាតិខាងការងារ (ILO) រៀបចំសិក្ខាសាលាត្រីភាគី និងវគ្គបណ្តុះបណ្តាលបំប៉នចំណេះដឹងមូលដ្ឋានអំពីសេដ្ឋកិច្ច ស្ថិតិ ជាពិសេស អំពីលក្ខណៈវិនិច្ឆ័យបែបសង្គម (ស្ថានភាពគ្រួសារ, អត្រាអតិផរណា, និងការចំណាយក្នុងការរស់នៅ) និងបែបសេដ្ឋកិច្ច (ផលិតភាព, ភាពប្រកួតប្រជែង, ស្ថានភាពទី | ▪ ប្រើប្រាស់ភាសាបច្ចេកទេសឱ្យបានច្បាស់ស្រឡះ<br>▪ សុំឱ្យមានកិច្ចប្រជុំផ្ទៃក្នុងកម្រិតបច្ចេកទេសរវាងអ្នកសម្របសម្រួល IDP (MEF និង CDC) យ៉ាងតិច ២ដង ក្នុង១ឆ្នាំ<br>▪ សុំចែករំលែកចំណេះដឹងវិទ្យាសាស្ត្ររវាងអន្តរក្រសួង សម្រាប់ជំរុញយុទ្ធសាស្ត្រអនុវត្ត IDP។<br>- ក្រុមប្រឹក្សាជាតិគណនេយ្យ÷<br>*បញ្ហាប្រឈម÷*<br>▪ កត្តាកិច្ចសហការអន្តរស្ថាប័ននៅមានកម្រិត<br>▪ កត្តាធនធានថវិកា<br>▪ ឆន្ទៈនៃការកាន់បញ្ជីគណនេយ្យ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដារដោយសហគ្រាស ជាទូទៅនៅមានកម្រិត |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ផ្សារការងារ, និងកម្រិតចំណោញរបស់វិស័យ) ដែលជាមូលដ្ឋានគ្រឹះក្នុងការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាប្រកបដោយការទទួលខុសត្រូវ មានសមធម៌ តម្លាភាព និងភាពប្រាកដនិយមនៃភាគីនីមួយៗ ដោយផ្អែកលើលក្ខណៈវិទ្យាសាស្ត្រ ស្ថិតិ និងរូបមន្តពិតប្រាកដ<br>▪ បានបន្តបង្កើត និងរៀបចំការប្រជុំក្រុមការងារបច្ចេកទេសត្រីភាគី នៃគណៈកម្មការប្រឹក្សាការងារ ដែលមានសមាសភាព ១៦រូប ស្មើគ្នាពីភាគីនីមួយៗ ដើម្បីពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមា សរុបចំនួន ៦លើក ក្នុងឆ្នាំ២០១៧ និងចំនួន ១១លើក ក្នុងឆ្នាំ២០១៨។ ជាលទ្ធផល បានកំណត់ប្រាក់ឈ្នួលអប្បបរមាប្រកបដោយភាពសុខដុម និងស្របតាមកាលវិភាគ សម្រាប់ឆ្នាំ ២០១៨ មានចំនួន ១៧០ដុល្លារ/ខែ និងឆ្នាំ ២០១៩ ចំនួន ១៨២ដុល្លារ/ខែ។ ការកំណត់ប្រាក់ឈ្នួលអប្បបរមាទាំង២លើកនេះ បានដំណើរការទៅដោយរលូន មានភាពទទួលយកបានដោយគ្រប់ភាគី ជៀសបាននូវការតវ៉ាតាមផ្លូវសាធារណៈ ដែលនេះជាការបង្ហាញឱ្យឃើញនូវភាពចាស់ទុំ និងយន្តការកាន់តែរឹងមាំក្នុងការកំណត់ប្រាក់ឈ្នួលនៅកម្ពុជា | ▪ ទោះបីជារបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសស្របតាមស្តង់ដា ក៏មិនប្រាកដថាគ្រឹះស្ថានហិរញ្ញវត្ថុនឹងផ្តល់ឥណទានដល់សហគ្រាសដោយមិនមានទ្រព្យបញ្ចាំឡើយ សូម្បីតែធនាគារអភិវឌ្ឍន៍ជនបទ។<br>*សំណូមពរ÷*<br>▪ ជួយជំរុញកិច្ចសហការអន្តរស្ថាប័ន<br>▪ បង្កើតកញ្ចប់ថវិកាសម្រាប់អនុវត្តសកម្មភាពរបស់ស្ថាប័នដែលចូលរួមអនុវត្តគោលនយោបាយនេះ។<br>- គណៈកម្មាធិការផលិតភាពកម្ពុជា (គ.ផ.ក.)÷<br>▪ ខ្វះមូលធនមនុស្ស<br>▪ ខ្វះវប្បធម៌វិទ្យាសាស្ត្រ និងគំរូអភិបាលកិច្ចសាជីវកម្ម ដែលធ្វើឱ្យមានការរាំងស្ទះដល់ការអនុវត្ត IDP |

| | វិធានការជាក់ស្តែងចម្បង | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមាក្នុងឆ្នាំ២០១៧ និងទទួលបានការអនុម័ត និងប្រកាសឱ្យប្រើកាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ ២០១៨ ដោយបានបញ្ចូលនូវគោលការណ៍ទាំង៥, លក្ខណៈវិនិច្ឆ័យទាំង៧,៧ និងកាលវិភាគនៃការចរចាប្រាក់ឈ្នួលអប្បបរមា ដែលជាលទ្ធផលនៃសិក្ខាសាលាត្រីភាគីថ្នាក់ជាតិកាលពីខែមេសា ឆ្នាំ ២០១៤ និងយន្តការត្រីភាគីដែលមានសំឡេងស្មើៗគ្នាចូលទៅក្នុងច្បាប់<br>▪ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីលើសេចក្តីព្រាងច្បាប់នេះ ចំនួន ០២លើក ក្នុងឆ្នាំ ២០១៧ និងចំនួន ០២លើក ក្នុងឆ្នាំ២០១៨ និងបានរៀបចំកិច្ចប្រជុំអន្តរក្រសួងចំនួន ០២លើក ក្នុងឆ្នាំ២០១៨ ដើម្បីទទួលធាតុចូលបន្ថែម មុនដាក់ជូនរដ្ឋសភាពអនុម័ត ហើយដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៨<br>▪ បន្តរក្សាស្ថិរភាពទីផ្សារពលកម្ម ទប់ស្កាត់ និងកាត់បន្ថយវិវាទការងារ តាមរយៈការពង្រឹងគណៈ-កម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញានៅថ្នាក់ជាតិ និងថ្នាក់រាជ-ធានីខេត្ត, ការធ្វើទំនើបកម្ម និងពង្រឹងយន្តការអធិការកិច្ចការងារតែមួយ, ការបន្តលើកកម្ពស់ | ▪ សមត្ថភាពស្រូបយកចំណេះដឹងរបស់វិស័យឯកជននៅមានកម្រិត ដែលធ្វើឱ្យការអនុវត្តគោលនយោបាយរដ្ឋាភិបាលមិនប្រទាក់ក្រឡាគ្នា និងមិនទាន់ពេញសក្តានុពល<br>▪ ការចែករំលែកព័ត៌មាន និងទិន្នន័យរវាងអន្តរក្រសួងស្ថាប័នមិនទាន់មានសង្គតិភាព និងនៅមានកម្រិត<br>▪ កង្វះចំណេះដឹងវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រគោលនយោបាយ ក្នុងការវាស់វែង និងវាយតម្លៃលើសមិទ្ធផល និងបច្ច័យគោលនយោបាយសេដ្ឋកិច្ចឧស្សាហកម្ម ប្រកបដោយប្រសិទ្ធភាព និងទុកចិត្តបាន<br>▪ មិនទាន់មានយន្តការរួម ដែលច្បាស់លាស់ សម្រាប់តាមដាន និងវាយ |

| | ទិដ្ឋភាពការដាក់ស្នែងចបូន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព |ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | លក្ខខណ្ឌការងារ, ការពង្រឹងយន្តការចរចាប្រាក់ឈ្នួលអប្បបរមា, ការពង្រឹងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ, ការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារពាក់ព័ន្ធនឹងការទូទាត់ប្រាក់បំណាច់អតីតភាពការងារ, ការដោះស្រាយទាន់ពេលវេលាករណីរោងចក្រក្ស័យធន ឬបិទទ្វារដោយថៅកែរត់ចោល, ការបន្តផ្សព្វផ្សាយ និងការបកស្រាយទាន់ពេលវេលាទៅនឹងចម្ងល់នានាអំពីលិខិតបទដ្ឋានគតិយុត្តថ្មីៗពាក់ព័ន្ធវិស័យការងារ។ ជាលទ្ធផលចំនួនវិវាទការងារសរុបមានការថយចុះជាបន្តបន្ទាប់ ពោលគឺបានធ្លាក់ចុះពី ៨៥៣ករណី ក្នុងឆ្នាំ២០១៦ មកត្រឹម ៦០៣ករណី នៅឆ្នាំ២០១៧ (ថយចុះ ២៩,៣%) និងមកត្រឹម ៥៨០ករណី ក្នុងឆ្នាំ២០១៨ (ថយចុះ ៣,៨%) ដែលការធ្លាក់ចុះនេះបានឆ្លុះបញ្ចាំងពីប្រសិទ្ធភាព នៃការដាក់ចេញនូវវិធានការរបស់ក្រសួងក្នុងការទប់ស្កាត់ផ្សះផ្សា និងដោះស្រាយវិវាទគ្រប់ជាន់ថ្នាក់។ ភាតរយនៃកូដកម្មមានការថយចុះ ដោយថយពី ២២០ករណី ក្នុងឆ្នាំ២០១៦ មកត្រឹម ៩៧ករណី នៅឆ្នាំ២០១៧(ថយចុះ ៤៤%) និងមកត្រឹម ៤៧ករណី នៅឆ្នាំ២០១៨(ថយចុះ ៥១.៥%ធៀបនឹងឆ្នាំ២០១៧)។ | តម្លៃទៅលើការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល<br>▪ ក្រុមហ៊ុនឯកជន មិនទាន់ជ្រាបច្បាស់ពីសារ និងយុទ្ធសាស្ត្រនៃ IDP<br>▪ បញ្ហាជាន់ដែនសមត្ថកិច្ច និងមុខងារនៅក្នុងអន្តរក្រសួងស្ថាប័ន<br>▪ កង្វះការការពារអ្នកប្រើប្រាស់ និងវិធានប្រកួតប្រជែង។<br>*សំណើដំណោះស្រាយ÷*<br>▪ សុំឱ្យមានកិច្ចប្រជុំផ្ទៃក្នុងកម្រិតបច្ចេកទេសរវាងលេខាធិការដ្ឋាន IDP និងមន្ត្រីបច្ចេកទេសនៃក្រសួងស្ថាប័នពាក់ព័ន្ធយ៉ាងតិច២ដង ក្នុង១ឆ្នាំ<br>▪ ៗកែលម្អអភិបាលកិច្ច និងយុទ្ធសាស្ត្រប្រកួតប្រជែង |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានពង្រឹងប្រសិទ្ធភាពនៃយន្តការទប់ស្កាត់ផ្សះផ្សា និងដោះស្រាយវិវាទការងារគ្រប់កម្រិត តាមរយៈការពង្រឹងសមត្ថភាពមន្ត្រីផ្សះផ្សាវិវាទ ដោយសហការជាមួយដៃគូពាក់ព័ន្ធ ព្រមទាំងបានរៀបចំបង្កើតវិទ្យាស្ថានជាតិការងារដែលនឹងដាក់ឱ្យដំណើរការនៅឆ្នាំ២០១៩ ក្នុងគោលបំណងអភិវឌ្ឍសមត្ថភាព និងផ្តល់វិក្រឹត្យការដល់មន្ត្រីរាជការក្នុងវិស័យការងារ ដែលជាលទ្ធផលអត្រា [illegible] ផ្សះផ្សាវិវាទបានកើនជាបន្តបន្ទាប់ គឺបានកើនពី ៣៧,៦% ឆ្នាំ២០១៦ ទៅ ៥២,១% ឆ្នាំ២០១៧ និង ៥៦,៩%ឆ្នាំ២០១៨ ព្រមទាំងបន្តអនុវត្តយន្តការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយក្នុងកំឡុងឆ្នាំ២០១៧ និង ២០១៨ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដោះស្រាយវិវាទការងាររួមសរុបចំនួន ១៣១ករណី<br>▪ បានដំឡើងប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងពី ១៥៣ដុល្លារ នៅឆ្នាំ២០១៧ ដល់ ១៧០ដុល្លារ នៅឆ្នាំ២០១៨<br>▪ បានកាត់បន្ថយចំណាយរបស់កម្មករនិយោជិត ដោយពង្រីកការតបណ្តាញអគ្គិសនី និងទឹកស្អាត | ▪ បង្កើនកិច្ចសហប្រតិបត្តិការសិក្សាស្រាវជ្រាវអន្តរក្រសួងក្នុងក្របខណ្ឌគោលនយោបាយ<br>▪ ប្រើប្រាស់ភាសាបច្ចេក-ទេស ឱ្យបានច្បាស់ស្រឡះ<br>▪ ជំរុញឱ្យមានទិន្នន័យវិទ្យា-សាស្ត្រនៅគ្រប់ជាន់ថ្នាក់<br>▪ សន្ទានកម្មគោលនយោបាយផលិតភាព ក្នុងគោលនយោបាយវិនិយោគ និងលក្ខខណ្ឌក្នុងការទទួលបានរបបលើកទឹកចិត្ត<br>▪ សុំចែករំលែកចំណេះដឹងវិទ្យាសាស្ត្ររវាងអន្តរក្រសួងសម្រាប់ជំរុញយុទ្ធសាស្ត្រអនុវត្ត IDP។<br>- រដ្ឋបាលខេត្តកណ្តាល÷<br>▪ កង្វះកម្លាំងពលកម្ម ដែលប្រកបដោយជំនាញវិជ្ជាជីវៈ ទាមទារឱ្យមានការបណ្តុះ- |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ដែលមានតម្លៃទាបនៅតំបន់ផ្ទះជួល, ផ្តល់ការធ្វើដំណើរតាមរថយន្តក្រុងរបស់រដ្ឋដោយមិនបង់ថ្លៃ, ការធ្វើដំណើរតាមកាណូតពីភ្នំពេញទៅក្រុងតាខ្មៅដោយមិនគិតប្រាក់ដល់ចុងឆ្នាំ២០១៨, ដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សជាប់ពន្ធដល់ ១ ២០០ ០០០រៀល ចាប់ពីឆ្នាំ២០១៨, បន្តលើកលែងពន្ធលើប្រាក់អត្ថប្រយោជន៍បន្ថែមនានា, ផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មការិនីដែលសម្រាលកូនបាន ១នាក់ បានថវិកា ៤០០ ០០០រៀល កូនភ្លោះពីរនាក់ បានថវិកា ៨០០ ០០០រៀល កូនភ្លោះបីនាក់ បានថវិកា ១ ២០០ ០០០រៀល<br>▪ បានពង្រីករបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពនៅឆ្នាំ២០១៧ បន្ថែមលើផ្នែកហានិភ័យការងារ ដោយបានតម្រូវឱ្យនិយោជកបង់ប្រាក់ភាគទានផ្នែកថែទាំសុខភាព ១០០% ជំនួសកម្មករនិយោជិតចាប់ពីខែមករា ឆ្នាំ២០១៨, និងបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលមានវិសាលភាពកាន់តែទូលំទូលាយ ធានាសង្គតិភាព និងសមធម៌រវាងមន្ត្រីរាជការសាធារណៈ និងកម្មករនិយោជិត, បានផ្តល់ប្រាក់ឈ្នួលចំនួន ១២០% ចំនួន ៣ខែ ដល់បងប្អូនកម្មការិនីពេល | បណ្តាលជំនាញបច្ចេកទេស។ |

| | វិធានការដាក់ស្តែងបូន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | សម្រាលកូន (៥០% ដោយនិយោជក និង៧០% ដោយបេឡាជាតិរបបសន្តិសុខសង្គម)<br>▪ បន្តលើកកម្ពស់លក្ខខណ្ឌការងារ សុវត្ថិភាព និងសុខភាពការងារ ដោយច្របាច់បញ្ចូលគ្នាក្រុមអធិការកិច្ចការងារច្រើនក្រុម ឱ្យទៅជាក្រុមអធិការកិច្ចការងារតែមួយរបស់ក្រសួង និងធ្វើទំនើបកម្មប្រព័ន្ធអធិការកិច្ចការងារ តាមរយៈការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា និងចំណាត់ថ្នាក់នៃកម្រិតហានិភ័យរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាននីមួយៗជាមូលដ្ឋានចម្បងក្នុងការចុះអធិការកិច្ច ដែលយន្តការនេះគឺអាចធានាបានការគោរពលក្ខខណ្ឌការងារផង និងមិនរំខានដល់ដំណើរការរបស់សហគ្រាស គ្រឹះស្ថានផង<br>▪ បានដោះស្រាយករណីរោងចក្រក្ស័យធន ឬបិទទ្វារដោយថៅកែរត់ចោល បានចំនួន ១៣ ករណី មានកម្មករនិយោជិតសរុប ៨ ០៥២នាក់ និងបានផ្តល់សេវាជួយស្វែងរកការងារដល់កម្មករនិយោជិតចំនួន ៦ ៨៩៥នាក់<br>▪ បានរៀបចំនិងដាក់ឱ្យអនុវត្តគោលនយោបាយជាតិ ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ និងបានអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលលើវិស័យអាទិភាព | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | និងសម្រាប់វិក្រឹត្យការសមត្ថភាពគ្រូបច្ចេកទេស ដើម្បីពង្រីកការបណ្តុះបណ្តាលបែបទំនើបដែលឈរលើស្តង់ដាសមត្ថភាព ចាប់ពីឆ្នាំ២០១៧<br>▪ បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល និងបានបង្កើនការវិភាជថវិកាសម្រាប់គាំទ្រការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈចំនួន៤,៤៥% នៅឆ្នាំ២០១៨<br>▪ បានបង្កើនការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈរយៈពេលវែង តាមវិស័យអាទិភាពទាំង៥ រួមមាន សំណង់ អគ្គិសនី មេកានិករថយន្តកម្មន្តសាល និងធុរកិច្ច/ព័ត៌មានវិទ្យា ដើម្បីគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្ម<br>▪ បានបង្កើតវិទ្យាស្ថានពហុបច្ចេកទេសមិត្តភាពកម្ពុជា-ចិន ខេត្តព្រះសីហនុ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុនៅឆ្នាំ២០១៧<br>▪ បានកំណត់ថ្ងៃទី១៥ មិថុនា ជារៀងរាល់ឆ្នាំ ជាទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET-DAY) និងបានបង្កើនថវិកាសម្រាប់ការផ្សព្វផ្សាយដើម្បីបង្កើនការចុះឈ្មោះចូលរៀន<br>▪ បានបង្កើនការវិភាជថវិកាសម្រាប់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ សម្ភារបរិក្ខារ រោងជាង មន្ទីរពិសោធន៍សម្រាប់គាំទ្រដល់ការបណ្តុះបណ្តាល | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | បច្ចេកទេស និងជំនាញដើម្បីឆ្លើយតបនឹងតម្រូវការឧស្សាហកម្ម (នៅឆ្នាំ២០១៧ កើនឡើង ៤,៥៥% ពីឆ្នាំ២០១៦, នៅឆ្នាំ២០១៨ កើនឡើង ៥,៩៣% ពីឆ្នាំ២០១៧)។ ថវិការបស់គម្រោង ADB/AFD (នៅឆ្នាំ២០១៧ កើនឡើង ៣៦,០២% ពីឆ្នាំ២០១៦, នៅឆ្នាំ២០១៨ កើនឡើង ២៨៩,៣៥% ពីឆ្នាំ២០១៧)។<br>▪ បានបង្កើតវិទ្យាស្ថានពហុបច្ចេកទេសមិត្តភាពកម្ពុជា-ចិន ខេត្តព្រះសីហនុ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ និងចាប់ផ្តើមផ្តល់ការបណ្តុះបណ្តាលក្នុងឆ្នាំ២០១៨ លើមុខជំនាញរួមមាន មេកានិករថយន្ត អគ្គិសនី សំណង់ព័ត៌មានវិទ្យា ទេសចរណ៍ បដិសណ្ឋារកិច្ច ដល់សិស្ស-និស្សិតចំនួន ២១០នាក់។<br>▪ បានបង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យចំនួន ៤ គឺវិស័យសំណង់នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ, វិស័យអគ្គិសនីនៅវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ, វិស័យមេកានិករថយន្តនៅវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង និងវិស័យកម្មន្តសាលនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ក្នុងគោលបំណងដើម្បីពិគ្រោះយោបល់លើផែនការសកម្មភាពក្នុងការផ្តល់ដំបូន្មាន នឹងកំណត់ទិសដៅ | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងចង្ក្រមការ | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ក្នុងការអភិវឌ្ឍសមត្ថភាព និងប្រសិទ្ធភាពនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។<br>- ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ បានកសាងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រ (១២+៤) នៅវិទ្យាស្ថានគរុកោសល្យ<br>▪ បានប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការរាជធានីភ្នំពេញ ទៅជាវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ<br>▪ បានប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការខេត្តបាត់ដំបង ទៅជាវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង<br>▪ មានគ្រឹះស្ថានឧត្តមសិក្សាចំនួន៧៣ ក្នុងនោះគ្រឹះស្ថានរដ្ឋមានចំនួន១៣ និងគ្រឹះស្ថានឯកជនមានចំនួន៦០ ដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ខ្លួន ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាចំនួន១២១ ក្នុងទូទាំងប្រទេស<br>▪ ពង្រីកវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសរដ្ឋនិងឯកជនបាន ១៤កន្លែង<br>▪ បង្កើនសិស្សចូលរៀនក្នុងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសពីចំនួន ១.១៤៨នាក់ (ស្រី ៤៦៤នាក់) ក្នុងឆ្នាំសិក្សា ២០១៦-២០១៧ មកចំនួន | |

| | វិធានការជាក់ស្ដែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ១.៤៧១នាក់ (ស្រី ៥២៦នាក់) ក្នុងឆ្នាំសិក្សា ២០១៧-២០១៨។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>▪ (ការងារឆ្នាំ២០១៦) បានជ្រើសរើសបេក្ខជនមកពីវិស័យឯកជន និងមន្ត្រីស្ថាប័នរដ្ឋ ចំនួន ៧៥៧នាក់ ឱ្យចូលរួមកម្មវិធីវគ្គបណ្ដុះបណ្ដាលស្ដីពីវិធីសាស្ត្រលើកកម្ពស់ផលិតភាពរបស់អង្គការផលិតភាពអាស៊ី និងអង្គការផលិតភាពជប៉ុន<br>▪ (ការងារឆ្នាំ២០១៧-២០១៨) មជ្ឈមណ្ឌលផលិតភាពជាតិកម្ពុជា (NPCC-National Productivity Center of Cambodia) បានប្រឹងប្រែង លើកកម្ពស់សមត្ថភាពរបស់ខ្លួនយ៉ាងសកម្ម តាមរយៈការចូលរួមវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលានានា នៅប្រទេសសមាជិកអង្គការផលិតភាពអាស៊ី (APO-Asia Productivity Organization) ទាំង ១៩ប្រទេស ចំនួន ០២លើក និងមានមន្ត្រីចូលរួមចំនួន០៦នាក់។ ទន្ទឹមនឹងនោះ NPCC ក៏បានបំពេញសមត្ថកិច្ចរបស់ខ្លួន សំដៅលើកកម្ពស់ផលិតភាព និងគុណភាពដល់សហគ្រាសធុនតូច និងមធ្យម រោងចក្រ សហគ្រាសឯកជន និងស្ថាប័នរដ្ឋ ដោយទទួលបានលទ្ធផលដូចតទៅ÷ បានជ្រើសរើសបេក្ខជនមកពីវិស័យឯកជន និងមន្ត្រីស្ថាប័នរដ្ឋ | |

| | វិធានការដាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ចំនួន១,១៦៨ (៥៧គម្រោង) ឱ្យចូលរួមកម្មវិធីវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្រ្តលើកកម្ពស់ផលិតភាពរបស់អង្គការផលិតភាពអាស៊ី និងអង្គភាពផលិតភាពជប៉ុន គឺមានការកើនឡើង ប្រមាណជា ៨០% ធៀបទៅនឹងឆ្នាំ២០១៦។ ក្រៅពីនេះក្រសួងក៏បានផ្តល់ពានរង្វាន់ "ស៥" ចំនួន០៤ពានរង្វាន់ ជូនដល់សហគ្រាស រោងចក្រ និងសិប្បកម្ម។ ដូច្នេះ សិក្ខាកាមដែលបានចូលរួមកម្មវិធីវគ្គបណ្តុះបណ្តាល សរុបមានចំនួន២,២៣៤ នាក់ និងពានរង្វាន់ "ស៥" ត្រូវបានផ្តល់ជូនក្រុមហ៊ុនសហគ្រាស រោងចក្រ និងសិប្បកម្ម សរុបបានចំនួន ១៥ ពានរង្វាន់ រហូតមកដល់បច្ចុប្បន្ន។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សដែលត្រូវជាប់ពន្ធ<br>▪ បានដំឡើងកម្រិតទាយជ្ជទានសម្រាប់សហព័ទ្ធ និងកូនក្នុងបន្ទុក ដើម្បីកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស<br>▪ បានដាក់ចេញយន្តការអនុគ្រោះពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែមសម្រាប់ចំណាយលើការដឹកជញ្ជូន, ស្នាក់នៅ និងហូបចុករបស់កម្មករនិយោជិត | |

| | វិធានការជាក់ស្តែងបូន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងចម្លងភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានដាក់ចេញនូវយន្តការលើកលែងអាករលើតម្លៃបន្ថែមតាមរយៈការផ្គត់ផ្គង់មិនជាប់អាករ ដើម្បីសម្រួលដល់បន្ទុកចំណាយរបស់កម្មករប្រជាពលរដ្ឋ ដែលក្នុងនោះរួមមាន៖ ទឹកស្អាត អគ្គិសនី, និងសេវាសាធារណៈមួយចំនួន<br>▪ បានរៀបចំសិក្ខាសាលាប្រឹក្សាយោបល់ និងចែករំលែកចំណេះដឹងស្តីពី "ការបង្កើនផលិតភាពពលកម្មនៅកម្ពុជា"ដោយមានការចូលរួមពី ២៤ ស្ថាប័ន<br>▪ បានប្រឹក្សានិងផ្តល់យោបល់លើគោលនយោបាយ IDP ជាមួយ ERIA, iB-AN និង WB ក្នុងក្របខណ្ឌរក្សាកំណើនម៉ាក្រូ និងមីក្រូសេដ្ឋកិច្ច ក៏ដូចជាសេដ្ឋកិច្ចបរិយាប័ន្ន<br>▪ ចូលរួម និងប្រឹក្សាជាមួយ ILO នៅក្នុងសិក្ខា-សាលាកម្រិតខ្ពស់ ស្តីពីការពិនិត្យតាមដានប្រាក់ឈ្នួលអប្បបរមា<br>▪ ចូលរួមក្នុងការចរចាប្រាក់ឈ្នួលអប្បបរមាប្រចាំឆ្នាំ<br>▪ ចូលរួមពិភាក្សាក្នុងកម្រិតបច្ចេកទេសលើសេចក្តីព្រាងច្បាប់ប្រាក់ឈ្នួលអប្បបរមា<br>▪ បានចូលរួមរៀបចំកម្មវិធីកសាងសមត្ថភាពដើម្បីបង្កើនភាពប្រកួតប្រជែង (Skills for Competitiveness Development Program) | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ក្នុងទឹកប្រាក់ប្រមាណ ៦០ លានដុល្លារអាមេរិក ក្រោមក្របខ័ណ្ឌឥណទានសម្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី។<br>▪ បានសហការអនុវត្តគម្រោងដែលសហហិរញ្ញប្បទានដោយ ADB និង AFD ក្នុងនោះរួមមាន÷ (១) គម្រោងពង្រឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (ជំហានទី២) មានទឹកប្រាក់សរុប ១៥លានដុល្លារអាមេរិក និង (២) គម្រោងសាងសង់សាលាជាតិបណ្តុះបណ្តាលវិជ្ជា-ជីវៈទេសចរណ៍ មានទឹកប្រាក់ប្រមាណ ១៣,៥ លានដុល្លារអាមេរិក ដែលហិរញ្ញប្បទានដោយAFD<br>▪ បានដាក់ឱ្យអនុវត្តគម្រោងសាកល្បងមូលនិធិជាតិអភិវឌ្ឍន៍ជំនាញ<br>▪ បានវិភាជថវិកា ២០៥ ពាន់លានរៀល សម្រាប់អនុវត្តគម្រោងកម្មវិធីសាច់ប្រាក់ ដែលនឹងចូលរួមបង្កើនជំនាញទប់ស្កាត់ ចំណាកស្រុកនិងចំណាកប្រទេស បង្កើនផលិតភាព និងលើកកម្ពស់ជីវភាពរបស់ប្រជាជននៅជនបទ<br>▪ សម្រេចបានគម្រោងសិក្សាស្រាវជ្រាវចំនួន០២÷<br>- គម្រោងទី១ ស្តីពី "ឥទ្ធិពលនៃប្រាក់ឈ្នួលអប្បបរមាលើ សុខុមាលភាព និងផលិតភាព | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងចន្លោះភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ពលកម្មរបស់កម្មករនិយោជិត ក្នុងវិស័យកាត់ដេរនៅកម្ពុជា ឆ្នាំ២០១៨"<br>- គម្រោងទី២ ស្តីពី "ឥទ្ធិពលនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ ទី៤.០ លើទីផ្សារពលកម្ម និងការអភិវឌ្ឍជំនាញនៅកម្ពុជា"។<br>▪ បានផ្តល់អនុសាសន៍ជូនរដ្ឋាភិបាល÷<br>- នវានុវត្តកម្មលើអភិក្រមការងារ ដើម្បីបង្កើត និងបញ្ជ្រាបបច្ចេកវិទ្យា, បច្ចេកទេសអភិបាលកិច្ចល្អ (scientific management), និងបង្កើតផលិតផលសម្រាប់ប្រើប្រាស់ក្នុងប្រទេស<br>- ធ្វើនវានុវត្តកម្មលើគំរូសេដ្ឋកិច្ចនិងធុរកិច្ច ឆ្ពោះទៅវប្បធម៌គ្រប់គ្រងបែបវិទ្យាសាស្ត្រ<br>- បង្កើនគុណភាពអ្នកវិទ្យាសាស្ត្រ និងវិស្វករ ដោយត្រូវសិក្សាស្រាវជ្រាវធ្វើនវានុវត្តកម្ម និងពាណិជ្ជកម្មលើផលិតផល (product commercialization)<br>- ផ្តល់អនុសាសន៍ ដើម្បីជំរុញតួនាទី និងការទទួលខុសត្រូវរបស់សហជីព ក្នុងការពង្រឹងគុណភាព និងជំនាញវិជ្ជាជីវៈពលកម្ម, អភិក្រមការងារ, ធានាឱ្យបានស្ថិរភាពនៃការផ្គត់ផ្គង់ | |

| | វិធានការដាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងថវិកា | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | កម្លាំងពលកម្ម និងកម្មវិធីបណ្តុះបណ្តាលជំនាញដល់កម្មករ។<br>▪ វិភាគលើក្របខណ្ឌភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន (PPP scheme) ដើម្បីធានាបាននូវការអភិវឌ្ឍមូលធនមនុស្ស និងការបង្កើនផលិតភាពពលកម្ម<br>▪ ជំរុញអភិបាលកិច្ចសាជីវកម្ម (corporate governance) និងការគ្រប់គ្រងបែបវិទ្យាសាស្ត្រក្នុងវិស័យសាធារណៈ និងវិស័យឯកជន<br>▪ យន្តការសិក្សាប្រៀបធៀប (comparative study) និងធ្វើសុពលកម្ម (validation) លើគម្រោងសិក្សាស្រាវជ្រាវស្តីពី"ឥទ្ធិពលនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤.០ លើទីផ្សារពលកម្ម និងការអភិវឌ្ឍជំនាញនៅកម្ពុជា" រួមមាន÷<br>- សិក្សាប្រៀបធៀបលើយុទ្ធសាស្ត្រសេដ្ឋកិច្ច-ឧស្សាហកម្ម និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មរវាងប្រទេសម៉ាឡេស៊ី, ប្រទេសមីយ៉ាន់ម៉ា និងប្រទេសកម្ពុជា ដើម្បីឆ្លើយតបតាមតម្រូវការសេដ្ឋកិច្ចឧស្សាហកម្មជំនាន់ទី៤.០<br>- ប្រឹក្សាយោបល់ទៅលើគោលនយោបាយ និងយុទ្ធសាស្ត្រត្រៀមខ្លួនរបស់ ១០អគ្គនាយកដ្ឋាន | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | នៃ៩ក្រសួង និងមន្ទីរឧស្សាហកម្មនិងសិប្បកម្ម និងមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍(ចំនួន ០៤ ខេត្ត) ដើម្បីឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ចនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤.០<br>- ប្រឹក្សាយោបល់ និងសិក្សាទៅលើកម្មវិធីនិងយុទ្ធសាស្ត្រកសាងជំនាញ និងមូលធនមនុស្សសម្រាប់បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤.០ ជាមួយវិទ្យាស្ថានជាតិបណ្តុះបណ្តាលជំនាញវិទ្យាសាស្ត្រនិងបច្ចេកវិជ្ជា (NPIC និង ITC) និង JBAC។<br>▪ កម្មវិធីសិក្សាគណនេយ្យករជំនាញត្រូវបានដាក់ឆ្លងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ និងត្រៀមដាក់ឱ្យអនុវត្ត<br>▪ បានបង្កើនការយល់ដឹងជាសាធារណៈលើការបំពេញកាតព្វកិច្ចពន្ធ តាមរយៈសិក្ខាសាលា វីដេអូ រូបភាព ពាក្យស្លោក ការសម្ភាសន៍ និងការផ្សព្វផ្សាយតាមបណ្តាញវិទ្យុ ទូរទស្សន៍ បណ្តាញទំនាក់ទំនងសង្គម<br>▪ បានប្រជុំពិភាក្សាជាមួយសភាពាណិជ្ជកម្ម សមាគមពាណិជ្ជកម្ម សមាគមរោងចក្រកាត់ដេរ ដើម្បីបញ្ជ្រាបការយល់ដឹងពីកាតព្វកិច្ចដល់សហគ្រាស ជាពិសេសក្នុងក្របខ័ណ្ឌដៃគូពិភាក្សា | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | រវាងអគ្គនាយកដ្ឋានពន្ធដារ និងវិស័យឯកជន ដើម្បីឆ្លើយតបនឹងចម្ងល់នានាបន្ថែមរបស់វិស័យឯកជន ក្នុងនោះសិក្ខាសាលាដែលរៀបចំដោយនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំមានចំនួន ១៣ដង (៤៧០០ សហគ្រាស), សិក្ខាសាលាផ្សព្វផ្សាយ រៀបចំដោយនាយកដ្ឋានអ្នកជាប់ពន្ធតូចនិងមធ្យម និងសិក្ខាសាលាដែលសហការជាមួយដៃគូមានចំនួន ៣៨ដង (អ្នកចូលរួម ៥១៦៤នាក់), សិក្ខាសាលាដែលរៀបចំដោយសាខាពន្ធដារខេត្ត ខណ្ឌ ចំនួន ៨៩ ដង (អ្នកចូលរួម ៤៧២៩នាក់)<br>▪ បានពិគ្រោះយោបល់ និងបំភ្លឺដល់អ្នកជាប់ពន្ធជាលាយល័ក្ខណ៍អក្សរ តាមរយៈ CALL CENTER តាម LIVE CHAT តាម Email តាមបណ្តាញទំនាក់ទំនងសង្គម បញ្ជរពិគ្រោះយោបល់ និងប្រអប់ពិគ្រោះយោបល់។<br>- ក្រុមប្រឹក្សាជាតិគណនេយ្យ÷<br>▪ បានសហការជាមួយវិទ្យាស្ថានគណនេយ្យជំនាញ និងសវនករកម្ពុជា ដើម្បីបង្កើតកម្មវិធីសិក្សាគណនេយ្យជំនាញថ្នាក់ជាតិ<br>▪ បានរៀបចំ និងសម្រេចសេចក្តីព្រាងកម្មវិធីសិក្សាខាងលើនេះរួចរាល់ ដោយបានទទួលការឯកភាព | |

| | វិធានការជាក់ស្ដែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ដាក់ឱ្យអនុវត្តពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>▪ បានគិតគូររៀបចំបង្កើតគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញថ្នាក់ជាតិ<br>▪ កំពុងរៀបចំយន្តការគ្រប់គ្រងវិញ្ញាសា ការប្រឡង និងកំណែ និងទម្រង់នៃវិញ្ញាសាសម្រាប់ការប្រឡងលើមុខវិជ្ជានីមួយៗ<br>▪ ត្រៀមពិភាក្សាជាមួយក្រសួងអប់រំ យុវជន និងកីឡា និង/ឬក្រសួងការងារ លើបញ្ហាបច្ចេកទេស និងក្របខណ្ឌទទួលស្គាល់។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖<br>ក្នុងឆ្នាំ២០១៦៖<br>▪ បានដឹកនាំកិច្ចប្រជុំពាក់ព័ន្ធនឹងការជំរុញការបណ្ដុះបណ្ដាលជំនាញ និងធនធានមនុស្ស និងបានចូលរួមកិច្ចប្រជុំពិភាក្សាទាក់ទងនឹងការកំណត់ប្រាក់ឈ្នួលអប្បបរមា និងការពង្រឹងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ<br>▪ បានចូលរួមយ៉ាងសកម្មក្នុងការងារកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០១៧ ក្នុងក្របខ័ណ្ឌគណៈកម្មការប្រឹក្សាការងារ, ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីប្រាក់ឈ្នួលអប្បបរមា, ការរៀបចំ | |

| | វិធានការជាក់ស្តែងបន្ត | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងថវិកាភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥, ការរៀបចំ និងអនុវត្តគោលនយោបាយគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ, និងច្បាប់ស្តីពីសហជីព<br>ក្នុងឆ្នាំ២០១៧÷<br>▪ បានចូលរួមយ៉ាងសកម្មក្នុងការងារកំណត់ប្រាក់-ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០១៨ ក្នុងក្របខណ្ឌគណៈកម្មការប្រឹក្សាការងារ, ការរៀបចំសេចក្តី-ព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា, និងការបន្តអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ, និងច្បាប់ស្តីពីសហជីព<br>▪ បានចូលរួមកិច្ចប្រជុំរបស់អនុគណៈកម្មការទី១ ស្តីពីការបង្កើនឱកាសការងារសមរម្យ និងមានផលិតភាពខ្ពស់ ដើម្បីជំរុញការអនុវត្តផែនការសកម្មភាព និងវិធានការនៃគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥<br>▪ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា<br>▪ បានចូលរួមក្នុងការលើកកម្ពស់លក្ខខណ្ឌការងារ និងសុខុមាលភាពរបស់កម្មករ និយោជិត តាមរយៈការចូលរួមរៀបចំសិក្ខាសាលាផ្សព្វផ្សាយការអនុ- | |

| | វិធានការដាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងទន្លេនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | វត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងសិក្ខាសាលាស្វែងយល់អំពីការអនុវត្តច្បាប់ពាក់-ព័ន្ធនឹងការធ្វើចំណាកស្រុក ការទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ជូនកម្មករនិយោជិត នៅតាមតំបន់សេដ្ឋកិច្ចពិសេស<br>▪ បានធ្វើការសិក្សាស្រាវជ្រាវ និងធ្វើបច្ចុប្បន្នភាពលើជំនួយស្មារតីទាក់ទងនឹងប្រធានបទស្តីពីការជំរុញការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស។<br>ក្នុងឆ្នាំ២០១៨÷<br>▪ បានធ្វើការស្រាវជ្រាវលើស្ថានភាពប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍សំខាន់ៗរបស់កម្មករ-និយោជិតក្នុងវិស័យកាត់ដេរ និងផលិតស្បែកជើង ដើម្បីជាមូលដ្ឋានក្នុងការពិភាក្សានិងការផ្តល់ការសម្របសម្រួលដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់កម្មករ-និយោជិត ព្រមទាំងបង្កើនផលិតភាពរបស់ពួកគេ<br>▪ បាននិងកំពុងចូលរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥ សំដៅធ្វើយ៉ាងណាឱ្យការអនុវត្តគោលនយោបាយនេះទទួលបាន | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ជោគជ័យ ដោយជួយបង្កើត និងបង្កើនឱកាសការងារសមរម្យប្រកបដោយសុខុមាលភាពជូនដល់បងប្អូនប្រជាពលរដ្ឋខ្មែរយើង តាមរយៈការជំរុញនិងទាក់ទាញវិនិយោគបន្ថែមទាំងក្នុងស្រុក និងពីបរទេស<br>▪ បានសម្រេចអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើការវិនិយោគលើគម្រោងថ្មី និងគម្រោងពង្រីកផលិតកម្ម សរុបចំនួន ២៥៦គម្រោង ដែលមានទុនវិនិយោគចំនួនប្រមាណ ៧ ពាន់លានដុល្លារអាមេរិក និងដែលអាចបង្កើតការងារបានចំនួន ២៣៩.០៨៨កន្លែងក្នុងប្រទេសកម្ពុជា<br>▪ បានចូលរួមសម្របសម្រួលរៀបចំពិធីសំណេះ-សំណាលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាមួយកម្មករ និយោជិត នៅតាមតំបន់សេដ្ឋកិច្ចពិសេស<br>▪ បានចូលរួមសម្របសម្រួលលើកិច្ចសហប្រតិបត្តិ-ការរវាងអ្នកអភិវឌ្ឍតំបន់ និងក្រុមការងារពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការប្រជុំផ្សព្វផ្សាយនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនូវលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការបើកប្រាក់ឈ្នួលជូនកម្មករ និយោជិត និងការទូទាត់ប្រាក់បំណាច់អតីតភាពការងារ | |

| | វិធានការជាក់ស្តែងបន្ត | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានចូលរួមសម្របសម្រួលដល់ការងារដោះស្រាយវិវាទការងារ និងស្វែងរកដំណោះស្រាយជូនកម្មករ និយោជិត និងនិយោជក នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។<br>- ទីស្តីការគណៈរដ្ឋមន្ត្រី បានចូលរួមប្រជុំការងារពាក់ព័ន្ធនឹង IDP លើការជំរុញការបណ្តុះបណ្តាលធនធានមនុស្ស។<br>- ក្រសួងអភិវឌ្ឍន៍ជនបទ÷<br>▪ បានបញ្ជូនមន្ត្រីសរុបចំនួន ៥០ នាក់ (ស្រីចំនួន ១១ នាក់) ចូលរួមវគ្គបណ្តុះបណ្តាលសិក្ខាសាលា និងទស្សនកិច្ចសិក្សានៅក្រៅប្រទេសបានចំនួន ៣០លើក<br>▪ បានផ្តល់ការបណ្តុះបណ្តាលជំនាញមូលដ្ឋានទាំង ០៨ខេត្ត គឺខេត្តស្វាយរៀង, ខេត្តព្រៃវែង, ខេត្តតាកែវ, ខេត្តកំពង់ស្ពឺ, ខេត្តកំពង់ចាម, ខេត្តបាត់ដំបង, ខេត្តកំពត និងខេត្តពោធិ៍សាត់ លើមុខជំនាញអ៊ុតសក់, កែសម្ផស្ស, កាត់សក់បុរស-ស្ត្រី, កាត់ដេរ, សិប្បកម្មតម្បាញ, សម្លៀកបំពាក់បុរស-នារី, កុំព្យូទ័ររដ្ឋបាល, ភាសាអង់គ្លេស, ជួសជុលគ្រឿងម៉ាស៊ីនខ្នាតតូច, បច្ចេកទេសចិញ្ចឹមជ្រូក, ចិញ្ចឹមមាន់លក្ខណៈគ្រួសារ, បណ្តុះផ្សិតចំបើង, បច្ចេកទេសបណ្តុះកូនឈើ និងផ្សាំមែក, បច្ចេក- | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងទឡ្ហនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ទេសដាំដំណាំគ្រួសារ, ធ្វើជីកំប៉ុស្តិ៍,ការជួសជុលអណ្តូងស្នប់ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៣ ៤៦៨ នាក់ (ស្រី ១ ៤៥១ នាក់)<br>▪ បានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋានដើម្បីបង្កើតការងារជូនប្រជាពលរដ្ឋនៅខេត្តគោលដៅទាំង០៨គឺ÷ ខេត្តព្រៃវែង, ស្វាយរៀង, កំពង់ចាម, បាត់ដំបង, ពោធិ៍សាត់ កំពត, កំពង់ស្ពឺ និងតាកែវបានចំនួន ១៩៣វគ្គ ដែលមានសិក្ខាកាមចូលរួមចំនួន ៤៥២៥នាក់ ក្នុងនោះមានស្រ្តីចូលរួមចំនួន ២ ១៥៧នាក់ មុខជំនាញវិជ្ជាជីវៈដែលបានបណ្តុះបណ្តាលរួមមាន÷ កាត់សក់បុរសស្រ្តី, អ៊ុតសក់, សំអាង, កាត់ដេរសម្លៀកបំពាក់, ការប្រើកុំព្យូទ័រ, ភាសាអង់គ្លេស, ជួសជុលទូរស័ព្ទដៃ, ជួសជុលកុំព្យូទ័រ, ជួសជុលរថយន្ត, ជួសជុលគ្រឿងម៉ាស៊ីនកសិកម្ម, ជួសជុលម៉ូតូ-ទូរទស្សន៍, ដំឡើងគ្រឿងសង្ហារឹម ផ្តៅ វិពាក់ ឈើ ។ល។<br>▪ បានផ្តល់ជំនាញផលិតសាប៊ូ នៅខេត្តកំពង់ធំ និងកំពង់ឆ្នាំង<br>▪ បានផ្តល់ការបណ្តុះបណ្តាលជំនាញក្នុងសហគមន៍ នៅខេត្តកំពង់ស្ពឺ និងខេត្តតាកែវ ពីកម្មវិធីផលិតស្បៀង ធ្វើជីកំប៉ុស្តិ៍ ១៦វគ្គ ដែលមានអ្នកទទួលផលសរុប ៤៨០នាក់ (ស្រី ២៥៣នាក់) | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងធនធានភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានបង្រៀនដាំបន្លែ និងផ្តល់ពូជបន្លែតាមគ្រួសារ បានចំនួន ៦៦០គ្រួសារ<br>▪ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការបង្កើតសួនបន្លែតាមផ្ទះនិងបច្ចេកទេសដាំដុះ ចំនួន ០៣វគ្គ នៅខេត្តស្ទឹងត្រែង ក្រចេះ និងខេត្តព្រៃវែង ដែលមានអ្នកចូលរួម ១៦០នាក់ ។<br>- គណៈកម្មាធិការផលិតភាពកម្ពុជា (គ.ផ.ក.)÷<br>▪ ក្នុងក្របខណ្ឌសិក្សាស្រាវជ្រាវគោលនយោបាយបែបវិទ្យាសាស្ត្រ សម្រាប់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្រាប់ឆ្នាំ២០១៧ និង២០១៨ គ.ផ.ក. បានសិក្សាស្រាវជ្រាវលើគម្រោងចំនួន០៥÷ (១) ឥទ្ធិពលនៃកំណើនប្រាក់ឈ្នួលអប្បបរមាលើសុខុមាលភាព និងផលិតភាពពលកម្មរបស់កម្មករក្នុងវិស័យកាត់ដេរនៅកម្ពុជា ឆ្នាំ២០១៧ និងឆ្នាំ២០១៨, (២) ការបង្កើនភាតព្វកិច្ច និងភារកិច្ចរបស់សហជីព ដើម្បីគាំទ្រកំណើនសេដ្ឋកិច្ចផលិតភាពពលកម្ម និងភាពប្រកួតប្រជែងរបស់កម្ពុជា, (៣) ការងារទីផ្សារពលកម្ម និន្នាការកម្លាំងពលកម្ម និងផលិតភាពជាតិ, (៤) ភាគលាភប្រជាសាស្ត្រ និងគណនេយ្យបង្វែរថ្នាក់ជាតិ និង (៥) ឥទ្ធិពលនៃបដិវត្តន៍ឧស្សាហកម្មជំណាក់ | |

| | វិធានការជាក់ស្ដែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | កាលទី៤.០ លើទីផ្សារពលកម្ម និងការអភិវឌ្ឍជំនាញនៅកម្ពុជា<br>▪ បានបំពេញកម្មវិធីមិនមែនគម្រោងសិក្សាស្រាវជ្រាវចំនួន០៣ រួមមាន÷(១) កម្មវិធីអភិវឌ្ឍធនធានមនុស្សសម្រាប់ភ្នាក់ងារជំនាញជាតិចំនួន៨លើក លើ៨ប្រធានបទ រួមមាន÷ ១. ការគ្រប់គ្រងខ្សែចង្វាក់ផ្គត់ផ្គង់, ២. តួនាទីទីផ្សារ, ៣. យុទ្ធសាស្ត្រឧស្សាហកម្ម, ៤. ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកម្មន្តសាល, ៥. ទស្សនវិស័យសាជីវកម្ម÷ វិស័យសាធារណៈ និងវិស័យឯកជន, ៦. ការអភិវឌ្ឍផែនការអាជីវកម្ម, ៧. យុទ្ធសាស្ត្រលក់ និងទីផ្សារ, និង ៨. ការគ្រប់គ្រង និងបែងចែកពេលវេលា, (២) សិក្ខាសាលាប្រឹក្សាយោបល់ និងចែករំលែកចំណេះដឹងស្តីពី “គំហើញនៃគម្រោងសិក្សាស្រាវជ្រាវរបស់ ត.ជ.ក ក្នុងឆ្នាំ២០១៧” ដែលមានប្រធានបទពិភាក្សាចំនួន ០២គឺ÷ ១. ឥទ្ធិពលនៃប្រាក់ឈ្នួលអប្បបរមាលើសុខុមាល-ភាព និងផលិតភាពពលកម្មរបស់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើងនៅកម្ពុជា សម្រាប់ឆ្នាំ២០១៧, និង ២. ការបង្កើនកាតព្វកិច្ច និងភារកិច្ចរបស់សហជីព ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ផលិតភាព | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ពលកម្ម និងភាពប្រកួតប្រជែងនៅកម្ពុជា, (៣) សិក្ខាសាលាប្រឹក្សាយោបល់ និងចែករំលែកចំណេះដឹងស្តីពី "ការបង្កើនផលិតភាពពលកម្មនៅកម្ពុជា" ដែលមានប្រធានបទពិភាក្សាចំនួន ៦គឺ ÷ ១. ភាគលាភប្រជាសាស្ត្រនៃកម្លាំងពលកម្មនៅកម្ពុជា, ២. ផលិតភាពរបស់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា÷ កិច្ចប្រឈម និងដំណោះស្រាយ, ៣. អភិបាលកិច្ចល្អនៅក្នុងវិស័យឯកជន ÷ កិច្ចប្រឈម និងការឆ្លើយតប, ៤. ផលិត-ភាពនៅក្នុងវិស័យសាធារណៈ÷ កិច្ចប្រឈមលើមូលធនមនុស្សក្នុងស្ថាប័នរដ្ឋ និងយុទ្ធសាស្ត្រដោះស្រាយ, ៥. ផលិតភាពពលកម្មក្នុងវិស័យកាត់ដេរនៅកម្ពុជា, និង ៦. កិច្ចប្រឈម និងការឆ្លើយតបរបស់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា<br>▪ បានជំរុញ និងគាំទ្រវិទ្យាសាស្ត្រគោលនយោបាយ (policy sciences) ដើម្បីក្តាប់យកភាពជាម្ចាស់លើការសិក្សាស្រាវជ្រាវគោលនយោបាយ និងបង្កើតគោលនយោបាយជាតិ<br>▪ បានបង្កើនការយល់ដឹងអំពីរចនាសម្ព័ន្ធសេដ្ឋកិច្ច, វប្បធម៌គ្រប់គ្រង, គំរូផលិតកម្ម និងគំរូធុរកិច្ចនៅតាមភូមិសាស្ត្រសេដ្ឋកិច្ចនានាក្នុងប្រទេសកម្ពុជា | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានបង្កើនចំណេះដឹងលើវិធីសាស្ត្រស្វែងរក និងប្រមូលទិន្នន័យមីក្រូ សម្រាប់វាស់វែងបច្ច័យគោលនយោបាយក្នុងកម្រិតមីក្រូ<br>▪ បានជំរុញឱ្យមានការកែលម្អអភិបាលកិច្ចទីផ្សារសម្រាប់កម្ពុជា<br>▪ បានជំរុញកំណើនផលិតភាពជាតិសរុប (Total Factor Productivity-TFP) និងឧត្តមភាពប្រកួតប្រជែង ដើម្បីកសាងសេដ្ឋកិច្ចដែលមានតម្លៃបន្ថែម និងផលិតភាពខ្ពស់<br>▪ បានជំរុញការធ្វើទំនើបកម្មលើគំរូផលិតកម្ម, គំរូសេដ្ឋកិច្ច និងគំរូធុរកិច្ចនៅកម្ពុជា ដើម្បីជំរុញផលិតភាពសេដ្ឋកិច្ច (productive economy)<br>▪ បានជំរុញវប្បធម៌ផលិតភាព និងវប្បធម៌វិទ្យាសាស្ត្រសម្រាប់ធ្វើនវានុវត្តកម្មលើអភិក្រមការងារក្នុងវិស័យសាធារណៈ និងឯកជន<br>▪ បានអភិវឌ្ឍ និងអនុវត្តកម្មវិធីវិទ្យាសាស្ត្រទិន្នន័យ (data science) ដើម្បីប្រសិទ្ធភាពក្នុងការវាស់វែង និងវាយតម្លៃសមិទ្ធផលគោលនយោបាយលើសុខុមាលភាពប្រជាពលរដ្ឋ និងប្រទេសជាតិក៏ដូចជាតម្លាតនៃការអនុវត្តគោលនយោបាយទាំងកម្រិតមីក្រូ និងម៉ាក្រូ | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានពង្រឹងការសិក្សា និងវាស់វែងពីឥទ្ធិពល និងបច្ច័យរបស់ IDP លើសេដ្ឋកិច្ចឧស្សាហកម្ម, ស្ថិរភាពនៃការផ្គត់ផ្គង់កម្លាំងពលកម្ម, ការផ្ទេរចំណេះដឹង និងជំនាញវិជ្ជាជីវៈ, ការជំរុញផលិត-ភាព និងការកែលម្អកម្រិតជីវភាពរស់នៅ<br>▪ បានជំរុញកិច្ចសហប្រតិបត្តិការអន្តរក្រសួង-ស្ថាប័ន ដើម្បីកែលម្អយន្តការភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន (PPP) លើការទទួលខុសត្រូវរួមក្នុងការវិនិយោគលើមូលធនមនុស្ស និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម<br>▪ បានចូលរួម និងវិភាគទានចំណេះដឹងវិទ្យាសាស្ត្រ និងយុទ្ធសាស្ត្រអនុវត្ត ក៏ដូចជាយុទ្ធសាស្ត្រឆ្លើយតបគោលនយោបាយជូនអន្តរក្រសួងស្ថាប័នពាក់ព័ន្ធនឹងផលិតភាពសេដ្ឋកិច្ច<br>▪ បានជំរុញការកែលម្អប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ និងការតភ្ជាប់អន្តរក្រសួង-ស្ថាប័ន ក្នុងក្របខណ្ឌសហប្រតិបត្តិការយុទ្ធសាស្ត្រគោលនយោបាយ (policy connectedness and policy coordination)<br>▪ បានបង្កើនការយល់ដឹង និងចែករំលែកចំណេះដឹងជូនមន្ត្រីសាធារណៈអំពីការរៀបចំយុទ្ធសាស្ត្រ | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ត្រៀមខ្លួនឆ្លើយតបទៅលើឥទ្ធិពលនៃបដិវត្តន៍ឧស្សាហកម្មដំណាក់កាលទី៤.០<br>▪ បានបង្កើនកម្រិតចំណេះជំនាញ និងយល់ដឹងស៊ីជម្រៅជូនភ្នាក់ងារជំនាញជាតិលើចក្ខុវិស័យ និងទស្សនវិស័យអំពីបច្ច័យនៃគោលនយោបាយម៉ាក្រូលើសេដ្ឋកិច្ច និងហិរញ្ញវត្ថុគ្រួសាររបស់កម្មករក្នុងវិស័យកាត់ដេរ<br>▪ បានបង្កើនគុល្យភាពសារនយោបាយ ដើម្បីបន្សាបគំនិតអគតិរបស់សហជីពក្នុងវិស័យកាត់ដេរ លើស្ថាប័នពលកម្មកម្ពុជា<br>▪ បានផ្តល់ការយល់ដឹងលើភាពចាំបាច់នៃផលិតភាពពលកម្ម និងឧត្តមភាពប្រកួតប្រជែង ជូនមន្ត្រីអន្តរក្រសួងស្ថាប័នសាធារណៈ និងឯកជន នៅកម្រិតជាតិ និងតាមរាជធានី-ខេត្ត។<br>- រដ្ឋបាលខេត្តកណ្តាល៖ បានចូលរួមសហការជាមួយមន្ទីរឧស្សាហកម្ម និងសិប្បកម្ម និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការជំរុញកម្មវិធីនិងគម្រោងវិនិយោគសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេស និងជំនាញដែលមានការសម្របសម្រួលជាប្រព័ន្ធឆ្លើយតបនឹងតម្រូវការឧស្សាហកម្ម នៅឆ្នាំខាងមុខ។<br>- រដ្ឋបាលខេត្តព្រះសីហនុ៖ | |

| | វិធានការជាក់ស្តែងចម្បង | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងថវិកា | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានជំរុញ និងណែនាំជាប្រចាំដល់មន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យបន្តចុះការធ្វើអធិការកិច្ចតាមបណ្តារោងចក្រសហគ្រាសនៅក្នុងខេត្ត ដើម្បីផ្តល់លក្ខខណ្ឌការងាររបស់កម្មករនិយោជិក ឱ្យស្របទៅតាមច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តនានា និងជាពិសេសកែលម្អស្ថិរភាពទីផ្សារពលកម្ម និងកាត់បន្ថយចំនួនវិវាទការងារ<br>▪ បានអនុវត្តប្រាក់ឈ្នួលអប្បបរមាជូនដល់កម្មករនិយោជិតបាន ១០០% លើសហគ្រាសវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងចំនួន៥៣ សហគ្រាសគ្រឹះស្ថាន<br>▪ បានពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ÷ ការផ្សះផ្សាវិវាទការងារ និងទំនាក់ទំនងវិជ្ជាជីវៈ បានដោះស្រាយចំនួន៥០ករណី<br>▪ បានអភិវឌ្ឍ និងលើកកម្ពស់លក្ខខណ្ឌការងារ÷ នៅក្នុងឆ្នាំ២០១៨ មន្ទីរបានចុះធ្វើអធិការកិច្ចការងារលើលក្ខខណ្ឌការងារទូទៅ និងចាត់វិធានការចំពោះសហគ្រាសដែលបានប្រព្រឹត្តល្មើសច្បាប់ដូចតទៅ ធ្វើអធិការកិច្ចការងារសាមញ្ញ បានចំនួន៧២លើក និងធ្វើអធិការកិច្ចការងារពិសេសបាន | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ចំនួន ៥៧លើក ក្នុងនោះដាក់កំហិតបានចំនួន ៧៦ករណី និងផាកពិន័យ បានចំនួន៦ករណី<br>▪ បានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ÷ ចំនួនសហគ្រាសដែលបានចុះអធិការកិច្ចហ្វឹកហ្វឺនកូនជាងបានចំនួន៩៣ ក្នុងនោះចំនួនកូនជាងត្រូវបានហ្វឹកហ្វឺនសរុប១៥៦២នាក់ ផ្តល់វិញ្ញាបនបត្រនិងបណ្ណទទួលស្គាល់ជំនាញ ១៥០៨នាក់។ | |
| ទី៤ | អភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុ-បំណង ដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស ដោយរៀបចំផែនការមេសម្រាប់ការអភិវឌ្ឍ ក្របខណ្ឌច្បាប់ និងនិយតកម្ម ព្រមទាំងយន្តការគ្រប់គ្រងចាំបាច់នានា ដែលនឹងផ្តល់សិទ្ធិអំណាចនិងយុត្តាធិការពេញលេញសម្រាប់ការកៀរគរ ទាក់ទាញ និងប្រមូលផ្តុំនូវប្រភពធនធាន | - *ផែនការមេសម្រាប់ការអភិវឌ្ឍខេត្តព្រះ- សីហនុឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពហុបំណង*<br>- *ក្របខ័ណ្ឌច្បាប់ និងនិយតកម្ម*<br>- *យន្តការរដ្ឋបាល និងការគ្រប់គ្រង*<br>- *ផែនការប្រតិបត្តិ និងវិនិយោគ។* | ២០១៨ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ បាននិងកំពុងពិចារណាទៅលើសំណើរបស់តំណាងការិយាល័យនៃក្រសួងស្ថាប័នពាក់ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ទៅលើ (១) ការជំរុញអ្នកអភិវឌ្ឍន៍ឱ្យសាងសង់ប៉ុស្តិ៍យាមនៅត្រង់ច្រកចេញចូលតំបន់ ដើម្បីងាយ-ស្រួលត្រួតពិនិត្យទំនិញចេញ-ចូល, (២) ការរៀបចំកិច្ចប្រជុំប្រចាំខែរវាងការិយាល័យតំណាងក្រសួងស្ថាប័ន និងតំណាងក្រុមហ៊ុន, (៣) ការស្នើសុំបន្ថែមចំនួនមន្ត្រី និងថវិកាឧបត្ថម្ភ (ការិយា-ល័យតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) និង (៤) ការបង្កើនកិច្ចសហការគ្រប់ភាគីពាក់ព័ន្ធក្នុងរដ្ឋបាលតំបន់។ | - ក្រសួងពាណិជ្ជកម្ម÷ កង្វះខាតធនធានមនុស្ស និងធនធានហិរញ្ញវត្ថុសម្រាប់បន្តតាក់តែងសេចក្តីព្រាងច្បាប់ដែលមានការពាក់ព័ន្ធតាមកម្មវិធីដែលបានគ្រោង។<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ សមត្ថភាពធនធានមនុស្ស និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត។<br>- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល÷<br>▪ គ្មានកញ្ចប់ថវិកាសម្រាប់គាំទ្រដល់ផែនការសកម្មភាព |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | បញ្ញាញាណ សកម្មភាពធុរកិច្ចនិងវិនិយោគ ដើម្បីអភិវឌ្ឍខេត្តនេះឱ្យទៅជាប៉ូលសេដ្ឋកិច្ចសំខាន់មួយ និងជាមជ្ឈមណ្ឌលឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ ស្របតាមទស្សនាទាននៃការអភិវឌ្ឍប្រកបដោយចីរភាព និងមានគុណភាពបរិស្ថាន ព្រមទាំងឱ្យប្រែក្លាយជា**ទីក្រុងឧស្សាហកម្មបៃតងអាស៊ាន** នាពេលអនាគត។ | | | ▪ បានជំរុញ (១) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចក្រុងព្រះសីហនុ ដែលរួមមានអាងប្រព្រឹត្តិកម្មទឹកកខ្វក់, ផ្លូវថ្នល់, លូទឹក, សួនច្បារ, បណ្តាញទឹក-ភ្លើង, ការឈូសឆាយដី និងការសាងសង់រោងចក្រ និង (២) ការពង្រឹងសន្តិសុខក្នុងតំបន់ ទាំងថ្ងៃ ទាំងយប់។<br>▪ បានសម្របសម្រួលដំណើរទស្សនកិច្ចសិក្សាដោយអ្នកវិនិយោគក្នុងស្រុក និងក្រៅស្រុក ក្នុងតំបន់សេដ្ឋកិច្ចពិសេសក្នុងខេត្តព្រះសីហនុ ជាពិសេសតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ និងតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ ក្នុងគោលបំណងស្វែងយល់អំពីដំណើរការរបស់តំបន់, ស្ថានភាពនៃការវិនិយោគ និងការអភិវឌ្ឍនៅក្នុងតំបន់, ព្រមទាំងសក្តានុពលក្នុងតំបន់។<br>▪ បានសម្របសម្រួលការសិក្សាស្រាវជ្រាវ ដោយស្ថាប័នជាតិ និងអន្តរជាតិ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងខេត្តព្រះសីហនុ ជាពិសេស តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ និងតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ ក្នុងគោលបំណងស្វែងយល់អំពីការកែប្រែក្រុងព្រះសីហនុទាំងមូលឱ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណង | ▪ ពុំមានមន្ត្រីជំនាញ សកម្មគ្រប់គ្រាន់សម្រាប់បំពេញការងារ<br>▪ ពុំមានទីប្រឹក្សាសម្រាប់រៀបចំផែនការ។ |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានទាក់ទាញអ្នកវិនិយោគទាំងក្នុងនិងក្រៅប្រទេស ដើម្បីឱ្យចូលមកវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស (តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ និងតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ)<br>▪ បានដឹកនាំកិច្ចប្រជុំសម្របសម្រួលវិវាទរបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់<br>▪ បានចូលរួមសម្រួលឱ្យមានដំណើរការបន្ថែមទៀតនូវគម្រោងវិនិយោគចំនួន ១៨គម្រោងដែលមានទុនវិនិយោគប្រមាណជា ៣០០លានដុល្លារ និងបង្កើតការងារប្រមាណជា ៧.០០០កន្លែង នៅតំបន់សេដ្ឋកិច្ចពិសេសក្នុងខេត្តព្រះសីហនុ(តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ មាន១៧គម្រោងស្មើនឹង ៤៣លានដុល្លារ និងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុទី១ មាន ១គម្រោង ស្មើនឹង ២៥៩លានដុល្លារ) ក្នុងឆ្នាំ២០១៧<br>▪ បាននិងកំពុងសិក្សាស្រាវជ្រាវ និងប្រមូលធាតុចូលលើប្រធានបទនៃការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនៅបណ្តាប្រទេសជិតខាងជឿនលឿនមួយចំនួន។<br>ក្នុងឆ្នាំ២០១៨÷ | |

| | វិធានការដាក់ស្នើឧបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បាននិងកំពុងធ្វើការស្រាវជ្រាវ និងរៀបចំឯកសារសំយោគស្តីពីការប្រែក្លាយខេត្តព្រះសីហនុ ជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណង<br>▪ ចូលរួមពិគ្រោះយោបល់ និងផ្តល់ធាតុចូលលើសេចក្តីព្រាងរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាពគម្រោងអភិវឌ្ឍន៍កំពង់ផែទេសចរណ៍ខេត្តព្រះ-សីហនុ អនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន<br>▪ បានសហការជាមួយអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO) ដើម្បីរៀបចំវេទិកាចែករំលែកបទពិសោធន៍ស្តីពីកិច្ចអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសនៅទីក្រុងសិនជិន ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ<br>▪ បានធ្វើការស្រាវជ្រាវ និងរៀបចំជំនួយស្មារតីស្តីពីតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ សម្រាប់ដាក់ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា<br>▪ បានចូលរួមសម្របសម្រួលបង្កើត និងដាក់ឱ្យមានដំណើរការបន្ថែមទៀតនូវតំបន់សេដ្ឋកិច្ចចំនួន ៣ នៅក្នុងខេត្តព្រះសីហនុ | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានចូលរួមសម្របសម្រួលរៀបចំកិច្ចប្រជុំរវាងតំណាងកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងតំណាងពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់រាជរដ្ឋាភិបាលជប៉ុន (JICA) ប្រចាំនៅកម្ពុជា ដើម្បីរៀបចំ និងកំណត់យុទ្ធសាស្ត្រស្វែងរកទីផ្សារ និងការផ្សព្វផ្សាយតំបន់សេដ្ឋកិច្ចកំពង់ផែស្វយ័តក្រុងព្រះសីហនុ<br>▪ បាននិងកំពុងបន្តពិចារណាទៅលើសំណើរបស់តំណាងការិយាល័យនៃក្រសួងស្ថាប័នពាក់ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុទៅលើ (១) ការជំរុញអ្នកអភិវឌ្ឍន៍ឱ្យសាងសង់ប៉ុស្តិ៍យាមនៅត្រង់ច្រកចេញចូលតំបន់ ដើម្បីងាយស្រួលត្រួតពិនិត្យទំនិញចេញ-ចូល, (២) ការរៀបចំកិច្ចប្រជុំប្រចាំខែរវាងការិយាល័យតំណាងក្រសួងស្ថាប័ន និងតំណាងក្រុមហ៊ុន ព្រមទាំង (៣) ការបង្កើនកិច្ចសហការគ្រប់ភាគីពាក់ព័ន្ធក្នុងរដ្ឋបាលតំបន់។ ជាមួយគ្នានោះ បាននិងកំពុងពិចារណាទៅលើសំណើពាក់ព័ន្ធនឹងការកែសម្រួលប្រាក់ឧបត្ថម្ភឱ្យស្របតាមស្ថានភាពជាក់ស្តែង។<br>▪ បានបន្តជំរុញ (១) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចក្រុងព្រះសីហនុ ដែលរួម | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងចូលរួមអនុវត្ត | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | មានរោងចក្រ, ផ្លូវថ្នល់, លូទឹក, សួនច្បារ, បណ្តាញទឹក-ភ្លើង, និងការឈូសឆាយដី និង (២) ការពង្រឹងសន្តិសុខក្នុងតំបន់ ទាំងថ្ងៃ ទាំងយប់<br>▪ បានចូលរួមសម្រួលឱ្យមានដំណើរការបន្ថែមទៀតនូវគម្រោងវិនិយោគចំនួន ៤៤គម្រោងដែលមានទុនវិនិយោគប្រមាណជា ២៧៩លានដុល្លារ និងបង្កើតការងារប្រមាណជា ១១.៥០០កន្លែង នៅតំបន់សេដ្ឋកិច្ចពិសេសក្នុងខេត្តព្រះសីហនុ (តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ មាន ៤៣គម្រោង ស្មើនឹង ២៧៩លានដុល្លារ និងតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ មាន ១ គម្រោង ស្មើនឹង ៣៧ម៉ឺនដុល្លារ) ក្នុងឆ្នាំ២០១៨។<br>ក្រសួង/ ស្ថាប័នចូលរួម÷<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>ក្នុងឆ្នាំ២០១៧-២០១៨÷<br>▪ បានកសាងផែនការមេជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា កម្ពុជាឆ្នាំ២០១៤-២០២០ និងចូលរួមកសាងផែនការសកម្មភាពផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០១៦-២០២៥<br>▪ បានសម្របសម្រួលជាមួយអង្គការ UNIDO ក្នុងការរៀបចំបង្កើតគម្រោងកម្មវិធីកិច្ចសហប្រតិបត្តិការភាពជាដៃគូរបស់ប្រទេស (Programme for | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងយន្តការ | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | Country Partnership - PCP)នៅកម្ពុជាតាម-រយៈការចុះហត្ថលេខាលើសេចក្តីព្រាងប្រកាសរួមចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្នុងនោះបាននាំទៅដល់គម្រោងបង្កើតកិច្ចសហប្រតិបត្តិ-ការនានាក្រោមក្របខណ្ឌ PCP ក្នុងនោះមានគម្រោងបង្កើតផែនការមេដើម្បីអភិវឌ្ឍន៍ខេត្តព្រះសីហនុ តំបន់សេដ្ឋកិច្ចពិសេសពហុបំណងក្រោមជំនួយបច្ចេកទេសរបស់សាធារណរដ្ឋប្រជាមានិតចិន តាមរយៈក្រុមការងារបច្ចេកទេសនៃវិទ្យាស្ថានផែនការនគរូបនីយកម្ម និងរចនាបថរបស់ទីក្រុងស៊ិនជិន (Urban Planning and Design Institution of Shenzen)<br>▪ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីសុវត្ថិភាព ការផ្ទេរបច្ចេកវិទ្យា និងបរិស្ថានឧស្សាហកម្ម ដល់រោងចក្រ សហគ្រាសក្នុងស្រុកបានចំនួន ០៥ដង ដោយមានសិក្ខាកាមចូលរួមចំនួន ៥២៨នាក់ ដើម្បីបញ្ជ្រាបចំណេះដឹងដល់កម្មករនិយោជិតពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា<br>▪ បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគ-យល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការផ្ទេរបច្ចេកវិទ្យារវាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម ជាមួយ | |

| | វិធានការដាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | សួនបច្ចេកវិទ្យា Daegu Technopark នៃសាធារណរដ្ឋកូរ៉េ<br>▪ បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការជំរុញលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យានៅកម្ពុជា ដោយសម្រេចបាន ២៥%។<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់÷<br>▪ បានរៀបចំផែនការសកម្មភាពការងារឆ្នាំ២០១៥-២០២៥ ក្នុងការចុះគាំទ្របច្ចេកទេសរៀបចំប្លង់គោល និងផែនការប្រើប្រាស់ដីទីក្រុង ស្រុក និងទីប្រជុំជន តាមលំដាប់អាទិភាពអនុវត្ត IDP<br>▪ បានរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តព្រះសីហនុ និងផែនការប្រើ-ប្រាស់ដីនៅក្នុងឃុំចំនួន២គឺ ឃុំរាម និងឃុំអូរឧកញ៉ាហេង ក្នុងខេត្តព្រះសីហនុ<br>▪ បានរៀបចំ និងកំពុងស្នើសុំការអនុម័តពីគណៈ-រដ្ឋមន្ត្រី ផែនការរៀបចំដែនដីតំបន់ឆ្នេរ ដោយទទួលបានការឯកភាពពីគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា និងគណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្មថ្នាក់ជាតិរួច | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងចងក្រងគោលនយោបាយ | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បាននិងកំពុងរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីក្រុងព្រះសីហនុ និងស្រុកស្ទឹងហាវ<br>▪ បានបញ្ចប់ការរៀបចំ និងកំពុងស្នើសុំការសម្រេចដាក់ឱ្យប្រើប្រាស់ប្លង់មេឆ្នេរអូរត្រេះ ព្រមទាំងកំពុងរៀបចំប្លង់លម្អិតនត្យូបនីយកម្មស្តីពីកម្ពស់អគារក្នុងតំបន់ឆ្នេរអូរត្រេះ<br>▪ បាននិងកំពុងរៀបចំផែនការប្រើប្រាស់ដីចំណីឆ្នេរ ០៦ទីតាំងគឺ ឆ្នេរម្លប់ជ្រៃ ឆ្នេរកោះពស់ ឆ្នេរឯករាជ្យ ឆ្នេរអូរឈើទាល ឆ្នេរអូរត្រេះ និងឆ្នេរកោះរុង<br>▪ បានរៀបចំបញ្ចប់ផែនការប្រើប្រាស់ដីតំបន់ពាយកំពេញ<br>▪ បាននិងកំពុងរៀបចំប្លង់គោលប្រើប្រាស់ដីកោះរ៉ុង កោះឫស្សី និងកោះក្របី<br>▪ បាននិងកំពុងរៀបចំប្លង់កែលម្អឆ្នេរអូរឈើទាល<br>▪ បាននិងកំពុងរៀបចំផែនការប្រើប្រាស់ដីតំបន់បឹងព្រៃកទប់<br>▪ បានរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់ប្លង់ស្ថាបត្យកម្មខ្លោងទ្វារច្រកចូលឆ្នេរចំនួន០៨កន្លែង<br>▪ បានរៀបចំប្លង់ស្ថាបត្យកម្មតួបកម្សាន្តនៃគម្រោងកែលម្អឆ្នេរខ្សាច់កំសាន្ត | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់ផែនទីបណ្តាញផ្លូវថ្នល់ ឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ និងបណ្តាញប្រភពទឹកនៅកោះរ៉ុង<br>▪ បាននិងកំពុងរៀបចំផែនទីដីចំណីឆ្នេរសមុទ្រ និងបែងចែកប្រភេទឆ្នេរសមុទ្រ<br>▪ បានចុះវាស់វែង ដាំបង្គោលប្រថពីវិភាគ និងរៀបចំផែនទីរូបថតពីលើអាកាសនៅតាមកោះ<br>▪ បាននិងកំពុងរៀបចំផែនទីប្រភេទឆ្នេរសមុទ្រ<br>▪ បានចុះសិក្សា និងវាស់វែងកំណត់ទីតាំងសម្រាប់ការសាងសង់ខ្លោងទ្វារច្រកចូល ឆ្នេរឯករាជ្យ ឆ្នេរម្លប់ជ្រៃ ឆ្នេរកោះពស់ ឆ្នេរអូរឈើទាល ឆ្នេរអូរត្រេះ ឆ្នេរអូរឈើទាល២ និងពយកំពេញ<br>▪ បានចុះត្រួតពិនិត្យទប់ស្កាត់សកម្មភាពចាក់ដីរំលោភចូលឆ្នេរសមុទ្រនៅឆ្នេរព្រែកត្រែង ដោយតម្រូវឱ្យកាយយកដីចេញវិញ ដើម្បីរក្សាឆ្នេរធម្មជាតិដូចដើម<br>▪ បានចុះត្រួតពិនិត្យការដ្ឋានសាងសង់ និងរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់ អាងបង្គន់អនាម័យ និងប្រព័ន្ធលូ សម្រាប់ការអភិវឌ្ឍដីនិងសំណង់ នៅតំបន់ឆ្នេរសមុទ្រ<br>▪ បាននិងកំពុងអនុវត្តគម្រោងសាងសង់ស្ថានីយបូមទឹកកខ្វក់ចំនួន ៤ ទីតាំងគឺ÷ ស្ថានីយទី១នៅ | |

| | ទិដ្ឋភាពការងារជាក់ស្តែងចម្បង | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងថវិកា | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ឆ្នេរឯករាជ្យ ស្ថានីយទី២នៅឆ្នេរសុខា ស្ថានីយទី៣នៅអូរសម្អាត និងស្ថានីយទី៤នៅឆ្នេរអូរឈើទាល និងការងារដាក់ទុយោបញ្ជូនទឹក និងដាក់លូបេតុងបង្ហូរទឹក<br>▪ បានផ្តល់ម៉ាស៊ីនសំអាតឆ្នេរសមុទ្រចំនួន ៣គ្រឿងជូនរដ្ឋបាលខេត្តព្រះសីហនុ<br>▪ បានចុះត្រួតពិនិត្យនិងវាយតម្លៃឆ្នេរខ្សាច់នៅខេត្តព្រះសីហនុ សម្រាប់ការប្រឡងប្រណាំងឆ្នេរខ្សាច់កម្សាន្តស្អាតឆ្នាំ២០១៨ និងបានរៀបចំពិធីប្រកាសជ័យលាភីឆ្នេរខ្សាច់កម្សាន្តស្អាត<br>▪ បានចែកបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋក្នុងខេត្តព្រះសីហនុសរុបចំនួន ២៩ ០៩២ បណ្ណ<br>▪ កំពុងដោះស្រាយវិវាទដីធ្លីក្នុងខេត្តព្រះសីហនុសរុបចំនួន ១៤០ករណី។<br>▪ បានផលិតអ័រតូហ្វតូរូបថតពីលើអាកាសមាត្រដ្ឋាន ១:៤០០០ នៅខេត្តព្រះសីហនុ<br>▪ បានពិនិត្យ និងផ្តល់លិខិតអនុញ្ញាតសាងសង់ជូនប្រជាពលរដ្ឋក្នុងខេត្តព្រះសីហនុចំនួន ៥៨៥ គម្រោង<br>▪ បានសហការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រៀបចំនិងទទួលបានការអនុម័តពីរាជរដ្ឋាភិបាល លើគោលនយោបាយស្តីពីការលើកទឹក- | |

| | វិធានការដាក់ស្នើងបូន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ<br>▪ បានសហការជាមួយអាជ្ញាធរខេត្តព្រះសីហនុ ក្នុងការចុះសិក្សាតំបន់ដែលរងគ្រោះដោយទឹកជំនន់ និងខ្យល់កន្ត្រាក់នៅស្រុកស្ទឹងហាវ ស្រុកកំពង់សិលា និងស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជ្រើស-រើសទីតាំងសមស្រប ដើម្បីសាងសង់លំនៅឋានដែលធន់នឹងគ្រោះទឹកជំនន់ និងខ្យល់កន្ត្រាក់<br>▪ បានរៀបចំបទដ្ឋានបច្ចេកទេសស្តីពីការអភិវឌ្ឍកោះនៅតំបន់ឆ្នេរសមុទ្រកម្ពុជា និងកំពុងស្នើសុំការសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ<br>▪ បាននិងកំពុងរៀបចំច្បាប់ និងក្របខណ្ឌគតិយុត្តដើម្បីគាំទ្រដល់ការគ្រប់គ្រង ការអភិវឌ្ឍ និងការសាងសង់ ដូចជាច្បាប់សំណង់ ច្បាប់រៀបចំដែនដី និងនគរូបនីយកម្ម ច្បាប់គ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា និងបទដ្ឋានគតិយុត្តមួយចំនួនទៀត ដើម្បីគាំទ្រដល់ការអនុវត្ត IDP ។<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានបន្តចូលរួមសម្រួលកិច្ចដំណើរការរោងចក្រ និងក្រុមហ៊ុនជាង១៥០នៅតំបន់សេដ្ឋកិច្ចពិសេសនានាក្នុងខេត្តព្រះសីហនុ<br>▪ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីនីតិវិធីគយពិសេស និងនីតិវិធីគយផ្សេងៗទាក់ទងនឹងការអនុវត្តការងារដល់ធុរជន និងជើងសារក្នុងតំបន់សេដ្ឋកិច្ចពិសេសបានចំនួន ០២ លើក (ការិយាល័យគយនិងរដ្ឋាករតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ)<br>▪ ៣កំពុងរៀបចំផែនការមេគម្រោងប្រព័ន្ធលូ និងប្រព្រឹត្តកម្មទឹកកខ្វក់ នៅខេត្តព្រះសីហនុ។<br>- ក្រសួងទេសចរណ៍ ÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ អនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ខេត្តព្រះសីហនុ ២០១៦-២០២៥ បានអនុវត្តលើការរៀបចំសម្អាតឆ្នេរ, ការចូលរួមគ្រប់គ្រងកាកសំណល់រឹងរាវ និងបរិស្ថានតាមឆ្នេរខេត្តព្រះសីហនុ, និងការរៀបចំបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងឆ្នេរ<br>▪ បានជំរុញការគ្រប់គ្រងសេវាកម្ម អាជីវកម្មទេសចរណ៍ នៅខេត្តព្រះសីហនុ តាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការ សេវាករ និងប្រតិបត្តិករ | |

| | វិធានការជាក់ស្តែងចម្បង | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងចូលរួមអនុវត្ត | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ទេសចរណ៍, ការអប់រំការយល់ដឹងវគ្គសិក្សាខ្លីៗ ការបង្កើតឆ្នាំសមុទ្រ និងមគ្គុទ្ទេសក៍ទេសចរណ៍ខេត្តព្រះសីហនុ, និងការពង្រឹងយន្តការគ្រប់គ្រង និងអភិវឌ្ឍន៍ខេត្តព្រះសីហនុ តាមរយៈយន្តការគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ខេត្ត<br>▪ បានសហការយ៉ាងជិតស្និទ្ធជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងការរៀបចំគម្រោងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍សម្រាប់កំណើនប្រកបដោយបរិយាប័ន្ន ក្នុងមហាអនុតំបន់មេគង្គវគ្គ២ “GMS Tourism Infrastructure for Inclusive Growth Stage II”<br>▪ បានរៀបចំបង្កើតក្រុមការងារអន្តរក្រសួង និងផ្នែកពាក់ព័ន្ធនានា សម្រាប់សម្របសម្រួលក្នុងការរៀបចំ “គម្រោងទេសចរណ៍នាគរាជ”<br>▪ បានរៀបចំគម្រោងអភិវឌ្ឍន៍តំបន់ទេសចរណ៍ពិសេស “គម្រោងទេសចរណ៍នាគរាជ” ដែលរាជរដ្ឋាភិបាលបានសម្រេចឱ្យក្រសួងទេសចរណ៍ដឹកនាំក្នុងការសិក្សារៀបចំគម្រោងអភិវឌ្ឍន៍ទេសចរណ៍នាគរាជ នៅខេត្តព្រះសីហនុ | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ កំពុងរៀបចំកសាងផែនការវិនិយោគទេសចរណ៍តំបន់ឆ្នេរ ក្នុងនោះមានការផ្តោតការយកចិត្តទុកដាក់ខ្ពស់នៅខេត្តព្រះសីហនុ<br>▪ ទទួលទេសចរបានចំនួន ១.៩៩៥.២០៤នាក់ ក្នុងនោះទេសចរជាតិមានចំនួន ១.៥២៥.២៨៦នាក់ កើនឡើង ១៦% និងទេសចរអន្តរជាតិចំនួន ៤២២.៩០៣ កើនឡើងចំនួន ១៥% ទីផ្សារធំជាងគេគឺទីផ្សារទេសចរចិន<br>▪ មានសណ្ឋាគារចំនួន ៦៩ និងមានបន្ទប់ចំនួន ៣.៥២១<br>▪ មានផ្ទះសំណាក់ចំនួន ៣២១ និងមាន ៤.១៣២ បន្ទប់<br>▪ បានប្រគល់ម៉ាស៊ីនបោសសំអាតឆ្នេរ និងខ្សាច់ចំនួន០២គ្រឿងជូនមន្ទីរទេសចរណ៍។<br>ក្នុងឆ្នាំ២០១៨÷<br>▪ បានពិនិត្យ និងកំពុងធ្វើបច្ចុប្បន្នភាពឡើងវិញលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ខេត្តព្រះសីហនុ ២០១៦-២០២៥ ទៅជាផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ខេត្តព្រះសីហនុ ២០២០-២០២៥<br>▪ គម្រោងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍សម្រាប់កំណើនប្រកបដោយបរិយាប័ន្ន ក្នុងមហាអនុតំបន់ | |

| | វិធានការដាក់ស្នើឧបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | មេគង្គវគ្គ២ "GMS Tourism Infrastructure for Inclusive Growth Stage II" ដែលគាំទ្រហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ីត្រូវបានដាក់ឱ្យអនុវត្ត<br>▪ បន្តសកម្មភាពសិក្សា និងអនុវត្តគម្រោងអភិវឌ្ឍន៍តំបន់ទេសចរណ៍ពិសេស "គម្រោងទេសចរណ៍នាគរាជ" ដែលរាជរដ្ឋាភិបាលបានសម្រេចឱ្យក្រសួងទេសចរណ៍ ដឹកនាំក្នុងការសិក្សារៀបចំគម្រោងអភិវឌ្ឍន៍ទេសចរណ៍នាគរាជ នៅខេត្តព្រះសីហនុ<br>▪ បង្កើតគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ខេត្តព្រះសីហនុ<br>▪ បានបើកវគ្គបណ្តុះបណ្តាលជូនមន្ត្រីមន្ទីរ និងផ្នែកឯកជន លើមុខវិជ្ជា "គេហកិច្ច ការិយាល័យជួរមុខ បារ និងភេសជ្ជៈ"<br>▪ ទទួលទេសចរបានចំនួន ២.០៤៧.៧៧៤នាក់ ក្នុងនោះទេសចរជាតិមានចំនួន ១.៤៦៦.៥៩០ នាក់ ថយចុះ៣,៨% និងទេសចរអន្តរជាតិចំនួន ៥៨១.១៤៨ កើនឡើងចំនួន២៣,៧% ទីផ្សារធំជាងគេគឺទេសចរចិន<br>▪ មានសណ្ឋាគារចំនួន ៨៤ និងមានបន្ទប់ចំនួន ៤.៤៧៨ | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ មានផ្ទះសំណាក់ចំនួន ២៨៩ និងមាន ៣.៣៥៩ បន្ទប់។<br>- ក្រសួងពាណិជ្ជកម្ម÷<br>▪ បានបញ្ចប់ការតាក់តែងសេចក្តីព្រាងច្បាប់មួយចំនួន ហើយបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យសម្រេច ក្នុងនោះមាន សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ការធ្វើវិសោធនកម្មច្បាប់កិច្ចសន្យាមានកិច្ចធានា និងសេចក្តីព្រាងច្បាប់ស្តីពី E-Commerce។ល។ ដើម្បីជួយសម្រួលដល់បរិយាកាសធុរកិច្ច និងវិនិយោគក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្ម<br>▪ បានបង្កើតបន្ថែមនូវស្ថានតំណាងពាណិជ្ជកម្មនៅបរទេស<br>▪ បានអនុម័តលើប្រកាសរួមស្តីពីការកែប្រែកម្រងសេវាសាធារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>▪ បានរៀបចំច្បាប់ឱបាស្រ័យពាណិជ្ជកម្ម និងត្រូវបានអនុម័តឱ្យប្រើប្រាស់ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០១៧ | |

| | វិធានការដាក់ស្ដែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធស្វ័យប្រវត្តិកម្ម ដូចជា ការចុះបញ្ជីក្រុមហ៊ុន ការស្នើសុំពាណិជ្ជនាម ការសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ និងការបង់កម្រៃសេវាសាធារណៈជូនរដ្ឋតាមប្រព័ន្ធធនាគារ<br>▪ បានធ្វើប្រតិភូកម្មជូនដល់មន្ទីរពាណិជ្ជកម្មខេត្តនៅតាមព្រំដែនចំនួន៤ក្នុងការចេញ C/O នាំចេញផលិតផលកសិកម្មទៅទីផ្សារ។<br>- ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព÷<br>▪ បានស្នើ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តមួយចំនួនរួមមាន÷ (១)អនុក្រឹត្យលេខ ២៣៥ អនក្រ.បក ស្ដីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ដែលអាចមានគោលដៅជំរុញឱ្យមានការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទឹកកខ្វក់ និងសំណល់រាវ ដែលនឹងអាចជួយដល់ការគ្រប់គ្រងសំណល់រាវពីតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្ម, (២ )អនុក្រឹត្យលេខ ២៣៨ អនក្រ.បក ស្ដីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម ដែលមានគោលដៅជំរុញការចូលរួមចំណែកពីវិស័យឯកជន ក្នុងការការពារបរិស្ថាន និងសង្គម, និង (៣)ប្រកាសលេខ ៤៤៥ ប្រក. | |

| | វិធានការជាក់ស្ដែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងទឡ្ហនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | បស្ថ ស្ដីពីការដាក់ឱ្យអនុវត្តវិធានការស្វ័យត្រួតពិនិត្យ និងស្វ័យរាយការណ៍បំពុល ដែលមានគោលដៅជំរុញម្ចាស់រោងចក្រ សហគ្រាសត្រូវអនុវត្តការត្រួតពិនិត្យ ការគ្រប់គ្រង និងការបញ្ចេញសំណល់ដោយខ្លួនឯង និងសហការផ្ដល់របាយការណ៍មកក្រសួងបរិស្ថាន<br>▪ បានកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រង តាមរយៈអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ការពន្លឿនដំណើរការរៀបចំក្រមបរិស្ថាន ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថាន ២០១៦-២០២៣<br>▪ បានផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុវត្តថវិកាកម្មវិធី ដើម្បីចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ដោយកំពុងតិតតួរ និងពិនិត្យលើការអនុវត្តសេវា-កម្មចុះបញ្ជី ការផ្ដល់អាជ្ញាបណ្ណ និងការកសាងឯកសារបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំមួយចំនួនពាក់ព័ន្ធការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស សុវត្ថិភាពផលិតកម្ម និងតំបន់ឧស្សាហ-កម្មផ្សេងៗទៀត | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ បានពង្រឹងការគ្រប់គ្រងគុណភាពបរិស្ថាន តាមរយៈការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន, អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក, អនុក្រឹត្យស្តីពីការបង្កើតមូលនិធិបរិស្ថាននិងសង្គម, អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, និងអនុក្រឹត្យស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក ដើម្បីការពារបរិស្ថាន និងលើកកម្ពស់ការវិនិយោគប្រកបដោយនិរន្តរភាព<br>▪ បានធ្វើបច្ចុប្បន្នភាពប្រភពបំពុលរោងចក្រសហគ្រាសនៅទូទាំង ប្រទេសមានចំនួន១១៨៤ ទីតាំង (២០១៨) ដែលក្នុងនោះបានចុះត្រួតពិនិត្យការបំពុលបរិស្ថានបានចំនួន២៣៩ករណី ដោះស្រាយបណ្តឹងការបំពុលបរិស្ថានចំនួន ១០ករណី ចេញលិខិតបញ្ជាកែលម្អការបំពុលបរិស្ថាន ២៣ករណី និងបានពិន័យអន្តរកាលលើបទល្មើសបំពុលបរិស្ថានចំនួន ១៣ករណី<br>▪ បានប្រជុំក្រុមការងារអន្តរក្រសួង ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង និងពេញលេញ ចំនួន ៥៩៧ គម្រោង ក្នុងនោះមាន IESIA ចំនួន ៣៨២ គម្រោង និង ESIA ចំនួន ២១៥ គម្រោង ដែល | |

| | វិធានការដាក់ស្នើឡើងវិញ | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ក្នុងនោះគម្រោងរដ្ឋមានចំនួន ៨០គម្រោង និងគម្រោងឯកជនចំនួន ៥១៧ គម្រោង<br>▪ បានរៀបចំលិខិតឯកភាពលើរបាយការណ៍វាយ-តម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង និងពេញលេញ ចំនួន ៤៧៦ គម្រោង ក្នុងនោះមាន IESIA ចំនួន ៣២៩ គម្រោង និង ESIA ចំនួន ១៤៧ គម្រោង ដែលក្នុងនោះគម្រោងរដ្ឋមានចំនួន ៧០គម្រោង និងគម្រោងឯកជនចំនួន ៤០៦ គម្រោង<br>▪ បានរៀបចំលិខិតឯកភាពលើកិច្ចសន្យាការពារបរិស្ថានបានចំនួន ១៩៨៨គម្រោង (ទិន្នន័យនេះគិតត្រឹមខែកក្កដា ឆ្នាំ២០១៩)<br>▪ បានសម្របសម្រួលបង្កើតក្រុមការងារអន្តរ-ក្រសួងពាក់ព័ន្ធដើម្បីសិក្សាវាយតម្លៃបទប្បញ្ញត្តិ និងគោលនយោបាយសារពើពន្ធសម្រាប់យាន-យន្តដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសកម្ពុជា<br>▪ បានបង្កើតក្រុមការងារបច្ចេកទេសវាយតម្លៃសក្តានុពល ថាមពលពន្លឺព្រះអាទិត្យដើម្បីពិនិត្យផ្តល់យោបល់ និងអនុសាសន៍ក្នុងការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងថាមពលកកើតឡើងវិញ និងចងក្រងការអនុវត្តគោលនយោបាយយុទ្ធ-សាស្ត្រ ផែនការសកម្មភាពពាក់ព័ន្ធនឹងថាមពល | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | កកើតឡើងវិញ។ លើសពីនេះ អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. បានរៀបចំរបាយការណ៍ស្តីពីការវាយតម្លៃសក្តានុពលអភិវឌ្ឍន៍បៃតងនៅកម្ពុជា (Green Growth Pontential Assessment Cambodia Country Report) និងបានរៀបចំបញ្ចប់របាយការណ៍ស្តីពីផលប៉ះពាល់សេដ្ឋកិច្ចសង្គម និងបរិស្ថាននៃការជំរុញវិស័យឧស្សាហកម្មបៃតងនៅកម្ពុជា (The Economic, Social and Environmental Impacts of Greening Industrial Sector in Cambodia) ផងដែរ<br>▪ បានសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្តីពីការធ្វើផែនការ និងប្រើប្រាស់បច្ចេកវិទ្យាដែលបញ្ចេញកាបូនតិច។ សមិទ្ធផលសំខាន់ៗដែលទទួលបានពីកិច្ចសហការនេះគឺ ក) បញ្ជីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យឧស្សាហកម្ម (ការផលិត និងការប្រើប្រាស់) ខ) បានសាកល្បងអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថាន (EMS) និងប្រព័ន្ធផលិតកម្មស្អាត និងប្រសិទ្ធភាពថាមពល (RECP) ដែលបានអនុវត្តដោយរោងចក្រឧស្សាហកម្មក្នុងគោលដៅកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និង គ) ការពង្រឹង | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | សមត្ថភាព និងការផ្សព្វផ្សាយអំពីវិធីសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មដែលបញ្ចេញកាបូនតិច។<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន៖ បាននិងកំពុងគម្រោងសិក្សាអំពីលទ្ធភាពនៃគម្រោង និងផែនការមេសម្រាប់បណ្តាញទឹកកខ្វក់ និងប្រព័ន្ធរំដោះទឹកក្រុងព្រះសីហនុ (ក្រុមហ៊ុន Beijing Urban Construction Group Co., Ltd.)។<br>- ទីស្តីការគណៈរដ្ឋមន្ត្រីបាន៖<br>▪ បានចូលរួមរៀបចំផែនការមេ និងគម្រោងនានាសម្រាប់អភិវឌ្ឍខេត្តព្រះសីហនុ<br>▪ ចូលរួមរៀបចំក្របខណ្ឌច្បាប់ និយ័តកម្ម និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងយន្តការគ្រប់គ្រងចាំបាច់នានា ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយជាប៉ូលសេដ្ឋកិច្ចសំខាន់និងជាមជ្ឈមណ្ឌលឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍។<br>- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល៖<br>ក្នុងឆ្នាំ២០១៦៖<br>▪ បានពិភាក្សាជាមួយមន្ត្រីជំនាញតំណាងក្រុមហ៊ុនខេមបូឌៀ អ៊ែផត (SCA) មន្ត្រីជំនាញតំណាងក្រុមហ៊ុនខាមបូឌៀ អ៊ែរត្រាហ្វិកសឺវីស (CATS) និងនាយកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះ- | |

| | វិធានការដាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | សីហនុដើម្បីសិក្សាពីផែនការអភិវឌ្ឍន៍សេវាកម្មអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ<br>▪ បានធ្វើការផ្សព្វផ្សាយគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ជូនមន្ត្រីជំនាញកំពុងបម្រើការនៅអាកាសយានដ្ឋានអន្តរ-ជាតិខេត្តព្រះសីហនុ<br>▪ បាននិងកំពុងរៀបចំសេចក្តីព្រាងផែនការសកម្មភាព ២០១៨-២០២៥ លើវិស័យអាកាស-ចរស៊ីវិល ដើម្បីចូលរួមអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណង។<br>ក្នុងឆ្នាំ២០១៧÷<br>▪ បាននិងកំពុងរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអាកាសចរស៊ីវិល ឆ្នាំ២០១៨-២០២៥<br>▪ បាននិងកំពុងរៀបចំសេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០១៨-២០២៥ លើវិស័យអាកាសចរស៊ីវិលដើម្បីចូលរួមអភិវឌ្ឍន៍ខេត្តព្រះសីហនុឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពហុបំណង<br>▪ អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ បានសង់ផ្លូវបរថ្មីចំនួន ១ ជាសរុបបច្ចុប្បន្ន មាន ២ផ្លូវបរ ជួសជុលពង្រីកចំណតយន្តហោះសម្រាប់ប្រភេទ ៤C ចំនួន ២ចំណត សរុបមានចំនួន ៦ | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងថវិកា | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ចំណត បាននិងកំពុងសាងសង់ពង្រីកស្ថានីយ ដល់ ៤៧៨១ ម៉ែត្រការ៉េ ដែលអាចទទួលអ្នកដំណើរបានជាង ៥០ម៉ឺននាក់ក្នុងមួយឆ្នាំ បានបំពាក់ពោងខ្យល់ថ្មីចំនួន ១កន្លែងផងដែរ។<br>ក្នុងឆ្នាំ២០១៨៖<br>▪ បាននិងកំពុងរៀបចំផែនការសកម្មភាពឆ្នាំ ២០២៣-២០២៥ លើវិស័យអាកាសចរស៊ីវិល ដើម្បីចូលរួមអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពហុបំណង<br>▪ បាននិងកំពុងរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអាកាសចរស៊ីវិល២០១៩-២០២៣ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានរៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឆ្នាំ២០២០ ព្រមទាំងបានជំរុញសកម្មភាពមួយចំនួនទៀតដូចខាងក្រោម៖<br>ក្នុងឆ្នាំ២០១៧៖<br>▪ ក្រុមហ៊ុន CFOCN បានកសាងបណ្តាញខ្សែកាប្លីអុបទិកបានពង្រីកបន្ថែមខ្សែកាបអុបទិករហូតដល់ ប្រវែង ១៩.០០០ គ.ម ទូទាំងប្រទេស និងបានកសាងខ្សែកាប្លីអុបទិក ឆ្លងកាត់តំបន់សេដ្ឋ-កិច្ចពិសេសក្រុងព្រះសីហនុរួចរាល់ | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ▪ ក្រុមហ៊ុន Viettel Cambodia បានពង្រីកបន្ថែមខ្សែរកាប្លីអុបទិករហូតដល់ ២១.០០០ គ.ម ទូទាំងប្រទេស និងបានកសាងខ្សែរកាប្លីអុបទិកឆ្លងកាត់តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុបានរួចរាល់<br>▪ ទូរគមនាគមន៍កម្ពុជា (TC) មានបណ្តាញខ្សែកាប្លីអុបទិកសរុប ១.៦០០គ.ម នៅទូទាំងប្រទេសកម្ពុជា។<br>ក្នុងឆ្នាំ២០១៨÷<br>▪ ក្រុមហ៊ុន CFOCN បានស្ថាបនាបណ្តាញខ្សែកាប្លីអុបទិកបានប្រវែងសរុប ១៩.៣៧៩ គ.ម ទូទាំងប្រទេស÷<br>- បណ្តាញខ្សែកាប្លីអុបទិកឆ្អឹងខ្នងមានប្រវែង ៧.៨៧៧ គ.ម<br>- បណ្តាញខ្សែកាប្លីអុបទិកទ្រទ្រង់ខ្សែកាប្លីក្រោមបាតសមុទ្រមានប្រវែង ៤.៧៤៥ គ.ម (៣៨០ គ.ម ក្នុងប្រទេសកម្ពុជា)<br>- បណ្តាញខ្សែកាប្លីអុបទិកចូលស្ថានីយមានប្រវែង ៥.៧៤៩ គ.ម<br>- បណ្តាញតចូលគេហដ្ឋានប្រជាជនអ្នកប្រើ-ប្រាស់មានចំនួន ៣៤៦.០០០ ខ្សែ និងស្ថាបនាប្រព័ន្ធបំពង់ក្រោមដីមានប្រវែង ១.០២៦គ.ម។<br>▪ ក្រុមហ៊ុន Viettel Cambodia បានពង្រីកបណ្តាញខ្សែរកាប្លីអុបទិកថ្មីដែលមានប្រវែងសរុប | |

| | វិធានការជាក់ស្តែងបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងថវិកាភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | ២២.០០០គ.ម ទូទាំងប្រទេសសម្រាប់តំបន់សេដ្ឋ-កិច្ចពិសេសថ្មីៗ និងនៅខណ្ឌផ្លូវជាតិផ្សេងៗ<br>▪ ក្រុមហ៊ុន TelcoTech បានដាក់ឱ្យដំណើរការបណ្តាញខ្សែកាប្លិ៍ក្រោមបាតសមុទ្រនៅត្រីមាសទី០១ ឆ្នាំ២០១៧ ដែលមានឈ្មោះថា Malaysia-Cambodia-Thailand (MCT) មានប្រវែងសរុប ១.៣០០គ.ម (ស្ថិតក្នុងដែនសមុទ្រកម្ពុជា ប្រវែង ៤៧០គ.ម) និងមានសមត្ថភាពបញ្ជូនទិន្នន័យចំនួន ១១០ Gbps។<br>▪ ទូរគមនាគមន៍កម្ពុជា មានបណ្តាញខ្សែកាប្លិ៍អុបទិកសរុប ២.៤១០គ.ម នៅទូទាំងប្រទេសកម្ពុជា÷<br>- ទូរគមនាគមន៍កម្ពុជាបានពង្រីកបន្ថែមខ្សែកាប្លិ៍អុបទិករហូតដល់ ១.៩៥៤ គ.ម ដែលក្នុងនោះប្រព័ន្ធបញ្ជូនទិន្នន័យតាមរយៈ កាប្លិ៍អុបទិកនៃគម្រោង CP-P5 ត្រូវបានប្រើប្រាស់ពេញលេញ ដោយភ្ជាប់ពីទីរួមខេត្តកំពង់ចាម ស្គន់ ភ្នំពេញ តាកែវ កំពត និងក្រុងព្រះសីហនុ<br>- ដោយឡែកក្នុងតំបន់ក្រុងព្រះសីហនុ ទូរគមនាគមន៍កម្ពុជា បានស្ថាបនាខ្សែកាប្លិ៍អុបទិក (៩៦,៤៦ គ.ម) និងខ្សែកាប្លិ៍ទង់ដែង | |

| | វិធានការដាក់ស្នើចម្បង | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | សម្រាប់បណ្ដាញទូរស័ព្ទ (copper ប្រវែង ២៤,៣១ គ.ម) សរុប ១២០,៧៧ គ.ម។<br>▪ ប្រៃសណីយ៍កម្ពុជាបានដាក់បណ្ដាញដឹកជញ្ជូនភស្ដុភារ ដើម្បីរួមចំណែកក្នុងការធ្វើឱ្យខេត្តព្រះ-សីហនុក្លាយជាខេត្តមួយដែលមានទំនើបកម្ម<br>▪ មូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍បានស្ថាបនាស្ថានីយអង់តែនទូរស័ព្ទចំនួន៤ស្ថានីយ ដែលក្នុងនោះ ពីរស្ថានីយបានសាងសង់ដោយក្រុមហ៊ុនស្មាតអាស្យាតា និង២ស្ថានីយសាងសង់ដោយក្រុមហ៊ុនវៀតថែលខាំបូឌា ដែលអាចផ្ដល់សេវាពីប្រភេទ 2G រហូតដល់ 4G នៅខេត្តព្រះ-សីហនុ<br>▪ មូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍បានស្នើក្រុមហ៊ុនវៀតថែលខាំបូឌា បំពាក់ឧបករណ៍បន្ថែមសម្រាប់សេវា 3G ទៅលើស្ថានីយ 2G ដែលខ្លួនមានស្រាប់ចំនួន៦ស្ថានីយ និងកែប្រែលក្ខណៈបច្ចេកទេសដើម្បីពង្រីកតំបន់សេវាចំនួន ៦ ស្ថានីយបន្ថែមទៀតនៅខេត្តព្រះសីហនុ។<br>- រដ្ឋបាលខេត្តព្រះសីហនុ÷ បានត្រៀមខ្លួនរួចជាស្រេចក្នុងការចូលរួមសហការរៀបចំជាមួយនឹងថ្នាក់ជាតិ ក្នុងការរៀបចំនូវផែនការមេសម្រាប់ការអភិវឌ្ឍខេត្តព្រះ-សីហនុឱ្យក្លាយទៅតំបន់សេដ្ឋកិច្ចពហុបំណង និងការ | |

| | វិធានការដាក់ស្នើខបួន | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវសម្របសម្រួល និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|---|---|
| | | | | រៀបចំផែនការប្រតិបត្តិ និងវិនិយោគ ដោយបានរៀបចំក្រុមការងារដែលមានមន្ត្រីបង្គោល និងមន្ត្រីបច្ចេកទេសទទួលបន្ទុកការងារ IDP សម្រាប់អនុវត្តបំពេញភារកិច្ចនេះ។ | |

## ឧបសម្ព័ន្ធទី២ : ឧបសម្ព័ន្ធ “ឃ”: ម៉ាទ្រីសនៃវិធានការគោលនយោបាយ និងផែនការសកម្មភាព

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| ***១)-ការជំរុញការទាក់ទាញវិនិយោគ*** | | | |
| *ក-បរិយាកាសវិនិយោគ* | | | |
| - ពិនិត្យឡើងវិញនូវច្បាប់វិនិយោគ ព្រមទាំងវិធានច្បាប់ពាក់ព័ន្ធដទៃទៀត ដោយផ្តែកលើតម្រូវការជាក់ស្តែងក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម សំដៅលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យឧស្សាហកម្ម រួមមានការទាក់ទាញការវិនិយោគ ការផ្ទេរបច្ចេកវិទ្យា ការបង្កើតការងារ និងបណ្តុះ-បណ្តាលជំនាញ និងការបង្កើនតម្លៃបន្ថែមនៃឧស្សាហកម្មជារួម | ២០១៥ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ការងារឆ្នាំ២០១៧-២០១៨<br>▪ បានបន្តស្រាវជ្រាវប្រព័ន្ធលើកទឹកចិត្តវិនិយោគ និងច្បាប់វិនិយោគនៃបណ្តាប្រទេសក្នុងតំបន់ ដើម្បីជាធាតុចូលសម្រាប់ការរៀបចំច្បាប់ស្តីពីវិនិយោគ<br>▪ បានបន្តរៀបចំសេចក្តីព្រាងច្បាប់វិនិយោគក្នុងកម្រិតបច្ចេកទេស ព្រមទាំងបានគិតគូរអំពីការផ្តល់ការលើកទឹកចិត្តដល់វិស័យអាទិភាព ការផ្ទេរបច្ចេកវិទ្យា ការបង្កើតការងារ ការបណ្តុះបណ្តាលជំនាញ និង សហគ្រាសធុនតូចនិងមធ្យមដែលមានសក្តានុពលផងដែរ<br>▪ ដើម្បីបន្តលើកកម្ពស់ការទាក់ទាញវិនិយោគ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌគតិយុត្ត និងបរិយាកាសអនុគ្រោះសម្រាប់ការវិនិយោគ ក.អ.ក តាមរយៈក្រុមការងារចរចា និងគណៈកម្មាធិការសម្របសម្រួលវិនិយោគ បានបំពេញការងារយ៉ាងសកម្មក្នុងការចូលរួមការចរចាកិច្ចព្រមព្រៀងអន្តរជាតិជាច្រើនដូចជា÷<br>- បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគទ្វេភាគីចំនួន ១ រវាងកម្ពុជា និងអេមីរ៉ាតអារ៉ាប់រួម បន្ថែមលើកិច្ចព្រមព្រៀងវិនិយោគទ្វេភាគី សរុបចំនួន ២៧ ដែលមានស្រាប់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - បានចូលរួមបញ្ចប់ការចរចាកិច្ចព្រមព្រៀងវិនិយោគអាស៊ាន-ហុងកុង (AHKIA) ស្របជាមួយនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង (AHKFTA)<br>- បានចូលរួមកិច្ចប្រជុំក្រុមការងារវិនិយោគក្រោមក្របខណ្ឌភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) ដែលគ្រោងនឹងបញ្ចប់ក្នុងឆ្នាំ២០១៩<br>- បានចូលរួមកិច្ចប្រជុំ គណៈកម្មាធិការចម្រុះភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់អាស៊ាន-ជប៉ុន<br>- បានចូលរួមកិច្ចប្រជុំ ក្រុមការងារពិសេសស្តីពី កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាន (TF-ATISA)។<br>- ចូលរួមពិភាក្សា និងបញ្ចប់បញ្ជីរក្សាសិទ្ធិរបស់កម្ពុជា ក្រោមកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់។<br>- បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយអាស៊ាន-ជប៉ុន (AJCEP)។<br>▪ ចូលរួមពិនិត្យ និងផ្តល់ធាតុចូលសម្រាប់ឯកសារស្តីពីការលើកទឹកចិត្តផ្នែកពន្ធ (Tax Incentives) ដែលសិក្សាដោយអ្នកស្រាវជ្រាវពីអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)<br>▪ បានចូលរួមពិភាក្សា និងផ្តល់ធាតុចូលលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញចំពោះការពង្រីកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការដាក់ឱ្យអនុវត្តច្បាប់ស្តីវិនិយោគកម្ពុជា (មាត្រា១៥ ស្តីពីគម្រោងពង្រីក)<br>▪ បានរៀបចំកិច្ចប្រជុំអន្តរស្ថាប័ន ដើម្បីពិនិត្យឡើងវិញនូវខ្លឹមសារអនុក្រឹត្យលេខ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីមុខទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់<br>▪ បានអនុវត្តតាមខ្លឹមសារអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យអាទិភាព<br>▪ ប្រកាសលេខ ៧៤១ សហវ.ប្រក ស្តីពីវិធាន និងនីតិវិធីសម្រាប់អនុវត្តពន្ធលើប្រាក់ចំណូល និងពន្ធអាករនានាទាក់ទិននឹងសកម្មភាពកាត់ដេរ និងតម្រឹមរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់<br>▪ អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធសម្រាប់ប្រតិបត្តិការប្រេងកាតក្នុងប្លុកអេ "A"<br>▪ បានចេញអនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ<br>១. អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ២. ប្រកាសរួមលេខ១០១ កយសហវ.ប្រក/១៨ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងចាត់ចែងវត្ថុតាង<br>៣. ប្រកាសរួមលេខ ៧១៤ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>៤. ប្រកាសរួមលេខ ៤៩៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>៥. ប្រកាសរួមលេខ ៤៩៩ សហវ.ប្រក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈរបស់និយ័តករទូរគមនា-គមន៍កម្ពុជា<br>៦. ប្រកាសរួមលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលក្នុងវិស័យអាកាសចរស៊ីវិល។<br>▪ បានចូលរួមរៀបចំប្រកាសរួមស្តីពីសេវាសាធាណៈរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ការកែសម្រួលតម្លៃប្លង់លេខទូរសព្ទរបស់នីយ័តករទូរគមនាគមន៍<br>▪ កំពុងរៀបចំប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើ-ពន្ធ ដើម្បីកាត់បន្ថយពេលវេលាបង់ និងទូទាត់ប្រាក់សម្រាប់អ្នកវិនិយោគ និងអតិថិជន | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានចូលរួមពិនិត្យ ផ្តល់មតិ និងកែសម្រួលកិច្ចព្រមព្រៀងសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែមួយចំនួនពាក់ព័ន្ធនឹងគម្រោងវិនិយោគសម្បទានរ៉ែ<br>▪ បានចូលរួមពិនិត្យ និងរៀបចំគំរូកិច្ចព្រមព្រៀងសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ ដោយផ្តោតលើទិដ្ឋភាពហិរញ្ញវត្ថុ និងតម្លាភាពចំណូលចូលក្នុងថវិការដ្ឋ<br>▪ បានចូលរួមពិនិត្យ, ផ្តល់មតិ និងកែសម្រួលសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការប្រមូលចំណូលសួយសារធនធានរ៉ែពីការប្រើប្រាស់ធនធានរ៉ែសំណង់ក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ។<br>- ទីស្តីការគណៈរដ្ឋមន្ត្រី បានចូលរួមពិគ្រោះយោបល់លើឯកសារពាក់ព័ន្ធនឹងគោលនយោបាយស្តីពីវិនិយោគរបស់កម្ពុជា។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍៖<br>ក្នុងឆ្នាំ២០១៧៖<br>▪ ចូលរួមពិនិត្យឡើងវិញនូវច្បាប់វិនិយោគ ព្រមទាំងវិធានច្បាប់ដទៃទៀតពាក់ព័ន្ធនឹងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន<br>▪ បញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ ការគ្រប់គ្រងនិងការបែងចែកវិសាលគមន៍ហ្វ្រេកង់វិទ្យុ<br>▪ បញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យ ICT<br>▪ បញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការអនុវត្តមូលនិធិ ការកសាងសមត្ថភាព ការស្រាវជ្រាវ និងអភិវឌ្ឍក្នុងវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន<br>▪ បញ្ចប់សេចក្តីព្រាងប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>▪ បញ្ចប់សេចក្តីព្រាងប្រកាសស្តីពីអាជ្ញាបណ្ណវិស័យទូរគមនាគមន៍។<br>ក្នុងឆ្នាំ២០១៨÷<br>▪ បានដាក់ចេញអនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល<br>▪ ប្រកាសរួមស្តីពីការដាក់ឱ្យប្រើប្រាស់ទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យារបស់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ (DMC)<br>▪ ប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់ព័ត៌មានអំពីការសាងសង់ដំឡើង រុះរើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍នៅតាមភូមិសាស្ត្រខេត្ត<br>▪ បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពីនីតិវិធីនៃការផ្តល់របាយការណ៍សេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា ជូនអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>▪ បានបញ្ចប់ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការពិន័យអន្តរ-ការណ៍ចំពោះបទល្មើសក្នុងវិស័យទូរគមនាគមន៍<br>▪ បានបញ្ចប់ការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍អ៊ីនធឺណិតល្បឿនលឿន<br>▪ បានផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ច្បាប់ស្តីពីទូរគមនាគមន៍ | |

| វិធានការគោលនយោបាយ/ផែនការ សកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំលេខ១១០ ប.ទ ស្តីពីការចែកចាយលក់ស៊ីមកាតទូរស័ព្ទគ្រប់ប្រព័ន្ធ ដោយតម្រូវអតិថិជនមានអត្តសញ្ញាណបណ្ណ ឬឯកសារពាក់ព័ន្ធឱ្យបានត្រឹមត្រូវ<br>▪ បានផ្សព្វផ្សាយប្រកាសស្តីពីបញ្ញើហាមឃាត់<br>▪ បានរៀបចំ និងទទួលបានការសម្រេចដាក់ឱ្យប្រើប្រាស់អនុក្រឹត្យស្តីពីការកំណត់តម្រៃនៃការប្រើប្រាស់លេខទូរស័ព្ទ និងលេខទូរ-គមនាគមន៍<br>▪ បានដាក់ចេញនូវប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈដោយនិយ័តករទូរគមនាគមន៍កម្ពុជា<br>▪ បានដាក់ចេញនូវប្រកាសអន្តរក្រសួង ស្តីពីការគ្រប់គ្រងការផ្សព្វ-ផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅព្រះរាជាណាចក្រកម្ពុជា<br>▪ បានដាក់ចេញនូវប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់ព័ត៌មានអំពីការសាងសង់ ដំឡើង រុះរើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍នៅតាមភូមិសាស្ត្រខេត្ត<br>▪ បានដាក់ចេញនូវប្រកាស ស្តីពីការប្រគល់ភារកិច្ច និងសិទ្ធិក្នុងការផ្តល់សេវាសាធារណៈមួយចំនួនរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជូននិយ័តករទូរគមនាគមន៍កម្ពុជា<br>▪ បានដាក់ចេញនូវសេចក្តីណែនាំ ស្តីពីការស្នើសុំលិខិតអនុញ្ញាតចុះឈ្មោះគេហទំព័រ .KH<br>▪ បានដាក់ចេញនូវសេចក្តីណែនាំ ស្តីពីការស្នើសុំលិខិតអនុញ្ញាតការបើកអាជីវកម្មសាលបម្រើសេវាអ៊ិនធឺណិតនៅក្នុងរាជធានីភ្នំពេញ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានដាក់ចេញនូវសេចក្តីណែនាំ ស្តីពីការស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់លេខទូរស័ព្ទ និងលេខទូរគមនាគមន៍<br>▪ បានដាក់ចេញនូវសេចក្តីណែនាំ ស្តីពីការស្នើសុំលិខិតអនុញ្ញាតបើកលក់ និង/ឬជួសជុលគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ នៅក្នុងរាជធានីភ្នំពេញ<br>▪ បានដាក់ចេញនូវសេចក្តីណែនាំ ស្តីពីការពង្រឹងការគ្រប់គ្រងលើការសាងសង់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍គ្រប់ប្រភេទនៅតាមភូមិសាស្ត្ររាជធានីខេត្ត។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម៖<br>▪ បានចូលរួមយ៉ាងសកម្មក្នុងការផ្តល់ធាតុចូល និងកិច្ចប្រជុំ "ច្រកចេញ-ចូលតែមួយ" របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលើការអនុម័តលើកទឹកចិត្តដល់គម្រោងវិនិយោគនានា<br>▪ បានរៀបចំធ្វើគោលនយោបាយជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ក្នុងនោះបានគិតគូរពីការកំណត់និយមន័យសហគ្រាសធុនតូច និងមធ្យមឡើងវិញតាមវិស័យ ក្នុងគោលបំណងឱ្យមានការកំណត់ការលើកទឹកចិត្តចំគោលដៅ<br>▪ បានផ្តល់ការបណ្តុះបណ្តាលដល់កម្មករបច្ចេកទេសសុវត្ថិភាពឧស្សាហកម្មដោយមិនគិតថ្លៃបានចំនួនសរុប ១៣ លើក។ | |
| - ពិនិត្យឡើងវិញនិងកែសម្រួលលក្ខខណ្ឌវិនិច្ឆ័យពិសេសសម្រាប់ទាក់ទាញ "គម្រោងវិនិយោគសក្តានុពលនិងមានគុណភាព" ដែលផ្តល់ផលវិជ្ជមាននិងតម្លៃបន្ថែម សម្រាប់ការបើកផ្លូវដល់ | ២០១៥ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖<br>ការងារឆ្នាំ២០១៧-២០១៨ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| ការអភិវឌ្ឍ និងការទាក់ទាញឧស្សាហកម្មថ្មីៗមកកម្ពុជា | | ▪ បានបន្តកិច្ចការងារទាក់ទងនឹងការពិនិត្យ និងកែសម្រួលលើលក្ខណៈវិនិច្ឆ័យនានា សម្រាប់ទាក់ទាញគម្រោងវិនិយោគដែលមានសក្ដានុពល និងគុណភាព និងបានបញ្ចូលទៅក្នុងសេចក្ដីព្រាងច្បាប់ស្ដីពីវិនិយោគ<br>▪ បានគិតគូរ និងការរៀបចំឯកសារទស្សនាទានស្ដីពីយុទ្ធសាស្ត្រជំរុញការវិនិយោគចំគោលដៅ<br>▪ បានធ្វើការសិក្សាស៊ីជម្រៅលើវិស័យអេឡិចត្រូនិក និងផលិតកម្មគ្រឿងបន្លាស់យានយន្ត ក្នុងគោលបំណងដាក់ចេញនូវយុទ្ធសាស្ត្រវិនិយោគចំគោលដៅ (Targeted Investment Strategy) ដើម្បីទាក់ទាញគម្រោងវិនិយោគដែលមានតម្លៃបន្ថែមខ្ពស់ ជាពិសេសគម្រោងវិនិយោគក្នុងវិស័យអេឡិចត្រូនិក និងផលិតកម្មគ្រឿងបន្លាស់យានយន្ត។<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ បានសិក្សាពិនិត្យផ្ដល់ការលើកទឹកចិត្ត និងគាំទ្រដល់គម្រោងវិនិយោគមួយចំនួន ដូចជា ករណីការនាំចូលសម្ភារៈផ្គុំបាយ និងការទទួលស្គាល់ម្ចាស់កម្មសិទ្ធិលើការនាំចូលសម្ភារៈ និងវត្ថុធាតុដើម ក្នុងរូបភាពជា ផលិត/ដេរកាត់ តម្រឹម (CMT: Cut Make and Trim)។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>ការងារឆ្នាំ២០១៧-២០១៨÷<br>▪ បាននិងកំពុងរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីការជំរុញលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យានៅកម្ពុជា ដោយសម្រេចបាន ២៥%។<br>ការងារឆ្នាំ២០១៨÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ▪ បានចេញប្រកាសលេខ០៨០ MIH/2018 ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណរដ្ឋប្រជាមានិតចិន នៅកម្ពុជា និងបានចុះអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសាធារណរដ្ឋប្រជាមានិតចិន នៅកម្ពុជា រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតចិន ព្រមទាំងបានកែសម្រួលនីតិវិធីចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្មឱ្យមានភាពល្អប្រសើរឡើង តាមរយៈការចុះបញ្ជីស្វ័យប្រវត្តិកម្មប្រព័ន្ធចុះបញ្ជី<br>▪ បានបោះពុម្ពច្បាប់ និងឯកសារពាក់ព័ន្ធនានា សៀវភៅស្តង់ដារកម្ពុជា ចំនួន៣មុខ (៣៦០ក្បាល)។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍៖ ក្នុងឆ្នាំ២០១៧ បានចូលរួមផ្តល់ធាតុចូលលើការពិនិត្យ និងកែសម្រួលលក្ខខណ្ឌវិនិច្ឆ័យពិសេសសម្រាប់ទាក់ទាញការវិនិយោគក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។<br>- ក្រសួងពាណិជ្ជកម្ម៖<br>▪ បានកែសម្រួលនីតិវិធី បែបបទឯកសារចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីកម្មសិទ្ធិបញ្ញា និងការស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងធ្វើប្រតិភូកម្មដល់មន្ទីរពាណិជ្ជកម្មតាមបណ្តាខេត្តជាប់ព្រំដែន មាន ខេត្តបាត់ដំបង ប៉ៃលិន បន្ទាយ-មានជ័យ និងខេត្តស្វាយរៀង | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានអនុញ្ញាតដល់ក្រុមហ៊ុននាំចេញសម្រាប់ការចុះឈ្មោះក្នុងប្រព័ន្ធចុះបញ្ជីអ្នកនាំចេញសម្រាប់នាំទៅទីផ្សារសហភាពអឺរ៉ុប។<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ÷<br>▪ បានកែលម្អនីតិវិធីសម្រាប់ការផ្តល់លិខិតអនុញ្ញាតបង្កើតរោងសន្និធិ លក់ចែកចាយផលអនុផលព្រៃឈើ ឬរោងសិប្បកម្មកែច្នៃផលអនុផលព្រៃឈើប្រភេទតូច ជូនដល់អតិថិជនតាមការស្នើសុំជាក់ស្តែងដោយបានអនុញ្ញាតផ្តល់ជាគោលការណ៍ប្រចាំឆ្នាំជូនដល់ខណ្ឌរដ្ឋបាលព្រៃឈើ ដើម្បីផ្តល់សេវារហ័សជូនអ្នកស្នើសុំ<br>▪ បានរៀបចំសៀវភៅណែនាំស្តីពីការផ្តល់វិញ្ញាបនបត្រនៃការអនុវត្តកសិកម្មល្អដល់កសិដ្ឋានសហគមន៍ និងកសិករ (GAP Farms Certification Manual) និងបានរៀបចំទម្រង់វិញ្ញាបនបត្រពាក្យស្នើសុំចុះឈ្មោះជាកសិដ្ឋាន ឬចម្ការនៃការអនុវត្តកសិកម្មល្អ, បែបបទនៃការស្នើសុំវិញ្ញាបនបត្រនៃការអនុវត្តកសិកម្មល្អ ទម្រង់វាយតម្លៃចម្ការ ឬកសិដ្ឋានដំណាំបន្លែ, និងឈើហូបផ្លែដើម្បីចុះឈ្មោះជាចម្ការ ឬកសិដ្ឋាននៃការអនុវត្តកសិកម្មល្អ (Evaluation Tool For Registration For GAP Certification Farm) និងសៀវភៅកំណត់ត្រានៃការអនុវត្តកសិកម្មល្អកម្ពុជា (Cam GAP)<br>▪ បានរៀបចំ និងអនុវត្តលិខិតបទដ្ឋានគតិយុត្តសម្រាប់ជំរុញការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា រវាងក្រុមហ៊ុន និងកសិករចំនួន ៣២កិច្ចសន្យា<br>▪ បង្កើនការចរចាតម្រូវការអនុវត្តវិធានអនាម័យសត្វ និងភូតគាម-អនាម័យ ដើម្បីបើកច្រកនាំចេញផលិតផលកសិកម្ម ទៅកាន់ទីផ្សារ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | អន្តរជាតិ៖ (១) បានចចារបើកទីផ្សារនាំចេញផ្លែស្វាយកម្ពុជាទៅកាន់ប្រទេសថៃ ដោយជោគជ័យ និង (២) កំពុងចរចាបើកទីផ្សារនាំចេញផ្លែក្រូចឆ្មារ ម្ទេសស្រស់ និងផ្លែល្មៅស្រស់ទៅកាន់ប្រទេសថៃ<br>▪ ជំរុញការអនុវត្តអនុក្រឹត្យស្តីពីផលិតកម្មតាមកិច្ចសន្យាក្នុងគោលដៅពង្រឹងការភ្ជាប់ទំនាក់ទំនង និងភាពជាដៃគូរវាងគ្រួសារកសិករខ្នាតតូច ក្រុមកសិករសហគមន៍កសិកម្ម ជាមួយក្រុមហ៊ុនស៊ីភី ដោយសម្របសម្រួលកិច្ចសន្យាចិញ្ចឹមជ្រូក និងបក្សី។<br>- រដ្ឋបាលរាជធានីភ្នំពេញ៖<br>▪ មានអនុគណៈកម្មាធិការវិនិយោគរាជធានី និងមន្ទីរ អង្គភាពជំនាញផ្សេងៗ ជាសេនាធិការ បានទាក់ទាញអ្នកវិនិយោគ និងចុះបញ្ជីសំណើវិនិយោគរបស់ក្រុមហ៊ុនថ្មីៗ ដោយផ្តល់ជូននូវយន្តការសម្របសម្រួលកាត់បន្ថយពេលវេលា ថវិកា និងការលើកទឹកចិត្តតាមរយៈយន្តការច្រកចេញ-ចូលតែមួយ អនុវត្តទៅតាមច្បាប់ និងលិខិតបទដ្ឋានដូចបានអនុវត្តនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជាដែរ។ លទ្ធផលគិតត្រឹមខែធ្នូ ឆ្នាំ២០១៨៖<br>- សហគ្រាសធុនតូច និងមធ្យម សិប្បកម្ម និងរោងចក្រវិនិយោគដែលបានមកចុះបញ្ជីតាមរយៈយន្តការច្រកចេញ-ចូលតែមួយនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ និងនៅរដ្ឋបាលរាជធានីភ្នំពេញដែលមានមន្ទីរឧស្សាហកម្ម និងសិប្បកម្មជាសេនាធិការ សរុបមានចំនួន ៧.៤៩៥ មូលដ្ឋាន ហើយអាចស្រូបទាញកម្លាំងពលកម្មសរុប បានចំនួន ១៤៤.១៧៤ នាក់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | - សហការរៀបចំព្រឹត្តិការណ៍តាំងពិព័រណ៍បានចំនួន០២លើក ដែលបានផ្តល់ឱកាសឱ្យមានការជួបពិភាក្សារវាងពាណិជ្ជករ អាជីវករ សេវាករជាតិ និងអន្តរជាតិ ក្នុងគោលបំណងដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងស្វែងរកទីផ្សារសម្រាប់ផលិតផលរបស់ខ្លួនតាមរយៈវេទិកាធុរកិច្ចនានា<br>- ចុះសិក្សាស្រាវជ្រាវទៅលើផលិតផលក្នុងរាជធានីភ្នំពេញ ដើម្បីអាចចាត់ទុកជាផលិតផលសក្តានុពលរបស់ រាជធានី និង ជំរុញការលើកកម្ពស់ផលិតផលក្នុងស្រុក ស្វែងរកទីផ្សារជូនដល់ផលិតករ សិប្បករ និង កសិករកម្ពុជា ដើម្បីបង្កើតការងារ បង្កើនប្រាក់ចំណូល និងជួយទប់ស្កាត់ក្នុងការធ្វើចំណាកស្រុករបស់យុវជនវ័យក្មេង<br>- សហការទប់ស្កាត់ការប្រើប្រាស់សារធាតុគីមីហាមឃាត់ក្នុងផលិតផលទំនិញ ដោយបានចុះអង្កេតត្រួតពិនិត្យ គុណភាពសុវត្ថិភាព និងសេវាកម្មលើផលិតផលទំនិញនៅតាមទីផ្សារក្នុងរាជធានីភ្នំពេញបានចំនួន ៦០៥លើក លើគោលដៅផ្សាររដ្ឋ ផ្សារទំនើប-មីនីម៉ាត ហាង និងផ្ទះលក់ទំនិញ ព្រមទាំងបានសហការរៀបចំវគ្គផ្សព្វផ្សាយមួយចំនួនទៀត។<br>▪ បានធ្វើការជំរុញជាបន្តបន្ទាប់ឱ្យរោងចក្រ (មានទុនវិនិយោគក្រោម ២លានដុល្លារអាមេរិក) សហគ្រាសធុនតូច និងមធ្យម ចូលរួមក្នុងការថែរក្សាគុណភាពបរិស្ថានតាមរយៈការគ្រប់គ្រងបានច្បាស់លាស់នូវសំណល់រឹង សំណល់ឧស្សាហកម្ម សំណល់រាវ និងឧស្ម័ន ដែលបញ្ចេញដោយរោងចក្រ-សហគ្រាស និងជំរុញឱ្យមូល- | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ដ្ឋានខាងលើរៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន ឬកិច្ចសន្យាការពារបរិស្ថាន។ | |
| - បន្តពង្រឹងបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគ និងធុរកិច្ច តាមរយៈការបន្តកែលម្អក្របខ័ណ្ឌគតិយុត្ត ក្របខ័ណ្ឌអភិបាលកិច្ច និងប្រសិទ្ធភាពនៃស្ថាប័នសាធារណៈពាក់ព័ន្ធ ពិសេស ការពង្រឹងយន្តការ *"ច្រកចេញចូលតែមួយ"* នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឱ្យក្លាយជាយន្តការប្រកបដោយប្រសិទ្ធភាពក្នុងការទាក់ទាញវិនិយោគ | ២០១៥ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ការងារឆ្នាំ២០១៧-២០១៨÷<br>▪ បានដឹកនាំកិច្ចប្រជុំ "ច្រកចេញ-ចូលតែមួយ" ជាទៀងទាត់ ដើម្បីពិនិត្យមើល និងអនុម័តគម្រោងវិនិយោគ ដោយបន្តពង្រឹងប្រសិទ្ធភាពច្រកចេញ-ចូលតែមួយ និងបានចុះបញ្ជីគម្រោងវិនិយោគចំនួន១៨៣ ក្នុងឆ្នាំ២០១៧ និងចំនួន២៥៦ ក្នុងឆ្នាំ២០១៨<br>▪ បានពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈរបស់ ក.អ.ក. តាមរយៈការតាមដាន និងវិភាគនូវប្រសិទ្ធភាពនៃការផ្តល់សេវាបច្ចុប្បន្ន និងដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដូចជា ការកំណត់សេវាអាទិភាព និងបង្កើតយន្តការទទួលបណ្តឹងតវ៉ាពីសំណាក់អ្នកវិនិយោគពាក់ព័ន្ធនឹងការទទួលសេវានៅ ក.អ.ក ជាដើម<br>▪ បានបន្តកិច្ចការងារទាក់ទងនឹងការរៀបចំគេហទំព័រថ្មីរបស់ ក.អ.ក<br>▪ បាននិងកំពុងតិតគូររៀបចំការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិកនូវគម្រោងវិនិយោគ, ការដាក់ពាក្យស្នើសុំនាំចូលដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋចំពោះវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង, និងការដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ<br>▪ បានរៀបចំរបៀបវារៈកិច្ចប្រជុំយន្តការអន្តរស្ថាប័ន ដើម្បីពិនិត្យសំណើសុំការនាំចូលដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ លើការនាំចូលរបស់បណ្តាក្រុមហ៊ុនវិនិយោគ សរុបចំនួន៦១៦លើក | - រដ្ឋបាលខេត្តបន្ទាយមានជ័យ និងរដ្ឋបាលខេត្តកណ្តាល÷<br>បញ្ហាប្រឈម÷<br>▪ ខ្វះមន្ត្រីនៅពេលបង្កើតអង្គភាពច្រកចេញចូលតែមួយ<br>▪ គ្មានអគារ ឬការិយាល័យ។<br>សំណើសំណូមពរ÷<br>▪ ជ្រើសរើសមន្ត្រីបន្ថែម<br>▪ សាងសង់អគារថ្មី។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ▪ បានផ្តល់សេវាពិគ្រោះយោបល់ជូនអ្នកវិនិយោគខ្មែរ និងបរទេសសរុបចំនួន ៥៤៧នាក់ និងបានសម្របសម្រួលកម្មវិធីជួបសម្តែងការគួរសមរបស់គណៈប្រតិភូវិនិយោគ ចំនួន ២៣លើក ដែលមានអ្នកវិនិយោគសរុប ៦៥៩នាក់មកពីប្រទេសចិន ថៃ ជប៉ុន និងសិង្ហបុរី<br>▪ បានធ្វើការស្រាវជ្រាវពីការចុះបញ្ជីគម្រោងវិនិយោគតាមប្រព័ន្ធអេឡិចត្រូនិកតាមបណ្តាប្រទេសក្នុងតំបន់ និងបានរៀបចំកិច្ចប្រជុំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងគោលបំណងរៀបចំនូវការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិកនូវគម្រោងវិនិយោគ, ការដាក់ពាក្យស្នើសុំនាំចូលដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋចំពោះវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង, និងការដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋនៅ ក.អ.ក។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷<br>▪ បានរៀបចំកែសម្រួលសមាសភាពក្រុមការងារនៃយន្តការ CPPM និងបានបង្កើតក្រុមការងារចំនួន ០៤ នៃយន្តការ CPPM រួមមាន÷ (១) ក្រុមការងារគយ-ឧស្សាហកម្មបម្រើឱ្យការនាំចេញវិស័យកាត់ដេរ (២) ក្រុមការងារគយ-ឧស្សាហកម្មបម្រើឱ្យការនាំចេញវិស័យមិនមែនកាត់ដេរ (៣) ក្រុមការងារគយ-ធុរកិច្ចបម្រើទីផ្សារក្នុងស្រុក និង (៤) ក្រុមការងារគយ-ឧស្សាហកម្មធុនតូច និងមធ្យម (ប្រកាសលេខ ៧៣២ សហវ.បក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៨) | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានរៀបចំកិច្ចប្រជុំ CPPM លើកទី៧ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ និងបានប្រជុំក្រុមការងារទាំង៤ នៃ CPPM ដើម្បីដោះស្រាយនូវបញ្ហា និងកង្វល់នានាពាក់ព័ន្ធនឹងការងារគយមានដូចជា÷<br>(១)ការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ<br>(២)ការធ្វើសាមញ្ញកម្មនិតិវិធីទំនិញសេវាបញ្ជើរហ័ស<br>(៣)ការរៀបចំនិងដាក់អនុវត្តកម្រៃសេវាគយ<br>(៤)ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ<br>(៥)ការចូលរួមចំណែករបស់គយ និងវិស័យឯកជនក្នុងការអនុវត្តគោលនយោបាយពិពិធកម្មសេដ្ឋកិច្ច<br>(៦)ការរៀបចំខ្លួនឆ្លើយតបចំពោះការវិវត្តន៍នៃសេដ្ឋកិច្ចឌីជីថល និង<br>(៧)ការកែសម្រួលអនុក្រឹត្យស្តីពីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់(អនុក្រឹត្យ ២០៩) ជាដើម<br>▪ បានចូលរួមកិច្ចប្រជុំស្តីពី (១) បច្ចុប្បន្នភាពនីតិវិធីគយកម្ពុជាជាមួយធុរជនជប៉ុន ចិន កូរ៉េ ថៃ, និង (២) សេវាក្រៅផ្លូវការលើការងារដឹកជញ្ជូននៅក្រសួងសាធារណការ និងដឹកជញ្ជូន<br>▪ បានបោះពុម្ពចែកផ្សាយលទ្ធផលកិច្ចប្រជុំលើកទី៦ យន្តការភាពជាដៃគូគយផ្នែកឯកជន និងផ្សព្វផ្សាយលើគេហទំព័ររបស់អគ្គនាយក-ដ្ឋានគយ និងរដ្ឋាករកម្ពុជា<br>▪ បានសហការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីកម្រៃសេវា-កម្មគយផ្សេងទៀត ជាមួយសភាពាណិជ្ជកម្មកម្ពុជា និងអឺរ៉ុបនៅភ្នំពេញ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានប្រជុំពិគ្រោះពិភាក្សារវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងបណ្តាក្រុមហ៊ុនដឹកជញ្ជូនបញ្ញើរហ័ស និងបានដាក់ឱ្យអនុវត្តមុខងារប្រកាសកញ្ចប់បញ្ញើរហ័ស ឬទំនិញតម្លៃទាប (De Minimis) តាមប្រព័ន្ធអេឡិចត្រូនិកគយ<br>▪ បានចូលរួមកិច្ចប្រជុំក្រុមការងារទី៣ ផ្នែកកម្មន្តសាល សហគ្រាសធុនតូច និងមធ្យម និងសេវា នៅទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីពិនិត្យដោះស្រាយសំណូមពរពីវិស័យឯកជន។<br>- ក្រសួងពាណិជ្ជកម្ម÷<br>▪ បានផ្ទេរិមជ្ឈការ និងវិសហមជ្ឈការនូវកិច្ចការមួយចំនួនធំដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មនិងលិខិតស្នាមផ្សេងៗ<br>▪ បានរៀបចំបង្កើតឱ្យមានសភាពាណិជ្ជកម្មតាមរាជធានី-ខេត្ត ដោយមកដល់បច្ចុប្បន្នមានសភាពាណិជ្ជកម្មចំនួន១៥មណ្ឌល<br>▪ បានប្រមូលផ្តុំចងក្រងផលិតករ កសិករ ជាបណ្តាញអាជីវកម្ម តាមរយៈការបង្កើតសមាគមដំឡូងមី ចំនួន ១៤<br>▪ បានរៀបចំបង្កើតសម្ព័ន្ធសមាគមជលផលសមុទ្រកម្ពុជា ដែលប្រមូលសមាគមជលផលសមុទ្រចំនួន៥ នៅខេត្តកំពត ព្រះសីហនុ និងខេត្តកោះកុង<br>▪ បានគ្រោងបង្កើតសមាគមមួយចំនួនបន្ថែមទៀត<br>▪ បានបង្កើតកម្មវិធីបង្កើនសមត្ថភាពសហព័ន្ធស្រូវអង្ករកម្ពុជាដើម្បីមានលទ្ធភាពអាចដំណើរការនិងទទួលខុសត្រូវលើការងារអនុវត្តផែនការរបស់ខ្លួន ជាពិសេសពង្រឹងយន្តការនៃការត្រួតពិនិត្យ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | គុណភាពអង្ករកម្ពុជា និងជំរុញការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិឱ្យបានច្រើន<br>▪ បានចេញប្រកាសរួមរវាងក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារក្នុងការបង្កើតក្រុមការងារលើកិច្ចការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្ម<br>▪ ជួយសម្រួលដល់វិនិយោគិន និងធុរជនក្នុងការទូទាត់សេវាកម្មនានា តាមរយៈ E-Payment<br>▪ បានចងក្រងក្រុម កសិករ ផលិតករ ជាបណ្តាញពាណិជ្ជកម្មនិងជំនួបពាណិជ្ជកម្ម ដើម្បីធ្វើឱ្យប្រសើរឡើងលើខ្សែសង្វាក់តម្លៃ និងការបញ្ញាទិញ<br>▪ បានរៀបចំ និងកសាងសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍ផលិតផលតាមវិស័យនីមួយៗដូចជា ដំឡូងមី ម្រេច<br>▪ កំពុងជំរុញអនុវត្តន៍កម្មវិធីបើកច្រកទីផ្សារសម្រាប់កសិករខ្នាតតូចក្នុងខេត្តគោលដៅចំនួន១៥ ឆ្ពោះទៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនចំនួន ៧៥.០០០គ្រួសារ តាមរយៈជំរុញការផលិត និងផ្គត់ផ្គង់ទីផ្សារនូវផលិតផលដំឡូងមី មាន់ស្រែ បន្លែ ស្រូវ សូត្រខ្មែរ<br>▪ បានតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ខ្លួនជាមួយប្រព័ន្ធ ASYCUDA រួចហើយ។<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍÷<br>ក្នុងឆ្នាំ២០១៧÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានបន្តពង្រឹងប្រសិទ្ធភាពយន្តការភាពជាដៃគូរវាងក្រសួង/អង្គភាព និយ័តកម្មផ្នែកឯកជន ដើម្បីលើកទឹកចិត្តវិស័យឯកជនចូលរួមលើកឡើងនិងផ្តល់ធាតុចូល ដើម្បីដោះស្រាយនូវកង្វល់នានាពាក់ព័ន្ធនឹងការងារវិនិយោគ និងនិយ័តកម្មក្នុងវិស័យប្រៃសណីយ៍ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន<br>▪ បានរៀបចំវេទិកាថ្នាក់តំបន់ស្តីពីធុរកិច្ច និងព្រឹត្តិការណ៍ពិព័រណ៍ICT ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំ TELMIN 2017 នៅខេត្តសៀមរាប។<br>ក្នុងឆ្នាំ២០១៨÷<br>▪ បានរៀបចំកម្មវិធីប្រកួតប្រជែងនិងបណ្តុះបណ្តាលអាជីវកម្មបច្ចេកវិទ្យាចំនួនពីរដោយសហការជាមួយក្រុមហ៊ុនអន្តរជាតិ÷ E27 និង Seedstars ដែលផ្តល់លទ្ធភាពឱ្យអាជីវកម្មបច្ចេកវិទ្យានៅកម្ពុជាអាចតភ្ជាប់ជាមួយអ្នកវិនិយោគថ្នាក់តំបន់ និងអន្តរជាតិនានា។<br>- ក្រសួងមហាផ្ទៃ÷<br>▪ បានបន្តពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>▪ បានបន្តជំរុញកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>▪ បានរៀបចំប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>▪ បន្តធ្វើវិមជ្ឈការហិរញ្ញវត្ថុ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានពង្រឹងពង្រីកយន្តការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>▪ បានពង្រឹងយន្តការគណនេយ្យភាពរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ<br>▪ បានបង្កើត និងដាក់ឱ្យដំណើរការនូវការិយាល័យច្រកចេញចូលតែមួយចំនួន ៥២ (ក្រុង ២៦ ស្រុក ១៤ និងខណ្ឌ ១២ ក្នុងខេត្ត ២៤ និងរាជធានីភ្នំពេញ)<br>▪ បានចេញសេចក្តីសម្រេចស្តីពីការកំណត់ស្រុកគោលដៅ សម្រាប់បង្កើតការិយាល័យច្រកចេញ-ចូលតែមួយចំនួន ៣៧ នៅខេត្តទាំង ២៤បន្ថែមទៀត និងគ្រោងដាក់ឱ្យដំណើរការក្នុងត្រីមាសទី ២ ឆ្នាំ ២០១៨<br>▪ បានផ្តល់សេវារដ្ឋបាលចំនួន ២៣៥ប្រភេទ ដែលស្ថិតនៅក្នុង ១៤ វិស័យ រួមមាន÷ វិស័យនីត្យានុកូលកម្ម, អគ្រានុកូលដ្ឋាន, អប់រំ យុវជន និងកីឡា, សុខាភិបាល, សាធារណការ និងដឹកជញ្ជូន, សុរិយោដី, សំណង់, ពាណិជ្ជកម្ម, ទេសចរណ៍, វប្បធម៌ និងវិចិត្រសិល្បៈ, កសិកម្ម, ការងាររដ្ឋបាល, ឧស្សាហកម្ម និងសិប្បកម្ម, និងរ៉ែ និងថាមពល<br>▪ បានបង្កើត និងដាក់ដំណើរការនូវការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋត្រូវបានបង្កើតនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅចំនួន ៨៣ នៃ២៥រាជធានី ខេត្ត ដែលក្នុងនោះមាន ២៦ក្រុង ៤៥ស្រុក និង១២ខណ្ឌ ស្មើ៤២% នៃក្រុង ស្រុក ខណ្ឌទូទាំងប្រទេស (សរុប ១៩៧ ក្រុងស្រុកខណ្ឌ គិតត្រឹមឆ្នាំ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ២០១៨)។ ការិយាល័យច្រកចេញចូលតែមួយបាននិងកំពុងផ្តល់សេវារដ្ឋបាលសរុបចំនួន២៣៥ប្រភេទសេវាស្ថិតនៅក្នុង ១៤វិស័យ ដែលទទួលប្រតិភូកម្មពីក្រសួង ស្ថាប័នចំនួន ១០។<br>▪ បានបង្កើត និងដាក់ឱ្យដំណើរការនូវអង្គភាព និងការិយាល័យប្រជាពលរដ្ឋថ្នាក់រាជធានីខេត្តទាំង២៥ ដោយបាននិងកំពុងផ្តល់សេវារដ្ឋបាលសរុបចំនួនជាង ៦០០ប្រភេទសេវាស្ថិតនៅក្នុង ១៤ វិស័យ ដែលទទួលប្រតិភូកម្មពីក្រសួង ស្ថាប័នចំនួន ១២ នៅចុងត្រីមាសទី៣ ឆ្នាំ២០១៨<br>▪ បានសម្រេចអនុលោមភាពលើគម្រោងអភិវឌ្ឍន៍ឆ្នាំ២០១៨ របស់រដ្ឋបាលរាជធានីខេត្ត សរុបចំនួន ៤៧៩គម្រោង ដែលមានតម្លៃជាទឹកប្រាក់សរុប ៩២០.៤៤១.៨៤៣.៩៣២រៀល។<br>- ក្រសួងទេសចរណ៍÷<br>▪ ឆ្នាំ២០១៧ ទទួលបានគម្រោងវិនិយោគពាក់ព័ន្ធទេសចរណ៍ចំនួន ៩គម្រោង មានទុនសរុប ៣.១៦៦លានដុល្លាអាមេរិក<br>▪ ឆ្នាំ២០១៨ ទទួលបានគម្រោងវិនិយោគពាក់ព័ន្ធទេសចរណ៍ចំនួន ១១គម្រោង មានទុនសរុប ១.៥០០លានដុល្លាអាមេរិក។<br>- រដ្ឋបាលរាជធានីភ្នំពេញ÷<br>▪ បានបន្តសហការគ្នាជាមួយអនុគណៈកម្មាធិការវិនិយោគរាជធានី និងមន្ទីរ-អង្គភាពជំនាញផ្សេងៗក្នុងការទាក់ទាញអ្នកវិនិយោគ និងចុះបញ្ជីសំណើវិនិយោគរបស់ក្រុមហ៊ុនថ្មីៗដោយផ្តល់ជូននូវយន្ត-ការសម្របសម្រួលកាត់បន្ថយពេលវេលា ថវិកា និងការលើកទឹក | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ចិត្ត តាមរយៈយន្តការច្រកចេញ-ចូលតែមួយ អនុវត្តទៅតាមច្បាប់ និងលិខិតបទដ្ឋាន<br>▪ បានបន្តកាត់បន្ថយការិយាធិបតេយ្យក្នុងការចុះបញ្ជីតាមរយៈការពង្រឹងច្រកចេញចូលតែមួយឱ្យកាន់ល្អប្រសើរឡើង ក្នុងគោលបំណងកាត់បន្ថយពេលវេលា និងថវិកាក្នុងការបំពេញបែបបទ។<br>- រដ្ឋបាលខេត្តកណ្តាល៖<br>▪ ឆ្នាំ២០១៧ បានបង្កើតការិយាល័យច្រកចេញចូលតែមួយនៅក្រុង-ស្រុកចំនួនបី៖ ក្រុងតាខ្មៅ ស្រុកខ្សាច់កណ្តាល ស្រុកស្អាង<br>▪ ឆ្នាំ២០១៨ បានបង្កើតអង្គភាពច្រកចេញចូលតែមួយនៅរដ្ឋបាលខេត្ត និងនៅការិយាល័យច្រកចេញចូលតែមួយស្រុកចំនួនពីរ៖ ស្រុកកៀនស្វាយ និងស្រុកអង្គស្នួល។<br>- រដ្ឋបាលខេត្តបន្ទាយមានជ័យ៖<br>▪ បានបង្កើតអង្គភាពច្រកចេញចូលតែមួយរបស់ខេត្ត និងក្រុងសិរីសោភ័ណ ក្រុងប៉ោយប៉ែត<br>▪ អនុគណៈកម្មាធិការវិនិយោគខេត្តបានឯកភាពជាគោលការណ៍ទទួលស្គាល់ការផ្ទេរភាគហ៊ុន ប្តូរអភិបាល និងការតម្កល់លក្ខន្តិកៈម្ចាស់ភាគហ៊ុនថ្មីរបស់ក្រុមហ៊ុនផេភើរទ្រីអ៊ិនវេសមេន (ខេមបូឌា)។ | |
| - ធ្វើវិចារណកម្មលើការលើកទឹកចិត្តបន្ថែមចំពោះគម្រោងវិនិយោគដែលរួមចំណែកក្នុងការបណ្តុះបណ្តាលជំនាញ ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ ព្រមទាំងនវានុវត្តន៍ | មធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ បានពិភាក្សា និងបានដាក់បញ្ចូលការលើកទឹកចិត្តបន្ថែមចំពោះគម្រោងវិនិយោគដែលបានចូលរួមក្នុងការបណ្តុះបណ្តាលជំនាញ ការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍនវានុវត្តន៍ទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីវិនិយោគ។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានចូលរួមកិច្ចប្រជុំ (១) ក្រុមការងារអាស៊ានចិនស្តីពីវិធានការដើមកំណើតនៅសិង្ហបុរី, (២)កម្មវិធីត្រួតពិនិត្យកុងតឺន័រតំបន់អាស៊ីអាគ្នេយ៍នៅបាងកក, និង (៣) ការកសាងផែនការសកម្មភាពតភ្ជាប់សេដ្ឋកិច្ចកម្ពុជា- ឡាវ- វៀតណាម នៅក្រសួងពាណិជ្ជកម្ម<br>▪ បានកែសម្រួលបន្ថយអត្រាអាករនាំចេញកៅស៊ូកែច្នៃ និងការធ្វើវិមជ្ឈការការងារកំណត់តម្លៃគិតពន្ធគយ ទៅអាកាសយានដ្ឋានអន្តរជាតិបន្ថែមទៀត<br>▪ បាននិងកំពុងចូលរួមកសាងនីតិវិធីដឹកជញ្ជូនឆ្លងកាត់តាមផ្លូវដែកនៅប៉ោយប៉ែត<br>▪ បាននិងកំពុងកសាងគម្រោងស្តីពីការសិក្សារយៈពេលបញ្ចេញទំនិញពីគយ (Time Release Study: TRS), ការត្រួតពិនិត្យទំនិញតែម្តងនៅទីលានមាត់ច្រក (Single Stop Inspection: SSI) អនុវត្តតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន (Cross Border Trade Agreement: CBTA), និង ប្រព័ន្ធសៀលសម្រាប់តាមដានការចរាចរទំនិញ និងតម្រាយផ្លូវមានភាពជាសៀលអេឡិច-ត្រូនិក (Cargo Tracking System)<br>▪ បានរៀបចំកិច្ចប្រជុំអន្តរស្ថាប័ន ដើម្បីពិនិត្យឡើងវិញនូវខ្លឹមសារអនុក្រឹត្យលេខ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីមុខទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានបង្កើតផែនការលើកទឹកចិត្តផ្នែកពន្ធសម្រាប់ច្បាប់វិនិយោគថ្មី និងបន្តចូលរួមរៀបចំសេចក្តីព្រាងកែសម្រួលបទប្បញ្ញត្តិពាក់ព័ន្ធនឹងការលើកទឹកចិត្ត។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានចូលរួមផ្តល់ធាតុចូលលើការរៀបចំបទប្បញ្ញត្តិ ពាក់ព័ន្ធនឹងការលើកទឹកចិត្តខាងផ្នែកពន្ធដារនិងពន្ធគយលើគម្រោងវិនិយោគក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។ | |
| - ពង្រឹងសមត្ថភាពស្ថាប័ន និងសមាហរណកម្មមុខងារគ្រប់គ្រង និងទាក់ទាញវិនិយោគ ជាមួយមុខងារជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម ដែលស្ថិតក្រោមសមត្ថកិច្ចរួមនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈការរៀបចំផែនការសកម្មភាពរយៈពេលខ្លី និងមធ្យម ការកែទម្រង់ និងទំនើបកម្មស្ថាប័ន និងការលើកកម្ពស់សមត្ថភាពមន្ត្រី ដើម្បីប្រកបដោយប្រសិទ្ធភាពទៅនឹងចក្ខុវិស័យនិងគោលដៅនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម | ២០១៥ ទៅ មធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ÷<br>ការងារឆ្នាំ២០១៧-២០១៨÷<br>▪ បាននិងកំពុងបន្តពង្រឹងសមត្ថភាពមន្ត្រី ក្នុងការរៀបចំអនុវត្ត និងពិនិត្យការតាមដានអនុវត្តគោលនយោបាយនេះ បន្ថែមលើតួនាទីជាប្រតិបត្តិករ<br>▪ បានពង្រឹងសមត្ថភាព និងរៀបចំរចនាសម្ព័ន្ធអភិបាលកិច្ចស្ថាប័នតាមរយៈការបង្កើតលេខាធិការដ្ឋានដឹកនាំ និងសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ ដែលជាសេនាធិការរបស់គណៈកម្មាធិការប្រតិបត្តិ ក.អ.ក<br>▪ បានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំរបស់លេខាធិការដ្ឋានដឹកនាំ និងសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជានៃ ក.អ.ក | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានបន្តពង្រឹងសមត្ថភាពមន្ត្រី ក្នុងការរៀបចំអនុវត្ត និងពិនិត្យការតាមដានអនុវត្តគោលនយោបាយនេះ បន្ថែមលើតួនាទីជាប្រតិបត្តិករ តាមរយៈការបញ្ជូនមន្ត្រីជំនាញឱ្យចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលពាក់ព័ន្ធទាំងក្នុងប្រទេស និងក្រៅប្រទេស។<br>- រដ្ឋបាលខេត្តកោះកុង៖<br>ក្នុងឆ្នាំ២០១៧៖<br>▪ បានចាត់តាំងមន្ត្រីជំនាញ ០១រូបទៅចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី "Economic Corridor Development for Competitive an Inclusive Asia training" នៅប្រទេសសិង្ហបុរី ម៉ាឡេស៊ី និងព្រះរាជាណាចក្រថៃ<br>▪ បានចាត់តាំងមន្ត្រីជំនាញ ០១រូបទៅចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី Special Economic Zones (SEZs) as Catalysts for Economic Corridors, Value Chain and production Networks នៅទីក្រុងសៀងហៃនៃសាធារណរដ្ឋប្រជាមានិតចិន។<br>ក្នុងឆ្នាំ២០១៨៖<br>▪ មន្ត្រីចំនួន ០២រូបបានចូលរួមសិក្ខាសាលាបណ្ដុះបណ្ដាលស្ដីពីការជំរុញការវិនិយោគដែលរៀបចំឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅខេត្តសៀមរាប<br>▪ អភិបាលរងនៃគណៈអភិបាលខេត្តបានដឹកនាំមន្ត្រីជំនាញ ០៤រូបចូលរួមផ្សព្វផ្សាយ និងទាក់ទាញអ្នកវិនិយោគនៅខេត្តសាងស៊ីនៃសាធារណរដ្ឋប្រជាមានិតចិន | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានចាត់តាំងមន្ត្រីជំនាញ ០១រូបទៅចូលរួមកម្មវិធីទស្សនកិច្ចសិក្សាស្តីពីការជំរុញគម្រោងវិនិយោគ និងកិច្ចសម្រួលវិនិយោគ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ។ | |
| - ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃយន្តការត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោងវិនិយោគ ដើម្បីជានាការគោរពគោលការណ៍និងលក្ខខណ្ឌនៃកិច្ចសន្យាវិនិយោគ ព្រមទាំងអនុលោមភាពនៃច្បាប់កម្ពុជាជាធរមាន | ២០១៥ ទៅ មធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ÷<br>ការងារឆ្នាំ២០១៧-២០១៨÷<br>▪ បានធ្វើការងារជាច្រើនក្នុងគោលបំណងពង្រឹង និងធ្វើឱ្យប្រសើរឡើងនូវយន្តការត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោងវិនិយោគ ដូចខាងក្រោម÷<br>- ការចុះពិនិត្យលើការអនុវត្តគម្រោងវិនិយោគចំនួន ៧៧ ក្រុមហ៊ុន<br>- ការងារតាមដានក្រុមហ៊ុនអត់សកម្មភាពចំនួន ៩២ក្រុមហ៊ុន<br>- ការចុះពិនិត្យទីតាំងស្នើសុំវិនិយោគ ចំនួន ២៧៧សំណើ<br>- ការពិនិត្យលើសំណើសុំនាំចូលដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ ចំនួន ១.១៨៤សំណើ<br>- ការពិនិត្យលើសំណើសុំពង្រីកផលិតកម្ម ចំនួន ៦០សំណើ<br>- ការពិនិត្យលើសំណើសុំប្តូរទីតាំង ចំនួន ៣១ សំណើ<br>- ការពិនិត្យលើសំណើសុំបិទទីតាំងពង្រីកផលិតកម្ម ចំនួន ៣ សំណើ<br>- ការពិនិត្យលើសំណើសុំផ្ទេរ-ទទួល នូវគ្រឿងម៉ាស៊ីន ចំនួន ៤៨សំណើ<br>- ការពិនិត្យលើសំណើសុំកម្ទេចនូវគ្រឿងម៉ាស៊ីន និងវត្ថុធាតុដើម ចំនួន ៧សំណើ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័នដឹកនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | - ការពិនិត្យលើសំណើសុំនាំចេញនូវគ្រឿងម៉ាស៊ីន ចំនួន ២ សំណើ។<br>▪ បង្កើនល្បឿន និងភាពសកម្មថែមទៀត ក្នុងការធ្វើបច្ចុប្បន្នកម្មតួលេខវិនិយោគ ដើម្បីក្តាប់ឱ្យបាននូវទុនវិនិយោគ និងការប្រើប្រាស់កម្លាំងពលកម្មជាក់ស្តែងរបស់ក្រុមហ៊ុននីមួយៗ ដោយបញ្ចូលក្នុងប្រព័ន្ធទិន្នន័យ<br>▪ រៀបចំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យការអនុវត្តគម្រោងរបស់បណ្តាក្រុមហ៊ុន ដែលបានចុះកិច្ចសន្យាវិនិយោគលើកោះនានា នៅខេត្តកែប កំពត ព្រះសីហនុ និងកោះកុង<br>▪ បន្តតាមដាន និងជំរុញការអនុវត្តជាក់ស្តែងរបស់បណ្តាតំបន់សេដ្ឋកិច្ចពិសេស ដែលបានទទួលអនុក្រឹត្យបង្កើតតំបន់សេដ្ឋកិច្ចពិសេសពីរាជរដ្ឋាភិបាលឱ្យស្របតាមគោលការណ៍កំណត់<br>▪ បន្តពិនិត្យ តាមដាន និងទប់ស្កាត់ការនាំចូលខុសពីគោលការណ៍អនុញ្ញាត នៃបណ្តាគម្រោងវិនិយោគនៅក្នុងតំបន់ ពើមរយៈរដ្ឋបាលតំបន់<br>▪ បន្តតាមដានការអនុវត្តជាក់ស្តែងរបស់បណ្តាក្រុមហ៊ុនវិនិយោគតាមបណ្តាកោះ-ឆ្នេរ ដែលបានចុះហត្ថលេខារួច ដើម្បីជំរុញការអនុវត្តស្របតាមគោលការណ៍កំណត់<br>▪ បានរៀបចំ និងចងក្រងប្រព័ន្ធត្រួតពិនិត្យ និងតាមដានការអនុវត្ត និងប្រតិបត្តិការរបស់គម្រោងវិនិយោគ ទាំងរបស់អ្នកអភិវឌ្ឍន៍តំបន់ និងទាំងអ្នកវិនិយោគក្នុងបណ្តាតំបន់សេដ្ឋកិច្ចពិសេស និង | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ស្វែងយល់អំពីបញ្ហាប្រឈម និង/ឬវិវាទផ្សេងៗ ដើម្បីរកដំណោះស្រាយសមស្រប និងបានទាន់ពេលវេលា<br>▪ បាននិងកំពុងរៀបចំ សម្អាត និងបែងចែកទិន្នន័យគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលនៅមានដំណើរការ និងលែងមានដំណើរការ។<br>- ក្រសួងបរិស្ថាន÷<br>▪ បានដាក់ចេញនូវសារាចរណែនាំលេខ ១៩៤ សជណ.បស្ថ ស្តីពីការដាក់ចេញនូវវិធានការសម្រាប់កិច្ចគាំពារបរិស្ថានពីប្រភពដែលមានគោលដៅណែនាំដល់ម្ចាស់រោងចក្រឱ្យយកចិត្តទុកដាក់ក្នុងការចាត់ និងអនុវត្តវិធានការគ្រប់គ្រងសំណល់ និងការទប់ស្កាត់ការបំពុលបរិស្ថាន<br>▪ បានដាក់ចេញនូវប្រកាសលេខ ១១៦ ប្រក.បស្ថ ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូលក្ខខណ្ឌការងារសម្រាប់គម្រោងបង្កើតរោងចក្រ និងសិប្បកម្ម ដែលមានគោលដៅណែនាំដល់ម្ចាស់រោងចក្រសិប្បកម្មពីទំហំការងារនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលត្រូវរៀបចំក្រោមបញ្ញត្តិច្បាប់បរិស្ថាន<br>▪ បាននិងកំពុងលើកកម្ពស់ការយល់ដឹងអំពីបរិស្ថានដល់សាធារណៈជន និងវិស័យឯកជនតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា សំដៅកែប្រែទម្លាប់ និងផ្នត់គំនិតដល់សាធារណៈជនឱ្យអនុវត្តទម្លាប់ល្អខាងប្រតិបត្តិការបៃតង និងមេត្រីភាពបរិស្ថាន ដើម្បីធានាប្រសិទ្ធភាពនៃកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷<br>▪ បានបន្តវាយតម្លៃទំហំទំនិញនាំចូល និងទឹកប្រាក់ពន្ធ និងអាករជាបន្ទុករដ្ឋរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមខែនីមួយៗជាប្រចាំ<br>▪ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពីយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ជូនដល់វិស័យឯកជនចំនួន ៣ដង<br>▪ បានបន្តពង្រីកយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយតាមអាជីវកម្មដ្ឋានពីវិស័យកាត់ដេរទៅវិស័យនិងរបបគយផ្សេងទៀត តាមការជ្រើសរើសកម្រិតហានិភ័យ ចំនួន ២៩ក្រុមហ៊ុន<br>▪ បានចូលរួមចុះត្រួតពិនិត្យការអនុវត្តគម្រោងវិនិយោគនិងសំណើសុំផ្ទេរ លក់ និងបោះបង់ចោលទំនិញទទួលបានការលើកទឹកចិត្តរបស់ គ.ល.គ ចំនួន៤៧ក្រុមហ៊ុន។<br>▪ បានចុះបញ្ជីក្រុមហ៊ុនថ្មីដែលមានអនុលោមខ្ពស់ (Best Traders Group) ក្នុងឆ្នាំ២០១៨ ចំនួន១៣ក្រុមហ៊ុន និងគិតត្រឹមឆ្នាំ ២០១៨ មានសរុបចំនួន ៣០ក្រុមហ៊ុន<br>▪ បានចេញវិញ្ញាបនបត្រអនុលោមភាពជូនអ្នកជាប់ពន្ធ (អនុលោមភាពមាសបានចំនួន ៦៥សហគ្រាស)<br>▪ បានចូលរួមក្នុងការពង្រឹង និងតាមដាននូវគម្រោងវិនិយោគតាមរយៈការវាយតម្លៃ និងការផ្តល់ជូននូវវិញ្ញាបនបត្របញ្ជាក់ពីការបំពេញកាតព្វកិច្ចសារពើពន្ធរបស់សហគ្រាសវិនិយោគ។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ចូលរួមក្នុងការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃយន្តការត្រួតពិនិត្យនិងតាមដានការអនុវត្តគម្រោងវិនិយោគក្នុងវិស័យប្រេងឥន្ធនៈ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន<br>▪ កំពុងពិនិត្យតាមដានគម្រោងខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រ និងគម្រោងវិនិយោគទូរគមនាគមន៍ផ្សេងទៀត។<br>- រដ្ឋបាលខេត្តកណ្តាល ដាក់ចេញនូវសេចក្តីសម្រេចស្តីពីការបង្កើតអនុគណៈកម្មការវិនិយោគខេត្ត។ | |
| - ពង្រឹងយន្តការផ្តល់សេវាថែទាំវិនិយោគ ដោយផ្អែកលើឧត្តមានុវត្តន៍ជាសកល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការសម្រួលការ វិនិយោគ និងដោះស្រាយបញ្ហាប្រឈមរបស់វិនិយោគិន ក្នុងគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោងវិនិយោគ | ២០១៥ ទៅមុខ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ការងារឆ្នាំ២០១៧-២០១៨÷<br>▪ បានបន្តពិភាក្សា និងរៀបចំយន្តការផ្ទៃក្នុង ដើម្បីគាំទ្រដល់វេទិការាជរដ្ឋាភិបាលជាមួយវិស័យឯកជន ព្រមទាំងបន្តចូលរួមកិច្ចប្រជុំក្រុមការងារតាមវិស័យ និងកិច្ចប្រជុំផ្សេងៗដែលពាក់ព័ន្ធ<br>▪ បានដឹកនាំកិច្ចប្រជុំលើកទី១៥ និងទី១៦ នៃគណៈកម្មាធិការចម្រុះកម្ពុជា-ជប៉ុន ក្រោមកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងជប៉ុន ស្តីពីសេរីភាវូបនីយកម្ម ការជំរុញ និងការការពារវិនិយោគ<br>▪ បានដឹកនាំកិច្ចប្រជុំរវាង ក.អ.ក និងសភាពាណិជ្ជកម្មកម្ពុជា ក្នុងគោលបំណងបង្កើនទំនាក់ទំនងឱ្យកាន់តែមានភាពជិតស្និទ្ធរវាង ក.អ.ក និងវិស័យឯកជន តាមរយៈការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមក ព្រមទាំងធ្វើបច្ចុប្បន្នភាពនៃគោលនយោបាយគាំទ្រនានាដែលរាជរដ្ឋាភិបាលបានដាក់ចេញដើម្បីអភិវឌ្ឍវិស័យឯកជន | |

| ទិសដៅការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | សំដៅផ្ដល់នូវទំនុកចិត្តបន្ថែមទៀតដល់ផ្នែកឯកជនក្នុងការធ្វើប្រតិបត្តិការធុរកិច្ច និងវិនិយោគនៅកម្ពុជា<br>▪ បានដឹកនាំកិច្ចប្រជុំលើកទី២ នៃគណៈកម្មាធិការសេដ្ឋកិច្ចចម្រុះកម្ពុជា-កូរ៉េ។ | |
| - បន្តពង្រឹងប្រសិទ្ធភាពនៃ *"វេទិការាជរដ្ឋាភិបាលជាមួយនឹងវិស័យឯកជន"* ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម | ២០១៥ ទៅ មធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ការងារឆ្នាំ២០១៧-២០១៨÷<br>▪ បានបន្តពិភាក្សា និងរៀបចំយន្តការផ្ទៃក្នុង ដើម្បីគាំទ្រដល់វេទិការាជរដ្ឋាភិបាលជាមួយវិស័យឯកជន ព្រមទាំងបន្តចូលរួមកិច្ចប្រជុំក្រុមការងារតាមវិស័យ និងកិច្ចប្រជុំផ្សេងៗដែលពាក់ព័ន្ធ<br>▪ បានដឹកនាំកិច្ចប្រជុំរវាង ក.អ.ក និងសភាពាណិជ្ជកម្មកម្ពុជា ក្នុងគោលបំណងបង្កើនទំនាក់ទំនងឱ្យកាន់តែមានភាពជិតស្និទ្ធរវាង ក.អ.ក និងវិស័យឯកជន តាមរយៈការផ្លាស់ប្ដូរព័ត៌មានគ្នាទៅវិញទៅមក ព្រមទាំងធ្វើបច្ចុប្បន្នភាពនៃគោលនយោបាយគាំទ្រនានាដែលរាជរដ្ឋាភិបាលបានដាក់ចេញដើម្បីអភិវឌ្ឍវិស័យឯកជន សំដៅផ្ដល់នូវទំនុកចិត្តបន្ថែមទៀតដល់ផ្នែកឯកជនក្នុងការធ្វើប្រតិបត្តិការធុរកិច្ច និងវិនិយោគនៅកម្ពុជា។ | |
| - រៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រ និងវិធានការជាក់ស្ដែង ដើម្បីជំរុញការផ្សព្វផ្សាយ និងទាក់ទាញការវិនិយោគ ដោយផ្ដោតលើប្រទេសគោលដៅមួយចំនួន និងកំណត់ប្រភេទឧស្សាហកម្មអាទិភាពច្បាស់លាស់ | ២០១៥ ទៅ មធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ការងារឆ្នាំ២០១៧-២០១៨÷<br>▪ បានបញ្ចប់ការរៀបចំវីដេអូផ្សព្វផ្សាយ ដើម្បីទាក់ទាញការវិនិយោគដែលផ្ដោតទៅលើប្រទេសគោលដៅមួយចំនួនដូចជាជប៉ុន និងចិន | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានសហការរៀបចំ និងចូលរួមសិក្ខាសាលា និងវេទិកាពាក់ព័ន្ធនឹងការទាក់ទាញវិនិយោគទាំងក្នុង និងក្រៅស្រុក សរុបចំនួន ២៧ លើក<br>▪ បាននិងកំពុងរៀបចំសេចក្តីព្រាងឯកសារទស្សនាទានស្តីពីយុទ្ធសាស្ត្រទាក់ទាញវិនិយោគចំគោលដៅ<br>▪ បាននិងកំពុងបន្តកិច្ចសហការជាមួយអ្នកអភិវឌ្ឍន៍តំបន់លើកិច្ច-ការផ្សព្វផ្សាយ និងទាក់ទាញអ្នកវិនិយោគថ្មីៗឱ្យមកបណ្តាក់ទុនវិនិយោគនៅតំបន់នានាដែលបានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងមានដំណើរការរដ្ឋបាលក្នុងតំបន់រួច<br>▪ បានរៀបចំដំណើរទស្សនកិច្ចទៅកាន់រោងចក្រនៅតាមបណ្តាតំបន់សេដ្ឋកិច្ចពិសេស<br>▪ បានទទួលជួបគណៈប្រតិភូពីបណ្តាប្រទេសផ្សេងៗ ដើម្បីពិភាក្សាការងារលើគម្រោងវិនិយោគអភិវឌ្ឍន៍តំបន់ និងគម្រោងវិនិយោគក្នុងតំបន់<br>▪ បានរៀបចំ និងចូលរួមសកម្មភាព សិក្ខាសាលា ឬវេទិកា ទាំងក្នុង និងក្រៅប្រទេស ទាក់ទងនឹងការទាក់ទាញវិនិយោគ។ | |
| - ពិនិត្យឡើងវិញនូវយន្តការផ្តល់ព័ត៌មានវិនិយោគ ដោយយកចិត្តដាក់លើភាពងាយស្រួលក្នុងការទទួលព័ត៌មាន ពិសេស ការកែលម្អមាតិកាព័ត៌មាន ដែលផ្អែកលើប្រតិកម្មតបនៃអ្នកប្រើប្រាស់។ | ២០១៥ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ការងារឆ្នាំ២០១៧-២០១៨÷<br>▪ បានបន្តធ្វើបច្ចុប្បន្នភាពជាប្រចាំនៅលើគេហទំព័ររបស់ខ្លួន និងបទបង្ហាញស្តីពីការជំរុញការទាក់ទាញវិនិយោគឱ្យកាន់តែមានភាពទាក់ទាញ និងផ្តល់ព័ត៌មានកាន់តែគ្រប់ជ្រុងជ្រោយជូនអ្នកវិនិ-យោគ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងការដាក់ឱ្យប្រើប្រាស់ការផ្តល់ព័ត៌មានសេវាសាធារណៈ (សេវាអាទិភាព) តាមបច្ចេកវិទ្យាទូរស័ព្ទឆ្លាតហ្មូន<br>▪ បានបន្តធ្វើការស្រាវជ្រាវ និងធ្វើបច្ចុប្បន្នភាពលើបទបង្ហាញស្តីពីការជំរុញការទាក់ទាញវិនិយោគឱ្យកាន់តែមានភាពទាក់ទាញ និងផ្តល់ព័ត៌មានកាន់តែគ្រប់ជ្រុងជ្រោយជូនអ្នកវិនិយោគ។ | |
| *ខ-ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងការរៀបចំតំបន់ឧស្សាហកម្ម* | | | |
| - ពិនិត្យឡើងវិញអំពីក្របខ័ណ្ឌលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទាំងក្រុមហ៊ុនបរទេស ទាំងក្រុមហ៊ុនក្នុងស្រុក និងទាំងសហគ្រាសធុនតូច និងមធ្យម | ២០១៥ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសក្នុងកម្រិតបច្ចេកទេស ដោយបានធ្វើការគិតគូរផ្តល់ការលើកទឹកចិត្តពិសេសជូនក្រុមហ៊ុនទាំងឡាយរាប់ទាំងសហគ្រាសធុនតូចនិងមធ្យម ដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷<br>▪ បានបន្តអនុវត្តការលើកលែងពន្ធលើអចលនទ្រព្យសម្រាប់ក្រុមហ៊ុនដែលមានទីតាំងស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ហើយដែលបម្រើផ្ទាល់ដល់សកម្មភាពផលិតកម្ម (ប្រកាសលេខ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ<br>▪ បានបន្តចូលរួមពិនិត្យពិចារណាលើប្រព័ន្ធលើកទឹកចិត្ត ពន្ធអាករ និងពន្ធគយតាមរយៈកិច្ចប្រជុំ ដើម្បីកសាងសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ពាក់ព័ន្ធ និងការគ្រប់គ្រងវិនិយោគ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានដាក់ចេញនូវយន្តការអនុគ្រោះពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែមសម្រាប់ចំណាយលើការដឹកជញ្ជូន ស្នាក់នៅ និងហូបចុករបស់កម្មករនិយោជិត។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>ការងារឆ្នាំ២០១៧-២០១៨÷<br>▪ បានចូលរួមជាសមាជិកក្នុងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេស និងចូលរួមយ៉ាងសកម្មក្នុងការផ្តល់ធាតុចូល និងកិច្ចប្រជុំ "ច្រកចេញ-ចូលតែមួយ"របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើការអនុម័តលើកទឹកចិត្តដល់គម្រោងវិនិយោគបង្កើតតំបន់សេដ្ឋកិច្ចពិសេស<br>▪ បានរៀបចំធ្វើគោលនយោបាយជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ក្នុងនោះបានគិតគូរពីការកំណត់និយមន័យសហគ្រាសធុនតូច និងមធ្យមឡើងវិញតាមវិស័យ ក្នុងគោលបំណងឱ្យមានការកំណត់ការលើកទឹកចិត្តចំគោលដៅជាពិសេសបានគិតគូរពីការលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យមដែលស្ថិតនៅក្នុងតំបន់ ឬចង្កោមប្រមូលផ្តុំ (SME Cluster Zone)។ | |
| - ចាត់វិធានការ និងជំរុញឱ្យមានការចូលរួមកាន់តែសកម្មថែមទៀតពីវិស័យឯកជន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្តាទីតាំងនៃតំបន់សេដ្ឋកិច្ចពិសេសដែលបានទទួល គោលការណ៍ពីរាជរដ្ឋាភិបាលកន្លងមក សំដៅ ធានាឱ្យ | ២០១៩ មធ្យម ទៅ វែង | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ÷<br>ការងារឆ្នាំ២០១៧-២០១៨÷<br>▪ បាននិងកំពុងជំរុញអ្នកអភិវឌ្ឍតំបន់ឱ្យបន្តកាន់តែសកម្មថែមទៀតក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ច | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ សមត្ថភាពធនធានមនុស្ស និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត។ |

| **វិធានការគោលនយោបាយ/ផែនការសកម្មភាព** | **រយៈពេល/ឆ្នាំ** | **ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព** | **ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)** |
|---|---|---|---|
| មានភាពទាក់ទាញ និងការចាប់អារម្មណ៍ពីសំណាក់វិនិយោគិន ដែលកំពុងស្វែងរកទីតាំងបង្កើតមូលដ្ឋានផលិតកម្មក្នុងតំបន់ទាំងនោះ | | ពិសេសរៀងៗខ្លួន ដែលមានដូចជាផ្លូវថ្នល់ លូទឹក សួនច្បារ បណ្ដាញទឹក-ភ្លើង ការឈូសឆាយដី ការដាំដើមឈើ ជាដើម<br>▪ បានសម្របសម្រួល និងលើកទឹកចិត្តដល់ការអភិវឌ្ឍតំបន់ប្រកបភាតរភាពបរិស្ថាន។ ជាក់ស្ដែង មានការរៀបចំបំពាក់នូវប្រព័ន្ធប្រើប្រាស់ថាមពលដើរដោយពន្លឺព្រះអាទិត្យ ក្នុងគោលបំណងសន្សំសំចៃថាមពល និងផ្គត់ផ្គង់ការប្រើប្រាស់ក្នុងតំបន់ នៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងមានការរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមួយចំនួនទៀត<br>▪ បានចូលរួមជំរុញទាក់ទាញគម្រោងវិនិយោគចំនួន ៤៧ថ្មី នៅក្នុងឆ្នាំ២០១៧ និងចំនួន ៧៩ថ្មី នៅក្នុងឆ្នាំ២០១៨ ពីវិស័យឯកជនឱ្យធ្វើការវិនិយោគ នៅតាមបណ្ដាតំបន់សេដ្ឋកិច្ចពិសេស។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំបទដ្ឋានគតិយុត្ត និងនីតិវិធីប្រតិបត្តិការសម្រាប់គ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន។<br>- រដ្ឋបាលខេត្តស្វាយរៀង បានសហការជាមួយបណ្ដាភាគីពាក់ព័ន្ធ និងផ្នែកឯកជន ក្នុងការគាំទ្រការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មដែលមានស្រាប់ និង/ឬបង្កើតថ្មីក្នុងដែនសមត្ថកិច្ចខេត្តស្វាយរៀង។ | - រដ្ឋបាលខេត្តស្វាយរៀង ÷ មន្ទីរ អង្គភាពពាក់ព័ន្ធមួយចំនួនពុំទាន់អនុវត្តបានល្អប្រសើរស្របតាមផែនការសកម្មភាពដែលបានកំណត់។ |
| - ជំរុញការបង្កើតកម្រងឧស្សាហកម្ម និងសួនឧស្សាហកម្មធំៗ តាមរយៈការអនុម័ត *"ច្បាប់ស្ដីពីតំបន់សេដ្ឋកិច្ចពិសេស"* សំដៅអភិវឌ្ឍតំបន់ទាំងនោះឱ្យឈានដល់កម្រិតស្តង់ដារអន្តរជាតិលើគ្រប់ទិដ្ឋភាព រួមមាន ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានហេ | ២០១៥ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ បានរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីតំបន់សេដ្ឋកិច្ចពិសេសក្នុងកម្រិតបច្ចេកទេស ដោយបានគិតគូរគ្រប់ជ្រុងជ្រោយពីប្រព័ន្ធគ្រប់គ្រងមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ ការ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| ដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត វត្ថុធាតុដើម និងធាតុចូលផ្សេងៗ កិច្ចសម្រួលការដឹកជញ្ជូន និងពាណិជ្ជកម្ម ព្រមទាំងការលើកទឹកចិត្ត និងវិធានការគាំទ្រជាក់ស្តែងផ្សេងទៀត ដើម្បីជំរុញការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស | | ផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត វត្ថុធាតុដើមនិងធាតុចូលផ្សេងៗ កិច្ចសម្រួលការដឹកជញ្ជូន និងពាណិជ្ជកម្ម ព្រមទាំងការលើកទឹកចិត្តជាដើម។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានជំរុញដាក់ឱ្យដំណើរការនូវរបបគយព្យួរពន្ធក្នុងតំបន់សេដ្ឋកិច្ចពិសេស ដូចជា ភណ្ឌាគារគយមានដែនកំណត់ និងមណ្ឌលផលិតកម្ម ឬសេវាកម្មក្នុងទម្រង់នានា<br>▪ បានបន្តផ្សព្វផ្សាយ និងអនុវត្តឱ្យបានពេញលេញនូវនីតិវិធីគយពិសេសក្នុងតំបន់សេដ្ឋកិច្ចពិសេស ភ្ជាប់ជាមួយអនុក្រឹត្យពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសជាធរមានសម្រាប់ជាមូលដ្ឋានក្នុងការកសាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស<br>▪ បានជំរុញឱ្យមានការបែងចែកដែនគយក្នុងតំបន់សេដ្ឋកិច្ចពិសេស ជាពីរផ្នែកតាមបទប្បញ្ញត្តិជាធរមាន គឺដែនគយជាតិ និងដែនគយពិសេសដែលទទួលបានការលើកទឹកចិត្តផ្សេងពីគ្នា<br>▪ បានសិក្សារៀបចំសេចក្តីព្រាងបទប្បញ្ញត្តិស្តីពីភណ្ឌាគារមានដែនកំណត់សម្រាប់គ្រប់គ្រងទំនិញដែលផលិតក្នុងតំបន់សេដ្ឋកិច្ចពិសេស<br>▪ បានរៀបចំប្រកាសស្តីពីការអនុវត្តអាករលើតម្លៃបន្ថែម ចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យា ដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ, ឧស្សាហកម្មវាយនភណ្ឌ, ឧស្សាហកម្មផលិតស្បែកជើង, ឧស្សាហកម្មផលិតកាបូបយួរ និងកាបូបដៃ, និងឧស្សាហកម្មផលិតមួក | |

| វិធានការគោលនយោបាយ/ផែនការ សកម្មភាព | រយៈពេល/ ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានរៀបចំសេចក្ដីព្រាងសេចក្ដីណែនាំស្ដីពីការធ្វើសវនកម្មលើវិស័យដឹកជញ្ជូន ដើម្បីឱ្យមានការឯកភាពគ្នាក្នុងរង្វង់សវនករពន្ធដារ ធានាបាននូវសង្គតិភាពក្នុងការធ្វើសវនកម្ម។<br>- រដ្ឋបាលខេត្តស្វាយរៀង<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានចូលរួមផ្ដល់ធាតុចូលដែលពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ក្នុងការរៀបចំច្បាប់ស្ដីពីតំបន់សេដ្ឋកិច្ចពិសេស ក្នុងឆ្នាំ២០១៧។ | |
| - បន្តអភិវឌ្ឍតំបន់ឧស្សាហកម្មតាមបណ្ដាខេត្តដែលជាមូលដ្ឋានប្រមូលផ្ដុំនៃសហគ្រាសធុនតូច និងមធ្យម សំដៅជំរុញលើកកម្ពស់ភាពប្រកួត-ប្រជែងនៃសហគ្រាសទាំងនោះ ពិសេសតាមរយៈការផ្ដល់អាទិភាពលើការតភ្ជាប់បណ្ដាញអគ្គិសនី និងការផ្គត់ផ្គង់ទឹកស្អាត ការតភ្ជាប់ផ្លូវដឹកជញ្ជូន និងភស្តុភារកម្ម ព្រមទាំងការសម្រួល និងការលើកទឹកចិត្តផ្សេងទៀតពីរដ្ឋ | មធ្យម ទៅ វែង | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖<br>ការងារឆ្នាំ២០១៧-២០១៨៖<br>▪ បានប្រជុំពិនិត្យលើគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួន ៤ (២ នៅខេត្តកំពត, ១ នៅខេត្តកំពង់ឆ្នាំង, និង ១ នៅខេត្តស្វាយរៀង) ក្នុងឆ្នាំ២០១៧<br>▪ បានប្រជុំពិនិត្យលើគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួន ៥ (១ នៅខេត្តកណ្ដាល, ១ នៅខេត្តកោះកុង, និង ៣ នៅខេត្តព្រះសីហនុ) ក្នុងឆ្នាំ២០១៨<br>▪ បានសម្រេចចេញអនុក្រឹត្យបង្កើតតំបន់សេដ្ឋកិច្ចចំនួន ២ នៅខេត្តស្វាយរៀង។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៧ តំបន់សេដ្ឋកិច្ចពិសេសមានចំនួនសរុប ៤៧តំបន់ ដែលក្នុងនោះ ៣២តំបន់ ត្រូវបានបង្កើតដោយអនុក្រឹត្យ ហើយ ១៩តំបន់ កំពុងមានដំណើរការ ដោយមានគម្រោងវិនិយោគសរុបចំនួន ៣៥១ ជាមួយនឹងទុនវិនិយោគចំនួន ២ប៊ីលានដុល្លារ និងអាចបង្កើតការងារចំនួនប្រមាណជា ១០ម៉ឺនកន្លែង | - រដ្ឋបាលខេត្តកណ្ដាល៖<br>▪ ថវិកាមិនទាន់ឆ្លើយតបទៅនឹងតម្រូវការនៃគម្រោង<br>▪ ដោះស្រាយផលប៉ះពាល់ជាមួយប្រជាជន។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានសម្រេចចេញអនុក្រឹត្យបង្កើតតំបន់សេដ្ឋកិច្ចចំនួន ២ នៅខេត្តព្រះសីហនុ។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៨ តំបន់សេដ្ឋកិច្ចមានចំនួនសរុប ៥៩តំបន់ ដែលក្នុងនោះ ៣៨តំបន់ ត្រូវបានបង្កើតដោយអនុក្រឹត្យ ហើយ ២០តំបន់ កំពុងមានដំណើរការ ដោយមានគម្រោងវិនិយោគសរុបចំនួន ៤០៤ ជាមួយនឹងទុនវិនិយោគចំនួន ៣ប៊ីលានដុល្លារ និងអាចបង្កើតការងារចំនួនប្រមាណជា ១១ម៉ឺនកន្លែង។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>ការងារឆ្នាំ២០១៧÷<br>▪ បាននិងកំពុងរៀបចំសេចក្ដីព្រាងច្បាប់ ស្ដីពីការផ្គត់ផ្គង់ទឹកស្អាត ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជន សម្រាប់ផ្គត់ផ្គង់ទឹកស្អាតដល់រោងចក្រ សហគ្រាសកម្មន្តសាល និងតំបន់អភិវឌ្ឍន៍ពាក់ព័ន្ធវិស័យឧស្សាហកម្មនានា ដើម្បីសម្រេចគោលដៅនៃការផ្គត់ផ្គង់ទឹកស្អាត ប្រើប្រាស់នៅទីប្រជុំជនឱ្យបាន ១០០% នៅឆ្នាំ២០២៥<br>▪ បានធ្វើកំណែទម្រង់ក្នុងការផ្គត់ផ្គង់ទឹកស្អាត ដោយបានដាក់ចេញនូវគោលការណ៍លើកទឹកចិត្តឱ្យវិស័យឯកជនចូលរួមធ្វើការវិនិ-យោគបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅតាមទីប្រជុំជន ស្រុក ឃុំ សង្កាត់ ដែលរដ្ឋមិនទាន់មានលទ្ធភាពធ្វើបាន ដោយផ្ដល់សិទ្ធិធ្វើអាជីវកម្មរហូតដល់២០ឆ្នាំ ដែលពីមុនអនុញ្ញាតឱ្យត្រឹម៣ឆ្នាំ ដើម្បីធានាបាននិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាត និងពង្រីកផ្ទៃសេវាផ្គត់ផ្គង់ឱ្យបានលឿន | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានអនុវត្តគោលនយោបាយផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារក្រីក្រ ឬមានចំណូលទាប និងសម្រាប់និស្សិត កម្មករ កម្មការិនី ស្នាក់នៅបន្ទប់ជួល ទោះបីការកំណត់ថ្លៃទឹកថ្មីនេះទាបជាងថ្លៃដើមផលិតក្តី<br>▪ ក្នុងឆ្នាំ២០១៧ ការផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជន បានសរុបចំនួន ២៨០,៨១៣,១៣៧ម$^{៣}$ ដែលបានផ្តល់ឱ្យប្រជាជនប្រមាណ ៨៥.៨៤% រស់នៅទីប្រជុំជនទូទាំងប្រទេសទទួលបានទឹកស្អាតប្រើប្រាស់។<br>ការងារឆ្នាំ២០១៧-២០១៨÷<br>▪ បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជន សម្រាប់ផ្គត់ផ្គង់ទឹកស្អាតដល់រោចក្រ សហគ្រាសកម្មន្តសាល និងតំបន់អភិវឌ្ឍន៍ពាក់ព័ន្ធវិស័យឧស្សាហកម្មនានា ដើម្បីសម្រេចគោលដៅនៃការផ្គត់ផ្គង់ទឹកស្អាត ប្រើប្រាស់នៅទីប្រជុំជនឱ្យបាន ១០០% នៅឆ្នាំ២០២៥<br>▪ បានធ្វើកំណែទម្រង់ក្នុងការផ្គត់ផ្គង់ទឹកស្អាត ដោយបានដាក់ចេញនូវគោលការណ៍លើកទឹកចិត្តឱ្យវិស័យឯកជនចូលរួមធ្វើការវិនិយោគបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅតាមទីប្រជុំជន ស្រុក ឃុំ សង្កាត់ ដែលរដ្ឋមិនទាន់មានលទ្ធភាពធ្វើបាន ដោយផ្តល់សិទ្ធិធ្វើអាជីវកម្មរហូតដល់២០ឆ្នាំ ដែលពីមុនអនុញ្ញាតឱ្យត្រឹម៣ឆ្នាំ ដើម្បីធានាបាននិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាត និងពង្រីកផ្ទៃសេវាផ្គត់ផ្គង់ឱ្យបានលឿន | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានអនុវត្តគោលនយោបាយផ្គត់ផ្គង់ទឹកស្អាតដល់គ្រួសារក្រីក្រ ឬមានចំណូលទាប និងសម្រាប់និស្សិត កម្មករ កម្មការិនី ស្នាក់នៅបន្ទប់ជួល ទោះបីការកំណត់ថ្លៃទឹកថ្មីនេះទាបជាងថ្លៃដើមផលិតក្តី។<br>- រដ្ឋបាលខេត្តកណ្តាល៖<br>ក្នុងឆ្នាំ២០១៧៖<br>▪ បានតភ្ជាប់បណ្តាញអគ្គិសនីចំនួន ១០០៦ភូមិលើ ១០១០ភូមិ<br>▪ បណ្តាញផ្គត់ផ្គង់ទឹក ៤៤មូលដ្ឋាន<br>▪ ផ្លូវបេតុងចំនួន ៥៤ខ្សែ ប្រវែង ២៧.៧៤៣ម៉ែត្រ និងផ្លូវជីល្បាយភ្នំ ២ខ្សែ ប្រវែង ២.៥៨៥ម៉ែត្រ<br>▪ បង្គោលភ្លើងបំភ្លឺសាធារណៈ៥ខ្សែ ៨៤បង្គោល<br>▪ សាងសង់អគារច្រកចេញចូលតែមួយ ១អគារ<br>▪ សាងសង់អគារសាលាឃុំ ២អគារ។<br>ក្នុងឆ្នាំ២០១៨៖<br>▪ បានតភ្ជាប់បណ្តាញអគ្គិសនីចំនួន ១០០៨ភូមិលើ ១០១០ភូមិ<br>▪ បណ្តាញផ្គត់ផ្គង់ទឹក អាជីវកម្មទឹកស្អាតឯកជន ៤៨មូលដ្ឋាន កើនលើសឆ្នាំ២០១៧ ចំនួន ៤មូលដ្ឋាន។ ចំនួនភូមិគ្របដណ្តប់មាន ៦៤៩ភូមិ កើន ៨៦ភូមិ។ ចំនួនខ្នងផ្ទះបានតទឹកមាន ៨៩.១៧៧ខ្នង កើន ១២.៥៩២ខ្នងផ្ទះ។<br>▪ ផ្លូវបេតុង ៤០ខ្សែ ប្រវែង ៣៣.៨៣៤ម៉ែត្រ<br>▪ ផ្លូវគ្រួសក្រហម ២ខ្សែ ប្រវែង ៦.០៥០ម៉ែត្រ<br>▪ បង្គោលភ្លើងបំភ្លឺសាធារណៈ១០ខ្សែ ស្មើនឹង ៣២១បង្គោល<br>▪ សាងសង់អគារច្រកចេញចូលតែមួយ ២អគារ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ សាងសង់អគារសាលាឃុំ ១០អគារ<br>▪ សាងសង់អគារសាលារៀន ១អគារ។<br>- រដ្ឋបាលខេត្តស្វាយរៀង÷<br>▪ បាននិងកំពុងបន្តអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការ សម្រាប់ការប្រមូល ទិន្នន័យពាណិជ្ជកម្មតាមច្រករបៀង សេដ្ឋកិច្ចភាគខាងត្បូង និងរវាងវិទ្យាស្ថានមេគង្គ ក្នុងការអនុវត្តគម្រោង លើកកម្ពស់ភាពប្រកួតប្រជែង នៃសហគ្រាសខ្នាតតូច និងមធ្យម នៅតាមច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង នៃប្រទេសអាស៊ាន នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលមានការគាំទ្រពីរដ្ឋាភិបាលជប៉ុន តាមរយៈមូលនិធិជប៉ុនអាស៊ាន (JAIF)<br>▪ បានដំណើរការគម្រោងអាងប្រព្រឹត្តិកម្ម និងទីលានញែកសំរាមសម្រាប់តំបន់ ឧស្សាហកម្មក្រុងបាវិត លើផ្ទៃដីប្រមាណ ២០ ហ.ត សម្រេចបាន ៣០%<br>▪ បច្ចុប្បន្នមានក្រុមហ៊ុន ចំនួន ៣ កំពុង ដំណើរការ គឺទី១ ក្រុមហ៊ុន សុវ៉ាស៊ីន ទទួលគ្រប់គ្រងកាកសំណល់ឧស្សាហកម្ម, ទី២ ក្រុមហ៊ុន ហាយប្រ៊ីដ ហ្គាបែធ ទទួលគ្រប់គ្រងកាកសំណល់ទីប្រជុំជន ក្រុងបាវិត និងទី៣ ក្រុមហ៊ុន សុភីសម្បត្តិ ទទួលគ្រប់គ្រងកាកសំណល់ទីប្រជុំជន នៅក្រុងស្វាយរៀង )<br>▪ បានដំណើរការអាងប្រព្រឹត្តិកម្មសំណល់រាវអាចចម្រោះបាន ១០.៣២៩ម៉ែត្រគូបក្នុង១ថ្ងៃ ដែលមានរោងចក្រចំនួន ០៨ កន្លែង និងតំបន់សេដ្ឋកិច្ចពិសេស ០២ (មេនហាតធេន និងតាយសេង) | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ដាក់ដំណើរការខ្សែបញ្ជូនតង់ស្យុង១៥០គីឡូវ៉ុល នៅត្រីមាសទី១ ឆ្នាំ ២០១៧ និងកំពុងបន្តចែកចាយពីអនុស្ថានីយប្រែកម្នេស ឆ្ពោះទៅអង្គភាពអគ្គិសនីខេត្តស្វាយរៀង និងឆ្ពោះទៅតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន ក្រុងបាវិត។<br>- រដ្ឋបាលខេត្តបន្ទាយមានជ័យ÷<br>ក្នុងឆ្នាំ២០១៨÷<br>▪ រៀបចំកែលម្អសួនច្បារសួនមានជ័យនិងដាំបង្គោលភ្លើងអមសងខាងផ្លូវ<br>▪ ការរៀបចំតម្លើងភ្លើងស្តុបផ្លូវរង្វង់មូលដៃសាមពីរ ១កន្លែង, ផ្លូវសាមគ្គី មានជ័យ ១ កន្លែង, ផ្លូវចូលផ្សាររាត្រី ១កន្លែង, ផ្លូវបំបែក៧មករា សង្កាត់ទឹកថ្លា ១កន្លែង, ប្តូរនៅកន្លែងស្តុបចាស់ ១កន្លែង<br>▪ ផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រង ការធ្វើអាជីវកម្មធនធានរ៉ែ<br>▪ ជំរុញការបន្តអាជ្ញាបណ្ណការដ្ឋានដែលអស់សុពលភាព<br>▪ ផ្សព្វផ្សាយសារាចរដល់គ្រប់អាជីវករស្តីពីគម្រោងផែនការអាជីវកម្មរ៉ែ ថ្មសំណង់<br>▪ ផ្សព្វផ្សាយប្រកាសស្តីពីនីតិវិធីស្វ័យប្រកាស និងបង់សួយសារលើតម្លៃធនធានរ៉ែ ដល់សម្បទាននិក ដែលមានអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ការធ្វើអាជីវកម្មរ៉ែ ថ្មសំណង់ដល់អាជីវករ<br>▪ អញ្ជើញម្ចាស់ការដ្ឋានមកប្រកាស និង បង់សួយសារ ត្រីមាសទី១ ឆ្នាំ២០១៩ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ចុះពិនិត្យការដ្ឋានអាជីវកម្មធនធានរ៉ែ នៅតំបន់ភ្នំរូងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ<br>▪ ចុះត្រួតពិនិត្យរណ្តៅដី នៅក្រុងប៉ោយប៉ែត<br>▪ ចុះពិនិត្យការដ្ឋានអាជីវកម្មធនធានរ៉ែ នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ<br>▪ ចុះពិនិត្យសកម្មភាពរ៉ែ អាចម៍ដីចល័ត នៅស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ<br>▪ ចុះត្រួតពិនិត្យការដ្ឋានរបស់លោក អាំង គីហេង នៅតំបន់ភ្នំស្លក្រាម ស្រុកស្វាយចេក<br>▪ ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៤-២០១៧ និងទិសដៅបន្តឆ្នាំ២០១៨ របស់ក្រសួងរ៉ែ និងថាមពល<br>▪ ចុះត្រួតពិនិត្យទីតាំងស្នើសុំធ្វើអាជីវកម្មធនធានរ៉ែរបស់លោក សឿម សំបូរ នៅតំបន់ភ្នំលៀប ស្រុកព្រះនេត្រព្រះ<br>▪ ចុះត្រួតពិនិត្យការដ្ឋានស្នើសុំអាជ្ញាបណ្ណ ដីក្រហម (ឡាតេរីត) នៅស្រុកព្រះនេត្រព្រះ<br>▪ ចូលរួមប្រជុំគណៈកម្មការកែលម្អសោភ័ណភាពស្រុកទប់ស្កាត់សំណង់អនាធិបតេយ្យ និងរៀបចំសណ្តាប់ធ្នាប់ ស្រុកអូរជ្រៅ<br>▪ ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី៧ លើកំណែទី១០ នៃសេចក្តីព្រៀងក្រមបរិស្ថាន និងធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា<br>▪ ចុះត្រួតពិនិត្យការដ្ឋានអាជីវកម្មរ៉ែ នៅក្រុងប៉ោយប៉ែត<br>▪ ចុះត្រួតពិនិត្យការដ្ឋានថ្មសំណង់នៅតំបន់ភ្នំធំ ស្រុកមង្គលបូរី | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ចូលរួមប្រជុំពិគ្រោះយោបល់ ស្តីពីគម្រោងផែនការចំណូលវិស័យធនធានរ៉ែប្រចាំឆ្នាំ២០១៩នៅទីស្តីការក្រសួងរ៉ែ និងថាមពល<br>▪ ចុះពិនិត្យអាជីវកម្មរ៉ែអនាធិបតេយ្យនៅក្នុងស្រុកព្រះនេត្រព្រះ<br>▪ ចុះពិនិត្យទីតាំងស្នើសុំអាជ្ញាបណ្ណថ្មសម្ភារៈសំណង់នៅតំបន់ភ្នំរូង ស្រុកម៉ាឡៃ<br>▪ ចុះពិនិត្យអាជីវកម្មធនធានរ៉ែនៅស្រុកថ្មពួក ក្រុងប៉ោយប៉ែត<br>▪ ចុះពិនិត្យការធ្វើអាជីវកម្មធនធានរ៉ែ នៅស្រុកព្រះនេត្រព្រះ<br>▪ ចូលរួមសហការត្រួតពិនិត្យទីតាំងដីសាធារណៈរបស់រដ្ឋដីភ្នំ នៅតំបន់ភ្នំសំពៅ ស្រុកព្រះនេត្រព្រះ<br>▪ ចុះពិនិត្យការធ្វើអាជីវកម្មធនធានរ៉ែនៅក្នុងស្រុកព្រះនេត្រព្រះ ក្រុងប៉ោយប៉ែត<br>▪ ចុះទៅពិភាក្សាការងារអំពីមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍នៅក្នុងឃុំអូរប្រាសាទ ស្រុកមង្គលបូរី<br>▪ ចុះពិនិត្យទីតាំងស្នើសុំអាជ្ញាបណ្ណថ្មី នៅតំបន់ភ្នំស្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ<br>▪ ចុះពិនិត្យការធ្វើអាជីវកម្មរ៉ែនៅតំបន់ភ្នំលៀប ស្រុកព្រះនេត្រព្រះ និងនៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ<br>▪ ចុះពិនិត្យការធ្វើអាជីវកម្មរ៉ែអនាធិបតេយ្យ នៅស្រុកភ្នំស្រុក និងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ<br>▪ ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងនីតិវិធីនៃការប្រមូលចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ និងការគ្រប់គ្រងគណនីទាំង២០៨របស់ក្រសួងរ៉ែ និងថាមពល | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ចុះទៅត្រួតពិនិត្យអ៊ិចស្តាចល័តក្នុងឃុំសារង្គ ស្រុកស្វាយចេក<br>▪ តម្លៃប្រើប្រាស់អគ្គិសនីសម្រាប់អតិថិជនទូទៅតាមបណ្តាស្រុកដែលតភ្ជាប់ពីសេវាករ ស្មើនឹង ៧៧០រៀលក្នុង១គីឡូវ៉ាត់ម៉ោង<br>▪ តម្លៃប្រើប្រាស់អគ្គិសនីសម្រាប់អតិថិជនទូទៅក្នុងក្រុងសិរីសោភ័ណដែលតភ្ជាប់ពីអគ្គិសនីបន្ទាយមានជ័យស្មើនឹង៧៥០រៀលក្នុង១គីឡូវ៉ាត់ម៉ោង ចាប់ពី ៥១គីឡូវ៉ាត់ម៉ោង ឡើងទៅ<br>▪ តម្លៃសម្រាប់អតិថិជនក្រីក្រទូទៅ នៅក្នុងខេត្តបន្ទាយមានជ័យដែលប្រើប្រាស់អគ្គិសនីត្រឹមតែ ១០គីឡូវ៉ាត់ម៉ោងចុះ ក្រោមស្មើនឹង ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង<br>▪ តម្លៃប្រើប្រាស់សម្រាប់អតិថិជនក្រីក្រទូទៅ នៅក្នុងខេត្តបន្ទាយមានជ័យដែលប្រើប្រាស់ អគ្គិសនីចាប់ពី១១គីឡូវ៉ាត់ម៉ោង ដល់ ៥០គីឡូវ៉ាត់ម៉ោង ស្មើនឹង៦១០ រៀលក្នុង១គីឡូវ៉ាត់ម៉ោង<br>▪ តម្លៃសម្រាប់អតិថិជនប្រើប្រាស់ក្នុងវិស័យកសិកម្ម ចាប់ពីម៉ោង ៩ យប់ ដល់ម៉ោង៧ព្រឹក ស្មើនឹង ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង(តម្លៃអនុគ្រោះតាមរយៈមូលនិធិអគ្គិសនីជនបទ)<br>▪ ផ្នែកផលិតនិងចែកចាយអគ្គិសនីខេត្តបន្ទាយមានជ័យមានចំនួន ២៣ អាជ្ញាបណ្ណគ្របដណ្តប់ លើស្រុកចំនួន ០៧ និងក្រុងចំនួន ០២ទូទាំងខេត្ត។ ហើយនឹងកំពុងដាំបង្គោល ពង្រីកបណ្តាញក្នុងឃុំសរុបចំនួន ៦៥ និងភូមិសរុបចំនួន៦៥៨ ភូមិ ចំពោះ បណ្តាញចរន្តដែលបានតចរន្តរួចមានចំនួន ៦៣៩ ភូមិ ស្មើ ៩៧.១% នៃចំនួនភូមិសរុប<br>▪ អាជ្ញាបណ្ណអគ្គិសនីសរុបក្នុងខេត្តមានចំនួន ២៣ អាជ្ញាបណ្ណ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ថាមពលផ្គត់ផ្គង់សរុបទូទាំងខេត្ត ស្មើនឹង៤៤៣.៣៨២.៥៦១ គីឡូវ៉ាត់ម៉ោង<br>▪ ថាមពលតម្រូវការមានចំនួនសរុបទូទាំងខេត្តស្មើ៤៥០.៣១៩.១៧៣ គីឡូវ៉ាត់ម៉ោង<br>▪ អតិថិជនប្រើប្រាស់សរុបទូទាំងខេត្តមានចំនួន ១២៣.០២៧ គ្រួសារ។ | |
| - ជំរុញការអភិវឌ្ឍរបៀងឧស្សាហកម្ម ពិសេសផ្តោតលើរបៀងសេដ្ឋកិច្ចតំបន់ឆ្នេរខាងត្បូង (Southern Coastal Economic Corridor) រួមមាន ខេត្តព្រះសីហនុ និងខេត្តកោះកុង ព្រម-ទាំងរបៀងតាមបណ្តោយផ្លូវជាតិសំខាន់ៗដែលតភ្ជាប់ប៉ូលសេដ្ឋកិច្ចក្នុងស្រុក ក៏ដូចជា តភ្ជាប់របៀងសេដ្ឋកិច្ចកម្ពុជាទៅនឹងប្រទេសជិតខាងនៅក្នុងក្របខ័ណ្ឌនៃរបៀងសេដ្ឋកិច្ចមហាអនុ-តំបន់មេគង្គ និងអាស៊ាន | មធ្យម ទៅ វែង | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ បានចូលរួមវេទិការបៀងសេដ្ឋកិច្ចមហាអនុតំបន់មេគង្គលើកទី៩ និងសន្និសីទថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់មេគង្គលើកទី២២ នៅប្រទេសវៀតណាម។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានវិភាជថវិកាចំនួន ៤០.៦៦១លានរៀល ជួសជុលផ្លូវជាតិលេខ ៤៨ ភ្នំពេញ-កោះកុង ប្រវែង ៧០.៧១៥ ម៉ែត្រ<br>▪ បានវិភាជថវិកា ១៥.០៦៦ លានរៀល សម្រាប់ជួសជុលផ្លូវជាតិលេខ ៤ ក្នុងព្រំដែនខេត្តព្រះសីហនុ ប្រវែង ២.៥៥០ ម៉ែត្រ។<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ បាន និងកំពុងរៀបចំផែនការរៀបចំដែនដីថ្នាក់ជាតិ និងតាមតំបន់<br>▪ បានរៀបចំ និងកំពុងស្នើសុំការអនុម័ត ផែនការរៀបចំដែនដីតំបន់ឆ្នេរ ផែនការរៀបចំដែនដីខេត្តចំនួន០២គឺ÷ ខេត្តបាត់ដំបង និងខេត្តព្រះសីហនុ ព្រមទាំង ប្លង់គោលប្រើប្រាស់ដីក្រុងចំនួន០១គឺ÷ ក្រុងសៀមរាប និងផែនការប្រើប្រាស់ដីនៅក្នុងឃុំចំនួន០២គឺ÷ ឃុំរាម និងឃុំអូរឧកញ៉ាហេង ខេត្តព្រះសីហនុ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងឃុំចំនួន២គឺៈ ឃុំទួលគគីរ និងឃុំតាតៃក្រោម ខេត្តកោះកុង<br>▪ បាននិងកំពុងរៀបចំផែនការរៀបចំដែនដីខេត្តចំនួន០៣គឺ÷ ខេត្តសៀមរាប ខេត្តតាកែវ និងខេត្តប៉ៃលិន ព្រមទាំងប្លង់គោលប្រើប្រាស់ដី ក្រុងចំនួន១៤ ស្រុកចំនួន០៧ និងទីប្រជុំជនចំនួន០៥ គឺ÷ ក្រុងព្រះសីហនុ ក្រុងបាត់ដំបង ក្រុងកែប ក្រុងសៀមរាប ក្រុងប៉ោយប៉ែត ក្រុងខេមរភូមិន្ទ ក្រុងបាវិត ក្រុងកំពង់ចាម ក្រុងសួង ក្រុងច្បារមន ក្រុងកំពត ក្រុងព្រៃវែង ក្រុងកំពង់ឆ្នាំង ក្រុងតាខ្មៅ ស្រុកស្ទឹងហាវ ស្រុករលាប្អៀរ ស្រុកលំផាត់ ស្រុកវ៉ើនសៃ ស្រុកថាឡាបរិវ៉ាត់ ស្រុកបរវេល និងស្រុកស្អាង ព្រមទាំងទីប្រជុំជនស្វាយអន្ទរ ទីប្រជុំជនអ្នកលឿង និងទីប្រជុំជនជ្រៃធំ និងទីប្រជុំជនទីរួមខេត្តត្បូងឃ្មុំ ទីប្រជុំជនទីរួមស្រុកចិត្របុរី។ ទន្ទឹមនេះក៏បាននិងកំពុងរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ចំនួន ០៦ ផងដែរគឺ÷ សង្កាត់ចំនួន០១ ក្នុងខេត្តកំពត, ឃុំចំនួន០៥ ក្នុងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។<br>▪ បានគាំទ្របច្ចេកទេសរៀបចំប្លង់បែងចែកតំបន់ប្រើប្រាស់ដី និងសន្ទស្សន៍ប្រើប្រាស់ដីនៅខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក និងខណ្ឌចំការមន រាជធានីភ្នំពេញ<br>▪ បានរៀបចំ និងកំពុងស្នើសុំការអនុម័តលើឯកសារក្របខណ្ឌអភិវឌ្ឍតំបន់ទីក្រុងជុំវិញបឹងទន្លេសាប<br>▪ បាននិងកំពុងរៀបចំផែនទីដីចំណីឆ្នេរសមុទ្រ និងបែងចែកប្រភេទឆ្នេរសមុទ្រ នៅខេត្តកោះកុង និងខេត្តព្រះសីហនុ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់ផែនទីបណ្តាញផ្លូវថ្នល់ឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ និងបណ្តាញប្រភពទឹកនៅកោះរុង<br>▪ កំពុងរៀបចំផែនទីដីចំណីឆ្នេរសមុទ្រ ផែនការមេគ្រប់គ្រងការអភិវឌ្ឍ និងអភិរក្សកោះនៃតំបន់ឆ្នេរសមុទ្រកម្ពុជា<br>▪ បាននិងកំពុងរៀបចំផែនទីមគ្គុទ្ទេសក៍សម្រាប់ទេសចរណ៍ខេត្តកែប<br>▪ បានចុះពិនិត្យ និងតាមដានការសាងសង់ខ្លោងច្រកចូលឆ្នេរ និងការអនុវត្តផែនការកែលម្អតូបកម្សាន្តនៅឆ្នេរឯករាជ្យ ឆ្នេរអូរឈើទាល និងឆ្នេរអូរត្រេះ<br>▪ បាននិងកំពុងរៀបចំផែនការប្រើប្រាស់ដីតំបន់បឹងព្រែកទប់<br>▪ បាននិងកំពុងរៀបចំប្លង់គោលប្រើប្រាស់ដីកោះពស់ កោះឬស្សី និងកោះក្របី នៅខេត្តព្រះសីហនុ កោះសេះ និងកោះតី នៅខេត្តកំពត<br>▪ បានស្រង់ទិន្នន័យទីតាំងកោះទាំង ៧៥ ក្នុងនោះ ៣៤ កោះ ទទួលបានការវិនិយោគ<br>▪ បាន និងកំពុងរៀបចំច្បាប់ និងក្របខណ្ឌគតិយុត្ត ដើម្បីគាំទ្រដល់ការគ្រប់គ្រង ការអភិវឌ្ឍ និងការសាងសង់ ដូចជាច្បាប់សំណង់ ច្បាប់រៀបចំដែនដីនិងនគរូបនីយកម្ម ច្បាប់គ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា និងបទដ្ឋានគតិយុត្តមួយចំនួនទៀត ដើម្បីគាំទ្រដល់ការអនុវត្ត IDP<br>▪ បានចេញបណ្ណកម្មសិទ្ធិដីក្នុងការចុះបញ្ជីដំបូងសរុបចំនួន ២៣៧.១៤៣បណ្ណ និងចុះបញ្ជីបន្តសរុបចំនួន ៥០.០៨៨បណ្ណ<br>▪ បានដោះស្រាយវិវាទដីធ្លី ២០៨ ករណី | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានពិនិត្យ និងផ្តល់លិខិតអនុញ្ញាតសាងសង់ជូនប្រជាពលរដ្ឋចំនួន ៣.០៥២គម្រោង។<br>ក្នុងឆ្នាំ២០១៨÷<br>▪ បានរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តចំនួន០២គឺ÷ ខេត្តព្រះសីហនុ និងខេត្តបាត់ដំបង ព្រមទាំងប្លង់គោលប្រើប្រាស់ដីក្រុង និងទីប្រជុំជនចំនួន ០៨ គឺ÷ ក្រុងបាត់ដំបង ក្រុងសៀមរាប ក្រុងតាខ្មៅ ក្រុងកំពត ក្រុងកែប ទីប្រជុំជនទីរួមខេត្តត្បូងឃ្មុំ ទីប្រជុំជនស្វាយអន្ទរ និងទីប្រជុំជនជ្រៃធំ។ ទន្ទឹមនេះក៏បានរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ ចំនួន ០២ ផងដែរគឺ÷ ឃុំរាម និងឃុំអូរឧកញ៉ាហេង ខេត្តព្រះសីហនុ<br>▪ បានរៀបចំ និងកំពុងស្នើសុំការអនុម័តផែនការរៀបចំដែនដីតំបន់ឆ្នេរ និងផែនការប្រើប្រាស់ដីនៅក្នុងឃុំចំនួន០២គឺ÷ ឃុំរកាត និងឃុំស្នាមព្រះ ខេត្តពោធិសាត់<br>▪ បាននិងកំពុងរៀបចំផែនការរៀបចំដែនដីខេត្តចំនួន០៣គឺ÷ ខេត្តសៀមរាប ខេត្តតាកែវ និងខេត្តប៉ៃលិន ព្រមទាំងប្លង់គោលប្រើប្រាស់ដីក្រុងចំនួន១១ ស្រុកចំនួន១០ និងទីប្រជុំជនចំនួន០៣ គឺ÷ ក្រុងព្រះសីហនុ ក្រុងប៉ោយប៉ែត ក្រុងខេមរភូមិន្ទ ក្រុងស្ទឹងត្រែង ក្រុងច្បារមន ក្រុងក្រចេះ ក្រុងកំពង់ចាម ក្រុងសួង ក្រុងកំពង់ឆ្នាំង ក្រុងបាវិត ក្រុងព្រៃវែង ស្រុកស្ទឹងហាវ ស្រុករលាប្អៀរ ស្រុកបរវេល ស្រុកស្អាង ស្រុកលំផាត់ ស្រុករវៀនសែ ស្រុកថាឡាបរិវ៉ាត់ ស្រុកក្ងនមុំ ស្រុកសៀមប៉ាង ស្រុកសៀមបូក | |

| វិធានការគោលនយោបាយ/ផែនការ សកម្មភាព | រយៈពេល/ ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ទីប្រជុំជនអន្លង់វែង ទីប្រជុំជនអ្នកលឿង និងទីប្រជុំជនទីរួមស្រុកចិត្របុរី។ ទន្ទឹមនេះក៏បាននិងកំពុងរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ចំនួន ៩៦ គឺ÷ ឃុំចំនួន០៥ក្នុងខេត្តត្បូងឃ្មុំ, សង្កាត់ចំនួន០១ក្នុងខេត្តកំពត, ឃុំចំនួន៣០ក្នុងខេត្តព្រៃវែង, សង្កាត់ចំនួន០២ និងឃុំចំនួន២៨ ក្នុងខេត្តកំពង់ធំ និងឃុំចំនួន៣០ក្នុងខេត្តបាត់ដំបងផងដែរ។<br>▪ បានចេញបណ្ណកម្មសិទ្ធិដីសរុបចំនួន ១៧៨.៨១២ បណ្ណ<br>▪ បានចុះបញ្ជីជួលរយៈពេលវែងសរុបចំនួន ១១បណ្ណ ចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ចសរុបចំនួន ៧៤បណ្ណ ចុះបញ្ជីពីការផ្ទេរសិទ្ធិសរុបចំនួន ៣៥.០០១បណ្ណ និងចុះបញ្ជីសិទ្ធិប្រាតិភោគសរុបចំនួន ២១.២១៨បណ្ណ<br>▪ បានដោះស្រាយវិវាទដីធ្លី ៣៦៤ករណី<br>▪ បានពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់ជូនប្រជាពលរដ្ឋចំនួន២.៨៦៧គម្រោង។<br>- រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ | |
| - លើកកម្ពស់ការប្រកួតប្រជែងរវាងតំបន់សេដ្ឋកិច្ចពិសេសនានា ដោយសិក្សាបង្កើតសូចនាករសួល សម្រាប់វាស់ស្ទង់សមិទ្ធកម្មនៃកិច្ចដំណើរការរបស់តំបន់សេដ្ឋកិច្ចទាំងនោះ សម្រាប់ជាលក្ខខណ្ឌវិនិច្ឆ័យក្នុងការ ផ្តល់ការលើកទឹកចិត្ត និងជំរុញឧត្តមានុវត្តន៍ | ២០១៥ មធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ បានចូលរួមសិក្សាអំពីយន្តការក្នុងការវាយតម្លៃប្រសិទ្ធភាពនៃកិច្ចដំណើរការតំបន់សេដ្ឋកិច្ចពិសេសនៅទីក្រុងសៀងហៃ។<br>- រដ្ឋបាលខេត្តព្រះសីហនុ បានធ្វើការទំនាក់ទំនងជាមួយប្រទេសថៃ ចំនួន៤លើក និងប្រទេសវៀតណាម ចំនួន ២លើក ដើម្បីកៀរគរអ្នកវិនិយោគចូលមក។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| - រៀបចំផែនការអភិវឌ្ឍទីប្រជុំជន/ទីក្រុងឱ្យក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្ម ផ្ដោតលើខេត្តព្រះសីហនុ ខេត្តកោះកុង ក្រុងបាវិត និងក្រុងប៉ោយប៉ែត តាមរយៈការបង្កើតយន្តការស្ថាប័នសម្របសម្រួលមួយ ដើម្បីជំរុញការអភិវឌ្ឍមជ្ឈមណ្ឌលឧស្សាហកម្មគ្រប់ជ្រុងជ្រោយ រួម-មាន ការកំណត់តំបន់ដីធ្លីផ្អែកលើផែនការប្រើ-ប្រាស់ដីធ្លីច្បាស់លាស់ ការគ្រប់គ្រងបរិស្ថានដែលជានាទីរភាពនៃប្រព័ន្ធអេកូឡូស៊ី ការអភិ-វឌ្ឍលំនៅឋាន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលរួមមាន អគ្គិសនី ផ្លូវថ្នល់ កំពង់ផែ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធការពារទឹកជំនន់ ប្រព័ន្ធបញ្ចេញចោលកាកសំណល់ និងទឹកសម្អុយ ព្រមទាំងសេវាសង្គម រួមទាំងសេវាសុខាភិបាល អប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដោយផ្អែកលើផែនការអភិវឌ្ឍរយៈពេលវែង | មធ្យម ទៅ វែង | - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ បានរៀបចំ និងកំពុងស្នើសុំការអនុម័តលើផែនការរៀបចំដែនដីខេត្តព្រះសីហនុ និងផែនការប្រើប្រាស់ដីនៅក្នុងឃុំចំនួន០២គឺ ឃុំរាម និងឃុំអូរឧកញ៉ាហេង ខេត្តព្រះសីហនុ<br>▪ បាននិងកំពុងរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុងចំនួន០៤ គឺ ក្រុងព្រះសីហនុ ក្រុងខេមរភូមិន្ទ ក្រុងបាវិត និងក្រុងប៉ោយប៉ែត ថ្នាក់ស្រុកចំនួន០១គឺស្រុកស្ទឹងហាវ<br>▪ បានរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងឃុំចំនួន២គឺ ឃុំទួលគគីរ និងឃុំតាតៃក្រោម ខេត្តកោះកុង<br>▪ បន្តការរៀបចំច្បាប់ និងក្របខណ្ឌគតិយុត្ត ដើម្បីគាំទ្រដល់ការគ្រប់គ្រង ការអភិវឌ្ឍ និងការសាងសង់ ដូចជាច្បាប់សំណង់ ច្បាប់រៀបចំដែនដីនិងនគរូបនីយកម្ម ច្បាប់គ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា និងបទដ្ឋានគតិយុត្តមួយចំនួនទៀត ដើម្បីគាំទ្រដល់ការអនុវត្ត IDP<br>▪ បានចែកបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋក្នុងខេត្តព្រះសីហនុសរុបចំនួន ១.២៩៩ បណ្ណ ក្នុងខេត្តកោះកុងសរុបចំនួន ៧៥៩ បណ្ណ ក្នុងក្រុងបាវិតសរុបចំនួន ២៨ បណ្ណ និងក្នុងក្រុងប៉ោយប៉ែតសរុបចំនួន ២២៥បណ្ណ<br>▪ បានដោះស្រាយវិវាទដីធ្លីក្នុងខេត្តព្រះសីហនុសរុបចំនួន ១៣ ករណី ក្នុងខេត្តកោះកុងសរុបចំនួន ០៩ករណី និងក្នុងក្រុងប៉ោយប៉ែតសរុបចំនួន ០១ករណី | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានផលិតអ័រតូហ្វូតូរូបថតពីលើអាកាសមាត្រដ្ឋាន ១:៤000 នៅខេត្តព្រះសីហនុ និងបានបោះពុម្ពប្លង់សុរិយោដី អ័រតូហ្វូតូ និងបញ្ជីឈ្មោះម្ចាស់ដីមាត្រដ្ឋាន ១:១000 ខ្នាត A0 គាំទ្រការងារចុះបញ្ជីដីធ្លី នៅខេត្តកោះកុង<br>▪ បានពិនិត្យ និងផ្តល់លិខិតអនុញ្ញាតសាងសង់ជូនប្រជាពលរដ្ឋក្នុងខេត្តព្រះសីហនុចំនួន ៦៩គម្រោង ក្នុងខេត្តកោះកុងចំនួន ៩២គម្រោងក្នុងក្រុងបាវិតចំនួន ៨២គម្រោង និងក្នុងក្រុងប៉ោយប៉ែតចំនួន ៤១គម្រោង<br>▪ បានសហការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រៀបចំនិងទទួលបានការអនុម័តពីរាជរដ្ឋាភិបាល លើគោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ<br>▪ បានសហការជាមួយអាជ្ញាធរខេត្តព្រះសីហនុ ក្នុងការចុះសិក្សាតំបន់ដែលរងគ្រោះដោយទឹកជំនន់និងខ្យល់កន្ត្រាក់នៅស្រុកស្ទឹងហាវ ស្រុកកំពង់សិលា និងស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជ្រើសរើសទីតាំងសមស្រប ដើម្បីសាងសង់លំនៅឋានដែលធន់នឹងគ្រោះទឹកជំនន់ និងខ្យល់កន្ត្រាក់។<br>ក្នុងឆ្នាំ២០១៨÷<br>▪ បានរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តព្រះសីហនុ និង ផែនការប្រើប្រាស់ដីនៅក្នុងឃុំចំនួន២គឺ ឃុំរាម និងឃុំអូរឧកញ៉ាហេង ក្នុងខេត្តព្រះសីហនុ។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ▪ បាននិងកំពុងរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុងចំនួន០៤ គឺ ក្រុងព្រះសីហនុ ក្រុងខេមរភូមិន្ទ ក្រុងបាវិត និងក្រុងប៉ោយប៉ែត ថ្នាក់ស្រុកចំនួន០១គឺ ស្រុកស្ទឹងហាវ<br>▪ បានចែកបណ្ណកម្មសិទ្ធិដីជូនប្រជាពលរដ្ឋក្នុងខេត្តព្រះសីហនុ សរុបចំនួន ១.០០១បណ្ណ ក្នុងខេត្តកោះកុងសរុបចំនួន ៧៥៩បណ្ណ ក្នុងក្រុងបាវិតសរុបចំនួន ៣២បណ្ណ និងក្នុងក្រុងប៉ោយប៉ែតសរុបចំនួន ២៥៩៩បណ្ណ<br>▪ កំពុងដោះស្រាយវិវាទដីធ្លីក្នុងខេត្តព្រះសីហនុសរុបចំនួន ១២៧ករណី ក្នុងខេត្តកោះកុងសរុបចំនួន ០៩ករណី និងក្នុងក្រុងប៉ោយប៉ែតសរុបចំនួន ០១ករណី<br>▪ បានបន្តផលិតអ័រតូហ្វូតូរូបថតពីលើអាកាសមាត្រដ្ឋាន ១:៤០០០ នៅខេត្តព្រះសីហនុ និងបានបន្តបោះពុម្ពប្លង់សុរិយោដី អ័រតូហ្វូតូ និងបញ្ជីឈ្មោះម្ចាស់ដីមាត្រដ្ឋាន ១:១០០០ ខ្នាតA0 គាំទ្រការងារចុះបញ្ជីដីធ្លី នៅខេត្តកោះកុង<br>▪ បានពិនិត្យ និងផ្តល់លិខិតអនុញ្ញាតសាងសង់ជូនប្រជាពលរដ្ឋក្នុងខេត្តព្រះសីហនុចំនួន ៣៦៤គម្រោង ក្នុងខេត្តកោះកុងចំនួន ៨៨គម្រោង ក្នុងក្រុងបាវិតចំនួន ៨០គម្រោង និងក្នុងក្រុងប៉ោយប៉ែតចំនួន ៨២គម្រោង<br>▪ បានសាងសង់លំនៅឋានបន្សាំនឹងការប្រែប្រួលអាកាសធាតុចំនួន ៤ខ្នង សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះដោយការប្រែប្រួលអាកាសធាតុ នៅក្នុងស្រុកព្រៃនប់ និងស្រុកកំពង់សិលា ខេត្តព្រះសីហនុ។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖<br>ការងារឆ្នាំ២០១៧-២០១៨៖<br>▪ បានចូលរួមប្រជុំលើសេចក្ដីព្រាងផែនការប្រើប្រាស់ដីខេត្តព្រះសីហនុ និងខេត្តបាត់ដំបង<br>▪ បានបន្តចូលរួមប្រជុំ និងផ្ដល់ធាតុចូលពាក់ព័ន្ធនឹងការងាររៀបចំផែនការអភិវឌ្ឍទីប្រជុំជន/ទីក្រុងឱ្យក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្ម ដូចជា យុទ្ធសាស្ត្រសមាហរណកម្មតំបន់ឆ្នេរ និងផែនការរៀបចំដែនដីខេត្តព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣០ និងឯកសារក្របខណ្ឌអភិវឌ្ឍតំបន់ទីក្រុងជុំវិញបឹងទន្លេសាប។<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន៖<br>▪ បានបញ្ចប់គម្រោងអភិវឌ្ឍចំណតពហុបំណងកំពង់ផែស្វយ័តក្រុងព្រះសីហនុប្រវែង ៣៣០ម ជម្រៅទឹក ១៣,៥ម និងចំណតមូលដ្ឋានផ្គត់ផ្គង់ភស្តុភារសម្រាប់ការរុករកប្រេង បណ្ដោយប្រវែង ២០០ម. ជម្រៅទឹក ៧,៥ម.<br>▪ គម្រោងសាងសង់ចំណតផែកុងតឺន័រក្រុងព្រះសីហនុ ប្រវែង៣៥០ម ជម្រៅទឹក ១៤,៥ម បានចុះហត្ថលេខាលើពិធីប្តូរសារ និងកិច្ចព្រមព្រៀងប្រាក់កម្ចីលេខ CP-P21 លើចំណាយទឹកប្រាក់ ២០៣លានដុល្លារអាមេរិក កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលជប៉ុន ក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់**សម្ដេចតេជោនាយករដ្ឋមន្ត្រី** នៅប្រទេសជប៉ុន គ្រោងអនុវត្តសាងសង់នៅចុងឆ្នាំ២០១៩ និងបញ្ចប់ក្នុងឆ្នាំ២០២២។ តាមរយៈចំណតផែកុងតឺន័រថ្មីនេះ នឹងអាចឱ្យនាវាដឹកជញ្ជូនកុងតឺន័រធុនធំ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | អន្តរជាតិប្រមាណ ៩៣% ចូលចតនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុបាន ដែលធ្វើឱ្យតម្លៃដឹកជញ្ជូនតាមសមុទ្រ (Ocean Freight Fee) នឹងមានតម្លៃប្រហាក់ប្រហែលជាមួយប្រទេសជិតខាង។<br>▪ សិក្សាគម្រោងអភិវឌ្ឍន៍ទីលានស្តុកទំនិញ និងកុងតឺន័រ (ICD) លើផ្ទៃដីជាង៥៤ហិកតានៅក្រៅបរិវេណកំពង់ផែ<br>▪ សិក្សាបន្ថែមតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ ដោយបង្កើតគម្រោងសាកល្បង " Customs Manufacturing Bonded Warehouse" និង"Free Port" ព្រមទាំងបម្រុងជា Logistic Hub<br>▪ ត្រៀមអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងខាងត្បូង ផ្តោតលើការអភិវឌ្ឍក្រុងចំនួនបួន (កែលម្អហេដ្ឋារចនាសម្ព័ន្ធក្រុង÷ ក្រុងប៉ោយប៉ែត ក្រុងបាត់ដំបង ក្រុងបាវិត និងទីប្រជុំជនអ្នកលឿង) រួមមានការសាងសង់ប្រព័ន្ធលូចម្រោះទឹកសំណល់ និងទីលានកែច្នៃសំរាម សាងសង់ផ្លូវក្រុង ប្រព័ន្ធការពារទឹកជំនន់ និងទប់ច្រាំងបាក់។ ដោយឡែក បានចុះហត្ថលេខាអនុវត្តគម្រោងសាងសង់សម្រាប់អនុគម្រោងក្រុងបាត់ដំបង រួចរាល់។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷<br>▪ បានចូលរួមជាមួយក្រុមបេសកកម្មរបស់ធនាគារពិភពលោក ក្រោមគម្រោងជំនួយបច្ចេកទេសស្តីពី "ការពិនិត្យមើលឡើងវិញអំពីនគរូបនីយកម្មកម្ពុជា" (Cambodia Urbanization Review)<br>▪ បានអនុម័តផែនការដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងអភិវឌ្ឍន៍បណ្តាក្រុងរបៀងទី១ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានបញ្ចប់ការងារដោះស្រាយទីតាំងដីសម្រាប់សាងសង់ស្ថានីយបូមជុំរុញទឹកកខ្វក់និងចម្រោះទឹកកខ្វក់ នៅក្រុងប៉ោយប៉ែត ក្រុងបាត់ដំបង និងក្រុងបាវិត<br>▪ បានពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងអភិវឌ្ឍន៍បណ្តាក្រុងរបៀងទី២ (ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ក្រុងកំពត និងក្រុងព្រះសីហនុដូចជាការរៀបចំបណ្តាញ លូប្រព័ន្ធការពារទឹកជំនន់ ប្រព័ន្ធប្រោះទឹកកខ្វក់ និងទីលានចាក់សំរាម)<br>▪ បញ្ចប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ទីប្រជុំជននៃទីរួមខេត្តត្បូងឃ្មុំដំណាក់ដំបូង<br>▪ បានពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងសមធម៌ និងកែលម្អគុណភាពសេវាសុខាភិបាល<br>▪ បានចូលរួមអនុវត្តគម្រោងកែលម្អគ្រប់គ្រងបរិស្ថានក្រុងជុំវិញបឹងទន្លេសាប ដែលមានភូមិសាស្ត្រក្នុងខេត្តកំពង់ឆ្នាំង, ខេត្តពោធិ៍សាត់, ខេត្តកំពង់ធំ, ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។<br>- ក្រសួងបរិស្ថាន ៖<br>▪ បានកែលម្អការគ្រប់គ្រងសំណល់រឹងទីប្រជុំជនតាមរាជធានី ខេត្ត បន្ទាប់ពីរាជរដ្ឋាភិបាលបានអនុម័តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន<br>▪ បានពង្រឹងការគ្រប់គ្រងគុណភាពបរិស្ថាន តាមរយៈការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន, អនុក្រឹត្យ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអនុក្រឹត្យស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម<br>▪ បានដាក់ចេញនូវ÷(១)អនុក្រឹត្យលេខ ២៣៥ អនក្រ.បក ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ ដែលអាចមានគោលដៅជំរុញឱ្យមានការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទឹកកខ្វក់ និងសំណល់រាវ ដែលនឹងអាចជួយដល់ការគ្រប់គ្រងសំណល់រាវពីតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្ម និង (២)អនុក្រឹត្យលេខ ១៦៨ អនក្រ.បក ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក ដែលមានគោលដៅជំរុញការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក ដែលអាចបង្កហានិភ័យដល់បរិស្ថាន។<br>- ក្រសួងធនធានទឹក និងឧតុនិយម÷<br>▪ បានសាងសង់ច្រាំងទន្លេមេគង្គ នៅក្រុងកំពង់ចាម បានប្រវែង ៧៨ម សម្រាប់ទប់កុំឱ្យបាក់ច្រាំងទន្លេ<br>▪ បានជួសជុល និងសាងសង់នូវទំនប់ការពារទឹកប្រៃជីត្រេះប្រវែង ៤.០០០ម នៅស្រុកបុទុមសាគរ ដើម្បីការពារទប់ស្កាត់ទឹកប្រៃកុំឱ្យហូរចូលលើផ្ទៃដីចំនួន ២៨២ហ.ត ព្រមទាំងបានជួសជុល និងថែទាំនូវទំនប់ការពារទប់ស្កាត់ទឹកប្រៃសរុបចំនួន ៧គម្រោង ដើម្បីរក្សានិរន្តរភាពការពារទឹកប្រៃបានចំនួន ២.២៩៦ហ.ត នៅក្នុងខេត្តកោះកុង<br>▪ បានជួសជុល និងថែទាំជាប្រចាំនូវទំនប់ការពារទប់ស្កាត់ទឹកប្រៃសរុបចំនួន ៦គម្រោង ដើម្បីរក្សានិរន្តរភាពការពារទឹកប្រៃបានចំនួន ៩.៧៧៨ហ.ត នៅក្នុងខេត្តព្រះសីហនុ។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - រដ្ឋបាលខេត្តស្វាយរៀង បានធ្វើបច្ចុប្បន្នភាព និងអនុម័តផែនការសម្រាប់អនុវត្តការកាត់បន្ថយអត្រា និងតម្លាតថ្លៃលក់អគ្គិសនីពីឆ្នាំ២០១៧ ដល់ ២០២០។<br>- រដ្ឋបាលខេត្តព្រះសីហនុ÷<br>▪ បានកំណត់ទីតាំងស្រុកចំនួន ២ សម្រាប់បន្តអភិវឌ្ឍន៍តំបន់ឧស្សាហកម្ម គឺស្រុកស្ទឹងហាវ និងស្រុកកំពង់សីលា ដែលមានកត្តាស្ថានភាពភូមិសាស្ត្រសមស្របនឹងការអភិវឌ្ឍវិស័យឧស្សាហកម្មធុនធ្ងន់ និងស្រាល<br>▪ បានដាក់ស្នើទៅក្រសួងមហាផ្ទៃ ដើម្បីពង្រីកវិសាលភាពក្រុងព្រះសីហនុ ដោយកាត់ឃុំបិតត្រាំង និងមួយផ្នែកនៃឃុំរាម ចូលមកក្រុងព្រះសីហនុ ប៉ុន្តែចំណុចនេះក្រសួងកំពុងពិនិត្យ និងមិនទាន់សម្រេចនៅឡើយ<br>▪ បានកំពុងសិក្សាលើទីប្រជុំជនស្រុកពីរដែលមានសក្តានុពលអាចពង្រីកជាក្រុងបាន គឺស្រុកព្រៃនប់ និងស្រុកស្ទឹងហាវ<br>▪ សម្រាប់ឆ្នាំ២០១៨ បានអភិវឌ្ឍរបៀងឧស្សាហកម្ម ពិសេសផ្តោតទៅលើរបៀងសេដ្ឋកិច្ចតំបន់ឆ្នេរខាងត្បូង យោងតាមផែនការរៀបចំដែនដី ខេត្តព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣០ រដ្ឋបាលខេត្ត បានកំណត់គោលដៅ ស្រុកបីបន្ថែមទៀត គឺស្រុកស្ទឹងហាវ ស្រុកព្រៃនប់ និងស្រុកកំពង់សីលា សម្រាប់ធ្វើការអភិវឌ្ឍតភ្ជាប់ទៅនឹងប៉ូលសេដ្ឋកិច្ចក្នុងស្រុកទៅនឹងប្រទេសជិតខាង ថៃ និងវៀតណាម<br>▪ បានបង្កើនសមត្ថភាពស្ថានីយចម្រោះទឹកកខ្វក់ក្រុងព្រះសីហនុ ពី ៦៥០០ម៣ ដល់ ២០០០០ម៣/១ថ្ងៃ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ គ្រោងផែនការសម្រាប់សាងសង់លូរំដោះ ទឹកភ្លៀង និងលូទឹកកខ្វក់នៅក្នុងទូទាំងក្រុង ព្រមទាំងគ្រោងកែលម្អសមត្ថភាពអាងប្រព្រឹត្តិកម្មរបស់ខេត្តផងដែរ។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍៖<br>▪ បានចូលរួមរៀបចំផែនការអភិវឌ្ឍទីប្រជុំជន/ទីក្រុងឱ្យក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្ម<br>▪ បានចូលរួមសិក្ខាសាលាស្តីពី Smart City នៅក្រៅប្រទេស។ | |
| - អភិវឌ្ឍតំបន់ជុំវិញទីក្រុងភ្នំពេញឱ្យក្លាយជាតំបន់ឧស្សាហកម្មប្រមូលផ្តុំ ដោយមានផែនការប្រើប្រាស់ដីធ្លីច្បាស់លាស់ ដោយបែងចែករវាងតំបន់ឧស្សាហកម្ម និងតំបន់និវេសនដ្ឋាន ឬទីប្រជុំជន រួមទាំងផែនការរយៈពេលវែងសម្រាប់ប្រែក្លាយទីក្រុងភ្នំពេញទៅជាមជ្ឈមណ្ឌលរដ្ឋបាល ឧស្សាហកម្ម វិទ្យាសាស្ត្រ និងនវានុវត្តន៍ | មធ្យម ទៅ វែង | - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់៖<br>ក្នុងឆ្នាំ២០១៧៖<br>▪ បាននិងកំពុងរៀបចំប្លង់បែងចែកតំបន់ប្រើប្រាស់ដី និងសន្ទស្សន៍ប្រើប្រាស់ដីនៅខណ្ឌ ដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក និងខណ្ឌចំការមន រាជធានីភ្នំពេញ<br>▪ បានចែកបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញសរុប ៤.០២៤បណ្ណ<br>▪ បានដោះស្រាយវិវាទដីធ្លី ១៤៤ ករណី ដោយបានដោះស្រាយបញ្ចប់ ០៦ ករណី<br>▪ បានពិនិត្យ និងផ្តល់លិខិតអនុញ្ញាតសាងសង់ជូនប្រជាពលរដ្ឋចំនួន១.១០១គម្រោង<br>▪ បានសហការបង្កើតក្រុមការងាររៀបចំកម្មវិធិអភិវឌ្ឍលំនៅឋានសាធារណៈ តម្លៃទាបជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ<br>▪ បានសហការជាមួយក្រុមហ៊ុន ARAKAWA ដោះស្រាយជូនប្រជាពលរដ្ឋដែលជាម្ចាស់ចំណែកឯកជនចំនួន៤៩២គ្រួសារ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | បញ្ចៀសបាននូវហានិភ័យជាយថាហេតុនៃគ្រោះថ្នាក់ដោយអគារប៊ូឌីញ"ស " ដែលចាស់ទ្រុឌទ្រោម ព្រមទាំងបានសហការសាងសង់លំនៅឋានតម្លៃសមរម្យចំនួន ២.០០០បន្ទប់ នៅខណ្ឌសែនសុខ។<br>ក្នុងឆ្នាំ២០១៨÷<br>▪ បានរៀបចំបញ្ចប់ និងត្រៀមស្នើសុំការអនុម័តសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដីខណ្ឌទាំង១២ នៅក្នុងរាជធានីភ្នំពេញ<br>▪ បានរៀបចំប្លង់ ស្ថាបត្យកម្មចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយាន នៅក្នុងរាជធានីភ្នំពេញ សម្រាប់សាធារណៈ និងជនពិការ<br>▪ បានចែកបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញសរុប ៨.៤១៨ បណ្ណ<br>▪ កំពុងដោះស្រាយវិវាទដីធ្លី ៤១ករណី ដោយបានដោះស្រាយបញ្ចប់ ៤ ករណី<br>▪ បានបោះពុម្ពប្លង់សុរិយោដី អ័រតូហ្វូតូ និងបញ្ជីឈ្មោះម្ចាស់ដី មាត្រដ្ឋាន ១:១០០០ ខ្នាតA0 ដើម្បីគាំទ្រដល់ការងារចុះបញ្ជីដីធ្លីនៅក្នុងរាជធានីភ្នំពេញ<br>▪ បានពិនិត្យ និងផ្តល់លិខិតអនុញ្ញាតសាងសង់ជូនប្រជាពលរដ្ឋចំនួន ១.១០២គម្រោង<br>▪ បានចុះពិនិត្យការដ្ឋានគម្រោងអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ "ប្រ៉ូហ្គ្រេនជាក" មានទីតាំងស្ថិតនៅខណ្ឌពោធិ៍សែនជ័យ និង | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | "លំនៅឋានអារ៉ាខាវ៉ា" មានទីតាំងស្ថិតនៅខណ្ឌសែនសុខ ក្នុងរាជធានីភ្នំពេញ<br>▪ បានពិនិត្យ និងផ្ដល់យោបល់លើសំណើគម្រោងអភិវឌ្ឍលំនៅឋានរបស់ក្រុមហ៊ុន Phnom Penh Special Economic Zone និងក្រុមហ៊ុន Worldbridge Homes Co., Ltd.<br>▪ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងសៀវភៅបទដ្ឋានបច្ចេកទេសលំនៅឋានសម្រាប់គ្រួសារមានប្រាក់ចំណូលមធ្យម និងទាប។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ បានបន្តចូលរួមប្រជុំ និងផ្ដល់ធាតុចូលពាក់ព័ន្ធនឹងអនុក្រឹត្យស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ព្រមទាំងសេចក្ដីសម្រេចស្ដីពីការរៀបចំផែនការរៀបចំដែនដីថ្នាក់ជាតិ និងសេចក្ដីសម្រេចស្ដីពីនីតិវិធីនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី។<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន៖ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ក្រុងតាខ្មៅកំពុងសិក្សាគម្រោងលម្អិត។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖<br>▪ បានបញ្ចប់ការងារដោះស្រាយទីតាំងសម្រាប់សាងសង់សាលាជាតិបណ្ដុះបណ្ដាលវិជ្ជាជីវៈទេសចរណ៍ នៅរាជធានីភ្នំពេញ<br>▪ បញ្ចប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងសាងសង់ផ្លូវក្រវ៉ាត់ក្រុងទី២ បានស្មើរតែទាំងស្រុង | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ▪ បានបញ្ចប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងស្តារឡើងវិញផ្លូវជាតិលេខ ៥១ ពីថ្នល់ទទឹង (ផ្លូវជាតិលេខ ៤) ទៅឧត្តុង (ផ្លូវជាតិលេខ ៥) មានប្រវែង ៣៧.៩៥ គ.ម។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>▪ បាននិងកំពុងសាងសង់មន្ទីរពិសោធន៍ឧស្សាហកម្មថ្មី និងមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវកម្ពស់៧ជាន់ ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ២ ក្នុងសង្កាត់ចាក់អង្រែលើខណ្ឌមានជ័យ<br>▪ បានដាក់ឱ្យដំណើរការប្រព័ន្ធទិន្នន័យស្រាវជ្រាវអេឡិចត្រូនិក (online) លើគំនូរឧស្សាហកម្ម (Industrial Design) និងវិញ្ញាបនបត្រតក្កកម្ម (Patents) នៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម។<br>- ក្រសួងធនធានទឹក និងឧតុនិយមបានជួសជុល និងថែទាំជាប្រចាំនូវទំនប់សណ្តរក្រាំងពង្រ (ទំនប់ ៧មករា) ប្រវែង ៩.៩៤២ម និងសំណង់ទ្វារទឹក ៤កន្លែង ស្ថិតនៅខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីរក្សានិរន្តរភាពការពារទប់ស្កាត់ទឹកជំនន់ស្ទឹងព្រែកត្នោត គឺការពារផ្ទៃដីបានចំនួន ៣.៨០១ហ.ត ក្នុងនោះ ស្រូវវស្សា ១.៤៨១ហ.ត លំនៅឋាន និងរោងចក្រ ២.៣២០ហ.ត។<br>- រដ្ឋបាលរាជធានីភ្នំពេញ÷<br>▪ ដើម្បីអភិវឌ្ឍតំបន់នៅជុំវិញរាជធានីភ្នំពេញ ឱ្យក្លាយទៅជាតំបន់ឧស្សាហកម្មប្រមូលផ្តុំ រដ្ឋបាលរាជធានីភ្នំពេញ មានទិសដៅរៀបចំផែនការប្រើប្រាស់ដីធ្លីសម្រាប់រយៈពេលវែង ដោយរុញសំណង់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | រោងចក្រឧស្សាហកម្មគ្រប់ប្រភេទ ឱ្យទៅនៅជិតតំបន់ផែស្ងួតរ៉ាំសំរោង និងនៅជិតផ្លូវក្រវ៉ាត់ទី៣ ក្នុងគោលដៅដើម្បី÷<br>១. ជួយសម្រួលដល់ការដឹកជញ្ជូនវត្ថុធាតុដើម និងផលិតផលសម្រេចរបស់វិនិយោគិនដែលជាម្ចាស់រោងចក្រឧស្សាហកម្មទាំងអស់ តាមរយៈការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវរថភ្លើង និងតាមផ្លូវក្រវ៉ាត់ក្រុងទី៣ ដែលជាផ្លូវតភ្ជាប់ជាមួយបណ្តាញផ្លូវជាតិនៅជុំវិញទីក្រុង<br>២. កាត់បន្ថយការកកស្ទះចរាចរណ៍ ដោយសារការដឹកជញ្ជូនឆ្លងកាត់ទីក្រុងរបស់រថយន្តដឹកជញ្ជូនធំៗ<br>៣. ជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ចឱ្យទៅដល់តំបន់ជាយក្រុង ក៏ដូចជាផ្តល់ការងារដល់ប្រជាពលរដ្ឋនៅទីនោះ ដើម្បីឱ្យជីវភាពរបស់ពួកគាត់មានភាពប្រសើរឡើង។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍÷<br>▪ បានចូលរួមអភិវឌ្ឍន៍តំបន់ជុំវិញទីក្រុងភ្នំពេញ ឱ្យក្លាយជាតំបន់ឧស្សាហកម្មប្រមូលផ្តុំ<br>▪ កំពុងរៀបចំគម្រោងសាកល្បង Smart Parking សម្រាប់ទីក្រុងភ្នំពេញ។ | |
| - សិក្សារៀបចំស្ទួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូចនិងមធ្យម សំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំបរទេស និងសហគ្រាសក្នុងស្រុកពិសេសការចូលរួមក្នុងខ្សែច្រវាក់តម្លៃ និងខ្សែ | មធ្យម ទៅ វែង | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ការងារឆ្នាំ២០១៧-២០១៨÷<br>▪ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ដោយបានធ្វើការសិក្សា និងបានគិតគូរចំពោះតំបន់ឧស្សាហកម្មទូទៅ | - រដ្ឋបាលខេត្តបន្ទាយមានជ័យ÷<br>បញ្ហាប្រឈម÷<br>▪ កង្វះធនធានមនុស្សនិងមន្ត្រីបច្ចេកទេសក្នុងការបំពេញតួនាទីភារកិច្ចស្នូលរបស់អង្គភាព |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| ច្រវាក់ផលិតកម្មតំបន់ ក្នុងបរិការណ៍នៃសមាហរណកម្មតំបន់ | | សម្រាប់សហគ្រាសធុនតូចនិងមធ្យម និងការតភ្ជាប់ខ្សែច្រវាក់តម្លៃរវាងសហគ្រាសក្នុងស្រុក និងសហគ្រាសធំបរទេស<br>▪ បានចូលរួមសហការ និងផ្ដល់ការសម្របសម្រួលលើការសិក្សាអង្កេតរបស់អង្គការសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ស្ដីពីការតភ្ជាប់រវាងក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស និងសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- រដ្ឋបាលរាជធានីភ្នំពេញ៖ បានប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីឆ្នាំ ២០៣៥ របស់រាជធានីភ្នំពេញ ជាឧបករណ៍គោលក្នុងការតម្រង់ទិស និងគ្រប់គ្រងការអភិវឌ្ឍក្នុងន័យធានាដល់សក្ដានុពលដែលមានស្រាប់របស់ទីក្រុង គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ធានាសន្តិសុខស្បៀងជាពិសេស តម្រង់ទិសនៃការអភិវឌ្ឍប្រកបដោយតុល្យភាព និងភាពស៊ីសង្វាក់គ្នារវាងរាជធានី និងទីក្រុងតូចបន្ទាប់ ខេត្ត និងទីក្រុងរបស់ប្រទេសជាដៃគូកិច្ចសហប្រតិបត្តិការ តាមរយៈការបែងចែកជាតំបន់សំខាន់ៗដូចជា៖ ប៉ូលអភិវឌ្ឍន៍ស្នូល តំបន់ទីក្រុងប្រកបដោយគុណភាពអន្តរជាតិ តំបន់បម្រុងទុកនូវហេដ្ឋារចនាសម្ព័ន្ធបរិវត្តមេចាំបាច់ តំបន់អភិវឌ្ឍនគរូបនីយកម្មក្នុងកម្រិតទីក្រុងធំ និងតំបន់ពិសេសៗ ដែលមានបេតិកភណ្ឌ និងផ្ដល់សោភណភាពទីក្រុង។ បច្ចុប្បន្ននេះ នៅរាជធានីភ្នំពេញមានតំបន់ឧស្សាហកម្មសំខាន់ៗដូចជា៖ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ សួនឧស្សាហកម្មកាណាឌីយ៉ា សួនឧស្សាហកម្មវឌ្ឍនៈI និងសួនឧស្សាហកម្មវឌ្ឍនៈII។ល។<br>- រដ្ឋបាលខេត្តស្វាយរៀង | ▪ ឧបករណ៍ស្ដង់ដារមាត្រាសាស្ត្រ<br>▪ គុណភាពផលិតផលទំនិញភាគច្រើននៅពុំទាន់ទទួលបានអាជ្ញាបណ្ណស្ដង់ដារកម្ពុជា<br>▪ ប្រជាពលរដ្ឋក្នុងទីប្រជុំជនថ្មពួក និងបឹងត្រកួន កំពុងតែប្រឈមនឹងបញ្ហាអត់ទឹកស្អាតប្រើប្រាស់មូលហេតុដោយសារក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតភូមិនិមិត្តស្នើសុំបញ្ឈប់ប្រតិបត្តិការផលិត និងផ្គត់ផ្គង់ទឹកស្អាត<br>▪ ការយល់ដឹងរបស់សិប្បករ-អាជីវករពីច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រសិប្បកម្ម និងលិខិតបទដ្ឋានពាក់ព័ន្ធនៅមានកម្រិត។<br>សំណើដំណោះស្រាយ៖<br>▪ ចុះផ្សព្វផ្សាយច្បាប់<br>▪ បន្តផ្សព្វផ្សាយច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រ សិប្បកម្ម។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - រដ្ឋបាលខេត្តបន្ទាយមានជ័យ៖<br>ក្នុងឆ្នាំ២០១៧៖<br>▪ បានចូលរួមប្រជុំពិភាក្សាស្តីពីការជំរុញការលើកកម្ពស់ ការផ្តល់សេវាសាធារណៈវិស័យសហគ្រាសធុនតូចនិងមធ្យម នៅសាលប្រជុំទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧<br>▪ បានចូលរួមប្រជុំនៅមន្ទីរពាណិជ្ជកម្មស្តីពីការពិភាក្សាបញ្ហារាំងស្ទះដល់ខ្សែច្រវាក់ផលិតកម្មក្នុងការធ្វើពាណិជ្ជកម្មឆ្លងដែនតាមច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងនៅប្រទេសកម្ពុជាដែលរៀបចំដោយវិទ្យាស្ថានមេគង្គ មកពីប្រទេសថៃ<br>▪ បានចុះត្រួតពិនិត្យទីតាំងផលិតទឹកពិសារ នីណា របស់លោកស្រីលីម សៀវអ៊ីង ស្ថិតក្នុងភូមិពង្រ សង្កាត់កំពង់ស្វាយ ក្រុងសិរី-សោភ័ណ ឱ្យរៀបចំដាក់ផ្លាកឈ្មោះសិប្បកម្មឱ្យបានត្រឹមត្រូវរាល់ការផលិតត្រូវមានអនាម័យល្អ ឱ្យអនុលោមតាមច្បាប់ដែលបានកំណត់និងចុះថែកលិខិតអញ្ជើញសិប្បកម្មថ្មី និងបន្តបានចំនួន១២មូលដ្ឋាន (សិប្បកម្មទ្វារដំបូលបង្អួចដែក ០៤មូលដ្ឋាន ទូកញ្ចក់ ០៤មូលដ្ឋាន និងសិប្បកម្មវាយឡាំង និងទរទឹក ០៤មូលដ្ឋាន)<br>▪ បានចុះត្រួតពិនិត្យរោងចក្រ SCWADO ផលិតគ្រឿងឧបករណ៍អេឡិចត្រូនិក ដែលធ្លាយទុយោហ្គាស ឡចំហាយរំលាយសំណរបង្កឱ្យមានអ្នករបួស និងតាមការពិនិត្យជាក់ស្តែងក្រុមហ៊ុនមិនទាន់មានលិខិតបញ្ជាក់ពីក្រសួងទៅលើលក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្មលើឡចំហាយនៅឡើយ។ ទន្ទឹមនឹងនោះ ក្រុមការងារ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | មន្ទីរបានស្នើឱ្យរោងចក្រត្រូវដាក់ពាក្យស្នើសុំលិខិតបញ្ជាក់ពីក្រសួងឱ្យបានត្រឹមត្រូវមុននិងដំណើរការឡចំហាយ។<br>▪ ការិយាល័យបានចូលរួមប្រជុំវេទិកាសន្ទនា រវាងវិស័យឯកជន និងសាធារណៈសម្រាប់ការលើកកម្ពស់អគ្រាការងារ ដើម្បីទាំងអស់គ្នាក្នុងខេត្តបន្ទាយមានជ័យលើកទី៣ នៅក្រុងប៉ោយប៉ែតនាថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៧<br>▪ ការិយាល័យបានចូលរួមវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានមេគង្គ ប្រទេសថៃ<br>▪ បានចុះចែកវិញ្ញាបនបត្រដល់ម្ចាស់សិប្បកម្ម និងបានដាក់លិខិតអញ្ជើញឱ្យមកដាក់ពាក្យស្នើសុំបន្តនិងស្នើសុំបើកសិប្បកម្មថ្មីក្នុងក្រុងសិរីសោភ័ណបាន ១២មូលដ្ឋាន<br>▪ ការិយាល័យបានរៀបចំផែនការចុះជំរុញសិប្បករ អាជីវករឱ្យមកចុះបញ្ជីជាបន្តបន្ទាប់ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម<br>▪ បានចុះចែកវិញ្ញាបនបត្រដល់ម្ចាស់សិប្បកម្ម និងបានដាក់លិខិតអញ្ជើញឱ្យមកដាក់ពាក្យស្នើសុំបន្ត និងស្នើសុំបើកសិប្បកម្មថ្មី<br>▪ ចុះត្រួតពិនិត្យសិប្បកម្មទឹកត្រី ទឹកស៊ីអ៊ីវ ទឹកម្ទេស របស់ លោក សុខ លាង ដើម្បីយកសំណាកទៅពិសោធន៍នៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា<br>▪ បានចុះផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម<br>▪ បានបន្តជំរុញការចុះបញ្ជីស្ថិតិឧស្សាហកម្មសិប្បកម្មឱ្យបានល្អប្រសើរជាបន្តបន្ទាប់ | |

| ទិដ្ឋានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានខិតខំប្រមូលចំណូលពីកម្រៃសេវាប្បញ្ញត្តិ ឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល<br>▪ បានយកចិត្តទុកដាក់បំពាក់បំប៉នដល់សិប្បកម្មផលិតចំណីអាហារ ឱ្យមានអនាម័យ។<br>ក្នុងឆ្នាំ២០១៨÷<br>▪ សហគ្រាសធុនតូច មធ្យម និងសិប្បកម្មមូលដ្ឋានសរុបចំនួន ១.០៣៥មូលដ្ឋាន ទុនសរុប១០៣.៨១៥.៥០១ដុល្លារទុនអចល័តចំនួន៧៩.៥៨៣.៩០២ដុល្លារ និងមានពលករសរុបចំនួន១៤.៧៦៥នាក់ ស្រី៧.៨៤៦នាក់<br>▪ ឧស្សាហកម្ម សរុបចំនួន ២០រោងចក្រ ទុន៧៧.៤៨១.០៩៩ដុល្លារ ទុនអចល័ត ៥៨.១៦៨.៦៨៧ដុល្លារ ពលករសរុប÷១០.៣៣៩នាក់ ស្រី៦.៥៦២នាក់ ក្នុងនោះ តំបន់សេដ្ឋកិច្ចពិសេសអូរនាងមាន រោងចក្រចំនួន០៣ គឺរោងចក្រកាត់ដេរសម្លៀកបំពាក់ និងរោងចក្រផលិត ប្រអប់គ្រឿងអលង្ការ និងរោងចក្រ ML.Intimate កាត់ដេរសម្លៀកបំពាក់<br>▪ តំបន់សេដ្ឋកិច្ចពិសេសសាន់កូ មានរោងចក្រ០៨ គឺរោងចក្រ SC WADO ផលិតគ្រឿងឧបករណ៍អេឡិចត្រូនិច រោងចក្រ TECHNO PARK ផលិតគ្រឿងបន្លាស់រថយន្ត រោងចក្រ KOIWABOUN ផលិតគ្រឿងបង្គុំកៅអីរថយន្ត រោងចក្រ NHK SPRING ផលិតស្រោមពូករថយន្ត និងរោងចក្រ SUMITRONIC ផលិតគ្រឿងបង្គុំអគ្គិសនី រោងចក្រ EXEDY POI PET ផលិតគ្រឿងបន្លាស់រថយន្ត និងទោចក្រយានយន្ត រោងចក្រ Mabuchi (Cambodia) Co.,Ltd | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ផលិតគ្រឿងគ្រោងពីដែកនិងទូដែក រោងចក្រ Sanko Electronics (Cambodia) Co.,Ltd. គ្រឿងបន្លាស់អគ្គិសនី រោងចក្រ CS.Industry ផលិតគ្រឿងបង្កិវថយន្តផលិតពីផ្លាស្ទិក<br>▪ សួនឧស្សាហកម្មក្រុងសិរីសោភ័ណ មានរោងចក្រកាត់ដេរសម្លៀកបំពាក់ចំនួន០៣មូលដ្ឋានមានដូចជា÷រោងចក្រ SP BROTHER កាត់ដេរសម្លៀកបំពាក់ រោងចក្រ TKGARMENT កាត់ដេរសម្លៀកបំពាក់រោងចក្រ SUVIT KONGPIYACHARN កាត់សម្លៀកបំពាក់<br>▪ រោងចក្រ ធីបក្ខ អេសហ្វល កែច្នៃកៅស៊ូឆ្អិន ស្ថិតនៅភូមិគីឡូម៉ែត្រលេខ៤ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត<br>▪ រោងចក្រ ORIENT & EIGHT HAPPINESS ផលិតបារី ស្ថិតនៅភូមិអណ្ដូងថ្មមាស សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត<br>▪ រោងចក្រ BAKAVA កិនស្រូវ ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ<br>▪ រោងចក្រ KOREA កិនស្រូវ ស្ថិតនៅភូមិរហាល ឃុំរហាល ស្រុកព្រះនេត្រព្រះ<br>▪ រោងចក្រ ហ្វូសហ្វេត & ខេមីខល ផលិតជីហ្វូសស្វាត ស្ថិតនៅភូមិភ្នំធំត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី<br>▪ សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម÷ មានមូលដ្ឋានសរុប ១.០១៥មូលដ្ឋាន មានទុនសរុបចំនួន ២៦.៣៣៤.៤០២ដុល្លារ មានទុនអចល័តចំនួន ២១.៤១៥.២១៥ដុល្លារ មានពលកម្មសរុប ៤.៤២៦នាក់ ស្រីមានចំនួន ៤.៤២៦នាក់ | |

| ទិសដៅការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័នដឹកនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ▪ បើកមូលដ្ឋានសិប្បកម្មថ្មី ចំនួន ៣០មូលដ្ឋាន ÷ ក្រុងប៉ោយប៉ែត ០៩មូលដ្ឋាន ក្រុងសិរីសោភ័ណ០៦មូលដ្ឋាន ស្រុកព្រះនេត្រព្រះ ០៨មូលដ្ឋាន ស្រុកម៉ាឡៃ ០១មូលដ្ឋាន ស្រុកមង្គលបូរី ០២មូលដ្ឋាន ស្វាយចេក០២មូលដ្ឋាន ស្រុកថ្មពួក០២មូលដ្ឋាន<br>▪ ចេញនូវវិញ្ញាបនបត្រថ្មី និងបន្តមានចំនួន ៩០មូលដ្ឋាន នៅស្រុកមង្គលបូរី ៣០មូលដ្ឋាន ក្រុងសិរីសោភ័ណ ៣៣មូលដ្ឋាន ស្រុកអូរជ្រៅ ០៩មូលដ្ឋាន ស្រុកស្វាយចេក ០១មូលដ្ឋាន ក្រុងប៉ោយប៉ែត ១៣មូលដ្ឋាន ស្រុក ព្រះនេត្រព្រះ ០៤មូលដ្ឋាន<br>▪ ចុះចែកវិញ្ញាបនបត្រដល់ម្ចាស់សិប្បកម្ម និងបានដាក់លិខិតអញ្ជើញអោយមកដាក់ពាក្យស្នើសុំបន្ត និង ស្នើសុំបើកសិប្បកម្មថ្មី -ចុះត្រួតពិនិត្យរោងចក្រទឹកស្អាត និងសិប្បកម្មទឹកកកដើម (សេះហោះមានជ័យ) ក្នុងក្រុងសិរីសោភ័ណ ដែល ដឹកនាំដោយលោកប្រធានមន្ទីរផ្ទាល់<br>▪ ចូលរួមសហការជាមួយ ការិយាល័យស្តង់ដារ និងមាត្រាសាស្ត្រចុះធ្វើអធិការកិច្ចសិប្បកម្មផលិតផលទឹកត្រី-ទឹកស៊ីអ៊ីវ ទឹកម្ទេសរបស់លោក សុខ លាង<br>▪ ចុះជំរុញសិប្បករក្នុងស្រុកអូរជ្រៅបាន០៨មូលដ្ឋាន ឱ្យមកដាក់ពាក្យស្នើសុំពន្យារបន្តនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត<br>▪ ចូលរួមសិក្ខាសាលាស្តីពីការផលិត និងការត្រួតពិនិត្យគុណភាពទឹកពិសាដបនៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ<br>▪ ចូលរួមប្រជុំស្តីពីការងារប្រតិភូកម្មដល់ថ្នាក់ក្រោមជាតិ នៅទីស្តីការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ចុះយកសំណាកទឹកពិសាដបចំនួន ០៣មូលដ្ឋានទៅវិភាគនៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា<br>▪ ចុះដាក់លិខិតអញ្ជើញឱ្យមកដាក់ពាក្យស្នើសុំ និងបន្តវិញ្ញាបនបត្រដល់សិប្បកម្មចំនួន ០៥ សិប្បកម្ម ទឹកកក អនាម័យ ០២មូលដ្ឋាន និងសិប្បកម្មបេតុងលាយស្រេច ០៣មូលដ្ឋាន នៅក្រុងប៉ោយប៉ែត<br>▪ ចុះដាក់លិខិតអញ្ជើញអោយមកដាក់ពាក្យស្នើសុំបន្តវិញ្ញាបនបត្រដល់សិប្បកម្មនៅក្នុងក្រុងសិរីសោភ័ណ<br>▪ ផ្សព្វផ្សាយស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការធ្វើប្រតិភូកម្មអំណាចនៃការចុះបញ្ជីសិប្បកម្ម ដែលមានដើមទុនក្រោម ៥០.០០០$ (ហាសិបពាន់ ដុល្លារអាមេរិក) និងគ្មានហានិភ័យ<br>▪ ចុះត្រួតពិនិត្យរោងចក្រនៅតំបន់សេដ្ឋកិច្ចពិសេសសានកូ រោងចក្រ CS Industry និងរោងចក្រ Sanco Electronic ដែលស្ថិតនៅភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត<br>▪ សហការជាមួយការិយាល័យស្តង់ដារ និងមាត្រាសាស្ត្រ និងមន្ត្រីវិទ្យាស្ថានស្តង់ដារបានចុះពិនិត្យក្រុមហ៊ុន KHEMVALE LO HD របស់លោក សុខ ម៉េងហុង ដែលនាំចូលសារធាតុគីមី<br>▪ ចុះណែនាំសិប្បកម្មផលិតទឹកពិសារបស់លោក សេង សុវណ្ណារ័ត្ន មានទីតាំងនៅភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ចុះណែនាំសិប្បកម្មផលិតទឹកពិសាជប ដែលគ្មានច្បាប់អនុញ្ញាត មានទីតាំងនៅភូមិភ្នំជញ្ជាំង ឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ<br>▪ យកសំណាកគំរូចំណីអាហារទូទាំងខេត្តបាន៣០មូលដ្ឋាន យកទៅពិសោធន៍នៅមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា<br>▪ ចូលរួមសិក្ខាសាលាស្តីពី ទស្សនៈវិស័យនៃការអភិវឌ្ឍសហគ្រាសមីក្រូតូច និងមធ្យម នៅសាលប្រជុំសាកលវិទ្យាល័យមានជ័យ។ | |
| - បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមាន ទឹកស្អាត អគ្គិសនី គមនាគមន៍ និងទូរគមនាគមន៍ជាដើម សំដៅបម្រើឱ្យគោលដៅឧស្សាហកម្ម ពិសេសការបោះទីតាំងតំបន់សេដ្ឋកិច្ចពិសេស ការអភិវឌ្ឍប៉ូលឧស្សាហកម្ម និងការប្រែក្លាយតំបន់ទីប្រជុំជន/ទីក្រុងជាមជ្ឈមណ្ឌលឧស្សាហកម្មជាតិ ស្របតាម ផែនការរៀបចំដែនដី នគរូបនីយកម្ម និងផែនការប្រើប្រាស់ដី | មធ្យម ទៅ វែង | - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ បាននិងកំពុងកែសម្រួល ដើម្បីស្នើសុំការអនុម័តផែនការរៀបចំដែនដីខេត្តចំនួន០២គឺ÷ ខេត្តបាត់ដំបង និងខេត្តព្រះសីហនុ<br>▪ បាននិងកំពុងរៀបចំផែនការរៀបចំដែនដីខេត្តចំនួន០៣គឺ÷ ខេត្តសៀមរាប ខេត្តតាកែវ និងខេត្តប៉ៃលិន ព្រមទាំងប្លង់គោលប្រើប្រាស់ដី ក្រុងចំនួន១៤ ស្រុកចំនួន០៧ និងទីប្រជុំជនចំនួន០៥ គឺ៖ ក្រុងព្រះសីហនុ ក្រុងបាត់ដំបង ក្រុងកែប ក្រុងសៀមរាប ក្រុងប៉ោយប៉ែត ក្រុងខេមរភូមិន្ទ ក្រុងបាវិត ក្រុងកំពង់ចាម ក្រុងសួង ក្រុងច្បារមន ក្រុងកំពត ក្រុងព្រៃវែង ក្រុងកំពង់ឆ្នាំង ក្រុងតាខ្មៅ ស្រុកស្ទឹងហាវ ស្រុករលាប្អៀរ ស្រុកលំផាត់ ស្រុករ៉ូវៀងសៃ ស្រុកថាឡាបរិវ៉ាត់ ស្រុកបរវេល និងស្រុកស្អាង ព្រមទាំងទីប្រជុំជនស្វាយអន្ទរ ទីប្រជុំជនអ្នកលឿង និងទីប្រជុំជនជ្រៃធំ និងទីប្រជុំជនទីរួមខេត្តត្បូងឃ្មុំ ទីប្រជុំជនទីរួម | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ស្រុកចិត្របុរី។ ទន្ទឹមនេះក៏បាន និងកំពុងរៀបចំផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ក្រាំងអំពិល ក្រុងកំពតផងដែរ។<br>▪ បានចេញបណ្ណកម្មសិទ្ធិដីសរុបចំនួន ២៣៧ ១៤៣ បណ្ណ<br>▪ បានចុះបញ្ជីជួលរយៈពេលវែងសរុបចំនួន ៤៣បណ្ណ ចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ចសរុបចំនួន ២៤បណ្ណ ចុះបញ្ជីពីការផ្ទេរសិទ្ធិសរុបចំនួន ២៨ ៨៩៤បណ្ណ និងចុះបញ្ជីសិទ្ធិប្រាតិភោគសរុបចំនួន២១ ៤២៧បណ្ណ<br>▪ បានដោះស្រាយវិវាទដីធ្លី ២០៨ ករណី<br>▪ បានពិនិត្យ និងផ្តល់លិខិតអនុញ្ញាតសាងសង់ជូនប្រជាពលរដ្ឋចំនួន ៣ ០៩២គម្រោង។<br>ក្នុងឆ្នាំ២០១៨÷<br>▪ បានរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តចំនួន០២គឺ÷ ខេត្ត ព្រះសីហនុ និងខេត្តបាត់ដំបង ព្រមទាំងប្លង់គោលប្រើប្រាស់ដីក្រុង និងទីប្រជុំជន ចំនួន ០៨ គឺ÷ ក្រុងបាត់ដំបង ក្រុងសៀមរាប ក្រុងតាខ្មៅ ក្រុងកំពត ក្រុងកែប ទីប្រជុំជនទីរួមខេត្តត្បូងឃ្មុំ ទីប្រជុំជនស្វាយអន្ទរ និងទីប្រជុំជនជ្រៃធំ។ ទន្ទឹមនេះក៏បានរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងឃុំចំនួន ០២ ផងដែរគឺ÷ ឃុំរាម និងឃុំអូរឧកញ៉ាហេង ខេត្តព្រះសីហនុ។<br>▪ បាននិងកំពុងរៀបចំផែនការរៀបចំដែនដីខេត្តចំនួន០៣គឺ÷ ខេត្តសៀមរាប ខេត្តតាកែវ និងខេត្តប៉ៃលិន ព្រមទាំងប្លង់គោលប្រើប្រាស់ដីក្រុងចំនួន ១១ ស្រុកចំនួន ១០ និងទីប្រជុំជនចំនួន | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ០៣ គឺ÷ ក្រុងព្រះសីហនុ ក្រុងប៉ោយប៉ែត ក្រុងខេមរភូមិន្ទ ក្រុងស្ទឹងត្រែង ក្រុងច្បារមន ក្រុងក្រចេះ ក្រុងកំពង់ចាម ក្រុងសួង ក្រុងកំពង់ឆ្នាំង ក្រុងបាវិត ក្រុងព្រៃវែង ស្រុកស្ទឹងហាវ ស្រុករលាប្អៀរ ស្រុកបវេល ស្រុកស្អាង ស្រុកលំផាត់ ស្រុករ៉ើនសៃ ស្រុកថាឡាបរិវ៉ាត់ ស្រុកកូនមុំ ស្រុកសៀមប៉ាង ស្រុកសៀមបូក ទីប្រជុំជនអន្លង់វែង ទីប្រជុំជនអ្នកលឿង និងទីប្រជុំជន ទីរួម ស្រុកចិត្របុរី។ ទន្ទឹមនេះក៏បាន និងកំពុងរៀបចំបញ្ចប់សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ក្រាំងអំពិល ក្រុងកំពត ផងដែរ។<br>▪ បានចេញបណ្ណកម្មសិទ្ធិដីសរុបចំនួន ១៧៨.៨១២ បណ្ណ<br>▪ បានចុះបញ្ជីជួលរយៈពេលវែងសរុបចំនួន ១១បណ្ណ ចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ចសរុបចំនួន ៧៤បណ្ណ ចុះបញ្ជីពីការផ្ទេរសិទ្ធិសរុបចំនួន ៣៥.០០១បណ្ណ និងចុះបញ្ជីសិទ្ធិប្រាតិភោគសរុបចំនួន ២១.២១៨បណ្ណ<br>▪ បានដោះស្រាយវិវាទដីធ្លី ៣៦៤ករណី<br>▪ បានពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់ជូនប្រជាពលរដ្ឋចំនួន២.៨៦៧គម្រោង។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ការងារក្នុងឆ្នាំ២០១៧-២០១៨÷<br>▪ បានចូលរួម និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរួបវន្ត ជាពិសេសនៅជុំវិញតំបន់សេដ្ឋកិច្ច | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ពិសេស ដែលរួមមានដូចជាផ្លូវថ្នល់ លូទឹក សួនច្បារ បណ្តាញទឹក-ភ្លើង ការឈូសឆាយដី ការដាំដើមឈើ ជាដើម<br>▪ បានសម្របសម្រួល និងលើកទឹកចិត្តដល់ការអភិវឌ្ឍតំបន់ប្រកបដោយភាតរភាពបរិស្ថាន។ ជាក់ស្តែង ប្រព័ន្ធប្រើប្រាស់ថាមពលដើរដោយពន្លឺព្រះអាទិត្យត្រូវបានបំពាក់ ក្នុងគោលបំណងសន្សំសំចៃថាមពល និងផ្គត់ផ្គង់ការប្រើប្រាស់ក្នុងតំបន់ នៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងមានការរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមួយចំនួនទៀត។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>▪ បានចេញប្រកាសអនុញ្ញាតឱ្យដំណើរការអាជីវកម្មទឹកស្អាតក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងតំបន់សេដ្ឋកិច្ចពិសេសផ្សេងទៀតតាមការស្នើសុំរបស់អ្នកវិនិយោគ<br>▪ បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជនសម្រាប់ផ្គត់ផ្គង់ទឹកស្អាតដល់រោងចក្រ សហគ្រាសកម្មន្តសាល និងតំបន់អភិវឌ្ឍន៍ពាក់ព័ន្ធវិស័យឧស្សាហកម្មនានា ដើម្បីសម្រេចគោលដៅនៃការផ្គត់ផ្គង់ទឹកស្អាត ប្រើប្រាស់នៅទីប្រជុំជនឱ្យបាន ១00% នៅឆ្នាំ២០២៥។<br>- ក្រសួងរ៉ែនិងថាមពល÷<br>▪ បាននិងកំពុងសិក្សាគម្រោងសាងសង់អនុស្ថានីយថ្មីក្នុងតំបន់សេដ្ឋ-កិច្ចពិសេសភ្នំពេញ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បាននិងកំពុងសាងសង់ខ្សែបណ្តាញមេចេញពីអនុស្ថានីយដើម្បីរំលែកបន្ទុកលើខ្សែចាស់ និងបង្កើនស្ថិរភាពក្នុងការផ្គត់ផ្គង់ឱ្យរោងចក្រឧស្សាហកម្ម។<br>▪ បានដាក់ឱ្យដំណើរការអនុស្ថានីយទួលពង្រ (GS8) អានុភាព ៧៥ មេហ្គាវ៉ាត់ ដើម្បីជួយបង្កើនការផ្គត់ផ្គង់ដល់តំបន់ឧស្សាហកម្មតំបន់វេងស្រេង និងទួលពង្រ<br>▪ ពង្រីកការផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ធុនធំ ដែលភ្ជាប់ចេញពីខ្សែបណ្តាញតង់ស្យុងខ្ពស់ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (PP-SEZ) និងរោងចក្រស៊ីម៉ង់ត៍ Conch នៅស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង<br>▪ បាននឹងកំពុងសាងសង់អនុស្ថានីយនៅតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ (SHV-SEZ) អានុភាពសរុប ៥០មេហ្គាវ៉ាត់ ដែលគ្រោងដាក់ឱ្យដំណើរការក្នុងឆ្នាំ២០១៩<br>▪ គ្រោងបន្ថែមកម្លាំងត្រង់ស្វូរតាមបណ្តាអនុស្ថានីយក្នុងរាជធានីភ្នំពេញ និងខេត្តក្រុងសំខាន់ៗ ដែលជាទិសដៅអាទិភាព ដើម្បីបង្កើនសមត្ថភាព និងស្ថិរភាពក្នុងការផ្គត់ផ្គង់ជូនអតិថិជន។<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន÷<br>▪ គម្រោងសាងសង់ផ្លូវក្រវ៉ាត់ក្រុងខ្សែទី២ ប្រវែង១៦,៦៨គ.ម (មហាវិថីសហព័ន្ធរុស្ស៊ី-ព្រែកហូរ) កំពុងសាងសង់។<br>▪ គម្រោងសាងសង់ផ្លូវក្រវាត់ក្រុងខ្សែទី៣ (ផ្លូវជាតិលេខ៥-អូរឡឹម-ផ្លូវជាតិលេខ១) ប្រវែង៤៥,៦១គ.ម កំពុងសាងសង់។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានចូលរួមរៀបចំ និងវិភាជន៍ថវិកាឆ្នាំ២០១៨ សម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចមាននៅក្នុងច្បាប់ស្តីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨<br>▪ បានរៀបចំបញ្ជីគម្រោង/កម្មវិធី ក្នុងក្របខ័ណ្ឌថវិកាជាតិ រួមមានផ្លូវថ្នល់ ទឹកស្អាត អគ្គិសនី គមនាគមន៍ និងទូរគមនាគមន៍<br>▪ បាននិងកំពុងសហការអនុវត្តគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី២ ក្នុងទឹកប្រាក់សរុប ១៦,៥ លានដុល្លារអាមេរិក<br>▪ បាននិងកំពុងសហការអនុវត្តគម្រោងផ្គត់ផ្គង់ទឹកស្អាតសៀមរាប ហិរញ្ញប្បទានដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ដែលមានទឹកប្រាក់ប្រមាណ ៩៣,២៤ លានដុល្លារអាមេរិក ដែលមានសមត្ថភាពផលិតទឹកបាន ៦០ ០០០ ម$^{៣}$ ក្នុងមួយថ្ងៃ និងបណ្តាញចែកចាយទឹកស្អាតមួយចំនួននៅក្នុងខេត្ត<br>▪ បាននិងកំពុងសហការអនុវត្តគម្រោងពង្រីកបន្ថែមបន្ទាន់សមត្ថភាពផ្គត់ផ្គង់ទឹកស្អាតខេត្តសៀមរាប ដែលអនុវត្តដោយរដ្ឋាករទឹកស្វយ័តខេត្តសៀមរាប និងគម្រោងពង្រីកសមត្ថភាពរោងចក្រផលិតទឹកស្អាតចំការមន និងប្រព័ន្ធចែកចាយទឹក ហិរញ្ញប្បទានដោយទីភ្នាក់ងារអភិវឌ្ឍន៍បារាំង<br>▪ បាននិងកំពុងសហការអនុវត្តគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ជំហានទី២ ដែលអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងទឹកប្រាក់សរុប ១៦,៥លានដុល្លារអាមេរិក<br>▪ បានបញ្ចប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងផ្លូវជាតិលេខ១, លេខ៥ (ពីស្ពានព្រែកព្នៅទៅស្ពានព្រែកក្តាម), លេខ៦, | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | លេខ៣១, លេខ៣៣, លេខ៥៦, គម្រោងស្តារឡើងវិញផ្លូវដែកនៅកម្ពុជា (ខ្សែភ្នំពេញ-ខេត្តព្រះសីហនុ) និងគម្រោងសាងសង់ប៉ុស្តិ៍ត្រួតពិនិត្យច្រកទ្វារអន្តរជាតិព្រែកចក្រ<br>▪ បានបញ្ចប់ការងារដោះស្រាយផលប៉ះពាល់ដោយសារ គម្រោងផ្លូវជាតិលេខ២១<br>▪ បាននិងកំពុងអនុវត្តការងារដោះស្រាយផលប៉ះពាល់ ដោយសារគម្រោងផ្លូវជាតិលេខ៥ (បាត់ដំបង-បន្ទាយមានជ័យ និងព្រែកក្តាម-ថ្លាម្អម), លេខ៥៨, លេខ២, និងលេខ២២<br>▪ ៧បានបញ្ចប់ការអនុវត្តការងារដោះស្រាយផលប៉ះពាល់នៃគម្រោងផ្លូវជាតិលេខ៥៣, លេខ១៣ និងលេខ១៥៧៧<br>▪ បាននិងកំពុងអនុវត្តការងារដោះស្រាយផលប៉ះពាល់ ដោយសារគម្រោងសាងសង់ប៉ុស្តិ៍ត្រួតពិនិត្យច្រកទ្វារអន្តរជាតិព្រៃវល្លិ៍, គម្រោងរៀបចំច្រកទ្វារអន្តរជាតិស្ទឹងបទ<br>▪ អនុម័តផែនការដោះស្រាយផលប៉ះពាល់គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណការ និងដឹកជញ្ជូន នៅភូមិសាស្ត្រខេត្តបាត់ដំបង<br>▪ បានបញ្ចប់ការងារដោះស្រាយផលប៉ះពាល់គម្រោង សាងសង់ផ្លូវជាតិលេខ៥៥ មានប្រវែង ១៨២.១៦៦គ.ម ដែលមានភូមិសាស្ត្រនៅក្នុងខេត្តពោធិ៍សាត់<br>▪ បានបញ្ចប់ការងារដោះស្រាយផលប៉ះពាល់គម្រោងជួសជុលកែលម្អស្ពានមិត្តភាពកម្ពុជាជប៉ុនជ្រោយចង្វារ ស្ថិតក្នុងភូមិសាស្ត្ររាជធានី | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ភ្នំពេញ គម្រោងស្តារឡើងវិញផ្លូវជាតិលេខ៥១ ដែលមានភូមិសាស្ត្រស្ថិតក្នុងខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ<br>▪ បន្តអនុវត្តការងារដោះស្រាយផលប៉ះពាល់គម្រោងស្តារឡើងវិញផ្លូវជាតិលេខ១១ ដែលមានភូមិសាស្ត្រស្ថិតក្នុងខេត្តត្បូងឃ្មុំ និងខេត្តព្រៃវែង<br>▪ បានបញ្ចប់ការអនុវត្តការងារដោះស្រាយផលប៉ះពាល់ ដោយសារគម្រោងកែលម្អផ្លូវខេត្តលេខ១៥០B និង១៥១B និងផ្លូវខេត្តលេខ៣១៤D។<br>- រដ្ឋបាលខេត្តព្រះសីហនុ÷<br>▪ បានរៀបចំកែលម្អប្រព័ន្ធបញ្ជូនភ្លើងនៅក្នុងក្រុង និងឆ្ពោះទៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ<br>▪ បានរៀបចំកែលម្អប្រព័ន្ធចាស់ និងរៀបចំប្រព័ន្ធបញ្ជូនភ្លើងថ្មីទៅកាន់តំបន់ទើបអភិវឌ្ឍន៍នៅក្នុងក្រុង និងគ្រោងបញ្ចប់នៅដំណាច់ត្រីមាសទី១ ឆ្នាំ២០១៨<br>▪ ជួយសម្របសម្រួលក្នុងការដោះស្រាយផលប៉ះពាល់ក្នុងការសាងសង់ផ្លូវល្បឿនលឿនភ្ជាប់ពីខេត្តព្រះសីហនុ ទៅរាជធានីភ្នំពេញ។<br>- រដ្ឋបាលខេត្តស្វាយរៀង÷<br>▪ បាននិងកំពុងដំណើរការ រោងចក្រទឹកស្អាតចំនួន ០៦ ទីតាំង ស្ថិតក្នុងទីប្រជុំចំនួន ០៦ ដែលមានសេវាគ្របដណ្តប់ពី ៣២% ទៅ ៦២ %<br>▪ បានដាក់ឱ្យប្រើប្រាស់នូវបណ្តាញទឹកស្អាត ពង្រីកថ្មី ប្រវែង ១២៨០៨ ម នៅក្រុងស្វាយរៀង និងគ្រោងដាក់ឱ្យប្រើប្រាស់ បណ្តាញទឹកស្អាត ៤៥០០ ម/ឆ្នាំ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បញ្ចប់ការសិក្សាប្រភពទឹក អាងទន្លេរ៉ៃគោ និង ទីតាំង សាងសង់រោងចក្រផលិត ទឹកស្អាតថ្មី ដែលមាន សមត្ថភាពផលិត ២០០០០ ម៉ែត្រគូប/ថ្ងៃ ជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)<br>▪ កំពុងសិក្សាសមិទ្ធិលទ្ធភាពគ្រោងផ្គត់ផ្គង់ទឹកស្អាត តាមដងផ្លូវជាតិលេខ១ ពីក្រុងស្វាយរៀងទៅក្រុងបាវិត និងតំបន់សេដ្ឋកិច្ចពិសេស<br>▪ ជំរុញការបញ្ចប់ និងដាក់ឱ្យដំណើរការរោងចក្រផលិតទឹកស្អាតនៅឃុំក្រោលគោ ស្រុកស្វាយជ្រំ<br>▪ គ្រោងដំណើរការសិក្សាសមិទ្ធិលទ្ធភាពសាងសង់រោងចក្រផ្គត់ផ្គង់ទឹកស្អាត នៅប្រជុំជន ស្រុកកំពង់រោទិ៍ ប្រជុំជន ស្រុកចន្ទ្រា និងប្រជុំជនដូនស ស្រុកស្វាយជ្រំ<br>▪ ដាក់ដំណើរការខ្សែបញ្ជូនតង់ស្យុង ១៥០គីឡូវ៉ុល នៅត្រីមាសទី១ ឆ្នាំ ២០១៧ និងកំពុងបន្តចែកចាយ ពីអនុស្ថានីយ ច្រកម្ទេស ឆ្ពោះទៅអង្គភាពអគ្គិសនី ខេត្តស្វាយរៀង និងឆ្ពោះទៅតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន ក្រុងបាវិត<br>▪ ពង្រីកបណ្ដាញតង់ស្យុងទាប (LV) បានប្រវែង ៨៨.៤៩០ម<br>▪ ពង្រីកបណ្ដាញតង់ស្យុងមធ្យម (MV) បានប្រវែង ៣២.២៤៧ម<br>▪ រៀបចំតបណ្ដាញអគ្គិសនី ចូលតាមភូមិបាន ២១២ភូមិ និងបន្តចែកចាយ ជូនប្រជាពលរដ្ឋប្រើប្រាស់ ចំនួន ៥០,៣៣៦គ្រួសារស្មើនឹង ៣៤.៧៥%<br>▪ បាននិងកំពុងអនុវត្តតម្លៃអគ្គិសនី ជូនអ្នកប្រើប្រាស់ មានបីកម្រិតគឺ÷ មិនលើស ១០គីឡូវ៉ាត់ម៉ោង/ខែ ថ្លៃ ៤៨០រៀល/គីឡូវ៉ាត់ម៉ោង, ចាប់ពី | |

| វិធានការគោលនយោបាយ/ផែនការ<br>សកម្មភាព | រយៈពេល/<br>ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ១១-៥០គីឡូវ៉ាត់ម៉ោង/ខែថ្លៃ ៦១០រៀល/គីឡូវ៉ាត់ម៉ោង, ចាប់ពី ៥១ គីឡូវ៉ាត់ម៉ោង/ខែ ឡើងទៅ ថ្លៃ៧៩០រៀល/គីឡូវ៉ាត់ម៉ោង<br>▪ បានដំណើរការការងារជួសជុលពង្រីកកំណាត់ផ្លូវជាតិ លេខ១ ប្រវែង ៦.១០០ម ត្រង់គ.ម ១៥៩+២០០ ដល់គ.ម ១៦៥+៣០០ ដោយក្រាល កៅស៊ូ DBST ពង្រីកម្ខាងៗពីអ័ក្សផ្លូវ ប្រវែង ១៥ម (កំពុងដោះស្រាយផលប៉ះពាល់)<br>▪ បានដំណើរការអនុវត្តគម្រោងអាងប្រព្រឹត្តិកម្ម សម្រាប់តំបន់ឧស្សាហកម្មក្រុងស្វាយរៀង លើផ្ទៃដី ប្រមាណ ៣ហ.ត<br>▪ បានដំណើរការអនុវត្តគម្រោង ស្ថាបនាកំពង់ផែអូរស្ងាច់ សម្រេចបាន ប្រមាណ ៣៥ % លើការងារដូចខាងក្រោម÷<br>- ការងារស្ថាបនាផ្លូវដីថ្មី ទំហំ ៨៦២មX៧ម និងចាក់ដីសម្រាប់សាងសង់កំពង់ផែអូរស្ងាច់ (ទន្លេវៃគោ)ផ្ទៃដី១៣,២៤៣ម²<br>- ការងារស្ថាបនាលើកដីធ្វើ កំពង់ផែអូរស្ងាច់ (ទន្លេវៃគោ) ទំហំ ៥០មX១០០ម កម្ពស់ ២,៦០ម<br>- ការងារស្ថាបនាផែដែក បណ្តែតទឹកទំហំ ៦០ម x ១២ម និងផ្លូវបេតុង ប្រវែង ៣៦ម ទទឹង ៦,៤០ម សម្រាប់ចុះផែ<br>▪ ការងារពង្រីកផ្លូវបេតុង សងខាងផ្លូវជាតិលេខ១ ពីគ.ម ១៦៥ + ៣០០ ដល់គ.ម១៦៦+ ៨០០ ប្រវែង ១.៥០០ម សម្រេច ១០០%<br>▪ បានដំណើរការ ការងារជួសជុលកំណាត់ផ្លូវខេត្តលេខ៣១៦ ប្រវែង ១៣.១២០ម បំបែកចេញ ពីផ្លូវជាតិលេខ១ ត្រង់គ.ម ១៤៣ + ២០០ ស្ថិតក្នុងឃុំស្វាយតាយាន ទៅដល់ផ្លូវខេត្ត ៣១៤C ក្នុងឃុំខ្សែត្រ ស្រុកកំពង់រោទិ៍ ដោយគ្រោងចាក់ក្រាលកៅស៊ូ DBST ទទឹង ៧ម | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ចិញ្ចើម ១ម សងខាងព្រមទាំងស្ពានលូកាត់ ទទឹង ផ្លូវប្រវែង១២ម ចំនួន ១២កន្លែង សម្រេចបាន ៨០%<br>▪ បានដំណើរការការងារជួសជុលកំណាត់ផ្លូវខេត្តលេខ៣១៨C ប្រវែង ១៣,០០០ម បំបែកចេញពីផ្លូវជាតិលេខ១៨ (៣១៨D) ត្រង់គ.ម ១៦+០០០ ចាប់ពីសាលាស្រុកកំពង់រោទិ៍ ទៅដល់ឃុំត្នោត ស្រុកកំពង់រោទិ៍ ដោយគ្រោងចាក់ក្រាល កៅស៊ូ DBST ទទឹង ៦ម ចិញ្ចើម ១ម សងខាង ព្រមទាំងស្ពានលូកាត់ទទឹងផ្លូវ ប្រវែង ១១ម ចំនួន ១០ កន្លែង សម្រេចបាន ២៥ %<br>▪ ការងារជួសជុលផ្លូវខេត្តលេខ៣១៥ ប្រវែង ៧,៥០០ម ដោយក្រាលកៅស៊ូ DBST ពី គ.ម១០+៧០០ ដល់ គ.ម១៨+២០០ សម្រេចបាន ៥៩ %។<br>- រដ្ឋបាលខេត្តកោះកុង៖<br>▪ បានប្រជុំអន្តរក្រសួងរៀបចំបង្កើតតំបន់សេដ្ឋកិច្ច ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ១កន្លែង មានផ្ទៃដីសរុបចំនួន ១៤៨ ហ.ត<br>▪ បានពង្រីកបណ្តាញចែកចាយអគ្គិសនីនៅតាមបណ្តាស្រុកទាំង៦ និងក្រុងខេមរភូមិន្ទរបស់ខេត្តកោះកុងបានចែកចាយថាមពលអគ្គិសនីសរុបចំនួន ៦៤.២៥៤.១២៥ គីឡូវ៉ាត់ម៉ោង<br>▪ បានរៀបចំបង្កើតឱ្យមានរោងចក្រផលិតទឹកស្អាតមួយកន្លែង នៅស្ទឹងអូរស្រីស្រណោះ ឬហៅទឹកជ្រោះតាប៉នសម្រាប់ផ្គត់ផ្គង់ក្រុងខេមរភូមិន្ទ សម្រេចបាន អាងទឹកប្រព្រឹត្តិកម្មទឹក ១០០% អាងស្តុកទឹក ១០០% និងស្ពានទំនប់ទឹកបាន ៤០% | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានរៀបចំប្លង់គោលស្តីពីការប្រើប្រាស់ដីធ្លីក្នុងក្រុងខេមរភូមិន្ទ នឹងបានបញ្ចប់ ១០០%<br>▪ បានកំណត់ទីតាំងសម្រាប់ទុកដាក់សម្រាម ១កន្លែង ទំហំផ្ទៃដី ៣ហ.ត។ | |
| - កំណត់ឱ្យបានច្បាស់លាស់នូវឯកសារបទដ្ឋាន និងគោលការណ៍ណែនាំស្តីពីការការពារបរិស្ថាន និងសុវត្ថិភាពផលិតកម្ម សម្រាប់គម្រោងវិនិយោគដែលបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មផ្សេងទៀត | ២០១៥<br>ទៅ<br>មធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ការងារក្នុងឆ្នាំ២០១៧-២០១៨÷<br>▪ បានបន្តចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ<br>▪ បានជំរុញ និងលើកទឹកចិត្តអ្នកអភិវឌ្ឍន៍តំបន់ក្នុងការរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់ នៅក្នុងតំបន់ដែលខ្លួនធ្វើការអភិវឌ្ឍ ដើម្បីធានាបង្កើននូវកិច្ចការពារបរិស្ថាន<br>▪ បានបន្តជំរុញ និងលើកទឹកចិត្តអ្នកអភិវឌ្ឍន៍តំបន់ក្នុងការពង្រឹងសន្តិសុខក្នុងតំបន់ តាមរយៈការដាក់សន្តិសុខយាមក្នុងតំបន់ទាំងថ្ងៃទាំងយប់<br>▪ បានចូលរួមលើកកម្ពស់សុខុមាលភាពរបស់កម្មករ និយោជិត តាមរយៈការគាំទ្រដល់ការរៀបចំកម្មវិធីទាក់ទងនឹងសុខភាពជូនកម្មករនិយោជិត ដូចជា កម្មវិធីចុះផ្សព្វផ្សាយអំពីរបបសន្តិសុខសង្គមរបស់ទីភ្នាក់ងារបេឡាជាតិរបបសន្តិសុខសង្គម និងកម្មវិធីក្រុមគ្រូពេទ្យចុះពិនិត្យព្យាបាលជំងឺជូនកម្មករ។<br>- ក្រសួងបរិស្ថាន÷<br>▪ បានការរៀបចំ (១) ក្រមបរិស្ថាន និងធនធានធម្មជាតិ, (២) យុទ្ធសាស្ត្របរិស្ថាន និងផែនការសកម្មភាពជាតិ, (៣) ការអនុវត្តយុទ្ធសាស្ត្រវេជ- | - រដ្ឋបាលខេត្តកណ្តាល÷<br>បញ្ហាប្រឈម÷<br>▪ កង្វះមន្ត្រី និងមធ្យោបាយចុះបំពេញការងារ<br>▪ ការយល់ដឹងរបស់ម្ចាស់សហគ្រាស និងសិប្បករពីបច្ចេកវិទ្យាថ្មីនៅមានកម្រិត។<br>សំណើដំណោះស្រាយ÷<br>▪ ស្នើសុំក្របខណ្ឌបន្ថែម<br>▪ បង្កើនការយល់ដឹងតាមរយៈការសិក្សារៀនសូត្រ។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ប្ញកជាតិ, (៤) ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រង តំបន់ការពារធម្មជាតិ សំដៅថែរក្សានិរន្តរភាពគុណភាពបរិស្ថាន, (៥) ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងផែនការសកម្មភាពតាមវិស័យឧស្សាហកម្ម កម្មន្តសាល ថាមពល និងដឹកជញ្ជូន ដើម្បីវិកិលទៅរកការអភិវឌ្ឍបញ្ចេញកាបូនតិច ធន់ប្រសិទ្ធភាពធនធាន និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន, (៦) ការអនុវត្តក្របខណ្ឌផែនការជាតិ "ទីក្រុងបៃតង" និងការរៀបចំបទ្បីគោលនយោបាយចតុកោណរបស់រាជរដ្ឋាភិបាល សំដៅរួមចំណែកកាត់បន្ថយការបំពុល សន្សំសំចៃថាមពល ថែរក្សាបានបរិស្ថានល្អ និងការអភិវឌ្ឍដោយចេរភាព, និង (៧) សាកល្បងអនុវត្តគោលការណ៍ "ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី" ក្នុងបរិបទជួយដល់វិស័យសេដ្ឋកិច្ចសង្គម និងនយោបាយបរិស្ថានកម្ពុជា។<br>- រដ្ឋបាលខេត្តស្វាយរៀង បាននិងកំពុងជំរុញតំបន់សេដ្ឋកិច្ចពិសេសទាំងអស់ រៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន និងសាងសង់អាងប្រព្រឹត្តិកម្មឱ្យបានត្រឹមត្រូវតាមស្តង់ដារ។<br>- រដ្ឋបាលខេត្តកណ្តាល÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ បានជំរុញរោងចក្រ សហគ្រាស សិប្បកម្ម អាជីវកម្ម និងសេវាកម្មឱ្យធ្វើការកែលម្អខ្សែច្រវាក់ផលិតកម្ម ដើម្បីធានាបាននូវបរិស្ថានឧស្សាហកម្ម និងគុណភាពស្របតាមស្តង់ដារជាតិ និងអន្តរជាតិ<br>▪ បានជំរុញការអនុវត្តច្បាប់ក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្មតាមរយៈការចុះផ្សព្វផ្សាយផ្ទាល់ដល់មូលដ្ឋាន រោងចក្រ សហ- | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | គ្រាស និងសិប្បកម្ម ដែលមានក្នុងទូទាំងខេត្ត។ សរុបរោងចក្រមានចំនួន ១៨៥ មូលដ្ឋាន ក្នុងនោះមានផ្នែកវាយនភណ្ឌនិងសម្លៀកបំពាក់ ១២៤ ផ្នែកផលិតផលពីស្បែក ១៣ និងផ្នែកផ្សេងៗ មាន ៤៨។<br>ក្នុងឆ្នាំ២០១៨÷<br>▪ ជំរុញរោងចក្រ សហគ្រាស សិប្បកម្ម អាជីវកម្ម និងសេវាកម្មឱ្យធ្វើការកែលម្អខ្សែសង្វាក់ផលិតកម្ម ដើម្បីធានាបាននូវបរិស្ថានឧស្សាហកម្ម ដែលមានគុណភាពស្របតាមស្តង់ដារជាតិ និងអន្តរជាតិ<br>▪ ជំរុញការអនុវត្តច្បាប់ក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម តាមរយៈការចុះផ្សព្វផ្សាយផ្ទាល់ដល់មូលដ្ឋានរោងចក្រ សហគ្រាស សិប្បកម្ម ដែលមានទូទាំងខេត្ត។ សរុបរោងចក្រមានចំនួន ២០០ មូលដ្ឋាន កើន១៥ ត្រូវជា ៧.៥០%។ ក្នុងនោះ÷ ផ្នែកវាយនភណ្ឌនិងសម្លៀកបំពាក់មាន១២៧ កើន៣ ត្រូវជា ២.៣៦%។ ផ្នែកផលិតផលពីស្បែកមាន÷ ១៦ កើន ៣ ត្រូវជា ១៨.៧៥% និងផ្នែកផ្សេងៗ មាន ÷ ៥៧ កើន៩ ត្រូវជា ១៥.៧៨%។ | |
| - បន្តពង្រឹង និងលើកកម្ពស់សមត្ថភាពរដ្ឋបាល និងក្របខ័ណ្ឌស្ថាប័នសម្រាប់គ្រប់គ្រងប្រតិបត្តិការនៃតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការបង្កើនប្រសិទ្ធភាពនៃយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស សំដៅជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសឯកទេស ដោយផ្តោតលើវិស័យអាទិភាពមួយចំនួន ដូចជា | ២០១៥ ទៅ មធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ការងារក្នុងឆ្នាំ២០១៧-២០១៨<br>▪ បានបន្តរៀបចំកែសម្រួលរចនាសម្ព័ន្ធអភិបាលកិច្ចស្ថាប័ន និងពង្រឹងសមត្ថភាពមន្ត្រីនៅតាមរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ដើម្បីផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ជូនអ្នកវិនិយោគ<br>▪ បាននិងកំពុងពិចារណាលើ (១) សំណើឱ្យមានការសាងសង់ប៉ុស្តិ៍យាមមួយ នៅត្រង់ច្រកចេញចូលតំបន់សេដ្ឋកិច្ចពិសេស ដើម្បី | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| ការកែច្នៃកសិផល សម្រាប់នាំចេញ (ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចឯកទេស ត្រូវចំណុះលើកត្តាសំខាន់ៗ ដូចជា ទីតាំងភូមិសាស្ត្រ ប្រភេទប្រតិបត្តិការអាជីវកម្ម មូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធរួមទាំង អគ្គិសនី និងទឹកស្អាត និងប្រព័ន្ធភស្តុភារកម្ម ព្រមទាំងការលើកទឹកចិត្តផងដែរ) | | ងាយស្រួលត្រួតពិនិត្យទំនិញចេញ-ចូល និង (២) សំណើបន្ថែមមន្ត្រីតំណាងពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបម្រើការក្នុងរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស<br>▪ បានចូលរួមសម្របសម្រួលរៀបចំកិច្ចប្រជុំរវាងតំណាងកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងតំណាងពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់រាជរដ្ឋាភិបាលជប៉ុន (JICA) ប្រចាំនៅកម្ពុជា ដើម្បីរៀបចំ និងកំណត់យុទ្ធសាស្ត្រស្វែងរកទីផ្សារ និងការផ្សព្វផ្សាយតំបន់សេដ្ឋកិច្ចកំពង់ផែស្វយ័តក្រុងព្រះសីហនុក្នុងឆ្នាំ២០១៨<br>▪ បាននិងកំពុងបន្តពិចារណាទៅលើសំណើរបស់តំណាងការិយាល័យនៃក្រសួងស្ថាប័នពាក់ព័ន្ធ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ទៅលើ (១) ការជំរុញអ្នកអភិវឌ្ឍន៍ឱ្យសាងសង់ប៉ុស្តិ៍យាមនៅត្រង់ច្រកចេញចូលតំបន់ ដើម្បីងាយស្រួលត្រួតពិនិត្យទំនិញចេញ-ចូល, (២) ការរៀបចំកិច្ចប្រជុំប្រចាំខែរវាងការិយាល័យតំណាងក្រសួងស្ថាប័ន និងតំណាងក្រុមហ៊ុន ព្រមទាំង (៣) ការបង្កើនកិច្ចសហការគ្រប់ភាគីពាក់ព័ន្ធក្នុងរដ្ឋបាលតំបន់ក្នុងឆ្នាំ២០១៨។ ជាមួយគ្នានោះ បាននិងកំពុងពិចារណាទៅលើសំណើពាក់ព័ន្ធនឹងការកែសម្រួលប្រាក់ឧបត្ថម្ភឱ្យស្របតាមស្ថានភាពជាក់ស្តែង។ | |
| - ពិនិត្យលទ្ធភាពក្នុងការជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសធំៗ និងមានបទដ្ឋានខ្ពស់ដោយប្រើយន្តការភាពជាដៃគូររវាងរដ្ឋ និងវិស័យឯកជន។ | មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំ និងកំពុងបន្តអនុវត្តឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ការងារក្នុងឆ្នាំ២០១៧-២០១៨÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ដោយមានការតិតតួរពីការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសធំៗ និងមានបទដ្ឋានខ្ពស់ដោយប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន<br>▪ បានលើកទឹកចិត្ត និងជំរុញគម្រោងវិនិយោគអភិវឌ្ឍន៍តំបន់តាមរយៈជំនួបពិភាក្សាការងារជាមួយគណៈប្រតិភូមកពីបណ្តាប្រទេសផ្សេងៗ។ | |
| *២)-ការពង្រីក និងធំនើបកម្មសហគ្រាសធុនតូច និងមធ្យម* | | | |
| *ក-ការរៀបចំស្ថាប័ន និងការលើកទឹកចិត្ត* | | | |
| - ជំរុញឱ្យមានការរៀបចំផែនការរយៈពេលមធ្យមសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម ដោយកំណត់យកមុខសញ្ញាសហគ្រាសដែលមានសក្តានុពលក្នុងការនាំចេញ ការអភិវឌ្ឍផលិតផលថ្មី ការតភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs) ការតភ្ជាប់ខ្សែច្រវាក់តម្លៃ និងការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មតំបន់ ហើយរៀបចំនូវក្របខ័ណ្ឌសកម្មភាពចាំបាច់ និងជាក់ស្តែងដើម្បីអភិវឌ្ឍន៍ សហគ្រាសទាំងនោះ | ២០១៥ ទៅ មធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានសម្របសម្រួលឱ្យសហគ្រាសខ្នាតតូច និងមធ្យមបានចូលរួមពិព័រណ៍ក្នុង និងក្រៅប្រទេស និងរៀបចំបេសកកម្មពាណិជ្ជកម្មទៅកាន់គោលដៅទីផ្សារដើម្បីឱ្យសហគ្រាសខ្នាតតូចនិងមធ្យមបានសិក្សារៀនសូត្រពីភាពជឿនលឿននៃឧស្សាហកម្មខ្នាតតូច និងមធ្យមនៃបណ្តាប្រទេសទាំងនោះ។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ការងារក្នុងឆ្នាំ២០១៧-២០១៨÷<br>▪ បានបន្តចូលរួម និងផ្តល់ធាតុចូលលើសេចក្តីព្រាងឯកសារក្របខណ្ឌគោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា<br>▪ បានចូលរួមសហការ និងផ្តល់ការសម្របសម្រួលលើការសិក្សាអង្កេតរបស់អង្គការសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ស្តីពីការ | - ក្រសួងពាណិជ្ជកម្ម÷<br>▪ ថវិកា និងធនធានមនុស្សនៅមានកំណត់។<br>- រដ្ឋបាលខេត្តកណ្តាល÷<br>▪ ផលិតផលមិនទាន់ទទួលបានការគាំទ្រពីសំណាក់អ្នកប្រើប្រាស់<br>▪ ដោយសារគុណភាព និងសោភ័ណ្ឌភាពក្នុងការវេចខ្ចប់ មិនទាន់ទាញ។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | តភ្ជាប់រវាងក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស និងសហគ្រាសធុនតូច និងមធ្យមក្នុងស្រុក នៅកម្ពុជា<br>▪ បាននិងកំពុងធ្វើការស្រាវជ្រាវ និងប្រមូលធាតុចូលទាក់ទងនឹងប្រធានបទការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមនៅតាមបណ្តាប្រទេសក្នុងតំបន់<br>▪ បានជួបប្រជុំពិភាក្សា និងផ្តល់ធាតុចូលលើសេចក្តីព្រាងរបាយការណ៍បឋម នៃការសិក្សាអង្កេតលើការតភ្ជាប់រវាងពហុសាជីវកម្ម និងសហគ្រាសក្នុងស្រុកនៅកម្ពុជា ដែលបានរៀបចំដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងគ្រោងសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីលទ្ធផលនៃការសិក្សាស្រាវជ្រាវស្តីពីការតភ្ជាប់រវាងក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស និងសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា។<br>- ក្រសួងពាណិជ្ជកម្ម ÷<br>▪ បានរៀបចំសិក្ខាសាលាជាស៊េរី សម្រាប់ពង្រឹងបង្កើតគំនិតច្នៃប្រឌិតលើការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិក<br>▪ បានរៀបចំយុទ្ធនាការទិញផលិតផលខ្មែរបានចំនួន ១០លើក (ក្នុងនោះ៤លើក នៅឆ្នាំ២០១៦ ២លើក នៅឆ្នាំ២០១៧ និង០៤លើក នៅឆ្នាំ២០១៨) នៅក្នុងរាជធានី-ខេត្ត ដោយបានប្រមូលភ្ញៀវសហគ្រាសតូចធំដែលបានកំពុងផលិត ផលិតផល និងសេវាកម្មមកដាក់តាំងបង្ហាញដើម្បីស្វែងរកដៃគូពាណិជ្ជកម្ម និងទទួលការបណ្តុះបណ្តាលបន្ថែមពីកិច្ចការអភិវឌ្ឍផលិតផល និងសេវាកម្ម | |

| វិធានការគោលនយោបាយ/ផែនការ សកម្មភាព | រយៈពេល/ ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ការពង្រឹងឡើងវិញនូវប្រព័ន្ធផលិតកម្ម ដើម្បីផលិតទំនិញ និងសេវាមានគុណភាព មានសុវត្ថិភាព សម្រាប់អ្នកប្រើប្រាស់<br>▪ បាននឹងកំពុងពង្រីកទីផ្សារគោលដៅថ្មីបន្ថែមសម្រាប់បញ្ជាប់ការនាំចេញផលិតផលកម្ពុជាទៅទីផ្សារទាំងនោះ<br>▪ បានបើកមជ្ឈមណ្ឌលដាក់តាំងបង្ហាញផលិតផលកម្ពុជា នៅក្នុងប្រទេសចិនបានចំនួន ៥ទីតាំង និងបន្តចរចាបើកមជ្ឈមណ្ឌលដាក់លក់ផលិតផលខ្មែរ បន្ថែមទៀតនៅក្នុងប្រទេសចិន<br>▪ បានសម្របសម្រួលឱ្យសហគ្រាសខ្នាតតូច និងមធ្យមបានចូលរួមពិព័រណ៍ក្នុង និងក្រៅប្រទេស និងរៀបចំបេសកកម្មពាណិជ្ជកម្មទៅកាន់ទីផ្សារគោលដៅដើម្បីឱ្យសហគ្រាសខ្នាតតូច និងមធ្យមបានសិក្សារៀនសូត្រពីភាពជឿនលឿននៃឧស្សាហកម្មខ្នាតតូច និងមធ្យមនៃបណ្តាប្រទេសទាំងនោះ<br>▪ រៀបចំជំនួបពាណិជ្ជកម្មក្នុង និងក្រៅប្រទេសសំដៅទាក់ទាញការវិនិយោគ និងស្វែងរកដៃគូពាណិជ្ជកម្មថ្មីបន្ថែម<br>▪ បានរៀបចំសិក្ខាសាលាស្តីពី ការជំរុញផលិតផលសក្តានុពលទៅកាន់ទីផ្សារជាតិ និងអន្តរជាតិ និងបញ្ជ្រាបការយល់ដឹងពីគោលនយោបាយ និងយន្តការពាណិជ្ជកម្ម ដែលរដ្ឋាភិបាលបាននិងកំពុងអនុវត្តជូនពាណិជ្ជករ<br>▪ បានបង្កើតផ្សារព្រំដែនកម្ពុជា-វៀតណាម នៅឃុំដា ខេត្តត្បូងឃ្មុំ<br>▪ បានចុះពង្រឹងសមត្ថភាព និងសកម្មភាពរបស់សមាគមកសិ-ពាណិជ្ជកម្ម តាមបណ្តារាជធានី-ខេត្ត | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានចុះ MOU ជាមួយអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡស័ក្ត (AQSIQ) ស្តីពីកិច្ចសហប្រតិបត្តិការនៃការលើកកម្ពស់គុណភាព និងជំរុញការនាំចេញទៅកាន់ទីផ្សារចិន។<br>- រដ្ឋបាលខេត្តកណ្តាល÷<br>▪ ក្នុងឆ្នាំ២០១៧ បានសម្របសម្រួលឱ្យសហគ្រាសខ្នាតតូច និងមធ្យមបានចូលរួមតាំងពិព័រណ៍ក្នុង និងក្រៅប្រទេស។ សហគ្រាសធម្យមនិងតូចចំនួន៤មូលដ្ឋាន បានចូលរួមតាំងពិពណ៌ នៅខេត្តបង្ហាញផលិតផល÷ ចានកែវស្មោរ ទុយោជ័រ ទឹកពិសាជប និងទឹកត្រី។<br>▪ ក្នុងឆ្នាំ២០១៨ បានសម្របសម្រួលឱ្យសហគ្រាសខ្នាតតូច និងមធ្យមចូលរួមតាំងពិពណ៌ក្នុង និងក្រៅប្រទេស។ សហគ្រាសមធ្យមនិងតូចចំនួន ០៥មូលដ្ឋាន បានចូលរួមតាំងពិពណ៌នៅខេត្ត បង្ហាញផលិតផល ចាន កែវស្មោរ ទុយោជ័រ ទឹកពិសាជប និងទឹកផ្លែឈើ។<br>- រដ្ឋបាលខេត្តស្វាយរៀង | |
| - ពង្រឹងនូវក្របខ័ណ្ឌ និងយន្តការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ពិសេសសំដៅរៀបចំការចុះបញ្ជី ការគ្រប់គ្រង និងការតាមដានវឌ្ឍនភាពនៃវិស័យនេះ ដែលទាក់ទាញសហគ្រាសកម្ពុជាឱ្យទៅចុះបញ្ជីរបបពន្ធដូវការ ដែលអាចឱ្យរាជរដ្ឋាភិបាលកម្ពុជាមានព័ត៌មានច្បាស់លាស់ សម្រាប់រៀបចំគោលនយោបាយ គាំទ្រ ដើម្បីផ្តល់លទ្ធភាពឱ្យសហគ្រាសទាំងនោះមានលទ្ធភាព | ២០១៥ ទៅ មធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>▪ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការសម្របសម្រួលការចុះបញ្ជីពាក់ព័ន្ធនឹងសហគ្រាសធុនតូច និងមធ្យម និងសេវាកម្ម នៅក្រោមក្របខ័ណ្ឌឯបូលតែមួយ ដែលបច្ចុប្បន្នបានដាក់ជូនទៅដល់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច ដើម្បីដាក់ប្រជុំឆ្លងចុងក្រោយ មុននឹងជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច | - រដ្ឋបាលខេត្តកណ្តាល÷<br>▪ ខ្វះមន្ត្រីនិងមធ្យោបាយចុះបំពេញការងារ។ |

| ទិដ្ឋភាពគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព |ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| ទទួលបានព័ត៌មានពីឥណទាន និងការពិគ្រោះយោបល់ផ្នែកធុរកិច្ច ដើម្បីពង្រីកសកម្មភាព និងការវិនិយោគ | | ▪ បានកសាងឯកសារក្របខ័ណ្ឌគោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ដោយមានកិច្ចសហប្រតិបត្តិការពី JICA<br>▪ បានចេញប្រកាសស្ដីពីនីតិវិធី និងបែបបទស្នើសុំប្រកាសបង្កើតរោងចក្រ និងសិប្បកម្ម និងប្រកាសស្ដីពីនីតិវិធីអនុវត្តបទប្បញ្ញត្តិលើកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម ព្រមទាំងបាននិងកំពុងរៀបចំនិយមន័យទៅតាមវិស័យនីមួយៗ<br>▪ បានរៀបចំកសាងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីពង្រឹងការគ្រប់គ្រងរោងចក្រ និងសិប្បកម្មនៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងជំរុញការចុះបញ្ជីឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសង្គតិភាពខ្ពស់។<br>- ក្រសួងពាណិជ្ជកម្ម៖<br>▪ បានចាត់បញ្ជូនមន្ត្រីជំនាញចូលរួមក្នុងក្រុមការងារទទួលចុះបញ្ជីសហគ្រាសខ្នាតតូច និងមធ្យម នៅច្រកចេញ-ចូលតែមួយ ដែលមានការិយាល័យនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>▪ ចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីកាត់បន្ថយពេលវេលា និងលុបបំបាត់ការចំណាយក្រៅផ្លូវការ ជាមួយការទូទាត់ជាមួយធនាគារកាណាឌីយ៉ា ធនាគារអេស៊ីលីដា និងក្រុមហ៊ុន Visa<br>▪ បានលុបចោលកម្រៃគ្រប់គ្រងការនាំចេញ (EMF) ដើម្បីរក្សា និងពង្រីកការនាំចេញ និងរក្សាកំណើនផលិតភាព និងបៀវត្ស។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិក្នុងការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមស្របតាមការវិវត្តន៍នៃបច្ចេកវិទ្យាជារៀងរាល់ឆ្នាំ។<br>- ទីស្តីការគណៈរដ្ឋមន្ត្រី បានចូលរួមប្រជុំការងារពាក់ព័ន្ធនឹង IDP លើការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម។<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំបង្កើតសាខាត្រួតពិនិត្យអនាម័យសត្វ និងភូតគាមអនាម័យប្រចាំតំបន់ និងបង្កើតស្នាក់ការត្រួតពិនិត្យ អនាម័យសត្វនិងភូតគាមអនាម័យនៅតាមច្រកទ្វារព្រំដែនអន្តរជាតិនិងធ្វើប្រតិបត្តិការ ដើម្បីសម្រួលការនាំចេញផលិតផល ដែលមានដើមកំណើតពីសត្វ និងដំណាំកសិកម្មបង្កស្កាត់ការរាតត្បាតជម្ងឺសត្វនិងការរាតត្បាតសមាសភាពចង្រៃជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វនិងភូតគាមអនាម័យ÷<br>    - បានរៀបចំបង្កើតស្ថានីយចត្តាឡីស័កសត្វ<br>    - ការបង្កើតគណៈកម្មការគ្រប់គ្រងហានិភ័យសុខភាពសត្វ និងផលិតកម្មសត្វ<br>    - បានបង្កើតក្រុមការងារបច្ចេកទេសភាពស៊ាំនឹងឱសថប្រឆាំងនឹងមេរោគ<br>    - ការដាក់ចេញនូវវិធានការនានា ដើម្បីរឹតបន្តឹងការត្រួតពិនិត្យអនាម័យសត្វ និងភូតគាមអនាម័យ<br>    - ការអនុម័តប្រកាសស្តីពីនីតិវិធីនៃការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - រដ្ឋបាលរាជធានីភ្នំពេញ÷<br>▪ គិតត្រឹមខែធ្នូ ឆ្នាំ២០១៧ សហគ្រាសធុនតូច និងមធ្យម សិប្បកម្ម និងរោងចក្រវិនិយោគ មានសរុបចំនួន ៣៥១៧មូលដ្ឋាន (ស្រូបទាញកម្លាំងពលកម្មសរុបចំនួន ៦៨៧៤៩នាក់) ដែលបានមកចុះបញ្ជីតាមរយៈយន្តការច្រកចេញ-ចូលតែមួយនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងនៅរដ្ឋបាលរាជធានីភ្នំពេញ ដែលមានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ជាសេនាធិការ<br>▪ បានចុះជំរុញឱ្យម្ចាស់សិប្បកម្មចុះបញ្ជីសិប្បកម្មស្របច្បាប់បានចំនួន ៦៤៥មូលដ្ឋាន ក្នុងនោះមូលដ្ឋានថ្មីមានចំនួន ៣៩២មូលដ្ឋាន និងចុះបញ្ជីបន្តមានចំនួន ២៥៣មូលដ្ឋាន<br>▪ បានចុះពិនិត្យ និងវាយតម្លៃពាក្យសុំស្នើបង្កើតបន្ត និងសុំវិញ្ញាបនបត្រដំណើរការច្បាប់ថ្នាក់ក្រសួងបានចំនួន ១១៤មូលដ្ឋាន ក្នុងនោះសំណើសុំថ្មីមានចំនួន ២០មូលដ្ឋាន សំណើបន្តមានចំនួន ៥៣មូលដ្ឋាន និងសំណើសុំវិញ្ញាបនបត្រដំណើរការមានចំនួន ៤១មូលដ្ឋាន<br>▪ បានចុះជំរុញមូលដ្ឋានផលិតម្ហូបអាហារឱ្យយកផលិតផលទៅពិនិត្យគុណភាពបាន ២៤៩មុខផលិតផល<br>▪ បានចុះពិនិត្យ និងអនុវត្តផលិតកម្មល្អ (GMP) និងអនាម័យល្អ (GHP) បានចំនួន ៤៦មូលដ្ឋាន<br>▪ បានចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដៃបាញ់ប្រេងនៅស្ថានីយប្រេងឥន្ធនៈបានចំនួន៣០៩ស្ថានីយ-ដេប៉ូ មាន ៥៩៨ទូ ស្មើនឹង ៣.១៩៥ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ដៃបាញ់ប្រេង ក្នុងនោះដៃមិនអនុលោមមានចំនួន ២៨ ហើយបានជួសជុល និងកែលម្អជាស្ថាពរ<br>▪ បានចុះត្រួតពិនិត្យ លើបរិមាណ ចំណុះ និងទំងន់ លើផលិតផលវេចខ្ចប់ចំនួន ៤៦មូលដ្ឋាន មាន ៦១មុខផលិតផល ស្មើនឹង ១៣៩ ខ្នាតផលិតផល<br>▪ បាននាំយកជញ្ជីងយុត្តិធម៌ទៅដាក់តាំងនៅតាមទីផ្សារក្នុងភូមិសាស្ត្ររាជធានីភ្នំពេញបានចំនួន ០៣គ្រឿង ក្នុងនោះផ្សារធំថ្មី ០១គ្រឿង និងផ្សារអូរឬស្សី ០២គ្រឿង<br>▪ ចុះយកសំណាកទឹក នៅស្ថានីយផលិតទឹកស្អាតចំនួន ៣មូលដ្ឋាន ទៅពិនិត្យគុណភាពនៅមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ហើយបរិមាណផលិតទឹកសរុបមាន ៤១១.៧៣១ម$^{៣}$<br>▪ ចំពោះការងារបណ្តុះបណ្តាល មន្ទីរ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រី ឧស្សាហករ និងសិប្បករ មានដូចជា÷ ការគ្រប់គ្រងការបញ្ហា និងសុវត្ថិភាពឡចំហាយ ការផ្សព្វផ្សាយពីការបញ្ចូលសារធាតុអ៊ីយ៉ូតទៅក្នុងអំបិលទឹកត្រី និងទឹកស៊ីអ៊ីវ ការផ្សព្វផ្សាយពីការលើកកំពស់ គុណភាពទឹកកកដើម និងទឹកកកអនាម័យ ការបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រអភិវឌ្ឍផលិតភាព "ស៥"<br>▪ មន្ទីរបានចូលរួមពិភាក្សា ដើម្បីចងក្រងជាសមាគមសិប្បករ និងឧស្សាហករ និងសមាគមអ្នកផលិតទឹកកកដើម និងទឹកកកអនាម័យ<br>▪ តាមរយៈមន្ទីរឧស្សាហកម្ម និងសិប្បកម្ម បាននឹងកំពុងជំរុញការចុះបញ្ជីផ្លូវការរបស់សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ស្រប | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | តាមគោលការណ៍ណែនាំរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងស្មារតីនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។<br>▪ ក្នុងគោលដៅលើកកម្ពស់ និងអភិវឌ្ឍសហគ្រាសធុនតូច ធុនមធ្យម និងសិប្បកម្មផងដែរ មន្ទីរពាណិជ្ជកម្មក្នុងនាមជាសេនាធិការបានអនុវត្តដូចខាងក្រោម÷<br>- សហការរៀបចំព្រឹត្តិការណ៍តាំងពិព័រណ៍បានចំនួន០២លើក<br>- ចុះសិក្សាស្រាវជ្រាវទៅលើផលិតផលក្នុងរាជធានីភ្នំពេញ ដើម្បីអាចចាត់ទុកជាផលិតផលសក្តានុពលរបស់រាជធានីភ្នំពេញ និងជំរុញការលើកកម្ពស់ផលិតផលក្នុងស្រុក ស្វែងរកទីផ្សារជូនដល់ផលិតករ សិប្បករ និងកសិករកម្ពុជា ដើម្បីបង្កើតការងារ បង្កើនប្រាក់ចំណូល និងជួយទប់ស្កាត់ក្នុងការធ្វើចំណាកស្រុករបស់យុវជនវ័យក្មេង<br>- សហការទប់ស្កាត់ការប្រើប្រាស់សារធាតុគីមីហាមឃាត់ក្នុងទំនិញ ដោយចុះអង្កេតត្រួតពិនិត្យគុណភាពសុវត្ថិភាព និងសេវាកម្មលើផលិតផលទំនិញនៅតាមទីផ្សារក្នុងរាជធានីភ្នំពេញបានចំនួន ៥៩៩ លើក លើគោលដៅផ្សាររដ្ឋ ផ្សារទំនើបមីនីម៉ាត ហាង និងផ្ទះលក់ទំនិញ ព្រមទាំងបានសហការរៀបចំវគ្គផ្សព្វផ្សាយមួយចំនួនទៀត។<br>▪ សម្រាប់ឆ្នាំ២០១៨ បានចុះជំរុញអោយម្ចាស់សិប្បកម្មចុះបញ្ជីសិប្បកម្មស្របច្បាប់បានចំនួន ៧៤២មូលដ្ឋាន ក្នុងនោះមាន÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - ចុះបញ្ជីនៅការិយាល័យច្រកចេញចូលតែមួយរបស់មន្ទីរ÷ សុំសេចក្តីសម្រេច៧៦ មូលដ្ឋាន, សុំវិញ្ញាបនបត្រ៨៤ មូលដ្ឋាន, ចុះបញ្ជីបន្ត ៦៣ មូលដ្ឋាន<br>- ចុះបញ្ជីនៅអង្គភាពច្រកចេញចូលតែមួយរដ្ឋបាលរាជធានីភ្នំពេញ÷ចុះបញ្ជីថ្មី ២៩ មូលដ្ឋាន, សុំវិញ្ញាបនបត្រ ២១ មូលដ្ឋាន, ចុះបញ្ជីបន្ត ២៨ មូលដ្ឋាន<br>- ចុះបញ្ជីនៅការិយាល័យច្រកចេញចូលតែមួយរដ្ឋបាលខណ្ឌទាំង១២÷ ចុះបញ្ជីថ្មី ៣១ មូលដ្ឋាន, ចុះបញ្ជីបន្ត ០២ មូលដ្ឋាន, ចុះបញ្ជីមុនប្រតិភូកម្មបាន ៤០៨ មូលដ្ឋាន។<br>▪ បានសហការជាមួយក្រុមការងារអធិការកិច្ចក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចុះធ្វើអធិការកិច្ច រោងចក្រ សគ្រាស និងសិប្បកម្មបានចំនួន ៤០៤ មូលដ្ឋាន ពិនិត្យលើការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម រាប់បញ្ចូលច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្មឆ្នាំ២០១៤ ច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា និងច្បាប់ស្តីពីស្តង់ដារកម្ពុជា<br>▪ បានចុះជំរុញមូលដ្ឋានផលិតម្ហូបអាហារឱ្យយកផលិតផលទៅពិនិត្យគុណភាពបាន១៣៣ មុខផលិតផល ក្នុងនោះអនុលោម ៩៨ មុខផលិតផល និងមិនអនុលោម ៣៥ មុខផលិតផល<br>▪ បានចុះជំរុញមូលដ្ឋានផលិតចំណីអាហារ និងភេសជ្ជៈ ឱ្យទៅចុះបញ្ជីផលិតផល (ចបផ) បានចំនួន ៤៥ មុខផលិតផល<br>▪ បានចុះជំរុញមូលដ្ឋានផលិតចំណីអាហារ និងភេសជ្ជៈ ឱ្យទៅដាក់ពាក្យស្នើសុំប្រើប្រាស់សញ្ញាស្តង់ដារ បានចំនួន ០២ មូលដ្ឋាន | |

| ទិដ្ឋភាពគោលនយោបាយ/ផែនការ សកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដៃបាញ់ប្រេងនៅស្ថានីយប្រេងឥន្ធនៈបានចំនួន ៣១០ស្ថានីយ-ដេប៉ូ មាន៥៧៣ទូ ស្មើនឹង ៣២៨៤ ដៃបាញ់ប្រេង ក្នុងនោះដៃមិនអនុលោមមានចំនួន២៦១ ហើយបានជូនដំណឹងទៅក្រុមហ៊ុនដើម្បី ជួសជុល និងកែលម្អជាស្ថាពរ<br>▪ បានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ (កែវវ៉ៃ) ចំនួន០៩ មូលដ្ឋានស្មើនឹង ៣៩ កែវវ៉ៃ ក្នុងនោះមិនអនុលោម ០<br>▪ ចុះត្រួតពិនិត្យ លើបរិមាណ ចំណុះ និងទំងន់ លើផលិតផលវេចខ្ចប់ចំនួន ៤០មូលដ្ឋាន មាន ១៥០មុខផលិតផល ស្មើនឹង១៧៧ខ្នាតផលិតផល (បរិមាណ ចំណុះ ទំងន់)<br>▪ មន្ទីរបានត្រួតពិនិត្យជញ្ជីងមិនស្វ័យប្រវត្តិ (NAWI) នៅសហគ្រាសផលិតឱសថ PPM ចំនួន១៣ ជញ្ជីង<br>▪ ចុះយកសំណាកទឹក នៅស្ថានីយផលិតទឹកស្អាតចំនួន ០២មូលដ្ឋាន ទៅពិនិត្យគុណភាពនៅមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា<br>▪ ចំពោះការងារបណ្តុះបណ្តាល មន្ទីរ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីឧស្សាហករ និងសិប្បករ មានដូចជា÷<br>- ការគ្រប់គ្រងគុណភាពទឹកពិសារដប<br>- ការផ្សព្វផ្សាយពីការបញ្ចូលសារធាតុអ៊ីយ៉ូតទៅក្នុងអំបិល ទឹកត្រី និងស៊ីអ៊ីវ<br>- សិក្ខាសាលាស្តីពីការដាក់អោយប្រើប្រាស់ប្រពន្ធកត់ត្រាព័ត៌មានរបស់អ្នកផ្គត់ផ្គង់សេវាទឹកស្អាត (Water Supply Monitoring System - WSMS) | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - ការបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រអភិវឌ្ឍផលិតភាព "ស៥"។<br>- រដ្ឋបាលខេត្តកណ្តាល÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ ពង្រឹងនិងក្តាប់បានណែនស្ថិតិ ទិន្នន័យសហគ្រាសធុនតូច និងមធ្យមដែលមានសរុប ២០៦៤ មូលដ្ឋាន។ ក្នុងនោះមានច្បាប់ចំនួន ១១៧៦មូលដ្ឋាន។ កម្លាំងពលកម្មសរុប÷ ១៨ ៣៩៥នាក់ ក្នុងនោះស្រ្តី÷ ៩៩៥៤នាក់ ទុនសរុប÷ ៣១ ៥៦៧ ៦២០ដុល្លារ ។<br>ក្នុងឆ្នាំ២០១៨÷<br>▪ ធ្វើបច្ចុប្បន្នភាពស្ថិតិ និងទិន្នន័យសហគ្រាសធុនតូច និងមធ្យមនិងសិប្បកម្ម ដោយកាត់ចេញនូវសិប្បកម្មដែលឈប់ដំណើរការ ចំនួនមានជាក់ស្តែង÷ ១ ៦៥៥មូលដ្ឋាន<br>▪ បានដំណើរការការិយាល័យច្រកចេញចូលតែមួយថ្នាក់មន្ទីរ និងទទួលបាននូវប្រតិភូកម្មពីក្រសួង ក្នុងការចេញសេចក្តីសម្រេចបង្កើតនិងចេញវិញ្ញាបនបត្រដំណើរការ សហគ្រាសធុនតូចនិងមធ្យមដែលមានទុនសមមូលចាប់ពី៥០ពាន់ដុល្លារដល់ ៥០០ពាន់ដុល្លារ<br>▪ សម្រេចការចុះបញ្ជីចាស់ ថ្មីបាន ៣៣៤មូលដ្ឋាន សរុបមានច្បាប់ ១២៥៥មូលដ្ឋាន កើន៧៩ ស្មើ ២៣.៦៥%។ កម្លាំងពលកម្មសរុប ÷ ១៨ ៨៨៣នាក់ កើន ៤៨៨នាក់ ស្មើ២.៥៨% ក្នុងនោះស្ត្រីមាន ១០ ០៩២នាក់។ ទុនសរុប÷ ៦២ ៦២៣ ២១៤ ដុល្លារ ស្មើ ៤៩.៥៩%។<br>- រដ្ឋបាលខេត្តព្រះសីហនុ÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ រួមជាមួយនឹងមន្ទីរឧស្សាហកម្ម និងសិប្បកម្ម បានជំរុញ និងចុះស្រាវជ្រាវដល់មូលដ្ឋានសហគ្រាសដើម្បីណែនាំសហគ្រិនទាំងអស់ឱ្យចុះបញ្ជីរបបពន្ធផ្លូវការ<br>▪ បន្តគ្រប់គ្រង និងតាមដានវឌ្ឍនភាពរបស់សហគ្រាសក្នុងខេត្ត ដើម្បីមានព័ត៌មានច្បាស់លាស់ ជូនក្រសួងស្ថាប័នពាក់ព័ន្ធងាយស្រួលរៀបចំគោលនយោបាយគាំទ្រ និងផ្តល់ជូនសហគ្រាសនូវពត៌មានឥណទាន ការពិគ្រោះយោបល់ផ្នែកធុរកិច្ច ដើម្បីពង្រីកសកម្មភាពវិនិយោគ<br>▪ បានរួមជាមួយមន្ទីរឧស្សាហកម្ម សិប្បកម្ម ខិតខំជំរុញលើកទឹកចិត្តគរឱ្យប្រជាពលរដ្ឋចូលរួមក្នុងការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម។ ជាក់ស្តែងឧស្សាហកម្មតូច និងសិប្បកម្ម មានសរុបចំនួន ១០៧៧ មូលដ្ឋាន ក្នុងនោះក្រុងព្រះសីហនុ មានចំនួន ៥៧៤មូលដ្ឋាន ស្រុកព្រៃនប់ មានចំនួន៣៣៥មូលដ្ឋាន ស្រុកស្ទឹងហាវ មានចំនួន ៨៥មូលដ្ឋាន និងស្រុកកំពង់សីលា មានចំនួន៨៣មូលដ្ឋាន ដែលមានពលករសរុបចំនួន ៣៥១២នាក់ ស្រី៧១៩នាក់ និង ដើមទុនសរុបចំនួន ១៥.៩៤២.៧០០ដុល្លា ។ ក្នុងចំណោមសហគ្រាសតូច និងសិប្បកម្មខាងលើ មន្ទីរជំនាញ បានចុះបញ្ជី និងចេញវិញ្ញាបនបត្រ បានសរុបចំនួន៣១១មូលដ្ឋាន។<br>▪ បានចុះធ្វើការត្រួតពិនិត្យ ទៅលើមូលដ្ឋានសហគ្រាសសិប្បកម្មផលិតកែច្នៃម្ហូបអាហារ (ដែលមានហានិភ័យខ្ពស់) ក្នុងឆ្នាំ២០១៨ បាន សរុបចំនួន ៣៥មូលដ្ឋាន | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ មូលដ្ឋានផលិតទឹកស្អាតក្នុងខេត្ត មានសរុបចំនួន១១មូលដ្ឋាន ក្នុងនោះបានទទួលប្រកាសអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានចំនួន០៨មូលដ្ឋាន និង០៣មូលដ្ឋាន។<br>- រដ្ឋបាលខេត្តស្វាយរៀង÷<br>▪ បាននិងកំពុងធ្វើបច្ចុប្បន្នភាពស្ថិតិ SME បានប្រមាណ៧១,២៥%<br>▪ ចុះបញ្ជីរោងចក្របានចំនួន ៨៨ ស្មើនឹង៩២,៦៣% និងSME បានចំនួន ១៤៨ មូលដ្ឋាន ស្មើនឹង ៩២,៥០%<br>▪ បានចុះធ្វើអធិការកិច្ចលើការអនុវត្តកិច្ចដំណើការរោងចក្រ និងសិប្បកម្មបានចំនួន ៦៩ រោងចក្រ<br>▪ បានចុះត្រួតពិនិត្យគម្រោងប្លង់រួម និងទីតាំងគ្រឿងចក្រ និងគ្រឿងម៉ាស៊ីន ចំនួន ១៨ រោងចក្រ<br>▪ បានចុះត្រួតពិនិត្យ និងវាយតម្លៃផ្នែកសុវត្ថិភាពបរិស្ថាន ការទុកដាក់ ការប្រើប្រាស់ និងការដាក់ស្លាកសញ្ញា សារធាតុគីមី សារធាតុគ្រោះថ្នាក់ បាន ២១ រោងចក្រ<br>▪ បានសហការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការបង្កើត និងដំណើរការបណ្តុំសហគ្រាសធនតូចនិងមធ្យម និងសិប្បកម្ម ចំនួន ០១ លើក ដល់អ្នកពាក់ព័ន្ធ និងវិស័យឯកជន។ | |
| - ជួយគាំទ្រដល់ការផ្ទេរបច្ចេកវិទ្យា តាមរយៈទស្សនកិច្ចសិក្សា និងការបណ្តុះបណ្តាលពីបណ្តាប្រទេសនានាជុំវិញពិភពលោក | ២០១៥ មធ្យម ទៅ វែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>▪ បានសហការជាមួយវិស័យឯកជនក្នុងការរៀបចំពិព័រណ៍ឧស្សាហកម្មសម្លៀកបំពាក់ និងវាយនភ័ណ្ឌកម្ពុជាអន្តរជាតិ និងពិព័រណ៍ឧស្សាហកម្មគ្រឿងយន្តអន្តរជាតិរៀងរាល់ពីរឆ្នាំម្តង | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានចាត់បញ្ជូនមន្ត្រីបច្ចេកទេសទៅចូលរួមកម្មវិធីទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យានៃក្រសួងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃសាធារណរដ្ឋប្រជាមានិតចិន ជប៉ុន កូរ៉េ និងបណ្តាប្រទេសអាស៊ានមួយចំនួនទៀត តាមរយៈកិច្ចសហប្រតិបត្តិការអាស៊ានផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍÷<br>▪ បានរៀបចំផែនការមេការកសាងសមត្ថភាពការស្រាវជ្រាវ និងអភិវឌ្ឍ ក្នុងវិស័យ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន<br>▪ បានរៀបចំសន្និសិទស្រាវជ្រាវលើបច្ចេកវិទ្យាភាសាថ្នាក់តំបន់ចំនួន២ដង និងថ្នាក់ជាតិទៀតចំនួន៣ដង<br>▪ បានចុះអនុស្សារណរួមជាគ្រឹះស្ថានស្រាវជ្រាវ និងសកលវិទ្យាល័យក្នុងតំបន់អាស៊ានចំនួន៥៤<br>▪ បានអនុវត្តគម្រោងស្រាវជ្រាវជាលក្ខណៈអន្តរជាតិចំនួន៦។ | |
| - បង្កើតមូលនិធិសម្រាប់ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ដោយមានយន្តការគ្រប់គ្រងត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ ដោយ រដ្ឋាភិបាលផ្តល់នូវការវិភាជថវិកាសមស្រប យោងតាមតម្រូវការ និងលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ | ២០១៥ ទៅ មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសិក្សា និងរៀបចំឯកសារផ្សេងៗ ដើម្បីបង្កើត និងផ្តល់ហិរញ្ញប្បទានដល់គម្រោងសាកល្បងគ្រប់គ្រងមូលនិធិជាតិអភិវឌ្ឍន៍ជំនាញ ដើម្បីជំរុញការអភិវឌ្ឍសមត្ថភាព និងផលិតភាពរបស់វិស័យឯកជន និងវិស័យផ្សេងទៀត ។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍÷<br>▪ បានរៀបចំទស្សនទាននិងយន្តការគ្រប់គ្រងសម្រាប់ មូលនិធិការកសាងសមត្ថភាពការស្រាវជ្រាវ និងអភិវឌ្ឍន៍ ក្នុងវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងបានកំណត់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ហិរញ្ញប្បទាន សម្រាប់គាំទ្រដំណើរការរបស់មូលនិធិ និងតាមរយៈការអនុម័តច្បាប់ទូរគមនាគមន៍<br>▪ បានកំពុងប្រើប្រាស់មូលនិធិការកសាងសមត្ថភាពការស្រាវជ្រាវ និងអភិវឌ្ឍន៍ ក្នុងវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដើម្បីអនុវត្តគម្រោងផ្សេងៗ។ | |
| - កសាងធនធានមនុស្ស ដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មឱ្យមានភាពរឹងមាំ និងជីវភាព ដោយផ្តល់ការហ្វឹកហាត់លើជំនាញឯកទេស សម្រាប់ដោះស្រាយកង្វះខាតជំនាញក្នុងវិស័យ អាទិភាព ដោយបង្កើនអាហារូបករណ៍សម្រាប់ការបណ្តុះបណ្តាលវិស្វករ និងអ្នកបច្ចេកទេស | មធ្យម ទៅ វែង | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបណ្តុះបណ្តាលសិស្សបច្ចេកទេសវិជ្ជាជីវៈ កម្រិតជាន់ខ្ពស់បច្ចេកទេស/ឯកទេស និងវិស្វករក្នុងវិស័យអាទិភាព (សំណង់ មេកានិក អគ្គិសនី/អេឡិចត្រូនិក សេវាកម្មធុរកិច្ច/ព័ត៌មានវិទ្យា និងកម្មន្តសាល) ចំនួន ៩ ១០៥នាក់ ដែលមានការកើនឡើង ធៀបនឹងឆ្នាំមុនៗ ដោយសាររាជរដ្ឋាភិបាលបានបង្កើនអាហារូបករណ៍, ការផ្សព្វផ្សាយ, និងការធ្វើទំនើបកម្មសម្ភារបរិក្ខារ។<br>- ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ បានអនុម័តគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ<br>▪ បានរៀបចំផែនការសកម្មភាពអភិវឌ្ឍធនធានមនុស្សនៅមធ្យមសិក្សា<br>▪ បានអនុម័តក្របខណ្ឌគោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន<br>▪ បានរៀបចំសេចក្តីព្រាងឯកសារទស្សនាទានស្តីពីការអភិវឌ្ឍរោងជាងនៅសាលាមធ្យមសិក្សា<br>▪ បានរៀបចំសេចក្តីព្រាងណែនាំស្តីពីការគ្រប់គ្រងធនធានមនុស្ស | - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា÷<br>▪ បានជួបប្រទះនូវបញ្ហាប្រឈម និងហានិភ័យក្នុងការអនុវត្តគោលនយោបាយនេះផងដែរ រួមមាន÷ (១) ពុំទាន់មានទិន្នន័យជាក់លាក់ស្តីពីការបើកធ្វើអាជីវកម្មឯកជន, ឧស្សាហកម្មធុនតូច ឬមធ្យមរបស់ជនពិការ, អតីតយុទ្ធជន, ជនចូលនិវត្ត និងជនងាយរងគ្រោះ។ល។, (២) មជ្ឈមណ្ឌលផលិតឧបករណ៍សិប្បនិម្មិត រណប និងរទេះមួយចំនួនកំពុងប្រឈមនឹងការបិទទ្វារ ដោយសារកង្វះធនធាន, និង (៣) ជនពិការ, អតីតយុទ្ធជន និងនិវត្តជន មានការខ្វះខាតធនធានក្នុងការបើកអាជីវកម្ម។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានរៀបចំសេចក្តីព្រាងផែនការសកម្មភាពឧត្តមសិក្សា ២០១៨-២០២២ ដំណាក់កាលទី១នៃផែនទីបង្ហាញផ្លូវសម្រាប់ឧត្តមសិក្សានៅកម្ពុជាឆ្នាំ២០៣០ និងក្រោយឆ្នាំ២០៣០<br>▪ បានបញ្ចប់សេចក្តីព្រាងស្តង់ដាសម្រាប់ទទួលស្គាល់គុណភាពអប់រំថ្នាក់បណ្ឌិត<br>▪ បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីជ្រើសរើសនិស្សិតចូលរៀន និងបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា<br>▪ បានអភិវឌ្ឍប្រព័ន្ធអភិវឌ្ឍសមត្ថភាពសិស្សផ្នែកគណិតវិទ្យា និងប្រវត្តិវិទ្យា (www.bacii.moeys.gov.kh)<br>▪ បានអភិវឌ្ឍកម្មវិធីទូរសព្ទដៃ "កម្មវិធីល្បែងសិក្សាមេរៀនជីវវិទ្យាថ្នាក់ទី១២" លើប្រព័ន្ធប្រតិបត្តិ Android ជំនួយដល់ការសិក្សាសម្រាប់សិស្សថ្នាក់ទី១២<br>▪ បានធ្វើតេស្តវាយតម្លៃលទ្ធផលសិក្សា និងកម្មវិធីសិក្សា<br>▪ បានធ្វើតេស្តវាយតម្លៃកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ (PISA-D គឺជាការវាយតម្លៃប្រព័ន្ធអប់រំរបស់ប្រទេសមួយ ដោយផ្តោតលើគុណផលសិក្សារបស់សិស្សអាយុ ១៥ឆ្នាំ លើមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ និងអំណាន)<br>▪ ផ្សព្វផ្សាយលទ្ធផលតេស្តវាយតម្លៃកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ (PISA-D)។<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖<br>▪ បានបណ្តុះបណ្តាលជំនាញ និងធនធានមនុស្សក្នុងផ្នែកអភិវឌ្ឍកៅស៊ូដល់មន្ត្រីជំនាញ (TOT: Training of Trainers) បន្តបើក | ▪ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ ព្រមទាំងដើម្បីជំរុញការអនុវត្តវិធានការគោលនយោបាយខាងលើនេះឱ្យសម្រេចបានតាមការរំពឹងទុក និងមានប្រសិទ្ធិភាពខ្ពស់, ក្រសួងបានស្នើនូវវិធានការមួយចំនួន រួមមាន៖ (១) បង្កើតឱ្យមានកញ្ចប់ថវិកាសម្រាប់ក្រុមការងារ IDP តាមក្រសួងនិងស្ថាប័នដែលជាសមាជិក ដោយបញ្ចូលក្នុងកញ្ចប់ថវិការដ្ឋរបស់ក្រសួង, (២) ស្នើលើកគម្រោងចំណាយសម្រាប់ចុះកំណត់អត្តសញ្ញាណ និងស្រង់ទិន្នន័យរាប់បានអំពីការធ្វើអាជីវកម្ម, (៣) ស្នើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្តយកចិត្តទុកដាក់បន្ថែមទៀតលើមជ្ឈមណ្ឌលដែលមានស្រាប់ ដើម្បីបំពាក់ឧបករណ៍ សម្ភារៈទំនើបៗ, ពង្រឹងសមត្ថភាពមន្ត្រីបន្ថែម, ពង្រឹង និងពង្រីកផលិតផលគ្រប់ដោយបរិមាណនិងគុណភាព, (៤) បង្កលក្ខណៈងាយស្រួលដល់បងប្អូន |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | វគ្គបណ្តុះបណ្តាលដល់មន្ត្រីអគ្គនាយកដ្ឋានកៅស៊ូ មន្ត្រីវិទ្យាស្ថានស្រាវជ្រាវស៊ូកម្ពុជា និងមន្ត្រីការិយាល័យកៅស៊ូតាមខេត្ត ចំនួន ៣ វគ្គគឺ÷ (១) ស្ថានភាពឧស្សាហកម្មកៅស៊ូធម្មជាតិពិភពលោក (២) នីតិវិធីប្រមូលទិន្នន័យស្ថិតិ និងព័ត៌មានកៅស៊ូ និង (៣) ការរៀបចំថវិកាកម្មវិធី ដែលមានមន្ត្រីចូលរួម សរុបចំនួន ១១០នាក់<br>▪ បានចុះបើកវគ្គបណ្តុះបណ្តាលការបើកមុខចៀរជ័របួង និងបច្ចេកទេសចៀរជ័រកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារ នៅខេត្តគោលដៅចំនួន ០៦ខេត្ត គឺខេត្តសៀមរាប ឧត្តរមានជ័យ ត្បូងឃ្មុំ ព្រៃវែង រតនគិរី និងមណ្ឌលគិរី បានចំនួន ០៦វគ្គ ដោយមានកសិករចូលរួមសរុប ៣០១នាក់ ក្នុងគម្រោងសរុប ២៧០នាក់ (៤៥នាក់/វគ្គ)<br>▪ បានបញ្ជូនមន្ត្រីជំនាញកសិ-ឧស្សាហកម្ម ជាពិសេសមន្ត្រីជាស្ត្រីចូលរួមវគ្គបណ្តុះបណ្តាលមួយចំនួន ដើម្បីពង្រឹងសមត្ថភាពនៅបណ្តាប្រទេសអាស៊ី និងអឺរ៉ុប និងប្រទេសតាមបណ្តោយខ្សែក្រវ៉ាត់នានា ស្តីពីការត្រួតពិនិត្យក្នុងពេលនាំចេញ និងនាំចូលផលិតផលកសិកម្ម និងចំណីអាហារ និងបានបញ្ចូលគម្រោងស្នើសុំជូនសាធារណរដ្ឋប្រជាមានិតចិន (មេគង្គ-ឡានឆាង)។<br>– ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា÷<br>▪ មូលនិធិជនពិការតាមរយៈមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងអង្គការដៃគូ បានផ្តល់សេវាស្តារលទ្ធភាពពលកម្មគ្រប់ប្រភេទជូនពិការចំនួន ៥៤.៥៤១នាក់ ក្នុងនោះ សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ២៤.៧៧៧នាក់ និងស្តារវេជ្ជសាស្ត្រ ៨២.៥៧០នាក់ | ជនពិការ អតីតយុទ្ធជន និងជនចូលនិវត្តន៍អាចមានលទ្ធភាពខ្ចីប្រាក់ក្នុងអត្រាការប្រាក់ទាប និងមិនមានការប្រាក់សម្រាប់ប្រកបអាជីវកម្មផ្ទាល់ខ្លួន, (៥) ស្នើឱ្យមានកិច្ចសហការគ្នាយ៉ាងជិតស្និតរវាងក្រុមការងារ MoSVY/IDP និងគណៈកម្មាធិការបរិយាប័ន្នរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជំរុញការចូលរួមក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឱ្យកាន់តែមានប្រសិទ្ធភាព, និង (៦) ស្នើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្ទេរទាំងមុខងារ ការទទួលខុសត្រូវ និងប្រភពធនធានដល់ក្រុមការងារ IDP នៃក្រសួងស្ថាប័ននីមួយៗដើម្បីក្រុមការងារមានលទ្ធភាពអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍ជូនជនពិការ រួមមាន÷<br>- ការផ្គូសផ្គុលឧបករណ៍សិប្បនិម្មិត និងរណបជូនជនពិការ ៦.៦៧៤នាក់<br>- ការផ្តល់រទេះរុញនិងរទេះកង់បី១០៣គ្រឿង ឈើច្រត់ ១៧៥រាយ និងស្បែកជើងខ្ពស់ទាប ១០៥គូ<br>- បានបញ្ជូនកុមារពិការទៅសាលារៀន ១៦៣នាក់<br>- និង ការចុះសួរសុខទុក្ខអ្នក ជំងឺនៅតាមសហគមន៍ ១.៧៣២នាក់។<br>▪ មូលនិធិជនពិការតាមរយៈមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងអង្គការដៃគូបានផ្តល់សេវាស្តារលទ្ធភាពពលកម្មគ្រប់ប្រភេទជូនពិការចំនួន ៨១.៩៧៦នាក់ ក្នុងនោះ សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ២៥.៨៦៤នាក់ និងស្តារវេជ្ជសាស្ត្រ ៥៦.១១២នាក់<br>▪ បានផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍ជូនជនពិការ រួមមាន÷<br>- ការផ្គូសផ្គុលឧបករណ៍សិប្បនិម្មិត និងរណបជូនជនពិការ ៨.៥៨៩នាក់<br>- ការផ្តល់រទេះរុញនិងរទេះកង់ បី១២១គ្រឿង ឈើច្រត់ ១៦៥រាយ និងស្បែកជើងខ្ពស់ទាប ១៤៨គូ<br>- បានផ្តល់កង់ដល់ជនពិការ ២៤ គ្រឿង<br>- បានបញ្ជូនកុមារពិការទៅ សាលារៀន ២៧១នាក់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - ការពិនិត្យ និងព្យាបាលជូនជនពិការ១.០២២នាក់<br>- និងការចុះសួរសុខទុក្ខអ្នកជំងឺនៅតាមសហគមន៍ ៩៣៨នាក់។ | |
| - ពិនិត្យលទ្ធភាពផ្ដល់ការគាំទ្រដល់សហគ្រាសខ្នាតតូច និងមធ្យមសម្រាប់ការបណ្ដុះបណ្ដាល និងការវិនិយោគលើគ្រឿងម៉ាស៊ីន ឬបរិក្ខារផលិតកម្ម ព្រមទាំងការលើកទឹកចិត្តផ្សេងទៀត ដោយផ្សារភ្ជាប់លក្ខខណ្ឌនៃការផលិតវត្ថុធាតុដើមក្នុងស្រុក ការលើកកម្ពស់គុណភាពផលិតផល និងទំនើបកម្មនៃខ្សែច្រវាក់ផលិតកម្ម សំដៅផ្សារភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs) | មធ្យម ទៅ វែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានបន្តចូលរួមអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងគោលដៅរក្សាបាននូវបរិស្ថានធុរកិច្ចសមធម៌មួយ ទន្ទឹមនឹងការកាត់បន្ថយតាមលទ្ធភាពនូវរបាំងពន្ធ និងរបាំងមិនមែនពន្ធផ្សេងៗដែលជាបន្ទុករបស់ធុរជនជាពិសេសបន្ទុកពេលវេលា និងការចំណាយក្រៅផ្លូវការ<br>▪ បានចូលរួមកិច្ចប្រជុំក្រុមការងារទី៣ ផ្នែកកម្មន្តសាល សហគ្រាសធុនតូចនិងមធ្យម និងសេវា ដើម្បីពិនិត្យដោះស្រាយនូវសំណូមពរពីវិស័យឯកជន<br>▪ បានដាក់ចេញនូវយន្តការលើកទឹកចិត្តពន្ធដារដល់សហគ្រាសធុនតូចនិងមធ្យមដែលចុះបញ្ជីដោយស្ម័គ្រចិត្ត តាមរយៈ÷(១) អនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ និង (២) ប្រកាស ៥០២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧<br>▪ បានរៀបចំកែសម្រួលអត្រាពន្ធ និងអាករលើមុខទំនិញមួយចំនួនជាពិសេសចំពោះមុខទំនិញបម្រើវិស័យកសិកម្ម និងគាំទ្រសហគ្រាសធុនតូចនិងមធ្យម ដើម្បីឱ្យកាន់តែសមស្របតាមគោលនយោបាយជំរុញលើកទឹកចិត្តឱ្យមានការលូតលាស់វិស័យទាំងនេះ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានបង្កើតក្រុមការងារគយ-សហគ្រាសធុនតូចនិងមធ្យម នៃយន្តការ CPPM ដើម្បីដោះស្រាយបញ្ហា ឬសំណូមពរនានារបស់សហគ្រាសធុនតូចនិងមធ្យម។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ បានចូលរួមសហការ និងផ្តល់ការសម្របសម្រួលលើការសិក្សាអង្កេតរបស់អង្គការសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ស្តីពីការតភ្ជាប់រវាងក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស និងសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក ដើម្បីជាធាតុចូលក្នុងការពិនិត្យមើលការជំរុញការតភ្ជាប់រវាងសហគ្រាសធុនតូចនិងមធ្យម និងសាជីវកម្មធំៗ ដើម្បីជានាំឱ្យបាននូវកាលានុវត្តភាពក្នុងការឈានឡើងទៅក្នុងខ្សែច្រវាក់ផលិតកម្មក្នុងតំបន់ និងសកល។<br>- រដ្ឋបាលខេត្តស្វាយរៀង | |
| - លើកស្ទួយសមត្ថភាពវិទ្យាស្ថានឧត្តមសិក្សា ដើម្បីជាមូលដ្ឋានរឹងមាំមួយសម្រាប់ក្រេបជញ្ជក់យកវិទ្យាសាស្ត្រ បង្កើនការហ្វឹកហ្វឺន និងនវានុវត្តន៍បច្ចេកវិទ្យាថ្មីៗ សម្រាប់តម្រូវការទីផ្សារ | មធ្យម<br>ទៅវែង | - ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ មាននិស្សិតចាប់ពីថ្នាក់បរិញ្ញាបត្ររង ដល់ថ្នាក់បណ្ឌិត ចំនួន ២០៧.៤២៣នាក់ និស្សិតស្រីចំនួន ៩៤.២៤២នាក់ ស្មើនឹង ៤៥,៤៣% នៅក្នុងឆ្នាំ២០១៦-២០១៧ និងមាននិស្សិតចាប់ពីថ្នាក់បរិញ្ញាបត្ររង ដល់ថ្នាក់បណ្ឌិតចំនួន ២១១.៤៨៤នាក់ និស្សិតស្រីចំនួន ៩៨.៦៣០នាក់ ស្មើនឹង៤៦,៦៣% ក្នុងឆ្នាំ២០១៧-២០១៨<br>▪ បានបង្កើតគណៈកម្មាធិការវិទ្យាសាស្ត្រកម្ពុជា សម្រាប់ការស្រាវជ្រាវ និងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងបង្កើតសាលាបណ្ឌិត<br>▪ បានរៀបចំវិបស្សនាក្រុមប្រឹក្សាសាកលវិទ្យាធិការដោយផ្តោតលើការរៀបចំឡើងវិញឋានៈសាស្ត្រាចារ្យ ការកសាង និងការលើកកម្ពស់គុណភាពអប់រំនិងស្វ័យភាពឧត្តមសិក្សា | - ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ គុណភាពនិស្សិតបញ្ចប់ការសិក្សានៅមានគម្លាតជំនាញ ពុំទាន់ឆ្លើយតបពេញលេញទៅនឹងតម្រូវការនៃទីផ្សារការងារ និងសង្គម<br>▪ ការរៀបចំប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង និងការអនុវត្តយន្តការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងនៅតាមគ្រឹះស្ថានឧត្តមសិក្សាមួយចំនួននៅមិនទាន់ដំណើរការល្អ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ក្នុងឆ្នាំសិក្សា ២០១៦-២០១៧ មាននិស្សិតថ្នាក់បរិញ្ញាបត្ររងចំនួន ២០.៥៧០នាក់ និស្សិតស្រី ៥១,០៦% និងនិស្សិតថ្នាក់បរិញ្ញាបត្រ ចំនួន ១៦៥.៣៥៩ និស្សិតស្រី ៤៧,៨៧%។ និស្សិតដែលសិក្សាមុខជំនាញទាក់ទងនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា (STEAM) មានចំនួនសរុប ៤៤.៣៦៦នាក់ និស្សិតស្រី ២៩,៨%។ និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ មានចំនួន ២១.៤៩៤ (ស្រី ២១,២៤%) ដែលក្នុងនោះមាន និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន ២០.២៧២នាក់ (ស្រី ២២,២%) និងនិស្សិតថ្នាក់បណ្ឌិត ចំនួន ១.២២២នាក់ (ស្រី ៥,១៦%)។<br>▪ ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ មាននិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររង ១៩.៨៧១នាក់ ស្រី ៩.៨០៧នាក់ ស្មើ ៤៩,៣៥% និងនិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រមាន ១៦៨.២៤២នាក់ និស្សិតស្រី ៤៩,៦៨%។ បើធៀបនឹងឆ្នាំសិក្សា២០១៦-២០១៧ និស្សិតថ្នាក់បរិញ្ញាបត្រកើន ២.៨៨៣នាក់ ស្មើ ១,៧% និស្សិតស្រីកើន ៤.៤១៣នាក់។<br>▪ បានទទួលថវិកាវិភាជន៍ពីរាជរដ្ឋាភិបាលសម្រាប់ការបង្រៀនមុខជំនាញពាក់ព័ន្ធនៅតាមវិទ្យាស្ថាន និងគ្រឹះស្ថានឧត្តមសិក្សានានា<br>▪ បានបន្តកែលម្អនីតិវិធី និងដំណើរការទទួលស្គាល់គុណភាពអប់រំនៅគ្រឹះស្ថានឧត្តមសិក្សា និងកំពុងធ្វើការវាយតម្លៃលើគ្រឹះស្ថានឧត្តមសិក្សាមួយចំនួន។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍÷ | ▪ ការវិនិយោគលើកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រលើមុខជំនាញអាទិភាព វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម នៅមានកម្រិត។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានលើកស្ទួយសមត្ថភាពវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់ការបណ្តុះបណ្តាលធនធានមនុស្ស ការស្រាវជ្រាវ និងអភិវឌ្ឍន៍ នវានុវត្តន៍ និងសហគ្រិនភាព<br>▪ កំពុងរៀបចំបង្កើតកម្មវិធីវាស់ស្ទង់សមត្ថភាពផ្នែកទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានថ្នាក់ជាតិ<br>▪ បានពង្រឹង និងលើកស្ទួយសមត្ថភាពវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានតាមរយៈការបញ្ជូនមន្ត្រីទៅសិក្សាថ្នាក់បណ្ឌិតចំនួន ៤នាក់ និងអនុបណ្ឌិតចំនួន ៥នាក់ និងបានរៀបចំវគ្គបណ្តុះបណ្តាលផ្សេងៗទៀត<br>▪ ផ្តល់អាហារូបករណ៍ខាងផ្នែកបច្ចេកវិទ្យាសរុបចំនួន៧៩នាក់ក្នុងឆ្នាំ ២០១៧ និង ២០១៨ សម្រាប់មុខជំនាញបច្ចេកវិទ្យា។ | |
| - បង្កើតពានរង្វាន់សម្រាប់ការប្រកួតប្រជែងបច្ចេកទេសនៅលើគ្រប់មុខសញ្ញាអាទិភាព | ២០១៥ ទៅ មធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍÷<br>▪ បានបង្កើតព្រឹត្តិការណ៍ដើម្បីជំរុញ និងលើកទឹកចិត្តការអភិវឌ្ឍ និងការប្រើប្រាស់សេវាប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងបន្តរៀបចំការប្រកួតប្រជែងពានរង្វាន់ថ្នាក់ជាតិបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (Cambodia ICT Award)<br>▪ បានជំរុញនិងលើកទឹកចិត្តដល់និស្សិត អ្នកស្រាវជ្រាវ សហគ្រាសធុនតូចនិងមធ្យម ឱ្យចូលរួមការប្រកួតប្រជែងពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានថ្នាក់ជាតិ ថ្នាក់តំបន់ និងពិភពលោក | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានរៀបចំពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០១៧ ដោយមានក្រុមហ៊ុនចូលរួមចំនួន ១១២ ហើយកម្ពុជាទទួលបានមេដាយមាសបី<br>▪ បានរៀបចំបង្កើតពានរង្វាន់អាជីវកម្មបង្កើតថ្មីថ្នាក់តំបន់ (ASEAN Rice Bowl Start Up Awards)<br>▪ បន្តផ្ដួចផ្ដើមផ្សព្វផ្សាយ និងរៀបចំការប្រកួតប្រជែងពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានថ្នាក់ជាតិ ឆ្នាំ២០១៨<br>▪ បន្តចូលរួមរៀបចំការប្រកួតប្រជែងពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានថ្នាក់តំបន់ (ASEAN ICT Awards) ឆ្នាំ២០១៨។ | |
| - ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង គស្ដិមតិ និងការពារសិទ្ធិប្រយោជន៍ ក៏ដូចជា ពង្រឹងទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល ក្នុងការទទួលការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ | ២០១៥ ទៅ មធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | |
| - ពង្រឹងសមត្ថភាព និងសហគ្រិនភាពនៃសហគ្រាសក្នុងស្រុក ដើម្បីអាចផ្សារភ្ជាប់ និងទាញយកផលប្រយោជន៍ពីសក្ដានុពលសហគ្រាស និងវិនិយោគបរទេសធំៗ ស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស។ | មធ្យម ទៅ វែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ បានចូលរួមសហការ និងផ្ដល់ការសម្របសម្រួលលើការសិក្សាអង្កេតរបស់អង្គការសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ស្ដីពីការតភ្ជាប់រវាងក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស និងសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក ដើម្បីកំណត់អំពីភាពខ្លាំង ភាពខ្សោយ បញ្ហាប្រឈម និងកាលានុវត្តភាព ក្នុងការតភ្ជាប់ | |

| វិធានការគោលនយោបាយ/ផែនការ សកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ផលិតកម្ម ជាមួយសហគ្រាស និងវិនិយោគបរទេសធំៗ ជាពិសេសបណ្តាគម្រោងវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ | |
| *ខ-ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យ* | | | |
| - ធ្វើវិសោធនកម្មកែលម្អច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដោយរៀបចំស្តង់ដារគណនេយ្យសាមញ្ញសម្រាប់សហគ្រាសធុនតូច និងមធ្យម | | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគណនេយ្យ÷<br>▪ បានដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ<br>▪ សេចក្តីព្រាងអនុក្រឹត្យចំនួន២ ត្រូវបានបង្កើតនិងកំពុងដំណើរការ÷ (១) អនុក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ត្រូវបានបញ្ជូនទៅ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដើម្បីចុះហត្ថលេខា និង (២) អនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ ដែលត្រូវជំនួសអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីគណនេយ្យនិងសវនកម្មវិញ ដោយសារលក្ខខណ្ឌគតិយុត្តតម្រូវ ហើយអនុក្រឹត្យនេះត្រូវបានដាក់ឆ្លងកិច្ចប្រជុំក្រុមប្រឹក្សាជាតិគណនេយ្យ ១លើក និងបានដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈចំនួន ១លើក<br>▪ កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីលក្ខខណ្ឌ នីតិវិធី និងបែបបទនៃការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងសេចក្តីព្រាងប្រកាសស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្ម ព្រមទាំងសេចក្តីព្រាងប្រកាសមួយចំនួនទៀត តាមខ្លឹមសារនៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម<br>▪ បានសិក្សាស្រាវជ្រាវដោយសហការជាមួយគណៈកម្មការមូលបត្រកម្ពុជាដើម្បីពិនិត្យលើលទ្ធភាពនៃការរៀបចំស្តង់ដាររបាយការណ៍ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷<br>បញ្ហាប្រឈម÷<br>▪ បេសកកម្ម និងមុខងារភារកិច្ចមានការកើនឡើងយ៉ាងគំហុក ដែលធ្វើឱ្យការអនុវត្តសកម្មភាពនៅក្នុងផែនការនេះយឺតយ៉ាវ។<br>សំណូមពរ÷<br>▪ បន្តគាំទ្រដល់ការអនុវត្តសកម្មភាព<br>▪ គួរមានកញ្ចប់ថវិកាបន្ថែម ដើម្បីជំរុញការងាររៀបចំស្តង់ដាពិសេសសម្រាប់ផ្តល់អ្នកជំនាញការ<br>▪ ការយល់ដឹងអំពីការរៀបចំបញ្ជីគណនេយ្យនៅមានកម្រិតដែលទាមទារការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបន្ថែម។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ហិរញ្ញវត្ថុសាមញ្ញសម្រាប់សហគ្រាសធុនតូច និងមធ្យមដើម្បីសម្រួលដល់សហគ្រាសធុនតូច និងមធ្យមអាចមានលទ្ធភាពទទួលបានឥណទានតាមរយៈធនាគារ និងតាមរយៈទីផ្សារមូលបត្រ<br>▪ សហគ្រាសខ្នាតតូចត្រូវបានអនុញ្ញាតឱ្យកាន់កាប់បញ្ជិកាគណនេយ្យសាមញ្ញ។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | |
| - ពង្រឹងយន្តការក្រោមដំបូលតែមួយសម្រាប់ការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម ដោយប្រើប្រាស់ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យសម្រាប់ជាមូលដ្ឋានវាយតម្លៃ និងជាលក្ខខណ្ឌសម្រាប់ការផ្តល់ការលើកទឹកចិត្តនិងការគាំទ្រពីរាជរដ្ឋាភិបាល | ២០១៥ | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>▪ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការសម្របសម្រួលការចុះបញ្ជីពាក់ព័ន្ធនឹងសហគ្រាសធុនតូច និងមធ្យម និងសេវាកម្ម នៅក្រោមក្របខ័ណ្ឌដំបូលតែមួយ ដែលបច្ចុប្បន្នបានដាក់ជូនទៅដល់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច ដើម្បីដាក់ប្រជុំឆ្លងចុងក្រោយ មុននឹងជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច<br>▪ បានធ្វើប្រតិភូកម្មមុខងារដល់ថ្នាក់ក្រោមជាតិ (ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរជំនាញ) សំដៅធ្វើឱ្យការផ្តល់សេវាដែលពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានពង្រាយ និងបង្កិតជិតទៅដល់អ្នកដែលត្រូវការសេវា។ ការចុះបញ្ជីរោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ដែលកំពុងអនុវត្តនៅថ្នាក់កណ្តាល នឹងត្រូវបានផ្ទេរសមត្ថកិច្ចឱ្យទៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត។<br>- ក្រសួងពាណិជ្ជកម្ម÷ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ ស្នើសុំសម្រួលកិច្ចសហការបន្ថែមជាមួយស្ថាប័នពាក់ព័ន្ធ<br>▪ ការចុះបញ្ជី SME គួរតែជាសមត្ថកិច្ចរបស់ក្រសួងមានសមត្ថកិច្ច ហើយក្រសួងមានសមត្ថកិច្ច គួរធ្វើបញ្ជីមកស្ថាប័នពាក់ព័ន្ធ<br>▪ ស្នើសុំសម្រួលកិច្ចសហការបន្ថែមជាមួយក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងឧត្តមភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ▪ បានចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីកាត់បន្ថយពេលវេលា និងលុបបំបាត់ចំណាយក្រៅផ្លូវការ ជាមួយការទូទាត់ជាមួយធនាគារកាណាឌីយ៉ា ធនាគារអេស៊ីលីដា និងក្រុមហ៊ុន Visa<br>▪ បានបន្តផ្សព្វផ្សាយតាមស្ថាប័នរាជធានី-ខេត្ត ពីនីតិវិធីស្នើសុំការបញ្ជាក់ប្រភពដើមទំនិញ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ លើកទឹកចិត្តដល់សហគ្រាស ដែលកាន់កាប់បញ្ជិកាគណនេយ្យត្រឹមត្រូវដោយលើកលែងពន្ធអប្បបរមា<br>▪ ត្រៀមសហការអនុវត្តនូវយន្តការក្រោមដំបូលតែមួយសម្រាប់ការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ បានចូលរួមផ្តល់កិច្ចសហការក្នុងការពង្រឹងយន្តការចុះបញ្ជីសហ-គ្រាសធុនតូច និងមធ្យម<br>▪ បានបញ្ចប់សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។<br>*ក្នុងឆ្នាំ២០១៨÷*<br>▪ បានរៀបចំ និងទទួលបានការសម្រេចដាក់ឱ្យប្រើប្រាស់អនុក្រឹត្យស្តីពីការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន<br>▪ កំពុងរៀបចំយន្តការជួយសម្រួលដល់ការចុះបញ្ជីក្រុមហ៊ុនបច្ចេកវិទ្យាដែលទើបបង្កើតថ្មី | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានផ្តល់អញ្ញាបណ្ណបញ្ជើឆាប់រហ័សអន្តរជាតិ ៣៨ ក្រុមហ៊ុន។<br>- រដ្ឋបាលខេត្តព្រះសីហនុ បានរៀបចំការិយាល័យច្រកចេញចូលតែមួយនៅស្រុកព្រៃនប់ និងបានរៀបចំការិយាល័យច្រកចេញចូលតែមួយថ្នាក់ខេត្ត ដែលនឹងដាក់ឱ្យដំណើរការនៅឆ្នាំ២០១៨។<br>- រដ្ឋបាលខេត្តស្វាយរៀង៖<br>▪ បានធ្វើបច្ចុប្បន្នភាពស្ថិតិសហគ្រាសធុនតូចនិងមធ្យមបានប្រមាណ ២៥%<br>▪ ចុះបញ្ជីរោងចក្របានចំនួន ៧៥ ស្មើនឹង ៩៤,៩៣ % និងសហគ្រាសធុនតូចនិងមធ្យម ដែលមានហានិភ័យបានចំនួន ៧៨មូលដ្ឋាន ស្មើនឹង ៨៦,៦៦%។ | |
| - លើកទឹកចិត្តដល់សហគ្រាសធុនធំ សហគ្រាសធុនតូចនិងមធ្យម ឱ្យកាន់បញ្ជីគណនេយ្យ និងធ្វើការបង់ពន្ធតាមរបបពិត | ២០១៩ ទៅ មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគណនេយ្យ៖<br>▪ បានធ្វើសិក្ខាសាលាផ្សព្វផ្សាយពីអត្ថប្រយោជន៍នៃការកាន់បញ្ជីគណនេយ្យបានត្រឹមត្រូវ៖ ទទួលបានអនុលោមភាពមាស មិន ជាប់ពន្ធអប្បបរមាទទួលបានការបង្វិលសងអាករលើតម្លៃបន្ថែម មុនការធ្វើសវនកម្ម ជៀងផ្ទាត់សវនកម្មពេញលេញ ២ឆ្នាំម្តងជាដើម<br>▪ បានស្វែងរកយន្តការក្នុងការផ្តល់ការលើកទឹកចិត្តជូនសហគ្រាសក្រុមហ៊ុន ក្នុងការកាន់បញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តាមរយៈគោលនយោបាយសារពើពន្ធ<br>▪ បានសិក្សាអំពីការលំបាករបស់សហគ្រាសធុនធំ និងសហគ្រាសធុនតូច និងមធ្យម ក្នុងការអនុវត្តស្តង់ដារគណនេយ្យ និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ កំពុងសិក្សាអំពីស្តង់ដារគណនេយ្យសម្រាប់សហគ្រាសធុនមធ្យម និងធុនតូច ដើម្បីសហគ្រាសធុនតូច និងធុនមធ្យមអាចចូលរួមនៅក្នុងទីផ្សារមូលបត្របាន។ | |
| - ពង្រឹងអភិបាលកិច្ចសាជីវកម្មសម្រាប់ពង្រឹងនិងពង្រីកវិស័យឯកជន ដើម្បីលើកស្ទួយវប្បធម៌នៃគណនេយ្យភាពសង្គម និងលទ្ធភាពទទួលបានហិរញ្ញប្បទានក្នុងទីផ្សារហិរញ្ញវត្ថុ តាមរយៈផ្តល់ការបណ្តុះបណ្តាលលើការគ្រប់គ្រងទូទៅ ការគ្រប់គ្រងប្រព័ន្ធផលិតកម្ម និងការគ្រប់គ្រងបច្ចេក-វិទ្យាសម្រាប់សហគ្រាសធុនតូច និងមធ្យម | ២០១៥ ទៅ មធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងពាណិជ្ជកម្ម÷<br>▪ បានបើកវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវពាណិជ្ជកម្ម ដើម្បីពង្រឹងសមត្ថភាពវិស័យឯកជនឱ្យបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញក្នុងការធ្វើអាជីវកម្មប្រកបដោយប្រសិទ្ធភាព<br>▪ បានសិក្សាអំពីខ្សែច្រវាក់តម្លៃលើផលិតផលសក្តានុពល និងផលិតផលប្រើប្រាស់ជាប្រចាំថ្ងៃ<br>▪ បានបន្តរៀបចំសិក្ខាសាលាអប់រំផ្សព្វផ្សាយពីនីតិវិធីនាំចេញ និងការពង្រឹងសមត្ថភាព និងការវេចខ្ចប់<br>▪ បានបន្តចុះធ្វើការអប់រំ និងណែនាំពីរបៀបស្វែងរកទីផ្សារដល់ផលិតករដាំដុះ និងចិញ្ចឹមសត្វខ្នាតតូច តាមបណ្តាខេត្តគោលដៅ<br>▪ បានសហការជាមួយម្ចាស់ជំនួយ និងអនុវត្តគម្រោងកសិកម្មខ្នាតតូច ដើម្បីផ្តល់លទ្ធភាពទទួលបានព័ត៌មានទីផ្សារ និងផ្តល់ហិរញ្ញ-ប្បទានខ្នាតតូចជូនដល់កសិករតាមតំបន់គោលដៅ។ | - ក្រសួងពាណិជ្ជកម្ម÷<br>▪ កង្វះធនធានមនុស្ស<br>▪ ធនធានហិរញ្ញវត្ថុសម្រាប់ចងក្រងឯកសារផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់ភាគីពាក់ព័ន្ធ។ |
| - ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីភាពងាយស្រួល និងអត្ថប្រយោជន៍នៃការចុះបញ្ជី | ២០១៥ | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- រដ្ឋបាលខេត្តកណ្តាល÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ តាមរយៈការចុះអនុវត្តការងារគ្រប់ជំនាញ រដ្ឋបាលខេត្តបានធ្វើការផ្សព្វផ្សាយជូនម្ចាស់រោងចក្រសហគ្រាសនិងសិប្បកម្មអាជីវកម្ម ពី | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ភាពងាយស្រួលក្នុងការចុះបញ្ជី នៅការិយាល័យច្រកចេញចូលតែមួយក្រុង/ស្រុក និងពន្យល់ពីអត្ថប្រយោជន៍ដែលទទួលបានពីការចុះបញ្ជីដូចជា÷ ការទទួលបានការអនុគ្រោះពន្ធ លទ្ធភាពសម្រាប់កម្ចីទុន ក៏ដូចជាការពារផ្នែកសន្តិសុខ ជាដើម។<br>ក្នុងឆ្នាំ២០១៨÷<br>▪ បានធ្វើការផ្សព្វផ្សាយជូនដល់ម្ចាស់សហគ្រាស និងសិប្បកម្មពីភាពងាយស្រួលក្នុងការចុះបញ្ជីនៅការិយាល័យច្រកចេញ-ចូលតែមួយថ្នាក់ក្រុង-ស្រុក<br>▪ បានផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ ដែលទទួលបានពីការចុះបញ្ជីដូចជា÷ ការទទួលបានការអនុគ្រោះពន្ធលទ្ធភាពសម្រាប់កម្ចីទុន ក៏ដូចជាការគាំពារផ្នែកសន្តិសុខ ជាដើម។ | |
| - ផ្តល់ការបណ្តុះបណ្តាលលើការកាន់បញ្ជីគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម | ២០១៥ ទៅ មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគណនេយ្យ÷<br>▪ បានផ្សព្វផ្សាយសិក្ខាសាលាបណ្តុះបណ្តាលស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធតូចនិងមធ្យម រួមទាំងការកាន់បញ្ជីគណនេយ្យ<br>▪ បានបន្តរៀបចំសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីពន្ធដារអំពីគំរូបញ្ជីគណនេយ្យសាមញ្ញ<br>▪ បានបន្តរៀបចំសិក្ខាសាលាបណ្តុះបណ្តាលអ្នកជាប់ពន្ធតូចអំពីគំរូបញ្ជីគណនេយ្យសាមញ្ញ និងកាតព្វកិច្ចសារពើពន្ធនានា<br>▪ បានបន្តលើកទឹកចិត្តដល់អ្នកជាប់ពន្ធគ្រប់ប្រភេទ ដែលបានកាន់កាប់បញ្ជីគណនេយ្យបានត្រឹមត្រូវឱ្យរួចផុតពីការបង់ពន្ធអប្បបរមា<br>▪ បានបន្តរៀបចំការបណ្តុះបណ្តាលមន្ត្រីពន្ធដារអំពីឯកសារគំរូកត់ត្រាចំណូលចំណាយងាយៗ និងរបាយការណ៍ហិរញ្ញវត្ថុគំរូងាយៗ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគណនេយ្យ÷<br>បញ្ហាប្រឈម÷<br>▪ ការយល់ដឹងរបស់មន្ត្រី និងអ្នកជាប់ពន្ធនៅមានកម្រិត ដែលទាមទារការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបន្ថែម<br>▪ កត្តា[illegible]ធនធានមនុស្ស<br>▪ កត្តាកិច្ចសហការអន្តរស្ថាប័ននៅមានកម្រិត |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | សម្រាប់មីក្រូសហគ្រាស (Simplified Financial Reporting for Micro-Enterprises) ដើម្បីបណ្តុះបណ្តាលបន្តជូនសហគ្រាសជាប់កាតព្វកិច្ច។ | ▪ ខ្វះបញ្ហាធនធានថវិកាគាំទ្រដល់ការបណ្តុះបណ្តាល ដោយសារភាពស្មុគស្មាញនៃស្តង់ដានាំឱ្យគ្រូបង្គោលទាមទារកម្រៃខ្ពស់។<br>សំណូមពរ÷<br>▪ ស្នើសុំការគាំទ្រផ្នែកហិរញ្ញវត្ថុបន្ថែមសម្រាប់ការបណ្តុះបណ្តាល ដោយប្រើថវិការបស់សហគមន៍ផ្តល់ជំនួយដែលមានស្រាប់ (ADB)។ ប៉ុន្តែជាក់ស្តែង គម្រោងថវិកាក្រោមហិរញ្ញប្បទានពី ADB ត្រូវបានកាត់បន្ថយសម្រាប់ឆ្នាំ២០១៨ និង២០១៩។ |
| *គ-ការជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម* | | | |
| - ពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផល ដូចជាតំបន់កែច្នៃ និងផលិតសង្ការិម តំបន់កែច្នៃផលិតសម្ភារៈពីកៅស៊ូ តំបន់កែច្នៃផលិតម្ហូបអាហារពីសមុទ្រ តំបន់កែច្នៃចំណីអាហារសម្រាប់គោលដៅប្រើប្រាស់ក្នុងស្រុកផង និងនាំចេញផង ជាពិសេសដោយប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន | ២០១៥ ទៅ មធ្យម | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ÷<br>▪ បានសិក្សា វិភាគ និងវាយតម្លៃតំបន់សក្តានុពលនៃផលិតកម្មកៅស៊ូធម្មជាតិនៅកម្ពុជា (តំបន់១÷ កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ព្រៃវែង និងស្វាយរៀង, តំបន់២÷ កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ សៀមរាប និង បន្ទាយមានជ័យ និងតំបន់៣÷ បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ កោះកុង ព្រះសីហនុ កំពត និងកំពង់ស្ពឺ)។ ដើម្បីឆ្លើយតបទៅនឹងសកម្មភាពនេះ អគ្គនាយកដ្ឋានកៅស៊ូបានបន្តរៀបចំចង្កោមសកម្មភាពសម្រាប់ធ្វើការសិក្សាទៅតាមតំបន់នានាដែលបានកំណត់។ | - រដ្ឋបាលខេត្តបន្ទាយមានជ័យ÷<br>បញ្ហាប្រឈម÷<br>▪ តម្លៃផលិតផលកសិកម្ម (សត្វ, ស្រូវ, បន្លែ) មិនមានស្ថិរភាពលើទីផ្សារ<br>▪ ដំណាំស្រូវដើមរដូវនៅស្រុកមួយចំនួនខ្វះទឹកដោយជួបបញ្ហារាំងស្ងួត ត្រូវបូមទឹកជួយសង្គ្រោះ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ សម្របសម្រួលនិងគាំទ្រក្នុងការបង្កើត និងដំណើរការតំបន់ប្រមូលផ្ដុំកន្លែងចិញ្ចឹមសត្វ កសិដ្ឋានចិញ្ចឹមសត្វ កន្លែងផលិតចំណីសត្វ បសុឱសថ កន្លែងកែច្នៃវេចខ្ចប់សាច់និង ផលិតផលសត្វដែលមានលក្ខណៈទំនើបសម្រាប់លើកកម្ពស់លក្ខខណ្ឌអនាម័យគុណភាពនិងសុវត្ថិភាពធានាដល់សុខភាពសាធារណៈ÷<br>- បានគាំទ្រលើការបង្កើតកសិដ្ឋានចិញ្ចឹមសត្វសរុបចំនួន ២.៦០០កន្លែង (មាន់ ៦៨១កន្លែង, ទា ១១.៧០ កន្លែង, ក្រួច ២កន្លែង, ពពែ ៥កន្លែង, ជ្រូក៦៥៣កន្លែង, គោក្របី ៨៣ កន្លែង និងសេះ ២កន្លែង)<br>- សម្របសម្រួលក្នុងការបង្កើតរោងចក្រផលិតចំណីសត្វចំនួន ១៣កន្លែង<br>- បានគាំទ្របច្ចេកទេសលើការរៀបចំបង្កើតសត្តឃាតដ្ឋាន ចំនួន ១៦៨កន្លែង<br>- គាំទ្របច្ចេកទេសដល់ក្រុមហ៊ុនលក់បសុឱសថនិងចំណីសត្វ មានចំនួន ១៤ក្រុមហ៊ុន។<br>▪ ចងក្រងនិងពង្រឹងសមត្ថភាពសហគមន៍អភិវឌ្ឍន៍ការចិញ្ចឹមសត្វ ចំណីសត្វ និងកែច្នៃផលិតផលសាច់÷<br>- បានចងក្រងសហគមន៍ចិញ្ចឹមសត្វបានចំនួន ១៥ (សហគមន៍ចិញ្ចឹមជ្រូក សហគមន៍ចិញ្ចឹមគោ សហគមន៍ចិញ្ចឹមទា និង សហគមន៍ភ្នាក់ងារសុខភាពសត្វភូមិ)<br>- ចងក្រងក្រុមផលិតមាន់ និងទីផ្សារចំនួន ៧០៧ក្រុម<br>- ចងក្រងក្រុមកម្មវិធីបង្វិលពូជ និងក្រុមសន្សំចំនួន ៤០ក្រុម | ▪ បទល្មើសលួចដឹកជញ្ជូនសត្វឆ្លងកាត់ និងការលួចនាំចូលជី ថ្នាំកសិកម្ម ចូលខុសច្បាប់ពីព្រំដែន នៅតែមាន<br>▪ បទល្មើសលួចដឹកជញ្ជូនផលអនុផលព្រៃឈើ ផល នេសាទ ការលួចនេសាទខុសច្បាប់ការលួចរានដីព្រៃលិចទឹកនៅតែមាន។<br>សំណើដំណោះស្រាយ÷<br>▪ មន្ត្រីជំនាញចុះផ្សព្វផ្សាយណែនាំ ឱ្យកសិករ ចិញ្ចឹម ដាំដុះតាមតម្រូវការទីផ្សារ<br>▪ មន្ត្រីជំនាញចុះពិនិត្យតាមដានជួយ អន្តរាគមន៍<br>▪ មន្ត្រីជំនាញចុះសហការធ្វើការទប់ស្កាត់។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - បានបើកវគ្គបណ្តុះបណ្តាលចំនួន៣៦វគ្គ ដើម្បីពង្រឹងសមត្ថភាពសហគមន៍លើការដឹកនាំ និងគ្រប់គ្រងក្រុមបច្ចេកទេសចិញ្ចឹមសត្វ ជ្រើសរើសពូជ ការពារជំងឺសត្វ និងដំណាំចំណីសត្វ។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម៖<br>ក្នុងឆ្នាំ២០១៧៖<br>▪ បានបង្កើតក្រុមការងារចុះពិនិត្យសិក្សា និងកំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់នូវតំបន់ការពារដីស្រែអំបិល និងរៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍន៍ស្រែអំបិល<br>▪ បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងស្រែអំបិល និងផលិតកម្មអំបិល ដាក់ជូនថ្នាក់ដឹកនាំចុះហត្ថលេខា និងប្រើប្រាស់ជាផ្លូវការ<br>▪ បាននិងកំពុងរៀបចំកម្រងបណ្តុំសហគ្រាសធុនតូចនិងមធ្យម នៅខេត្តកណ្តាល ដើម្បីកែច្នៃផលិតផលផ្លែឈើសម្រាប់នាំចេញ និងនៅខេត្តកំពង់ឆ្នាំង ដើម្បីកែច្នៃផលផលកម្ពុជាសម្រាប់នាំចេញ<br>▪ នៅក្នុងឆ្នាំ២០១៧ ការផលិតអំបិលសរុបបានចំនួន ១៤៣.៦៧៩ តោន លើផ្ទៃដីទំហំ ៥.០៧១,៨២ហ.ត ក្នុងខេត្តកែប និងខេត្តកំពត និងមានក្រុមសាមគ្គីចំនួន ១៩៧ក្រុមសាមគ្គីដែលបានបង្កើតការងារសរុបចំនួន ៥.០០០នាក់។<br>ក្នុងឆ្នាំ២០១៨៖<br>▪ ផ្ទៃដីស្រែអំបិលសរុបមានចំនួន ៥,៣០៥.១១ហិកតា ក្នុងនោះខេត្តកំពត-ខេត្តកែប មានចំនួន៤,៨២១.៩៧ហិកតា និងមានក្រុមសាមគ្គីចំនួន ២០០ក្រុមសាមគ្គីដែលបានបង្កើតការងារសរុប | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ៥,០០០នាក់។ ក្នុងឆ្នាំ២០១៨នេះ ការផលិតអំបិលពុំបានទទួលផលល្អ ដោយកត្តាអាកាសធាតុ ដែលមិនអាចធានាការផ្គត់ផ្គង់ក្នុងស្រុកបានគ្រប់គ្រាន់ ដូចនេះដើម្បីរក្សាតុល្យភាពនៃការផ្គត់ផ្គង់តាមតម្រូវការ ក្រសួងបានគាំទ្រឱ្យមានការនាំចូលអំបិលចំនួន៣០,០០០តោន ពីប្រទេសចិន និងប្រទេសថៃ។<br>- ក្រសួងពាណិជ្ជកម្ម ÷<br>▪ បានសម្របសម្រួលក្រុមហ៊ុនមកពីប្រទេសចិន មកបង្កើតតំបន់កែច្នៃផលិតផលកសិឧស្សាហកម្ម កម្ពុជា នៅខេត្តព្រះសីហនុ និងខេត្តកោះកុង និងសម្ព័ន្ធសមាគមជលផលសមុទ្រកម្ពុជា ដែលប្រមូលសមាគមជលផលសមុទ្រចំនួន ៥ នៅខេត្តកំពត ព្រះសីហនុ និងខេត្តកោះកុង និងគ្រោងបង្កើតជាបន្តបន្ទាប់បន្ថែមទៀត<br>▪ បានកំពុងបន្តធ្វើសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលអាស៊ាន-ចិន អាស៊ាន-ជប៉ុន អាស៊ាន-កូរ៉េ និងដៃគូជំរុញពាណិជ្ជកម្មដ៏ទៃទៀតទាំងក្នុងតំបន់ និងលើពិភពលោក ដើម្បីបើកច្រកទីផ្សារលើផលិតផលដែលបានកែច្នៃរួចហើយ<br>▪ បានបន្តផ្តល់ការលើកទឹកចិត្តដល់ផលិតផលកសិកម្ម កសិឧស្សាហ-កម្មដែលបានកែច្នៃរួចហើយបានចូលរួមតាំងពិព័រណ៍ ដើម្បីស្វែងរកដៃគូពាណិជ្ជកម្ម និងធ្វើចរាចរបានទូលំទូលាយនៅលើទីផ្សារ<br>▪ បានសហការជាមួយអង្គការ UNIDO រៀបចំបង្កើតទីផ្សារដាក់លក់ផលិតផលសមុទ្រនៅខេត្តកំពត (ផ្សារទំនើប ចាន់ ស៊ីថា) ដើម្បីផ្តល់ឱកាសដល់កសិករ ផលិតករ និងសមាជិកសម្ព័ន្ធសមាគមជលផលសមុទ្រកម្ពុជា ដាក់លក់ផលិតផលក្នុងទីផ្សារនេះ។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បាននិងកំពុងសហការអនុវត្តគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប (ហិរញ្ញប្បទានបន្ថែម) ដែលមានទឹកប្រាក់ប្រមាណ ៦៦លានដុល្លារអាមេរិក<br>▪ បាន និងកំពុងសហការអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្ម ខ្នាតតូច (Accelerating Inclusive Markets for Smallholders - AIMS) ជាមួយមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍវិស័យកសិកម្ម (IFAD) ដែលមានទឹកប្រាក់ប្រមាណ ៦១ លានដុល្លារអាមេរិក។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ÷<br>ក្នុងឆ្នាំ២០១៧-២០១៨÷<br>▪ ក្នុងក្របខណ្ឌវិនិយោគ នៅក្នុងឆ្នាំ២០១៧ បានពិនិត្យ និងអនុម័តគម្រោងវិនិយោគលើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម បានចំនួន ១០ ដែលមានទុនវិនិយោគប្រមាណជា ៣៩៦លានដុល្លារអាមេរិក ស្មើនឹង ៦% នៃទុនវិនិយោគសរុបដែលចុះបញ្ជីនៅ ក.អ.ក<br>▪ ក្នុងក្របខណ្ឌវិនិយោគ នៅក្នុងឆ្នាំ២០១៨ បានពិនិត្យ និងអនុម័តគម្រោងវិនិយោគលើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម បានចំនួន ១៨ ដែលមានទុនវិនិយោគប្រមាណជា ៤៥៨លានដុល្លារអាមេរិក ស្មើនឹង ៧% នៃទុនវិនិយោគសរុបដែលចុះបញ្ជីនៅ ក.អ.ក<br>▪ បានបន្តធ្វើការផ្សព្វផ្សាយជូនអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេសអំពីបរិយាកាស និងកាលានុវត្តភាពវិនិយោគនៅកម្ពុជា ជាពិសេស | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | សក្តានុពលនៃការវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម ព្រមទាំងបានពិភាក្សាការងារជាមួយតំណាងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានាក្នុងការផ្តល់ការគាំទ្រនិងលើកកម្ពស់ការវិនិយោគក្នុងវិស័យនេះ<br>▪ បានធ្វើការស្រាវជ្រាវនិងធ្វើបច្ចុប្បន្នភាពលើប្រធានបទទាក់ទងនឹងវិស័យកសិ-ឧស្សាហកម្ម<br>▪ បាននិងកំពុងតិតគូរ និងរៀបចំការសិក្សាស្រាវជ្រាវអំពីការរៀបចំតំបន់កែច្នៃកសិផល ដោយផ្អែកតាមបទពិសោធន៍ក្នុងតំបន់។<br>- ទីស្តីការគណៈរដ្ឋមន្ត្រី បានចូលរួមប្រជុំការងារពាក់ព័ន្ធនឹង IDP លើវិស័យកសិ-ឧស្សាហកម្ម។<br>- រដ្ឋបាលខេត្តបន្ទាយមានជ័យ÷<br>ក្នុងឆ្នាំ២០១៨÷<br>▪ បានតាមដានដំណាំឧស្សាហកម្មរយៈពេលវែង និងរយៈពេលខ្លីមានសរុប ១០.២៦៤ហិកតា ក្នុងនោះមានដំណាំរយៈពេលវែង÷ មាន ០៦ហិកតា ស្វាយចន្ទី ៧៧៦ហិកតា ប្រេងខ្យល់ ១.៦០១ហិកតា ល្ហុងខ្វង ៤០៨ ហិកតា កៅស៊ូ ៩៣៥ហិកតា<br>▪ បានបណ្តុះបណ្តាលបច្ចេកទេសមុននិងក្រោយពេលប្រមូលផលការស្តុកទុក វេចខ្ចប់ និងកែច្នៃដំណាំបន្លែចំនួន ០៤លើក មានកសិករចូលរួម ១២៤នាក់ ស្រី៧១នាក់<br>▪ ស្រង់ស្ថិតិដំណាំកៅស៊ូគ្រួសារនៅតាមស្រុក រួមមានស្រុកព្រះនេត្រព្រះ ស្រុកភ្នំស្រុក ស្រុកថ្មពួក ស្រុកម៉ាឡៃ ស្រុកស្វាយចេក ស្រុកអូរជ្រៅ រួមមានដំណាំកៅស៊ូ ៩៣៥ហិកតា និងអាចប្រមូលផលទឹក | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ជ័រ បានចំនួន៣០ហិកតា នៅក្នុងស្រុកព្រះនេត្រព្រះ ដោយមានទិន្នផល២,៥០តោនក្នុងមួយហិកតា/ឆ្នាំ<br>▪ ចុះយកសំណាកស្លឹកកៅស៊ូនៅស្រុកភ្នំស្រុក ផ្ញើទៅវិទ្យាស្ថានជាតិស្រាវជ្រាវដំណាំកៅស៊ូ<br>▪ ផ្សព្វផ្សាយបច្ចេកទេសដាំដុះ ថែទាំ ដំណាំកៅស៊ូគ្រួសារ ដល់កសិករ ចំនួន០៣វគ្គ មានកសិករចូលរួម៨១នាក់ ស្រី៤៤នាក់<br>▪ បណ្តុះបណ្តាលស្តីពីសមាសភាពចង្រៃ និងជំងឺកៅស៊ូ ដល់កសិករចំនួន០៣វគ្គ កសិករចូលរួម ៧៤នាក់ ស្រី៥២នាក់។ | |
| - ផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់ទាំងនោះ | ២០១៥ ទៅ មធ្យម | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ បានបន្តកិច្ចការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពីវិនិយោគ ដោយបានគិតគូរផ្តល់ការលើកទឹកចិត្តបន្ថែមដល់ក្រុមហ៊ុនទាំងឡាយណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងដែលបានបោះទីតាំងនៅក្នុងតំបន់កែច្នៃកសិផល។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ កំពុងបន្តចូលរួមកសាងសេចក្តីព្រាងបទប្បញ្ញត្តិពាក់ព័ន្ធនានាក្នុងលក្ខខណ្ឌរក្សាឱ្យបាននូវតុល្យភាពរវាងកិច្ចសម្រួលពាណិជ្ជកម្ម និងអនុលោមភាពច្បាប់<br>▪ បានធ្វើវិសោធនកម្មច្បាប់ បទប្បញ្ញត្តិមួយចំនួន ដើម្បីលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យកសិកម្ម (ការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃជាការផ្គត់ផ្គង់មិនជាប់អាករ)។ល។<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷<br>▪ ក្រសួងសាមីមិនទាន់ស្នើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| - បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផលបច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេស ដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ | មធ្យម ទៅ វែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានពិភាក្សារៀបចំទស្សនទាន និងយន្តការគ្រប់គ្រងមូលនិធិ ព្រមទាំងការស្វែងរកហិរញ្ញប្បទាន និងការវិភាជថវិកា។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | |
| - រៀបចំនូវយន្តការសម្រួលដល់ការនាំចេញ កសិផលកែច្នៃ ដោយដោះស្រាយបញ្ហាភស្តុភារកម្ម លុបបំបាត់កម្រៃក្រៅផ្លូវការ និងកែលម្អការសម្រួលពាណិជ្ជកម្ម | ២០១៥ ទៅ មធ្យម | - ក្រសួងពាណិជ្ជកម្ម÷<br>▪ បានរៀបចំ និងបង្កើតក្រុមប្រឹក្សាភិបាលដឹកនាំវិស័យម្រេច និងដំឡូងមីកម្ពុជា ដើម្បីជាចំណុចទាក់ទាញ និងកៀរគរវិនិយោគ និងធ្វើការអភិវឌ្ឍលើវិស័យនេះ<br>▪ បានបន្តធ្វើកំណែទម្រង់លើច្រើនវិស័យដើម្បីជួយសម្រួលដល់វិស័យឯកជនដូចជា ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម, ការចុះបញ្ជីក្រុមហ៊ុនតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងការចុះបញ្ជីពាណិជ្ជសញ្ញា តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម, ធ្វើប្រតិភូកម្មការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញលើផលិតផលកសិកម្ម តាមមន្ទីរពាណិជ្ជកម្មខេត្តជាប់ព្រំដែន<br>▪ បានបន្តពង្រឹងឧស្សាហកម្មស្រូវអង្ករតាមរយៈការពង្រឹងគុណភាព សុវត្ថិភាព រចនាសម្ព័ន្ធដឹកនាំ សហព័ន្ធនាំចេញអង្ករកម្ពុជា និងការប្រកួតប្រជែងអង្ករកម្ពុជាលើទីផ្សារអន្តរជាតិ<br>▪ បានលុបបំបាត់កម្រៃគ្រប់គ្រងការនាំចេញ (EMF) សម្រាប់ផលិតផលកាត់ដេរ សម្លៀកបំពាក់ និងស្បែកជើង<br>▪ បានរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីដំឡូងមី និងសេចក្តីព្រាងគោលនយោបាយជាតិស្តីពីម្រេចកម្ពុជា ដើម្បីជំរុញ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព |ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | និងសម្រួលដល់ទីផ្សារក្នុងស្រុក និងការនាំចេញទៅកាន់ទីផ្សារក្នុងតំបន់ និងអន្តរជាតិ។<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ÷<br>▪ លើកកម្ពស់ការយល់ដឹងអំពីលិខិតបទដ្ឋានច្បាប់និងនីតិវិធីស្នើសុំការត្រួតពិនិត្យនិងផ្តល់វិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ<br>▪ បានបើកវគ្គផ្សព្វផ្សាយអំពីបែបបទនៃការផ្តល់វិញ្ញាបនបត្រសម្រាប់ការនាំចេញទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យបានចំនួន ០៦វគ្គ<br>▪ បានរៀបចំនិងលើកកម្ពស់ស្តង់ដាររូបនីយកម្មដំណាំកសិកម្មនិងការវាយតម្លៃការទទួលស្គាល់អនុលោមភាព÷<br>- បានរៀបចំស្តង់ដារពូជដំណាំស្រូវ ពោត សណ្តែកបាយ សណ្តែកសៀង ល្ពៅ ប៉េងប៉ោះ និងស្វាយ<br>- បានពង្រាងស្តង់ដារពូជដំណាំស្វាយកែវរមៀត ចេក ខ្នុរ ក្រូចឃ្វិច និងធុរេន។<br>▪ បន្តរៀបចំបង្កើតច្បាប់ស្តីពីកៅស៊ូ លិខិតបទដ្ឋានក្រោមច្បាប់ និងសម្រេចបានលទ្ធផលដូចខាងក្រោម÷<br>- ក្រុមការងារនៃអគ្គនាយកដ្ឋានកៅស៊ូបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូរួចរាល់ហើយ និងបានបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យ និងកែសម្រួលបន្ត<br>- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកៅស៊ូ បានចេញប្រកាសលេខ១៨០ ប្រក.កសក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពី | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | នីតិវិធីនៃការគ្រប់គ្រងស្លាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ ដែលជាសមិទ្ធផល ថ្មីមួយទៀតនៃការខិតខំប្រឹងប្រែង របស់អគ្គនាយកដ្ឋានកៅស៊ូក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់គ្រប់គ្រងវិស័យកៅស៊ូឱ្យមានប្រសិទ្ធភាព។<br>▪ បាននូវការរៀបចំមូលដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសមួយចំនួនរួមមាន៖ ប្រកាសស្ដីពីការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាគុណភាពផលិតផលជលផល, សៀវភៅណែនាំស្ដីពីការនាំចេញផលិតផលជលផល, គោលការណ៍បច្ចេកទេសស្ដីពីការអនុវត្តស្ដង់ដារអនាម័យល្អ ស្ដង់ដារផលិតល្អ គោលការណ៍ HACCP, ក្រមអនុវត្តសម្រាប់ការកែច្នៃបង្គាបង្កក បង្គាក្រៀម សាច់ក្ដាម និងការកែច្នៃទឹកត្រី<br>▪ បានផ្ដល់ទិដ្ឋាការអាជ្ញាបណ្ណនាំចេញផល អនុផលព្រៃឈើចំនួន ១៣ក្រុមហ៊ុន មានបរិមាណឈើកែច្នៃ សរុបចំនួន៧១១.៩៥២ម៉ែ៣ ចំណាំងកម្ទេចឈើចំនួន ៦.០០០តោន ជ័រទឹកចំនួន ៤៣៥តោន និងផលិតផលឬស្សីអាកាស្យា ចំនួន៦០តោន ព្រមទាំងបានផ្ដល់ទិដ្ឋាការអាជ្ញាបណ្ណនាំចូលផល អនុផលព្រៃឈើ ចំនួន ៤ក្រុមហ៊ុន មានបរិមាណឈើកែច្នៃចំនួន ៦.០១៤ម៣។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖<br>▪ បានរៀបចំបញ្ចប់សេចក្ដីព្រាងប្រកាសស្ដីពីការបំពេញបែបបទគយមុនទំនិញមកដល់ (Pre-Arrival Clearance) និងបានកែសម្រួលបច្ចេកទេសប្រព័ន្ធសម្រាប់គាំទ្រដល់ការអនុវត្តនីតិវិធីនេះ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានជំរុញលើកទឹកចិត្តដល់ក្រុមហ៊ុនកសិ-ឧស្សាហកម្ម ចំនួន ៤ ក្រុមហ៊ុនឱ្យចូលជាសមាជិកក្រុមធុរជនល្អបំផុត ដើម្បីទទួលបានកញ្ចប់លើកទឹកចិត្តក្នុងការសម្រួលនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយទាំងនាំចូល និងនាំចេញ<br>▪ បានបន្តអនុវត្តការកែសម្រួលនីតិវិធីគយដើម្បីផ្តល់កិច្ចសម្រួលពាណិជ្ជកម្មបន្ថែមទៀត ដល់វិស័យឯកជនក្នុងការបំពេញបែបបទគយ តាមស្មារតីនៃកិច្ចប្រជុំភាពជាដៃគូរវាងគយ-វិស័យឯកជន (CPPM) លើកទី៧<br>▪ បានបង្កើត និងកែលម្អ Hotline នៅតាមអង្គភាពគយនិងរដ្ឋាករមួយចំនួនសម្រាប់ផ្តល់ព័ត៌មាន និងសម្រាប់ការតវ៉ាប្រកបដោយប្រសិទ្ធភាពតាមមាត់ច្រកនានា។<br>- រដ្ឋបាលខេត្តព្រះសីហនុ បានធ្វើទស្សនកិច្ចនៅបណ្តាប្រទេសជាមិត្ត និងបានខិតខំធ្វើការទាក់ទាញ និងផ្សព្វផ្សាយដើម្បីអូសទាញវិនិយោគគិនមកវិនិយោគលើវិស័យនេះឱ្យកាន់តែរីកចម្រើនថែមទៀត។ | |
| - សិក្សាកំណត់នូវមុខទំនិញអាទិភាពដែលមានសក្តានុពលកែច្នៃសម្រាប់នាំចេញ ហើយរៀបចំផែនការសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដោយផ្អែកលើខ្សែច្រវ៉ាក់តម្លៃ ដើម្បីកំណត់មូលដ្ឋានគាំទ្រជាក់លាក់ដល់ការអភិវឌ្ឍវិស័យទាំងនោះ។ | មធ្យម ទៅ វែង | - ក្រសួងពាណិជ្ជកម្ម៖<br>▪ បានកសាងឯកសារយុទ្ធសាស្រ្តសមាហរណកម្មពាណិជ្ជកម្មកម្ពុជា និងផែនទីបង្ហាញផ្លូវអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ២០១៤-២០១៨ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកាលពីខែមករា ឆ្នាំ២០១៤ ដោយបានកំណត់នូវមុខទំនិញជាអាទិភាពរបស់កម្ពុជា រួមមានផលិតផល អង្ករ ជលផល ចំណីអាហារកែច្នៃម្រេច ដំឡូងមី ស្វាយចន្ទី ពោត សណ្តែកសៀង កញ្ចុងអង្ករ សូត្រ កៅស៊ូ បន្លែ ផ្លែឈើ និងទំនិញសម្គាល់ភូមិសាស្រ្ត។ល។ | - ក្រសួងពាណិជ្ជកម្ម៖<br>▪ ទីផ្សារតូចចង្អៀត<br>▪ ការអភិវឌ្ឍនូវសម្ភារៈវេចខ្ចប់ និងស្តង់ដារអនាម័យនៅមានកម្រិត<br>▪ កង្វះលទ្ធភាពក្នុងការវិនិយោគក្នុងស្រុក និងបរទេស<br>▪ កង្វះខាតថវិកា ធនធានមនុស្ស និងបច្ចេកទេសក្នុងការអនុវត្ត។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានរៀបចំបង្កើតអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា ដើម្បីបម្រើទីផ្សារក្នុងស្រុក និងជំរុញការនាំចេញផលិតផលហាឡាលកម្ពុជាទៅទីផ្សារអន្តរជាតិ ជាពិសេសទីផ្សារនៅមជ្ឈិមបូព៌ា<br>▪ បានសិក្សាផលិតផលថ្មីៗ ដែលមានសក្តានុពលបម្រើឱ្យទីផ្សារក្នុងស្រុក និងសម្រាប់នាំចេញដែលទើបតែលេចចេញនៅក្នុងខេត្តមួយចំនួនដូចជា ស្វាយអំពៅ ខេត្តស្វាយរៀង កោះកុង ព្រះវិហារ, ផ្លែចេក ខេត្តកំពង់ចាម ព្រះវិហារ, ផ្លែល្ហុង ខេត្តព្រះវិហារ, ផលិតផលសូត្រ ខេត្តសៀមរាប កំពង់ធំ តាកែវ បន្ទាយមានជ័យ កំពត និងខេត្តកណ្តាល<br>▪ បានបង្កើតក្រុមការងារនិងសិក្សាលទ្ធភាពដាក់បញ្ចូលគុយទាវភ្នំពេញនិងផលិតផលផ្កាអំបិលទៅជាផលិតផល ម៉ាកសម្ងាហភាព<br>▪ បានសម្ពោធពិធីដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ "ក្រូចថ្លុងកោះទ្រង់"។<br>▪ កំពុងពិនិត្យលទ្ធភាព និងសិក្សាផលិតផលសក្តានុពលកម្ពុជា រួមមាន ម្នាស់ទឹកឃ្មុំខេត្តស្ទឹងត្រែង ស្រាផលិតពីផ្លែផាសិន ខេត្តមណ្ឌលគិរី ផ្លែមៀនខេត្តប៉ៃលិន បន្ទាយមានជ័យ បាត់ដំបង និងពោធិ៍សាត់ ។ល។<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖<br>▪ បានរៀបចំ និងផ្សព្វផ្សាយសៀវភៅមគ្គុទ្ទេសក៍ស្តីពីការវិនិយោគក្នុងវិស័យកសិ-ឧស្សាហកម្ម (២០១៥) | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ កំណត់ និងសិក្សាវាយតម្លៃតំបន់ដាំដុះ និងកែច្នៃផលិតផលកសិកម្មសំខាន់ៗ ៖ (១) សិក្សា និងវាយតម្លៃ ការប្រើប្រាស់ដីកសិកម្មនៅខេត្តកំពង់ធំ និង (២) ពង្រាងផែនទីតំបន់សមស្របដំណាំការ៉ុត ស្រូវ ដីទំនាបវាំពីងទឹកភ្លៀង ស្រូវចម្ការ ស្រូវឡើងទឹក អំពៅ ម្រេច ពោត ស្វាយ ធុរេន ដំឡូងមី និងស្វាយចន្ទី<br>▪ ស្រាវជ្រាវ អភិវឌ្ឍ និងផ្សព្វផ្សាយពូជដំណាំដែលមានផលិតភាពខ្ពស់ ធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ និងឆ្លើយតបទីផ្សារជាសក្តានុពលសម្រាប់ផលិតជាវត្ថុធាតុ ដើម្បីបម្រើឱ្យវិស័យកសិ-ឧស្សាហកម្ម៖<br>- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍកសិកម្ម អភិរក្សលើដំណាំពោត និងសណ្តែក<br>- សិក្សាពីជម្រើសសមស្របលើការគ្រប់គ្រងទឹកនិងដីកសិកម្មសម្រាប់និរន្តរភាពផលិតកម្មដំណាំ<br>- សិក្សាស្រាវជ្រាវ និងជ្រើសរើសពូជដំណាំឧស្សាហកម្មដូចជា ដំណាំពោត សណ្តែកដី សណ្តែកបាយ សណ្តែកសៀង និងស្វាយចន្ទី<br>- ពិសោធផលិតកម្មពូជពោតអ៊ីប្រ៊ីត<br>- សិក្សាវាយតម្លៃពូជស្រូវឆ្លើយតបតម្រូវការទីផ្សារ<br>- ចងក្រងសៀវភៅបច្ចេកទេសស្តីពីការគ្រប់គ្រងសមាសភាពចង្រៃលើដំណាំស្រូវ<br>- បានចងក្រងសៀវភៅណែនាំបច្ចេកទេសដាំដុះដំណាំស្វាយ និងកំពុងសិក្សាស្រាវជ្រាវផលិតកម្មដំណាំស្វាយ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងថវិកា | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - កំពុងសិក្សាអភិវឌ្ឍបច្ចេកទេសដាំដុះស្រូវ ឧបករណ៍ព្រោះដាំគ្រាប់ស្រូវលើដីស្ងួតបំពាក់ជាមួយត្រាក់ទ័រ និងគោយន្ត ពិសោធន៍កំណត់ការប្រើប្រាស់កម្រិតគ្រាប់ពូជ បរិមាណជីប្រើប្រាស់ទៅតាមប្រភេទដី ចន្លោះគុម្ពស្រូវ និងពិសោធន៍បរិក្ខារទុកដាក់ស្រូវដែលរក្សាគុណភាពស្រូវអង្ករបានយូរ<br>- បានផ្សព្វផ្សាយបច្ចេកទេសដាំដុះស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម តាមរយៈសាលារៀន ស្រែកសិករ ទិវាបង្ហាញទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ ឯកសារបច្ចេកទេស និងតាមប្រព័ន្ធសាធារណៈ។<br>▪ ពង្រឹង និងពង្រីកមូលដ្ឋានការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍លើមុខដំណាំសេដ្ឋកិច្ចសំខាន់ៗសម្រាប់បម្រើឱ្យឧស្សាហកម្មកែច្នៃ និងការនាំចេញ (ស្រូវ ពោត សណ្តែកសៀង ម្រេច ដំឡូងមី ចេក ស្វាយ ស្វាយចន្ទី និងបន្លែ)<br>▪ រៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់ការអភិវឌ្ឍផលិតកម្មដំណាំ និងរៀបចំទស្សនវិស័យដំណាំឆ្នាំ២០៣០<br>▪ រៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់អភិវឌ្ឍន៍ផលិតកម្មសត្វ និងសុខភាពសត្វ÷ (១) ក្របខ័ណ្ឌផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍន៏វិស័យបសុសត្វ ២០១៦-២០២៥ ត្រូវបានរៀបចំរួចរាល់ និងបានដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០១៥, (២) បច្ចុប្បន្ននេះ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ ២០១៦-២០២៥ កំពុងតែត្រូវបានប្រើប្រាស់ជាឯកសារគោលក្នុងការរៀបចំផែនការសកម្មភាពជាក់ស្តែងសម្រាប់អនុវត្តប្រចាំឆ្នាំ, | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | (៣) ផែនការយុទ្ធសាស្ត្រថវិកា២០១៨-២០២០, និង (៤) សិក្សា និងរៀបចំយុទ្ធសាស្ត្រដំណោះស្រាយទីផ្សាររយៈពេលមធ្យម និងវែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងឆ្នាំ២០១៨ ៗបានរៀបចំអនុកម្មវិធីចំនួន១ គឺការធ្វើពិពិធកម្មមុខទំនិញឧស្សាហកម្ម ដែលក្នុងនោះមានចង្កោមសកម្មភាព ចំនួន០៥ និងសកម្មភាពចំនួន២០។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ក្នុងឆ្នាំ២០១៧-២០១៨÷<br>▪ បានបន្តចូលរួមប្រជុំពិភាក្សានិងផ្តល់យោបល់ទាក់ទងទៅនឹងការកំណត់មុខដំណាំអាទិភាពមួយចំនួនសម្រាប់កែច្នៃនាំចេញ ដូចជាការប្រជុំផ្តល់ធាតុចូលទៅលើសេចក្តីព្រាងគោលនយោបាយជាតិដំឡូងមីកម្ពុជា<br>▪ បានសិក្សាស្វែងយល់អំពីឯកសារផ្សេងៗពាក់ព័ន្ធទៅនឹងការកំណត់ដំណាំអាទិភាព រួមមាន អង្ករ កៅស៊ូ (ផលិតផលពាក់កណ្តាលសម្រេច) ស្វាយ ម្រេច អំបិល គ្រាប់ស្វាយចន្ទី ដំឡូងមី សណ្តែកសៀង និងពោត ដែលអាចធ្វើការកែច្នៃសម្រាប់នាំចេញ<br>▪ បន្តចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងគម្រោងខ្សែច្រវាក់តម្លៃនៃកសិធុរកិច្ច ប្រកបដោយភាតរភាពបរិស្ថាន ដោយផ្តោតលើមុខដំណាំ៤មុខរួមមាន ស្រូវ ពោត ដំឡូងមី និងស្វាយ ដែលគ្រោងអនុវត្តនៅខេត្តតាកែវ កំពត កំពង់ចាម និងត្បូងឃ្មុំ ក្នុងគោលបំណងបង្កើនផលិតភាព តាមរយៈការអនុវត្តផលិតកម្ម និងការកែច្នៃ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ផលិតផលកសិកម្មឱ្យមាននិរន្តរភាព និងសម្របតាមការប្រែប្រួលអាកាសធាតុ កែលម្អគុណភាព និងបង្កើនតម្លៃបន្ថែម។ | |
| *៣)-ការកែលម្អបរិស្ថាននិយតកម្ម* | | | |
| *ក-វិធានការសម្រួលពាណិជ្ជកម្ម និងជំរុញការនាំចេញ* | | | |
| - ពន្លឿនបញ្ចប់ការអនុវត្តផែនការកែទម្រង់ការសម្រួលពាណិជ្ជកម្ម រួមទាំងការដាក់ឱ្យប្រើប្រាស់សេវា *"បញ្ជរតែមួយជាតិ"* ដោយមានការសម្របសម្រួលគ្នាក្នុងចំណោមអាជ្ញាធរតាមមាត់ច្រកអន្តរជាតិទាំងអស់ ហើយធានាឱ្យមានសមាហរណកម្មជាមួយនឹងសេវា *"បញ្ជរតែមួយអាស៊ាន"* និងការតភ្ជាប់ទៅនឹង បណ្ដាញភស្ដុភារកម្មអន្តរជាតិ | ២០១៥ ទៅ មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានពង្រីកភាពគ្របដណ្ដប់លើភូមិសាស្ត្រ និងមុខងារប្រព័ន្ធអាស៊ីគូដា ទៅគ្រប់ការិយាល័យគយនិងរដ្ឋាករនៅទូទាំងប្រទេស<br>▪ កំពុងអភិវឌ្ឍប្រព័ន្ធបញ្ជរតែមួយជាតិដំណាក់កាលទី២ ដោយពង្រីកទៅក្រសួងស្ថាប័ន ៥ ÷ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសុខាភិបាល, ក្រសួងពាណិជ្ជកម្ម និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ព្រមទាំងតំណភ្ជាប់ជាមួយកំពង់ផែអន្តរជាតិ និងអាកាសយានដ្ឋាន<br>▪ បានចុះអនុស្សរណៈយោគយល់គ្នារវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ជាមួយកំពង់ផែស្វយ័តក្រុងព្រះសីហនុ ដើម្បីផ្លាស់ប្ដូរព័ត៌មានពាក់ព័ន្ធនាវា<br>▪ បានបន្តអនុវត្តយន្តការភាពជាដៃគូគយ-ផ្នែកឯកជន និងតាមបញ្ញត្តិប្រកាសអន្តរក្រសួងស្ដីពីការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យជាធរមាន<br>▪ បានពង្រីកភាពគ្របដណ្ដប់លើភូមិសាស្ត្រ និងមុខងារប្រព័ន្ធអាស៊ីគូដា ដែលជាមូលដ្ឋាននៃប្រព័ន្ធបញ្ជរតែមួយជាតិទៅគ្រប់ការិយាល័យគយសំខាន់ៗ | - ក្រសួងពាណិជ្ជកម្ម បានស្នើសុំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាក្រសួងនាំមុខលើបញ្ហានេះតាមស្មារតីកិច្ចប្រជុំប្រចាំខែឧសភានៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷<br>▪ ខ្វះប្រភពថវិកាសម្រាប់អនុវត្ត<br>▪ ខ្វះធនធានមនុស្សសម្រាប់ដំណើរការ និងថែរក្សា។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ សិក្សាលទ្ធភាពមុខងារតភ្ជាប់ជាមួយស្វ័យប្រវត្តិកម្មគយផ្សេងទៀត ដូចជា ប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យគយ (CRMDS), ប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (TCMS), ប្រព័ន្ធទ្រទ្រង់តម្លៃគិតពន្ធគយ (CVSS) និងប្រព័ន្ធស្ថិតិគយ<br>▪ មុខងារគាំទ្រនីតិវិធីគយផ្សេងទៀតត្រូវបានដាក់ឱ្យអនុវត្តជាបន្តបន្ទាប់។ ប្រព័ន្ធបញ្ជរតែមួយជាតិដំណាក់កាលទី១ គឺការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ (អាស៊ីគូដា) ទៅប្រព័ន្ធស្វ័យប្រវត្តិកម្មវិញ្ញាបនបត្របញ្ជាក់ប្រភពទំនិញ និងតភ្ជាប់ទៅប្រព័ន្ធបញ្ជរតែមួយអាស៊ាន ដើម្បីអាចបញ្ជូន និងទទួលវិញ្ញាបនបត្រ CO Form D ក្នុងទម្រង់អេឡិកត្រូនិក ជាមួយប្រទេសសមាជិកដទៃ ដែលគ្រោងដាក់ឱ្យដំណើរការសាកល្បងនាពេលខាងមុខ<br>▪ បានជ្រើសរើស និងបណ្ដុះបណ្ដាលជើងសាគយវិជ្ជាជីវៈជាមធ្យម ១០០រូបក្នុងឆ្នាំ ដើម្បីត្រៀមបម្រុងអនុវត្តប្រព័ន្ធនេះ។<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន÷<br>▪ បាននិងកំពុងអនុវត្តនូវផែនការមេតភ្ជាប់អាស៊ាន ២០២៥ (Master Plan of ASEAN Connectivity 2025)<br>▪ គម្រោងអភិវឌ្ឍមជ្ឈមណ្ឌលឡូជីស្ទីកភ្នំពេញ (Phnom Penh Logistics Complex) កំពុងសិក្សាបុរេសមិទ្ធិលទ្ធភាព គ្រោងនឹងបញ្ចប់នៅខែវិច្ឆិកា ឆ្នាំ២០១៩ ខាងមុខនេះ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី គ្រោងនឹងវិនិយោគក្រោមរូបភាពភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានសហការជាមួយ JICA និងធនាគារពិភពលោក ក្នុងការកំណត់បញ្ហាដែលនាំឱ្យរាំងស្ទះដល់ការអភិវឌ្ឍភស្តុភារកម្ម និងប្រមូលបានព័ត៌មានត្រឡប់ពីអ្នកពាក់ព័ន្ធ សំដៅជំរុញផែនការមេភស្តុភារកម្មជាតិឱ្យមានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយ។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានចូលរួមសហការអនុវត្តផែនការកែទម្រង់ការសម្រួលពាណិជ្ជកម្ម រួមទាំងដាក់ឱ្យប្រើប្រាស់សេវាប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់បញ្ជរតែមួយជាតិ (គាំទ្រផ្នែកបច្ចេកទេស បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់ការដាក់ឱ្យប្រើប្រាស់បញ្ជរតែមួយជាតិ)។<br>- ក្រសួងពាណិជ្ជកម្មបានស្នើសុំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាក្រសួងនាំមុខលើបញ្ហានេះ តាមស្មារតីកិច្ចប្រជុំ ប្រចាំខែឧសភា ឆ្នាំ២០១៧ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ | |
| - បង្កើតនូវមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្ម ដែលប្រមូលផ្តុំនូវព័ត៌មានអំពីវិធានពាណិជ្ជកម្ម តារាងពន្ធ និងកម្រៃផ្លូវការដែលត្រូវបង់ដោយពាណិជ្ជករ ហើយដាក់ព័ត៌មានទាំងនេះលើបណ្តាញអ៊ីនធើណែត | ២០១៥ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានបន្តធ្វើបច្ចុប្បន្នកម្មនូវបណ្តាទិន្នន័យនិងឯកសារគយចាំបាច់នានាក្នុង គេហទំព័រគយ www.customs.gov.kh ដែលបានដាក់ឱ្យដំណើរការ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៦មក<br>▪ បានផ្សព្វផ្សាយជាសាធារណៈក្នុងគេហទំព័រគយ www.customs.gov.kh និងបានធ្វើបច្ចុប្បន្នភាពជាប្រចាំ។<br>- ក្រសួងពាណិជ្ជកម្ម បានស្នើសុំ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជា ក្រសួងនាំមុខលើបញ្ហានេះ តាមស្មារតីកិច្ចប្រជុំ ប្រចាំខែឧសភា ឆ្នាំ២០១៧ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ | - ក្រសួងពាណិជ្ជកម្ម បានស្នើសុំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាក្រសួងនាំមុខលើបញ្ហានេះ តាមស្មារតីកិច្ចប្រជុំប្រចាំខែឧសភា នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| - កែលម្អការធ្វើបែបបទបញ្ចេញទំនិញ (Custom Clearance) សម្រាប់ទំនិញដែលលើកលែងពន្ធ ដោយពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធ កាត់បន្ថយនូវតម្រូវការឯកសារមិនចាំបាច់ សម្រួលនីតិវិធីឱ្យបានឆាប់រហ័ស និងលុបបំបាត់ចំណាយក្រៅផ្លូវការ | ២០១៥ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ រយៈពេលបំពេញបែបបទគយត្រូវបានកាត់បន្ថយមកត្រឹម១ម៉ោង ៣នាទី សម្រាប់ផ្លូវអាកាស, ២ម៉ោង៥៨ នាទី សម្រាប់ផ្លូវទឹក និង ១ម៉ោង៣៥នាទី សម្រាប់ផ្លូវគោក (គិតពីពេលចុះបញ្ជិកាប្រតិវេទន៍ ដល់ពេលអនុញ្ញាតឱ្យយកទំនិញចេញ - Release Order)<br>▪ បន្តរៀបចំកិច្ចប្រជុំក្រោមក្របខ័ណ្ឌយន្តការភាពជាដៃគូគយ និងផ្នែកឯកជន ជាទៀងទាត់តាមសំណូមពរក្នុងកម្រិតក្រុមការងារបច្ចេកទេសទាំង ៤ នៃយន្តការនេះ ហើយកិច្ចប្រជុំរបស់យន្តការនេះត្រូវបានធ្វើភ្លាមប្រសិនបើមានសំណូមពរការងារចាំបាច់<br>▪ បានជួបប្រជុំជាមួយសមាគមធុរជនតាមវិស័យ មានជាអាទិ៍ សមាគមធុរកិច្ចជប៉ុន, សភាពាណិជ្ជកម្មអឺរ៉ុប, ទីភ្នាក់ងារជំរុញពាណិជ្ជកម្ម-វិនិយោគកូរ៉េ, សភាពាណិជ្ជកម្មចិន, សហព័ន្ធស្រូវអង្ករ និងសមាគមយានយន្តកម្ពុជា។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ បានបន្តពង្រឹងការពិនិត្យ និងការអនុម័តលើសំណើការនាំចូលដោយពន្ធជាបន្ទុករបស់រដ្ឋរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ | |
| - កាត់បន្ថយនូវនីតិវិធីត្រួតពិនិត្យដែលជាន់គ្នា និងគ្មានតម្លាភាព | ២០១៥ | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ កំពុងបន្តរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យវិនិយោគ (Investment Tracking System) ក្នុងគោលបំណងតាមដានគម្រោងវិនិយោគ និងបង្កើនតម្លាភាព។<br>- ក្រសួង/ស្ថាប័នពាក់ព័ន្ធ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| - រៀបចំឱ្យមានផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម ដែលជាមូលដ្ឋានក្នុងការជួយសម្រួលពាណិជ្ជកម្ម និងជាប្រព័ន្ធដែលមានប្រសិទ្ធភាពអាចទុកចិត្តបាន និងមានភាពប្រកួតប្រជែងខ្ពស់ | ២០១៥<br>ទៅ<br>មធ្យម | - ក្រសួងសាធារណការ និងដឹកជញ្ជូន÷<br>▪ ក្រសួងរួមជាមួយនឹងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន និង ធនាគារពិភពលោកបានបញ្ចប់ការសិក្សាផែនការមេស្តីពីការកែលម្អប្រព័ន្ធភស្តុភារកម្មនៅព្រះរាជាណាចក្រកម្ពុជា ២០១៨-២០២៥ គ្រោងនឹងដាក់ឱ្យអនុវត្តក្នុង៣ដំណាក់កាល រយៈពេលខ្លី (២០១៨-២០១៩) មធ្យម (២០២០-២០២២) និងវែង (២០២៣-២០២៥)<br>▪ បានសហការជាមួយ JICA និងធនាគារពិភពលោក ក្នុងការកំណត់បញ្ហាដែលនាំឱ្យរាំងស្ទះដល់ការអភិវឌ្ឍភស្តុភារកម្ម និងប្រមូលបានព័ត៌មានត្រឡប់ពីអ្នកពាក់ព័ន្ធ សំដៅជំរុញផែនការមេភស្តុភារកម្មជាតិឱ្យមានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយ។<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានចូលរួមពិគ្រោះយោបល់ និងបានផ្តល់ធាតុចូលក្នុងការរៀបចំផែនការមេអភិវឌ្ឍន៍ប្រព័ន្ធឡូជិស្ទីក ក្រោមការដឹកនាំរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន (គម្រោងរបស់ JICA)<br>▪ បានចូលរួមពិគ្រោះយោបល់ និងប្រមូលធាតុចូលក្នុងការអនុវត្តគម្រោងផែនការមេសម្រាប់ប្រព័ន្ធដឹកជញ្ជូននៅកម្ពុជា (Intermodal Transport Master Plan in Cambodia) ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនចុះហត្ថលេខារវាងទ្វេភាគី កម្ពុជា-ចិន កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍÷<br>▪ បានចូលរួមសហការរៀបចំផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធឡូជិស្ទីក<br>▪ បានកែសម្រួលសេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យប្រៃសណីយ៍។ | |
| - ជំរុញកិច្ចខិតខំប្រឹងប្រែងថ្នាក់តំបន់និងអនុតំបន់នានា ដូចជា អាស៊ាន និងកម្មវិធីមហាអនុតំបន់មេគង្គ ដើម្បីអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែន (CBTA) និង “យន្តការបញ្ជរតែមួយ” ដែលត្រូវបានបង្កើតឡើងក្នុងគោលដៅកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារកម្មអន្តរជាតិក្នុងតំបន់ ទន្ទឹមនឹងការរៀបចំបង្កើតក្របខ័ណ្ឌស្ថាប័នចាំបាច់នានា ដើម្បីធ្វើសមាហរណកម្មបញ្ចូលក្នុងប្រព័ន្ធភស្តុភារកម្ម កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលឱ្យកាន់តែទូលំទូលាយជាមួយអាជ្ញាធរដៃគូពាក់ព័ន្ធ ដែលមានកាតព្វកិច្ចក្នុងការសម្រួលការដឹកជញ្ជូន ការចល័តមនុស្ស និងទំនិញ | ២០១៥ ទៅ មធ្យម | - ក្រសួងសាធារណការ និងដឹកជញ្ជូន÷<br>▪ បានបញ្ចប់គម្រោងសាងសង់ស្ពានឆ្លងកាត់ព្រំដែនកម្ពុជា-ថៃ (ស្ទឹងបត់-បានណងអៀង) និងផ្លូវភ្ជាប់ក្បាលស្ពាន ប្រវែងសរុប ៦២០ម<br>▪ គម្រោងសាងសង់ស្ពានជ្រៃធំ ប្រវែង ៤២៧,៨ម និងផ្លូវតភ្ជាប់ស្ពាន ប្រវែង ២,៦៦គ.ម (ស្រុកកោះធំ/ខេត្តកណ្តាល-ឡុងប៊ិញ/ខេត្តអាងយ៉ាង) ថវិកាសរុបចំនួន ១៨,៧៦លានដុល្លារអាមេរិក បានធ្វើពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧<br>▪ ក្រសួងសាធារណការ និងដឹកជញ្ជូនកម្ពុជា និងក្រសួងដឹកជញ្ជូនវៀតណាម បានចុះអនុស្សារណៈយោគយល់គ្នាស្តីពីជំរុញការសិក្សា និងសាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-បាវិត និង ហូជីមិញ-ម៉ុកបៃ<br>▪ បានចុះហត្ថលេខាលើកិច្ចកិច្ចព្រមព្រៀងស្តីពីការជញ្ជូនឆ្លងកាត់ព្រំដែនតាមផ្លូវដែករវាងកម្ពុជា-ថៃ<br>▪ បានបញ្ចប់ការសាងសង់ និងជួសជុល ផ្លូវដែក ភ្នំពេញ-បាត់ដំបង-ប៉ោយប៉ែត និងដាក់ឱ្យដំណើរការបណ្តោះអាសន្ន<br>▪ ជួសជុលកំណាត់ផ្លូវដែកប្រវែង៦,៥គ.ម (ប៉ោយប៉ែត ព្រំប្រទល់កម្ពុជា-ថៃ) បានតភ្ជាប់ផ្លូវដែកកម្ពុជា-ថៃ រួចរាល់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បន្ត និងជំរុញអនុវត្តគម្រោងសាងសង់ស្ថានីយរថភ្លើងសំរោង និងគ្រោងសិក្សាការសាងសង់ស្ថានីយរថភ្លើងអន្តរជាតិស្ទឹងបត់<br>▪ ជួសជុលស្ថានីយរថភ្លើងប៉ោយប៉ែត សម្រេចបាន១០០%<br>▪ គម្រោងបំពាក់ប្រព័ន្ធសុវត្ថិភាពចរាចរណ៍ផ្លូវដែកភាគខាងជើង សម្រេចបាន១០០%។<br>**ក.កិច្ចសហប្រតិបត្តិការជាមួយប្រទេសឡាវ÷**<br>▪ បន្តអនុវត្តប្រតិបត្តិការដឹកជញ្ជូនអ្នកដំណើរឆ្លងកាត់តាមកិច្ចសន្យា។ ក្រុមហ៊ុនចម្រុះឡាវ-ជប៉ុន បានចុះបញ្ជីយានយន្តសរុប ១៤គ្រឿង (ក្បាលសណ្តោង ១៤ និងសីមីរ៉ឺម៉ក ១៤ ក្នុងចំណោមកូតា ៤០ គ្រឿង ដើម្បីធ្វើប្រតិបត្តិការដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែនរវាងកម្ពុជា-ឡាវ<br>▪ ៧បានឯកភាពសាកល្បងអនុវត្តកូតាយានយន្ត ចំនួន ២០គ្រឿងបន្ថែម តែមិនទាន់អនុវត្តបាននៅឡើយ។ គណៈកម្មាធិការសម្រួលការដឹកជញ្ជូនភាគីទាំងពីរ បានឯកភាពគ្នានិងកំពុងរៀបចំសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នាដំឡើងកូតាឱ្យដល់១៥០ គ្រឿង ការស្នើអនុវត្ត និងអនុញ្ញាតឱ្យរថយន្តគ្រួសារអាចចេញចូលទៅវិញទៅមករវាងប្រទេសទាំងពីរ ការស្នើផ្លូវឆ្លងកាត់ថ្មី ស្ទឹងត្រែង-ព្រះវិហារ-សៀមរាប ការរៀបចំពិធីសារស្តីពីការដឹកជញ្ជូនអ្នកដំណើរទៀងទាត់តាមកាលវេលា ការរៀបចំមន្ត្រីទំនាក់ទំនងនៅថ្នាក់ក្រសួង និងមន្ទីរថ្នាក់ខេត្ត រវាងភាគីទាំងពីរ ។ល។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ▪ ក្រសួងបានកំពុងជំរុញប្រជុំពិភាក្សាជាមួយភាគីឡាវ ក្នុងការងារគូសប្លង់បច្ចេកទេសរួមគ្នា និងវាយតម្លៃការសាងសង់ស្ពានឆ្លងកាត់ទន្លេល្ពៅ-សេឡាំផាវ។<br>**ខ. គម្រោងសហប្រតិបត្តិការជាមួយប្រទេសវៀតណាម÷**<br>▪ បន្តអនុវត្តកូតាយានយន្ត ៥០០គ្រឿងក្នុងក្របខ័ណ្ឌអនុស្សារណៈនៃការយោគយល់ស្តីពីការអនុវត្តកិច្ចព្រមព្រៀងការដឹកជញ្ជូនឆ្លងកាត់ព្រំដែនទ្វេភាគីកម្ពុជា-វៀតណាម ព្រមទាំងបានបញ្ចប់ការពង្រីកកំណាត់ផ្លូវជាតិលេខ១ជាបួនគន្លងផ្លូវ ក្នុងចន្លោះគ.ម.១៦៥+៣០០ ដល់ គ.ម.១៦៦+៨០០ (ច្រកទ្វារ ព្រំដែនបាវិត) ប្រវែង ១,៥០០ម ដោយប្រើប្រាស់ថវិកាជាតិ<br>▪ បានចុះហត្ថលេខាលើ (១)អនុស្សរណៈនៃការយោគយល់គ្នាស្តីពីយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការវិស័យដឹកជញ្ជូនរវាងកម្ពុជា-វៀតណាមឆ្នាំ២០១៨-២០២៥ និងចក្ខុវិស័យដល់ឆ្នាំ២០៣០, (២) អនុស្សរណៈនៃការយោគយល់គ្នាស្តីពីវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនផ្លូវទឹកកម្ពុជា-វៀតណាម និង (៣) ពិធីសារស្តីពីវិសោធនកម្មលើពិធីសារសម្រាប់ការអនុវត្តកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនផ្លូវគោកកម្ពុជា-វៀតណាម នៅរាជធានីភ្នំពេញ<br>▪ បន្តពិភាក្សា (១) រៀបចំអនុស្សារណៈនៃការយោគយល់គ្នាស្តីពីការអភិវឌ្ឍដឹកជញ្ជូនតាមតំបន់ឆ្នេរ កម្ពុជា-ថៃ-វៀតណាម និង (២) កែសម្រួលពិធីសារឆ្នាំ២០០៥ លើកិច្ចព្រមព្រៀងដឹកជញ្ជូនផ្លូវគោកទ្វេភាគីកម្ពុជា-វៀតណាម | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានឯកភាពឱ្យមានក្រុមការងារដឹកជញ្ជូនផ្លូវទឹក និងដឹកជញ្ជូនផ្លូវសមុទ្ររបស់ក្រសួងទាំងពីរ ពិភាក្សាគ្នា។ កម្ពុជា និងវៀតណាម បានរៀបចំពិធីសម្ពោធបើកឱ្យយានយន្តឆ្លងកាត់ព្រំដែនបាន ចំនួន០៦ច្រក (បាវិត ត្រពាំងផ្លុង ភ្នំដិន ព្រែកចាក ត្រពាំងស្រែ និងអូរយ៉ាដាវ) ក្នុងចំណោមច្រក០៧ដែលបានឯកភាព។<br>គ. កិច្ចសហប្រតិបត្តិការជាមួយប្រទេសថៃ÷<br>▪ អនុស្សារណៈនៃការយោគយល់ស្ដីពីការផ្លាស់ប្ដូរសិទ្ធិចរាចរណ៍ សម្រាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែននៅច្រកទ្វារប៉ោយប៉ែត-អារញ្ញប្រាថេត (ដំឡើងកូតាយានយន្ត ពី ៤០គ្រឿង ដល់ ១៥០គ្រឿង) បានចូលជាធរមានកាលនៅចុងខែមីនា ឆ្នាំ២០១៧ បន្ទាប់ពីភាគីទាំងពីរ បានចុះហត្ថលេខាកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ នៅទីក្រុងឈៀងម៉ៃ ប្រទេសថៃ ដើម្បីអនុវត្តអនុស្សារណៈនៃការយោគយល់ផ្ដួចផ្ដើមអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូន GMS ក្នុងឱកាសនៃកិច្ចប្រជុំលើកទី៥ គណៈកម្មការរួមនៃគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូន កាលពីថ្ងៃទី១៤-១៥ ខែធ្នូ ឆ្នាំ២០១៦<br>▪ ក្រសួងកំពុងអនុវត្តកូតាយានយន្ត ១៥០គ្រឿង និងបានរៀបចំចុះបញ្ជីយានយន្តតាមចំនួនកូតាកំណត់ខាងលើ ហើយគ្រោងការចុះបញ្ជីយានយន្ត៥០០គ្រឿង សម្រាប់កូតា GMS ផងដែរ។ ដោយឡែក ក្រុមហ៊ុនណាតាកាន់ខេមបូឌា (NATTAKAN Cambodia) និង ក្រុមហ៊ុនយុនស៊ុងថៃ (Thai Transport Co.) ជាក្រុមហ៊ុនចម្រុះទទួលបានការអនុញ្ញាតធ្វើសេវារថយន្តដឹកអ្នកដំណើរមានកំណត់ពេល (ឡានដ) ដោយប្រើរថយន្តក្រុងដឹកអ្នកដំណើរកម្ពុជា ០៤ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | គ្រឿង និងថៃ ០៤គ្រឿង ចេញដំណើរឆ្លាស់គ្នារាល់ថ្ងៃតាមទិសដៅ និងខ្សែផ្លូវរវាងសៀមរាប-បាងកក និងភ្នំពេញ-បាងកក<br>▪ ក្រសួងកំពុងពិចារណាសំណើរបស់ក្រុមហ៊ុនចម្រុះទាំងពីរ សុំដាក់ឱ្យដំណើរការបន្ថែមរថយន្តដឹកអ្នកដំណើរលើខ្សែផ្លូវសៀមរាប-បាងកក និងខ្សែផ្លូវផ្សេងៗទៀត ដូចជា សៀមរាប-ប៉ាតាយ៉ា ជាដើម។<br>ឃ. កិច្ចសហប្រតិបត្តិការរវាងកម្ពុជា-ឡាវ-វៀតណាម÷<br>▪ អនុស្សារណៈនៃការយោគយល់ស្តីពីការដឹកជញ្ជូនឆ្លងកាត់ព្រំដែនកម្ពុជា-ឡាវ-វៀតណាម បានចូលជាធរមាន ដោយបន្តអនុវត្តកូតាយានយន្តចំនួន ១៥០គ្រឿង សម្រាប់ធ្វើប្រតិបត្តិការឆ្លងកាត់។ ភាគីវៀតណាម បានផ្តួចផ្តើមឱ្យមានអនុស្សរណៈនៃការយោគយល់ និងផែនការមេ សម្រាប់ការតភ្ជាប់ និងអភិវឌ្ឍវិស័យដឹកជញ្ជូនរវាងបីប្រទេស។ វៀតណាម បានស្នើសុំឱ្យកម្ពុជា និងឡាវ ជួយផ្តល់ទិន្នន័យសម្រាប់ការសិក្សាផែនការមេ និងបានស្នើឱ្យមានការជួបប្រជុំជាបន្តបន្ទាប់ ដើម្បីផ្តល់មតិ និងបញ្ចប់ការងារនេះ។<br>ង .កិច្ចសហប្រតិបត្តិការដឹកជញ្ជូនក្នុងមហាអនុតំបន់មេគង្គ÷<br>▪ ប្រទេសជាសមាជិកមហាអនុតំបន់ទន្លេមេគង្គទាំង ០៦ គ្រោងនឹងចាប់ផ្តើមអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនអ្នកដំណើរ និងទំនិញនាពេលឆាប់ៗនេះ។ ក្នុងកិច្ចព្រមព្រៀងនេះ ប្រទេសនីមួយៗអាចចេញលិខិតអនុញ្ញាតឱ្យយានយន្ត ៥០០គ្រឿង ធ្វើប្រតិបត្តិការដឹកជញ្ជូនទៅតាមតំរាយផ្លូវដូចមានកំណត់ក្នុងពិធីសារទី១ នៃកិច្ចព្រមព្រៀង | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ចំពោះប្រទេសនៃមហាអនុតំបន់មេគង្គទាំង០៥ ដែលចូលរួមអនុវត្តកម្មវិធីប្រមូលផលដើមដៃ (Early Harvest) លើកលែងប្រទេសមីយ៉ាន់ម៉ា ត្រូវបានចុះហត្ថលេខារួចហើយលើអនុស្សារណៈនៃការយោគយល់គ្នា និងបានចាប់ផ្តើមផ្តល់លិខិតអនុញ្ញាត និងឯកសារអនុញ្ញាតឱ្យយានយន្តចេញចូលជាបណ្តោះអាសន្ន ដែលមានការទទួលស្គាល់គ្នាទៅវិញទៅមក ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៨។<br>**ច. កិច្ចសហប្រតិបត្តិការដឹកជញ្ជូនក្នុងតំបន់អាស៊ាន÷**<br>▪ ៙អាស៊ានកំពុងអនុវត្តគម្រោងសាកល្បងប្រព័ន្ធឆ្លងកាត់គយអាស៊ាន (ACTS) កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) នៅឆ្នាំ២០១៨នេះ ដែលជាច្រករបៀងខាងកើត-លិចនៃអាស៊ាន បន្ទាប់ពីអនុវត្តគម្រោងសាកល្បងនៅប្រទេសសិង្ហបុរី ថៃ និងម៉ាឡេស៊ី ដែលជាច្រករបៀងខាងជើង-ត្បូងនៃអាស៊ាន ក្រោមជំនួយពីសហគមន៍អឺរ៉ុប ដោយចាប់ផ្តើមពីការរៀបចំប្រព័ន្ធឆ្លងកាត់គយ (ASEAN Customs Transit System - ACTS)។ ប្រទេសសមាជិកអាស៊ាន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការសម្របសម្រួលការដឹកជញ្ជូនអ្នកដំណើរតាមរថយន្ត នៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧ នៅប្រទេសសិង្ហបុរី។<br>- ក្រសួងពាណិជ្ជកម្ម បន្តបញ្ជូនមន្ត្រីជំនាញចូលរួមចរចាលើកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែនក្រោមក្របខណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ថៃ, កម្ពុជា-វៀតណាម និងកម្ពុជា-ឡាវ។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានជួបពិភាក្សាការងារជាមួយអ្នកជំនាញការប្រព័ន្ធឆ្លងកាត់គយអាស៊ាន (ACTS) នៃគម្រោង ARISE Plus<br>▪ បានដាក់ឱ្យដំណើរការអនុវត្តប្រព័ន្ធប្រកាសប្រតិវេទន៍គយឆ្លងកាត់តាមទម្រង់អេឡិចត្រូនិក។ | |
| - ពង្រឹងសមត្ថភាពអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ឱ្យក្លាយជាភ្នាក់ងារជំរុញការនាំចេញ ដែលមានជំនាញខ្ពស់ក្នុងការវិភាគទីផ្សារនាំចេញ កំណត់មុខសញ្ញានាំចេញ និងរៀបចំបណ្តាញធុរកិច្ចដែលជាមូលដ្ឋានក្នុងការផ្តល់ការពិគ្រោះយោបល់ផ្នែកពាណិជ្ជកម្ម ផ្តល់ព័ត៌មានអំពីទីផ្សារក្រៅប្រទេស និងជួយសម្របសម្រួលសកម្មភាពជំរុញការនាំចេញ រួមទាំង ការរៀបចំការផ្សព្វផ្សាយទីផ្សារ ឬការតាំងពិព័រណ៍ | ២០១៥ | - ក្រសួងពាណិជ្ជកម្ម÷<br>▪ បានរៀបចំមជ្ឈមណ្ឌលពាណិជ្ជកម្មនៅក្រៅប្រទេស ពិសេសនៅប្រទេសចិន<br>▪ បង្កើតតំណាងពាណិជ្ជកម្មនៅបណ្តាប្រទេសថ្មីមួយចំនួនបន្ថែមទៀតដូចជា ប្រទេសអូស្ត្រាលី ប្រទេសប៊ែលហ្ស៊ិក ប្រទេសរុស្ស៊ី (បង្កើតឡើងវិញ) ប្រទេសឥណ្ឌូនេស៊ី និងតម្លើងស្ថានអគ្គរាជទូតទទួលបន្ទុកពាណិជ្ជកម្មនៅអង្គការពាណិជ្ជកម្មពិភពលោក នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស<br>▪ បន្តជំរុញការចូលរួមផ្សព្វផ្សាយផលិតផលខ្មែរ នៅទីផ្សារក្រៅប្រទេសតាមរយៈការចូលរួមរៀបចំពិព័រណ៍នៅក្រៅប្រទេស<br>▪ បង្កើតឱ្យមានការផ្សព្វផ្សាយ (កិច្ចប្រជុំប្រចាំឆ្នាំ ពិគ្រោះយោបល់ដែលទាក់ទងពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍)។ | - ក្រសួងពាណិជ្ជកម្ម÷ បញ្ហាថវិកា និងធនធានមនុស្សមានកំណត់។ |
| - ពិចារណាបង្កើតស្ថាប័នហិរញ្ញប្បទានតាមគោលនយោបាយដែលមានកាតព្វកិច្ចផ្តល់កម្ចីទៅឱ្យអ្នកនាំចេញ ដែលផលិតទំនិញនាំចេញក្នុងឧស្សាហកម្មអាទិភាព និងផ្តល់នូវ សេវាធានារ៉ាប់រងការ | ២០១៥ ទៅ មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានពិភាក្សាកម្រិតបច្ចេកទេស។<br>- ក្រសួងពាណិជ្ជកម្ម÷ | - ក្រសួងពាណិជ្ជកម្ម÷ គម្រោងថវិកាជំនួយត្រូវបានបញ្ចប់។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| នាំចេញ ដើម្បីកាត់បន្ថយភាពមិនប្រាកដប្រជាទាក់ទងនឹងការនាំចេញ | | ▪ ធ្លាប់បានអនុវត្តគម្រោងបើកច្រកទីផ្សារនាំចេញដោយបានជួយវិស័យឯកជន រៀបចំឯកសារគតិយុត្តសម្រាប់បម្រើដល់ការនាំចេញដោយប្រើប្រាស់ថវិកាជំនួយរបស់ដៃគូអភិវឌ្ឍន៍<br>▪ បានសហការជាមួយដៃគូអភិវឌ្ឍន៍ លើគម្រោងកសិកម្មទីផ្សារខ្នាតតូច (AIMs) នៅតាមមូលដ្ឋាន ដោយចែកចេញជា ៣ភូមិភាគ គឺភូមិភាគតាកែវ បាត់ដំបង និងភូមិភាគកំពង់ចាម។ | |
| - ពង្រឹងការសម្រួលពាណិជ្ជកម្ម តាមរយៈការកែលម្អនីតិវិធី ការពង្រឹងយន្តការដឹកជញ្ជូនឆ្លងដែន ការកាត់បន្ថយថ្លៃចម្លងការពាណិជ្ជកម្ម និងការពង្រឹងការសម្របសម្រួលស្ថាប័ន | ២០១៥ ទៅ មធ្យម | - ក្រសួងពាណិជ្ជកម្ម÷<br>▪ បានបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសម្រាប់អនុវត្តការសាងសង់ផ្សារព្រំដែនវៀតណាម-កម្ពុជានៅឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ<br>▪ បានបន្តអនុវត្តការចុះបញ្ជីសហគ្រាស / ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ / ការចុះបញ្ជីម៉ាកតាមប្រព័ន្ធ តាមប្រព័ន្ធអេឡិកត្រូនិច និងការបង់កម្រៃសេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិក (E-payment)។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ ចំណូលពន្ធអាករគយ ក្នុងឆ្នាំ២០១៧ សម្រេចបានតាមគោលដៅកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧<br>▪ ចំនួនប្រតិវេទន៍គយ (SAD: Single Administrative Document) ច្រកក្រហមមានកម្រិត ក្រោម ១៥% នៃប្រតិវេទន៍គយសរុប ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា<br>▪ ចំណូលពន្ធអាករគយ ក្នុងឆ្នាំ២០១៨ សម្រេចបានតាមគោលដៅកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ខ្វះថវិកាសម្រាប់បន្តអនុវត្ត។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ចំនួន SAD ច្រកក្រហមមានកម្រិតក្រោម ១១% នៃប្រតិវេទន៍គយសរុប ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។<br>▪ បានកែសម្រួលនីតិវិធីគយសម្រាប់ការដឹកជញ្ជូនទំនិញពីកំពង់ផែមកកាន់តំបន់សេដ្ឋកិច្ចពិសេស សម្រាប់ក្រុមហ៊ុនវិនិយោគក្នុងតំបន់<br>▪ កំពុងបន្តអនុវត្តតាមបទប្បញ្ញត្តិជាធរមាន។<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន÷<br>▪ បន្តចរចា និងជំរុញប្រទេសឡាវ ធ្វើការសហការរៀបចំឱ្យមានកិច្ចព្រមព្រៀងដឹកជញ្ជូនអ្នកដំណើរ<br>▪ បន្តចរចា និងជំរុញឱ្យប្រទេសថៃ ធ្វើការសហការរៀបចំឱ្យមានកិច្ចព្រមព្រៀងដឹកជញ្ជូនទ្វេភាគី<br>▪ ជំរុញធ្វើយ៉ាងណាឱ្យការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ត្រីភាគីប្រកបដោយភាពរលូន និងឈានទៅអនុវត្តកិច្ចព្រមព្រៀងមហា-អនុតំបន់ទន្លេមេគង្គនាពេលខាងមុខដ៏ខ្លី<br>▪ បង្កើតប្រព័ន្ធស្វ័យប្រវត្តិកម្មផ្តល់សេវាសាធារណៈការចុះបញ្ជីយានជំនិះ បណ្ណបើកបរ ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសអាជីវកម្មដឹកជញ្ជូនក្នុងប្រទេស និងការចុះបញ្ជីក្រុមហ៊ុនដឹកជញ្ជូន<br>▪ បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវមជ្ឈមណ្ឌលបណ្តុះបណ្តាលបើកបរយានយន្តធុនធ្ងន់<br>▪ កំពុងធ្វើសមាហរណកម្មការចុះបញ្ជីផ្តល់បណ្ណសម្គាល់ និងផ្លាកលេខយានយន្តជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្ម របស់អគ្គនាយកដ្ឋាន | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | គយ និងរដ្ឋាករ អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។<br>- រដ្ឋបាលខេត្តស្វាយរៀង បានបំពាក់ម៉ាស៊ីនស្កេនកុងទីន័របន្ថែមនៅការិយាល័យគយ នៅច្រកទ្វារបាវិត។ | |
| - ពិចារណាបង្កើតប្រព័ន្ធលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនក្នុងស្រុកដែលនាំចេញទំនិញថ្មីៗ និងនាំចេញបានចំនួនច្រើនជាងគេ ដោយផ្តល់នូវរង្វាន់លើកទឹកចិត្តពិសេស និងរង្វាន់នានា សម្រាប់ក្រុមហ៊ុនដែលបាននាំទំនិញដល់ចំនួនដែលបានកំណត់តាមរយៈការវាយតម្លៃប្រកបដោយតម្លាភាព ដោយផ្សារភ្ជាប់នឹងគោលដៅនៃការអភិវឌ្ឍឧស្សាហកម្ម | ២០១៥ | - ក្រសួងពាណិជ្ជកម្ម÷<br>▪ បានលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យម ឱ្យបានចូលរួមតាំងពិព័រណ៍តាមរយៈការផ្តល់ជូនស្តង់ដោយឥតគិតថ្លៃ និងចូលរួមព្រឹត្តិការណ៍ពាណិជ្ជកម្មទាំងក្នុង និងក្រៅប្រទេស<br>▪ រៀបចំវេទិកាអភិវឌ្ឍកសិ-ពាណិជ្ជកម្មចំនួន ៧លើក (នៅខេត្តសៀមរាប បាត់ដំបង ប៉ៃលិន ព្រះសីហនុ) ដើម្បីជំរុញលើកទឹកចិត្តដល់ផលិតករ សិប្បករ កសិករ ខិតខំផលិត ទំនិញ និងសេវាសម្រាប់បម្រើឱ្យទីផ្សារក្នុងមូលដ្ឋាន។ ក្រសួងក៏បានរៀបចំកម្មវិធីជូនបណ្ណសរសើរដល់កសិករឆ្នើម និងពាណិជ្ជករគំរូដើម្បីលើកទឹកចិត្តឱ្យពួកគាត់បានចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មយ៉ាងពេញលេញ។<br>▪ បានបន្តសម្របសម្រួលដល់ក្រុមហ៊ុនបានទៅស្វែងរកដៃគូនៅក្រៅប្រទេស<br>▪ បានសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងទេសចរណ៍ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំជំនួបពាណិជ្ជកម្មរវាងអ្នកផលិត និងម្ចាស់ផ្សារទំនើបដើម្បីនាំយកផលិតផលខ្មែរ (ផលិតផលឆ្នើម) ដាក់លក់ក្នុងទីផ្សារទំនើបមានដូចជា ផ្សារអ៊ីអន ផ្សារឡាក់គី ផ្សារស៊ីធីម៉ល ។ល។ | - ក្រសួងពាណិជ្ជកម្ម÷<br>▪ រង់ចាំកញ្ចប់ថវិកាកម្មវិធីឆ្នាំ២០១៧<br>▪ ផលិតផលខ្មែរនៅមានកម្រិតទាំងគុណភាព និងសោភ័ណភាព មិនទាន់អាចឆ្លើយតបតាមតម្រូវការទីផ្សារទំនើបនៅឡើយ។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានលើកទឹកចិត្តដល់សហគ្រាសដែលផលិតផលិតផលថ្មីៗ បានដាក់តាំងបង្ហាញផលិតផលរបស់ខ្លួននូវមជ្ឈមណ្ឌលពាណិជ្ជកម្មនៅក្រៅប្រទេស។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម៖<br>ក្នុងឆ្នាំ២០១៧៖<br>▪ បានរៀបចំវគ្គបណ្តុះបណ្តាល និងកម្មវិធីនានាទាំងក្នុង និងក្រៅប្រទេស ដោយសហការជាមួយអង្គការផលិតភាពអាស៊ី (APO) ចំនួន ៦៩គម្រោង មានអ្នកចូលរួមចំនួន ៩៥១នាក់។<br>ក្នុងឆ្នាំ២០១៨៖<br>▪ បានរៀបចំវគ្គបណ្តុះបណ្តាល និងកម្មវិធីនានាទាំងក្នុង និងក្រៅប្រទេស ដោយសហការជាមួយអង្គការផលិតភាពអាស៊ី (APO) ចំនួន៥៧គម្រោង មានអ្នកចូលរួម ១,១៦៨នាក់<br>▪ បានផ្តល់ពានរង្វាន់ "ស៥" ចំនួន០៤ពានរង្វាន់ ដល់សហគ្រាសរោងចក្រ និងសិប្បកម្ម ដែលមកដល់បច្ចុប្បន្ន ពានរង្វាន់ "ស៥" នេះ ត្រូវបានផ្តល់ជូនក្រុមហ៊ុនសហគ្រាស រោងចក្រ និងសិប្បកម្មសរុបបានចំនួន ១៥ពានរង្វាន់។ | |
| - ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង ក៏ដូចជាពង្រឹងទំនាក់ទំនងជាមួយនឹងរាជរដ្ឋាភិបាល។ | ២០១៥<br>ទៅ<br>មធ្យម | - ក្រសួងពាណិជ្ជកម្ម៖<br>▪ បានទទួលចុះបញ្ជីតំកល់លក្ខន្តិកៈសមាគមបានចំនួន ១៤៦ គិតត្រឹមឆ្នាំ២០១៨ មានដូចជា សមាគមម៉ាស៊ីនកិនស្រូវ សមាគមស្វាយចន្ទី សមាគមជំឡូងមី សមាគមស្វាយ សមាគមគ្រឿងអលង្ការ សមាគមស្ករត្នោត ។ល។ | - ក្រសួងពាណិជ្ជកម្ម៖<br>▪ កង្វះធនធាន ទាំងធនធានមនុស្ស និងហិរញ្ញវត្ថុនៅមានកម្រិត<br>▪ កញ្ចប់ថវិកាតូច និងមានភាពយឺតយ៉ាវ។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានបង្កើតកម្មវិធីពង្រឹងសមត្ថភាពសមាគមអាជីវកម្មទាំងនោះ តាមរយៈការចូលរួមសិក្ខាសាលាបណ្តុះបណ្តាល និងការផ្លាស់ប្តូរទស្សនកិច្ចសិក្សាពីតំបន់មួយទៅតំបន់មួយ<br>▪ បានសហការជាមួយអង្គការ UNDP រៀបចំជាគម្រោងកម្មវិធីពង្រឹងសមត្ថភាពសមាគមជំឡូងមីកម្ពុជា<br>▪ បានរៀបចំបង្កើតសមាគមកីតម្បាញខ្មែរកោះដាច់ ម្រេចខេត្តកំពង់ធំ និងសមាគមដូងខេត្តតាកែវ។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | |
| *ខ-ការពង្រឹងបទដ្ឋានឧស្សាហកម្ម និងកម្មសិទ្ធិឧស្សាហកម្ម* | | | |
| - បន្តពង្រឹងក្របខ័ណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រងមាត្រាសាស្ត្រ និងស្តង់ដារដែលជាគ្រឹះសម្រាប់សកម្មភាពឧស្សាហកម្ម និងខិតខំប្រឹងប្រែងបន្តរៀបចំក្របខ័ណ្ឌគតិយុត្ត និងការទទួលស្គាល់ជាអន្តរជាតិនូវស្ថាប័នជាតិសំខាន់ៗ រួមមាន មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងវិទ្យាស្ថានស្តង់ដារកម្ពុជា | មធ្យម ទៅ វែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ បានបង្កើតស្តង់ដារចំនួន ៦៣ស្តង់ដារបន្ថែមទៀត ដូចជា÷ ស្តង់ដារម្ហូបអាហារ ១ ស្តង់ដារអគ្គិសនីនិងអេឡិចត្រូនិក ៣១ ស្តង់ដារគីមី ២ ស្តង់ដារសំណង់ ១៣ ស្តង់ដារផលិតផលពីឈើ ១២ និងស្តង់ដារប្រព័ន្ធគ្រប់គ្រង ៤<br>▪ បានកំណត់ស្តង់ដារជាតិចំនួន ១៤៨ស្តង់ដារ ជាបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា (លើផលិតផលម្ហូបអាហារ ផលិតផលអគ្គិសនី ផលិតផលយានយន្ត និងផលិតផលអគ្គិសនី និងអេឡិចត្រូនិក)<br>▪ បានទទួលធ្វើតេស្តវិភាគគំរូផលិតផលចំនួន ៥.៥៣៤គំរូផលិតផល (ទាំងផ្នែកគីមីសាស្ត្រ និងមីក្រូជីវសាស្ត្រ)។ មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មមានសមត្ថភាពធ្វើតេស្ត រហូតដល់ ១៥៨ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ប៉ារ៉ាម៉ែត្រ ដែលក្នុងនោះមាន ៥០ប៉ារ៉ាម៉ែត្រ ត្រូវបានទទួលការវាយតម្លៃទទួលស្គាល់ជាអន្តរជាតិអនុលោមតាមស្តង់ដារ ISO/IEC 170025។<br>ក្នុងឆ្នាំ២០១៨÷<br>▪ បានបង្កើតស្តង់ដារចំនួន ២៨ស្តង់ដារ ដែលក្នុងនោះមានស្តង់ដារអនុម័តទទួលយក តាមស្តង់ដារអន្តរជាតិ ISO ផ្នែកវិធីសាស្ត្រធ្វើតេស្តផលិតផលពីឈើចំនួន១១ស្តង់ដារ ផ្នែកប្រព័ន្ធគ្រប់គ្រងចំនួន០១ស្តង់ដារ អនុម័តទទួលយកតាមស្តង់ដារអន្តរជាតិ IEC ផ្នែកអគ្គិសនី និងអេឡិចត្រូនិចចំនួន១៥ស្តង់ដារ និងកែសម្រួលស្តង់ដារកម្ពុជា CS:548:2017 សម្រាប់បន្ថែមលើម្ហូបអាហារ។ គិតត្រឹមឆ្នាំ២០១៨ ក្រសួងបានបង្កើតស្តង់ដារសរុបចំនួន ៨៩៥ ស្តង់ដារ។<br>▪ បានចេញប្រកាសស្តីពីការបង្កើតស្តង់ដារជាតិរួមមាន ÷ ស្តង់ដារអំបិលអ៊ីយ៉ូត ស្តង់ដារកម្ពុជាផ្នែកសំណង់ និងសម្ភារៈសំណង់ចំនួន១០ស្តង់ដារ និងស្តង់ដារកម្ពុជាផ្នែកប្រព័ន្ធគ្រប់គ្រងចំនួន០៤ស្តង់ដារ<br>▪ បានទទួលធ្វើតេស្តវិភាគគំរូផលិតផលចំនួន៦.២៨១ គំរូផលិតផល (ផ្នែកមីក្រូជីវសាស្ត្រម្ហូបអាហារ និងទឹក គីមីសាស្ត្រទឹក គីមីសាស្ត្រម្ហូបអាហារ និងគីមីសាស្ត្រមិនមែនម្ហូបអាហារ)។ | |
| - កែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម តាមរយៈអនុវត្តនីតិវិធីធ្វើកិច្ចសហប្រតិបត្តិការ ផ្តល់សិទ្ធិចុះបញ្ជីដល់ភ្នាក់ងារនៃប្រទេស | ២០១៥ ទៅ មធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>ក្នុងឆ្នាំ២០១៧÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| ជាដៃគូនានា និងសម្រួលក្នុងការចុះបញ្ជីភ្នាក់ងារដែលប្រកបអាជីវកម្មធ្វើជាតំណាងរបស់អ្នកដាក់ពាក្យសុំក្នុងការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម ដោយផ្តោតការយកចិត្តទុកដាក់លើការធ្វើស្វ័យប្រវត្តិកម្មប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម | | ▪ បានផ្តល់ប្រកាសនីយបត្រតក្កកម្មចំនួន ២២, ចុះបញ្ជីគំនូរឧស្សាហកម្មចំនួន ៣១៣, ចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មពីសិង្ហបុរីចំនួន ១៨ និងទទួលពាក្យសុំចុះបញ្ជីវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ចំនួន ៥៣។<br>ក្នុងឆ្នាំ២០១៨÷<br>▪ បានផ្តល់ប្រកាសនីយបត្រតក្កកម្មចំនួន ៥១, ចុះបញ្ជីគំនូរឧស្សាហកម្មចំនួន ៩៨, និងទទួលពាក្យសុំចុះបញ្ជីវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ចំនួន ១៣។ | |
| - ពង្រឹងការប្រើប្រាស់ស្តង់ដារនីយកម្ម និងការវាយតម្លៃការទទួលស្គាល់អនុលោមភាពដោយផ្សារភ្ជាប់ទៅនឹងការធ្វើលទ្ធកម្មសាធារណៈ ការទទួលបានការលើកទឹកចិត្ត និងការជួយឧបត្ថម្ភផ្សេងៗ | ២០១៥ ទៅ មធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម៣ បានចេញប្រកាសស្តីពីការបង្កើតស្តង់ដារជាតិរួមមាន÷ ស្តង់ដារកម្ពុជាផ្នែកផលិតផលអគ្គិសនី និងអេឡិចត្រូនិច ចំនួន៩ស្តង់ដារ ស្តង់ដារកម្ពុជា CS:548:2017 សម្រាប់អំបិលអ៊ីយ៉ូដ ស្តង់ដារកម្ពុជាផ្នែកសំណង់ និងសម្ភារសំណង់ចំនួន១០ស្តង់ដារ និងស្តង់ដារកម្ពុជាផ្នែកប្រព័ន្ធគ្រប់គ្រងចំនួន ៤ស្តង់ដារ។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានពង្រឹងនិងអនុវត្តស្តង់ដារនីយកម្មលើវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។<br>- រដ្ឋបាលខេត្តកណ្តាល÷<br>▪ ក្នុងឆ្នាំ២០១៧ សហគ្រាសធុនតូចនិងមធ្យមចំនួន ០២មូលដ្ឋាន ទទួលបានវិញ្ញាបនបត្រប្រើប្រាស់សញ្ញាស្តង់ដារកម្ពុជា (CS)<br>▪ ក្នុងឆ្នាំ២០១៨ សហគ្រាសធុនតូច និងមធ្យមចំនួន ០៣មូលដ្ឋាន ទទួលបានវិញ្ញាបនបត្រប្រើប្រាស់សញ្ញាស្តង់ដារកម្ពុជា (CS) សរុប ០៥មូលដ្ឋាន កើន ០៣មូលដ្ឋានត្រូវជា ៦០%។ | - រដ្ឋបាលខេត្តកណ្តាល÷<br>▪ បញ្ហាប្រឈម÷ ផលិតផលចំណីអាហារ និងភេសជ្ជៈមួយចំនួន មិនទាន់មានគុណភាព សមស្របតាមស្តង់ដារ<br>▪ សំណើដំណោះស្រាយ÷ ជំរុញការផលិតប្រកបដោយគុណភាពស្របតាមស្តង់ដារ។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| - បង្កើនការយល់ដឹង និងធ្វើការផ្សព្វផ្សាយអំពីសារប្រយោជន៍នៃស្តង់ដារ មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម ដើម្បីជំរុញចូលរួមឱ្យបានទូលំទូលាយពីសំណាក់សហគ្រិន | ២០១៥<br>ទៅ<br>មធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>▪ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ បាននិងកំពុងបន្តពង្រឹងក្របខណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រងការងារមាត្រាសាស្ត្ររបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន សម្រាប់សកម្មភាពឧស្សាហកម្ម សេវាសាធារណៈ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងបានខិតខំប្រឹងប្រែងបន្តរៀបចំក្របខណ្ឌគតិយុត្តិ និងសិក្សាស្រាវជ្រាវរៀបចំនីតិវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ព្យាសកម្ម តេស្តវិភាគ និងអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រ ដែលបម្រើឱ្យវិស័យឧស្សាហកម្ម<br>▪ បានបង្កើនសមត្ថភាពមន្ទីរពិសោធន៍មាត្រាសាស្ត្រឱ្យទទួលបាន ISO/IEC 17025។ ឧបករណ៍មាត្រាសាស្ត្រចំនួន ៥៣៥គ្រឿងត្រូវបានធ្វើព្យាសកម្ម និង១៨៧គ្រឿង ត្រូវបានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ព្រមទាំងមូលដ្ឋានចំនួន ៣.២២៦ ត្រូវបានចុះបញ្ជីឧបករណ៍មាត្រាសាស្ត្រ។ អាជ្ញាបណ្ណមាត្រាសាស្ត្រ ០៩ ត្រូវបានចេញឱ្យផលិត និងជួសជុល និងអាជ្ញាបណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រចំនួន ១២ ត្រូវបានអនុញ្ញាត។<br>- រដ្ឋបាលខេត្តកណ្តាល÷<br>▪ ក្នុងឆ្នាំ២០១៧ បានធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីស្តង់ដារកម្ពុជា និងច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជាជូនម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្ម អាជីវកម្ម ១៤៥ មូលដ្ឋាន<br>▪ ក្នុងឆ្នាំ២០១៨ បានធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជាជូនម្ចាស់រោងចក្រ សហគ្រាស សិប្បកម្ម និងអាជីវកម្ម ចំនួន ២០៧ មូលដ្ឋាន កើន ៦២មូលដ្ឋាន ត្រូវជា ២៩.៩៥%។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - រដ្ឋបាលខេត្តស្វាយរៀង បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីវិសោធនកម្មច្បាប់ស្តីពីស្តង់ដារកម្ពុជា និងបទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងផលិតផលម្ហូបអាហារ សម្ភារៈសំណង់ អគ្គិសនី អេឡិចត្រូនិក និងសារធាតុគីមី ដល់ម្ចាស់រោងចក្រ សហគ្រាស សិប្បកម្ម និងអ្នកចែកចាយ ចំនួន ៨៩ នាក់។ | |
| - ជួយគាំទ្រលើកកម្ពស់សមត្ថភាពនិងសមត្ថកិច្ចមាត្រាសាស្ត្រ និងស្តង់ដារ ក្នុងការធានានូវបរិមាណ គុណភាព សុវត្ថិភាព សេវាកម្ម បរិស្ថាន និងគ្រប់គ្រង | មធ្យម ទៅ វែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានបង្កើតគោលការណ៍កំណត់ផលិតផលកម្ពុជាមានគុណភាពខ្ពស់ ដើម្បីជំរុញការប្រកួតប្រជែងក្នុងផលិតកម្ម ការលើកកម្ពស់គុណភាពផលិតផល និងការធ្វើពាណិជ្ជកម្មលើទីផ្សារផលិតផលកម្ពុជា។<br>- រដ្ឋបាលខេត្តកណ្តាល÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ បានចុះអធិការកិច្ច និងណែនាំដល់ម្ចាស់សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម ១០៧មូលដ្ឋាន ពីភាពត្រឹមត្រូវ និងសុច្ចរិតក្នុងការធ្វើអាជីវកម្មពីកម្មវិធីស៥ និងបរិស្ថានរោងផលិតកម្ម អនាម័យ និងគុណភាពផលិតផល<br>▪ បានយកសំណាកផលិតផល ចំណីអាហារនិងភេសជ្ជៈ៨មុខមាន ៨៦សំណាក<br>▪ ជំរុញការចុះបញ្ជីមាត្រាសាស្ត្រ បានចំនួន៤៦ មូលដ្ឋាន។ សរុបរោងចក្រ សហគ្រាសដែលបានចុះបញ្ជីមាន ៣៨២មូលដ្ឋាន។<br>▪ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ដៃបាញ់ប្រេងតាមស្ថានីយ និងដេប៉ូចែកចាយ ប្រេងឥន្ធនៈ ២១០កន្លែង មានដៃចំនួន ១ ១១៩។<br>ក្នុងឆ្នាំ២០១៨÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានចុះអធិការកិច្ច និងណែនាំដល់ម្ចាស់សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម ចំនួន ១៨៩មូលដ្ឋាន កើន ១០៣មូលដ្ឋាន<br>▪ បានយកសំណាកផលិតផលចំណីអាហារនិងភេសជ្ជៈ ១៩មុខ កើន ១១មុខ មាន ១៨៩សំណាក កើន ១០៣ សំណាក<br>▪ ជំរុញការដាក់ពាក្យស្នើសុំប្រើប្រាស់សារធាតុគីមីបានចំនួន៧មូលដ្ឋាន<br>▪ ជំរុញការចុះបញ្ជីផលិតផលបាន៨ក្រុមហ៊ុន<br>▪ ជំរុញការចុះបញ្ជីមាត្រាសាស្ត្របាន ១៦១ មូលដ្ឋាន កើនលើសឆ្នាំ ២០១៧ ចំនួន ១១៥មូលដ្ឋាន សរុប ៤៩៧មូលដ្ឋាន<br>▪ ត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ដៃបាញ់ប្រេងតាមស្ថានីយ និងដេប៉ូចែកចាយប្រេងឥន្ធនៈ ២២៩កន្លែង កើន ១៩កន្លែង។ មានដៃបាញ់ប្រេង ១២៦៩ កើន ១៥០។<br>- រដ្ឋបាលខេត្តស្វាយរៀង បានធ្វើបច្ចុប្បន្នភាពឧបករណ៍មាត្រាសាស្ត្របាន ៧៥ %។ | |
| - ចាត់វិធានការជាក់ស្តែងក្នុងការពង្រឹងការអនុវត្តស្តង់ដារ មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម ដើម្បីប្រែក្លាយក្របខ័ណ្ឌទាំងនេះឱ្យក្លាយជាឧបករណ៍សម្រាប់ជំរុញការប្រកួតប្រជែង | មធ្យម ទៅ វែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>ក្នុងឆ្នាំ២០១៧-២០១៨÷<br>▪ បានផ្សព្វផ្សាយអំពីសារប្រយោជន៍នៃស្តង់ដារ តាមរយៈសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានា<br>▪ បានកំណត់ស្តង់ដារជាតិចំនួន១៤៨ស្តង់ដារ ជាបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា (លើផលិតផលម្ហូបអាហារ ផលិតផលអគ្គិសនី ផលិតផលយានយន្ត និងអេឡិចត្រូនិក)។<br>- រដ្ឋបាលខេត្តកណ្តាល÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានចុះអធិការកិច្ច និងណែនាំដល់ម្ចាស់សហគ្រាសធុនតូច និងមធ្យមពីភាពត្រឹមត្រូវនិងសុច្ចរិតក្នុងការធ្វើអាជីវកម្មពីកម្មវិធីស៥ និងបរិស្ថានរោងផលិតកម្ម អនាម័យ និងគុណភាពផលិតផល<br>▪ បានចុះប្រមូលផលិតផលចំណីអាហារនិងភេសជ្ជៈយកទៅពិនិត្យគុណភាពនៅមន្ទីរពិសោធន៍ក្រសួងចំនួន៨ប្រភេទមាន ៨៦សំណាកផលិតផល កើនលើសឆ្នាំ២០១៦ ចំនួន១៨សំណាក ស្មើនឹង២៩,៥០%<br>▪ បានត្រួតពិនិត្យផ្ទៀងផ្ទាត់ដៃបាញ់ប្រេងតាមស្ថានីយ និងដេប៉ូលក់ប្រេងចំនួន ២១០កន្លែង មាន ១.១១៩ដៃ កើនលើស ឆ្នាំ២០១៦ ចំនួន ៤០១ដៃ ស្មើ ៥៧,២០%។<br>- រដ្ឋបាលខេត្តស្វាយរៀង÷<br>▪ បានយកគម្រូផលិតផលទៅវិភាគគុណភាព ចំនួន ៨៩ សំណាក ស្មើនឹង ៨៩ រោងចក្រ សហគ្រាស<br>▪ បានចុះផ្ទៀងផ្ទាត់ដៃបាញ់ប្រេងចំនួន ៦៥៤ គ្រឿង<br>▪ បានចុះធ្វើអធិការកិច្ចរោងចក្រ និងសិប្បកម្ម ចំនួន ៦៦ រោងចក្រលើការអនុវត្តក្បួនផលិតកម្មល្អ (GMP) និងអនាម័យល្អ (GHP)។ | |
| - ជួយគាំទ្រលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចរបស់ *"មជ្ឈមណ្ឌលផលិតភាពកម្ពុជា"* សំដៅលើកកម្ពស់ផលិតភាព និងគុណភាពដល់សហគ្រាសធុនតូច និងមធ្យម | មធ្យម ទៅ វែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>▪ មជ្ឈមណ្ឌលផលិតភាពកម្ពុជា បានប្រឹងប្រែងលើកកម្ពស់សមត្ថភាពរបស់ខ្លួនយ៉ាងសកម្ម តាមរយៈការបណ្ដុះបណ្ដាល និងសិក្ខាសាលានានា នៅប្រទេសសមាជិកអង្គការផលិតភាពអាស៊ីទាំង ១៩ប្រទេស ចំនួន ០២លើក និងមានមន្ត្រីចូលរួមចំនួន ០៦នាក់<br>▪ បានបំពេញសមត្ថកិច្ចរបស់ខ្លួន សំដៅលើកកម្ពស់ផលិតភាព និងគុណភាពដល់សហគ្រាសធុនតូច និងមធ្យម រោងចក្រ សហគ្រាស | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងចឡនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ឯកជន និងស្ថាប័នរដ្ឋ ដោយទទួលបានលទ្ធផលដូចតទៅ៖ បានជ្រើសរើសបេក្ខជនមកពីវិស័យឯកជន និងមន្ត្រីស្ថាប័នរដ្ឋចំនួន ៩៥១នាក់ ឱ្យចូលរួមកម្មវិធីវគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រលើកកម្ពស់ផលិតភាពរបស់អង្គការផលិតភាពអាស៊ី និងអង្គភាពផលិតភាពជប៉ុន គឺមានការកើនឡើងប្រមាណជា ៨០% ធៀបទៅនឹងឆ្នាំ ២០១៦។ | |
| - ពង្រឹងសមត្ថភាព *"វិទ្យាស្ថានស្តង់ដារកម្ពុជា"* ក្នុងការសិក្សាស្រាវជ្រាវរៀបចំស្តង់ដារជាតិ សម្រាប់ផលិតផល សេវាកម្ម ផលិតកម្ម និងបច្ចេកទេស អនុលោមតាមស្តង់ដារតំបន់ និងអន្តរជាតិ | មធ្យម ទៅ វែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | |
| - ពង្រឹងសមត្ថភាពមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ក្នុងការសិក្សាស្រាវជ្រាវរៀបចំនីតិវិធីត្រួតពិនិត្យផ្ទៀងផ្ទាត់ ព្យាលកម្ម តេស្តវិភាគ និងការអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រដែលបម្រើឱ្យការអភិវឌ្ឍវិស័យឧស្សាហកម្ម | មធ្យម ទៅ វែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម៖<br>▪ ក្នុងឆ្នាំ២០១៧ បានបង្កើនសមត្ថភាពមន្ទីរពិសោធន៍មាត្រាសាស្ត្រ ឱ្យទទួលបាន ISO/IEC 17025។ ឧបករណ៍មាត្រាសាស្ត្រចំនួន ៥៣៥គ្រឿងត្រូវបានធ្វើព្យាលកម្ម និង ១៨៧គ្រឿង ត្រូវបានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ព្រមទាំងមូលដ្ឋានចំនួន ៣.២២៦ ត្រូវបានចុះបញ្ជីឧបករណ៍មាត្រាសាស្ត្រ។ អាជ្ញាបណ្ណមាត្រាសាស្ត្រ ០៩ ត្រូវបានចេញឱ្យផលិត និងជួសជុល និងអាជ្ញាបណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រ ចំនួន ១២ ត្រូវបានអនុញ្ញាត។<br>▪ ក្នុងឆ្នាំ២០១៨ ឧបករណ៍មាត្រាសាស្ត្រចំនួន ៦៤៦គ្រឿងត្រូវបានធ្វើព្យាលកម្ម និង ៧៦៣គ្រឿង ត្រូវបានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់។ | |
| *ត-ការសម្រួលការបំពេញកាតព្វកិច្ចពន្ធ និងអាករ* | | | |

| **វិធានការគោលនយោបាយ/ផែនការសកម្មភាព** | ***រយៈពេល/ឆ្នាំ*** | **ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព** | **ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)** |
| --- | --- | --- | --- |
| - សិក្សាឡើងវិញពីប្រព័ន្ធពន្ធដារ និងពន្ធគយ ដោយប្រែក្លាយឱ្យទៅជាឧបករណ៍ប្រមូលចំណូលផង និងជាឧបករណ៍ជំរុញការអភិវឌ្ឍឧស្សាហកម្មផង | មធ្យម ទៅ វែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បាននិងកំពុងចូលរួមអនុវត្តតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមយុទ្ធសាស្ត្រពាក់ព័ន្ធនានាជាធរមាន<br>▪ បានពិនិត្យលទ្ធភាពក្នុងការធ្វើវិចារណកម្មកែសម្រួលពន្ធអាករលើមុខទំនិញមួយចំនួនស្របតាមស្ថានភាពបច្ចុប្បន្ន<br>▪ បានសិក្សាស្រាវជ្រាវ និងរៀបចំយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣<br>▪ បានពិនិត្យឡើងវិញនូវប្រព័ន្ធពន្ធ និងអាករលើផលិតផលសំខាន់មួយចំនួន ដែលជាធាតុចូលនៃការរៀបចំទស្សនាទានស្តីពីការកែសម្រួលគោលនយោបាយសារពើពន្ធ។ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷<br>▪ ការចែករំលែកទិន្នន័យរវាងស្ថាប័នពាក់ព័ន្ធនៅតែមានកម្រិត។ |
| - ធ្វើវិចារណកម្មយន្តការប្រមូលចំណូល និងកែលម្អសេវាអ្នកជាប់ពន្ធ សំដៅលើកកម្ពស់វប្បធម៌បង់ពន្ធ ក្នុងចំណោមសហគ្រាស និងអ្នកជាប់ពន្ធគ្រប់ប្រភេទ | ២០១៥ ទៅ មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានបន្តធ្វើទំនើបភាវូបនីយកម្ម (Modernization) យន្តការពន្ធដាររួមទាំងយន្តការប្រមូលចំណូល តាមរយៈការធ្វើវិចារណកម្ម និងការគាំទ្រដោយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយបានរៀបចំប្រព័ន្ធ និងកម្មវិធីគ្រប់គ្រង ប្រមូលពន្ធ និងផ្តល់សេវាដល់អ្នកជាប់ពន្ធ ចំនួនប្រមាណ ៣៧ ដែលក្នុងនោះមានទាំងការប្រកាសដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ (E-filling and E-Payment)<br>▪ បានផ្តល់ការពិគ្រោះយោបល់ និងបំភ្លឺអ្នកជាប់ពន្ធ ជាលាយលក្ខណ៍អក្សរ តាមរយៈCALL CENTER តាម LIVE CHAT តាម Email តាមបណ្តាញទំនាក់ទំនងសង្គម បញ្ជរពិគ្រោះយោបល់ និងប្រអប់ពិគ្រោះយោបល់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានរៀបចំសេចក្តីព្រាងផែនការប្រតិបត្តិឆ្នាំ ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ ដោយមានបញ្ចូលសកម្មភាពដែលត្រូវអនុវត្តដើម្បីបន្តកែលម្អសេវាអ្នកជាប់ពន្ធ។ | |
| - បង្កើនការផ្តល់សេវាដើម្បីឱ្យអ្នកជាប់ពន្ធងាយស្រួលទទួលព័ត៌មានពីការបង់ពន្ធ និងការលើកលែងពន្ធ | ២០១៩ ទៅ មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានបង្កើតមជ្ឈមណ្ឌលផ្តល់ព័ត៌មាន (Call Center) ដើម្បីឆ្លើយតបនឹងការសាកសួរតាមទូរស័ព្ទពីអ្នកជាប់ពន្ធ និងការពិភាក្សាផ្សាយផ្ទាល់ (GDT Live Chat) ព្រមទាំង ព័ត៌មាន (GDT News) ដើម្បីផ្តល់ព័ត៌មានជូនអ្នកជាប់ពន្ធឱ្យបានកាន់តែប្រសើរ<br>▪ បង្កើតកម្រងសៀវភៅសំណួរចម្លើយដែលសួរញឹកញាប់ (FAQs) ដើម្បីគាំទ្រ Call Center<br>▪ បានរៀបចំការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធតាមធនាគារ និងកំពុងរៀបចំប្រព័ន្ធអេឡិចត្រូនិកសម្រាប់ការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធផងដែរ។ | |
| - ជំរុញការបង្វិលសងឱ្យបានឆាប់ ឬប្រើប្រាស់ជាឥណទានយោង (Tax Credit) ស្របតាមបទប្បញ្ញត្តិពន្ធដារជាធរមាន | មធ្យម ទៅ វែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានកាត់បន្ថយរយៈពេលបង្វិលសងបានឆាប់រហ័សជាងមុន (និងឈានទៅរកការបង្វិលសងត្រឹមរយៈពេល៤៥ថ្ងៃ)<br>▪ បានពង្រឹងយន្តការបង្វិលសងតាមរយៈការរៀបចំយន្តការវាយតម្លៃអនុលោមភាពរបស់អ្នកជាប់ពន្ធ<br>▪ បានពង្រឹងយន្តការបង្វិលសង តាមរយៈយន្តការវាយតម្លៃអនុលោមភាពរបស់អ្នកជាប់ពន្ធ (ប្រកាសលេខ ១៥៣៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែធ្នូឆ្នាំ២០១៦ ស្តីពីចំណាត់ថ្នាក់នៃអនុលោមភាពសារពើពន្ធ) | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷<br>▪ ទាមទារឱ្យមានការត្រួតពិនិត្យសក្ខីបត្រច្បាស់លាស់<br>▪ ដំណោះស្រាយ÷ ពង្រឹង និងពង្រីក ព្រមទាំងបង្កើនល្បឿនបង្វិលសង។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានបង្កើតការិយាល័យបង្វិលសងអាករលើតម្លៃបន្ថែម (ប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃ ទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ អគ្គនាយកដ្ឋានពន្ធដារ)។ | |
| - ពិនិត្យ និងសម្រួលឡើងវិញនូវក្របខ័ណ្ឌនៃការអនុវត្ត ដោយសម្រួល ឬដកចេញនូវយន្តការទាំងឡាយណាដែលបណ្តាលឱ្យខ្ទាស់គ្នារវាងនីតិវិធីនៃការយកពន្ធ និងការលើកលែងពន្ធ។ | ២០១៥ ទៅ មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានបន្តកិច្ចសហការក្នុងចំណោមស្ថាប័ន/អង្គភាពពាក់ព័ន្ធជាពិសេស ពាក់ព័ន្ធនឹងការផ្លាស់ប្តូរទិន្នន័យ ការលើកទឹកចិត្តពន្ធអាករ និង ការកសាងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ<br>▪ បានកែសម្រួលសមាសភាពក្រុមការងារកិច្ចសហប្រតិបត្តិការរវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ<br>▪ បន្តអនុវត្តប្រកាសលេខ៥១៨ សហវ.ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០១៧ ស្តីពីការណែនាំអនុវត្តពន្ធកាត់ទុកលើការបែងចែកភាគលាភ<br>▪ ប្រកាសលេខ ៥៧៧ សហវ.ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីវិធាននិងនីតិវិធីសម្រាប់អនុវត្តពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេស ត្រូវបានដាក់ឱ្យអនុវត្ត<br>▪ បានចូលរួមរៀបចំបទប្បញ្ញត្តិទាក់ទិននឹងសម្រួល ឬដកចេញនូវយន្តការទាំងឡាយណាដែលបណ្តាលឱ្យខ្ទាស់គ្នារវាងនីតិវិធីនៃការយកពន្ធការលើកលែងពន្ធ។ | |
| *ឃ-ការរៀបចំទីផ្សារពលកម្ម និងទំនាក់ទំនងវិជ្ជាជីវៈ* | | | |
| - បន្តពង្រឹងយន្តការទំនាក់ទំនងត្រីភាគី រួមមាន រដ្ឋាភិបាល និយោជក និងនិយោជិត តាមរយៈ *"គណៈកម្មការប្រឹក្សាការងារ"* ដើម្បីបង្កើនការយោគយល់គ្នា ទន្ទឹមនឹងការខិតខំរៀបចំប្រព័ន្ធ | ២០១៥ ទៅ មធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានបន្តពង្រឹងយន្តការគណៈកម្មការប្រឹក្សាការងារដែលជាយន្តការត្រីភាគី ក្នុងការចរចាប្រាក់ឈ្នួលអប្បបរមា, អត្ថប្រយោជន៍ផ្សេងៗ, និងលក្ខខណ្ឌការងារដោយ÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| យន្តការមួយប្រកបដោយប្រសិទ្ធភាពសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមា ដែលស៊ីចង្វាក់ទៅនឹងផលិតភាពការងារ សមស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច-សង្គម និងធានាបាននូវការអភិវឌ្ឍឧស្សាហកម្មជារួម | | ▪ បានរៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាការងារអាណត្តិទី៨ សរុបចំនួន ៦លើក ក្នុងឆ្នាំ២០១៧ និងចំនួន ១១លើក ក្នុងឆ្នាំ២០១៨ ដើម្បីពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមា ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យផ្អែកសង្គម (ស្ថានភាពគ្រួសារ អត្រាអតិផរណា និងការចំណាយក្នុងការរស់នៅ) និងផ្អែកសេដ្ឋកិច្ច (ផលិតភាព ភាពប្រកួតប្រជែងរបស់ប្រទេស ស្ថានភាពទីផ្សារការងារ និងកម្រិតចំណេញរបស់វិស័យ)។ ជាលទ្ធផល គណៈកម្មការបានកំណត់ប្រាក់ឈ្នួលអប្បបរមាប្រកបដោយភាពសុខដុម និងស្របតាមកាលវិភាគដែលត្រីភាគីបានឯកភាពសម្រាប់ឆ្នាំ២០១៨ មានចំនួន ១៧០ដុល្លារ/ខែ និងឆ្នាំ២០១៩ ចំនួន ១៨២ដុល្លារ/ខែ។<br>▪ បានបន្តបង្កើតក្រុមការងារបច្ចេកទេសត្រីភាគី ដែលមានតំណាង ១៦រូបស្មើៗគ្នា ពីភាគីរាជរដ្ឋាភិបាល, ពីភាគីនិយោជក និងពីភាគីកម្មករនិយោជិត ដើម្បីសម្រួលដល់ការពន្យល់ និងបកស្រាយអំពីលក្ខណៈវិនិច្ឆ័យ និងប្រភពទិន្នន័យដល់ភាគីពាក់ព័ន្ធដែលធ្វើឱ្យការចរចាប្រាក់ឈ្នួលអប្បបរមា ក្លាយទៅជាយន្តការបច្ចេកទេសពិតប្រាកដដោយផ្អែកលើលក្ខណៈវិទ្យាសាស្ត្រ ស្ថិតិ និងរូបមន្តច្បាស់-លាស់ស្របតាមគោលការណ៍សកល<br>▪ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ក្នុងឆ្នាំ២០១៧ និងទទួលបានការអនុម័ត និងប្រកាសឱ្យប្រើកាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៨ ដោយបានបញ្ចូលនូវគោលការណ៍ទាំង៥, លក្ខណៈវិនិច្ឆ័យទាំង៧, និងកាលវិភាគនៃការចរចាប្រាក់ឈ្នួលអប្បបរមា ដែលជាលទ្ធផលនៃសិក្ខាសាលាត្រីភាគីថ្នាក់ជាតិកាលពី | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ខែមេសា ឆ្នាំ២០១៤ និងយន្តការត្រីភាគីដែលមានសំឡេងស្មើៗគ្នាចូលនៅក្នុងច្បាប់<br>▪ បានបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមាដោយរៀបចំសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីលើសេចក្តីព្រាងច្បាប់នេះចំនួន ០២លើកក្នុង ឆ្នាំ២០១៧ និងចំនួន ០២លើក ក្នុងឆ្នាំ២០១៨ និងបានរៀបចំកិច្ចប្រជុំអន្តរក្រសួងចំនួន ០២លើក ក្នុងឆ្នាំ២០១៨ ដើម្បីទទួលធាតុចូលបន្ថែម មុនដាក់ជូនរដ្ឋសភាអនុម័ត ហើយដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៨<br>▪ បានពង្រឹងសមត្ថភាព និងការយល់ដឹងរបស់សមាជិកត្រីភាគីនៃគណៈកម្មការប្រឹក្សាការងារ ដោយធ្វើការសហការជាមួយអង្គការអន្តរជាតិខាងការងារ ក្នុងការរៀបចំនូវវគ្គបណ្តុះបណ្តាល<br>▪ បានសហការជាមួយអង្គការអន្តរជាតិខាងការងារ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៣លើក ដើម្បីពង្រឹងសមត្ថភាពវិភាគលើបម្រែបម្រួលនៃលក្ខណៈវិនិច្ឆ័យ ដល់សមាជិក និងមន្ត្រីលេខាធិការដ្ឋានគណៈកម្មការប្រឹក្សាការងារ ព្រមទាំងរៀបចំសិក្ខាសាលាចំនួន ២លើក ក្នុងឆ្នាំ២០១៨ ដើម្បីចែករំលែកបទពិសោធន៍ស្តីពីប្រព័ន្ធប្រាក់ឈ្នួលអប្បបរមានៅបណ្តាប្រទេសផ្សេងៗ និងសិក្សាពីប្រព័ន្ធតាមដានប្រាក់ឈ្នួលអប្បបរមា<br>▪ បានយកចិត្តទុកដាក់ការលើកកម្ពស់ការយល់ដឹងដល់កម្មករនិយោជិត សិស្ស-និស្សិត និងសាធារណជន អំពីយន្តការ និងលក្ខណៈវិនិច្ឆ័យក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជាតាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយបានចំនួន ៣២លើក | |

| វិធានការគោលនយោបាយ/ផែនការ សកម្មភាព | រយៈពេល/ ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ដែលមានអ្នកចូលរួមចំនួន ១ម៉ឺន៤ពាន់នាក់ ការបោះពុម្ពផ្សព្វផ្សាយសៀវភៅ និងរបាយការណ៍ចំនួន ៥ ៥០០ច្បាប់ និងខិត្តបណ្ណនានាចំនួន ១៣ ០០០ច្បាប់ ព្រមទាំងផលិតវីដេអូ ស៊ីឌីចំនួន ៤ ០០០ ស៊ីឌី។<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ | |
| - ផ្តួចផ្តើមឱ្យមានការសិក្សាស្រាវជ្រាវទៅលើទំនាក់-ទំនងរវាងបុគ្គលិកនិយោជិត និងនិយោជក ដើម្បីកំណត់ពីបទពិសោធន៍ល្អៗក្នុងការស្វែងរកដំណោះស្រាយជាប្រព័ន្ធមួយដែលអាចបង្កើនផលិតផលសរុប ជាពិសេសការបណ្តុះបណ្តាលអាជីពក្នុងការដោះស្រាយបញ្ហារបស់កម្មករ ស្របទៅតាមច្បាប់ការងារ និងបទប្បញ្ញត្តិជាធរមាន | ២០១៥ ទៅ មធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានរៀបចំវេទិកាសហជីពនៅថ្ងៃទិវាពលកម្មអន្តរជាតិ ១ឧសភា ឆ្នាំ២០១៧ និងបានពង្រីកវេទិកានេះពី ១លើក ទៅ ២លើក ក្នុងមួយឆ្នាំ នៅឆ្នាំ២០១៨<br>▪ បានរៀបចំប្រជុំជាទៀងទាត់នៃក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ (ក្រុមការងារទី៨) ដោយបានដោះស្រាយបញ្ហាការទូទាត់ប្រាក់បំណាច់អតីតភាពការងារ និងពន្យល់អំពីនីតិវិធីនៃការទូទាត់ប្រាក់បំណាច់អតីតភាពការងារ<br>▪ បានរៀបចំបង្កើតវិទ្យាស្ថានជាតិការងារ ក្នុងឆ្នាំ២០១៨ ដើម្បីសិក្សាស្រាវជ្រាវលើវិស័យការងារ, បណ្តុះបណ្តាលកម្មករនិយោជិត រដ្ឋ-បាលរោងចក្រ សហគ្រាស អំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាមួយនឹងវិស័យការងារ និងអភិវឌ្ឍសមត្ថភាពមន្ត្រី<br>▪ បានពង្រឹង និងពង្រីកសមត្ថភាពមន្ត្រីផ្សះផ្សាវិវាទ ដោយសហការជាមួយអង្គការអន្តរជាតិខាងការងារ បានចំនួន ៣វគ្គ សិក្ខាកាមចំនួន ១១៩នាក់ ក្នុងឆ្នាំ២០១៧<br>▪ បានផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ជាមួយគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) និងក្រុមប្រឹក្សាអាជ្ញាកណ្តាល | - រដ្ឋបាលខេត្តស្វាយរៀង÷<br>▪ កង្វះការចូលរួមសហការពីភាគីពាក់-ព័ន្ធ តួយ៉ាងសហគ្រាស គ្រឹះស្ថានមួយចំនួននៅតែអនុវត្តច្បាប់ស្តីពីការងារមិនទាន់បានល្អ និងកង្វះការយកចិត្តទុកដាក់លើការងារសុខភាពអនាម័យ និងសុវត្ថិភាពការងារដល់កម្មករ និយោជិត។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | អំពីមូលហេតុនៃជម្លោះ វិវាទការងារ និងសិល្បៈនៃការផ្សះផ្សាវិវាទការងារ។<br>- រដ្ឋបាលខេត្តស្វាយរៀង បានពង្រឹងសុខដុមនីកម្មនៃទំនាក់ទំនងវិជ្ជាជីវៈតាមរយៈការផ្សះផ្សាវិវាទបុគ្គល និងរួម ក្នុងនោះបានផ្សះផ្សាវិវាទបុគ្គល ០៧ ករណី ជាសះ ០១ ករណី និង វិវាទរួម០៨ ករណី ជាសះ ០៨ករណី (កូដកម្ម)។ | |
| - រៀបចំច្បាប់ស្តីពីសហជីពនិងច្បាប់ស្តីពីតុលាការការងារ | ២០១៥ ទៅ មធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បន្តពង្រឹងប្រសិទ្ធភាពការអនុវត្តច្បាប់ស្តីពីសហជីពដោយ÷<br>- បានចេញប្រកាសចំនួន ៤ ក្នុងឆ្នាំ២០១៨÷ ១. នីតិវិធីនៃការបង់ប្រាក់ភាគទានសហជីព និងប្រាក់សេវាភ្នាក់ងារ, ២.បែបបទនៃការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុរបស់សហជីព ឬសមាគមនិយោជក, ៣. ប្រតិភូបុគ្គលិកនៅក្នុងសហគ្រាស គ្រឹះស្ថាន, និង ៤. ភាពជាតំណាងបំផុតនៃសហជីព និងបែបបទនីតិវិធីដើម្បីទទួលបានភាពជាតំណាងបំផុត<br>- បានចេញសេចក្តីណែនាំ ស្តីពីការសម្រួលនីតិវិធី និងបែបបទក្នុងការចុះបញ្ជីសហជីព ក្នុងឆ្នាំ២០១៨។<br>▪ បានរៀបចំសិក្ខាសាលាត្រីភាគីចំនួន ១លើក ក្នុងឆ្នាំ២០១៧ និងបានបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីជម្រះក្តីវិវាទការងារ នៅខែកញ្ញា ឆ្នាំ២០១៧ និងបានសម្រេចបញ្ចប់រៀបចំសេចក្តីព្រាងច្បាប់នេះនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ ដោយផ្អែកលើសំណើរបស់ដៃគូពាក់ព័ន្ធ។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| - ពង្រឹងយន្តការចុះធ្វើអធិការកិច្ចលក្ខខណ្ឌការងារ តាមរយៈការពង្រីកកម្មវិធីរោងចក្រល្អប្រសើរ ឬពិនិត្យលទ្ធភាពក្នុងការបង្កើតក្រុមការងារចម្រុះធ្វើអធិការកិច្ចជាប្រចាំ និងមានកម្មវិធីច្បាស់លាស់ ដើម្បីកាត់បន្ថយចំនួនត្រួតពិនិត្យផង និងធានាបានប្រសិទ្ធភាពក្នុងការត្រួតពិនិត្យផង។ ក្រុមការងារចម្រុះនេះត្រូវរាយការណ៍ជាទៀងទាត់ជូនរាជរដ្ឋាភិបាល | ២០១៥ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានបន្តពង្រឹងយន្តការក្រុមអធិការកិច្ចការងារតែមួយ ដោយប្រធាប់បញ្ចូលគ្នាការធ្វើអធិការកិច្ចផ្សេងៗគ្នា របស់អង្គភាពចំនួន ៨, ប្រើប្រាស់បទដ្ឋានវាយតម្លៃតែមួយ, និងចុះធ្វើអធិការកិច្ចក្នុងពេលតែមួយ សំដៅកាត់បន្ថយបន្ទុករបស់ម្ចាស់សហគ្រាស គ្រឹះស្ថាន និងធានាប្រសិទ្ធភាព និងអនុលោមភាពតាមច្បាប់<br>▪ បានធ្វើទំនើបកម្មប្រព័ន្ធអធិការកិច្ចការងារ ដោយបញ្ចូលបញ្ជីត្រួតពិនិត្យរបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាជាមួយរបាយការណ៍ស្តីពីអធិការកិច្ចការងាររបស់ក្រសួង, មានប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងរបាយការណ៍ស្តីពីអធិការកិច្ចការងារតាមប្រព័ន្ធព័ត៌មានវិទ្យា<br>▪ បានបន្តពង្រឹងគុណភាព និងប្រសិទ្ធភាពអធិការកិច្ចការងារដោយផ្អែកលើការគ្រប់គ្រងហានិភ័យ តាមរយៈការសិក្សា វិភាគ និងកំណត់ចំណាត់ថ្នាក់នៃប្រភេទសហគ្រាស គ្រឹះស្ថានដែលជាគោលដៅប្រឈម ឬងាយប្រឈមទៅនឹងការរំលោភបំពានលក្ខខណ្ឌការងារ<br>▪ បានបន្តពង្រឹងក្រមសីលធម៌របស់មន្ត្រីអធិការកិច្ចការងារដោយរៀបចំ និងដាក់ឱ្យអនុវត្ត សៀវភៅណែនាំ (Guidelines) ស្តីពីអធិការកិច្ចការងារ និងសៀវភៅក្រមសីលធម៌សម្រាប់មន្ត្រីអធិការកិច្ចការងារ<br>▪ បានបណ្តុះបណ្តាលមន្ត្រីអធិការកិច្ចការងារ អំពីរបាយការណ៍អធិការកិច្ចការងារថ្មីចំនួន៤វគ្គ ស្មើនឹងចំនួន ៥៣៣នាក់ និងបាន | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | បញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលស្តីពីសុវត្ថិភាពនិងសុខភាពការងារ ចំនួន ៥៤នាក់ ក្នុងឆ្នាំ២០១៨<br>▪ បានបង្កើនការយល់ដឹងអំពីតួនាទី និងភារកិច្ចអធិការកិច្ចការងារតាមរយៈការផលិត និងការផ្សព្វផ្សាយស្ពតវីដេអូចំនួន ៣ភាគ និងខិត្តបណ្ណ ចំនួន ៤ ០០០ច្បាប់<br>▪ ជាលទ្ធផលនៃការពង្រឹងយន្តការអធិការកិច្ចការងារនាពេលកន្លងមកនេះ ចំនួនអធិការកិច្ចការងារបានថយចុះពីចំនួន ៩ ៧១៧លើក ក្នុងឆ្នាំ២០១៧ ទៅ ៩ ៣៥០លើក ក្នុងឆ្នាំ២០១៨ (ថយចុះ ៣,៨% ធៀបឆ្នាំ២០១៧) ខណៈដែលចំនួននៃវិវាទការងារសរុបបានថយចុះប្រមាណជា ៩,៦% ក្នុងរយៈពេលដូចគ្នានេះ។<br>- រដ្ឋបាលខេត្តព្រះសីហនុ÷<br>▪ បានជំរុញ និងណែនាំជាប្រចាំដល់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យបន្តចុះធ្វើអធិការកិច្ចតាមបណ្តារោងចក្រសហគ្រាសនៅក្នុងខេត្ត។ ការចុះធ្វើអធិការកិច្ចការងារ និងការចាត់វិធានការចំពោះសហគ្រាសដែលប្រព្រឹត្តល្មើសច្បាប់សរុបចំនួន ១៧៩លើក ក្នុងនោះការធ្វើអធិការកិច្ចសាមញ្ញចំនួន ៨៧លើក ការចុះធ្វើអធិការកិច្ចពិសេសចំនួន ៨០លើក និងការចុះពិនិត្យរបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការអន្តរជាតិខាងការងារ (ILO-BFC) ចំនួន ១២លើក។ សរុបសហគ្រាស គ្រឹះស្ថានកាត់ដេរមានចំនួន ៥៣ មានកម្មករនិយោជិតសរុបចំនួន ២១.៤៨២នាក់ (ស្រី ១៧.០៥៣) និងសហគ្រាស គ្រឹះស្ថានក្រៅពីកាត់ដេរមានចំនួន ៦៧១ មានកម្មករនិយោជិតសរុបចំនួន ៣៤.៦៦១នាក់។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - រដ្ឋបាលខេត្តស្វាយរៀង÷ បានចុះអធិការកិច្ចដើម្បីកែលម្អលក្ខខណ្ឌការងារលើកកម្ពស់ការងារអនាម័យ សុខភាព និងសុវត្ថិភាពការងារ នៅតាមសហគ្រាស គ្រឹះស្ថាន ក្នុងនោះបានចុះអធិការកិច្ចសាមញ្ញ ១៧ សហគ្រាស ចុះអធិការកិច្ចពិសេស ១៧ សហគ្រាស និងបានបន្តចុះអធិការកិច្ច តាមបណ្តាសហគ្រាសឱ្យបាន ៥ លើក ក្នុងមួយខែ។ | |
| - ពង្រឹងយន្តការគ្រប់គ្រងការជ្រើសរើសកម្លាំងពលកម្ម ការផ្តល់ព័ត៌មានពីទីផ្សារពលកម្ម និងការបណ្តុះបណ្តាលកម្មករឱ្យយល់ដឹងពីជីវភាព និងសិទ្ធិស្របច្បាប់របស់ខ្លួន ពិសេស កាត់បន្ថយការចំណាយហួសហេតុក្នុងការទទួលបានការងារ | ២០១៥ ទៅ មធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជាតិមុខរបរ និងការងារ÷<br>▪ បានពង្រីកការផ្តល់សេវាការងារទូទាំងប្រទេសដោយបានប្រមូលផ្សព្វផ្សាយព័ត៌មានអំពីឱកាសការងារចំនួនប្រមាណ ១៨ម៉ឺនកន្លែង, បានចុះឈ្មោះអ្នកស្វែងរកការងារចំនួនជាង ៣ម៉ឺននាក់, និងបានជួយស្វែងរកការងារជូនប្រជាពលរដ្ឋចំនួនជិត១ម៉ឺននាក់ ដែលមានការកើនឡើងជាបន្តបន្ទាប់ធៀបនឹងឆ្នាំមុនៗ ដោយសារការពង្រីកមជ្ឈមណ្ឌលការងារដល់ចំនួន ១៤ (មជ្ឈមណ្ឌលការងារចល័តចំនួន១) ការកើនឡើងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការផ្តល់សេវា ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវា ការយល់ដឹង និងការទុកចិត្តកាន់តែកើនឡើងពីនិយោជក និងអ្នកស្វែងរកការងារ<br>▪ បានពង្រឹង និងពង្រីកយន្តការ "វេទិកាការងារ" ដោយរៀបចំពិព័រណ៍ការងារ ទិវាជ្រើសរើស កម្លាំងពលកម្មថ្នាក់ជាតិ និងនៅតាមមូលដ្ឋាន សរុបចំនួន ៤៥៣លើក ដែលមានអ្នកចូលរួមសរុបជាង ១៨ម៉ឺននាក់ ដែលមានការកើនឡើងជាបន្តបន្ទាប់ជាងឆ្នាំមុនៗ ដោយសារការបង្កើនការផ្សព្វផ្សាយ និងការជឿទុកចិត្តលើគុណភាពសេវា | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានពង្រីកការផ្ដល់ព័ត៌មានទីផ្សារការងារតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ដោយមានអ្នកចូលប្រើគេហទំព័រកើនឡើងដល់ប្រមាណ ១១លានដង, Facebook ប្រមាណ ១០ម៉ឺននាក់, YouTube ជិត ៩ម៉ឺននាក់ និងកម្មវិធីសម្រាប់ទូរស័ព្ទស្មាតហ្វូនចំនួនជិត ៦ពាន់នាក់។<br>- រដ្ឋបាលខេត្តស្វាយរៀង÷<br>▪ បានណែនាំសហគ្រាសគ្រឹះស្ថាន ឱ្យផ្ដល់ព័ត៌មានស្ដីពីប៉ុស្ដិ៍ការងារទំនេរ រៀងរាល់ខែដល់មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តស្វាយរៀង<br>▪ គិតមកដល់ឆ្នាំ ២០១៨ ខេត្តស្វាយរៀងមាន រោងចក្រ សហគ្រាសគ្រឹះស្ថាន ១៦០ ទីតាំង ដែលមានកម្មករ និយោជិតខ្មែរ ៦៨.១៣៤ នាក់ ស្រី៤៣.៧២៩នាក់។ | |
| - លើកកម្ពស់សុខុមាលភាពរបស់កម្មករ តាមរយៈការជំរុញអនុវត្តគោលនយោបាយលំនៅឋានសម្រាប់កម្មករ ដែលអនុញ្ញាតឱ្យពួកគេ អាចមានលទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅឋានសម្រាប់បង្កើតគ្រួសារ និងមិនធ្វើការផ្លាស់ប្ដូរទីលំនៅញឹកញាប់ពេក ដែលបង្កើតបញ្ហាខ្វះកម្លាំងពលកម្មក្នុងរយៈពេលខ្លី | មធ្យម ទៅ វែង | - ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានសហការ និងផ្ដល់ធាតុចូលដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធ្វើគោលនយោបាយ និងកំណត់លក្ខណៈវិនិច្ឆ័យដល់កម្មករនិយោជិតដែលអាចមានលទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅដ្ឋានសម្រាប់បង្កើតគ្រួសារ និងមិនធ្វើការផ្លាស់ប្ដូរទីលំនៅញឹកញាប់ពេក ដែលបង្កើតបញ្ហាខ្វះកម្លាំងពលកម្មក្នុងរយៈពេលខ្លី។<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ បានសហការជាមួយក្រុមហ៊ុន Arakawa ដើម្បីដោះស្រាយជូនប្រជាពលរដ្ឋដែលជាម្ចាស់ចំណែកឯកជនចំនួន ៤៩២ គ្រួសារនៃអគារប៊ូឌីញ “ស” ប្រកបដោយជោគជ័យ បញ្ចៀសបាននូវ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ហានិភ័យជាយថាហេតុនៃគ្រោះថ្នាក់ដោយអគារប៊ូឌីញ ស មានសភាពចាស់ទ្រុឌទ្រោមខ្លាំង ហើយប្រជាពលរដ្ឋទាំង ៤៩២ គ្រួសារ ទទួលបាននូវប្រាក់ថ្លៃខ្ពស់ និងបានទៅតាំងទីលំនៅថ្មី ដោយពេញចិត្ត<br>▪ បានសហការជាមួយក្រុមហ៊ុន Worldbridgeland Co., Ltd. សាងសង់លំនៅឋានតម្លៃសមរម្យចំនួន ២ ២៩៧ ខ្នង លើផ្ទៃដីទំហំ ២៤ ហិកតា ស្ថិតនៅភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល<br>▪ បានសហការជាមួយក្រុមហ៊ុន B & BM Development Co., Ltd. សាងសង់លំនៅឋានតម្លៃសមរម្យចំនួន ៥ ៣៤០ ខ្នង នៅលើផ្ទៃដីទំហំ ៨២ ហិកតា ស្ថិតនៅស្រុកពញាឮ ខេត្តកណ្ដាល<br>▪ បានសហការជាមួយក្រុមហ៊ុន Arakawa សាងសង់លំនៅឋានតម្លៃសមរម្យ ចំនួន ២ ០០០ បន្ទប់ស្នាក់នៅ លើផ្ទៃដីទំហំ ១៣ ៦៨០ ម៉ែត្រក្រឡា ស្ថិតនៅខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>▪ បានសហការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រៀបចំនិងទទួលបានការអនុម័តពីរាជរដ្ឋាភិបាល លើគោលនយោបាយស្ដីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ<br>▪ បានចុះពិនិត្យការងារសាងសង់ផ្ទះគំរូដែលធន់នឹងការប្រែប្រួលអាកាសធាតុនៅខេត្តសៀមរាប និងខេត្តបាត់ដំបងសរុបចំនួន ០៨ លើក។<br>ក្នុងឆ្នាំ២០១៨÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានគាំទ្របច្ចេកទេសសិក្សាទីតាំងលំនៅឋានមិនរៀបរយចំនួន ២៦២ ខ្នងផ្ទះនៅខេត្តកំពង់ឆ្នាំង<br>▪ បានចុះប្រមូលទិន្នន័យកំណត់ស្ថានភាពលំនៅឋានដើម្បីកែលំអ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធលំនៅឋាននៅខេត្តព្រៃវែង និងបាត់ដំបង<br>▪ បានចុះពិនិត្យការដ្ឋានគម្រោងអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ "ប្រេក្ខនជាក" និង "លំនៅឋានអារ៉ាខាវ៉ា" នៅក្នុងរាជធានីភ្នំពេញ និង "លំនៅឋានទីក្រុងរណបសិរីមង្គល" នៅក្នុងខេត្តកណ្តាល<br>▪ បានពិនិត្យ និងផ្តល់យោបល់លើសំណើគម្រោងអភិវឌ្ឍលំនៅឋានរបស់ក្រុមហ៊ុន Phnom Penh Special Economic Zone និងក្រុមហ៊ុន Worldbridge Homes<br>▪ បានសាងសង់លំនៅឋានបន្សាំនឹងការប្រែប្រួលអាកាសធាតុចំនួន ៤ខ្នង សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះដោយការប្រែប្រួលអាកាសធាតុ នៅក្នុងស្រុកព្រៃនប់ និងស្រុកកំពង់សិលា ខេត្តព្រះសីហនុ។<br>- រដ្ឋបាលខេត្តស្វាយរៀង៖ បានសហការជាមួយរោងចក្រ សហគ្រាស គ្រឹះស្ថានចំនួន ១៧ សរុបចំនួន ៦៦ វគ្គ មានកម្មករ និយោជិតចូលរួម ១.៣៤៦ នាក់ ស្រី៨០៨ នាក់ ដើម្បីអប់រំផ្សព្វផ្សាយច្បាប់ ស្តីពីការងារ អនាម័យសុខភាព សុវត្ថិភាពការងារ និងគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ។ | |
| - ពិនិត្យឡើងវិញពីច្បាប់ការងារ និងការអនុវត្តកន្លងមក ដើម្បីស្វែងរកចំណុចវិជ្ជមាន និង | មធ្យម ទៅ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្តពង្រឹងតួនាទីរបស់គណៈកម្មការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| ចំណុចអវិជ្ជមាន ហើយធ្វើការគូសបញ្ជាក់ឡើងវិញពីតួនាទីរបស់និយោជក និងសហជីពក្នុងដំណើរការអភិវឌ្ឍទីផ្សារការងារ ដែលថ្លឹងបាននូវគុណភាពនៃការអភិវឌ្ឍ និងសុខុមាលភាព កម្មករ | វែង | ការងារ ដោយបានធ្វើការពិនិត្យជាប្រចាំអំពីចំណុចប្រឈមនានាដែលមាននៅក្នុងច្បាប់ស្តីពីការងារដោយបាន÷<br>▪ ធ្វើវិសោធនកម្មមាត្រា៨៧, មាត្រា៨៩, មាត្រា៩០, មាត្រា៩១, មាត្រា៩៤, មាត្រា១១០, មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារ ដើម្បីកែសម្រួលនីតិវិធី វិធីសាស្ត្រនៃការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ដែលជាប្រភពនៃវិវាទការងារ និងកូដកម្មជារឿយៗនៅពេលរោងចក្រក្ស័យធន ឬបិទទ្វារដោយថៅកែរត់ចោល<br>▪ ប្រែក្លាយផ្នែកទី១ ជំពូកទី៦ នៃច្បាប់ស្តីពីការងារដែលពាក់ព័ន្ធនឹងប្រាក់ឈ្នួលអប្បបរមា ទៅជាច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមានៅខែកក្កដា ឆ្នាំ២០១៨ ដើម្បីឱ្យមានយន្តការ លក្ខណៈវិនិច្ឆ័យ កាលវិភាគច្បាស់លាស់ និងមានសុខដុមនីយកម្មជាងមុនក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមា។<br>▪ ចេញប្រកាសចំនួន ២ ពាក់ព័ន្ធនឹងការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត និងការទូទាត់ប្រាក់បំណាច់អតីតភាពការងារ<br>▪ ធ្វើសិក្ខាសាលាផ្សព្វផ្សាយអំពីលិខិតបទដ្ឋានថ្មីៗចំនួន ៨លើក និងបកស្រាយទាន់ពេលវេលាទៅនឹងចម្ងល់នានាអំពីលិខិតបទដ្ឋានគតិយុត្តថ្មីៗពាក់ព័ន្ធវិស័យការងារ<br>▪ សិក្សាស្រាវជ្រាវប្រែក្លាយគោលនយោបាយស្តីពីសុវត្ថិភាព និងសុខភាពការងារ ទៅជាច្បាប់ស្តីពីសុវត្ថិភាព និងសុខភាពការងារ ដោយសហការជាមួយទីភ្នាក់ងារសុខភាព និងសុវត្ថិភាពការងារកូរ៉េ (KOSHA) និងអង្គការអន្តរជាតិខាងការងារ (ILO) | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ សិក្សា និងរៀបចំសេចក្តីព្រាងបញ្ជីឈ្មោះជំនាញវិជ្ជាជីវៈ។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖<br>ក្នុងឆ្នាំ២០១៧-២០១៨៖<br>▪ បានចូលរួមក្នុងការលើកកម្ពស់លក្ខខណ្ឌការងារ និងសុខុមាលភាពរបស់កម្មករ និយោជិត តាមរយៈការចូលរួមរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពជូនកម្មករ និយោជិត និងតាមរយៈសិក្ខាសាលាស្វែងយល់អំពីការអនុវត្តច្បាប់ពាក់ព័ន្ធនឹងការធ្វើចំណាកស្រុក ការទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ<br>▪ បានចូលរួមសម្របសម្រួលរៀបចំពិធីសំណេះសំណាលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាមួយកម្មករ និយោជិត នៅតាមតំបន់សេដ្ឋកិច្ចពិសេសក្នុងឆ្នាំ២០១៨<br>▪ បានចូលរួមសម្របសម្រួលលើកិច្ចសហប្រតិបត្តិការរវាងអ្នកអភិវឌ្ឍតំបន់ និងក្រុមការងារពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការប្រជុំផ្សព្វផ្សាយនៅក្នុងតំបន់សេដ្ឋកិច្ចនូវលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការបើកប្រាក់ឈ្នួលជូនកម្មករ និយោជិត និងការទូទាត់ប្រាក់បំណាច់អតីតភាពការងារក្នុងឆ្នាំ២០១៨<br>▪ បានចូលរួមសម្របសម្រួលដល់ការងារដោះស្រាយវិវាទការងារ និងស្វែងរកដំណោះស្រាយជូនកម្មករ និយោជិត និងនិយោជក នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្នុងឆ្នាំ២០១៨។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| - ពង្រឹងយន្តការគ្រប់គ្រងកម្មករជំនាញ ជាពិសេសត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់សមាហរណកម្មអាស៊ាន។ | ២០១៥ ទៅ មធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានចូលរួមប្រជុំក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការក្របខ័ណ្ឌគុណវុឌ្ឍិយោងអាស៊ាន (AQRF) ចំនួន ០៣លើក<br>▪ អនុគណៈកម្មការក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន (AQRF) បានរៀបចំដំណើរការផ្ទឹង CQF ជាមួយក្របខ័ណ្ឌគុណវុឌ្ឍិអាស៊ាន (AQRF-Asean Qualifications Reference Framework) ជាមួយក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (CQF-Cambodia Qualification Framework)<br>▪ អនុគណៈកម្មការទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក (MRS) និងអនុគណៈកម្មការ កិច្ចព្រមព្រៀងទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក (MRA) បានចូលរួមប្រជុំក្រុមការងារបច្ចេកទេសថ្នាក់តំបន់លើកទី៤ស្តីពីការឈានឆ្ពោះទៅរកការអនុវត្តការទទួលស្គាល់ជំនាញគ្នាទៅវិញទៅមករវាងប្រទេសក្នុងតំបន់អាស៊ាន និងបានកែសម្រួលកញ្ចប់ស្តង់ដាបណ្តុះបណ្តាលលើមុខរបរការងារកំបោរ និងការតបណ្តាញអគ្គិសនីក្នុងអគារជាមួយភាគីថៃសម្រាប់ការទទួលស្គាល់ជំនាញគ្នាទៅវិញទៅមករវាងប្រទេសកម្ពុជាជាមួយប្រទេសថៃ<br>▪ បានបណ្តុះបណ្តាលមន្ត្រី និងគ្រូបច្ចេកទេសអំពីវិធីសាស្ត្រផ្ទឹងស្តង់ដាជាតិ និងស្តង់ដាតំបន់ (CQF ជាមួយនឹង AQRF) ផ្នែកសំណង់ និងអគ្គិសនី នៅក្រៅប្រទេសបានចំនួន ២០នាក់, និងបានបណ្តុះបណ្តាលមន្ត្រី និងគ្រូបច្ចេកទេស លើជំនាញសសេរ | |

| ទិសដៅគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | កម្មវិធីសិក្សាបែប CBT ដែលស្របជាមួយនឹង AQRF ផ្នែកសំណង់ និងមេកានិចរថយន្ត នៅក្រៅប្រទេស បានចំនួន ៣៥នាក់។ | |
| - រៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ។ | ២០១៥ ទៅ មធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជាតិមុខរបរ និងការងារ បានផ្សព្វផ្សាយ និងពង្រឹងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ ដោយ÷<br>▪ បានរៀបចំ និងដាក់ឱ្យអនុវត្តផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ រយៈពេល ៣ឆ្នាំ (ឆ្នាំ២០១៧-២០១៩)<br>▪ បានដឹកនាំ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរំលេចផែនការសកម្មភាពនិងថវិកា ដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ របស់ក្រសួង ស្ថាប័ននីមួយៗ<br>▪ បានពង្រីកគណៈកម្មការរាជធានី ខេត្ត សម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ បានគ្រប់រាជធានី ខេត្ត<br>▪ បានរៀបចំសិក្ខាសាលាកសាងសមត្ថភាពចំនួន ២លើក ដល់សមាជិកគណៈកម្មការ ដើម្បីអនុវត្ត និងត្រួតពិនិត្យគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ<br>▪ បានអនុម័ត និងផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ សម្រាប់ឆ្នាំ២០១៧។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ក្នុងឆ្នាំ២០១៧-២០១៨÷<br>▪ បានចូលរួមកិច្ចប្រជុំផ្តល់ធាតុចូលក្នុងការរៀបចំ និងកិច្ចប្រជុំអនុម័តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ<br>▪ បានរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ សម្រាប់រយៈពេល៣ឆ្នាំ (២០១៧-២០១៩) ក្នុងក្របខណ្ឌ ក.អ.ក និងផ្ញើជូនទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ | |
| *៤)-ការសម្របសម្រួលគោលនយោបាយគាំទ្រ* | | | |
| *ក-ការបណ្តុះបណ្តាលជំនាញនិងធនធានមនុស្ស* | | | |
| - បង្កើតឱកាសទីពីរសម្រាប់ការទទួលបានការបញ្ចប់ថ្នាក់មធ្យមសិក្សា តាមរយៈការបង្កើតប្រព័ន្ធសមមូលសញ្ញាបត្រ ដោយផ្អែកលើការធ្វើតេស្តដែលអនុញ្ញាតឱ្យទទួលបានវិញ្ញាបនបត្រចំណេះដឹងទូទៅគ្រប់កម្រិត ទោះនៅក្រៅប្រព័ន្ធអប់រំផ្លូវការក៏ដោយ | ២០១៥ | - ក្រសួងអប់រំ យុវជន និងកីឡា<br>▪ រៀបចំកម្មវិធីសមមូលកម្រិតមូលដ្ឋានតាមប្រព័ន្ធអ៊ីនធឺណែតដោយសហការជាមួយយូណេស្កូ<br>▪ រៀបចំ និងកែសម្រួលសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការវាស់ស្ទង់សមត្ថភាពកម្រិតសមមូល<br>▪ ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូលកើនពី ៥.១៦៤នាក់ ក្នុងឆ្នាំ២០១៦ ដល់ ៥.២៧៥នាក់ ក្នុងឆ្នាំ២០១៧<br>▪ អភិវឌ្ឍមជ្ឈមណ្ឌលសិក្សាសហគមន៍មួយចំនួនឱ្យក្លាយជាគំរូ និងជំរុញការអនុវត្តកម្មវិធីអក្ខរកម្មសម្រាប់កម្មករ កម្មការិនី<br>▪ រៀបចំប្រកាសអន្តរក្រសួងស្តីពីការដំឡើងប្រាក់ម៉ោង សម្រាប់ប្រតិបត្តិការមជ្ឈមណ្ឌលសិក្សាសហគមន៍ពេញមួយឆ្នាំ និងឥណទានសម្រាប់ការបង្កើនប្រាក់ចំណូលដល់សិស្សបានបញ្ចប់កម្មវិធីបណ្តុះបណ្តាល | - ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ ការអនុវត្តកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ នៅពុំទាន់បានដំណើរការគ្រប់រាជធានី ខេត្ត។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ អនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈក្នុងរាជធានី ខេត្ត ២៥ ក្នុងនោះ កម្មវិធីក្រោយអក្ខរកម្មមាន ១៧, កម្មវិធីចូលរៀនឡើងវិញមាន២២, កម្មវិធីបង្កើនប្រាក់ចំណូលនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍មាន ២៤, កម្មវិធីសមមូលបឋមសិក្សាមាន ២៤, កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិមាន ៨, និងកម្មវិធីបំពេញវិជ្ជាមាន ២១<br>▪ ចាប់អនុវត្តនៅឆ្នាំ២០១៨ នូវកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ ដោយទទួលអ្នកសិក្សាចំនួន ៦.៣៩៤នាក់ ស្រី ៤៧,២៨% កើន ១.១១៩នាក់ ស្មើ ២១,២១% ស្រី ៣៥៦នាក់ ស្មើ ១៣,៣៥% ក្នុងនោះគ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡាមាន ៥.៨៣៨នាក់ ស្រី ៤៧,២៨% កើន ៧៨៣នាក់ ស្មើ ១៥,៤៩% ស្រី ១៩០នាក់ ស្មើ ៧,៣៩% និងគាំទ្រដោយដៃគូអភិវឌ្ឍន៍មាន ៥៥៦នាក់ ស្រី ៤៧,៣០% កើន ៣៣៦នាក់ ស្មើ ១៥២,៧៣% ស្រី ១៦៦នាក់ ស្មើ ១៧១,១៣%<br>▪ អនុវត្តកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធក្នុង ៩រាជធានី ខេត្ត មាន ២៤ថ្នាក់ គ្រប់គ្រងដោយក្រសួងមាន ២៣ ស្មើ ៩៥,៨៣% និងគាំទ្រដោយដៃគូអភិវឌ្ឍន៍មាន ១ថ្នាក់ ស្មើ ៤,១៧%។ មានគ្រូ ៥៧នាក់ ស្រី ១៧,៥៤% និងអ្នកសិក្សា ៥២០ នាក់ ស្រី ៣៩,៦២% ក្នុងនោះគ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡាមាន ៥០២នាក់ ស្រី ៣៧,៤៥% និងគាំទ្រដោយដៃគូអភិវឌ្ឍន៍មាន ១៨នាក់ ស្រី ១០០%។ អ្នកសិក្សាចូលរៀនថ្នាក់ឆ្នាំទី១ មាន ២៥០នាក់ ស្រី ៤២,០០% និងថ្នាក់ឆ្នាំទី២ មាន ២៧០នាក់ ស្រី ៣៧,៤១%។ អ្នកសិក្សាបានបញ្ចប់កម្មវិធី | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | សមមូលមធ្យមសិក្សាបឋមភូមិមាន ១៩៨នាក់ ស្រី ៨៤នាក់ ប្រឡងជាប់ ១៥១នាក់ ស្រី ៦៥នាក់។<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានពង្រីកការបណ្តុះបណ្តាលកម្មវិធីស្ពានចម្លងបន្តជំនាញ សម្រាប់ផ្តល់ឱកាសទី២ដល់សិស្សដែលបានបោះបង់ការសិក្សា នៅថ្នាក់ទី៧, ៨, និង៩ ដើម្បីអាចបន្តការសិក្សាទៅប្រព័ន្ធអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈផ្លូវការ បានចំនួន ២ ៧២៣នាក់ ត្រឹមឆ្នាំ២០១៨ ក្រោមគម្រោង ADB/AFD<br>▪ បានអនុវត្តសាកល្បងលើកម្មវិធីទទួលស្គាល់ការសិក្សាពីមុន (Recognition of Prior Learning- RPL) ដល់សិក្ខាកាម ១៦២ នាក់ ក្នុងឆ្នាំ២០១៨ លើមុខរបរការថែទាំ និងជួសជុលម៉ូតូ ការថែទាំនិងជួសជុលម៉ាស៊ីនធុនតូច និងការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ។<br>- រដ្ឋបាលខេត្តស្វាយរៀង បានបញ្ចប់កម្រិតជំនាញដល់សិក្ខាកាម សិស្ស និស្សិត ចំនួន ៩៧៥នាក់ ស្រី ៣៩៨នាក់ និងមានសហគ្រាសគ្រឹះស្ថានក្នុងខេត្ត ចំនួន៦៤ បានដំណើការហ្វឹកហ្វឺនកូនជាងសរុប ៣.៦៦៣នាក់ ស្រី ២.១៤១នាក់ គិតរហូតមកដល់ឆ្នាំ២០១៧។ | |
| - ពង្រឹងគុណភាពអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដោយផ្តោតលើការពង្រឹង មូលដ្ឋានចំណេះដឹងរបស់កុមារ និងយុវជន លើផ្នែក | ២០១៥<br>មធ្យម<br>វែង | - ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ បានបញ្ចប់សេចក្តីព្រាងឯកសារជំនួយស្តីពីវិធីសាស្រ្តរៀន និងបង្រៀនមុខវិជ្ជាស្នែម<br>▪ បានរៀបចំឯកសារអភិវឌ្ឍសាលារៀនជំនាន់ថ្មីផ្នែកបឋមសិក្សា | - ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ ខ្វះមន្ត្រីបច្ចេកទេស និងបុគ្គលិកអប់រំផ្នែក ICT ដើម្បីធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| គណិតវិទ្យា វិទ្យាសាស្ត្រ អក្សរសាស្ត្រ និងបច្ចេកវិទ្យា | | ▪ បានបង្កើនសាលារៀនជំនាន់ថ្មីចំនួន ១១ នៅរាជធានី ខេត្ត ចំនួន ៥ ក្នុងនោះមាន បឋមសិក្សាចំនួន ៤ និងមធ្យមសិក្សាចំនួន ៧<br>▪ កំពុងអនុវត្តគោលនយោបាយអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា<br>▪ បានសិក្សាស្រាវជ្រាវកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនរូបវិទ្យា និងភាសាអង់គ្លេស<br>▪ បានបង្កើតកម្មវិធីអេឡិចត្រូនិកសម្រាប់ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃកម្មវិធីសាលាកុមារមេត្រីដោយប្រើកុំព្យូទ័របន្ទះ (Tablet) ក្នុងការប្រមូលទិន្នន័យចាំបាច់<br>▪ បានបង្កើតកម្មវិធីដំណើរការតាមទូរស័ព្ទ ដែលហៅថា "តេស្ត" សម្រាប់សិស្សថ្នាក់ទី១ និងសិស្សថ្នាក់ទី២ ដែលអាចវាយតម្លៃសមត្ថភាពអំណានរបស់សិស្ស។ កម្មវិធីនេះ ត្រូវបានបង្កើនរហូតដល់ ៨៧សាលារៀន និងមានអ្នកទទួលផល/អ្នកយកប្រើប្រាស់កើនឡើងរហូតដល់ ១០.០០០នាក់<br>▪ បានផលិតវីឌីអូខ្លី ស្តីពីការបង្រៀន និងរៀនកម្មវិធីអំណាន និងគណិតវិទ្យាថ្នាក់ដំបូង<br>▪ បង្កើនការទទួលសិស្សសាលារៀនជំនាន់ថ្មីបានពីចំនួន ១.៣៩៦ នាក់ (ស្រី ៦៧៣នាក់) ក្នុងឆ្នាំសិក្សា២០១៦-២០១៧ មកចំនួន ២.៣១២នាក់ (ស្រី ១.១៣៨នាក់) ក្នុងឆ្នាំសិក្សា២០១៧-២០១៨<br>▪ ពង្រឹងការអនុវត្តសាលារៀនជំនាន់ថ្មីនៅសាលាបឋមសិក្សា តាម-រយៈ (១) ការរៀបចំបន្ទប់ពិសោធន៍ បំពាក់កុំព្យូទ័រ សាស្ត្រាចារ្យ | បុគ្គលិក និងគរុសិស្សនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន លើការគ្រប់គ្រង ធ្វើផែនការ ការពង្រាយគ្រូចេញថ្មី និងពង្រាយគ្រូឡើងវិញ<br>▪ សមត្ថភាពជំនាញវិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀននៅមធ្យមសិក្សាមិនទាន់ឆ្លើយតបទៅនឹងតម្រូវការអនុវត្តកម្មវិធីសិក្សាថ្មី<br>▪ គ្រឹះស្ថានមធ្យមសិក្សាភាគច្រើនមិនទាន់មានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារឧបទេស រោងជាងបណ្តាញទឹក អគ្គិសនី និងបង្គន់អនាម័យ ស្របតាមកម្មវិធីសិក្សា<br>▪ កង្វះមន្ត្រីជំនាញឯកទេសកម្មវិធីសិក្សា អភិវឌ្ឍផែនការ និងការគ្រប់គ្រងទិន្នន័យសៀវភៅសិក្សាគោល<br>▪ ខ្វះប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់អនុវត្តការងារតេស្តនៅថ្នាក់ក្រោម |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ណែនាំតាមមុខវិជ្ជា និងបណ្ណាល័យអេឡិចត្រូនិច និង (២) ការអនុវត្តកម្មវិធីសិក្សាតាមបែបសិស្សចល័តទៅតាមបន្ទប់មុខវិជ្ជា<br>▪ អភិវឌ្ឍ "ប្រព័ន្ធតាមដានការផ្គត់ផ្គង់សៀវភៅសិក្សាគោល (TnT)" ដើម្បីសម្រួលដល់ការតាមដាន ការផ្គត់ផ្គង់សៀវភៅសិក្សាគោលគ្រប់កម្រិតនិងគ្រប់មុខវិជ្ជាឱ្យទទួលបានប្រសិទ្ធភាព<br>▪ រៀបចំតាំងពិព័រណ៍សៀវភៅ ៣លើក (ទិវាអំណាន អង្គរសង្ក្រាន និងបណ្ណាល័យជាតិ)<br>▪ ផ្ដល់ថវិកាសម្រាប់ទិញបរិក្ខារកុំព្យូទ័រដល់សាលារៀន<br>▪ បង្កើតគេហទំព័រ (www.fmismoeys.com) សម្រាប់ផ្សព្វផ្សាយឯកសារពាក់ព័ន្ធនឹងនីតិវិធីរៀបចំ និងអនុវត្តថវិកាដែលមានលក្ខណៈជា E-Library<br>▪ អភិវឌ្ឍកម្មវិធីទូរសព្ទដៃមុខវិជ្ជាជីវវិទ្យា ថ្នាក់ទី១២ លើប្រព័ន្ធប្រតិបត្តិការ Android<br>▪ អភិវឌ្ឍប្រព័ន្ធអភិវឌ្ឍសមត្ថភាពសិស្សលើមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា សម្រាប់សិស្សថ្នាក់ទី១២<br>▪ ផលិតមាតិកាអប់រំឌីជីថល ១០ លើមុខវិជ្ជាគណិតវិទ្យាថ្នាក់ទី១២ សម្រាប់សិក្សាតាមប្រព័ន្ធអេឡិចត្រូនិច<br>▪ បានរៀបចំកម្មវិធីសិក្សាមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ សម្រាប់រៀនសរសេរកម្មវិធីកុំព្យូទ័រ (Coding) ចាប់ពីថ្នាក់ទី៧-៩<br>▪ ធ្វើវិក្រឹតការគ្រូបង្រៀនកម្រិតមូលដ្ឋានមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ប្រវត្តិវិទ្យា និងភាសាខ្មែរចំនួន ២១៥នាក់ | ជាតិ ព្រមទាំងសម្ភារៈ និងធនធានមនុស្ស<br>▪ គ្រឹះស្ថានសិក្សាភាគច្រើនខ្វះគ្រូតាមមុខវិជ្ជាឯកទេស គ្រូអប់រំបច្ចេកទេស គ្រូបំណិនជីវិត គ្រូប្រឹក្សាអាជីព បន្ទប់ប្រឹក្សាអាជីព និងសម្ភារឧបទេស<br>▪ ការផ្សព្វផ្សាយកម្មវិធីអប់រំតម្រង់ទិសវិជ្ជាជីវៈ មិនទាន់ឆ្លើយតបទៅនឹងបរិបទថ្មី<br>▪ គោលវិធីអប់រំ STEM មិនទាន់បានអនុវត្តទូលំទូលាយ<br>▪ សហគ្រាស កសិដ្ឋាន និងផ្នែកឯកជន ពុំទាន់ផ្ដល់កិច្ចសហការពេញលេញក្នុងការផ្ដល់កន្លែងចុះកម្មសិក្សា អាហារូបករណ៍ ការចែករំលែកបទពិសោធន៍ និងទស្សនកិច្ចសិក្សាដល់សិស្ស។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | (ស្រី ១០៧នាក់) នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនឆ្ពោះទៅបរិញ្ញាបត្រ<br>▪ ផ្តល់អាហារូបករណ៍ដល់គ្រូឧទ្ទេស ៣៦នាក់ ស្រី ១៣នាក់ ដែលបម្រើការងារនៅតាមសាលាគរុកោសល្យ ដើម្បីពង្រឹងសមត្ថភាពនៅផ្នែកការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ (STEM) ការអនុវត្តកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន និងការគ្រប់គ្រងសាលារៀននៅវិទ្យាស្ថានជាតិអប់រំ ប្រទេសសិង្ហបុរី<br>▪ បញ្ជូនគណៈគ្រប់គ្រងសាលារៀន ២០នាក់ ស្រី ៣នាក់ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការគ្រប់គ្រងអប់រំ និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់ការបង្រៀន-រៀន" នៅកូរ៉េខាងត្បូង<br>▪ កំពុងបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ៧០០នាក់ តាមប្រព័ន្ធពន្លឿន ដើម្បីឱ្យក្លាយទៅជាគ្រូកម្រិតឧត្តមលើ ៦មុខវិជ្ជារួមមាន គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា អក្សរសាស្ត្រខ្មែរ និងប្រវត្តិវិទ្យា។ | |
| - ជំរុញការអប់រំចំណេះទូទៅឱ្យបានយ៉ាងហោចណាស់ប្រាំបួនឆ្នាំ ដោយកាត់បន្ថយឱ្យបានជាអតិបរមានូវអត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា និងលើកកម្ពស់ការចូលរៀននៅថ្នាក់មធ្យមសិក្សា | ២០១៥<br>មធ្យម<br>វែង | - ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំជាកិច្ចអន្តរាគមន៍ជាច្រើនដើម្បីឱ្យ÷<br>▪ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាមាន ៧៩,០៦% ស្រី ៨២,៦៥% ប្រុស ៧៥,៦៨% (២០១៧-២០១៨)<br>▪ អត្រាបោះបង់ការសិក្សានៅបឋមសិក្សាថយចុះពី ៤,៦% នៅឆ្នាំ ២០១៦-២០១៧ មកនៅត្រឹម៤,១% នៅឆ្នាំ២០១៧-២០១៨<br>▪ ការចូលរៀននៅមធ្យមសិក្សាបឋមភូមិបានកើនពី ៥៣,៨% នៅឆ្នាំសិក្សា២០១៥-២០១៦ ដល់ ៥៨,៨% នៅឆ្នាំសិក្សា២០១៧- | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ២០១៨ ជាមួយនឹងអត្រាបោះបង់ការសិក្សាបានថយចុះពី ១៩,២% មក ១៥,៤%<br>▪ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិថយចុះពី ១៧,០% នៅឆ្នាំសិក្សា២០១៥-២០១៦ មកត្រឹម១៥,៤% នៅឆ្នាំ ២០១៦-២០១៧ និងកើនឡើងបន្តិច ០,៤%វិញ នៅឆ្នាំសិក្សា ២០១៧-២០១៨<br>▪ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិថយចុះពី ១៩,៤% នៅឆ្នាំសិក្សា២០១៥-២០១៦ មកត្រឹម១៨,៣% នៅឆ្នាំ ២០១៦-២០១៧ និងមកត្រឹម ១៦,៩% នៅឆ្នាំសិក្សា២០១៧-២០១៨។ | |
| - កែលម្អកម្មវិធីសិក្សាដោយដាក់បញ្ចូលជំនាញទន់ (Soft Skills) រួមមាន ជំនាញទំនាក់ទំនងសង្គមក្នុងការដោះស្រាយបញ្ហា ការគោរពវិន័យនៅកន្លែងធ្វើការ និងជំនាញជាច្រើនទៀតដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍមូលដ្ឋានគ្រឹះឧស្សាហកម្ម | មធ្យម ទៅ វែង | - ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ បានបញ្ចូលកម្មវិធីបណ្តុះបណ្តាលសហគ្រិនភាព ភាពជាអ្នកដឹកនាំ និងជំនាញទន់ ទៅក្នុងមុខវិជ្ជាបំណិនជីវិត<br>▪ បានបញ្ជ្រាបជំនាញទន់ទៅក្នុងវិធីសាស្ត្របង្រៀនតាមមុខវិជ្ជានៅតាមគ្រឹះស្ថានសិក្សា<br>▪ បានបំប៉នសមត្ថភាពស្តីពីការបង្កើតសហគ្រិននៅសហគមន៍ដល់គ្រូបង្គោល ៧១នាក់ ស្រី ៩,៨៥% និងយុវជន ៣.៤៧០នាក់ ស្រី ៥២,៧៦%<br>▪ បានបំប៉នសមត្ថភាពស្តីពីការអភិវឌ្ឍសហគ្រាសតាមសហគមន៍ដល់យុវជន ៤៣២នាក់ ស្រី ៦១,៨១%<br>▪ ចំនួនយុវជន ៩២៨នាក់បានទទួលការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំនិងសហគ្រិនភាព ក្នុងឆ្នាំ២០១៧-២០១៨ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - បណ្តុះបណ្តាលសិស្ស ៦២៥នាក់ ស្តីពីសហគ្រិនភាព<br>- បណ្តុះបណ្តាលយុវជនក្រៅសាលា ៤៣២នាក់ ស្រី ២៧៦នាក់ស្តីពីការអភិវឌ្ឍសហគ្រាសតាមសហគមន៍<br>- បោះពុម្ពសៀវភៅណែនាំបំណិនជីវិតផ្នែកបំណិនសហគ្រិន-ភាព ៦មុខ និងចែកជូនដល់ ៨៧សាលាគោលដៅ<br>- បំប៉នសមត្ថភាពគណៈគ្រប់គ្រង និងគ្រូបង្រៀន ស្តីពីការប្រើប្រាស់បំណិនជីវិតផ្នែកបំណិនសហគ្រិនភាពដល់ខេត្តគោលដៅ ៣ ខេត្តកំពង់ធំ កំពង់ស្ពឺ និងត្បូងឃ្មុំ អ្នកចូលរួម ៤៩នាក់ ស្រី ៨នាក់។<br>▪ ពង្រីកកម្មវិធីសាកល្បងការអប់រំសហគ្រិនភាព ២៥រាជធានី ខេត្ត សិស្សចូលរួម ៦២៥នាក់ ស្រី ៥០ភាគរយ ដើម្បីត្រៀមបញ្ចូលទៅក្នុងកម្មវិធីសិក្សាជាតិ ដោយសហការជាមួយអង្គការអន្តរជាតិខាងការងារ។<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានបញ្ចូលជំនាញទន់ទៅក្នុងកញ្ចប់ស្តង់ដាបណ្តុះបណ្តាលចំនួន ១០មុខរបរ/៣៦គុណវុឌ្ឍិ ត្រឹមឆ្នាំ២០១៨<br>▪ ទីភ្នាក់ងារជាតិមុខរបរនិងការងារ បានធ្វើការចងក្រងមេរៀន និងរៀបចំវគ្គបណ្តុះបណ្តាលស្តីពីជំនាញទន់ ដល់សិស្ស-និស្សិត យុវជន និងអ្នកស្វែងរកការងារចំនួន ៤០វគ្គ ដែលមានអ្នកចូលរួមចំនួន ១ ០២៤នាក់ ក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨។ | |
| - ពង្រឹងការយល់ដឹងអប់រំអំពីការចាប់អាជីពនិងជំនាញបច្ចេកទេស ក៏ដូចជាកម្មវិធីសិក្សាបន្ត | ២០១៥ ទៅ | - ក្រសួងអប់រំ យុវជន និងកីឡា÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| ដើម្បីអភិវឌ្ឍជំនាញ ដោយផ្សារភ្ជាប់ទៅនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់ | មធ្យម | ▪ បានអនុម័តស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ព្រមទាំងកំពុងរៀបចំស្តង់ដាគ្រូបង្រៀន និងបានពិភាក្សាលើឯកសារទស្សនាទានស្តីពីគន្លងអាជីព<br>▪ បានពង្រីកការបង្រៀន និងការរៀនអំពីការអប់រំបំណិនជីវិត ប្រឹក្សាអាជីព ក្រុមប្រឹក្សាយុវជន និងក្លឹបសិក្សារួមមាន គណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងប្រវត្តិវិទ្យា<br>▪ បានរៀបចំឯកសារណែនាំស្តីពីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សាសម្រាប់មធ្យមសិក្សាទុតិយភូមិ<br>▪ បានសហការជាមួយក្រុមហ៊ុនឯកជន ដើម្បីផ្សារភ្ជាប់ការបណ្តុះ-បណ្តាលបច្ចេកទេសនៅតាមគ្រឹះស្ថានសិក្សាជាមួយនឹងទីផ្សារការងារ<br>▪ បានកសាងឯកសារប្រឹក្សាអាជីពនិងព័ត៌មានស្តីពីជំនាញសិក្សា ដើម្បីបំប៉នគ្រូប្រឹក្សាអាជីពនៅមធ្យមសិក្សាទុតិយភូមិ<br>▪ បានបំប៉នសមត្ថភាពគ្រូប្រឹក្សាអាជីពនៅខេត្តបាត់ដំបងស្តីពីប្រសិទ្ធភាពនៃការគ្រប់គ្រងថ្នាក់រៀន ដោយមានគ្រូចូលរួម ៣៥នាក់ ស្រី ១២នាក់<br>▪ បានបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពីការណែនាំការងារប្រឹក្សាអាជីព សម្រាប់បុគ្គលិកអប់រំថ្នាក់មន្ទីរ និងថ្នាក់ស្រុក ខណ្ឌ អ្នកចូលរួម ៣០នាក់ ស្រី ៨នាក់<br>▪ បានរៀបចំវេទិកាតម្រង់ទិសវិជ្ជាជីវៈដល់សិស្ស ៤.៣៩៩នាក់ ស្រី ២.៥១២នាក់ នៅរាជធានីភ្នំពេញ ខេត្តកំពត កំពង់ឆ្នាំង តាកែវ សៀមរាប កោះកុង បន្ទាយមានជ័យ និងស្វាយរៀង | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានរៀបចំវេទិកាតម្រង់ទិសវិជ្ជាជីវៈនៅសាលាមធ្យមសិក្សាដល់សិស្សចំនួន ៣.៨៩៦នាក់ ស្រី ២.០៦០នាក់<br>▪ ពិនិត្យតាមដាន និងណែនាំការអនុវត្តសកម្មភាពផ្តល់សេវាអប់រំតម្រង់ទិសវិជ្ជាជីវៈដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន១០៧នាក់ ស្រី ៥៣នាក់ នៅខេត្តកំពង់ចាម ស្ទឹងត្រែង និងបាត់ដំបង<br>▪ បានបណ្តុះបណ្តាលគ្រូប្រឹក្សាអាជីពនៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស គ្រឹះស្ថានសិក្សា មជ្ឈមណ្ឌលយុវជន និងមជ្ឈមណ្ឌលការងារ ៣៥នាក់ ស្រី ១៥នាក់<br>▪ បានបើកសិក្ខាសាលាស្តីពីវឌ្ឍនភាពពង្រឹងមគ្គុទ្ទេសក៍អាជីព និងការប្រឹក្សាណែនាំនៅមធ្យមសិក្សា ឆ្នាំ២០១៨ អ្នកចូលរួម ៨៣នាក់ ស្រី ២០នាក់<br>▪ បានណែនាំការបែងចែកកម្មវិធីសិក្សាផ្នែកអប់រំបច្ចេកទេស មុខវិជ្ជាចំណេះទូទៅ÷ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា អក្សរសាស្ត្រខ្មែរ សីលធម៌ពលរដ្ឋ កុំព្យូទ័រ និងភាសាអង់គ្លេស<br>▪ បានបំប៉នសមត្ថភាពស្តីពីប្រឹក្សាអាជីពដល់គ្រូប្រឹក្សាអាជីព ៣៣នាក់ ស្រី ១៦នាក់<br>▪ បានព្រាងឯកសារទស្សនាទានស្តីពីការអភិវឌ្ឍរោងជាងនៅសាលាមធ្យមសិក្សា<br>▪ បានផ្សព្វផ្សាយវីដេអូខ្លីៗចំនួន៣០ ដើម្បីណែនាំពីអាជីពដល់សិស្ស។<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានជំរុញការផ្សព្វផ្សាយផ្នែក អ.ប.វ តាមរយៈការរៀបចំទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET-DAY) | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ដែលចំនួនអ្នកចូលរួមបានកើនឡើងពីចំនួន ៥.០០០នាក់ ក្នុងឆ្នាំ ២០១៦ ទៅចំនួន ៩.៨៩៩នាក់ ក្នុងឆ្នាំ២០១៧ (កើនឡើង ជិត២ដងពីឆ្នាំ២០១៦) និងចំនួន ២៧.៤៥៣នាក់ ក្នុងឆ្នាំ២០១៨ (កើនឡើង ជិត២ដង ពីឆ្នាំ២០១៧) ដែលការកើនឡើងនៃអ្នកចូលរួមនេះដោយសារការបង្កើនវិភាជថវិកាសម្រាប់ការផ្សព្វផ្សាយដើម្បីបង្កើនភាពទាក់ទាញការចុះឈ្មោះចូលរៀនក្នុងវិស័យ TVET<br>▪ បានរៀបចំកម្មវិធីទស្សនកិច្ចសិក្សារបស់សិស្ស-និស្សិតតាមគ្រឹះស្ថានសិក្សាដែលមានសិស្ស-និស្សិតចូលរួមចំនួន៤១៦នាក់<br>▪ តាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារ បានបង្កើនមគ្គទេសក៍អាជីពការងារ មុខរបរ និងការអប់រំបណ្តុះបណ្តាលជំនាញ នៅតាមវិទ្យាល័យ សាកលវិទ្យាល័យ និងគ្រឹះស្ថាន TVET បានចំនួន ៥៥១លើក ដែលមានសិស្ស-និស្សិតចូលរួមចំនួន ៣០.៥៦៤នាក់ ក្នុងឆ្នាំ២០១៧ និង២០១៨<br>▪ បានបោះពុម្ពសៀវភៅព័ត៌មាន TVET ចំនួន ១៧ ៣០០ក្បាល និងបោះពុម្ពខិត្តបណ្ណផ្សព្វផ្សាយចំនួន ១៥៨.៥០៩សន្លឹក ក្នុងឆ្នាំ ២០១៧ និង២០១៨។ | |
| - បង្កើនការបណ្តុះបណ្តាលបច្ចេកទេសឱ្យបានច្រើនជងជាងមុន តាមលទ្ធភាពលើជំនាញបច្ចេកទេស ជាពិសេស នៅក្នុងផ្នែកអគ្គិសនី មេកានិក ស្លង់ដារ មាត្រាសាស្ត្រ (ត្រួតពិនិត្យផ្ទៀងផ្ទាត់ ព្យាសកម្ម តេស្ត និងជំនាញប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ) និងគីមីសាស្ត្រ ទាំងក្នុង | មធ្យម ទៅ វែង | - ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ បានណែនាំការបែងចែកកម្មវិធីសិក្សាអប់រំបច្ចេកទេស មុខជំនាញបច្ចេកទេសអគ្គិសនី មេកានិក ក្បេត្រសាស្ត្រ និងបសុវប្បកម្ម<br>▪ អភិវឌ្ឍសៀវភៅសិក្សាគោលផ្នែកអប់រំបច្ចេកទេសលើ ៥ជំនាញ រួមមានអគ្គិសនី មេកានិច អេឡិចត្រូនិច ក្បេត្រសាស្ត្រ និងបសុវប្បកម្មសម្រាប់ឆ្នាំទី១។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| កម្រិតមធ្យមសិក្សាបច្ចេកទេស ទាំងក្នុងកម្រិតឧត្តមសិក្សា | | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានផ្តល់ការបណ្តុះបណ្តាលសិស្សបច្ចេកទេសវិជ្ជាជីវៈ (C១, C២, និង C៣) ក្នុងវិស័យអាទិភាព (សំណង់ មេកានិក អគ្គិសនី/អេឡិចត្រូនិក សេវាកម្មធុរកិច្ច/ព័ត៌មានវិទ្យា និងកម្មន្តសាល) ចំនួន ៥.៥២៩នាក់ ក្នុងឆ្នាំ២០១៧ និង២០១៨ ដែលមានការកើនឡើងជាងឆ្នាំមុនៗ ដោយសារកំណើននៃការផ្តល់អាហារូប-ករណ៍របស់រាជរដ្ឋាភិបាល គម្រោង ADB/AFD, ការផ្សព្វផ្សាយ, និងការធ្វើទំនើបកម្មសម្ភារះបរិក្ខារ<br>▪ បានបណ្តុះបណ្តាលសិស្សបច្ចេកទេសវិជ្ជាជីវៈ កម្រិតជាន់ខ្ពស់បច្ចេកទេស/ឯកទេស និងវិស្វករ ក្នុងវិស័យអាទិ៍ភាព (សំណង់ មេកានិក អគ្គិសនី/អេឡិចត្រូនិក សេវាកម្មធុរកិច្ច/ព័ត៌មានវិទ្យា និងកម្មន្តសាល) ចំនួន ៩.១០៥នាក់ ដែលមានការកើនឡើងធៀបនឹងឆ្នាំមុនៗ ដោយសាររាជរដ្ឋាភិបាលបានបង្កើនអាហារូប-ករណ៍, ការផ្សព្វផ្សាយ, និងការធ្វើទំនើបកម្មសម្ភារះបរិក្ខារ។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងឆ្នាំ២០១៧-២០១៨ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីសុវត្ថិភាព ការផ្ទេរបច្ចេកវិទ្យា និងបរិស្ថានឧស្សាហ-កម្ម ដល់ម្ចាស់រោងចក្រ សហគ្រាសក្នុងស្រុក បានចំនួន ១២ដង ដោយមានសិក្ខាកាមចូលរួមចំនួន ២.២៧០នាក់ ដើម្បីបញ្ជ្រាបចំណេះដឹងដល់កម្មករ និយោជិត ពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា។<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា÷<br>ក្នុងឆ្នាំ២០១៧÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ វិទ្យាស្ថានជាតិសង្គមកិច្ច មាននិស្សិតកំពុងសិក្សាចំនួន ៤៣៣នាក់ (ស្រី ២១១នាក់) ក្នុងនោះនិស្សិតថ្នាក់បរិញ្ញាបត្រសង្គមកិច្ច មានចំនួន ១០៦នាក់, និស្សិតបរិញ្ញាបត្រសង្គមវិទ្យា មានចំនួន ២៧នាក់, និស្សិតបរិញ្ញាបត្រកិច្ចគាំពារសង្គម មានចំនួន ៤៦នាក់, និស្សិតបរិញ្ញាបត្រគ្រប់គ្រងសាធារណៈ មានចំនួន ៥៥នាក់, បរិញ្ញាបត្ររដ្ឋបាលសាធារណៈចំនួន ១០៥នាក់, ថ្នាក់បរិញ្ញាបត្រគោលនយោបាយសង្គមចំនួន ៨នាក់, និស្សិតបរិញ្ញាបត្រគោល-នយោបាយសាធារណៈ មានចំនួន ១៥នាក់, និស្សិតបរិញ្ញាបត្រភាសាអង់គ្លេស មានចំនួន ៥៥នាក់, និងនិស្សិតបរិញ្ញាបត្រវិស្វកម្មឧបករណ៍សប្បនិម្មិត និងរណប មានចំនួន ១៦នាក់<br>▪ បានបណ្តុះបណ្តាលរយៈពេលខ្លីលើជំនាញសង្គមកិច្ច ចំនួន ២វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ១០៥នាក់ (ស្រី៣៦នាក់)<br>▪ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបន្ទាយព្រាប និងមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពោធិ៍សែនជ័យ បានទទួលសិស្ស ចំនួន ១២៣នាក់ (ស្រី ២៧នាក់) លើមុខជំនាញអេឡិចត្រូនិក ៣១នាក់, កសិកម្ម ១៩នាក់, ផ្នែកម៉ាស៊ីន ១៧នាក់, កាត់ដេរ២០នាក់, ជួសជុលម៉ូតូ១៤នាក់, ផ្នែកខ្សោយសតិបញ្ញា ១៣នាក់, សម្ពាង ០២នាក់ និងជួសជុលទូរស័ព្ទ ០៧នាក់ និងបានដោះស្រាយការងារ និងមុខរបរជូនជនពិការចំនួន ០៥នាក់។<br>ក្នុងឆ្នាំ២០១៨÷<br>▪ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបន្ទាយព្រាប និងមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពោធិ៍សែនជ័យ បានទទួលសិស្សចំនួន ១១៥នាក់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ស្រី ២៦នាក់ លើមុខជំនាញអេឡិចត្រូនិក ៣០នាក់, កសិកម្ម ០៦នាក់, ផ្នែកម៉ាស៊ីន ១៩នាក់, កាត់ដេរ ១៤នាក់, ជួសជុលម៉ូតូ ០៩នាក់, ផ្នែកខ្សោយសតិបញ្ញា១២នាក់, សម្ពាង០៦នាក់ និងជួសជុលទូរស័ព្ទ ១៨នាក់ និងបានដោះស្រាយការងារ និងមុខរបរជូនជនពិការចំនួន ៥០នាក់<br>▪ វិទ្យាស្ថានជាតិសង្គមកិច្ចមាននិស្សិតកំពុងសិក្សាចំនួន ៥០៣នាក់ (ស្រី២៦៧នាក់) កំពុងបន្តការសិក្សា ក្នុងនោះ និស្សិតថ្នាក់បរិញ្ញាបត្រសង្គមកិច្ចចំនួន ១០១នាក់, បរិញ្ញាបត្រសង្គមវិទ្យា៥៩នាក់, បរិញ្ញាបត្រកិច្ចគាំពារសង្គមចំនួន៥៥នាក់, ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងសាធារណៈ ៩០នាក់, បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ៩៩នាក់, បរិញ្ញាបត្រគោលនយោបាយសង្គម ០៥នាក់, បរិញ្ញាបត្រគោលនយោបាយសាធារណៈ ១៦នាក់, បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស៣៥នាក់ និងបរិញ្ញាបត្រវិស្វកម្មឧបករណ៍សិប្បនិម្មិត និងរណប ចំនួន ២៧នាក់<br>▪ បានបណ្តុះបណ្តាលរយៈពេលខ្លីលើជំនាញសង្គមកិច្ច ០៤វគ្គ ដែលមានអ្នកចូលរួមចំនួន ១០៩នាក់។<br>- រដ្ឋបាលខេត្តកណ្តាល÷<br>▪ ក្នុងឆ្នាំ២០១៧ មន្ត្រីការិយាល័យស្តង់ដារ និងមាត្រាសាស្ត្រចំនួន ៣នាក់ ត្រូវបានចាត់តាំងចូលរួមវគ្គបណ្តុះបណ្តាលវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រអាស៊ីប៉ាស៊ីហ្វិក សម្រាប់ជម្ងឺលេចឡើងថ្មីវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកវិទ្យាមាត្រាសាស្ត្រ វគ្គបំប៉នស្តីពីការត្រួតពិនិត្យជែបាញ់ប្រេង | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ក្នុងឆ្នាំ២០១៨ មន្ត្រីការិយាល័យស្តង់ដារ និងមាត្រាសាស្ត្រ ត្រូវបានចាត់តាំងចូលរួមវគ្គបណ្តុះបណ្តាល នៅមជ្ឈមណ្ឌលជាតិមាត្រាសាស្ត្រ ស្តីពីការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាជាតិសម្គាល់អំបិលដែលមានបញ្ចូលជាតិអ៊ីយ៉ូដ ការត្រួតពិនិត្យរង្វាស់រង្វាល់ថាមពលអគ្គិសនី ការលើកកម្ពស់ការគ្រប់គ្រងរោងចក្រ/សហគ្រាស ជំរុញផលិតភាព និងសុវត្ថិភាពចំណីអាហារ និងភេសជ្ជៈ ការត្រួតពិនិត្យទំនិញផលិត និងទំនិញវេចខ្ចប់ ការត្រួតពិនិត្យដៃបាញ់ប្រេង ការត្រួតពិនិត្យ និងប្រើប្រាស់ជញ្ជីងក្រោម ១.០០០ គីឡូក្រាម។ | |
| - ផ្តល់អាទិភាពដល់ការបង្កើតសាលាមធ្យមសិក្សាបច្ចេកទេសឱ្យបានច្រើន (ទាំងក្នុងប្រព័ន្ធអប់រំទូទៅ ទាំងក្រៅប្រព័ន្ធ) ដោយផ្តោតលើផ្នែកសំខាន់ៗ ដូចជាអគ្គិសនី ព័ត៌មានវិទ្យា កុំព្យូទ័រ ម៉ាស៊ីន ការជួសជុល និងការដំឡើងរថយន្តនិងម៉ូតូ ការកែច្នៃកសិផល និងសិប្បកម្ម | មធ្យម ទៅ វែង | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>ក្នុងឆ្នាំ២០១៧-២០១៨÷<br>▪ បានដំឡើងកម្រិតបណ្តុះបណ្តាលពីកម្រិតវិញ្ញាបនបត្រ ទៅកម្រិតជាន់ខ្ពស់បច្ចេកទេស/ឯកទេស និងវិស្វករ ដល់គ្រឹះស្ថានចំនួន ១៥ ព្រមទាំងបានសាងសង់រោងជាងបន្ថែមនៅគ្រឹះស្ថានចំនួន ៩ និងបំពាក់សម្ភារៈបណ្តុះបណ្តាលបន្ថែមដល់គ្រឹះស្ថានចំនួន ២៨<br>▪ បានចុះបញ្ជីកាគ្រឹះស្ថានបណ្តុះបណ្តាលឯកជនចំនួន ៥<br>▪ បានចុះអនុស្សារណៈ (MOU) ជាមួយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិដើម្បីពង្រីកការផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សរុបចំនួន ១៧អនុស្សារណៈ<br>▪ បានចុះអនុស្សារណៈ ជាមួយសហគ្រាសចំនួន ៥៣អនុស្សារណៈ ដើម្បីសិស្ស-និស្សិតចុះកម្មសិក្សា និងរកការងារធ្វើ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានចុះអនុស្សារណៈ ជាមួយគ្រឹះស្ថានបណ្តុះបណ្តាលក្នុងប្រទេស និងក្រៅប្រទេសចំនួន ១២៩អនុស្សារណៈ ដើម្បីគ្រូ និងសិស្សផ្លាស់ប្តូរទស្សនកិច្ចសិក្សា និងទទួលបានអាហារូបករណ៍។<br>- ក្រសួងអប់រំ យុវជន និងកីឡា៖ នៅឆ្នាំ២០១៨ មានវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសចំនួន ១៤ ស្ថិតក្នុងរាជធានីភ្នំពេញ និងខេត្តចំនួន ១៣ ដែលមានសិស្សសរុបចំនួន ១.៤៧១ ដែលផ្តោតលើជំនាញអគ្គិសនី អេឡិចត្រូនិច បសុវប្បកម្ម កសិកម្ម ក្សេត្រសាស្ត្រ និងមេកានិច។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍៖ បានចូលរួមសិក្ខាសាលាស្តីពីគោលនយោបាយអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។ | |
| - រៀបចំផែនការបណ្តុះបណ្តាលបច្ចេកទេស និងវិទ្យាសាស្ត្រ ដែលបម្រើឱ្យវិស័យឧស្សាហកម្ម ដោយរួមមានផែនការវិនិយោគច្បាស់លាស់ និងក្នុងទស្សនវិស័យរយៈពេលវែង | ២០១៥ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖<br>▪ បានរៀបចំនិងដាក់ឱ្យអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ និងបានអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលលើវិស័យអាទិភាព និងសម្រាប់វិក្រឹត្យការសមត្ថភាពគ្រូបច្ចេកទេស ដើម្បីពង្រីកការបណ្តុះបណ្តាលបែបទំនើបដែលឈរលើស្តង់ដាសមត្ថភាពចាប់ពីឆ្នាំ២០១៧<br>▪ បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល និងបានបង្កើនការវិភាជថវិកាសម្រាប់គាំទ្រការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ចំនួន ៤,៤៥% នៅឆ្នាំ២០១៨ និងបានខិតខំកៀរគរប្រភពធនធានពីដៃគូអភិវឌ្ឍន៍ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានបន្តអនុវត្តផែនការសកម្មភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ឆ្នាំ២០១៤-២០១៨ ដោយផ្តោតលើវិស័យអាទិភាពចំនួន ៥ រួមមាន សំណង់ អគ្គិសនី មេកានិករថយន្ត កម្មន្តសាល និងធុរកិច្ច/ព័ត៌មានវិទ្យា ដើម្បីគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្ម។<br>- ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ បានជំរុញអនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា<br>▪ បានរៀបចំនិងផ្សព្វផ្សាយសេចក្តីណែនាំប្រតិបត្តិ និងឯកសារមូលដ្ឋានស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅតាមគ្រឹះស្ថានមធ្យមសិក្សា និងអប់រំបច្ចេកទេស<br>▪ បានផ្សព្វផ្សាយវិធីរៀន និងបង្រៀន STEM ដល់គ្រូអនុវិទ្យាល័យ និងវិទ្យាល័យ<br>▪ បានរៀបចំឱ្យសិស្សរៀនអនុវត្តពិសោធន៍វិទ្យាសាស្ត្រ រចនារូបភាពក្នុងកុំព្យូទ័រដោយប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាទំនើប តាមរយៈរថយន្ត STEM ចល័ត<br>▪ បានអភិវឌ្ឍសៀវភៅអប់រំ STEM សៀវភៅវិស្វកម្ម សៀវភៅរឿង STEM និងចែកដល់សិស្សវិទ្យាល័យ និងអនុវិទ្យាល័យ និងដាក់នៅតាមបណ្ណាល័យ<br>▪ បានបន្តអនុវត្តកម្មវិធីតេស្តតាមប្រព័ន្ធព័ត៌មានវិទ្យា លើមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងប្រវត្តិវិទ្យា។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានចូលរួមរៀបចំផែនការបណ្តុះបណ្តាលបច្ចេកទេស និងវិទ្យាសាស្ត្រដែលបម្រើឱ្យវិស័យឧស្សាហកម្ម។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| - ជំរុញស្ថាប័ននីយកម្មនូវកម្មវិធីប្រព័ន្ធកម្មសិក្សា (Apprenticeship Schemes) ដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធលើកទឹកចិត្តដល់ក្រុមហ៊ុន និងសហគ្រាស ដែលទទួលអនុវត្តតាមប្រព័ន្ធកម្មសិក្សាបែបនេះ | ២០១៥ ទៅ មធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានរៀបចំ និងដាក់ឱ្យអនុវត្តគោលនយោបាយកម្មសិក្សា នៅឆ្នាំ ២០១៨ និងចាត់តាំងជនបង្គោលសម្រាប់ទំនាក់ទំនងជាមួយឧស្សាហកម្ម នៅគ្រប់គ្រឹះស្ថាន TVET ចំនួន ៣៩<br>▪ បានធ្វើការសិក្សាស្តីពីការធ្វើស្ថាប័ននីយកម្មប្រព័ន្ធហ្វឹកហ្វឺនកូនជាង/កម្មសិក្សា ក្រោមការគាំទ្ររបស់អង្គការអន្តរជាតិខាងការងារ ឆ្នាំ២០១៧ និងឆ្នាំ២០១៨<br>▪ បានបង្កើនការផ្តល់ធ្វើការហ្វឹកហ្វឺនកូនជាងបានចំនួន ៥១.០០១ នាក់ នៅក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ ដោយសារការពង្រឹងយន្តការអធិការកិច្ចការងារ និងការកើនឡើងនៃការចុះបញ្ជីសហគ្រាសគ្រឹះស្ថាន។ | |
| - ពង្រឹងការបណ្តុះបណ្តាលជំនាញឆ្លើយតបនឹងតម្រូវការរបស់វិស័យឯកជនទាំងវិន័យ កម្រិតជំនាញ និងសមត្ថភាពតាមរយៈការធ្វើសហប្រតិបត្តិការជាមួយនឹងវិនិយោគិនបរទេសគោលដៅមានដូចជាការបង្កើតមជ្ឈមណ្ឌលហ្វឹកហ្វឺនជំនាញជប៉ុន កូរ៉េ សិង្ហបុរី។ | ២០១៥ ទៅ មធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានបង្កើតវិទ្យាស្ថានពហុបច្ចេកទេសមិត្តភាពកម្ពុជា-ចិនខេត្តព្រះសីហនុ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ក្រោមគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន តាមរយៈ Wuxi Vocational Institute of Commerce នៅឆ្នាំ២០១៧ និងចាប់ផ្តើមផ្តល់ការបណ្តុះបណ្តាលក្នុងឆ្នាំ២០១៨ លើមុខជំនាញ មេកានិករថយន្ត, អគ្គិសនី, សំណង់, ព័ត៌មានវិទ្យា, ទេសចរណ៍, និងបដិសណ្ឋារកិច្ចដល់សិស្ស-និស្សិតចំនួន ២១០នាក់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានដាក់ឱ្យដំណើរការមជ្ឈមណ្ឌលឡានឆាងមេគង្គនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ក្រោមគម្រោងឡានឆាងមេគង្គ នៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងឆ្នាំ២០១៨<br>▪ បានបង្កើតសាលាមធ្យមសិក្សាបច្ចេកទេស និងវិជ្ជាជីវៈផ្លូវស្ទូត្រ ចំនួន ៤ កន្លែង (NTTI, PPI, ITI, RTC BATTAMBANG)<br>▪ បានបង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យចំនួន៤ គឺ វិស័យសំណង់នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ, វិស័យអគ្គិសនីនៅវិទ្យា-ស្ថានពហុបច្ចេកទេសព្រះកុសុមៈ, វិស័យមេកានិករថយន្តនៅវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង និងវិស័យកម្មន្តសាលនៅវិទ្យា-ស្ថានជាតិពហុបច្ចេកទេសកម្ពុជា។ ក្រុមប្រឹក្សាជំនាញតាមវិស័យទាំងនេះ បានប្រជុំគណៈកម្មាធិការបច្ចេកទេសចំនួន ៧លើក ដើម្បីរៀបចំផែនការសកម្មភាព និងកំណត់ទិសដៅក្នុងការអភិវឌ្ឍសមត្ថភាព និងប្រសិទ្ធភាពនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេក-ទេស និងវិជ្ជាជីវៈ។<br>- ក្រសួងអប់រំ យុវជន និងកីឡា៖<br>▪ បានបង្កើនចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសរហូតដល់ចំនួន១៤ ក្នុងឆ្នាំ២០១៨ ដោយមានសិស្សសរុបចំនួន១.៤៧១<br>▪ បានបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍការអប់រំបច្ចេកទេសតំបន់អាស៊ី-អាគ្នេយ៍<br>▪ បានបង្កើតវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺដោយសហការជាមួយនឹងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍មួយចំនួន ដើម្បីជួយគាំទ្រដល់ការបណ្តុះបណ្តាលលើមុខជំនាញពាក់ព័ន្ធនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម÷<br>- កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិ មានថវិកា ៤៥លានដុល្លារ (កម្មវិធី ១៥លានដុល្លារ និងគម្រោង ៣០លានដុល្លារ) គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី និងមានរយៈពេលអនុវត្តពីឆ្នាំ២០១៧ ដល់២០២១។ បន្ថែមពីនេះ កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិ ទី២ មានថវិកា ៥០លានដុល្លារ (កម្មវិធី ១៥លានដុល្លារ និងគម្រោង ៣៥លានដុល្លារ) និងមានរយៈពេលអនុវត្តពីឆ្នាំ២០១៨ ដល់២០២៤ ដោយផ្តោតលើការកែលម្អវិទ្យាល័យធនធានចំនួន ៥០ ក្នុងនោះក៏បានគាំទ្រដល់ការអប់រំមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រ ដោយបំពាក់គ្រឿងបរិក្ខារពាក់ព័ន្ធនិងការផ្តល់អាហារូបករណ៍។<br>- គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា មានថវិកា ៤០លានដុល្លារ គាំទ្រដោយធនាគារពិភពលោក និងមានរយៈពេលអនុវត្តពីឆ្នាំ២០១៧ ដល់២០២២ ដោយផ្តោតលើការអនុវត្តអភិក្រមការគ្រប់គ្រងតាមសាលារៀន<br>- មូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំទី៣ មានថវិកា ២០,៦លានដុល្លារ ផ្តោតលើការអភិវឌ្ឍសមត្ថភាព និងកម្មវិធីអប់រំគ្រូបង្រៀន | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពដំណាក់កាលទី៣ មានថវិកា ២៧,៣លានដុល្លារ និងមានរយៈពេលអនុវត្តពីឆ្នាំ២០១៧ ដល់២០២២<br>- គម្រោងបង្កើតវិទ្យាស្ថានគរុកោសល្យនៅភ្នំពេញ និងបាត់ដំបង មានថវិកា ៣០លានដុល្លារ គាំទ្រដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន និងមានរយៈពេលអនុវត្តពីឆ្នាំ ២០១៧ ដល់២០២២។ ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសជប៉ុន (JICA) បាននិងកំពុងជួយពង្រឹងសមត្ថភាពមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ដល់គ្រូបង្រៀននៅតាមអនុវិទ្យាល័យ និងគាំទ្រដល់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាលើការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យឧស្សាហកម្ម រ៉ែ និងថាមពលវិស្វកម្ម បំពាក់សម្ភារៈពិសោធន៍ និងផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជាទៅសិក្សានៅប្រទេសជប៉ុន<br>- គម្រោងកែលម្អបរិស្ថានសាលារៀន និងការផ្គត់ផ្គង់សម្ភារៈបរិក្ខារអប់រំនៅកម្ពុជា មានថវិកា ៤០លានដុល្លារ គាំទ្រដោយប្រទេសចិន និងមានរយៈពេលអនុវត្តពីឆ្នាំ២០១៦ ដល់ ២០១៨។ គម្រោងនេះផ្តោតលើការសាងសង់ និងជួសជុលអគារអនុវិទ្យាល័យ បន្ទប់សម្រាប់គ្រូ សាលប្រជុំ បំពាក់សម្ភារៈកីឡា កុំព្យូទ័រ នៅតាមរាជធានី ខេត្ត១១ និងការបណ្តុះបណ្តាលមន្ត្រីអប់រំនៅប្រទេសចិន។<br>- គម្រោងកែលម្អការអប់រំនៅឧត្តមសិក្សា មានថវិកា ៩២,៥ លានដុល្លារ គាំទ្រដោយធនាគារពិភពលោក និងរយៈពេល | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | អនុវត្តពីឆ្នាំ២០១៨ ដល់២០២៤ ដោយផ្តោតលើ (១) ការកែលម្អគុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា និងការស្រាវជ្រាវផ្នែក STEM និងកសិកម្ម និង (២) កែលម្អអភិបាលកិច្ចអនុវិស័យឧត្តមសិក្សា។ | |
| - ជំរុញការបណ្តុះបណ្តាលត្រីភាគី "រដ្ឋស្ថាប័នបណ្តុះបណ្តាលក្រុមហ៊ុន/រោងចក្រ" ដើម្បីបំពាក់ជំនាញ និងបង្កើនផលិតភាព ជាពិសេសការដាក់បញ្ចូលក្នុងកម្មវិធីអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់ តាមរយៈកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ និងសមាគមឧស្សាហកម្ម | ២០១៥ ទៅ មធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានធ្វើការសិក្សាលទ្ធភាពដើម្បីបង្កើតមូលនិធិជាតិអភិវឌ្ឍជំនាញដែលមានការចូលរួមចំណែកពីវិស័យឯកជន និងភាគីពាក់ព័ន្ធក្រោមការគាំទ្ររបស់ ADB ឆ្នាំ២០១៧<br>▪ បានពង្រីកកម្មវិធីសាកល្បងភាពជាដៃគូរវាងសាធារណៈ និងឯកជន (PPP) ដល់គ្រឹះស្ថានសាធារណៈចំនួន ៧ លើជំនាញជាងកំបោរ ជាងផ្សា ជាងគ្រឿង អគ្គិសនី រថយន្ត បរិក្ខារត្រជាក់ អ៊ុបទិក និងសិល្បៈចំអិនម្ហូប ចំនួន ៥០០នាក់ ក្នុងឆ្នាំ២០១៧ និង ២០១៨។<br>- ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ បានដាក់ឱ្យដំណើរការមជ្ឈមណ្ឌលផ្សព្វផ្សាយព័ត៌មានទីផ្សារការងារនៅខេត្តកំពង់ចាម កំពង់ធំ និងតាកែវ មានអ្នកចូលរួម ១.៥០០នាក់ ស្រី ៧៩១នាក់ និងកំពុងដំណើរការរៀបចំមជ្ឈមណ្ឌលនៅខេត្តបន្ទាយមានជ័យ និងព្រះសីហនុ<br>▪ បានសហការជាមួយក្រុមហ៊ុនឯកជន ដើម្បីផ្សារភ្ជាប់ការបណ្តុះបណ្តាលបច្ចេកទេសនៅតាមគ្រឹះស្ថានសិក្សាជាមួយនឹងទីផ្សារការងារ។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ▪ រៀបចំសិក្ខាសាលាបច្ចេកវិទ្យាដោយមានកិច្ចសហប្រតិបត្តិការត្រីភាគីរវាងរដ្ឋ- ស្ថាប័នបណ្តុះបណ្តាលជារៀងរាល់សប្តាហ៍<br>▪ រៀបចំឱ្យមានការពិគ្រោះយោបល់ជាមួយវិស័យឯកជន ជារៀងរាល់ឆ្នាំ ទាក់ទងនឹងកម្មវិធីសិក្សារបស់វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។ | |
| - ពង្រីកការបណ្តុះបណ្តាលជំនាញនៅនឹងកន្លែង ដោយផ្តោតការយកចិត្តទុកដាក់លើពលករតាមរោងចក្រ ដើម្បីឱ្យពលករទាំងនោះទទួលបានការអប់រំបណ្តុះបណ្តាល និងផ្តល់ក្តីសង្ឃឹម ក្នុងការអភិវឌ្ឍជំនាញ និងបច្ចេកទេសក្នុងពេលអនាគត | ២០១៥ ទៅ មធ្យម | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានរៀបចំប្រព័ន្ធទទួលស្គាល់សមត្ថភាពជំនាញ តាមរយៈការអនុវត្តកម្មវិធីទទួលស្គាល់ការសិក្សាពីមុន (RPL) និងការទទួលស្គាល់សមត្ថភាពបច្ចុប្បន្ន (RCC) ដោយដាក់ចេញនូវគោលការណ៍ណែនាំ ឆ្នាំ២០១៧ និងឆ្នាំ២០១៨ បានកំណត់បង្កើតមជ្ឈមណ្ឌលធ្វើតេស្តបញ្ជាក់សមត្ថភាពនៅខេត្តតាកែវ សៀមរាប បាត់ដំបង កំពត ស្វាយរៀង និងខេត្តក្រចេះ<br>▪ បានអនុវត្តសាកល្បងលើកម្មវិធីទទួលស្គាល់ការសិក្សាពីមុន (RPL) ដល់សិក្ខាកាម ១៦២នាក់ ក្នុងឆ្នាំ២០១៨ លើមុខរបរការថែទាំ និងជួសជុលម៉ូតូ ការថែទាំនិងជួសជុលម៉ាស៊ីនជុនតូច និងការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ។<br>- ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ បានផ្តួចផ្តើមអនុវត្តកម្មវិធីអក្ខរកម្មសម្រាប់កម្មករ កម្មការិនីតាមរោងចក្រ ដោយសហការជាមួយដៃគូអភិវឌ្ឍនិងម្ចាស់រោងចក្រនៅរាជធានីភ្នំពេញ ខេត្តសៀមរាប កណ្តាល និងកំពង់ស្ពឺ។ កម្មវិធីនេះនឹងពង្រីកដល់ ១១ខេត្ត និងរាជធានីភ្នំពេញនៅឆ្នាំ២០១៨។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានកសាងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលនៃកម្មវិធីអក្ខរកម្មសម្រាប់កម្មករ កម្មការិនីនៅតាមរោងចក្រ<br>▪ បានអនុវត្តសាកល្បងកម្មវិធីសិក្សាអក្ខរកម្មសម្រាប់កម្មករ កម្មការិនីតាមរោងចក្រនៅ ៤ខេត្ត រាជធានី<br>▪ បានកសាងក្របខណ្ឌកម្មវិធីសិក្សាសម្រាប់ជំនាញមុខរបរងាយៗ ដើម្បីប្រើប្រាស់នៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍<br>▪ បានអនុវត្តគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត<br>▪ បានផ្សព្វផ្សាយកម្មវិធីអក្ខរកម្មជូនកម្មករ កម្មការិនីនៅតាមរោងចក្រ ៨០នាក់ ស្រី ៤៣នាក់ ស្មើ ៥៣,៧៥%<br>▪ បានបំប៉នសមត្ថភាពស្តីពីវិធីសាស្ត្របង្រៀនកម្មករ កម្មការិនីតាមរោងចក្រ ដល់គ្រូអក្ខរកម្ម ១១នាក់ ស្រី ៣នាក់ ដោយសហការជាមួយយូណេស្កូ។<br>- រដ្ឋបាលខេត្តស្វាយរៀង៖<br>▪ បានជំរុញរោងចក្រ សហគ្រាស គ្រឹះស្ថាន ដើម្បីអនុវត្តកាតព្វកិច្ចហ៊ឹកហ៊ឺនកូនជាង<br>▪ បានបន្តដំណើរការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈទាំងបរិមាណ និងគុណភាព<br>▪ ក្នុងឆ្នាំ២០១៨ វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនស្វាយរៀង បានបណ្តុះបណ្តាលកម្រិតបច្ចេកទេស និងឯកទេសវិជ្ជាជីវៈដល់សិក្ខាកាម សិស្ស និស្សិត ចំនួន ១.២៧៣ នាក់ ស្រី ៥៧៤ នាក់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ សហគ្រាស គ្រឹះស្ថានក្នុងខេត្តចំនួន ៦៤ បានដំណើរការហ្វឹកហ្វឺនកូនជាង សរុប ៣.៥៤៩ នាក់ស្រី ២.១៥៤ នាក់។ | |
| - ពង្រឹងការអប់រំនៅសាកលវិទ្យាល័យដែលទាក់ទងទៅនឹងវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រមូលដ្ឋានសំខាន់ៗផ្សេងទៀត និងវិស្វកម្ម ដោយពង្រឹងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍ ដើម្បីឈានទៅកសាងគុណភាពអប់រំសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍។ | មធ្យម ទៅ វែង | - ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ កំពុងបន្តបង្កើនធនធានសម្រាប់ដំណើរការបណ្តុះបណ្តាលជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា<br>▪ បានបញ្ចប់ការសាងសង់អគារ STEM កម្ពស់ ៨ជាន់ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ<br>▪ បានបញ្ចប់ការសាងសង់អគារSTEM កម្ពស់ ៦ជាន់ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានបំពាក់សម្ភារៈបរិក្ខារមន្ទីរពិសោធន៍ ដើម្បីឈានទៅកសាងគុណភាពអប់រំសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍ សម្រាប់ចូលរួមសហការពង្រឹងការអប់រំនៅសាកលវិទ្យាល័យដែលទាក់ទងទៅនឹងវិទ្យាសាស្ត្រមូលដ្ឋានសំខាន់ៗនិងវិស្វកម្មក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។ | |
| ***៩- ការជំរុញវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍*** | | | |
| - ជំរុញការរៀបចំនូវក្របខ័ណ្ឌគោលនយោបាយ និងយន្តការអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | មធ្យម ទៅ វែង | - ក្រសួងផែនការ បានរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣ ដែលជាឯកសារតែមួយគត់របស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បីឈានទៅសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ២០៣០ និងក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ ដោយបានធ្វើការណែនាំច្បាស់លាស់ដល់គ្រប់ក្រសួង ស្ថាប័នទាំងអស់ | - ក្រសួងផែនការ÷<br>▪ ក្របខ័ណ្ឌគតិយុត្ត និងការអនុវត្តក្របខ័ណ្ឌគតិយុត្តដែលនៅមានកម្រិត<br>▪ យន្តការស្ថាប័ននៅមានកម្រិត |

| វិធានការគោលនយោបាយ/ផែនការ សកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | រៀបចំធាតុចូលរបស់ខ្លួនសម្រាប់អនុវត្តក្នុងចតុកោណទី២ "ការធ្វើពិពិធកម្មសេដ្ឋកិច្ច" ដែលមានជ្រុង "ការកែលម្អប្រព័ន្ធឡជិស្ទីក ការលើកកម្ពស់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល" និងការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងការឆ្លើយតបបដិវត្តន៍ឧស្សាហកម្មទី៤" ដែលជារួមក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធជាមួយចតុកោណទី២ នេះ បានបំពេញទៅតាមការណែនាំរបស់ក្រសួង។ មកទល់ពេលនេះ ឯកសារ ផ.យ.អ.ជ. ២០១៩-២០២៣ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី សភាជាតិ ព្រឹទ្ធសភា និងឡាយព្រះហស្តដោយព្រះមហាក្សត្រលើព្រះរាជក្រមសម្រាប់អនុវត្តរួចរាល់ហើយ។<br>- ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ បានដាក់ឱ្យដំណើរការគេហទំព័រគ្រូ/មជ្ឈមណ្ឌលធនធានអប់រំ (Krou/Teacher Website) និងទំព័របណ្តាញសង្គមហ្វេសប៊ុកផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា (MoEYS Cambodia)<br>▪ បាននិងកំពុងផ្សព្វផ្សាយខ្លឹមសារព័ត៌មាន និងឯកសារក្នុងទម្រង់ឌីជីថល/អេឡិចត្រូនិក ជូនដល់សិស្ស និស្សិត គ្រូ សាស្ត្រាចារ្យ និងសាធារណជន<br>▪ បានបង្កើតប្រព័ន្ធគ្រប់គ្រងសាលារៀន (SMAS: School Management System) ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងរដ្ឋបាល ការពិនិត្យតាមដានថ្នាក់រៀន ការពិនិត្យតាមដានការបង្រៀន ចំណាត់ថ្នាក់សិក្សា ការគ្រប់គ្រងពិន្ទុសិស្ស និងការលើកកម្ពស់ទំនាក់ទំនងដ៏មានប្រសិទ្ធភាពរវាងសាលារៀន គ្រូ ឪពុក | ▪ ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស ធនធានសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់អភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅមានកម្រិត។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ម្ដាយសិស្ស/អាណាព្យាបាលសិស្ស និងសិស្ស តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាមូលដ្ឋាន<br>▪ បានផ្គត់ផ្គង់សម្ភារៈបរិក្ខារស្តង់ដារអប្បបរមាសម្រាប់រដ្ឋបាលសាលារៀន ជូនគ្រឹះស្ថានសិក្សាចំនួន ២៣២<br>▪ បានរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យស្ដីពីការធ្វើផែនការ និងចែកចាយសៀវភៅសិក្សាគោល<br>▪ បានអនុវត្តសៀវភៅណែនាំស្ដីពីនីតិវិធីអធិការកិច្ច<br>▪ បានបណ្ដុះបណ្ដាលអធិការអប់រំចំនួន ៧៣នាក់ ស្រី ៩នាក់<br>▪ បានបណ្ដុះបណ្ដាលនាយកវិទ្យាល័យ ១០៣នាក់ ស្រី ៧នាក់ ស្ដីពីប្រព័ន្ធអធិការកិច្ចថ្មី<br>▪ បានបំប៉នសមត្ថភាពស្ដីពីប្រព័ន្ធអធិការកិច្ចថ្មីដល់អធិការអប់រំ ចំនួន ៤២នាក់ ស្រី ១១នាក់<br>▪ បានបំប៉នសមត្ថភាពស្ដីពីបញ្ញត្តិនៃការធានាគុណភាពអប់រំដល់មន្ត្រីការិយាល័យអធិការកិច្ច ដែលមិនមែនអធិការ ចំនួន ២០៧នាក់ ស្រី ៤៦នាក់<br>▪ បានបំប៉នសមត្ថភាពស្ដីពីប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំដល់មន្ត្រីថ្នាក់ក្រោមជាតិ ក្រុមពិនិត្យតាមដាន និងបំប៉នថ្នាក់ស្រុក នៅខេត្តគោលដៅទាំង៤ ចំនួន ២០៧នាក់ ស្រី ៣៤នាក់<br>▪ បានតាមដានការធ្វើអធិការកិច្ចតាមកាលកំណត់<br>▪ បានធ្វើអធិការកិច្ចតាមប្រធានបទ “ការបង្រៀនសំណេរថ្នាក់ទី៦” នៅតាមសាលាបឋមសិក្សា ចំនួន ៣៩ និងប្រធានបទ “អត្រា | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | បញ្ចប់ការសិក្សានៅបឋមសិក្សា" នៅតាមសាលាបឋមសិក្សា ចំនួន ៣៤<br>▪ បានរៀបចំឧបករណ៍អធិការកិច្ចការបង្រៀនរូបវិទ្យានៅថ្នាក់ទី១២<br>▪ បានបញ្ចប់ការសាងសង់អគារមត្តេយ្យសិក្សាធនធានចំនួន ៤៣ខ្នង និងបឋមសិក្សាចំនួន១៩ខ្នង ស្មើ ១០០បន្ទប់ និងការិយាល័យអប់រំ យុវជន និងកីឡា ១៤ខ្នង<br>▪ បានធ្វើអធិការកិច្ចតាមប្រធានបទ ការបង្រៀន និងរៀនថ្នាក់ទី១២ នៅ ៤០សាលា<br>▪ បានរៀបចំឧបករណ៍សម្រាប់ធ្វើអធិការកិច្ចតាមប្រធានបទស្តីពី "ការបង្រៀនរូបវិទ្យា" នៅ១៤ខេត្ត នៅតាមសាលាមធ្យមសិក្សា ៣៩សាលា<br>▪ បានធ្វើអធិការកិច្ចតាមកាលកំណត់ និងអធិការកិច្ចតាមប្រធានបទរួមមាន "ការបង្រៀនរូបវិទ្យា" នៅតាមសាលាមធ្យមសិក្សា<br>▪ បានរៀបចំឧបករណ៍អធិការកិច្ចតាមប្រធាន "ការបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤" និង "ការបង្រៀននិងរៀនថ្នាក់ទី១២"។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានចូលរួមរៀបចំផែនការមេអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលរៀបចំដោយក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ | |
| - ជំរុញនិងលើកទឹកចិត្តការផ្ទេរបច្ចេកវិទ្យាថ្មីៗ ក្នុងវិស័យកម្មន្តសាល រួមទាំងផ្នែកសិប្បកម្ម | មធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>ក្នុងឆ្នាំ២០១៧-២០១៨÷<br>▪ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីសុវត្ថិភាព ការផ្ទេរបច្ចេកវិទ្យា និងបរិស្ថានឧស្សាហកម្ម ដល់ម្ចាស់រោងចក្រ សហគ្រាសក្នុងស្រុក | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | បានចំនួន ០៥ដង ដោយមានសិក្ខាកាមចូលរួមចំនួន ៥២៨នាក់ ដើម្បីបញ្ជ្រាបចំណេះដឹងដល់កម្មករ និយោជិត ពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យឧស្សាហកម្ម<br>▪ បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការផ្ទេរបច្ចេកវិទ្យារវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយសួនបច្ចេកវិទ្យាដេគូ (Daegu Technopark) នៃសាធារណរដ្ឋកូរ៉េ<br>▪ បានចុះអនុស្សារណៈនៃការយោគយល់គ្នា (MoU) រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយអង្គការកម្មសិទ្ធិបញ្ញាសិង្ហបុរី (IPOS)<br>▪ បានធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)<br>▪ បានចូលជាសមាជិកពេញសិទ្ធិទី១៥១ នៃសន្ធិសញ្ញាប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) និងចូលជាសមាជិក WIPO CASE ដែលជាមជ្ឈមណ្ឌលកណ្តាលមួយ បង្កើតឡើងដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)។ | |
| - ពង្រឹងការគ្រប់គ្រងមណ្ឌលថ្មៃប្រឌិត និងបង្កើតថ្មីកម្ពុជា ដើម្បីលើកកម្ពស់ការបង្កើតតក្កកម្ម និងការបណ្តុះបណ្តាលកម្មសិទ្ធិឧស្សាហកម្ម | មធ្យម ទៅ វែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានរៀបចំ PIP Information ផ្ញើទៅក្រសួងផែនការ ស្តីពីការបង្កើតមជ្ឈមណ្ឌលភ្ញាស់បច្ចេកវិទ្យា (Technology Incubation Center) ដើម្បីត្រៀមលើកសំណើទៅដៃគូអភិវឌ្ឍន៍ស្នើសុំថវិកាអនុវត្តគម្រោង។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| - ពង្រឹង និងកសាងសមត្ថភាពធនធានមនុស្សទៅតាមតម្រូវការសម្រាប់ការស្រាវជ្រាវ និង អភិវឌ្ឍន៍បច្ចេកវិទ្យាឧស្សាហកម្ម | មធ្យម ទៅ វែង | - ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ បានបញ្ជូនមន្ត្រី ១១នាក់ ស្រី ១នាក់ ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រ និងការស្រាវជ្រាវគោលនយោបាយវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងប្រទេសវិចីមួយខ្សែក្រវាត់មួយ ព្រមទាំងការវិភាគទិន្នន័យ<br>▪ បានដាក់ឱ្យអនុវត្តលក្ខខណ្ឌប្រតិបត្តិនាយកទទួលបន្ទុកស្រាវជ្រាវ និងនាយកមជ្ឈមណ្ឌលស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា<br>▪ បានបញ្ជូនគ្រូបង្រៀនឧត្តមសិក្សាចំនួន ៩ នាក់ទៅសិក្សានៅប្រទេសបារាំង ថ្នាក់បណ្ឌិតផ្នែក STEM តាមរយៈកម្មវិធីអាហារូបករណ៍សហហិរញ្ញប្បទានរវាងក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋាភិបាលបារាំង។<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានបង្កើតកម្មវិធី និងផ្តល់មូលនិធិស្រាវជ្រាវ និងនវានុវត្តន៍ដល់គ្រឹះស្ថានចំនួន៣ ដើម្បីសាស្ត្រាចារ្យ និងនិស្សិត ធ្វើការសិក្សាស្រាវជ្រាវបង្កើតស្នាដៃ រួមគ្នាដើម្បីចាប់យកបច្ចេកវិទ្យាថ្មី ដូចជា Robot, Drone, AI<br>▪ បានចូលរួមការប្រកួតប្រជែង Robot ថ្នាក់ជាតិ ចំនួន ២លើក និងអន្តរជាតិចំនួន ១លើក<br>▪ បានដាក់តាំងបង្ហាញស្នាដៃស្រាវជ្រាវរបស់សិស្ស-និស្សិតនៅក្នុង TVET-DAY ក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័នដាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានបង្កើតមជ្ឈមណ្ឌលឧត្តមភាព (Centers of Excellence) ចំនួន ៤ (២នៅភ្នំពេញ ១នៅខេត្តបាត់ដំបង និង ១នៅខេត្តសៀមរាប)។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានចូលរួមពង្រឹង និងកសាងសមត្ថភាពធនធានមនុស្ស ទៅតាមតម្រូវការសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាឧស្សាហកម្ម តាមរយៈការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាដោយធ្វើការពិភាក្សាជាមួយវិស័យឯកជនជារៀងរាល់ឆ្នាំ។ | |
| - សហការ និងជំរុញការសិក្សាស្រាវជ្រាវ និងការលើកទឹកចិត្តផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានពិនិត្យលើការផ្តល់អាទិភាពវិភាជថវិកាសម្រាប់ចំណាយលើកម្មវិធីដែលមានគោលដៅជំរុញការងារស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។<br>- ក្រសួងអប់រំ យុវជន និងកីឡា៖<br>▪ បានស្រាវជ្រាវលើប្រធានបទ ២១០ រួមមាន ផ្នែកកសិកម្ម ធនាគារ ហិរញ្ញវត្ថុ សេដ្ឋកិច្ច ទីផ្សារ ធុរកិច្ច ទេសចរណ៍ សំណង់ ឧស្សាហកម្ម រ៉ែ ថាមពល បរិស្ថាន វិទ្យាសាស្ត្រចំណីអាហារ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ វិទ្យាសាស្ត្រសុខាភិបាល បច្ចេកវិទ្យាជីវវិទ្យា វិទ្យាសាស្ត្រសង្គម វិទ្យាសាស្ត្រអប់រំ ភាពជាអ្នកដឹកនាំ ការគ្រប់គ្រង សហគ្រិនភាព ច្បាប់ សារទូរគមនាគមន៍ និងការសិក្សាអំពីទីផ្សារការងាររបស់និស្សិត<br>▪ បានបោះពុម្ពផ្សាយ ១៣១ ប្រធានបទរួមមាន ការបោះពុម្ពផ្សាយក្នុងស្រុក ៥៤ និងការបោះពុម្ពអន្តរជាតិ ៧៧។<br>- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម៖ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានកសាងផែនការមេជាតិស្តីពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកម្ពុជា ឆ្នាំ២០១៤-២០២០ និងចូលរួមកសាងផែនការសកម្មភាពផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០១៦-២០២៥<br>▪ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីសុវត្ថិភាព ការផ្ទេរបច្ចេកវិទ្យា និងបរិស្ថានឧស្សាហកម្ម ដល់ម្ចាស់រោងចក្រ សហគ្រាសក្នុងស្រុក បានចំនួន ០៥ដង ដោយមានសិក្ខាកាមចូលរួមចំនួន ៥២៨ នាក់ ដើម្បីបញ្ជ្រាបចំណេះដឹងដល់កម្មករ និយោជិត ពាក់ព័ន្ធការអភិវឌ្ឍវិស័យឧស្សាហកម្ម<br>▪ បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការផ្ទេរបច្ចេកវិទ្យារវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយសួនបច្ចេកវិទ្យាដេគូ (Daegu Technopark) នៃសាធារណរដ្ឋកូរ៉េ<br>▪ ដើម្បីលើកកម្ពស់សមត្ថភាព និងការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងបានបញ្ជូនមន្ត្រីជំនាញចំនួន ០៥រូប ឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងវេទិកាពិគ្រោះយោបល់ផ្សេងៗនៅបរទេស ដូចជាប្រទេសថៃ ចិន កូរ៉េ ជាដើម។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានចូលរួមសហការ និងជំរុញការសិក្សាស្រាវជ្រាវ និងការលើកទឹកចិត្តផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ | |
| - សិក្សាលទ្ធភាពបង្កើតសួនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាភ្ជាប់នឹងសួនឧស្សាហកម្ម និងតំបន់ | មធ្យម ទៅ វែង | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០១៧-២០១៨ បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ដោយពិចារណាពីលទ្ធភាពបង្កើតសួនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាភ្ជាប់នឹងសួនឧស្សាហកម្ម និង | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| សេដ្ឋកិច្ចពិសេសនានា ដើម្បីផ្តល់សេវាពិសោធន៍ និងសិក្សាស្រាវជ្រាវដល់ឧស្សាហកម្ម | | តំបន់សេដ្ឋកិច្ចពិសេសនានា ដើម្បីផ្តល់សេវាពិសោធន៍ និងសិក្សាស្រាវជ្រាវដល់ឧស្សាហកម្ម។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានរៀបចំព័ត៌មានកម្មវិធីវិនិយោគសាធារណៈ (PIP Information) ផ្ញើទៅក្រសួងផែនការ ស្តីពីការបង្កើតមជ្ឈមណ្ឌលភ្ញាស់បច្ចេកវិទ្យា (Technology Incubation Center) ដើម្បីត្រៀមលើកសំណើទៅដៃគូអភិវឌ្ឍន៍ស្នើសុំថវិកាអនុវត្តគម្រោង។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានចូលរួមសិក្សាលទ្ធភាពបង្កើតសួនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ភ្ជាប់នឹងសួនឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេសនានា ដើម្បីផ្តល់សេវាពិសោធន៍ និងសិក្សាស្រាវ-ជ្រាវដល់ឧស្សាហកម្ម។ | |
| - បង្កើតយន្តការប្រឡងប្រណាំងអ្នកជំនាញបច្ចេក-វិទ្យា អ្នកមានគំនិតផ្តួចផ្តើមធុរកិច្ច វិស្វករដែលមានទេពកោសល្យ ដើម្បីចម្រាញ់ឧស្សាហករ ដែលមានទេពកោសល្យ និងបង្កើតកម្លាំងចលករឱ្យខិតខំបង្កើតនវានុវត្តន៍ ជាពិសេសក្នុងចំណោមវិស្វករ និងសហគ្រិនវ័យក្មេង | ២០១៥ | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>- ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ បានរៀបចំការប្រកួតវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិត-វិទ្យា នៅតាមអនុវិទ្យាល័យ និងវិទ្យាល័យ ក្នុងខេត្តបាត់ដំបង កំពង់ចាម និងសៀមរាប<br>▪ បានបង្កើនថវិកាឧបត្ថម្ភសម្រាប់ជ័យលាភីថ្នាក់ជាតិ និងអន្តរជាតិ<br>▪ បានផ្សព្វផ្សាយលទ្ធផលតេស្តវាយតម្លៃលទ្ធផលសិក្សាថ្នាក់ជាតិថ្នាក់ទី៦<br>▪ បានបំប៉នសមត្ថភាពលើការវិភាគទិន្នន័យតេស្តវាយតម្លៃកម្រិតអន្តរជាតិ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានបំប៉នសមត្ថភាពស្តីពីការវិភាគទិន្នន័យតេស្តវាយតម្លៃលទ្ធផលសិក្សាថ្នាក់ជាតិថ្នាក់ទី៨ លើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា ដល់មន្ត្រីជំនាញ។<br>▪ សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡងថ្ងៃទី២១-២២ ខែសីហា ឆ្នាំ២០១៧ មានបេក្ខជនចុះឈ្មោះចូលប្រឡង ចំនួន ១០១.៤១៣នាក់។ បេក្ខជនប្រឡងជាប់មានចំនួន ៦៣.៦៦៨នាក់ ស្មើនឹង ៦៣,៨% នៃបេក្ខជនដែលបានប្រឡងចំនួន ៩៩.៧២៨នាក់ ក្នុងនោះ ក្រុមជម្រើសផ្នែកវិទ្យាសាស្ត្រ មានបេក្ខជនប្រឡងជាប់ចំនួន ៣៤.២៣៤ ស្មើនឹង ៥៣,៤០% នៃបេក្ខជនដែលបានមកប្រឡងចំនួន ៦៤.១០៣នាក់។ សិស្សប្រឡងជាប់និទ្ទេស A មានចំនួន ៤២៤នាក់ ស្រី ២២១នាក់។<br>▪ សម្រាប់ឆ្នាំសិក្សា ២០១៧-២០១៨ បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ៦៧,០៧% កើន ៣,២៣% ស្រី ៦៩,៣៨% កើន ៣,៤៦% ក្នុងចំណោមបេក្ខជនដាក់ពាក្យចំនួន ១៥៤.១៣៥នាក់។ សិស្សជាប់និទ្ទេស A មាន ៤០៨នាក់ ថយ ១៦នាក់ ស្រី ១៩៤នាក់ ស្រីថយ ១៧នាក់។ បេក្ខជនមានពិការភាពភ្នែក និងគ ថ្លង់ ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ២៦នាក់ ស្រី ៤នាក់ ប្រឡងជាប់ ១០០%។<br>▪ បេក្ខជនប្រឡងជាប់សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈកម្រិត៣ ផ្នែកអគ្គិសនី ៨៤នាក់ ស្រី ១៥,៤៧% អេឡិចត្រូនិច ៣៤នាក់ ស្រី ៣៥,២៩% គ្រេស្រ្តសាស្ត្រ ២៣នាក់ ស្រី ៨២,៦០% និង | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | បសុវប្បកម្ម ៥៤នាក់ ស្រី ៨១,៤៨% ក្នុងចំណោមបេក្ខជនសរុប ចំនួន ១.២៩៨នាក់។<br>បន្ថែមពីនេះ ក្នុងឆ្នាំ២០១៧ ក្រសួងអប់រំ យុវជន និងកីឡាបាន÷<br>▪ បញ្ជូនសិស្សថ្នាក់ទី៥ និងទី៦ ចំនួន ១៦នាក់ ស្រី ៧នាក់ ចូលរួមប្រឡងប្រជែងសិស្សពូកែគណិតវិទ្យាអូឡាំព្យាដអន្តរជាតិ នៅហ្វី-លីពីន ក្នុងនោះសិស្សមួយក្រុម ៤នាក់ បានមេដាយសំរិទ្ធ និងសិស្ស៦នាក់ បានបណ្ណសរសើរ<br>▪ ជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិត-វិទ្យា និងរូបវិទ្យាថ្នាក់ទី៩ និងថ្នាក់ទី១២ ចំនួន៦០នាក់ ស្រី ២២នាក់ ដែលក្នុងមួយមុខវិជ្ជា និងមួយកម្រិតថ្នាក់ជ្រើសយក ១០នាក់<br>▪ បញ្ជូនសិស្សពូកែ ៦រូប ស្រី ៣រូប ទៅចូលរួមប្រកួតប្រជែងអ្នកវិទ្យាសាស្ត្រវ័យក្មេង អាស៊ានបូកបីលើកទី៦ នៅវៀតណាមទទួលបានមេដាយ ១៤គ្រឿង មាស១ ប្រាក់១០ និងសំរិទ្ធ៣<br>▪ បញ្ជូនសិស្សពូកែគណិតវិទ្យា ១០រូប ស្រី ៤រូប ទៅចូលរួមប្រឡងប្រជែងគណិតវិទ្យាអូឡាំព្យាដអន្តរជាតិលើកទី៥៨ នៅប្រេស៊ីល ទទួលបានពានរង្វាន់កិត្តិយស១<br>▪ បញ្ជូនសិស្សពូកែរូបវិទ្យា ៥រូប ស្រី ២រូប ទៅចូលរួមប្រឡងប្រជែងរូបវិទ្យាអូឡាំព្យាដអន្តរជាតិ លើកទី៤៨ នៅឥណ្ឌូនេស៊ី ទទួលបានពានរង្វាន់កិត្តិយស៥<br>▪ បញ្ជូនសិស្សពូកែ ៦រូប ស្រី ២រូប ទៅចូលរួមប្រឡងប្រជែងអ្នកវិទ្យាសាស្ត្រវ័យក្មេងអូឡាំព្យាដអន្តរជាតិលើកទី១៤ នៅប្រទេសហូឡង់ ទទួលបានមេដាយសំរិទ្ធ១គ្រឿង | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បញ្ជូនសិស្សពូកែគណិតវិទ្យា និងរូបវិទ្យា ៤រូប ស្រី ១រូប ចូលរួមប្រកួតប្រជែងជ្រើសរើសជើងឯកអ្នកវិទ្យាសាស្ត្រវ័យក្មេងរបស់ស៊ីមេអូ ក្នុងសន្និបាតថ្នាក់តំបន់លើកទី១១ ឆ្នាំ២០១៨នៅម៉ាឡេស៊ី<br>▪ ជ្រើសរើសបណ្តុះបណ្តាល និងដឹកនាំសិស្សានុសិស្ស ៣៣រូប ចូលរួមប្រកួតប្រជែងក្នុងកម្មវិធី "ទិវាប្រវត្តិសាស្ត្រធម្មជាតិសកល" នៅចុងជីង សាធារណរដ្ឋប្រជាមានិតចិន។ សិស្ស ៣នាក់ ទទួលមេដាយមាស, ១៤នាក់ មេដាយប្រាក់, និង ១៦នាក់ មេដាយសំរិទ្ធ។<br>រីឯក្នុងឆ្នាំ២០១៨ ក្រសួងអប់រំ យុវជន និងកីឡា បាន៖<br>▪ រៀបចំការចូលរួមប្រឡងរបស់សិស្សផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រអូរឡាំព្យាដលើកទី១៥ ឆ្នាំ២០១៨ មានសិស្សបឋមសិក្សា ២៤នាក់ ជាលទ្ធផលសិស្សទទួលបានមេដាយប្រាក់ ២នាក់ ផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រ និងសិស្សទទួលបានមេដាយសំរិទ្ធ ៥នាក់ ផ្នែកគណិតវិទ្យា ៣នាក់ និងផ្នែកវិទ្យាសាស្ត្រ ២នាក់ នៅចិន<br>▪ ជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យាថ្នាក់ទី៩ និងថ្នាក់ទី១២ ចំនួន ៦០នាក់ ស្រី ២៨នាក់ ដែលក្នុងមួយមុខវិជ្ជា និងមួយកម្រិតថ្នាក់ជ្រើសយក ១០ នាក់<br>▪ បញ្ជូនសិស្សពូកែរូបវិទ្យា និងគណិតវិទ្យា ៤នាក់ ស្រី ១នាក់ ទៅចូលរួមប្រកួតប្រជែងអ្នកស្រាវជ្រាវ អ្នកវិទ្យាសាស្ត្រ និងអ្នកគណិតវិទ្យាវ័យក្មេងរបស់ស៊ីមេអូលើកទី១១ នៅម៉ាឡេស៊ី ទទួលបានពានរង្វាន់ពិសេស ៤ គ្រឿង<br>▪ បញ្ជូនសិស្សពូកែរូបវិទ្យា ៨នាក់ ស្រី ៣នាក់ ទៅចូលរួមប្រកួតប្រជែងរូបវិទ្យាអូឡាំព្យាដទ្វីបអាស៊ី លើកទី១៩ នៅវៀតណាម | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បញ្ជូនសិស្សពូកែគណិតវិទ្យា ៦នាក់ ស្រី ៣នាក់ ទៅចូលរួមប្រឡងប្រជែងគណិតវិទ្យាអូឡាំព្យាដអន្តរជាតិលើកទី៥៩ នៅរ៉ូម៉ានី<br>▪ បញ្ជូនសិស្សពូកែរូបវិទ្យា ៥នាក់ ស្រី ២នាក់ ទៅចូលរួមប្រឡងប្រជែងរូបវិទ្យាអូឡាំព្យាដអន្តរជាតិលើកទី៤៩ នៅព័រទុយហ្គាល់<br>▪ បញ្ជូនសិស្សពូកែ ៦នាក់ ស្រី ២នាក់ ទៅចូលរួមប្រកួតប្រជែងអ្នកវិទ្យាសាស្ត្រវ័យក្មេងអាស៊ានបូកបីលើកទី៧ នៅម៉ាឡេស៊ី ទទួលបានមេដាយ ៩ គ្រឿង ក្នុងនោះមេដាយមាស ១ ប្រាក់ ១ និងសំរឹទ្ធ ៧។<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានរៀបចំការប្រកួតប្រជែងជំនាញថ្នាក់ជាតិលើកទី៦ នៅឆ្នាំ ២០១៧ លើ ៥ មុខជំនាញ (តបណ្តាញអគ្គិសនី, ផ្សារអគ្គិសនី, រៀបឥដ្ឋ, IT Software Solution for Business និង Web Design) មានបេក្ខជនចំនួន ៤៤នាក់<br>▪ បានសហការជាមួយក្រុមហ៊ុន SCG រៀបចំការប្រកួតប្រជែងជំនាញបូក និងជំនាញប្រកដំបូល ដែលមានបេក្ខជន ១៤ក្រុម ចំនួន ៣៤នាក់ចូលរួម<br>▪ បានចូលរួមការប្រកួតប្រជែង Robot ថ្នាក់ជាតិចំនួន ២លើក និងអន្តរជាតិចំនួន ១លើក<br>▪ បានបញ្ជូនបេក្ខជនចំនួន ១៣នាក់ ទៅចូលរួមការប្រកួតប្រជែងជំនាញថ្នាក់អាស៊ាននៅប្រទេសថៃលើ៨មុខជំនាញនៅឆ្នាំ២០១៨។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍÷<br>ក្នុងឆ្នាំ២០១៧÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានចូលរួមបង្កើតយន្តការប្រឡងប្រណាំងអ្នកជំនាញបច្ចេកវិទ្យាក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន<br>▪ សហការជាមួយក្រសួងអប់រំក្នុងការបង្កើតកម្មវិធីប្រកួតប្រជែងផ្នែកសរសេរកម្មវិធីកុំព្យូទ័រ។ | |
| - ពិនិត្យលទ្ធភាពវិនិយោគលើវិទ្យាស្ថានស្រាវជ្រាវរដ្ឋ ដោយផ្តោតទាំងស្រុងទៅលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ពិសេស ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងវិស័យអាទិភាពនីមួយៗ ដោយជ្រើសរើសអ្នកវិទ្យាសាស្ត្រ និងវិស្វករមានសមត្ថភាពជាមួយនឹងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍សមស្រប | មធ្យម ទៅ វែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានពិភាក្សាកម្រិតបច្ចេកទេសអំពីការផ្តល់ហិរញ្ញប្បទាន ចំពោះវិទ្យាស្ថានស្រាវជ្រាវរដ្ឋ<br>▪ បានពិនិត្យ និងស្រាវជ្រាវច្បាប់ និងលិខិតបទដ្ឋានដែលមានស្រាប់ដើម្បីពិនិត្យលទ្ធភាពរៀបចំគ្រឹះស្ថានសាធារណៈរដ្ឋបាល និងជំរុញនិងពង្រឹងតួនាទីរបស់គ្រឹះស្ថានឱ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិ។<br>- ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ បង្កើតកម្មវិធីអាហារូបករណ៍សហហិរញ្ញប្បទានផ្នែកបណ្ឌិត STEM ជាមួយរដ្ឋាភិបាលបារាំងដើម្បីបញ្ជូនគ្រូឧត្តមសិក្សាទៅបន្តការសិក្សានៅប្រទេសបារាំង<br>▪ រៀបចំនិងផ្សព្វផ្សាយសេចក្តីណែនាំប្រតិបត្តិ និងឯកសារមូលដ្ឋានស្តីពី ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យានៅតាមគ្រឹះស្ថានមធ្យមសិក្សា និងអប់រំបច្ចេកទេស<br>▪ អភិវឌ្ឍការអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា<br>▪ រៀបចំឱ្យមានបន្ទប់ពិសោធន៍តាមមុខវិជ្ជា បន្ទប់កុំព្យូទ័រនិងបំពាក់កុំព្យូទ័រ បន្ទប់មុខវិជ្ជា បន្ទប់គ្រូបង្រៀន និងបណ្ណាល័យសតវត្សរ៍ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ទី២១។ សាលារៀនជំនាន់ថ្មីបានអនុវត្តកម្មវិធីសិក្សាតាមបែបសិស្សចល័តទៅតាមបន្ទប់មុខវិជ្ជា។<br>▪ ពង្រឹងការបង្រៀន និងរៀនការអប់រំបំណិនជីវិត ការអប់រំ STEM ប្រឹក្សាអាជីព ក្រុមប្រឹក្សាយុវជន បន្ទប់សង្គ្រោះបឋម និងក្លឹបសិក្សាលើមុខវិជ្ជា គណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា សារព័ត៌មាន បច្ចេកវិទ្យាព័ត៌មាន និងប្រវត្តិវិទ្យា។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានរៀបចំព័ត៌មានកម្មវិធីវិនិយោគសាធារណៈ (PIP Information) ផ្ញើទៅក្រសួងផែនការ ស្តីពីការបង្កើតមជ្ឈមណ្ឌលភ្ញាស់បច្ចេកវិទ្យា (Technology Incubation Center) ដើម្បីត្រៀមលើកសំណើទៅដៃគូអភិវឌ្ឍន៍ស្នើសុំថវិកាអនុវត្តគម្រោង។<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍÷<br>▪ ពិចារណាផ្តល់ហិរញ្ញប្បទានចំពោះវិទ្យាស្ថានស្រាវជ្រាវរដ្ឋ ដោយផ្តោតទាំងស្រុងទៅលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>▪ បានបញ្ចប់អនុក្រឹត្យស្តីពីការបង្កើតនិងគ្រប់គ្រងមូលនិធិសិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍ ដោយផ្តោតលើការស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍។ | |
| - ជំរុញការសិក្សាអប់រំលើជំនាញវិទ្យាសាស្ត្របច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា (STEM) ពីកម្រិតបឋមសិក្សា រហូតដល់ក្រោយមធ្យមសិក្សា ពិសេសផ្តោតលើសិស្សក្មេងៗ ជាមួយ នឹងការកែទម្រង់កម្មវិធីសិក្សា ដោយការធ្វើស្តង់ដារនីយកម្ម | ២០១៥ ទៅ មធ្យម | - ក្រសួងអប់រំ យុវជន និងកីឡា÷<br>▪ បង្កើតកម្មវិធីតេស្តលំហាត់/សំណួរជីវវិទ្យាថ្នាក់ទី១២ សម្រាប់ដំណើរការតាមទូរស័ព្ទ<br>▪ ណែនាំការរៀន និងបង្រៀនវិទ្យាសាស្ត្រសម្រាប់បឋមសិក្សាថ្នាក់ទី៤ ទី៥ និងទី៦ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| នៃកម្មវិធីសិក្សាទាំងនោះពីកម្រិតបឋមសិក្សាឡើងទៅ | | ▪ រៀបចំពិពណ៌រណ៍មហោស្រពដើម្បីជំរុញ និងលើកកម្ពស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា<br>▪ ជំរុញការអនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា<br>▪ រៀបចំសិក្ខាសាលាស្តីពី ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀនវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា អ្នកចូលរួម ២៥០នាក់<br>▪ រៀបចំមហោស្រពវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅកម្ពុជាលើកទី៤ ជាមួយអង្គការ STEM កម្ពុជា មានអ្នកចូលរួមប្រមាណ ៣០ ០០០នាក់ នៅពហុកីឡដ្ឋានជាតិអូឡាំពិក<br>▪ បានបង្កើត និងគាំទ្រក្លឹបសិក្សាគណិតវិទ្យានៅតាមអនុវិទ្យាល័យ និងវិទ្យាល័យក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមការងារនៃគណៈកម្មការដឹកនាំថ្នាក់ជាតិ បានជ្រើសរើសនិស្សិតស្ម័គ្រចិត្តឱ្យចូលរួមចុះជួយបង្កើត និងគាំទ្រក្លឹបសិក្សាគណិតវិទ្យានៅតាមអនុវិទ្យាល័យ និងវិទ្យាល័យក្នុងរាជធានីភ្នំពេញ បានចំនួន ១៧១នាក់ ដែលក្នុងនោះមានសមាសភាព÷(១) ក្រុមបរិញ្ញាបត្រ មានចំនួន ១៥នាក់(ស្រី ៤នាក់), (២) ក្រុមឆ្នាំទី៤ មានចំនួន ២៣នាក់(ស្រី ៨នាក់), (៣) ក្រុមឆ្នាំទី៣ មានចំនួន ៤៧នាក់ (ស្រី ២៤នាក់), (៤) ក្រុមឆ្នាំទី២ មានចំនួន ៥០នាក់(ស្រី ១៨នាក់) និង(៥) ក្រុមឆ្នាំទី១ មានចំនួន ៣៦នាក់ (ស្រី ១១នាក់) ហើយ ៩៦% ជានិស្សិតផ្នែកគណិតវិទ្យានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| - ពិនិត្យឡើងវិញ និងប្រមូលផ្តុំសក្តានុពលធនធានធម្មជាតិ ដែលជំរុញឱ្យមានការវិនិយោគលើវិស័យឧស្សាហកម្មធុនធ្ងន់។ | មធ្យម ទៅ វែង | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | |
| *គ- ការកសាងហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍ឧស្សាហកម្ម* | | | |
| - បង្កើតយន្តការសម្របសម្រួលការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ផ្លូវថ្នល់ ផ្លូវរថភ្លើង ផ្លូវអាកាស និងកំពង់ផែ) ដោយផ្សារភ្ជាប់ទៅនឹងតំបន់គោលដៅនៃការអភិវឌ្ឍឧស្សាហកម្ម | ២០១៥ ទៅ មធ្យម | - ក្រសួងសាធារណការ និងដឹកជញ្ជូន÷<br>**ការងារដឹកជញ្ជូនផ្លូវគោក**<br>▪ ចុះបញ្ជីយានជំនិះបានចំនួន ១ ១២៤ ៣០៧គ្រឿង (ម៉ូតូ ៨៥៤ ១៤៥គ្រឿង កើនឡើង ៥,៨៣% និងរថយន្តគ្រប់ប្រភេទ ១៣៥ ០៨១គ្រឿង កើនឡើង ១៥,២៣% ធៀបនឹង២ឆ្នាំមុន (ឆ្នាំ ២០១៥-២០១៦)<br>▪ ផ្តល់បណ្ណបើកបរយានយន្តបានចំនួន ២១៥ ៤០២បណ្ណ (ម៉ូតូ ៩៨៧បណ្ណ ថយចុះ ៩០,៥៨% និងរថយន្ត ២១៤ ៤១៥បណ្ណ ថយចុះ ១០,២៣% ធៀបនឹង២ឆ្នាំមុន (ឆ្នាំ២០១៥-២០១៦)<br>▪ ផ្តល់លិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសចំនួន ១១២ ០៧២គ្រឿង (រថយន្តដឹកទំនិញ ៨៥ ៣៩៨គ្រឿង កើនឡើង ២,២០% និងរថយន្តដឹកអ្នកដំណើរ ២៦ ៦៧៤គ្រឿង ថយចុះ ៣,៦៤% ធៀបនឹង២ឆ្នាំមុន (ឆ្នាំ ២០១៥-២០១៦)<br>▪ ក្រុមហ៊ុនចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសសរុប ១០២ក្រុមហ៊ុន (ក្រុមហ៊ុនដឹកជញ្ជូនទំនិញ ៤២ក្រុមហ៊ុន ក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរ ៥៥ក្រុមហ៊ុន ក្រុមហ៊ុនភ្នាក់ងារផ្តល់សេវាដឹក | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ជញ្ជូន ៤ក្រុមហ៊ុន និងក្រុមហ៊ុនភ្នាក់ងារផ្តល់សេវាចែករំលែកយានជំនិះ ១ក្រុមហ៊ុន) គិតពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៧<br>▪ បន្តចរចា និងជំរុញប្រទេសឡាវ ធ្វើការសហការរៀបចំឱ្យមានកិច្ចព្រមព្រៀងដឹកជញ្ជូនអ្នកដំណើរ<br>▪ បន្តចរចា និងជំរុញឱ្យប្រទេសថៃ ធ្វើការសហការរៀបចំឱ្យមានកិច្ចព្រមព្រៀងដឹកជញ្ជូនទ្វេភាគី<br>▪ ជំរុញធ្វើយ៉ាងណាឱ្យការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ត្រីភាគីប្រព្រឹត្តទៅប្រកបដោយភាពរលូន និងឈានទៅអនុវត្តកិច្ចព្រម-ព្រៀងមហាអនុតំបន់ទន្លេមេគង្គនាពេលខាងមុខដ៏ខ្លី<br>▪ បង្កើតប្រព័ន្ធស្វ័យប្រវត្តិកម្មផ្តល់សេវាសាធារណៈការចុះបញ្ជីយានជំនិះ បណ្ណបើកបរ ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស អាជីវកម្មដឹកជញ្ជូនក្នុងប្រទេស និងការចុះបញ្ជីក្រុមហ៊ុនដឹកជញ្ជូន<br>▪ បានបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពជំនាញបច្ចេកទេសដល់អ្នកបើកបររថយន្តធុនធំ សម្រាប់វិស័យឯកជនជាមួយ GIZ<br>▪ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី “អនុក្រឹត្យស្តីពីការចេញផ្លាកលេខសម្គាល់យានជំនិះ” ដែលជាការធ្វើវិសោធកម្មបំពេញបន្ថែមបន្ថែមខ្លឹមសារឱ្យសមស្របនឹងសភាពការណ៍បច្ចុប្បន្ន<br>▪ បានចេញប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីយានយន្តការផ្តល់លេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយាន-យន្ត និងបានរៀបចំសេចក្តីណែនាំស្តីពី កាតព្វកិច្ចម្ចាស់ហាងលក់រថយន្ត ហាងលក់ទោចក្រយានយន្ត កាតព្វកិច្ចរបស់អង្គភាពនិងមន្ត្រីទទួលបន្ទុកអនុវត្តក្នុងការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ការងារដឹកជញ្ជូនឆ្លងកាត់ព្រំដែន<br>▪ ក្រុមហ៊ុនចម្រុះឡាវ-ជប៉ុន បានចុះបញ្ជីយានយន្តសរុប ១៤គ្រឿង ក្នុងចំណោមកូតា ៤០គ្រឿង ដើម្បីធ្វើប្រតិបត្តិការដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែនរវាងកម្ពុជា-ឡាវ។ គណៈកម្មាធិការសម្រួលការដឹកជញ្ជូនភាគីទាំងពីរ បានឯកភាពគ្នានិងកំពុងរៀបចំសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នាដំឡើងកូតាឱ្យដល់ ១៥០គ្រឿង ការស្នើអនុវត្ត និងអនុញ្ញាតឱ្យរថយន្តគ្រួសារអាចចេញចូលទៅវិញទៅមករវាងប្រទេសទាំងពីរ ការស្នើផ្លូវកាត់ថ្មី ស្ទឹងត្រែង-ព្រះវិហារ-សៀមរាប។<br>▪ បន្តអនុវត្តកូតាយានយន្ត ៥០០គ្រឿង ក្នុងក្របខ័ណ្ឌអនុស្សារណៈនៃការយោគយល់ស្តីពីការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនទ្វេភាគីកម្ពុជា-វៀតណាម<br>▪ អនុស្សារណៈនៃការយោគយល់ស្តីពីការផ្លាស់ប្តូរសិទ្ធិចរាចរណ៍ សម្រាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែននៅច្រកទ្វារប៉ោយប៉ែត-អារញ្ញប្រាថេត (ដំឡើងកូតាយានយន្ត ពី ៤០គ្រឿង ដល់ ១៥០គ្រឿង) បានចូលជាធរមាននៅចុងខែមីនា ឆ្នាំ២០១៧។ បច្ចុប្បន្នក្រសួងកំពុងអនុវត្តកូតាយានយន្ត ១៥០គ្រឿងនិងបានរៀបចំចុះបញ្ជីយានយន្តតាមចំនួនកូតាកំណត់ខាងលើ ហើយគ្រោងការចុះបញ្ជីយានយន្ត៥០០ គ្រឿងសម្រាប់កូតា GMS ផងដែរ។<br>▪ អនុស្សរណៈនៃការយោគយល់ស្តីពីការដឹកជញ្ជូនឆ្លងកាត់ព្រំដែនកម្ពុជា-ឡាវ-វៀតណាម បានចូលជាធរមាន ដោយអនុវត្តកូតាយានយន្តចំនួន ១៥០គ្រឿង សម្រាប់ធ្វើប្រតិបត្តិការឆ្លងកាត់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ▪ ប្រទេសជាសមាជិកមហាអនុតំបន់មេគង្គទាំង៦ (GMS) គ្រោងនឹងចាប់ផ្ដើមអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនអ្នកដំណើរ និងទំនិញនាពេលឆាប់ៗនេះ<br>▪ ៣អាស៊ានកំពុងអនុវត្តគម្រោងសាកល្បងប្រព័ន្ធឆ្លងកាត់គយអាស៊ាន (ASEAN-ACT) កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) នៅឆ្នាំ២០១៨នេះ ដែលជាច្រករបៀងខាងកើត-លិចនៃអាស៊ាន បន្ទាប់ពីអនុវត្តគម្រោងសាកល្បងនៅប្រទេសសឹង្ហបុរី ថៃ និង ម៉ាឡេស៊ី ដែលជាច្រករបៀងខាងជើង-ត្បូងនៃអាស៊ាន ក្រោមជំនួយពីសហគមន៍អឺរ៉ុប ដោយចាប់ផ្ដើមពីការរៀបចំប្រព័ន្ធឆ្លងកាត់គយ (ASEAN Customs Transit System, ACTS)។<br>**ការងារដឹកជញ្ជូនផ្លូវទឹក**<br>▪ បានសិក្សា និងអនុវត្តគម្រោងដឹកជញ្ជូនទំនិញ និងអ្នកដំណើរតាមកាណូតចាប់ពីស្ពានព្រែកព្នៅ-ភ្នំពេញ-តាខ្មៅ (១៥ទីតាំងផែចំណត) សំដៅដល់ការកាត់បន្ថយការកកស្ទះចរាចរណ៍ និងការចំណាយរបស់ពលរដ្ឋលើការធ្វើដំណើរ។ គម្រោងនេះក៏បានដាក់ឱ្យដំណើរការកាណូតដឹកអ្នកដំណើរតាមផ្លូវទឹកក្នុងក្រុង ពីឫស្សីកែវ ទៅតាខ្មៅ ចំនួន០៥ស្ថានីយ<br>▪ បានពង្រឹងគុណភាពផ្ដល់សេវាសាធារណៈលើការចុះបញ្ជីជលយានការត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ការផ្ដល់បណ្ណបើកបរ បណ្ណយន្តការី និងលិខិតអនុញ្ញាតធ្វើអាជីវកម្មជលយានយន្ត | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ គ្រប់គ្រងនាវាដែលធ្វើនាវាចរណ៍តាមប្រព័ន្ធទន្លេមេគង្គ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជំរុញអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវទឹក ឱ្យមានការរីកចម្រើន ឆ្លើយតបនឹងសេចក្តីត្រូវការអភិវឌ្ឍប្រទេស និងសេដ្ឋកិច្ចជាតិ<br>▪ អភិវឌ្ឍធនធានមនុស្សក្នុងវិស័យដឹកជញ្ជូនផ្លូវទឹក និងគ្រប់គ្រង និងជំរុញការអភិវឌ្ឍយានដ្ឋានជួសជុលនាវា<br>▪ បានជំរុញអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក និងរៀបចំបទដ្ឋានគតិយុត្តពាក់ព័ន្ធ<br>▪ លើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមវិនិយោគលើការដឹកជញ្ជូនផ្លូវទឹក<br>▪ ជំរុញអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការដឹកជញ្ជូនផ្លូវទឹកឆ្នាំ២០០៩<br>▪ បានបញ្ចប់ការងារសាងសង់កំពង់ផែតាស្លាង ក្រុងស្វាយរៀង ខេត្តស្វាយរៀង<br>▪ បានសិក្សា និងសាងសង់កំពង់ផែតូចៗនៅតាមប្រព័ន្ធទន្លេមេគង្គ និងតំបន់សមុទ្រ រួមទាំងការសិក្សា និងស្ពានផ្លូវទឹក<br>▪ សហការជាមួយផ្នែកឯកជន និងដៃគូអភិវឌ្ឍនានា ក្នុងការធានាអភិវឌ្ឍន៍កំពង់ផែប្រកបដោយនិរន្តរភាព រួមនឹងទំនើបកម្មប្រតិបត្តិការកំពង់ផែ ដូចជារៀបចំនឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យកំពង់ផែ (Port EDI)។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | **ការងារដឹកជញ្ជូនផ្លូវសមុទ្រ**<br>▪ ចុះពង្រឹងការងារគ្រប់គ្រងលើមធ្យាបាយដឹកជញ្ជូន និងនាវិក រួមទាំងការងារពាក់ព័ន្ធផ្សេងទៀតនៅតាមបណ្តាមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត នៅតាមតំបន់ឆ្នេរ<br>▪ បានសិក្សានិងលើកគម្រោងសាងសង់កំពង់ផែទេសចរណ៍ក្រុងកែប<br>▪ ជំរុញឱ្យមានការអភិវឌ្ឍធនធានមនុស្សនៅក្នុងវិស័យនាវាចរណ៍ តាមរយៈកាវិនិយោគឯកជន ការវិនិយោគដៃគូរវាងសាធារណៈ និងឯកជន លើការបង្កើតគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលផ្នែកនាវាចរណ៍សមុទ្រ<br>▪ លើកទឹកចិត្តឱ្យមានការវិនិយោគលើការដឹកជញ្ជូនតាមផ្លូវសមុទ្រ<br>▪ បានអនុវត្តគោលនយោបាយជាតិស្តីពីកំពង់ផែ និងប្រព័ន្ធគ្រប់គ្រងកំពង់ផែ ឆ្នាំ២០១៣<br>▪ ជំរុញលើកកម្ពស់ និងធានាឱ្យការដឹកជញ្ជូនតាមនាវាប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព និងបរិស្ថានល្អ ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ មានការប្រកួតប្រជែង ការជឿជាក់ និងតម្លៃសមស្រប<br>▪ ពិនិត្យលទ្ធភាពចុះបញ្ជីនាវាសញ្ជាតិកម្ពុជា ដោយអនុលោមតាមគោលការណ៍អន្តរជាតិ ពិសេសអង្គការសមុទ្រអន្តរជាតិ ដើម្បីធានាថាការចុះបញ្ជីនេះមានតម្លាភាព ស្របតាមការវិវឌ្ឍរបស់សង្គមជាតិ<br>▪ ជំរុញរៀបចំកសាងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងនាវា នាវិក កណ្តូធារកិច្ច | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ធ្វើកិច្ចសហប្រតិបត្តិការជាមួយ ReCAAP ISC និងបណ្តាប្រទេសជាសមាជិក និងកិច្ចសហប្រតិបត្តិការជាមួយអង្គការនាវាចរណ៍អន្តរជាតិ ដើម្បីកែតម្រូវការអនុវត្តសកម្មភាពនាវាចរណ៍សមុទ្រឱ្យស្របតាមអនុសញ្ញា IMO និងអន្តរជាតិ។<br>**ការងារផ្លូវដែក**<br>▪ ផ្លូវដែកមេកម្ពុជា មានចំនួន ០២ខ្សែ ប្រវែងសរុប ៦៥២គ.ម (ខ្សែទិសខាងជើងមានប្រវែង ៣៨៦គ.ម និងខ្សែទិសខាងត្បូងប្រវែង ២៦៦គ.ម) ដែលបានអនុវត្តដូចខាងក្រោម÷<br>- បានសាងសង់ផ្លូវដែក និងដាក់ឱ្យប្រើរថភ្លើងដឹកអ្នកដំណើរពីស្ថានីយភ្នំពេញ ទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ<br>- ជប៉ុនកំពុងសិក្សាលទ្ធភាពសាងសង់ផ្លូវរថភ្លើងស្វ័យប្រវត្តិលើអាកាស (AGT) នៅរាជធានីភ្នំពេញ<br>- សិក្សាគម្រោងផ្លូវដែក AGT Monorail Tramway Subway ក្នុងរាជធានីភ្នំពេញ<br>- ជំរុញឱ្យមានការតភ្ជាប់ផ្លូវដែកចូលរោងចក្រ សហគ្រាស តំបន់សេដ្ឋកិច្ចពិសេស ដូចជាពីស្ថានីយទួកមាសទៅរោងចក្រ K ស៊ីម៉ង់ ពីស្ថានីយកំពតទៅរោងចក្រស៊ីម៉ង់ចក្រីទីង<br>- កំពុងសិក្សាផ្លូវរថភ្លើងនៅបាត់ដំបង កំពង់ធំ សៀមរាប និងសិរីសោភ័ណ។<br>▪ **ក. ផ្លូវដែកទិសខាងជើង÷**<br>- បានបញ្ចប់ការសាងសង់ជួសជុលផ្លូវដែក និងដាក់ឱ្យដំណើរការដឹកជញ្ជូនជាបណ្តោះអាសន្ន ពីភ្នំពេញ-ប៉ោយប៉ែត | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | - បានតភ្ជាប់ផ្លូវដែកកម្ពុជា ជាមួយផ្លូវដែកថៃ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីការដឹកជញ្ជូនឆ្លងកាត់ព្រំដែនតាមផ្លូវដែកកម្ពុជា-ថៃ<br>- ជួសជុលកំណាត់ផ្លូវដែកប្រវែង៦,៥គ.ម(ប៉ោយប៉ែត ព្រំប្រទល់កម្ពុជា-ថៃ) បានតភ្ជាប់ផ្លូវដែកកម្ពុជា-ថៃ រួចរាល់<br>- បន្ត និងជំរុញអនុវត្តគម្រោងសាងសង់ស្ថានីយរថភ្លើងសំរោង និងគ្រោងសិក្សាការសាងសង់ស្ថានីយរថភ្លើងអន្តរជាតិស្ទឹងបត់<br>- ការងារជួសជុលស្ថានីយរថភ្លើងប៉ោយប៉ែតសម្រេចបាន ១០០%<br>- គម្រោងបំពាក់ប្រព័ន្ធសុវត្ថិភាពចរាចរណ៍ផ្លូវដែកភាគខាងជើង សម្រេចបាន១០០%។<br>- សិក្សាធ្វើឱ្យប្រសើរឡើងផ្លូវដែកភាគខាងជើង : គម្រោងសាងសង់ផ្លូវដែកថ្មី សិរីសោភ័ណ្ឌ-សៀមរាប<br>- ស្វែងរកការវិនិយោគតភ្ជាប់បណ្តាញផ្លូវដែកកម្ពុជា ជាមួយបណ្តាញផ្លូវដែក ប្រទេសជិតខាង ជាពិសេសបណ្តាញផ្លូវដែកសាំងហ្គាពួរ-គុនមីញ ផ្លូវដែកភ្នំពេញ-សៀមរាប និងភ្នំពេញ-បាវិត។<br>▪ ខ. ផ្លូវដែកទិសខាងត្បូង÷<br>- រាជធានីភ្នំពេញ- ក្រុងព្រះសីហនុ) បានស្តារ និងសាងសង់រួចបច្ចុប្បន្នកំពុងដំណើរការដឹកទំនិញ និងអ្នកដំណើរទេសចរណ៍ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - ដឹកជញ្ជូនទំនិញ មានចំនួនសរុប ១ ៣៤៧ ២៨១តោន កើនឡើង៧,៨៨% ធៀបនឹង២ឆ្នាំមុន(ឆ្នាំ២០១៥-២០១៦ : ១ ២៤៨ ៨៤១តោន)<br>- ដឹកជញ្ជូនអ្នកដំណើរ មានចំនួនសរុប ១៤៨ ១១៣នាក់ កើនឡើង ៩៥៨,៣២% ធៀបនឹង២ឆ្នាំមុន(ឆ្នាំ២០១៥-២០១៦ : ១៣ ៩៩៥នាក់)<br>- គម្រោងបំពាក់ប្រព័ន្ធសុវត្ថិភាពចរាចរណ៍ផ្លូវឆ្លងកាត់ផ្លូវដែក សម្រេចបាន១០០%<br>- គម្រោងជួសជុលស្ពានផ្លូវដែកទិសនិរតី និង គម្រោងជួសជុលពង្រឹងផ្លូវដែកនិរតីទិស សម្រេចបាន១០០%។<br>- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល÷<br>(ការងារឆ្នាំ២០១៧)<br>▪ បាននិងកំពុងរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអាកាសចរស៊ីវិល ឆ្នាំ២០១៨-២០២៥<br>▪ បានអនុញ្ញាតហោះហើរជាលក្ខណៈមិនតាមកម្មវិធី (Charter/ Extra Flight) ដល់ក្រុមហ៊ុនអកាសចរណ៍ចំនួន ២៤ក្រុមហ៊ុន បានចំនួន ១៥៣លើក<br>▪ បានធ្វើការកែសម្រួលលើអនុស្សរណៈយោគយល់គ្នារវាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលកម្ពុជា និងអាជ្ញាធរអាកាសចរស៊ីវិលនៃប្រទេសអូស្ត្រាលី នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងទឡ្ហនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានអនុញ្ញាតឱ្យក្រុមហ៊ុនអាកាសចរណ៍អេមីរ៉ាត់អ៊ែឡាញ ក្នុងការបើកផ្លូវហោះហើរថ្មី ដើម្បីផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាប្រក្រតី ចាប់តាំងពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៧<br>▪ ចូលរួមកិច្ចប្រជុំក្រុមការងារដឹកជញ្ជូនតាមផ្លូវអាកាសអាស៊ាន-សហភាពអឺរ៉ុប លើកទី២ ស្តីពីកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ពីថ្ងៃទី១៧-២០ ខែមករា ឆ្នាំ២០១៧ នៅទីក្រុងហ្សាកាតា<br>▪ ចូលរួមកិច្ចប្រជុំក្រុមការងារដឹកជញ្ជូនតាមផ្លូវអាកាសអាស៊ាន-ជប៉ុន លើកទី២ ស្តីពីកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសរវាងកម្ពុជា-ជប៉ុន និងកិច្ចប្រជុំពាក់ព័ន្ធ ពីថ្ងៃទី០៨-១០ កុម្ភៈ ឆ្នាំ២០១៧ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន<br>▪ ចូលរួមកិច្ចប្រជុំពិភាក្សាទ្វេភាគី រវាងរដ្ឋលេខាធិការអាកាសចរស៊ីវិលជាមួយអាជ្ញាធរអាកាសចរស៊ីវិលនៃប្រទេសកាហ្សាក់ស្ថាន ស្តីពីកិច្ច-ព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស និងចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ពីថ្ងៃទី២០-២១ ខែកុម្ភៈ ឆ្នាំ២០១៧ នៅទីក្រុងអាល់ម៉ាទី ប្រទេសកាហ្សាក់ស្ថាន<br>▪ ចូលរួមកិច្ចប្រជុំទ្វេភាគី រវាងរដ្ឋលេខាធិការអាកាសចរស៊ីវិល និងអាជ្ញាធរអាកាសចរស៊ីវិលតំបន់រដ្ឋបាលពិសេសហុងកុង នៃសាធា-រណៈប្រជាមានិតចិនស្តីពីការធ្វើសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស និងផ្នែកពាក់ព័ន្ធផ្សេងៗទៀតនៃវិស័យអាកាសចរស៊ីវិល ពីថ្ងៃទី២៤-២៥ ខែមេសា ឆ្នាំ២០១៧ នៅទីក្រុងហុងកុង | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័នដាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានចុះអនុស្សារណៈយោគយល់ស្តីពីសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស រវាងកម្ពុជា-ម៉ាកាវ ពីថ្ងៃទី០៧-១១ ខែសីហា ឆ្នាំ២០១៧ នៅប្រទេសម៉ុងហ្គោលី។<br>(ការងារឆ្នាំ២០១៨)<br>▪ បានកំណត់គោលដៅច្បាស់លាស់មួយលើការពង្រឹងនិងពង្រីកកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាមួយបណ្តាប្រទេសនានា តាមរយៈការចរចាជាលក្ខណៈទ្វេភាគី និងពហុភាគី<br>▪ រាល់ការចរចាកិច្ចព្រមព្រៀងទាំងអស់ រ.ល.អ.ស បានកំណត់យុទ្ធសាស្ត្រ និងយុទ្ធវិធីច្បាស់លាស់លើបណ្តាសមាសធាតុសេដ្ឋកិច្ចសំខាន់ៗ ដូចជា ការចាត់តាំងក្រុមហ៊ុនអាកាសចរណ៍ ការកំណត់ចំណុះដឹកជញ្ជូន ការកំណត់ផ្លូវហោះហើរ ការកំណត់បើកចំហរជើងហោះហើរសហការ (Code-Share Flights) ការប្រកួតប្រជែងដោយស្មើភាព និងការកំណត់សំណាញ់សុវត្ថិភាពនៃប្រតិបត្តិការហោះហើរជាដើម។<br>▪ បានចុះធ្វើសវនកម្មនៅអាកាសយានដ្ឋាន ដើម្បីផ្តល់វិញ្ញាបនបត្រអាកាសយានដ្ឋាន<br>▪ ចុះធ្វើ Surveillance Inspection. ARFFS សម្រាប់អាកាសយានដ្ឋានអន្តរជាតិ<br>▪ បានទទួលជំនាញការ ICAO ចំនួន២លើក តាមកម្មវិធី COSCAP-SEA សម្រាប់ការងារពិនិត្យ សំណួរ PQ និងវិញ្ញាបនបត្រអាកាសយានដ្ឋាន នៃអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានអនុវត្តធ្វើលំហាត់សមយុទ្ធទ្រង់ទាយធំ KOS EX18 ដោយអនុវត្តតាមនីតិវិធី ដែលសកម្មភាពបានចែង១២០ថ្ងៃ<br>▪ បានចុះត្រួតពិនិត្យ Airport Certification នៅអាកាសយានដ្ឋាន បានចុះធ្វើ Random Inspection ARFFS នៅអាកាសយានដ្ឋាន។<br>- ក្រសួងធនធានទឹក និងឧតុនិយម÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ បានសាងសង់ច្រាំងទន្លេមេគង្គ នៅក្រុងកំពង់ចាម បានប្រវែង ៧៨ម សម្រាប់ទប់កុំឱ្យបាក់ច្រាំងទន្លេ, បានជួសជុល និងសាងសង់នូវទំនប់ការពារទឹកប្រៃជីត្រេះ ប្រវែង ៤.០០០ម នៅស្រុកបុទុមសាគរ ដើម្បីការពារទប់ស្កាត់ទឹកប្រៃកុំឱ្យហូរចូលលើផ្ទៃដីចំនួន ២៨២ហ.ត ព្រមទាំងបានជួសជុលថែទាំនូវទំនប់ការពារទប់ស្កាត់ទឹកប្រៃសរុបចំនួន ៧គម្រោង ដើម្បីរក្សានិរន្តរភាពការពារទឹកប្រៃបានចំនួន ២.២៩៦ហ.ត នៅក្នុងខេត្តកោះកុង, និងបានជួសជុលថែទាំជាប្រចាំនូវទំនប់ការពារទប់ស្កាត់ទឹកប្រៃសរុបចំនួន ៦គម្រោង ដើម្បីរក្សានិរន្តរភាពការពារទឹកប្រៃបានចំនួន ៩.៧៧៨ហ.ត នៅក្នុងខេត្តព្រះសីហនុ ។<br>▪ បានជួសជុល និងថែទាំជាប្រចាំនូវទំនប់សណ្តរក្រាំងពង្រ (ទំនប់៧មករា) ប្រវែង ៩.៩៤២ម និងសំណង់ទ្វារទឹក ៤កន្លែង ស្ថិតនៅខណ្ឌដង្កោ ដើម្បីរក្សានិរន្តរភាពការពារទប់ស្កាត់ទឹកជំនន់ស្ទឹងព្រែក-ត្នោត គឺការពារផ្ទៃដីបានចំនួន ៣.៨០១ហ.ត ក្នុងនោះ ស្រូវវស្សា ១.៤៨១ហ.ត ព្រមទាំងលំនៅដ្ឋាន និងរោងចក្រ ២.៣២០ហ.ត នៅរាជធានីភ្នំពេញ។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ក្នុងឆ្នាំ២០១៨÷<br>▪ បានសាងសង់ច្រាំងទន្លេមេគង្គ នៅក្រុងកំពង់ចាម បានប្រវែង ១៤៨ម សម្រាប់ទប់កុំឱ្យបាក់ច្រាំងទន្លេ។<br>▪ បានជួសជុល និងសាងសង់នូវទំនប់ការពារទឹកប្រៃជីត្រេះជំហ៊ានទី ២ ប្រវែង ៣.៨០០ម នៅស្រុកបុទុមសាគរ ដើម្បីការពារទប់ស្កាត់ទឹកប្រៃកុំឱ្យហូរចូលលើផ្ទៃដីចំនួន ៧៨ហ.ត ព្រមទាំងបានជួសជុល និងថែទាំនូវទំនប់ការពារទប់ស្កាត់ទឹកប្រៃសរុបចំនួន ៩គម្រោង ដើម្បីរក្សានិរន្តរភាពការពារទឹកប្រៃបានចំនួន ៤.២៧១ហ.ត នៅក្នុងខេត្តកោះកុង។<br>▪ បានជួសជុល និងថែទាំជាប្រចាំនូវទំនប់ការពារទប់ស្កាត់ទឹកប្រៃសរុបចំនួន ៧គម្រោង ដើម្បីរក្សានិរន្តរភាពការពារទឹកប្រៃបានចំនួន ១១.៦២៨ហ.ត នៅក្នុងខេត្តព្រះសីហនុ។<br>▪ បានបន្តជួសជុល និងថែទាំប្រចាំទំនប់សណ្តរក្រាំងពង្រ (ទំនប់ ៧ មករា) ប្រវែង៩.៩៤២ម និងសំណង់ទ្វារទឹក ៤កន្លែង ដើម្បីរក្សានិរន្តរភាពការពារទប់ស្កាត់ទឹកជំនន់ស្ទឹងព្រែកត្នោត គឺការពារផ្ទៃដីចំនួន ៣.៨០១ហ.ត ក្នុងនោះ ស្រូវវស្សា ១.៤៨១ហ.ត ព្រមទាំងលំនៅដ្ឋាន និងរោងចក្រ ២.៣២០ហ.ត នៅខណ្ឌដង្កោ រាជធានីភ្នំពេញ។ | |
| - ពិនិត្យតម្រង់ការផ្គត់ផ្គង់ថាមពលទៅកាន់តំបន់ផលិតកម្មសំខាន់ៗ ដោយធានាឱ្យបានការផ្គត់ផ្គង់ចរន្តអគ្គិសនីស្របតាមតម្រូវការ និងមានស្ថិរភាព | ២០១៥ ទៅ មធ្យម | - ក្រសួងរ៉ែនិងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា÷<br>**ក. ផ្នែកផលិតកម្ម÷**<br>ក្នុងឆ្នាំ២០១៧÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| បំផុត ដែលអនុញ្ញាតឱ្យរោងចក្រ អាចគ្រោងផលិត-កម្មខ្លួនប្រកបដោយប្រសិទ្ធភាព | | ▪ ដាក់ឱ្យដំណើរការបន្ថែមស្ថានីយដុតធ្យូងថ្ម ១៣៥MW, ចុងឆ្នាំ ២០១៧ បន្ថែមអានុភាព ៥0MW ពីស្ថានីយវារីអគ្គិសនីសេសានក្រោម២, ឆ្នាំ២០១៨ បន្ថែមអានុភាព ៣៥0MW ពីស្ថានីយវារីអគ្គិសនីសេសានក្រោម២ (វារីអគ្គិសនីសេសានក្រោម២អានុភាពសរុប ៤00 MW) និងឆ្នាំ២០១៩ ដាក់ឱ្យ ដំណើរការបន្ថែមរោងចក្រអគ្គិសនីដុតធ្យូងថ្ម CEL ១៣៥ MW។ ជាមួយគ្នានេះដែររោចក្រធ្យូងថ្ម ម៉ាស៊ីនទី ៣ របស់រោងចក្រធ្យូងថ្ម CIIDG កំពុងដំណើរការ សាកល្បងវារីអគ្គិសនីសេសាន ក្រោម២ កំពុងសាងសង់ សម្រេច បាន ៨0%។<br>ក្នុងឆ្នាំ២០១៨÷<br>▪ ដាក់ឱ្យដំណើរការស្ថានីយវារីអគ្គិសនីសេសានក្រោម២ អានុភាពសរុប ៤00 MW។ ជាមួយគ្នានេះដែរ បានដាក់ឱ្យដំណើរការរោងចក្រអគ្គិសនីដុតធ្យូងថ្ម កម្លាំង ២៧0 MW។ លើសពីនេះ បានដាក់ឱ្យដំណើរការរោងចក្រអគ្គិសនីដុតធ្យូងថ្ម ម៉ាស៊ីនទី៣។ លើសពីនេះ បានដាក់ឱ្យដំណើរការវារីអគ្គិសនីសេសាន ក្រោម២ និងកំពុងសាងសង់ស្ថានីយអគ្គិសនីដើរដោយថាមពលពន្លឺព្រះ-អាទិត្យ នៅកំពង់ស្ពឺ។<br>**ខ. ផ្នែកខ្សែបញ្ជូនជាតិ÷**<br>ក្នុងឆ្នាំ២០១៧÷<br>▪ ដាក់ឱ្យដំណើរការខ្សែបញ្ជូន១១៥KVតភ្ជាប់ពីភ្នំពេញ-កំពង់សីល្ហ-បាវិត។ ថ្មីៗនេះ គម្រោងនេះបានដាក់ឱ្យដំណើរការរួចរាល់។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ដាក់ឱ្យដំណើរ ការខ្សែបញ្ជូន ២៣០kV តភ្ជាប់ពីខេត្តកំពង់ចាម-ក្រចេះ- ស្ទឹងត្រែង។ ថ្មីៗនេះ គម្រោងនេះបានដាក់ឱ្យដំណើរការរួចរាល់។<br>▪ ដាក់ឱ្យដំណើរ ការខ្សែបញ្ជូន ១១៥ kV តភ្ជាប់ពីឡាវ-ព្រះវិហារ (ពីព្រំដែន ឡាវ មកអនុស្ថានីយ អគ្គិសនី ជ័យសែន) ធ្វើគ្រឹះបង្គោល 48/158គ្រឹះ សម្រេចបាន ៣០%។<br>▪ ដាក់ឱ្យដំណើរការខ្សែបញ្ជូន ១១៥ kV តភ្ជាប់ពីបាត់ដំបង-ប៉ៃលិន។<br>ក្នុងឆ្នាំ២០១៨÷<br>▪ ដាក់ឱ្យដំណើរ ការខ្សែបញ្ជូន (១) ២៣០ kV អនុស្ថានីយកោះកុង-ក្រុងកោះកុង, (២) ២៣០kV បទុមសាគរ-ចំការ លួង និង (៣) ១១៥kV កំពង់ចាម-ព្រៃកប្រសព្វ<br>▪ ដាក់ឱ្យដំណើរ ការខ្សែបញ្ជូន ១១៥kV តភ្ជាប់ ពីព្រះវិហារ-កំពង់ធំ។ ថ្មីៗនេះ គម្រោងនេះបានដាក់ឱ្យដំណើរការរួចរាល់។<br>▪ ដាក់ឱ្យដំណើរ ការខ្សែបញ្ជូន (១) ១១៥ kV តភ្ជាប់ពីក្រុងព្រះសីហនុ-រាម និង (២) ១១៥kV តភ្ជាប់កំពង់សីល្ហ-ស្វាយអន្ទរ<br>▪ បានពិនិត្យគន្លងខ្សែបញ្ជូន និង ទីតាំងបង្គោលជាក់ ស្តែងនៃខ្សែបញ្ជូន និង ទីតាំងអនុស្ថានីយ<br>▪ ដាក់ឱ្យដើណើរការខ្សែបញ្ជូន ២៣០kV តភ្ជាប់ពីខេត្តបាត់ដំបង-សៀមរាប-កំពង់ធំ-កំពង់ចាម និងបណ្តាញជាកងបន្ថែម ជុំវិញរាជធានីភ្នំពេញ (ពីអនុស្ថានីយទី៦-អនុស្ថានីយខាងលិចភ្នំពេញ EPP អនុស្ថានីយទី៧) | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងចង្កូលភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ កំពុងសិក្សាដាក់ឱ្យដំណើរការខ្សែបញ្ជូន ១១៥ kV តភ្ជាប់ពីក្រឡាញ់-ឧត្តរមានជ័យ<br>▪ ខ្សែបញ្ជូនតភ្ជាប់ពីរាជធានីភ្នំពេញ-ខេត្តព្រះសីហនុ បានប្ដូរពី ២៣០ kV ទៅ ៥០០ kV វិញ។ ថ្មីៗនេះ គម្រោងនេះបានកំពុងសាងសង់។<br>▪ បានអនុម័តលើថវិកាកម្ម និងកំពុងសិក្សាលម្អិតលើលក្ខណៈបច្ចេកទេស។ បន្ថែមពីនេះ កំពុងស្នើការសម្រេចពីគណៈរដ្ឋមន្ត្រីដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាំង២។<br>- រដ្ឋបាលខេត្តស្វាយរៀង÷<br>▪ ដាក់ដំណើរការខ្សែបញ្ជូនតង់ស្យុង១៥០គីឡូវ៉ុល នៅត្រីមាសទី១ ឆ្នាំ ២០១៧ និងកំពុងបន្តចែកចាយ ពីអនុស្ថានីយ ច្រកម្ទេស ឆ្លោះទៅ អង្គភាពអគ្គិសនី ខេត្តស្វាយរៀង និងឆ្ពោះទៅតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន ក្រុងបាវិត<br>▪ ពង្រីកបណ្ដាញតង់ស្យុងទាប (LV) បានប្រវែង ៥៦.៦៤៥ម<br>▪ ពង្រីកបណ្ដាញតង់ស្យុងមធ្យម (MV) បានប្រវែង ៣០.៣៤២ម<br>▪ រៀបចំតបណ្ដាញអគ្គិសនីចូលតាមភូមិ និងបន្តចែកចាយជូនប្រជាពលរដ្ឋប្រើប្រាស់ចំនួន៦៩,៨៥០គ្រួសារស្មើនឹង ៤៨.២៣%<br>▪ បាននិងកំពុងអនុវត្តតម្លៃអគ្គិសនីជូនអ្នកប្រើប្រាស់មានបីកម្រិតគឺ÷មិនលើស ១០គីឡូវ៉ាត់ម៉ោង/ខែ ថ្លៃ ៤៨០រៀល/គីឡូវ៉ាត់ម៉ោង, ចាប់ពី (១១-៥០)គីឡូវ៉ាត់ម៉ោង/ខែថ្លៃ ៦១០រៀល/គីឡូវ៉ាត់ម៉ោង, ចាប់ពី៥១គីឡូវ៉ាត់ម៉ោង/ខែ ឡើងទៅថ្លៃ៧៧០រៀល/គីឡូវ៉ាត់ម៉ោង។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| - អនុវត្តគម្រោងកសាងស្ថានីយផលិតអគ្គិសនីដែលបានគ្រោង និងកំពុងបន្តអនុវត្តឱ្យទាន់ពេលវេលា ដើម្បីបំពេញកង្វះខាតថាមពលអគ្គិសនីនៅឆ្នាំ២០២០ រួមទាំងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និងគុណភាពនៃការបញ្ជូនថាមពល | មធ្យម ទៅ វែង | - ក្រសួងរ៉ែនិងថាមពល ដោយសហការជាមួយអាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ បានអនុវត្តគម្រោងវិនិយោគ លើកកម្ពស់ស្ថិរភាពនៃការផ្គត់ផ្គង់<br>▪ បាននិងកំពុងសិក្សាគម្រោងសាងសង់អនុស្ថានីយថ្មីក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ<br>▪ បាននិងកំពុងត្រួតពិនិត្យជាប្រចាំប្រព័ន្ធផ្គត់ផ្គង់ឱ្យមានស្ថិរភាពខ្ពស់ខិតទៅរកស្តង់ដារអន្តរជាតិ។<br>ក្នុងឆ្នាំ២០១៨÷<br>▪ បានសាងសង់ខ្សែបញ្ជូនតភ្ជាប់ពីសៀមរាប-ឧត្តរមានជ័យ ១១៥kV អនុស្ថានីយឧត្តរមានជ័យ និងអនុស្ថានីយបែកចាន (ពោធិ៍សែនជ័យ)។ | |
| - ពិនិត្យឡើងវិញនូវការប៉ាន់ស្មានពីតម្រូវការអគ្គិសនីរយៈពេលវែង និងផែនការអភិវឌ្ឍវិស័យថាមពល ឆ្លៀបនឹងចក្ខុវិស័យថ្មីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហកម្ម រួមទាំងពិនិត្យឡើងវិញនូវជម្រើសក្នុងការផ្គត់ផ្គង់ថាមពលដែលមានសមត្ថភាពគ្រប់គ្រាន់ ជាពិសេស សម្រាប់ផ្គត់ផ្គង់តំបន់ឧស្សាហកម្មយុទ្ធសាស្ត្រសំខាន់ៗ | ២០១៥ | - ក្រសួងរ៉ែ និងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ តាមផែនការវិនិយោគផ្នែកថាមពល រហូតដល់ឆ្នាំ២០២០ អគ្គិសនីកម្ពុជា មានលទ្ធភាពផ្គត់ផ្គង់តាមតម្រូវការ<br>▪ បានសិក្សាសមិទ្ធិលទ្ធភាពស្ថានីយអគ្គិសនីដុតធ្យូងថ្មឬឧស្ម័នប្រមាណ ២០០MW នៅក្បែររាជធានីភ្នំពេញដើម្បីលើកកម្ពស់សមត្ថភាពផ្គត់ផ្គង់ និងស្ថិរភាពប្រព័ន្ធបណ្តាញបញ្ជូនជាតិ។ ជាមួយគ្នានេះដែរ ទីប្រឹក្សាគម្រោងរបស់ក្រុមហ៊ុនធ្យូងថ្មជំហានទី២ CIIDG កំពុងសិក្សាពីសមិទ្ធិលទ្ធភាព។<br>ក្នុងឆ្នាំ២០១៨÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ តាមផែនការវិនិយោគផ្នែកថាមពល រហូតដល់ឆ្នាំ២០២០ អគ្គិសនីកម្ពុជា មានលទ្ធភាពផ្គត់ផ្គង់តាមតម្រូវការ<br>▪ បានអនុញ្ញាតឱ្យក្រុមហ៊ុន CIIDG ធ្វើការវិនិយោគសាងសង់រោងចក្រអគ្គិសនីដុតធ្យូងថ្ម អានុភាព ៧០០MW នៅខេត្តព្រះសីហនុ ដែលនឹងដាក់ឱ្យដំណើរការនៅឆ្នាំ២០២០ និង២០២១។ | |
| - បង្កើនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកែលម្អសេវា និងមធ្យោបាយដឹកជញ្ជូន សម្រាប់សម្រួល និងជួយគាំទ្រប្រតិបត្តិការអាជីវកម្ម | មធ្យម ទៅ វែង | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល÷<br>▪ បានអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិ និងអាកាសយានដ្ឋានក្នុងស្រុក នៅក្នុងឆ្នាំ២០១៧ ដូចខាងក្រោម÷<br>- អាកាសយានដ្ឋានអន្តរជាតិភ្នំពេញបានពង្រីកចំណតយន្តហោះសម្រាប់ប្រភេទ4E ចំនួន ៣ចំណត សរុបមានចំនួន ២១ចំណត និងបានជួសជុល និងពង្រីកស្ថានីយអ្នកដំណើរបានផ្ទៃក្រឡា ៤០.០៧៤ម$^{២}$ ដែលមានសមត្ថភាពអាចទទួលអ្នកដំណើរបានជាង៥លាននាក់ក្នុងមួយឆ្នាំ<br>- បានពង្រីកស្ថានីយផ្ទុកទំនិញបានផ្ទៃក្រឡា ៩.៤៤៥ម$^{២}$ ដែលមានសមត្ថភាពអាចទទួលទំនិញបាន ៣០.០០០តោនក្នុងមួយឆ្នាំ<br>- អាកាសយានដ្ឋានអន្តរជាតិសៀមរាប បានពង្រីកចំណតយន្តហោះសម្រាប់ប្រភេទ4D ចំនួន ២ចំណត សរុបមានចំនួន ២១ចំណត និងបានបំពាក់ពោងខ្យល់ថ្មី ១កន្លែង ព្រមទាំងបាននិងកំពុងសាងសង់ផ្លូវបរថ្មីចំនួន ២ គឺ Taxiway C និង Taxiway D | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ៗសមត្ថភាពធនធានមនុស្ស និងស្ថាប័នពាក់ព័ន្ធនៅមាន កម្រិត<br>- រដ្ឋបាលខេត្តកណ្ដាល÷<br>បញ្ហាប្រឈម÷<br>▪ អាជីវករមួយចំនួនខ្វះទុន សម្រាប់ដំណើរការកម្ចីមានការប្រាក់ខ្ពស់<br>▪ តំបន់ដែលរងផលប៉ះពាល់ពីការពង្រីកផ្លូវមានការយឺតយូរក្នុងការតបណ្ដាញ<br>▪ ប្រជាជននៅតាមជនបទមួយចំនួននៅមានទម្លាប់ប្រើប្រាស់ទឹកស្រះ អណ្ដូង បឹង ...។<br>សំណើដំណោះស្រាយ÷<br>▪ ខិតខំស្វះស្វែងរកដៃគូអភិវឌ្ឍន៍ជួនអាជីវករ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - អាកាសយានដ្ឋានក្នុងស្រុកខេត្តបាត់ដំបង បានជួសជុលចាក់ពង្រីកកំរាលផ្លូវរត់ បានប្រវែង ៤៧០ម លើប្រវែងសរុប ១.៦០០ម<br>- អាកាសយានដ្ឋានក្នុងស្រុកខេត្តស្ទឹងត្រែង បានជួសជុលថែទាំផ្លូវរត់ប្រចាំឆ្នាំ<br>- អាកាសយានដ្ឋានក្នុងស្រុកខេត្តកោះកុង បានសាងសង់របងអាកាសយានដ្ឋានស្មើនឹង ៧០០ម បានជួសជុលថែទាំ និងសំណង់អាគារប្រចាំឆ្នាំ តបណ្តាញទឹកស្អាត<br>- អាកាសយានដ្ឋានក្នុងស្រុកខេត្តរតនគិរី ខេត្តមណ្ឌលគិរី និងខេត្តព្រះវិហារ ត្រូវបានប្រគល់ជូនអាជ្ញាធរខេត្តអ្នកគ្រប់គ្រង និងអភិវឌ្ឍ តាមគោលការណ៍របស់រាជរដ្ឋាភិបាល។<br>(ការងារឆ្នាំ២០១៨)<br>▪ ៙អាកាសយានដ្ឋានបាត់ដំបងៈ បានជួសជុលផ្លូវរត់ទំហំ ៩២០០ ម² ថវិកា ២០០០លានរៀល (ដំណាក់កាលទី៣) នៅអាកាសយានដ្ឋានបាត់ដំបង<br>▪ ៙អាកាសយានដ្ឋានស្ទឹងត្រែងៈ បានបោះបង្គោលព្រំខ័ណ្ឌចំនួន៩០ បង្គោល ថវិកា១០០លានរៀលនៅអាកាសយានដ្ឋានស្ទឹងត្រែង<br>▪ ៙អាកាសយានដ្ឋានកោះកុង÷<br>- បានរុះរូសបណ្តាញអគ្គិសនីមេប្រវែង ២៧០ម អស់ថវិកា ១៨០ លានរៀល (ដំណាក់កាលទី១) នៅអាកាសយានដ្ឋានកោះកុង<br>- ចូលរួមប្រជុំការងារជាមួយក្រុមហ៊ុន Union Investment Group ក្នុងការអភិវឌ្ឍអាកាសយានដ្ឋានតារាសាគរ ខេត្តកោះកុង។ | ▪ ណែនាំឱ្យស្វែងយល់ពីប្លង់មេ និងគម្រោងពង្រីកផ្លូវ<br>▪ អាជ្ញាធរមូលដ្ឋានត្រូវខិតខំអប់រំប្រជាជនឱ្យមានការយល់ដឹងពីសារសំខាន់ក្នុងការប្តូរទម្លាប់មកប្រើប្រាស់ទឹកស្អាតក្នុងជីវភាពរស់នៅដើម្បីសុខភាព។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ៧អាកាសយានដ្ឋានកំពង់ឆ្នាំង៖ កំពុងចុះប្រមូលទិន្នន័យពាក់ព័ន្ធដែលជាអាកាសយានដ្ឋានបម្រុង និងយុទ្ធសាស្ត្រមួយក្នុងចំណោមអាកាសយានដ្ឋានក្នុងស្រុកដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖<br>ការងារក្នុងឆ្នាំ២០១៧-២០១៨<br>▪ ក្នុងក្របខណ្ឌវិនិយោគ បានពិនិត្យ និងអនុម័ត គម្រោងវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ បានចំនួន ១០ ដែលមានទុនវិនិយោគប្រមាណជា ១,៤ប៊ីលានដុល្លារអាមេរិក ស្មើនឹង ២២% នៃទុនវិនិយោគសរុបដែលចុះបញ្ជី នៅក.អ.ក ក្នុងឆ្នាំ២០១៧<br>▪ ក្នុងក្របខណ្ឌវិនិយោគ បានពិនិត្យ និងអនុម័ត គម្រោងវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ បានចំនួន ១១ ដែលមានទុនវិនិយោគប្រមាណជា ២,៨ប៊ីលានដុល្លារអាមេរិក ស្មើនឹង ៤៣% នៃទុនវិនិយោគសរុបដែលចុះបញ្ជី នៅក.អ.ក ក្នុងឆ្នាំ២០១៨<br>▪ បានជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ច ដែលរួមមាន អាងប្រព្រឹត្តិកម្មទឹកកខ្វក់, ផ្លូវថ្នល់, លូទឹក, សួនច្បារ, បណ្តាញទឹក-ភ្លើង, ការឈូសឆាយដី និងការសាងសង់រោងចក្រ និងការពង្រឹងសន្តិសុខក្នុងតំបន់ទាំងថ្ងៃទាំងយប់។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖<br>▪ បានចូលរួមក្នុងដំណើរការរៀបចំ និងបង្កើតមូលនិធិវិនិយោគអាស៊ាន (ASEAN Investment Fund - AIF) និងធនាគារ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងទឡ្ហនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | វិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (Asian Infrastructure Investment Bank: AIIB)<br>▪ បានជំរុញដៃគូអភិវឌ្ឍន៍ឱ្យផ្តល់ហិរញ្ញប្បទានសម្បទានកម្រិតខ្ពស់សម្រាប់វិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកែលម្អសេវា និងមធ្យោបាយដឹកជញ្ជូន<br>▪ បានចូលរួមរៀបចំបទដ្ឋានគតិយុត្ត និងនីតិវិធីប្រតិបត្តិការសម្រាប់គ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន<br>▪ បានធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានសម្រាប់រយៈពេលវែង<br>▪ បានរៀបចំបញ្ជីគម្រោងបឋមដែលគ្រោងនឹងអនុវត្តតាមយន្តការ PPPដោយផ្អែកលើសំណើជាផ្លូវការ, សិក្ខាសាលាពិគ្រោះយោបល់, និងកិច្ចប្រជុំពិភាក្សាជាមួយតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងជ្រើសរើសគម្រោងអាទិភាព។<br>- រដ្ឋបាលខេត្តស្វាយរៀង÷<br>▪ បានដំណើរការអនុវត្តគម្រោងស្ថាបនាកំពង់ផែអូរស្វាច់ សម្រេចបានប្រមាណ ១០០% លើការងារដូចខាងក្រោម÷<br>- ការងារស្ថាបនាផ្លូវដីថ្មី ទំហំ ៨៦២មX៧ម និងចាក់ដីសម្រាប់សាងសង់កំពង់ផែអូរស្វាច់ (ទន្លេវៃគោ)ផ្ទៃដី១៣,២៤៣ម២<br>- ការងារស្ថាបនាលើកដីធ្វើ កំពង់ផែអូរស្វាច់ (ទន្លេវៃគោ) ទំហំ ៥០មX១០០ម កម្ពស់ ២,៦០ម<br>- ការងារស្ថាបនាផែដែក បណ្តែតទឹកទំហំ ៦០ម x ១២ម និងផ្លូវបេតុង ប្រវែង ៣៦ម ទទឹង ៦,៤០ម សម្រាប់ចុះផែ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានដំណើរការ ការងារជួសជុលកំណាត់ផ្លូវខេត្តលេខ៣១៦ ប្រវែង ១៣.១២០ម បំបែកចេញ ពីផ្លូវជាតិលេខ១ ត្រង់គ.ម ១៤៣+២០០ស្ថិតក្នុងឃុំស្វាយតាយាន ទៅដល់ផ្លូវខេត្ត ៣១៤C ក្នុងឃុំខ្សែត្រ ស្រុកកំពង់រោទិ៍ ដោយគ្រោងចាក់ក្រាលកៅស៊ូ DBST ទទឹង ៧ម ចិញ្ចើម ១ម សងខាងព្រមទាំងស្ពាបនាលូកាត់ទទឹងផ្លូវប្រវែង១២ម ចំនួន ១២កន្លែង សម្រេចបាន ៩០%។<br>▪ បានដំណើរការការងារជួសជុលកំណាត់ផ្លូវខេត្តលេខ ៣១៤C ប្រវែង ១៣,០០០ម បំបែកចេញពីផ្លូវជាតិលេខ១៨ (៣១៨D) ត្រង់គ.ម ១៦+០០០ ចាប់ពីសាលាស្រុកកំពង់រោទិ៍ ទៅដល់ឃុំត្នោត ស្រុកកំពង់រោទិ៍ ដោយគ្រោងចាក់ក្រាល កៅស៊ូ DBST ទទឹង ៦ម ចិញ្ចើម ១ម សងខាង ព្រមទាំងស្ពាបនាលូកាត់ទទឹងផ្លូវប្រវែង ១១ម ចំនួន ១០កន្លែង សម្រេចបាន ៨៥ %។<br>▪ ការងារជួសជុលផ្លូវខេត្តលេខ៣១៥ ប្រវែង ៧,៥០០ម ដោយក្រាលកៅស៊ូ DBST ពី គ.ម១០+៧០០ ដល់ គ.ម១៨+២០០ សម្រេចបាន ៨០ %។<br>▪ ការងារជួសជុលផ្លូវខេត្តលេខ៣១៧អា ប្រវែង ២,៥០០ម ដោយក្រាលគ្រួសក្រហម សម្រេចបាន១៥%។<br>- រដ្ឋបាលខេត្តកណ្ដាល÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ បានពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត និងគម្រោងជំនួយបច្ចេកទេសហិរញ្ញវត្ថុ សម្រាប់គ្រួសារក្រីក្រជំហ៊ាន២ នៅបណ្ដាឃុំ÷ ប្រាសាទ កោះអន្លង់ចិន ព្រែករៃ លើកដែក សំរោងលើ។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានសហការជាមួយធនាគារពិភពលោក និងអគ្គនាយកដ្ឋានទឹកស្អាត បើកវគ្គបណ្តុះបណ្តាលដល់អាជីវករផលិតទឹកស្អាត ចំនួន ២៥នាក់ ស្តីពីប្រព័ន្ធកត់ត្រាទិន្នន័យទឹកស្អាត<br>▪ អាជីវកម្មទឹកស្អាតសរុប÷ ៤៤មូលដ្ឋាន មានចំនួន ៨០៨ភូមិ គ្របដណ្តប់ ៥៦៣។ ចំនួនខ្នងផ្ទះបានតទឹកមាន÷ ៧៦ ៥៨៥ខ្នងផ្ទះ។<br>▪ បានយកសំណាកទឹកស្អាត១០៤ សំណាក ទៅពិនិត្យគុណភាពទឹក។<br>ក្នុងឆ្នាំ២០១៨÷<br>▪ អាជីវកម្មទឹកស្អាតសរុប÷ ៤៨មូលដ្ឋាន កើន៤។ ចំនួន ៩១៩ភូមិ កើន ១០៦។ ចំនួនភូមិគ្របដណ្តប់មាន ៦៤៩ភូមិ កើន ៨៦។ ចំនួនខ្នងផ្ទះបានតទឹកមាន ៨៩ ១៧៧ កើន ១២ ៥៩២<br>▪ បានយកសំណាកទឹកស្អាត១២៦សំណាក ទៅពិនិត្យគុណភាពទឹក។ | |
| - ពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានី ទីប្រជុំជន តំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការពង្រឹងសមត្ថភាព អង្គភាពរដ្ឋាករទឹកសាធារណៈ និងឯកជន ស្របតាមបទដ្ឋានបច្ចេកទេសនៃការផ្គត់ផ្គង់សេវាទឹកស្អាត និងអនុលោមតាមស្តង់ដារទឹក បរិភោគជាតិ | ២០១៥ ទៅ មធ្យម | - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>▪ បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជន សម្រាប់ផ្គត់ផ្គង់ទឹកស្អាតដល់រោងចក្រ សហគ្រាសកម្មន្តសាល និងតំបន់អភិវឌ្ឍន៍ពាក់ព័ន្ធវិស័យឧស្សាហកម្មនានា ដើម្បីសម្រេចគោលដៅនៃការផ្គត់ផ្គង់ទឹកស្អាត ប្រើប្រាស់នៅទីប្រជុំជនឱ្យបាន ១០០% នៅឆ្នាំ២០២៥<br>▪ ក្នុងឆ្នាំ២០១៧ ការផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជន បាន ចំនួន ២៨០.៨១៣.១៣៧ម៣ ដែលបានផ្តល់ឱ្យប្រជាជន ប្រមាណជា ៨៥,៨៤% រស់នៅទីប្រជុំជនទូទាំងប្រទេសទទួលបានទឹកស្អាតប្រើប្រាស់។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - រដ្ឋបាលខេត្តកណ្តាល÷<br>▪ បានពង្រីកអាជីវកម្មផលិតទឹកស្អាតឯកជនរហូតដល់ ៤៥មូលដ្ឋាន ក្នុងឆ្នាំ២០១៧ កើន១៦ឃុំ និង៧៧ភូមិ មានអ្នកប្រើប្រាស់ ១០.០១៧ខ្នងផ្ទះ។ បរិមាណទឹកបានកើនឡើង ៣៨១.៣៣៦ ម៉ែត្រគូប ប្រវែងបណ្តាញបានកើនឡើង ១៣.៥២៤មែត្រ ដែលទុនវិនិយោគកើនឡើង ៧.៨១២.៩៨៧ ដុល្លារអាមេរិក។ បើធៀបនឹងឆ្នាំ២០១៦ បរិមាណទឹកផលិតបានកើនឡើង ៥.៧៨% ចំនួនស្ថានីយបានកើនឡើង ១៥.៣៨% តំបន់សេវាកម្មឃុំកើនឡើង ១៥.៥៨% ចំនួនភូមិកើនឡើង ១០.០១% ចំនួនអតិថិជនបានកើនឡើង ១២.៥៤% បណ្តាញមេបានកើនឡើង ០.៩០% ហើយទុនវិយោគបានកើនឡើង ៥១.៧%។<br>▪ បានសហការជាមួយគម្រោង ៣I របស់អូស្ត្រាលី សម្របសម្រួលគម្រោងវិនិយោគទឹកស្អាតនៅឃុំកោះអន្លង់ចិន ព្រែករៃ លើកដែក និងសំរោងលើ<br>▪ បានយកសំណាកទឹកស្អាតនៃស្ថានីយឯកជនចំនួន៣៧កន្លែងស្មើនឹង ១០៤គំរូសាក ទៅពិនិត្យគុណភាពនៅមន្ទីរពិសោធ៍ក្រសួង កើនលើសឆ្នាំ២០១៦ ចំនួន ៣សំណាក ត្រូវជា ២.៩៧%។<br>- រដ្ឋបាលខេត្តស្វាយរៀង÷<br>▪ បាននិងកំពុងដំណើរការរោងចក្រទឹកស្អាតចំនួន ០៧ទីតាំង ស្ថិតក្នុង ទីប្រជុំចំនួន ០៧ ដែលមានសមត្ថភាពផលិត ៩.៤៨០ម$^{៣}$/ថ្ងៃ និងមានសេវាគ្របដណ្តប់ពី ៣២% ទៅ ៦២ % | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានដាក់ឱ្យប្រើប្រាស់នូវបណ្តាញទឹកស្អាត ពង្រីកថ្មី ប្រវែង ១២.៨០៨ ម នៅក្រុងស្វាយរៀង និងគ្រោងដាក់ឱ្យប្រើប្រាស់បណ្តាញទឹកស្អាត ៤៥០០ ម/ឆ្នាំ<br>▪ បញ្ចប់ការសិក្សាប្រភពទឹកអាងទន្លេវៃគោ និងទីតាំងសាងសង់រោងចក្រ ផលិតទឹកស្អាតថ្មីដែលមានសមត្ថភាពផលិត ២០.០០០ ម³/ថ្ងៃ ជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)<br>▪ កំពុងសិក្សាសមិទ្ធិលទ្ធភាពគ្រោងផ្គត់ផ្គង់ទឹកស្អាត នៅតាមបណ្តាឃុំចំនួន១០ និងតាមដងផ្លូវជាតិលេខ១ ពីក្រុងស្វាយរៀងទៅក្រុងបាវិត និងតំបន់សេដ្ឋកិច្ចពិសេស<br>▪ ជំរុញការបញ្ចប់ និងដាក់ឱ្យដំណើរការរោងចក្រផលិតទឹកស្អាត នៅឃុំ ក្រោលគោ ស្រុកស្វាយជ្រំ<br>▪ គ្រោងដំណើរការសិក្សាសមិទ្ធិលទ្ធភាពសាងសង់រោងចក្រផ្គត់ផ្គង់ទឹកស្អាត នៅប្រជុំជន ស្រុកកំពង់រោទិ៍ ប្រជុំជន ស្រុកចន្ទ្រា និងប្រជុំជន ដូនស ស្រុកស្វាយជ្រំ<br>▪ បានផ្លាស់ប្តូរទុយោចាស់ប្រវែង ៣.២៣០ម និងជួសជុលប្រព័ន្ធចម្រោះ ២០០ម³/ម៉ោង និងបំពាក់ឧបករណ៍ពិសោធទឹក (គម្រោង ADB)។ | |
| - បន្តពង្រីក និងថែទាំកំណាត់ផ្លូវជាតិសំខាន់ៗ ដែលជាច្រកសម្រាប់ការដឹកជញ្ជូនទំនិញជាពិសេស ផ្លូវជាតិឱ្យក្លាយជាផ្លូវថ្នល់ធំទូលាយ ដើម្បីធ្វើឱ្យប្រសើរនូវការតភ្ជាប់ទៅកាន់ប្រទេសថៃ និងវៀតណាម ព្រមទាំងច្រករបៀងភ្នំពេញ- | មធ្យម ទៅ វែង | - ក្រសួងសាធារណការ និងដឹកជញ្ជូន÷<br>**១. គម្រោងផ្លូវពង្រីកជា ៤គន្លងផ្លូវ**<br>▪ ផ្លូវជាតិ៤គន្លងដែលបានបញ្ចប់ មានប្រវែង ១៥៧គ.ម÷ ផ្លូវជាតិលេខ១ ប្រវែង៤គ.ម ផ្លូវជាតិលេខ៣ ប្រវែង២គ.ម ផ្លូវជាតិលេខ ៤ (ភ្នំពេញ-កំពង់ស្ពឺ) ប្រវែង ៤៦គ.ម ផ្លូវជាតិលេខ៥ (ភ្នំពេញ- | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ថវិកានៅមានកម្រិត ដែល តម្រូវការមានច្រើនជាពិសេសលើកកម្ពស់ គុណភាពផ្លូវជាតិសំខាន់ៗ។<br>- រដ្ឋបាលខេត្តបន្ទាយមានជ័យ÷ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| សៀមរាប និងភ្នំពេញ-ក្រុងព្រះសីហនុ ទន្ទឹមនឹងការពិនិត្យសម្រាប់រយៈពេលវែងនូវលទ្ធភាពកសាងផ្លូវហាយវ៉េចំពោះ ផ្លូវជាតិសំខាន់ៗសម្រាប់ពង្រឹងសមត្ថភាពប្រព័ន្ធភស្តុភារកម្មរវាងកម្ពុជា និងប្រទេសជាទៀត ជាអាទិ៍ ប្រទេសថៃ និងវៀតណាម | | ស្ពានព្រែកក្តាម) ប្រវែង៣១គ.ម និងផ្លូវជាតិលេខ៦ (ភ្នំពេញ-ស្គន់) ប្រវែង ៦៩គ.ម។ កំពុងសាងសង់ពង្រីកបន្ថែមមានប្រវែងសរុប ៤៣១គ.ម<br>▪ កំណាត់ផ្លូវជាតិដែលកំពុងអនុវត្តសាងសង់ពង្រីកជា០៤ គន្លងបន្ថែម រួមមាន ផ្លូវជាតិលេខ៥(បាត់ដំបង-សិរីសោភ័ណ្ឌ និង ព្រែកក្តាម-ថ្លាម្អម) និងផ្លូវជាតិលេខ៣ (ចោមចៅ-កំពត) មានប្រវែងផ្លូវសរុប ៣៥៤,៧៩គ.ម។<br>**២. គម្រោងបានបញ្ចប់÷** មាន១៨គម្រោង (ក្នុងនោះគម្រោងស្តារ និងសាងសង់ផ្លូវថ្នល់ចំនួន១៤គម្រោង មានប្រវែងសរុប ១ ៣៤៦,២៤ គ.ម និងគម្រោងស្ពាន មានចំនួន០៤គម្រោង មានប្រវែងសរុប ១ ៩១៤,៨ម៉ែត្រ) ដូចមានខាងក្រោម ÷<br>▪ គម្រោងស្តារនិងពង្រីកកំណាត់ផ្លូវជាតិលេខ៦ប្រវែង៤០,៤៩គ.ម ជាផ្លូវ០៤គន្លង (គ.មលេខ៤-ថ្នល់កែង)<br>▪ គម្រោងស្តារនិងពង្រីកកំណាត់ផ្លូវជាតិលេខ៥ប្រវែង១៩.៥៤គ.ម (ភ្នំពេញ-ព្រែកក្តាម)<br>▪ គម្រោងស្តារ និងពង្រីកកំណាត់ផ្លូវជាតិលេខ៦ ប្រវែង២៤៧,៧០ គ.ម (ថ្នល់កែង-អង្គ្រង/សៀមរាប)<br>▪ គម្រោងស្តារផ្លូវខេត្តលេខ១៥៧៧ ប្រវែង៥១,៧៩គ.ម (ឃុំព្រែងស្រុករតនៈមណ្ឌល-ឃុំសំឡូត ខេត្តបាត់ដំបង)<br>▪ គម្រោងសាងសង់ស្ពានកោះធំ ប្រវែង៤១៥ម៉ែត្រ<br>▪ គម្រោងស្តារឡើងវិញផ្លូវជាតិលេខ២១ ប្រវែង ៥៥គ.ម (វង្វង់មូលតាខ្មៅ-ព្រែជធំ) | បញ្ហាប្រឈម÷<br>▪ មានការយឺតយ៉ាវក្នុងការអនុវត្តគម្រោងមួយចំនួនពុំទាន់បានបញ្ចប់<br>▪ ការអនុវត្តគម្រោងមួយចំនួនជិតបំណាច់ឆ្នាំមានការយឺតយ៉ាវ។<br>សំណើសំណូមពរ÷<br>▪ ខេត្តជួយជំរុញក្រុមហ៊ុនអនុវត្តឱ្យបានចប់សព្វគ្រប់ គម្រោងដែលនៅសេសសល់<br>▪ ជំរុញភាគីអ្នកទទួលការអនុវត្តឱ្យបានរួចរាល់ទាន់ពេលវេលា។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ គម្រោងសាងសង់ស្ពានជ្រៃធំ ប្រវែង ៤២៧,៨ម៉ែត្រ និងផ្លូវតភ្ជាប់ស្ពានប្រវែង ២,៦៦គ.ម (ស្រុកកោះធំ/ខេត្តកណ្ដាល-ឡុងប៊ិញ/ខេត្តអាងយ៉ាង)<br>▪ គម្រោងកែលំអផ្លូវជាតិលេខ១ ប្រវែង៤គ.ម (ស្ពានព្រះមុនីវង្ស-វត្តក្ដីតាកុយ)<br>▪ គម្រោងសាងសង់ស្ពានអាកាសមិត្តភាព កម្ពុជា-ចិនសែនសុខ<br>▪ គម្រោងស្ដារ និងពង្រីកកំណាត់ផ្លូវជាតិលេខ៦ ប្រវែង២៤៧,៧០គ.ម ចាប់ពីថ្នល់កែង ខេត្តកំពង់ចាម ដល់ អង្រ្គង ខេត្តសៀមរាប<br>▪ គម្រោងសាងសង់ផ្លូវជាតិលេខ ៥៥ (ផ្លូវជាតិលេខ៥-ក្រវាញ-ព្រំដែនកម្ពុជា-ថៃ) ប្រវែង១៨២,១៦គ.ម<br>▪ គម្រោងស្ដារផ្លូវជាតិលេខ៥៨ ប្រវែង១៧៤គ.ម(ប៉ោយប៉ែត - ផ្ទុង/ខេត្តឧត្តរមានជ័យ)<br>▪ ផ្លូវជាតិលេខ៥៣ ផ្លូវខេត្តលេខ១៥០BE ផ្លូវខេត្តលេខ១៥០BW និងផ្លូវខេត្តលេខ១៥១B ប្រវែងសរុប ៨៧,៩០គ.ម (តាជេស ខេត្តកំពង់ឆ្នាំង អមលាំង ខេត្តកំពង់ស្ពឺ)<br>▪ ផ្លូវជាតិ១៣ ប្រវែង៦២,៤០គ.ម (កំចាយមារ/ខេត្តព្រៃវែង-ប្រសូត/ខេត្តស្វាយរៀង)<br>▪ ផ្លូវលេខ៣១៤D ប្រវែង ២៥,៥០គ.ម (ប្រសូត-ព្រៃវល្លិ៍ ព្រំដែនកម្ពុជា-វៀតណាម)<br>▪ គម្រោងសាងសង់ផ្លូវលេខ ១៥៧៧ ប្រវែង ៥១,៧៩គ.ម សេកសក-សំឡូត | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងចន្លោះសមត្ថភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ គម្រោងស្ដារ និងលើកកម្រិតផ្លូវជាតិលេខ៧ ប៉ែកខាងត្បូង ក្រាលAC ប្រវែង៩៣,៤៦គ.ម(ខ្លាស្ទុះ-រមៀត)<br>▪ សាងសង់ស្ពានឆ្លងកាត់ព្រំដែនកម្ពុជា-ថៃ (ស្ទឹងបត់-បានណងអៀន) ប្រវែងសរុប ៦២០ម. ទទឹង១៧ម. ក្នុងនោះ តួស្ពានប្រវែង ១៣០ម.(ផ្នែកកម្ពុជា៦៥ម.) ផ្លូវភ្ជាប់ក្បាលស្ពានប្រវែង ៤៩០ម.(ផ្នែកកម្ពុជា១៥០ម.)។<br>៣. គម្រោងកំពុងដំណើរការ : មាន១៣គម្រោង (ក្នុងនោះគម្រោងស្ដារ និងសាងសង់ផ្លូវថ្នល់ចំនួន១០គម្រោង មានប្រវែងសរុបប្រមាណ ៩២៨,៨៦គ.ម គម្រោងស្ពាន មានចំនួន០២គម្រោង មានប្រវែងសរុបប្រមាណ ១ ១៣១,៨ម៉ែត្រ) និងគម្រោងសាងសង់អគារច្រកទ្វារព្រំដែនស្ទឹងបត់ ដូចមានខាងក្រោម ÷<br>▪ គម្រោងសាងសង់ផ្លូវក្រវាត់ក្រុងខ្សែទី២ប្រវែង១៦,៦៨គ.ម (មហាវិថីសហព័ន្ធរុស្ស៊ី-ព្រែកហូរ)<br>▪ គម្រោងសាងសង់ផ្លូវក្រវាត់ក្រុងខ្សែទី៣(ផ្លូវជាតិលេខ៥-អូរឡឹម-ផ្លូវជាតិលេខ១) ប្រវែង៤៥,៦១គ.ម<br>▪ គម្រោងស្ដារផ្លូវជាតិលេខ៥១ ប្រវែង៣៨គ.ម(ថ្នល់ទទឹង/ផ្លូវជាតិលេខ៤-ឧត្ដុង្គ/ផ្លូវជាតិលេខ៥)<br>▪ គម្រោងលើកកម្រិត និងថែទាំផ្លូវជាតិលេខ៣ ក្រាលAC ប្រវែង ៥៤,៣គ.ម(គ.ម១៤៧+១០០-២០១+៤០០)<br>▪ គម្រោងពង្រីកផ្លូវជាតិលេខ៣ (ចោមចៅ-ក្រុងកំពត) ប្រវែង ១៣៤,៨០គ.ម (៧០គ.ម ពង្រីក៤គន្លងផ្លូវ) | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ សាងសង់ស្ពានចំនួន០៧ ឡើងវិញបន្ទាន់នៅតំបន់ប្រឈមគ្រោះទឹកជំនន់ (លើផ្លូវជាតិលេខ៧៣ ស្ពានចំនួន០៥ នៅខេត្តក្រចេះ និងផ្លូវជាតិលេខ១១ ស្ពានចំនួន០២ នៅខេត្តព្រៃវែង)<br>▪ ផ្លូវជាតិលេខ១១ (អ្នកលឿង/ព្រៃវែង-ថ្នល់ទទឹង/ត្បូងឃ្មុំ) ប្រវែងសរុប ៩៦,៤៨គ.ម<br>▪ ស្ពានស្ទឹងត្រង់-ក្រូចឆ្មារ ប្រវែង ១ ១៣១ម.<br>▪ គម្រោងអភិវឌ្ឍន៍ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ ប្រវែង ១៩០គ.ម<br>▪ គម្រោងសាងសង់កំណាត់ផ្លូវជាតិលេខ៥ ក្រាល AC ប្រវែង ៨៤,៧៤គ.ម (បាត់ដំបង-សិរីសោភ័ណ)៤គន្លង<br>▪ គម្រោងសាងសង់កំណាត់ផ្លូវជាតិលេខ៥ ប្រវែង១៣៥,២៥គ.ម (ព្រែកក្តាម-ថ្លាម្អម)៤គន្លងផ្លូវ<br>▪ គម្រោងធ្វើឱ្យប្រសើរកំណាត់ផ្លូវជាតិលេខ៥ ភាគកណ្តាល (ថ្លាម្អម-បាត់ដំបងនិងសិរីសោភ័ណ-ប៉ោយប៉ែត) ជា៤គន្លងផ្លូវ<br>▪ គម្រោងសាងសង់អាគារច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ និងផ្លូវតភ្ជាប់ទៅផ្លូវជាតិលេខ៥។<br>៤. **គម្រោងត្រៀមអនុវត្ត÷** មានគម្រោងស្តារ និងសាងសង់ផ្លូវថ្នល់ចំនួន០៥គម្រោង មានប្រវែងសរុបប្រមាណ ៧៧៦,២១គ.ម ដូចមានខាងក្រោម ÷<br>▪ គម្រោងផ្លូវជាតិលេខ១១០ ប្រមោយ (ផជ.៥៥)-ស្វាច់មានជ័យ (ផជ.៤៨) ប្រវែង១៩៧គ.ម | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងចូលរួមគាំទ្រ/ចូលរួមភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ គម្រោងលើកកម្រិតផ្លូវជាតិលេខ៤៨ (ស្រែអំបិល-ខេត្តកោះកុង) ប្រវែង ១៥០គ.ម ក្រាលកៅស៊ូ AC<br>▪ គម្រោងផ្លូវជាតិលេខ៧១សេ<br>▪ គម្រោងថែទាំ និងជួសជុលផ្លូវជាតិលេខ៤ ក្រាលកៅស៊ូAC ប្រវែង២៣០គ.ម (ភ្នំពេញ-ក្រុងព្រះសីហនុ)<br>▪ គម្រោងសាងសង់ផ្លូវជាតិលេខ២ (ក្រុងតាខ្មៅ-ក្រុងដូនកែវ/អូរចិបក់) និងផ្លូវជាតិលេខ២២ (អូរចិបក់-អង្គតាសោម/ខេត្តតាកែវ) ប្រវែង ៧២,២១គ.ម<br>▪ អនុវត្តគម្រោងកែលម្អបណ្ដាញផ្លូវ ជួសជុល ថែទាំកំណាត់ផ្លូវជាតិលេខ១ ប្រវែង៩៧គ.ម AC (អ្នកលឿង-បាវិត) និងកំណាត់ផ្លូវជាតិលេខ៦ ក្រឡាញ់-ស៊ីសុផុន (៥០គ.ម)<br>៥. **គម្រោងអាទិភាពបន្ត÷** មាន១៦គម្រោង ដែលមានគម្រោងស្ពារ និងសាងសង់ផ្លូវថ្មល់ និងស្ពាន ដូចមានខាងក្រោម ÷<br>▪ គម្រោងសាងសង់ផ្លូវជាតិលេខ៤១<br>▪ គម្រោងសាងសង់ផ្លូវជាតិលេខ ៤៣ ត្រែងត្រយឹង(ផជ.៤)-ទ្វារថ្មី (ផជ.៣) ប្រវែង ៧៧ គម.<br>▪ គម្រោងសាងសង់ផ្លូវ៣១អា ជុំគីរី (ផ្លូវជាតិលេខ៤១)-ឈូក-កំពង់ត្រាច (ផ្លូវជាតិលេខ៣៣)ប្រវែង ៤២គម.<br>▪ គម្រោងស្ពារឡើងវិញផ្លូវជាតិលេខ៣៣<br>▪ គម្រោងសាងសង់ផ្លូវជាតិលេខ៤៣ ត្រែងត្រយឹង (ផជ.៤)-ទ្វារថ្មី (ផជ.៣) | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ គម្រោងសាងសង់ផ្លូវជុំវិញតិរី (ផជ.៤១)-ផជ.៣១A-ឈូក-ដងទង់-កំពង់ត្រាច (ផជ.៣១)<br>▪ សិក្សាស្តារឡើងវិញផ្លូវក្នុង និងផ្លូវវាងក្រុងព្រះសីហនុ<br>▪ គម្រោងសាងសង់ផ្លូវក្រវាត់ក្រុងខាងក្រៅ<br>▪ គម្រោងសាងសង់ស្ពានជ្រោយចង្វារ-ស្វាយជ្រុំ<br>▪ គម្រោងសាងសង់ស្ពានស្ពាង<br>▪ គម្រោងសាងសង់ផ្លូវក្រវាត់ក្រុងតាខ្មៅ<br>▪ គម្រោងស្តារឡើងវិញកំណាត់ផ្លូវពាមរក៍ ទៅកោះរកា (ព្រំដែនកម្ពុជា-វៀតណាម) ផ្លូវលេខ៣១០<br>▪ ផ្លូវជាតិលេខ៥០C (ផ្សារក្រោម ភូមិចាន់ណុល ផជ.៥-ភូមិរការ ផជ.៦ រួមទាំងស្ពាន ៣.៩ត.ម)ប្រវែង ៥៨ត.ម<br>▪ គម្រោងធ្វើឱ្យប្រសើរឡើងវិញលើផ្លូវជាតិ៦៧<br>▪ គម្រោងផ្លូវជាតិលេខ៦០B (កំពង់ថ្ម-ក្រុងក្រចេះ)<br>▪ គម្រោងសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-ប៉ោយប៉ែត-សៀមរាប និងភ្នំពេញ-បាវិត។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននិងកំពុងបន្តអនុវត្តគម្រោងពង្រីកផ្លូវជាតិលេខ ១, ៥, ៦, និង៧ ឱ្យទៅជា ៤ គន្លង (តាមតំបន់) ព្រមទាំងសម្រេចបានថែទាំផ្លូវជាតិ និងផ្លូវខេត្ត និងផ្លូវលំជនបទ ប្រវែងប្រមាណ ១១ ៤២៤គម ក្នុងនោះ÷<br>▪ ផ្លូវជាតិមួយលេខ ប្រវែង ១ ៨៧៧គម ទឹកប្រាក់ប្រមាណ ៣៨ ១៥១ លានរៀល | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ផ្លូវជាតិពីរលេខ ប្រវែង ២ ៨៨៣គម ទឹកប្រាក់ប្រមាណ ៣៦ ៦១៦ លានរៀល<br>▪ ផ្លូវខេត្តបីលេខ ប្រវែង ១ ៩៧២គម ទឹកប្រាក់ប្រមាណ ២៣ ៥២២ លានរៀល<br>▪ ផ្លូវខេត្តបួនលេខ ប្រវែង ២ ៤៥៥គម ទឹកប្រាក់ប្រមាណ ២៣ ៣៣៥ លានរៀល<br>▪ ផ្លូវលំជនបទ ប្រវែង ២ ២៣៧គម ទឹកប្រាក់ប្រមាណ ៨១ ៨៩៤លានរៀល។<br>- រដ្ឋបាលខេត្តស្វាយរៀង÷<br>▪ បានដំណើរការអនុវត្តគម្រោង ផ្លូវវាងសម្រាប់រថយន្តដឹកជញ្ជូនធុនធ្ងន់នៅក្រុងបាវិត ជាប់ ព្រំដែនកម្ពុជា-វៀតណាម ដែលមានប្រវែង ៩គ.មដើម្បីបញ្ចៀស ការកកស្ទះរវាងរថយន្តដឹក ទំនិញ និងរថយន្តទេសចរណ៍ នៅច្រកទ្វារព្រំដែន សម្រេចបាន ១០០% និងបានចូលរួមសិក្សាផែនការអភិវឌ្ឍន៍ផ្លូវល្បឿនលឿនភ្នំពេញ-បាវិត<br>▪ បានដំណើរការជួសជុលផ្លូវ ជាតិលេខ ១៣ ពីកំចាយមារ ខេត្តព្រៃវែង ទៅក្រុងស្វាយរៀង តភ្ជាប់ផ្លូវជាតិលេខ១ និងផ្លូវជាតិលេខ ៨ ប្រវែង ៦២គ.ម សម្រេចបាន ១០០% និងផ្លូវខេត្តលេខ៣១៤D ពីផ្លូវ ជាតិលេខ១ ត្រង់ចំណុចផ្សារប្រសូតិ ស្រុកស្វាយទាប ទៅច្រកទ្វារអន្តរជាតិព្រៃវល្លិ៍ ព្រំដែនកម្ពុជា-វៀតណាម ប្រវែង ២៦គ.ម សម្រេចបាន ៦៥% | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ការងារពង្រីកផ្លូវបេតុងសងខាងផ្លូវជាតិលេខ១ ពីគ.ម ១៦៥ + ៣០០ ដល់គ.ម១៦៦+ ៨០០ ប្រវែង ១.៥០០ម សម្រេច ១០០%។<br>- រដ្ឋបាលខេត្តបន្ទាយមានជ័យ÷<br>ក្នុងឆ្នាំ២០១៧÷<br>▪ បានជួសជុលផ្លូវកៅស៊ូ DBST តភ្ជាប់ផ្លូវជាតិលេខ៥ ផ្លូវចុះរោងម៉ាស៊ីនព្រហ្វូត សង្កាត់អូរអំបិលប្រវែង ២៦៦មx៦ម=១.៥៩៦ម$^{២}$<br>▪ បានចាក់ផ្លូវបេតុងកម្រាស់ ១៥ស.ម តភ្ជាប់ពីផ្លូវជាតិលេខ៥ ភូមិរោងម៉ាស៊ីន និងភូមិព្រហ្វូត សង្កាត់អូរអំបិល ប្រវែង ៧០០មx៦ម=៤.២០០ម$^{២}$<br>▪ បានជួសជុលចាក់ផ្លូវបេតុងកម្រាស់ ១៥ស.ម តភ្ជាប់ពីផ្លូវជាតិលេខ៥ ទៅពន្ធធនាគារខេត្ត ភូមិគាប សង្កាត់ទឹកថ្លា ប្រវែង ១.៧០០មx៧ម=១១.៩០០ម$^{២}$<br>▪ បានជួសជុលចាក់ផ្លូវបេតុងកម្រាស់១៥ស.ម តភ្ជាប់ពីផ្សាររាត្រីចេញ ផ្លូវជាតិលេខ៥ ភូមិព្រះពន្លា និងភូមិព្រៃឬស្សី សង្កាត់ព្រះពន្លា ប្រវែង២.០២០មx៦ម=១២.១២០ម$^{២}$<br>▪ បានចាក់ផ្លូវបេតុងកម្រាស់១៥សងទីម តភ្ជាប់ពីផ្លូវ ៥៦A ផ្លូវចូលវត្តតាហឺ និងផ្លូវចូលសាលាសង្កាត់កំពង់ស្វាយ២ ប្រវែង ១.០០០មx៧ម=៧.០០០ម២<br>▪ បានដាក់លូ Q៨០ ចំនួន ១.០០០កង់ តភ្ជាប់ពីផ្លូវលេខ៥៦ ដល់សាលាសង្កាត់ កំពង់ស្វាយ និងរ៉េហ្គា ៤០កន្លែង | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានដាក់លូ Q៨០ ប្រវែង១២៥កង់-លូ Q៦០ ប្រវែង ១២៤កង់ លូប្រអប់ប្រវែង៨៦ម តភ្ជាប់ពីផ្លូវជាតិលេខ៥ ចំហៀងខាងកើតផ្លូវឡើងតារាងបាល់ទាត់ សង្កាត់កំពង់ស្វាយ និងប៉ោយប៉ែត ៧កន្លែង<br>▪ បានដាក់លូខ្វាត Q១២០ កាត់ទទឹងផ្លូវ សង្កាត់អូរអំបិល ១០កន្លែងសង្កាត់ទឹកថ្លា ១០កន្លែង<br>▪ បានដាក់លូខ្វាតQ៨០ ប្រវែង ៦២០ម កាត់ទទឹង២ខ្សែ ផ្លូវលេខ៤ ដល់លេខ៦ សង្កាត់ កំពង់ស្វាយនិង ប៉ោយប៉ែត ២០កន្លែង<br>▪ បានស្តារលូក្នុងទីរួមខេត្តៈ បរិវេណផ្សារចំការគរ បរិវេណផ្សារសិរីសោភ័ណ បរិវេណសួនច្បារសាធារណៈតាមផ្លូវសាធារណៈ<br>▪ បានស្ថាបនាលើកកម្ពស់តួផ្លូវដីសប្រវែង ២.០០០ម ទំហំសរុប ៤.០០០ម២ និងដាក់លូជ្រុងប្រវែង ៣មx៤មx២០ម (ជំហានទី៤) ខាងត្បូងស្របតាមដងស្ទឹង សិរីសោភ័ណ ក្នុងសង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ។<br>ក្នុងឆ្នាំ២០១៨÷<br>▪ បានជួសជុលផ្លូវចាក់បេតុងកម្រាស់ ១៥សម តភ្ជាប់ពីផ្លូវចុះទឹកស្អាតក្នុង ភូមិរោងម៉ាស៊ីន ភូមិព្រហូត និងភូមិអូរអំបិលសង្កាត់អូរអំបិលប្រវែង ១.០០០មx៦ម=៦.០០០ម$^2$<br>▪ បានជួសជុលចាក់ផ្លូវបេតុងឆ្អឹងដែកកម្រាស់ ១៥សម និងលូប្រអប់ជ្រុងបេតុងសរសៃដែក1កន្លែងទំហំ ៣មx២.៥ម តភ្ជាប់ពីផ្លូវជាតិលេខ៥ ចូលភូមិផុងអារញ្ញសង្កាត់និមិត្ត ក្រុងប៉ោយប៉ែតប្រវែង ១.៦០០មx៥ម= ៨.០០០ម២ និងលូប្រអប់ជ្រុងទំហំ ៣មx ២.៥ម | |

| វិធានការគោលនយោបាយ/ផែនការ សកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានជួសជុលចាក់ផ្លូវកៅស៊ូ DBST កម្រាស់ ១៥សម តភ្ជាប់ផ្លូវជាតិលេខ៥៦ចូលទៅសាលាធីឆីងភូមិកំពង់ស្វាយប្រវែង ៤៥០មx៥ម=២.២៥០ម២<br>▪ បានដាក់លូមុខកាត់ Q១០០ កាត់ទទឹងផ្លូវចំនួន ៦កន្លែង និងចាក់បេតុងដៃលូសងខាងចំនួន១២ ក្នុងសង្កាត់អូរអំបិលនិងសង្កាត់កំពង់ស្វាយការដាក់លូចំនួន ៦០កង់<br>▪ បានជួសជុលលើកតួផ្លូវកម្ពស់ដីសក្រាលក្រួសក្រហម និងក្រាលកៅស៊ូ២ជាន់ DBST ក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ និងសង្កាត់និមិត្តក្រុងប៉ោយប៉ែតប្រវែង ២.៣៤០មx៩ម =២១.០៦០ម២<br>▪ បានថែទាំស្តារលូទឹកស្អុយក្នុងទីរួមខេត្ត និងបានដាក់លូប្រវែង ១.០០០ម។ | |
| - ធ្វើឱ្យប្រសើរឡើង និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៃតំបន់សេដ្ឋកិច្ចពិសេស រួមមាន ប្រព័ន្ធផ្លូវថ្នល់ ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ជាពិសេស នៅខេត្តស្វាយ-រៀង និងកោះកុង ដែលមានច្រកព្រំដែនអន្តរ-ជាតិ និងខេត្តព្រះសីហនុ ដែលមានកំពង់ផែសមុទ្រអន្តរជាតិ | មធ្យម ទៅ វែង | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ការងារក្នុងឆ្នាំ២០១៧-២០១៨<br>▪ បានបន្តជំរុញឱ្យអ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់របស់ខ្លួននីមួយៗឱ្យកាន់តែល្អប្រសើរឡើងស្របទៅតាមផែនការមេ និងតម្រូវការជាក់ស្តែងនៃសកម្មភាពវិនិយោគនៅក្នុងតំបន់ទាំងនោះ<br>▪ បានជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចដែលរួមមានអាងប្រព្រឹត្តិកម្មទឹកកខ្វក់, ផ្លូវថ្នល់, លូទឹក, សួនច្បារ, បណ្តាញទឹក-ភ្លើង, ការឈូសឆាយដី និងការសាងសង់រោងចក្រ និងការពង្រឹងសន្តិសុខក្នុងតំបន់ ទាំងថ្ងៃ ទាំងយប់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ▪ កំពុងសិក្សាបញ្ចូលបទប្បញ្ញត្តិមួយចំនួនពាក់ព័ន្ធទៅនឹងការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស។<br>▪ បានបញ្ចូលបទប្បញ្ញត្តិមួយចំនួនពាក់ព័ន្ធទៅនឹងការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖<br>▪ បាននិងកំពុងសហការអនុវត្តគម្រោងអភិវឌ្ឍន៍ចំណតផែពហុបំណងកំពង់ផែក្រុងព្រះសីហនុ ហិរញ្ញប្បទានដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន មានទឹកប្រាក់ ៧.១៧៦ លានយេន ដើម្បីពង្រីកសមត្ថភាពរបស់កំពង់ផែស្វយតក្រុងព្រះសីហនុ ក្នុងការទទួលនាវាដឹកជញ្ជូនទំនិញទូទៅ ដូចជា ចំណាំងឈើ (Wood Chip) ស្រូវសាឡី ធ្យូងថ្ម ដែក ស៊ីម៉ង់តិ៍ ជាដើម និងសាងសង់ចំណតមូលដ្ឋានផ្គត់ផ្គង់ប្រេងដើម្បីផ្គត់ផ្គង់សេវាឱ្យអាជីវកម្មប្រេងកាតនៅឈូងសមុទ្រកម្ពុជា<br>▪ បាននិងកំពុងសហការអនុវត្តគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មី ហិរញ្ញប្បទានដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន មានទឹកប្រាក់ប្រមាណ ២០៣លានដុល្លារអាមេរិក ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធ រួមមាន សាងសង់ចំណតផែ ៣៥០ម ជម្រៅទឹក ១៤,៥ម, ការងារចាក់ដីបំពេញសាងសង់ទីលាន, សាងសង់ស្ពានផ្លូវចូលចំណតផែថ្មី, ការចាក់ដីបំពេញសម្រាប់ជាទីតាំង | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ត្រួតពិនិត្យទំនិញរបស់គយ, ប្រព័ន្ធបង្ហូរទឹក, ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតប្រព័ន្ធអគ្គិសនី និងសម្បទាផ្សេងៗ<br>▪ បាននិងកំពុងសហការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើង ផ្លូវជាតិលេខ៤៨ ហិរញ្ញប្បទានដោយមូលនិធិសហប្រតិបត្តិការអភិវឌ្ឍសេដ្ឋកិច្ចកូរ៉េ(EDCF) កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ដោយសាងសង់ផ្លូវប្រវែង ១៥០គ.ម មានការងារកែសម្រួលអ័ក្សផ្លូវ និងបំពាក់ ស្លាកសញ្ញាចរាចរណ៍មួយចំនួន<br>▪ បាននិងកំពុងសហការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើង ផ្លូវជាតិលេខ២ និងផ្លូវជាតិលេខ២២ ហិរញ្ញប្បទានដោយមូលនិធិសហ-ប្រតិបត្តិការអភិវឌ្ឍសេដ្ឋកិច្ច កូរ៉េ ដោយសាងសង់ផ្លូវប្រវែង សរុប ៧២,២១គ.ម ក្នុងនោះ ផ្លូវជាតិលេខ២ ពីក្រុងតាខ្មៅ ទៅក្រុងដូនកែវ (អូរចំបក់) ប្រវែង ៦២.៥៧គ.ម និងផ្លូវលេខ២២ អូរចំបក់-អង្គតាសោម ប្រវែង ៩.៦៤គ.ម ដោយក្រាលកៅស៊ូ AC។<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន÷<br>▪ បានសិក្សាវាស់ស្ទង់ជម្រៅទឹក និងផលិតផែនទីអេឡិចត្រូនិកមាគ៌ានាវាចរណ៍ផ្លូវទឹកនៅតំបន់សមុទ្រ (អូរគ្រេះ-រាម) និងបន្តសិក្សាពីរាម-កោះថ្មី ខេត្តព្រះសីហនុ<br>▪ កំពុងសាងសង់កំពង់ចម្លងថ្មី សាងសង់ផ្លូវ និងផ្លូវចាក់បេតុងដែកឡើង-ចុះ ស្ថិតនៅត្រើយខាងលិច ក្នុងក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង និងកំពង់ផែក្រុងស្វាយរៀង | |

| វិធានការគោលនយោបាយ/ផែនការ សកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ គម្រោងលើកកម្រិតផ្លូវជាតិលេខ៤៨ (ស្រែអំបិល-ខេត្តកោះកុង) ប្រវែង ១៥០គ.ម ក្រាលកៅស៊ូ AC បច្ចុប្បន្ន កំពុងជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស។<br>- រដ្ឋបាលខេត្តស្វាយរៀង<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានពង្រឹង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ជាពិសេសនៅខេត្តស្វាយរៀង និងកោះកុង ដែលមានច្រកព្រំដែនអន្តរជាតិ និងខេត្តព្រះសីហនុដែលមានកំពង់ផែសមុទ្រអន្តរជាតិ។ | |
| - បន្តអភិវឌ្ឍផ្លូវដែកនៅកម្ពុជា បន្ទាប់ពីផ្លូវដែកភ្នំពេញ-ខេត្តព្រះសីហនុ បានដាក់ឱ្យដំណើរការ ដើម្បីប្រែក្លាយផ្លូវដែកជាជម្រើសដឹកជញ្ជូនមួយសំខាន់ ដែលចូលរួមចំណែកធ្វើឱ្យថ្លៃដឹកជញ្ជូនធ្លាក់ចុះ និងមានប្រសិទ្ធភាពជាងមុន | មធ្យម ទៅ វែង | - ក្រសួងសាធារណការ និងដឹកជញ្ជូន÷<br>▪ ក. ផ្លូវដែកទិសខាងជើង÷<br>- បានបញ្ចប់ការសាងសង់ជួសជុលផ្លូវដែក និងដាក់ឱ្យដំណើរការដឹកជញ្ជូន ជាបណ្តោះអាសន្ន ពីភ្នំពេញ-ប៉ោយប៉ែត<br>- បានតភ្ជាប់ផ្លូវដែកកម្ពុជា ជាមួយផ្លូវដែកថៃ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីការដឹកជញ្ជូនឆ្លងកាត់ព្រំដែនតាមផ្លូវដែកកម្ពុជា-ថៃ<br>- ជួសជុលកំណាត់ផ្លូវដែកប្រវែង៦,៥គ.ម (ប៉ោយប៉ែតព្រំប្រទល់កម្ពុជា-ថៃ) បានតភ្ជាប់ផ្លូវដែកកម្ពុជា-ថៃ រួចរាល់<br>- បន្ត និងជំរុញអនុវត្តគម្រោងសាងសង់ស្ថានីយរថភ្លើងសំរោង និង គ្រោងសិក្សាការសាងសង់ស្ថានីយរថភ្លើងអន្តរជាតិស្ទឹងបត់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | - ជួសជុលស្ថានីយរថភ្លើងប៉ោយប៉ែតសម្រេចបាន១០០%<br>- គម្រោងបំពាក់ប្រព័ន្ធសុវត្ថិភាពចរាចរណ៍ផ្លូវដែកភាគខាងជើង សម្រេចបាន ១០០%<br>- សិក្សាធ្វើឱ្យប្រសើរឡើងផ្លូវដែកភាគខាងជើង : គម្រោងសាងសង់ផ្លូវដែកថ្មី សិរីសោភណ្ឌ-សៀមរាប<br>- ស្វែងរកការវិនិយោគតភ្ជាប់បណ្តាញផ្លូវដែកកម្ពុជា ជាមួយបណ្តាញផ្លូវដែក ប្រទេសជិតខាង ជាពិសេសបណ្តាញផ្លូវដែកសាំងហ្គាពួរ-គុនមីញ ផ្លូវដែកភ្នំពេញ-សៀមរាប និងភ្នំពេញ-បាវិត។<br>▪ ខ. ផ្លូវដែកទិសខាងត្បូង÷<br>- រាជធានីភ្នំពេញ-ក្រុងព្រះសីហនុ បានស្តារ និងសាងសង់រួចបច្ចុប្បន្នកំពុងដំណើរការដឹកទំនិញ និងអ្នកដំណើរទេសចរណ៍<br>- ដឹកជញ្ជូនទំនិញ មានចំនួនសរុប ១ ៣៤៧ ២៨១តោន កើនឡើង៧,៨៨% ធៀបនឹង២ឆ្នាំមុន (ឆ្នាំ២០១៥-២០១៦ : ១ ២៤៨ ៨៤១តោន)<br>- ដឹកជញ្ជូនអ្នកដំណើរ មានចំនួនសរុប ១៤៨ ១១៣នាក់ កើនឡើង ៩៥៨,៣២% ធៀបនឹង២ឆ្នាំមុន (ឆ្នាំ២០១៥-២០១៦ : ១៣ ៩៩៥នាក់)<br>- គម្រោងបំពាក់ប្រព័ន្ធសុវត្ថិភាពចរាចរណ៍ផ្លូវឆ្លងកាត់ផ្លូវដែក សម្រេចបាន១០០% | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - គម្រោងជួសជុលស្ពានផ្លូវដែកនិរតីទិស និងគម្រោងជួសជុលពង្រឹងផ្លូវដែកទិសនិរតី សម្រេចបាន១០០%។ | |
| - អភិវឌ្ឍបណ្តាញដឹកជញ្ជូនតាមផ្លូវទន្លេ ដែលមានសក្តានុពលក្នុងការកាត់បន្ថយចំណាយភស្តុភារកម្ម ជាពិសេស សម្រាប់ការដឹកជញ្ជូនកសិផល ដោយកសាងកំពង់ផែតូចៗ ដែលអាចឱ្យនាវាដឹកជញ្ជូនចូលផ្ទុក និងផ្ទេរទំនិញនៅតាមដងទន្លេមេគង្គ ស្របគ្នានឹងការសាងសង់កំពង់ផែថ្មីនៅភ្នំពេញ និងខេត្តព្រះសីហនុ ដែលនឹងសម្រួលដល់ការដឹកជញ្ជូនតាមនាវាក្នុងបរិមាណកាន់តែច្រើន | មធ្យម ទៅ វែង | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>▪ បានសិក្សា និងអនុវត្តគម្រោងដឹកជញ្ជូនទំនិញ និងអ្នកដំណើរតាមកាណូតចាប់ពីស្ពានព្រែកព្នៅ-ភ្នំពេញ-តាខ្មៅ) ១៥ទីតាំងផែចំណត (សំដៅដល់ការកាត់បន្ថយការកកស្ទះចរាចរណ៍ និងការចំណាយរបស់ពលរដ្ឋលើការធ្វើដំណើរ។ គម្រោងនេះក៏បានដាក់ឱ្យដំណើរការកាណូតដឹកអ្នកដំណើរតាមផ្លូវទឹកក្នុងក្រុង ពីឫស្សីកែវ ទៅតាខ្មៅ ចំនួន០៥ស្ថានីយ រួចហើយ។<br>▪ បានពង្រឹងគុណភាពផ្តល់សេវាសាធារណៈលើការចុះបញ្ជីជលយាន ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ការផ្តល់បណ្ណបើកបរ បណ្ណយន្តការី និងលិខិតអនុញ្ញាតធ្វើអាជីវកម្មជលយានយន្ត<br>▪ គ្រប់គ្រងនាវាដែលធ្វើនាវាចរណ៍តាមប្រព័ន្ធទន្លេមេគង្គ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជំរុញអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវទឹក ឱ្យមានការរីកចម្រើន ឆ្លើយតបនឹងសេចក្តីត្រូវការអភិវឌ្ឍប្រទេស និងសេដ្ឋកិច្ចជាតិ<br>▪ អភិវឌ្ឍធនធានមនុស្ស ក្នុងវិស័យដឹកជញ្ជូនផ្លូវទឹក និង គ្រប់គ្រង និងជំរុញការអភិវឌ្ឍយានដ្ឋានជួសជុលនាវា<br>▪ បានជំរុញអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក និងរៀបចំបទដ្ឋានគតិយុត្តពាក់ព័ន្ធ<br>▪ លើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមវិនិយោគលើការដឹកជញ្ជូនផ្លូវទឹក | |

| ទិដ្ឋភាពការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ ជំរុញអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីការដឹកជញ្ជូនផ្លូវទឹក ឆ្នាំ២០០៩<br>▪ បានបញ្ចប់ការងារសាងសង់កំពង់ផែតាស្លាង ក្រុងស្វាយរៀង ខេត្តស្វាយរៀង<br>▪ បានសិក្សា និងសាងសង់កំពង់ផែតូចៗនៅតាមប្រព័ន្ធទន្លេមេគង្គ និងតំបន់សមុទ្រ រួមទាំងការសិក្សា និងស្តារផ្លូវទឹក<br>▪ សហការជាមួយផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍នានា ក្នុងការធានាអភិវឌ្ឍន៍កំពង់ផែប្រកបដោយនិរន្តរភាព រួមនឹងទំនើបកម្មប្រតិបត្តិការកំពង់ផែ ដូចជារៀបចំនឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យកំពង់ផែ (Port EDI)<br>▪ បន្តជំរុញការអភិវឌ្ឍចំណតផែទន្លេបិទUM២ ដើម្បីឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ច និងការនាំចេញផលិតផលកសិកម្មនៅតាមបណ្តាខេត្តទន្លេមេគង្គលើ<br>▪ បន្តជំរុញការសាងសង់ចំណតផែទំនិញចាក់ធារ នៅជិតចំណតផែកុងតឺន័រ LM១៧<br>▪ បន្តការថែទាំផ្លូវនាវាចរណ៍ និងធ្វើការបូមស្តារប្រឡាយនាវាចរណ៍ដែលស្ថិតនៅក្នុងដែនអាជីវកម្មរបស់កំពង់ផែស្វយ័តភ្នំពេញដើម្បីបង្កើនសមត្ថភាព និងសុវត្ថិភាពនៃការដឹកជញ្ជូន។ | |
| - ដោះស្រាយបញ្ហាកកស្ទះចរាចរណ៍នៅរាជធានីភ្នំពេញ ដែលធ្វើឱ្យចំណាយភស្តុភារកម្មកើនឡើងជាប្រចាំ ពិសេស ការកសាងផ្លូវក្រវាត់ក្រុង | ២០១៩ ទៅ មធ្យម | - ក្រសួងសាធារណការ និងដឹកជញ្ជូន៖<br>▪ គម្រោងសាងសង់ផ្លូវក្រវាត់ក្រុងខ្សែទី២ប្រវែង១៦,៦៨គ.ម (មហាវិថីសហព័ន្ធរុស្សី-ព្រែកហូរ) កំពុងសាងសង់ | |

| វិធានការគោលនយោបាយ/ផែនការ សកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| ឬផ្លូវវៀងក្រៅក្រុង ដើម្បីធានាឱ្យចរាចរប្រព្រឹត្តទៅដោយរលូន | | ▪ គម្រោងសាងសង់ផ្លូវក្រវ៉ាត់ក្រុងខ្សែទី៣ ប្រវែង ៤៥.៦១គ.ម(ផ្លូវជាតិលេខ៥-អូឌឹម-ផ្លូវជាតិលេខ១) បច្ចុប្បន្ន កំពុងដំណើរការសាងសង់។<br>- រដ្ឋបាលរាជធានីភ្នំពេញ÷<br>▪ សម្រាប់ឆ្នាំ២០១៧ បានស្ថាបនាកំណាត់ផ្លូវលេខ១០១៩ (ផ្លូវក្រវ៉ាត់ក្រុងទី២) ចាប់ពីទំនប់កប់ស្រូវដល់មហាវិថី សហព័ន្ធរុស្ស៊ី ប្រវែង ១០.១២០ម តម្លើងបង្គោលភ្លើង តម្លើងស្លាកសញ្ញាចរាចរ និងគូសគំនូសចរាចរ (២០១៥-២០១៧)<br>▪ បានស្ថាបនាពង្រីកផ្លូវទំនប់កប់ស្រូវ (ផ្លូវក្រវ៉ាត់ក្រុងទី៣) ពីផ្លូវជាតិលេខ៥ ដល់ផ្លូវជាតិលេខ៤ ប្រវែង ១៧.២៥០ម តម្លើងបង្គោលភ្លើង តម្លើងស្លាកសញ្ញាចរាចរ និងគូសគំនូសចរាចរ (២០១៥-២០១៨)<br>▪ បានស្ថាបនាពង្រីកផ្លូវកំណាត់ផ្លូវជាតិលេខ៤ ចាប់ពីរង្វង់មូលចោមចៅ ដល់ផ្លូវទំនប់កប់ស្រូវ ប្រវែង ១.៧៥០ម តម្លើងបង្គោលភ្លើង តម្លើងស្លាកសញ្ញាចរាចរ និងគូសគំនូសចរាចរ (២០១៦-២០១៨)<br>▪ ស្ថាបនាផ្លូវលេខ ២១៧ (ផ្លូវជើងឯក) ចាប់ពីស្ពានអាកាសស្ទឹងមានជ័យ ដល់ផ្លូវជាតិលេខ២ ប្រវែង ១២,៣២០ម ដោយស្ថាបនាជាផ្លូវបេតុងទំហំ ៩.៧៥ម ភ្លោះ តម្លើងសួនកណ្តាល តម្លើងបង្គោលភ្លើង តម្លើងស្លាកសញ្ញាចរាចរ និងគូសគំនូសចរាចរ (២០១៥-២០១៨)<br>▪ បានតម្លើងបង្គោលភ្លើង តម្លើងស្លាកសញ្ញាចរាចរ និងគូសគំនូសចរាចរលើ កំណាត់ផ្លូវជាតិលេខ២ ចាប់ពីស្ពានអាកាសក្បាលថ្នល់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ដល់រូបសំណាក់ព្រះនរាយណ៍ បន្ទាប់ពីបានជួសជុលគ្រឹះ និងចាក់អ៊ុតកៅស៊ូប្រវែង ៤.៣៥០ម កាលពីឆ្នាំ២០១៦<br>▪ ស្ថាបនាពង្រីកកំណាត់ផ្លូវជាតិលេខ៥ ចាប់ពីមុខឃ្លាំងស្តុកប្រេងឥន្ធនៈសូគីម៉ិច ដល់ស្ពានព្រែកព្នៅ ប្រវែង ៨.៧៥០ម តម្លើងបង្គោលភ្លើង តម្លើងស្លាកសញ្ញាចរាចរ និងគូសគំនូសចរាចរ (២០១៥-២០១៩)<br>▪ ស្ថាបនាផ្លូវបេតុងឆ្អឹងដែក ផ្លូវប្រទះឡាង ទទឹង ៧ម ប្រវែង ១២.៦២០ម ចាប់ពីផ្លូវជាតិលេខ ៤ ដល់ផ្លូវជាតិលេខ៣ (២០១៧)<br>▪ ស្ថាបនាស្ពានបេតុង ឡុង ឈិន ទទឹង ២០.៧ម ប្រវែង ៥៤ម (២០១៧)<br>▪ សាងសង់ស្ថានីយបូមទឹកទួលគោកទី១ ស្ថានីយបូមទឹកទួលគោកទី២ ស្ថានីយបូមទឹកព្រះពន្លា ស្ថានីយបូមទឹកបុរី១០០ខ្នង ស្ថានីយបូមទឹកល្វេប្រាំ និងស្ថានីយបូមទឹកបឹងត្របែក (២០១៦-២០១៨)<br>▪ កែលំអសួនច្បារវិមានឯករាជ្យ សួនមុខវត្តលង្ការ សួនមុខវត្តបទុមវតី សួនមុខព្រះបរមរាជវាំង សួនមុខផ្សាររាត្រី សួនវត្តភ្នំ សួនសាន់វេ សួនមុខស្ថានទូតបារាំង សួនរង្វង់មូលគួចកាណុង សួនរង្វង់មូលព្រហ្មបាយ័ន្ត សួនសម្តេច ហ៊ុន សែន សួនមុខព្រះសត្យមុនីចេតិយ៍ និងសួនចេនឡា (២០១៦-២០១៨)<br>▪ ត្រឹមខែធ្នូ ឆ្នាំ២០១៨ បានសាងសង់ហេដ្ឋារចនាសម្ព័ន្ធ សម្រាប់តភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និងការអភិវឌ្ឍន៍ ច្រករបៀងសេដ្ឋ-កិច្ច ភ្នំពេញ-ព្រះសីហនុ, ភ្នំពេញ-បាវិត និងភ្នំពេញ ប៉ោយប៉ែត ជាច្រើនដូចខាងក្រោម÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ○ ស្ថាបនាពង្រីកផ្លូវកំណាត់ផ្លូវជាតិលេខ១ ពី២គន្លងទៅ៤គន្លង ទិសដៅទៅមក ចាប់ពីស្ពានព្រះមុនីវង្ស ដល់ក្តីតាកុយ ប្រវែង ៤,០០០ម៉ែត្រ តម្លើងបង្គោលភ្លើងបំភ្លឺផ្លូវ តម្លើងភ្លើងសញ្ញាចរាចរ តម្លើងស្លាកសញ្ញាចរាចរ និងគូសគំនូសចរាចរ (២០១៧)<br>○ ជួសជុលគ្រឹះ និងចាក់អ៊ុតកៅស៊ូ កំណាត់ផ្លូវជាតិលេខ២ ចាប់ពីស្ពានអាកាសក្បាលថ្នល់ ដល់រូបសំណាក ព្រះនារាយណ៍ ប្រវែង ៤,៣៥០ម៉ែត្រ តម្លើងបង្គោលភ្លើងបំភ្លឺផ្លូវ តម្លើងស្លាកសញ្ញាចរាចរ និងគូសគំនូសចរាចរ (២០១៥-២០១៨)<br>○ ស្ថាបនាពង្រីកផ្លូវកំណាត់ផ្លូវជាតិលេខ៤ ចាប់ពីរង្វង់មូលចោមចៅ ដល់ផ្លូវទិនប់កប់ស្រូវ ប្រវែង១,៧៥០ម៉ែត្រ តម្លើងបង្គោលភ្លើងបំភ្លឺផ្លូវ តម្លើងស្លាកសញ្ញាចរាចរ និងគូសគំនូសចរាចរ(២០១៦-២០១៨)<br>○ ស្ថាបនាពង្រីកកំណាត់ផ្លូវជាតិលេខ៥ ពី២គន្លងទៅ៤គន្លង ទិសដៅទៅមក ចាប់ពីមុខឃ្លាំងស្តុកប្រេងឥន្ធនៈសូគីម៉ិច ដល់ព្រែកព្នៅប្រវែង ៥,៣៨០ម៉ែត្រ តម្លើងបង្គោលភ្លើងបំភ្លឺផ្លូវ តម្លើងស្លាកសញ្ញាចរាចរ និងគូសគំនូសចរាចរ (២០១៥-២០១៨)<br>○ ស្ថាបនាពង្រីកកំណាត់ផ្លូវជាតិលេខ៦ ពី២គន្លងទៅ៤គន្លង ទិសដៅទៅមក ចាប់ពីស្ពានមិត្តភាពកម្ពុជា-ជប៉ុន ដល់រដ្ឋបាលខណ្ឌជ្រោយចង្វារ ប្រវែង ៤,០០០ម៉ែត្រ តម្លើងបង្គោលភ្លើងបំភ្លឺផ្លូវ តម្លើងស្លាកសញ្ញាចរាចរ និងគូសគំនូសចរាចរ (២០១៥-២០១៨) | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ○ ស្ថាបនាពង្រីកមហាវិថីឈ្នះឈ្នះ (ផ្លូវក្រវាត់ក្រុងទី៣) ពី២គន្លងទៅ៤គន្លង ទិសដៅទៅមក ចាប់ពីផ្លូវជាតិលេខ៥ ដល់ផ្លូវជាតិលេខ៤ ប្រវែង ១៧,២៥០ម៉ែត្រ តម្លើងបង្គោលភ្លើងបំភ្លឺផ្លូវ តម្លើងស្លាកសញ្ញាចរាចរ និងគូសគំនូសចរាចរ (២០១៥-២០១៨)<br>○ កំពុងស្ថាបនាស្ពានអាកាស និងផ្លូវក្រោមដី រង្វង់មូលចោមចៅ ដែលមានស្ពានចំនួន៤ និងផ្លូវក្រោមដីចំនួន១, ស្ពានមេមានទទឹង ១៥ម៉ែត្រ បណ្តោយ៣៨២ម៉ែត្រ<br>○ កំពុងស្ថាបនាបន្ថែមស្ពានអាកាសក្បាលថ្នល់ តពីគម្រោងជំហានទី១ ដែលត្រូវសាងសង់ស្ពានខ្សែងបន្ថែមចំនួន៣ និងផ្លូវក្រោមដីចំនួន១, ស្ពានទី១ មានទទឹង៧ម៉ែត្រ បណ្តោយ២៤០ម៉ែត្រ, ស្ពានទី២ មានទទឹង៦,១៥ម៉ែត្រ បណ្តោយ១៩០ម៉ែត្រ, ស្ពានទី៣ មានទទឹង៧ម៉ែត្រ បណ្តោយ៣៨០ម៉ែត្រ។ | |
| - ពិនិត្យលទ្ធភាពនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងវិស័យឯកជន សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលអាចបន្ធូរបន្ទុកវិនិយោគសាធារណជន។ | ២០១៥ មធ្យម វែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានជំរុញការអនុវត្តឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគ សាធារណៈ ២០១៦-២០២០។ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ សមត្ថភាពធនធានមនុស្ស និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត។ |
| *ឃ-វិធានការផ្នែកហិរញ្ញប្បទាន* | | | |
| - បន្តអនុវត្ត *"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០"* ដែលជាក្របខ័ណ្ឌរួមនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា | មធ្យម ទៅ វែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបន្តសហការជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីកែសម្រួលលើខ្លឹមសារជាភាសាអង់គ្លេសនៃឯកសារ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥" ដោយផ្អែកលើខ្លឹមសារជាភាសាខ្មែរ ដែលបានអនុម័តរួចហើយ។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងថវិកា | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - ធនាគារជាតិនៃកម្ពុជា÷<br>១. ការរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច÷<br>▪ អតិផរណា÷ អត្រាអតិរណាត្រូវបានរក្សាឱ្យស្ថិតក្នុងកម្រិតទាបស្របតាមក្របខណ្ឌគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល និងបានអំណោយផលដល់ការលើកស្ទួយសកម្មភាពផលិតកម្មនិងពាណិជ្ជកម្ម ព្រមទាំងបានរួមចំណែកដ៏សំខាន់ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ជាក់ស្តែង នៅឆ្នាំ២០១៧ កន្លងទៅនេះ អត្រាអតិផរណាមានកម្រិតត្រឹម ២,៩% ប្រហាក់ប្រហែលនឹងឆ្នាំ២០១៦ (៣%) និងបានបន្តថមថយបន្តិចទៀតក្នុងឆ្នាំ២០១៨ ដល់កម្រិត ២,៥%។<br>▪ អត្រាប្តូរប្រាក់÷ ដូចគ្នានេះដែរ តម្លៃប្រាក់រៀលត្រូវបានរក្សាឱ្យមានស្ថិរភាពល្អប្រសើរ ដោយអត្រាប្តូរប្រាក់ធៀបនឹងប្រាក់ដុល្លារអាមេរិកមានកម្រិតជាមធ្យមត្រឹម ៤.០៨១ រៀល ក្នុងមួយទសវត្សរ៍ចុងក្រោយ ហើយនៅឆ្នាំ២០១៦នេះ មានកម្រិតជាមធ្យម ៤.០៥១ រៀលក្នុងមួយដុល្លារអាមេរិក ខណៈនៅឆ្នាំ២០១៧ និងឆ្នាំ២០១៨ ប្រាក់រៀលបានឡើងថ្លៃបន្តិចទៀត ក្នុងអត្រា ៤.០៥០ រៀលក្នុងមួយដុល្លារអាមេរិក។ ស្ថិរភាពអត្រាប្តូរប្រាក់ បានលើកទឹកចិត្តនិងជំរុញឱ្យមានការប្រើប្រាស់ប្រាក់រៀល ដោយបានឆ្លុះបញ្ចាំងតាមរយៈកំណើនប្រាក់រៀលក្នុងចរាចរណ៍ និងប្រាក់បញ្ញើជារៀល ជាមួយនឹងកំណើន ១៤% និង៩% រៀងគ្នា ក្នុងឆ្នាំ២០១៨។<br>▪ ការគរពូនទុនបម្រុងអន្តរជាតិ÷ ការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បានផ្តល់នូវបរិយាកាសអំណោយផលសម្រាប់ការវិនិយោគផ្ទាល់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | បរទេស ការពង្រីកអាជីវកម្មក្នុងស្រុក និងពាណិជ្ជកម្មឆ្លងដែនជាដើម។ ក្នុងបរិការណ៍នេះ កម្ពុជាអាចរក្សាបាននូវកំណើនអតិរេកនៃសមតុល្យជញ្ជីងទូទាត់ជាបន្តបន្ទាប់ និងបានគរពូនទុនបម្រុងអន្តរជាតិជាលំដាប់។ ជាលទ្ធផល ឆ្នាំ២០១៧ ជញ្ជីងទូទាត់កម្ពុជាមានអតិរេកប្រមាណ ១,៦ ប៊ីលានដុល្លារអាមេរិក និង ១,១ ប៊ីលានដុល្លារអាមេរិក ដែលបានរួមចំណែកគរពូនទុនបម្រុងអន្តរជាតិដុលដល់ ៨,៧ ប៊ីលានដុល្លារអាមេរិក និង ១០ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ រៀងគ្នា ដែលអាចរក្សាបានកម្រិតខ្ពស់នៃទូទាត់ ការនាំចូលទំនិញនិងសេវា ក្នុងកម្រិតប្រមាណ ៥ខែ។ គួររំលេចថា ការគ្រប់គ្រងនិងគរពូនទុនបម្រុងអន្តរជាតិ ជាការងារអាទិភាពមួយដើម្បីពង្រឹងរបបអត្រាប្តូរប្រាក់ រក្សាស្ថិរភាពហិរញ្ញវត្ថុ និងបង្កើនជំនឿទុកចិត្តរបស់ប្រទេស។<br>២. ការរីកចម្រើននៃវិស័យធនាគារ៖<br>▪ ស្ថិរភាពនយោបាយ ការរីកចម្រើនគ្រប់ផ្នែកនៃវិស័យសេដ្ឋកិច្ច និងភាពរឹងមាំនៃប្រព័ន្ធធនាគារ គឺជាកម្លាំងចលករយ៉ាងសំខាន់ក្នុងការពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារនៅកម្ពុជា។ វិស័យធនាគារបានដើរតួនាទីយ៉ាងសំខាន់ ជាអន្តរការីហិរញ្ញវត្ថុក្នុងការកេណ្ឌប្រមូលធនធានហិរញ្ញវត្ថុសម្រាប់បំពេញតម្រូវការវិនិយោគ និងគាំទ្រដល់ការរីកចម្រើននៃសេដ្ឋកិច្ច។ កម្ពុជាមានធនាគារពាណិជ្ជ ចំនួន ៣៩ និងបានកើនដល់ ៤៣ ក្នុងឆ្នាំ២០១៨ ខណៈធនាគារឯកទេស មានចំនួន ១៤ ហើយសាខារបស់គ្រឹះស្ថានធនាគារបានកើនពី ៨៥៦ សាខា ក្នុងឆ្នាំ២០១៧ ដល់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ៨៧៧ សាខា និងម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិបានកើនពី ១.៤៩០ ម៉ាស៊ីន ក្នុង២០១៧ ដល់ ១.៨៣២ ម៉ាស៊ីន ក្នុងឆ្នាំ ២០១៨។ ការរីកលូតលាស់នៃបណ្តាញសាខារបស់គ្រឹះស្ថានធនាគារ បានផ្តល់ដល់ប្រជាពលរដ្ឋកម្ពុជា ក្នុងការទទួលនិងប្រើប្រាស់សេវាហិរញ្ញវត្ថុកាន់តែមានភាពងាយស្រួល ដែលជំរុញដល់សកម្មភាពសេដ្ឋកិច្ច និងបរិយាប័ន្ន។ កំណើនឥណទាន កើនដល់ ៧០ ទ្រីលានរៀល (កើន ១៨,៥%) ក្នុងឆ្នាំ២០១៧ និងបានកើនដល់ ៧៩,៥ ទ្រីលានរៀល(កើន១៤%) ក្នុងឆ្នាំ២០១៨ ដោយបានដើរតួនាទីយ៉ាងសកម្មក្នុងការជំរុញការពង្រីកអាជីវកម្ម និងការប្រើប្រាស់ក្នុងស្រុក។ កំណើនឥណទានត្រូវបានបែងចែកទៅកាន់វិស័យសំខាន់ៗនៃសេដ្ឋកិច្ច ក្នុងនោះវិស័យពាណិជ្ជកម្ម ២៨% សំណង់និងអចលនទ្រព្យ ២៦% កសិកម្ម ៩% ជាពិសេសវិស័យកម្មន្តសាលដែលជាវិស័យអាទិភាពសម្រាប់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា បានស្រូបយកប្រមាណ ៦% នៃសំពៀតឥណទានសរុប។ ក្នុងស្ថានភាពដែលវិស័យធនាគារមានការរីកចម្រើន ការប្រកួតប្រជែង និងសុខភាពល្អនៃប្រព័ន្ធធនាគារ បានបន្តជំរុញនិងរួមចំណែកបន្ទាបអត្រាការប្រាក់។ អត្រាការប្រាក់ជារៀលបានថយចុះពី ១៤,៩% ក្នុងឆ្នាំ២០១៧ មក ១៤,៨% ជាមធ្យម ក្នុងឆ្នាំ២០១៨ និងអត្រាការប្រាក់ជាដុល្លារអាមេរិកបានថយពី ១១,៧% មក ១១% ជាមធ្យម ក្នុងឆ្នាំ២០១៨។ ”<br>៣. វឌ្ឍនភាពនៃវិស័យមីក្រូហិរញ្ញវត្ថុ÷ | |

| ទិសដៅការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ប្រកបដោយ និរន្តភាពទាំងវិសាលភាព ទំហំប្រតិបត្តិការ និងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការជួយជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា តាមរយៈការផ្តល់ឥណទានខ្នាតតូច និងមធ្យម។ នៅកម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៧៦ គ្រឹះស្ថាន ក្នុងឆ្នាំ២០១៧ និងបានកើន ដល់ ៧៩ គ្រឹះស្ថាន ក្នុងឆ្នាំ ២០១៨ ដែលក្នុងនោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមាន ចំនួន ៧។ ទំហំឥណទានក្នុងវិស័យនេះ កើនដល់ ១៧,៥ ទ្រីលានរៀល ក្នុងឆ្នាំ២០១៧ និងកើនដល់ ២១,៨ ទ្រីលានរៀល ក្នុងឆ្នាំ២០១៨ ដោយបានបែងចែកទៅតាមវិស័យផ្សេងៗរួមមាន គ្រួសារ ៣៦% វិស័យកសិកម្ម ២២% ពាណិជ្ជកម្ម ១៨% សេវាកម្ម ១១% ដឹកជញ្ជូន ៥% សំណង់ ៤% និងវិស័យផ្សេងៗ ៤%។ ដោយមានការជំរុញនិងលើកទឹកចិត្តពីធនាគារជាតិនៃកម្ពុជា ជាមួយនឹងបរិយាកាសប្រកួតប្រជែងខ្ពស់ អត្រាការប្រាក់ឥណទានប្រចាំឆ្នាំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានថយចុះពី ១៩,៧% ជាមធ្យម ក្នុងឆ្នាំ២០១៧ មក ១៧,៦% ក្នុងឆ្នាំ២០១៨។<br>៤. ការអភិវឌ្ឍប្រព័ន្ធទូទាត់៖<br>▪ ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ជាពិសេស ប្រព័ន្ធទូទាត់ មានតួនាទីដ៏សំខាន់ដើម្បីសម្រួលដល់សកម្មភាពពាណិជ្ជកម្ម និងតម្រូវការមូលនិធិទាន់ពេលវេលា សំដៅគាំទ្រដល់ការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ច។ ក្នុងន័យនេះ ក្រៅពីជំរុញគ្រឹះស្ថានជាសមាជិកឱ្យបន្តអភិវឌ្ឍបណ្តាញផ្តល់សេវារហ័ស តាមរយៈប្រតិបត្តិការធនាគារ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ចល័ត ប្រតិបត្តិការអនឡាញ និងឧបករណ៍ទូទាត់ផ្សេងៗទៀត ធនាគារជាតិនៃកម្ពុជា បាននិងកំពុងធ្វើទំនើបកម្មនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូទាត់ឱ្យកាន់តែប្រសើរឡើង ដូចជា ការដាក់ឱ្យដំណើរការបឋមប្រព័ន្ធ Cambodia Shared Switch (CSS) ដែលជាប្រព័ន្ធរួមមួយអនុញ្ញាតឱ្យអតិថិជនធ្វើប្រតិបត្តិការអន្តរធនាគារតាមរយៈបណ្ណឥណពន្ធ តាមម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM) និងទូទាត់ថ្លៃទំនិញតាមម៉ាស៊ីន POS, កំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដុលភ្លាមៗ (RTGS) ដើម្បីសម្រួលដល់ការទូទាត់តម្លៃធំ ជាពិសេសការទូទាត់ក្នុងទីផ្សារហិរញ្ញវត្ថុ, ការដាក់ចេញនូវមូលប្បទានបត្រស្តង់ដារ, ការបញ្ចាផ្ទេរឥណទានអេឡិចត្រូនិចសម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធធនគារ និងកំពុងសិក្សាពីលទ្ធភាពក្នុងការអនុវត្តស្តង់ដារ CHIP សម្រាប់បណ្ណទូទាត់ និងស្តង់ដារ QR Code សម្រាប់ការទូទាត់តាម QR Code នៅកម្ពុជា។ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បានកើនឡើងពីចំនួន ១១ គ្រឹះស្ថាន ក្នុងឆ្នាំ២០១៧ ដល់ ២០ គ្រឹះស្ថាន ក្នុងឆ្នាំ២០១៨។ | |
| - សិក្សា និងរៀបចំឱ្យមានយន្តការហិរញ្ញវត្ថុសមស្របសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ពិសេស ការផ្តល់កម្ចីដល់សហគ្រាសធុនតូច និងមធ្យម ព្រមទាំងជំរុញការផ្តល់ហិរញ្ញប្បទានដល់ឧស្សាហកម្មអាទិភាព | ២០១៩ ទៅ មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានរៀបចំប្រកាសស្តីពីគោលការណ៍ និងនីតិវិធី គ្រប់គ្រងការផ្តល់ឥណទានដល់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ នីតិបុគ្គលសាធារណៈដទៃទៀត និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ<br>▪ បានរៀបចំប្រជុំអន្តរក្រសួងលើកចុងក្រោយក្នុងការស្នើសុំឱ្យមានរយៈពេលកំណត់យ៉ាងយូរបំផុត ០២សប្តាហ៍ សម្រាប់យន្តការ "ចាត់ចែងរក្សាការពារ" នៅក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពី | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷<br>▪ គម្រោងធានាឥណទានជាផលិតផលថ្មីមួយដែលទាមទារការប្រជុំផ្សព្វផ្សាយសិក្ខាសាលាច្រើន និង គោលនយោបាយច្បាស់លាស់<br>▪ ត្រូវការជំនាញការដែលមានចំណេះដឹង និងបទពិសោធន៍ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ប្រតិបត្តិការដែលមានកិច្ចធានា។ ជាលទ្ធផល បានរៀបចំលិខិតផ្លូវការ ទៅក្រសួងយុត្តិធម៌ ដើម្បីសហការក្នុងការពន្លឿននីតិវិធីតុលាការឱ្យចេញដីកាសម្រេចរក្សាការពារ ក្នុងរយៈពេល ០២សប្ដាហ៍ នៅក្នុងវិស័យភតិសន្យាហិរញ្ញវត្ថុ<br>▪ បានចូលរួមប្រជុំចំនួន ៤លើក ដើម្បីពិនិត្យ និងពិភាក្សា លើសេចក្ដីព្រាងវិសោធនកម្មច្បាប់ស្ដីពីប្រតិបត្តិការដែល មានកិច្ចធានាជាមួយក្រសួងពាណិជ្ជកម្ម, ធនាគារជាតិនៃកម្ពុជា និងក្រសួងយុត្តិធម៌ នៅក្រសួងពាណិជ្ជកម្ម<br>▪ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ភាពប្រទាក់ ក្រឡាលើការអនុវត្តអាជីវកម្មទទួលបញ្ញើ និងទទួល ប្រតិភោគដោយអនុប្បទាន, ប្រតិបត្តិការដែលមាន កិច្ចធានា និង ភតិសន្យាហិរញ្ញវត្ថុ"<br>▪ បានសម្របសម្រួលដឹកនាំកិច្ចប្រជុំចំនួន ៤លើក ដើម្បី ដោះស្រាយកង្វល់របស់វិស័យឯកជន ពាក់ព័ន្ធទៅនឹងបញ្ហាប្រឈមលើការអនុវត្តរបស់ការិយាល័យតម្កល់ប្រតិបត្តិការដែលមានកិច្ចធានាជាមួយក្រសួងពាណិជ្ជកម្ម និងវិស័យឯកជន<br>▪ រៀបចំសេចក្ដីព្រាងប្រកាសស្ដីពីការធានារបស់រដ្ឋ ដែលនឹង (១) ផ្ដល់ការធានាដល់សហគ្រាសរបស់រដ្ឋក្នុងការទទួលឥណទាន (២) ផ្ដល់ការធានាដល់គម្រោង ដែលមានយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន<br>▪ ចូលរួមតាមដានវឌ្ឍនភាពនៃការកែទម្រង់ និងការកសាងសមត្ថភាពរបស់ធនាគារអភិវឌ្ឍន៍ជនបទ | ▪ ទាមទារសិក្សាឱ្យបានលម្អិតបន្ថែមទៀត។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានរៀបចំប្រជុំគណៈកម្មការឥណទាននៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍វិស័យកសិកម្មចំនួន៨លើក ដើម្បីពិនិត្យនិងវាយតម្លៃលើការស្នើសុំឥណទានថ្មី និងពន្យាពេលសងប្រាក់ជាដើមរបស់អតិថិជននៃវិស័យស្រូវអង្ករ<br>▪ បានបង្កើតក្រុមការងារកម្រិតនាយកដ្ឋាន និងអគ្គនាយកដ្ឋាន ដើម្បីសិក្សាស្រាវជ្រាវ, រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការអនុវត្តគម្រោងធានាឥណទានសម្រាប់គាំទ្រវិស័យស្រូវ-អង្ករនៅកម្ពុជា<br>▪ បានកែសម្រួលលទ្ធផលរបស់ជំនាញការនៃធនាគារអភិវឌ្ឍន៍អាស៊ី និង រៀបចំឯកសារពាក់ព័ន្ធនឹងគម្រោងធានាឥណទាន ១) ឯកសារប្រតិបត្តិគម្រោងធានាឥណទាន ២) កិច្ចព្រមព្រៀងគម្រោងធានាឥណទានរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និង ៣) ឧបករណ៍ក្នុងការអនុវត្តគម្រោង (Tools) ដោយមានការសម្របសម្រួលពីជំនាញការ AFD<br>▪ បានរៀបចំរបាយការណ៍លើការពិនិត្យ និងសិក្សាលើកិច្ចព្រមព្រៀងធានាឥណទានដោយផ្នែក (Partial Credit Guarantee Facility Agreement) ក្នុងការបង្កើតគម្រោងធានាឥណទានសម្រាប់វិស័យស្រូវ-អង្ករ<br>▪ បានរៀបចំសិក្ខាសាលាចែករំលែកស្តីពី“បទពិសោធន៍គម្រោងធានាឥណទាននៅប្រទេសជប៉ុន”<br>▪ បានប្រជុំជាមួយ JICA និងភាគីតៃវ៉ាន់ដើម្បីសុំជំនួយបច្ចេកទេសត្រៀមបង្កើតគម្រោងធានាឥណទាន | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ សម្រេចបានឯកសារគោលនយោបាយ និងឯកសារកិច្ចព្រមព្រៀងគំរូ និងនីតិវិធីសម្រាប់បង្កើតគម្រោងធានាឥណទានសម្រាប់វិស័យស្រូវ-អង្ករ<br>▪ ឯកសារទស្សនទាន និងរបាយការណ៍ស្តីពីការបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជាត្រូវបានឯកភាពពីសម្តេចតេជោនាយករដ្ឋមន្ត្រី<br>▪ ប្រកាសស្តីពីការបង្កើតក្រុមការងារដើម្បីរៀបចំគម្រោងបង្កើត "ធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា" ត្រូវបានអនុម័ត<br>▪ បានរៀបចំសេក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា។<br>- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷<br>▪ កំពុងជ្រើសរើសធនាគារដែលមានភាពអនុគ្រោះបំផុត និងការលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យម ដើម្បីធ្វើជាដៃគូក្នុងការជំរុញកិច្ចអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម ព្រមទាំងរៀបចំសិក្ខាសាលា ដើម្បីផ្តល់ឱកាសឱ្យធនាគារដែលបានជ្រើសរើសទាំងអស់ធ្វើការបង្ហាញផលិតផលរបស់ខ្លួន និងរៀបចំបណ្តុះបណ្តាលស្តីពីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់បណ្តុះបណ្តាលដល់សហគ្រាសធុនតូចនិងមធ្យមទាំងឡាយណាដែលមានបំណងចង់ទទួលយកកម្ចីពីធនាគារសាមី<br>▪ បានអញ្ជើញធនាគារចំនួន២៨មូលដ្ឋាន ដើម្បីពិភាក្សាអំពីការផ្តល់កម្ចីអនុគ្រោះបំផុត និងលើកទឹកចិត្តដល់ការបង្កើតសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា។ រហូតមកដល់ពេលនេះ ក្រុមការងារ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | របស់អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម បាននិងកំពុងសរុបលទ្ធផលដែលបានពិភាក្សាកន្លងមក នឹងដាក់ជូនថ្នាក់ដឹកនាំសម្រេច ជ្រើសរើសយកធនាគារអនុគ្រោះបំផុត និងមានការលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម។ | |
| - កែលម្អប្រសិទ្ធភាព និងអភិបាលកិច្ចប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពិសេស ការវិភាជ និង ការរៀបចំកម្មវិធីវិនិយោគសាធារណៈ សម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម | ២០១៥<br>មធ្យម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ បានសហការជាមួយធនាគារពិភពលោកក្នុងការសិក្សាអំពីការត្រួតពិនិត្យឡើងវិញលើការចំណាយសាធារណៈលើវិស័យអាទិភាព ដូចជា÷ កសិកម្ម ធារាសាស្ត្រ ការអប់រំ និងការលើកទឹកចិត្តផ្នែកសារពើពន្ធ។ ការសិក្សានេះត្រូវបានធ្វើឡើងដើម្បីត្រួតពិនិត្យប្រសិទ្ធភាពចំណាយ ទាំងក្នុងកម្រិតវិភាជ និងការប្រតិបត្តិ។<br>▪ បានចូលរួមក្នុងដំណើរការពិនិត្យឡើងវិញលើចំណាយ សារធារណៈលើវិស័យអាទិភាព÷ អប់រំ កសិកម្ម និងការលើកទឹកចិត្តសារពើពន្ធតាមរយៈ÷<br>- ការចូលរួមក្នុងការប្រមូលទិន្នន័យដែលពាក់ព័ន្ធនឹងចំណាយសាធារណៈលើវិស័យសំខាន់ៗដែលត្រូវបានសិក្សា<br>- ជួយសម្របសម្រួលធនាគារពិភពលោកឱ្យមានការប្រជុំប្រឹក្សាយោបល់ជាមួយស្ថាប័នដែលពាក់ព័ន្ធ ជាពិសេសក្រសួងសាមីដែលជាអ្នកអនុវត្តផ្ទាល់<br>- ចូលរួមក្នុងការវិភាគ និងផ្តល់យោបល់លើរបាយការណ៍បឋមដោយជំនាញការធនាគារពិភពលោក។<br>▪ បាននិងកំពុងចូលរួមរៀបចំសេចក្តីព្រាងក្របខ័ណ្ឌវិនិយោគសាធារណៈ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ការប្រើប្រាស់លទ្ធផលនៃការសិក្សានេះហាក់មិនទាន់បានទូលំទូលាយពោលគឺក្រសួងសាមីនៅតែបន្តរៀបចំថវិការបស់ខ្លួនដែលផ្អែកលើសកម្មភាព និងអាទិភាពដែលខ្លួនធ្លាប់ធ្វើកន្លងមក ដោយពុំបានធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន។ |

| វិធានការគោលនយោបាយ/ផែនការ សកម្មភាព | រយៈពេល/ ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានចូលរួមរៀបចំសេចក្តីព្រាងអនុក្រឹត្យគោលសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីគ្រប់ប្រភេទ<br>▪ បានចូលរួមពិនិត្យឡើងវិញនូវក្របខ័ណ្ឌចំណាយសាធារណៈ។<br>- ក្រសួងផែនការ បាននិងកំពុងបន្តណែនាំដល់គ្រប់បណ្តាក្រសួង ស្ថាប័ន ឱ្យចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ តាមរយៈការស្នើគម្រោងសម្រាប់ដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០២០-២០២២ ដែលសេចក្តីព្រាង ក.វ.ស នេះនឹងត្រូវអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងពេលឆាប់ៗនេះ។ | |
| - ពង្រឹងទីផ្សារមូលបត្រ ដើម្បីកៀរគរប្រភព ហិរញ្ញ-វត្ថុ និងប្រើប្រាស់វាឱ្យមានប្រសិទ្ធភាព ជាពិសេសពិចារណាលើលទ្ធភាពបង្កើតមូលបត្ររតនាគារ ដើម្បីធ្វើហិរញ្ញប្បទានគម្រោងអភិវឌ្ឍន៍ដែលគាំទ្រដល់ការបង្កើតមូលដ្ឋានឧស្សាហកម្ម | មធ្យម ទៅ វែង | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>▪ សម្រេចបានការរៀបចំប្រជុំសេចក្តីព្រាងអនុក្រឹត្យស្តីពី “ការគ្រប់គ្រង និងការបោះផ្សាយមូលបត្ររដ្ឋ” កម្រិតអន្តរស្ថាប័ន។<br>▪ បានកំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពី “ប្រតិបត្តិការមូលបត្ររដ្ឋ កម្រិតបច្ចេកទេស”<br>▪ បានរៀបចំសេចក្តីព្រាងប្រកាសស្តីពី “ការគ្រប់គ្រងនិងការបោះផ្សាយមូលបត្ររដ្ឋ” កម្រិតបច្ចេកទេស<br>▪ បានកំពុងរៀបចំសេចក្តីព្រាងស្តីពីឯកសារយុទ្ធសាស្ត្រនៃការអភិវឌ្ឍទីផ្សារមូលបត្រ នៅកម្ពុជាកម្រិតបច្ចេកទេស។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷<br>▪ សមត្ថភាពមន្ត្រីជំនាញនៅមានកម្រិតត្រូវការជំនួយបច្ចេកទេសបន្ថែម<br>▪ បញ្ហាធនធានថវិកាគាំទ្រដល់ការបណ្តុះបណ្តាលដោយសារភាពស្មុគ្រស្មាញនៃស្តង់ដារ នាំឱ្យគ្រូបង្ហាត់ទាមទារកម្រៃខ្ពស់<br>▪ ការយល់ដឹងរបស់មន្ត្រី និងអ្នកជាប់ពាក់ព័ន្ធនៅមានកម្រិត ដែលទាមទារការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបន្ថែម។ |
| - ពង្រឹងយន្តការសន្សំក្នុងស្រុក រួមមាន ការអភិវឌ្ឍ និងការកែទម្រង់មូលនិធិសោធន និងវិស័យ | មធ្យម ទៅ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷<br>**១- វិស័យធានារ៉ាប់រង÷** | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| ធានារ៉ាប់រង ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ | វែង | ▪ បានប្រជុំពិគ្រោះយោបល់ និងប្រមូលធាតុចូលជាមួយវិស័យឯកជន និងអង្គភាពពាក់ព័ន្ធ<br>▪ បានទទួលការបណ្តុះបណ្តាល និងបានចុះត្រួតពិនិត្យជាក់ស្តែងផ្អែកលើហានិភ័យលើស្ថានភាពអាជីវកម្ម និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រង<br>▪ បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីការកំណត់ដើមទុន និងស្តង់ដារសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង<br>▪ បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីការវិនិយោគ សម្រាប់ក្រុមហ៊ុន ធានារ៉ាប់រង<br>▪ បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីការធានារ៉ាប់រងបន្ត<br>▪ បាន និងកំពុងសិក្សាពីការអនុវត្តក្នុងតំបន់ និងប្រមូលធាតុចូល<br>▪ កំពុងសិក្សារៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រងយានយន្តជាកាតព្វកិច្ច<br>▪ បានប្រជុំពិគ្រោះយោបល់សាធារណៈជាមួយគ្រឹះស្ថានធានារ៉ាប់រងលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រង<br>▪ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រងខ្នាតតូច<br>▪ បានពិនិត្យ និងរៀបចំសេចក្តីព្រាងប្រកាសស្តីពី ការផ្តល់ អាជ្ញាបណ្ណជូនភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង<br>▪ បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការទទួលពាក្យបណ្តឹង និងនីតិវិធីនៃការផ្សះផ្សាវិវាទធានារ៉ាប់រង<br>▪ បានរៀបចំសេចក្តីព្រាងប្រកាសអភិបាលកិច្ចគ្រឹះស្ថានធានារ៉ាប់រង<br>▪ បានរៀបចំសេចក្តីព្រាងប្រកាសលតាប័ត្រធានារ៉ាប់រងយានយន្ត។ | ▪ ធនធានមនុស្សនៅមានកម្រិត ដូច្នេះត្រូវការការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសបន្ថែម ដើម្បីរៀបចំយុទ្ធសាស្ត្រ<br>▪ ទាមទារពេលវេលាច្រើន ដើម្បីសិក្សា ស្រាវជ្រាវ និងរៀបចំ<br>▪ ពុំទាន់មានលទ្ធភាពបង្កើតសមាគមធានារ៉ាប់រងដោយសារទីផ្សារតូច<br>▪ ទាមទារពេលវេលាច្រើនដើម្បីសិក្សា ស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម និងច្បាប់ស្តីពីរបបសោធនឯកជនស្ម័គ្រចិត្ត។<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ សំណូមពរឱ្យជំរុញការអនុម័តច្បាប់ស្តីពីរបបសន្តិសុខសង្គមឱ្យបានឆាប់រហ័ស។ |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | ២. វិស័យសោធន÷<br>▪ បានចូលរួមផ្តល់ធាតុចូលក្នុងការពិភាក្សាលើសេចក្តីសម្រេចលើសេចក្តីព្រាងអនុក្រឹត្យស្តីពី “ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការប្រតិបត្តិ” និងសេចក្តីសម្រេចស្តីពី “ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន” នៃក្រុមប្រឹក្សាជាតិគាំពារសង្គម<br>▪ ចូលរួមផ្តល់ធាតុចូលក្នុងសេចក្តីព្រាងគោលនយោបាយជាតិស្តីពីមនុស្សចាស់<br>▪ បានរៀបចំច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម<br>▪ រៀបចំបង្កើតរចនាសម្ព័ន្ធដឹកនាំ និងដាក់ឱ្យដំណើរការក្រុមប្រឹក្សាជាតិគាំពារសង្គម<br>▪ បានបញ្ចប់ការរៀបចំសេចក្តីព្រាងបឋមនៃច្បាប់ស្តីពីរបបសោធនឯកជនស្ម័គ្រចិត្តត្រឹមកម្រិតការិយាល័យ។<br>- ក្រសួងផែនការ÷<br>▪ បានរៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (ក.វ.ស ៣ឆ្នាំរំកិល) ២០១៨-២០២០ ដែលរៀបចំឡើងដោយអនុវត្តតាមនីតិវិធីថ្មី និងតាមអនឡាញ។ ការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំ-រំកិលនេះ គឺជាការបន្តការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីសុខុដុមនីយកម្មការងារផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ ដែលជាគោលដៅនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងការកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជា។ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ<br>(បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានបន្តរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៩-២០២១ ដែលកាន់តែមានភាពប្រសើរឡើង និងងាយស្រួលបន្ទាប់ពីធ្វើការកែលម្អ និងលើកកម្ពស់ដោយសហការយ៉ាងជិតស្និតជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា។<br>▪ បានធ្វើការបន្សុំគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ទៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ក្នុងការអនុវត្ត និងងាយស្រួលសម្រាប់ក្រសួងនិងស្ថាប័នធ្វើការបន្សុំផែនការអភិវឌ្ឍន៍វិស័យរបស់ខ្លួន។<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា÷<br>▪ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកែប្រែ និងការដំឡើងរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ដោយដំឡើងជា ៤ កម្រិត គឺ÷<br>- **កម្រិតទី១**÷ របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នទាបជាង ឬស្មើ ៤៦០.០០០ រៀល (សែសិបប្រាំមួយម៉ឺនរៀល) ត្រូវបន្ថែមឱ្យដល់ ៤៨០.០០០ រៀល (សែសិបប្រាំបីម៉ឺនរៀល) ក្នុងមួយខែ<br>- **កម្រិតទី២**÷ របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី ៤៦០.០០១ (សែសិបប្រាំមួយម៉ឺនរៀល) ដល់ ៨០០.០០០ (ប៉ែតសិបម៉ឺនរៀល) ត្រូវផ្តល់ជូនបន្ថែមចំនួន ២០.០០០ (ពីរម៉ឺនរៀល) ក្នុងមួយខែ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | - **កម្រិតទី៣÷** របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី ៨០០.០០១ រៀល (ប៉ែតសិបម៉ឺនមួយរៀល) ដល់ ៨១០.០០០ រៀល (ប៉ែតសិបមួយម៉ឺនរៀល) ត្រូវបន្ថែមឱ្យដល់ត្រឹម ៨២០.០០០ រៀល (ប៉ែតសិបពីរម៉ឺនរៀល) ក្នុងមួយខែ<br>- **កម្រិតទី៤÷** របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នចាប់ពី ៨១០.០០១រៀល (ប៉ែតសិបមួយម៉ឺនមួយរៀល) ឡើងទៅ ត្រូវផ្តល់ជូនបន្ថែម ១០.០០០រៀល (មួយម៉ឺនរៀល) ក្នុងមួយខែ<br>▪ បានចេញប្រកាសដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ និងឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គម ចំនួន ៤.៥៥០នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន ៤.៥១៦នាក់ និងផ្ទេរការគ្រប់គ្រងទៅតាមរាជធានីខេត្ត<br>▪ បានចេញប្រកាសលុបសព និវត្តិជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈសរុប ១.២៧៦នាក់ និងឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកចំនួន ៧២៧នាក់<br>▪ លុបសពមន្ត្រីរាជការស៊ីវិល ៣១នាក់<br>▪ បានលុបអ្នកនៅក្នុងបន្ទុកចេញពីបញ្ជីបើកប្រាក់ប្រចាំខែ៦៤នាក់<br>▪ បានកែសម្រួលកាំប្រាក់សោធនជូនសិទ្ធិវន្ត ៩១នាក់ និងផ្លាស់ប្តូរកាំប្រាក់ជូនមន្ត្រី រាជការស៊ីវិលឱ្យចូលនិវត្តន៍ ៥៩៧នាក់ និងអ្នកនៅក្នុងបន្ទុក ៦៧៩នាក់<br>▪ បើកផ្តល់ប្រាក់នៅសល់ក្នុងគណនីជូនគ្រួសារសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈ ១.៨៧២នាក់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បើកផ្តល់ប្រាក់របបសន្តិសុខសង្គមជូនគ្រួសារសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈ១.២៩២នាក់<br>▪ បើកផ្តល់ប្រាក់របបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកសពនិវត្តជន សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងសពមន្ត្រីរាជការស៊ីវិលចំនួន ៥.១៩៨នាក់<br>▪ បើកប្រាក់រំលឹកជូននិវត្តជន ៣.០៨៨នាក់<br>▪ ទទួលអតីតយុទ្ធជនដែលផ្ទេរពីក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃចំនួន ៣.៣២៧នាក់<br>▪ បានផ្ទេរសិទ្ធិជូនសិទ្ធិវន្តដែលមានជំងឺស្នើសុំផ្ទេរសិទ្ធិចំនួន ៣.២០៥នាក់<br>▪ បានផ្ទេរសិទ្ធិបើកប្រាក់ជូនគ្រួសារអតីតយុទ្ធជនចំនួន ២.៤៧១នាក់<br>▪ បញ្ចូលបន្ទុកអតីតយុទ្ធជន ១៨៤នាក់<br>▪ ផ្ទេរអតីតយុទ្ធជនតាមមន្ទីរ ស.អ.យ រាជធានី-ខេត្តចំនួន ២១២នាក់<br>▪ ផ្តល់ប្រាក់បូជាសព មួយលើកដំបូង និងប្រាក់ធានារ៉ាប់រងសង្គម ១.៦៨៧នាក់<br>▪ លុបបន្ទុកអតីតយុទ្ធជន ៤៩៣នាក់ កែសម្រួលប្រាក់គោលនយោបាយ៥.៩៦៤នាក់ ប្តូរអ្នកកាន់សៀវភៅ ៧៧នាក់<br>▪ ផ្តល់ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនជនពិការចំនួន ១.១៨៥នាក់<br>▪ ទទួលស្គាល់ និងផ្តល់របបគោលនយោបាយឡើងវិញ០៦នាក់<br>▪ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១៨ ស្តីពីការបន្ថែមរបបសន្តិសុខសង្គម | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | សម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ដោយបានដំឡើង ជា ៤កម្រិត រួមមាន÷<br>- កម្រិត១÷ របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នទាបជាង ឬស្មើ ៤៦០.០០០(សែសិបប្រាំមួយម៉ឺនរៀល) ត្រូវបន្ថែមឱ្យមកត្រឹម៤៨០.០០០(សែសិបប្រាំបីម៉ឺនរៀល) ក្នុងមួយខែ<br>- កម្រិត២÷ របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី៤៦០.០០១ (សែសិបប្រាំមួយម៉ឺនមួយរៀល) ដល់ត្រឹម ៨០០.០០០(ប៉ែតសិបម៉ឺនរៀល) ត្រូវផ្តល់ជូនបន្ថែមចំនួន ២០.០០០(ពីរម៉ឺនរៀល) ក្នុងមួយខែ<br>- កម្រិត៣÷ របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី៨០០.០០១ (ប៉ែតសិបម៉ឺនមួយរៀល) ដល់ត្រឹម ៨១០.០០០(ប៉ែតសិបមួយម៉ឺនរៀល) ត្រូវបន្ថែមឱ្យដល់ត្រឹម ៨២០.០០០ (ប៉ែតសិបពីរម៉ឺនរៀល) ក្នុងមួយខែ<br>- កម្រិត៤÷ របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នចាប់ពី ៨១០០០១(ប៉ែតសិបមួយម៉ឺនមួយរៀល) ឡើងទៅផ្តល់ជូនបន្ថែម១០.០០០(មួយម៉ឺនរៀល) ក្នុងមួយខែ<br>▪ បានចេញប្រកាសដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ និងឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គមចំនួន៣.៤១៣នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន ៣.០៤៧នាក់ និងផ្ទេរការគ្រប់គ្រងទៅតាមរាជធានីខេត្ត | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានចេញប្រកាសលុបសពនិវត្តិជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈសរុប១.៣១៨នាក់ និងឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកចំនួន ៨៥២នាក់<br>▪ លុបសពមន្ត្រីរាជការស៊ីវិល ១៩នាក់<br>▪ បានលុបអ្នកនៅក្នុងបន្ទុកចេញពីបញ្ជីបើកប្រាក់ប្រចាំខែ១២១នាក់<br>▪ បានកែសម្រួលកាំប្រាក់សោធនជូនសិទ្ធិវន្ត ១៣៣នាក់ និងលុបនិវត្តជន ១០នាក់<br>▪ បានបើកប្រាក់សោធនជូនជនបាត់បង់សម្បទាវិជ្ជាជីវៈឡើងវិញ ០១នាក់<br>▪ បានបើកផ្តល់ប្រាក់នៅសល់ក្នុងគណនីជូនគ្រួសារសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈ ៦៥៧នាក់<br>▪ បើកផ្តល់ប្រាក់របបសន្តិសុខសង្គមជូនគ្រួសារសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈ ១.១៨០នាក់<br>▪ បើកផ្តល់ប្រាក់របបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកសពនិវត្ត-ជន សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងសពមន្ត្រីរាជការស៊ីវិលចំនួន ៦.០២៦នាក់<br>▪ បានចុះពិនិត្យស្ថានភាពនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលមានជំងឺសុំផ្ទេរសិទ្ធិចំនួន ១១៥នាក់<br>▪ បានបើកប្រាក់រំលឹកជូននិវត្តជន ៣.១៤៥នាក់<br>▪ ទទួលអតីតយុទ្ធជនដែលផ្ទេរពីក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ២.៩៨៦នាក់ ក្នុងនោះក្រសួងមហាផ្ទៃ ៩១០នាក់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានផ្ទេរសិទ្ធិជូនសិទ្ធិវន្តដែលមានជីវិតស្នើសុំផ្ទេរសិទ្ធិចំនួន ១.៤៤៤នាក់<br>▪ បានផ្ទេរសិទ្ធិបើកប្រាក់ជូនគ្រួសារអតីតយុទ្ធជនចំនួន១.៤៥១នាក់<br>▪ បញ្ចូលបន្ទុកអតីតយុទ្ធជន ១៨៧នាក់<br>▪ ផ្ទេរអតីតយុទ្ធជនតាមមន្ទីរស.អ.យ រាជធានី-ខេត្តចំនួន២០០នាក់<br>▪ បានផ្តល់ប្រាក់បូជាសពមួយលើកដំបូង និងប្រាក់ធានារ៉ាប់រងសង្គម ១.០៦១នាក់<br>▪ បានលុបបន្ទុកអតីតយុទ្ធជន ២.០៦៧នាក់ ប្តូរអ្នកកាន់សៀវភៅ ៣០នាក់<br>▪ បានទទួលស្គាល់ និងផ្តល់របបគោលនយោបាយឡើងវិញ ១២នាក់<br>▪ បានកែសម្រួលប្រាក់របបឧបត្ថម្ភ ៥១នាក់<br>▪ បានផ្តល់របបសន្តិសុខសង្គមជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ៥៤.២៩៣នាក់<br>▪ បានបើកប្រាក់នៅសល់ក្នុងគណនីជូនគ្រួសារសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈ ៦៩នាក់<br>▪ បានផ្តល់ប្រាក់របបសន្តិសុខសង្គមជូនគ្រួសារសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈ ១៥៨នាក់<br>▪ បានផ្តល់ប្រាក់របបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកសពនិវត្ត-ជន, សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងសពមន្ត្រីរាជការស៊ីវិលចំនួន ៦.០២៦នាក់<br>▪ បានបើកប្រាក់វិលឹកជូននិវត្តជន ១.០២៧នាក់ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានផ្ទេរសិទ្ធិជូនសិទ្ធិវន្តដែលមានជម្ងឺស្នើសុំផ្ទេរសិទ្ធិចំនួន ២៣៤ នាក់<br>▪ បានផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារចំនួន ៨៦.៨៨០នាក់<br>▪ បានផ្ទេរសិទ្ធិបើកប្រាក់ជូនគ្រួសារយុទ្ធជនចំនួន ៥០៤នាក់<br>▪ បានបញ្ចូលបន្ទុកអតីតយុទ្ធជន ៤៥នាក់<br>▪ បានផ្តល់ប្រាក់បូជាសពមួយលើកដំបូង និងប្រាក់ធានារ៉ាប់រងសង្គម ២៩៧នាក់<br>▪ បានផ្តល់ប្រាក់វិលទៅមូលដ្ឋានមួយលើកដំបូងដល់ជនពិការ ២១នាក់។<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷<br>▪ បានបន្តពង្រីក និងអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គម សំដៅផ្តល់ការធានាសុខុមាលភាព និងកាត់បន្ថយបន្ទុកចំណាយរបស់កម្មករនិយោជិត ក៏ដូចជាកៀរគរប្រភពធនធានក្នុងស្រុកកាន់តែកើនឡើងដើម្បីចូលរួមជាប្រភពមូលធនហិរញ្ញវត្ថុបន្ថែមសម្រាប់គាំទ្រការវិនិយោគផ្សេងៗ ដែលនឹងបម្រើដល់ផលប្រយោជន៍របស់កម្មករនិយោជិត<br>▪ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលមានវិសាលភាពកាន់តែទូលំទូលាយ ធានាសង្គតិភាព និងសមធម៌រវាងមន្ត្រីរាជការសាធារណៈ និងកម្មករនិយោជិត។ | |
| - ផ្តល់អាទិភាពខ្ពស់នៅក្នុងកម្មវិធីវិនិយោគសាធារណៈ សម្រាប់សកម្មភាពគម្រោងនិងកម្ម | មធ្យម ទៅ | - ក្រសួងផែនការ÷ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| វិធីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម កនៀ្រងឧស្សាហកម្ម ឬរបៀងឧស្សាហកម្ម។ | វែង | ▪ បានរៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៨-២០២០ (ក.វ.ស ៣ ឆ្នាំរំកិល) ដែលរៀបចំឡើងដោយអនុវត្តតាមនីតិវិធីថ្មី និងតាមអនឡាញ។ ការរៀបចំ ក.វ.ស ៣ ឆ្នាំរំកិលនេះគឺជាការបន្តការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីសុខដុមនីយកម្ម, ការងារផែនការ, ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ ដែលជាគោលដៅនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងការកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជា។<br>▪ បានបន្តរៀបចំសេចក្តីព្រាង ក.វ.ស បីឆ្នាំរំកិល ២០១៩-២០២១ ដែលកាន់តែមានភាពប្រសើរឡើង និងងាយស្រួលបន្ទាប់ពីធ្វើការកែលម្អ និងលើកកម្ពស់ ដោយសហការយ៉ាងជិតស្និតជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា។<br>▪ នឹងធ្វើការបញ្ចូលគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៩-២០២៣ ក្នុងការអនុវត្ត និងងាយស្រួលសម្រាប់ក្រសួង និងស្ថាប័នធ្វើការបញ្ចូលផែនការអភិវឌ្ឍន៍វិស័យរបស់ខ្លួន។<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចូលរួមធ្វើអាទិភាវូបនីយកម្មកម្មវិធីវិនិយោគ។<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷<br>ការងារក្នុងឆ្នាំ២០១៧-២០១៨ | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ▪ បានតាមដានជាប្រចាំអំពីការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍នីមួយៗគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។<br>▪ បានរៀបចំរបាយការណ៍វិភាគស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជាឆ្នាំ២០១៨ ដោយបានវិភាគអំពីការវិវត្តនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការគាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។ ជារួមហិរញ្ញប្បទានសរុបប្រមាណ ៦៥១,៥ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៥-២០១៨ ត្រូវបានប្រើប្រាស់សម្រាប់គាំទ្រការអនុវត្តវិធានការគន្លឹះបួនជាក់ស្តែង ក៏ដូចជាវិធានការគោលនយោបាយ និងផែនការសកម្មភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥។ ក្នុងឆ្នាំ២០១៧ ដៃគូអភិវឌ្ឍន៍បានបើកផ្តល់ហិរញ្ញប្បទានសរុបប្រមាណ ២២១,៨ លានដុល្លារ។ ដោយឡែក ក្នុងឆ្នាំ២០១៨ ដៃគូអភិវឌ្ឍន៍បានបើកផ្តល់ហិរញ្ញប្បទានសរុបប្រមាណ ១៥៦,៧ លានដុល្លារ ដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ពោលគឺកើនឡើង ៥៧% ធៀបនឹងឆ្នាំ២០១៥ ដែលមានត្រឹម ៨៨,៨ លានដុល្លារ ហើយក្នុងឆ្នាំ២០១៩ អាចកើនឡើងដល់ ២០៩ លានដុល្លារ ពោលគឺកើនជិត ៣ដង ធៀបនឹងឆ្នាំ២០១៥។ ក្នុងឆ្នាំ២០១៧-២០១៨ វិធានការគន្លឹះបួនជាក់ស្តែង ទទួលបានការគាំទ្រច្រើនជាងវិធានការដទៃក្នុងទំហំប្រមាណ ២៧១,៥ លានដុល្លារ សមមូលនឹង៧២% នៃហិរញ្ញប្បទានសរុប និងបន្ទាប់គឺវិធានការស្តីពីការសម្របសម្រួល | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
| --- | --- | --- | --- |
| | | គោលនយោបាយគាំទ្រ ១៦%, វិធានការកែលម្អបរិស្ថាននិយ័តកម្ម ៩%, វិធានការពង្រីកសហគ្រាសធុនតូចនិងមធ្យម ២% និង វិធានការជំរុញការទាក់ទាញវិនិយោគ ១%។ ក្នុងចន្លោះឆ្នាំ ២០១៧-២០១៨ ដៃគូអភិវឌ្ឍន៍សំខាន់ៗដែលបានផ្តល់ការគាំទ្ររួមមាន÷ សាធារណរដ្ឋប្រជាមានិតចិន, ធនាគារអភិវឌ្ឍន៍អាស៊ី, ជប៉ុន, បារាំង និងអូស្ត្រាលី។ ក្រៅពីការគាំទ្រផ្ទាល់លើវិធានការគោលនយោបាយ និងវិធានការគន្លឹះ ដៃគូអភិវឌ្ឍន៍ជាច្រើនក៏បានបញ្ជ្រាបគោលនយោបាយនេះទៅក្នុងគម្រោងអភិវឌ្ឍន៍របស់ខ្លួន។ ជាក់ស្តែង ដៃគូអភិវឌ្ឍន៍បានបញ្ជ្រាបការអភិវឌ្ឍវិស័យឧស្សាហកម្មទៅក្នុងបណ្តាគម្រោងរបស់ខ្លួនដែលមានទំហំហិរញ្ញប្បទាន ប្រមាណ ១៦៨ លានដុល្លារ ស្មើនឹង ៨,៩% ក្នុងឆ្នាំ២០១៧ និង ប្រមាណ ១៦០ លានដុល្លារ ស្មើនឹង ៨,៤% ក្នុងឆ្នាំ២០១៨ នៃហិរញ្ញប្បទានសរុប។ ដៃគូអភិវឌ្ឍន៍សំខាន់ៗដែលគាំទ្រចំនួន ៣ រួមមាន÷ សាធារណរដ្ឋប្រជាមានិតចិន ៨៧,៦ លានដុល្លារ, ជប៉ុន ៣៩,៦ លានដុល្លារ និងធនាគារអភិវឌ្ឍន៍អាស៊ី ១៤,៥ លានដុល្លារ។ ផ្អែកលើសារៈសំខាន់នៃការលើកកម្ពស់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា បានបង្ហាញថា វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា ទទួលបានហិរញ្ញប្បទានសរុប ៨៧ លានដុល្លារ ក្នុងចន្លោះឆ្នាំ ២០១៥-២០១៧ ពោលគឺប្រមាណ ៣០ លានដុល្លារក្នុងមួយឆ្នាំ។ ក្នុងឆ្នាំ២០១៨ ការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍គាំទ្រដល់វិស័យនេះ មាន | |

| វិធានការគោលនយោបាយ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | ប្រមាណ ៣១,៨ លានដុល្លារ។ ក្នុងចំណោមដៃគូអភិវឌ្ឍន៍ចំនួន ១៣ ដែលបានគាំទ្រដល់វិស័យនេះ, ធនាគារអភិវឌ្ឍន៍អាស៊ី, អូស្ត្រាលី, ជប៉ុន, ណូវែលហ្សេឡង់ និងស្វីស បានផ្តល់ហិរញ្ញប្បទានច្រើនជាងគេសរុបប្រមាណ ២៦,៦ លានដុល្លារ ស្មើនឹង ៨៤% នៃទំហំហិរញ្ញប្បទានសរុបគាំទ្រដល់វិស័យនេះ ក្នុងឆ្នាំ២០១៨។<br>▪ បានបញ្ចូលសកម្មភាពដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មទៅក្នុងផែនការសកម្មភាពដែលត្រូវមានសង្គតិភាពជាមួយក្របខណ្ឌយុទ្ធសាស្ត្រស្តីពីកិច្ច-សហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ សម្រាប់ពង្រឹងភាពជាដៃគូ ការតម្រឹម និងការគ្រប់គ្រងដោយផ្តោតលើលទ្ធផល។ យុទ្ធសាស្ត្រនេះ បានកំណត់នូវគោលការណ៍, យន្ត-ការពិគ្រោះយោបល់ និងឧបករណ៍ ដើម្បីលើកកម្ពស់ស័ក្តិសិទ្ធិភាព, តម្លាភាព និងគណនេយ្យភាព ព្រមទាំងជាក្របខណ្ឌកៀរគរ និងតម្រង់ទិសការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ជំរុញកិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយា-ប័ន្ន។<br>▪ បានដាក់ចេញ និងអនុវត្តនូវគោលការណ៍បន្ថែមមួយចំនួនដើម្បីពង្រីកវិសាលភាពនៃភាពជាដៃគូ រួមមាន÷ កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន និងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង។ ក្នុងស្មារតីនេះ គ.ជ.នា/ក.អ.ក បានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល ដើម្បីបន្តដឹកនាំការសម្រប-សម្រួល និងកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ | |

| វិធានការគោលនយោបាយ/ផែនការ សកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព | ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ) |
|---|---|---|---|
| | | សម្រាប់រួមចំណែកគាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។<br>▪ ដើម្បីបន្តរួមចំណែកគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា គ.ជ.ឧ/ក.អ.ក នឹងបន្តអនុវត្តការងារអាទិភាព រួមមាន ÷ ១) ដឹកនាំកិច្ចពិគ្រោះយោបល់ទ្វេភាគី និងពហុភាគីជាមួយដៃគូអភិវឌ្ឍន៍ និងយន្តការភាពជាដៃគូដទៃទៀត ដើម្បីតម្រឹមការគាំទ្រជាមួយអាទិភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា, ២) សម្របសម្រួលការអនុវត្តសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលស្តីពីយន្តការពិគ្រោះយោបល់ និងឧបករណ៍នៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ដើម្បីលើកកម្ពស់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍, និង ៣) តាមដានលំហូរហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ដែលបានគាំទ្រវិស័យអាទិភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា តាមរយៈការធ្វើបច្ចុប្បន្នភាព និងសុពលភាពទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ និងរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា។ | |